# សេចក្តីពន្យល់នៃ
# ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

## សេចក្តីពន្យល់ស្តីពីករណីយុត្តិសាស្ត្រ អ.វ.ត.ក

## និង

## អន្តរជាតិសម្រាំង

*បោះពុម្ពផ្សាយលើកទី ២ នៅខែ ធ្នូ ឆ្នាំ២០១៥*

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

RAOUL
WALLENBERG
INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

# សេចក្តីពន្យល់នៃ
# ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

## សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រអ.វ.ត.ក
## និង អន្តរជាតិសម្រាំង

*បោះពុម្ពផ្សាយលើកទី២ នៅខែធ្នូ ឆ្នាំ២០១៥*

*ឯកសារយោងទាំងឡាយ ដែលមាននៅក្នុងសេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អាចទាញយកមកប្រើប្រាស់បានតាមរយៈអ៊ិនធើណេត៖*

*http://cambodia.ohchr.org*

សៀវភៅនេះ**មិនមែនសម្រាប់លក់ទេ** ហើយអាចទាញយកមកប្រើប្រាស់បានដោយសេរី តាមរយៈគេហទំព័រខាងលើ

**ការមិនទទួលខុសត្រូវ៖** ការបោះពុម្ពផ្សាយនេះ អាចដំណើរទៅបានអាស្រ័យដោយមានការគាំទ្រពីវិទ្យាស្ថានរ៉ាអុល វ៉ាលេនបឺក (**RWI**) ប្រចាំនៅរាជធានីភ្នំពេញ ទីភ្នាក់ងារប្រទេសស្វីសសម្រាប់ការអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC) និង ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR-Cambodia)។ មាតិកាទាំងឡាយ មិនចាំបាច់ឆ្លុះបញ្ចាំងនូវមតិរបស់វិទ្យាស្ថានរ៉ាអុល វ៉ាលេនបឺក (**RWI**) ប្រចាំនៅរាជធានីភ្នំពេញ រាជរដ្ឋាភិបាលប្រទេសស៊ុយអ៊ែត ទីភ្នាក់ងារប្រទេសស្វីសសម្រាប់ការអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC) ការិយាល័យ OHCHR-Cambodia ឬក៏អង្គការសហប្រជាជាតិទេ។

*សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖*
*សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក និងអន្តរជាតិសម្រាំង*
ការបោះពុម្ពផ្សាយលើកទី២ នៅខែធ្នូ ឆ្នាំ២០១៥

# តារាងមាតិកា

**តារាងមាតិកា** ........ i
**បុព្វកថា** ........ v
**សេចក្តីផ្តើម** ........ vii
**វិធានទូទៅ និងវិធានពាក់ព័ន្ធនឹងដំណាក់កាលមុនការជំនុំជម្រះ** ........ 1
មាត្រា ២៖ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ........ 4
មាត្រា ៧៖ ការរលត់នៃបណ្តឹងអាជ្ញា ........ 6
មាត្រា ១២៖ អាជ្ញាអស់ជំនុំ ........ 10
មាត្រា ១៣៖ បណ្តឹងរដ្ឋប្បវេណី និងព្យសនកម្ម ........ 16
មាត្រា ១៦៖ បណ្តឹងរដ្ឋប្បវេណីរបស់សិទ្ធិវន្តនៃជនរងគ្រោះ ........ 21
មាត្រា ៨៤៖ ការបើកការស៊ើបសួរ ........ 23
មាត្រា ៩៣៖ កំណត់ហេតុលើការស្តាប់ចម្លើយ ........ 25
មាត្រា ៩៦៖ ការឃាត់ខ្លួន ........ 29
មាត្រា ១២១៖ ការសម្ងាត់នៃការស៊ើបសួរ ........ 36
មាត្រា ១២៤៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ 39
មាត្រា ១២៥៖ វិសាលភាពនៃការប្តឹង ........ 42
មាត្រា ១២៦៖ ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ ........ 46
មាត្រា ១២៧៖ ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក ........ 48
មាត្រា ១២៩៖ មុខងាររបស់ក្រឡាបញ្ជី ........ 52
មាត្រា ១៣២៖ ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា ........ 55
មាត្រា ១៣៣៖ ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ ........ 60
មាត្រា ១៣៤៖ ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី ........ 65
មាត្រា ១៣៧៖ ការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ........ 69
មាត្រា ១៣៨៖ បណ្តឹងដោយមានការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ 74
មាត្រា ១៣៩៖ ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា ........ 78

មាត្រា ១៤៣៖ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ........ 81
មាត្រា ១៤៥៖ វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ ........ 86
មាត្រា ១៥០៖ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ........ 91
មាត្រា ១៥៤៖ សម្បថរបស់សាក្សី ........ 93
មាត្រា ១៥៦៖ សាក្សីដែលអនុញ្ញាតឲ្យរួចពីសម្បថ ........ 95
មាត្រា ១៥៧៖ ភាពគ្មានលទ្ធភាពស្តាប់ចម្លើយរបស់សាក្សីមួយចំនួន ........ 97
មាត្រា ១៦២៖ ភាពចាំបាច់នៃការធ្វើកោសលវិច័យ ........ 100
មាត្រា ១៦៥៖ ដីកាចាត់តាំងអ្នកជំនាញ ........ 104
មាត្រា ១៦៩៖ ការចាត់តាំងអ្នកជំនាញច្រើនរូប ........ 108
មាត្រា ១៧០៖ ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ ........ 111
មាត្រា ១៩៧៖ ដីកាបង្គាប់ឲ្យចាប់ខ្លួន និងយោបល់របស់ព្រះរាជអាជ្ញា ........ 115
មាត្រា ១៩៨៖ និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឲ្យចាប់ខ្លួន ........ 117
មាត្រា ២០៣៖ គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន ........ 121
មាត្រា ២០៥៖ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ........ 130
មាត្រា ២០៦៖ កំណត់សម្គាល់របស់ជនត្រូវចោទ និងការប្រាប់ហេតុផលនៃដីកា ........ 143
មាត្រា ២១០៖ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាអាទិ៍ ........ 151
មាត្រា ២១១៖ ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ........ 155
មាត្រា ២១៧៖ ការដោះលែងឲ្យនៅក្រៅឃុំតាមបណ្តឹងរបស់ជនត្រូវចោទ ........ 161
មាត្រា ២២៣៖ កាតព្វកិច្ចក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........ 166
មាត្រា ២៤៦៖ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ........ 171
មាត្រា ២៤៧៖ ដីកាដំណោះស្រាយ ........ 173
មាត្រា ២៤៩៖ សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ ........ 178
មាត្រា ២៥០៖ ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ........ 183
មាត្រា ២៥២៖ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ ........ 185
មាត្រា ២៥៣៖ ការប្តឹងទៅសភាស៊ើបសួរ ........ 186
មាត្រា ២៥៧៖ បញ្ជីបណ្តឹងឧទ្ធរណ៍ និងពាក្យសុំ ........ 190
មាត្រា ២៥៩៖ ការពិនិត្យសំណុំរឿង និងសារណា ........ 191
មាត្រា ២៦០៖ ដំណើរការនៃកិច្ចពិភាក្សាដេញដោល ........ 195
មាត្រា ២៦១៖ ការពិនិត្យលើនិយ័តភាពនៃនីតិវិធី ........ 200

មាត្រា ២៦៦៖ បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា ........ 203
មាត្រា ២៦៧៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ចៅក្រមស៊ើបសួរ ដោយជនជាប់ចោទ ........ 207
មាត្រា ២៦៨៖ បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដោយដើមបណ្តឹងរដ្ឋប្បវេណី ... 214
មាត្រា ២៧១៖ សមត្ថកិច្ចរបស់សភាស៊ើបសួរ ........ 221
មាត្រា ២៧៨៖ សាលដីកាដែលសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន ........ 223
មាត្រា ២៧៩៖ ភាពមិនអាចទទួលយកបាននៃពាក្យបណ្តឹងសុំមោឃកម្ម ........ 227
មាត្រា ២៨០៖ អានុភាពនៃមោឃកម្ម ........ 229

**ការជំនុំជម្រះ** ........ 232

មាត្រា ២៨៩៖ សមត្ថកិច្ចរបស់សាលាដំបូង ........ 234
មាត្រា ២៩១៖ របៀបប្តឹងទៅតុលាការ ........ 235
មាត្រា ២៩៧៖ ការកោះហៅសាក្សី ........ 240
មាត្រា ២៩៩៖ ការបញ្ចូលនីតិវិធី ........ 242
មាត្រា ៣០០៖ ការចូលខ្លួនរបស់ជនជាប់ចោទ ........ 244
មាត្រា ៣០៥៖ ការបង្ហាញខ្លួនរបស់ជនជាប់ចោទតាមដីកាបញ្ជូន ឬសាលដីកាបញ្ជូន ........ 246
មាត្រា ៣០៦៖ ការដោះលែងជនជាប់ចោទដែលជាប់ឃុំឲ្យមានសេរីភាពដោយឯកឯង ........ 254
មាត្រា ៣០៧៖ បណ្តឹងសុំដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទ ដែលជាប់ឃុំ ........ 260
មាត្រា ៣១១៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការ ........ 264
មាត្រា ៣១៣៖ ជំនួយ និងការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........ 268
មាត្រា ៣១៥៖ ការចូលបង្ហាញខ្លួនរបស់សាក្សី ........ 270
មាត្រា ៣១៦៖ សាធារណភាពនៃកិច្ចពិភាក្សាដេញដោល និងភាពសម្ងាត់នៃកិច្ចពិភាក្សាដេញដោល ........ 273
មាត្រា ៣១៨៖ ការធានាសណ្តាប់ធ្នាប់នៃសវនាការ ........ 278
មាត្រា ៣២១៖ ការវាយតំលៃលើភស្តុតាងដោយតុលាការ ........ 286
មាត្រា ៣២២៖ វិធានទាក់ទងនឹងភាគីដែលមានវត្តមាននៅក្នុងសវនាការ ........ 298
មាត្រា ៣២៥៖ ការសួរចម្លើយជនជាប់ចោទ ........ 300
មាត្រា ៣២៦៖ ការស្តាប់ចម្លើយរបស់ភាគី ........ 304
មាត្រា ៣៣០៖ ជំនួយ និងសម្បថរបស់អ្នកបកប្រែ ........ 311
មាត្រា ៣៣២៖ ការបង្ហាញវត្ថុតាង ........ 315
មាត្រា ៣៣៩៖ កិច្ចស៊ើបសួរបន្ថែមដែលបង្គាប់ដោយតុលាការ ........ 316
មាត្រា ៣៤២៖ សមត្ថកិច្ចរបស់តុលាការក្នុងរឿងអញ្ញត្រកម្ម ........ 319

មាត្រា ៣៥០៖ ការប្រកាសពីពិរុទ្ធភាព ..... 321
មាត្រា ៣៥៥៖ ការសម្រេចអំពីប្រយោជន៍ផ្នែករដ្ឋប្បវេណី ..... 324

**បណ្តឹងឧទ្ធរណ៍** ..... 328

មាត្រា ៣៧៥៖ បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍ ..... 329
មាត្រា ៣៩៩៖ អានុភាពនៃបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ ..... 335
មាត្រា ៤០១៖ ការកំណត់ប្រភេទគតិយុត្តនៃអង្គហេតុជាថ្មីដោយសាលាឧទ្ធរណ៍ ..... 337
មាត្រា ៤២៩៖ ការពន្យាររយៈពេលនៃការសរសេរសាលក្រម ..... 339
មាត្រា ៤៣៦៖ សេចក្តីសម្រេចលើបញ្ហាគតិយុត្ត ..... 340
មាត្រា ៤៥៣៖ ការសំអាងហេតុចំពោះសាលដីកា ..... 343

**កិច្ចដំណើរការនីតិវិធីពិសេស** ..... 346

មាត្រា ៥០៣៖ ការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ..... 347
មាត្រា ៥០៨៖ ការបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំ ..... 349
មាត្រា ៥៥៦៖ មូលហេតុនៃការប្តឹងជំទាស់ផ្តាច់សេចក្តីទៅក្រុមអាសនៈ ..... 351
មាត្រា ៥៥៧៖ ពាក្យប្តឹងជំទាស់ផ្តាច់សេចក្តីទៅក្រុមអាសនៈ ..... 359
មាត្រា ៥៥៨៖ អ្នកទទួលពាក្យប្តឹងជំទាស់ផ្តាច់សេចក្តីទៅក្រុមអាសនៈ ..... 361
មាត្រា ៥៦១៖ ការពិនិត្យពាក្យប្តឹងជំទាស់ផ្តាច់សេចក្តីទៅក្រុមអាសនៈ ..... 362
មាត្រា ៥៦២៖ សេចក្តីសម្រេចលើពាក្យប្តឹងជំទាស់ផ្តាច់សេចក្តីទៅក្រុមអាសនៈ ..... 365
មាត្រា ៥៦៣៖ កិច្ចដែលត្រូវបានបំពេញមុនពេលជូនដំណឹងអំពីពាក្យប្តឹង ..... 367

**តារាងរឿងក្តី** ..... 369

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ..... 369
គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប ..... 396
តុលាការសិទ្ធិមនុស្សអឺរ៉ុប ..... 406
តុលាការកំពូលបារាំង ..... 416

**តារាងប្រៀបធៀប៖ ក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុងអ.វ.ត.ក** ..... 435

**សេចក្តីថ្លែងអំណរគុណ** ..... 462

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ក្នុងការផ្តល់ជូននូវបុព្វកថា *ចំពោះសេចក្តីពន្យល់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ* ***(សេចក្តីពន្យល់នៃក្រម)*** — ការបោះពុម្ពផ្សាយលើកទី២។ សេចក្តីពន្យល់នៃក្រមនេះ គឺជាការបោះពុម្ពផ្សាយដំបូង នៅក្នុងប្រវត្តិសាស្ត្រថ្មីៗនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពន្យល់អំពីក្រមកម្ពុជា ដែលស្រដៀងគ្នាទៅនឹងករណីយុត្តិសាស្ត្រជាតិ និងអន្តរជាតិ។ ខណៈដែលសេចក្តីពន្យល់នៃក្រមនេះ ជាធនធានមួយថ្មីស្រឡាងសម្រាប់កម្ពុជា នៅលើឆាកអន្តរជាតិ *សេចក្តីពន្យល់នៃក្រមនេះ* ឆ្លុះបញ្ចាំងអំពីទំនៀមទំលាប់ដែលមានតាំងពីយូរមកហើយ ទាំងក្នុងទំនៀមទំលាប់ក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (Common Law) និងក្នុងប្រព័ន្ធច្បាប់ស៊ីវិល (Civil Law) ដើម្បីតាក់តែងជាសេចក្តីពន្យល់នេះឡើង។ តាមពិតទៅ នៅលើពិភពលោក សេចក្តីពន្យល់នៃក្រម ត្រូវបានគេចាត់ទុកថាជាលិខិតុបករណ៍ដ៏មានសារសំខាន់ មិនត្រឹមតែសម្រាប់អ្នកប្រកបវិជ្ជាជីវៈច្បាប់ប៉ុណ្ណោះទេ តែក៏សម្រាប់បុគ្គលណាដែលចាប់អារម្មណ៍ ក្នុងការស្វែងយល់អំពីរបៀបអនុវត្តច្បាប់ក្នុងការអនុវត្តន៍ជាក់ស្តែង។

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដាក់បញ្ចូលដោយផ្ទាល់នូវសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងអស់ទៅក្នុងច្បាប់ជាតិ ដែលប្រទេសកម្ពុជា គឺជាហត្ថលេខី។ *សេចក្តីពន្យល់នៃក្រម* គឺជាការរួមវិភាគទានចំពោះការអនុវត្តលើមាត្រានោះ។ ផ្តើមចេញពីគម្រូនានានៃករណីយុត្តិសាស្ត្រពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គការសហប្រជាជាតិ អឺរ៉ុប និងប្រទេសបារាំង *សេចក្តីពន្យល់នៃក្រម* ផ្តល់ជូននូវគោលការណ៍ណែនាំអំពីរបៀប ដែលមាត្រាទាំងឡាយក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ អាចត្រូវបានបកស្រាយ ក្នុងវិធីដែលអនុវត្តតាមបទដ្ឋានសិទ្ធិមនុស្ស។ ដោយសារតែសារៈសំខាន់នៃសេចក្តីពន្យល់នៃក្រមនេះ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR) បានសម្រេចចិត្តធ្វើបច្ចុប្បន្នភាពសេចក្តីពន្យល់នៃក្រមនេះ ដើម្បីធានាថាយុទ្ធសាស្ត្របច្ចុប្បន្នសំខាន់ៗរបស់ស្ថាប័នទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីពន្យល់នេះ។

ខ្ញុំគ្មានមន្ទិលសង្ស័យទេថា *សេចក្តីពន្យល់នៃក្រម- ការបោះពុម្ពផ្សាយលើកទី២* នេះនឹងបន្តលើកទឹកចិត្តឲ្យមានការផ្លាស់ប្តូរក្នុងការអនុវត្តច្បាប់ជាក់ស្តែងរបស់កម្ពុជា តាមរយៈការលើកសំអាងហេតុផ្លូវ

ច្បាប់កាន់តែប្រសើរឡើង ការប្រើប្រាស់សេចក្តីយោងករណីយុត្តិសាស្រ្តកាន់តែកើនឡើង និងការរៀបរៀងនាពេលអនាគតនៃធនធានស្រដៀងគ្នា សម្រាប់វិស័យច្បាប់ផ្សេងៗ។ ខ្ញុំមានទំនុកចិត្តថា អស់យៈពេលជាច្រើនឆ្នាំមកនេះ លិខិតុបករណ៍ដូចនេះ នឹងធ្វើឲ្យកាន់តែប្រសើរឡើង ដោយមិនអាចគណនាបានក្នុងការបំរើសេវាយុត្តិធម៌នៅប្រទេសកម្ពុជា។

ក្នុងនាមការិយាល័យ OHCHR ខ្ញុំសូមទទួលស្គាល់នូវការគាំទ្រប្រកបដោយសប្បុរសពីស្ថានទូតអង់គ្លេសនៅរាជធានីភ្នំពេញ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ក៏ដូចជាវិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម ដោយគ្មានស្ថាប័នទាំងនេះទេ សេចក្តីពន្យល់នៃក្រមនេះ មិនអាចដំណើរការបានឡើយ។ ខ្ញុំក៏សូមទទួលស្គាល់ផងដែរនូវការគាំទ្ររបស់វិទ្យាស្ថានរ៉ាអុល វ៉ាលេនបឺក (RWI) និងទីភ្នាក់ងារប្រទេសស្វីសសម្រាប់ការអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC) សម្រាប់ការបោះពុម្ពផ្សាយលើកទី២ នៃសេចក្តីពន្យល់នេះអាចដំណើរការទៅបាន។ ជាចុងក្រោយ ខ្ញុំសូមសំដែងនូវការដឹងគុណដល់អង្គការ និងមន្ត្រីទាំងឡាយជាអនេកប្បការ ដែលបានបំពេញការងារដោយគ្មាននឿយហត់ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដើម្បីប្រែក្លាយគំនិតនេះទៅជាការពិត។

ខ្ញុំសូមជំរុញលើកទឹកចិត្តដល់អ្នកប្រកបវិជ្ជាជីវៈច្បាប់កម្ពុជា ប្រើប្រាស់*សេចក្តីពន្យល់នៃក្រមនេះ* ដើម្បីពិភាក្សា និងជជែកដេញដោលអំពីក្រមនេះ ព្រមទាំងបញ្ចូលទស្សនទានដ៏មានប្រយោជន៍ ដែលក្រមនេះផ្តល់ជូនទៅក្នុងការលើកទឡ្ហីករណ៍របស់អស់លោក-លោកស្រី។ លោក-លោកស្រី នឹងស្វែងយល់ថា ក្នុងការអនុវត្តតាមដូច្នេះ លោក-លោកស្រី នឹងប្រណាំងប្រជែងជាមួយនឹងដៃគូរបស់លោក-លោកស្រីឲ្យធ្វើតាមដូចគ្នា។ នៅទីបំផុត លោក-លោកស្រី នឹងរួមចំណែកជួយគ្រប់ផ្នែកនៃប្រព័ន្ធយុត្តិធម៌ ដើម្បីយល់ដឹងកាន់តែប្រសើរ និងអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការការពារសិទ្ធិមនុស្ស។



**វ៉ាន់-ហ៊ី លី**

**តំណាង**

**ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

# សេចក្តីផ្តើម

ជាទូទៅ ទាំងក្នុងប្រព័ន្ធច្បាប់ស៊ីវិល (**Civil Law**) និងច្បាប់អង់គ្លូសាក់សុង (**Common Law**) គេតែងតែឃើញមានការបោះពុម្ពផ្សាយ ដែលពន្យល់បង្ហាញពីក្រម ឬច្បាប់ទាំងឡាយដែលមានយុត្តិសាស្ត្ររបស់តុលាការ និងសាលាក្តីដែលអនុវត្តក្រម និងច្បាប់ទាំងនោះ។ ដោយសារតែក្រម និងច្បាប់ទាំងឡាយ ត្រូវបានរៀបចំតាក់តែងពីគោលការណ៍ទូទៅក្នុងកម្រិតខ្ពស់ ករណីយុត្តិសាស្ត្រអាចជាឯកសារយោងដែលមានប្រយោជន៍ដល់ការអនុវត្តក្រម និងច្បាប់ទាំងនោះ ដោយសារយុត្តិសាស្ត្រ អាចផ្តល់ទស្សនៈស៊ីជម្រៅអំពីរបៀបនៃការបកស្រាយ និងអនុវត្តក្រម និងច្បាប់ទាំងនោះនៅក្នុងស្ថានភាពខុសៗគ្នា។

*សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា* គឺយកលំនាំតាមទំនៀមទម្លាប់ នៃកំណត់ពន្យល់អំពីក្រមនៅទូទាំងពិភពលោក។ សៀវភៅនេះ ពន្យល់បង្ហាញពីមាត្រាទាំងឡាយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលទើបតែត្រូវបានអនុម័តនាពេលថ្មីៗ (ហៅកាត់ថា **ក្រម**) ដោយមានយុត្តិសាស្ត្រដែលពាក់ព័ន្ធ ជាពិសេសរាប់បញ្ចូលទាំងករណីយុត្តិសាស្ត្រ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា **អ.វ.ត.ក**)។ ករណីយុត្តិសាស្ត្រនៃ អ.វ.ត.ក មានការពាក់ព័ន្ធដោយសារបទប្បញ្ញត្តិមួយចំនួនធំនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក បានយកលំនាំតាមក្រមនីតិវិធីនេះ ហេតុដូច្នេះហើយសេចក្តីសម្រេចទាំងឡាយរបស់ អ.វ.ត.ក ដែលទាក់ទងទៅនឹងនីតិវិធី តែងតែពាក់ព័ន្ធទៅនឹងមាត្រានានានៅក្នុងក្រមនីតិវិធី។

*សេចក្តីពន្យល់នៃក្រមនេះ* បានពិចារណាទៅលើសេចក្តីសម្រេចពាក់ព័ន្ធទាំងអស់ ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នៅក្នុងសំណុំរឿង០០១ (ប្រឆាំងនឹងកាំង ហ្កេច អ៊ាវ ហៅឌុច) រហូតទៅដល់ និងរួមទាំងសាលដីកាឧទ្ធរណ៍ ព្រមទាំងសេចក្តីសម្រេចពាក់ព័ន្ធទាំងអស់មុនអង្គសេចក្តី និងលើអង្គសេចក្តីនៅក្នុងសំណុំរឿង០០២ (ប្រឆាំងនឹងនួន ជា និង ខៀវ សំផន ហើយកាលពីមុនប្រឆាំងនឹងអៀង សារី អៀង ធីរិទ្ធ និងឌុចផងដែរ) ដែលទទួលបានជាសាធារណៈនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥។ ផ្អែកតាមករណីយុត្តិសាស្ត្រទាំងនេះ យើងក៏អាចចងក្រងកំណត់ពន្យល់អំពី

មាត្រាចំនួន ៩៣ នៅក្នុងក្រមនីតិវិធីសម្រាប់*សេចក្តីពន្យល់នៃក្រមនេះ* ជាពិសេសមាត្រាសំខាន់ៗ ដែលអនុវត្តក្នុងនីតិវិធីមុនអង្គសេចក្តី និងនីតិវិធីលើអង្គសេចក្តី។

រាល់កំណត់ពន្យល់អំពីមាត្រានីមួយៗ ចាប់ផ្តើមពីអត្ថបទនៅក្នុងមាត្រានៃក្រមនីតិវិធី ដើម្បីងាយស្រួលយោង។ បន្ទាប់មក យើងបានចងក្រងក្នុងកថាខណ្ឌដាច់ដោយឡែក ដែលចែងពីគោលការណ៍ខុសគ្នា ដែលពាក់ព័ន្ធ ឬការរកឃើញក្នុងករណីយុត្តិសាស្ត្ររបស់ អ.វ.ត.ក។ កថាខណ្ឌទាំងនេះ ចាប់ផ្តើមដោយប្រយោគដែលនិយាយពីទស្សនៈទូទៅ ជាអក្សរដិតខ្មៅ និងមានឃ្លាដែលពន្យល់ពីគោលការណ៍ពាក់ព័ន្ធ ឬការរកឃើញ។ បន្ទាប់ពីកថាខណ្ឌកំណត់ពន្យល់ យើងមានឃ្លាយោងខ្លី ដែលចង្អុលបង្ហាញពីប្រភពនៃសេចក្តីសម្រេចមួយ ឬច្រើនដែលជាមូលដ្ឋាននៃកំណត់ពន្យល់នេះ។ (ចូរអានខ្លឹមសារគំរូក្នុងប្រអប់)។ លើសពីនេះទៀត បន្ទាប់ពីផ្នែកកំណត់ពន្យល់ យើងមានកថាខណ្ឌខ្លីៗ ដែលកំណត់ពីវិធានស្រដៀងគ្នាមួយ ឬច្រើននៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ដែលពាក់ព័ន្ធ និងមានសេចក្តីអធិប្បាយអំពីភាពខុសគ្នារវាងវិធានទាំងនោះ និងមាត្រាក្នុងក្រមនីតិវិធី។

> ***ភាពចាំបាច់ ដើម្បីរក្សាតុល្យភាពរវាងការឃុំខ្លួន និងសេរីភាព៖*** តុលាការត្រូវតែថ្លឹងថ្លែងមូលហេតុនៃការឃុំខ្លួន ទៅនឹងសិទ្ធិមានសេរីភាពបុគ្គល។ សច្ចធារណ៍នៃសេរីភាពតម្រូវថា ការឃុំខ្លួនត្រូវបញ្ជាក់អំពីសំអាងហេតុ នៅក្នុងសេចក្តីសម្រេចឃុំខ្លួន និងត្រូវធ្វើឡើងដោយអនុលោមទៅតាមលក្ខខណ្ឌច្បាប់ និងនីតិវិធី។
>
> *រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ក្លាមៗសុំឲ្យដោះលែង អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក) ៦ មិថុនា ២០១១ កថាខណ្ឌ ៤៧ និង៥៦។*

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាការទទួលស្គាល់ និងការគោរពសន្ធិសញ្ញាសិទ្ធិមនុស្សដែលកម្ពុជាជាភាគី។ សន្ធិសញ្ញាទាំងនោះរួមមាន *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* (**ICCPR**) ដែលចែងពីគោលការណ៍ជាច្រើន ដែលត្រូវបានចាត់ទុកជាមូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះ ដើម្បីផ្តល់ការណែនាំបន្ថែមអំពីវិធីបកស្រាយ និងអនុវត្តមាត្រានានានៅក្នុងក្រមនីតិវិធី *សេចក្តីពន្យល់នៃក្រម*នេះ ក៏បានបញ្ចូលកំណត់ពន្យល់បន្ថែមទៅលើករណីយុត្តិសាស្ត្រនៃគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលជាស្ថាប័នមួយតាមដានការអនុវត្តកតិកាសញ្ញា ICCPR និងដែលតែងតែចេញសេចក្តីសម្រេចអំពីការបកស្រាយ និងការអនុវត្តបទប្បញ្ញត្តិ នៃកតិកាសញ្ញា ICCPR ដែលពាក់ព័ន្ធទៅនឹងនីតិវិធីព្រហ្មទណ្ឌ។ លើសពីនេះទៅទៀត សេចក្តីពន្យល់នៃក្រមនេះមានកំណត់ពន្យល់អំពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ដោយសារតែបទប្បញ្ញត្តិនៃនីតិវិធីព្រហ្មទណ្ឌនៅក្នុង*អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន* គឺដូចគ្នាទៅនឹងបទប្បញ្ញត្តិ

ទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ហើយតុលាការសិទ្ធិមនុស្សអឺរ៉ុប ក៏មានករណីយុត្តិសាស្ត្រដ៏សម្បូណ៌ និងរឹងមាំផងដែរ។

លើសពីនេះទៅទៀត *សេចក្តីពន្យល់នៃក្រម* នេះ ក៏បានបញ្ចូលកំណត់ពន្យល់អំពីករណីយុត្តិសាស្ត្ររបស់តុលាការកំពូលបារាំង ដែលជាតុលាការខ្ពស់បំផុតរបស់បារាំង។ ការធ្វើបែបនេះគឺដោយសារក្រមនីតិវិធី មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ហេតុដូច្នេះការបកស្រាយ និងការអនុវត្តក្រមបារាំង ដោយតុលាការកំពូលបារាំង អាចផ្តល់ទស្សនៈស៊ីជម្រៅបន្ថែមអំពីរបៀបនៃការបកស្រាយ និងអនុវត្តក្រមនីតិវិធីនៅកម្ពុជា។ កំណត់ពន្យល់នេះ ក៏អាចផ្តល់ទស្សនៈស៊ីជម្រៅ អំពីការអនុវត្តក្រមនីតិវិធីក្នុងស្ថានភាពសាមញ្ញៗ ដែលអាចជាទស្សនវិស័យមានប្រយោជន៍ ដោយសារតែករណីយុត្តិសាស្ត្ររបស់ អ.វ.ត.ក ត្រូវបានសម្រេចក្នុងបរិបទពិសេសបំផុត។

*សេចក្តីពន្យល់នៃក្រម*នេះ យោងទៅរកករណីយុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប និងរបស់តុលាការកំពូលបារាំងរហូតដល់ចុងឆ្នាំ២០១១។ ក៏ប៉ុន្តែគួរកត់សម្គាល់ថា កំណត់ពន្យល់សម្រាប់យុត្តិសាស្ត្រនេះ មិនបានពិស្តារទូលំទូលាយទេ។ ផ្ទុយទៅវិញ *សេចក្តីពន្យល់នៃក្រម*នេះ បានដាក់បញ្ចូលតែយុត្តិសាស្ត្រដែលយើងយល់ថាមានការពាក់ព័ន្ធខ្លាំងទៅនឹងមាត្រាទាំងឡាយនៅក្នុងក្រមនីតិវិធី និងបានចែងពន្យល់ច្បាស់អំពីវិធីដែលតុលាការអាចបកស្រាយ និងអនុវត្តមាត្រានៅក្នុងក្រមនីតិវិធីបាន។

ជាទីបញ្ចប់ គួរកត់សម្គាល់ផងដែរថារឿងក្តីទាំងអស់ ដែលបានយោងក្នុង *សេចក្តីពន្យល់នៃក្រម* នេះ ត្រូវបានអធិប្បាយពិស្តារទាំងស្រុង ក្នុងតារាងរឿងក្តីនៅទំព័រខាងក្រោយ នៅក្នុង *សេចក្តីពន្យល់នៃក្រម* នេះ។ លើសពីនេះទៀត អ្នកអានអាចទទួលបានអត្ថបទទាំងស្រុង នៃសេចក្តីសម្រេចនីមួយៗលើគេហទំព័រដែលមានផ្ទុកឯកសារទាំងនេះ (តាមរយៈគេហទំព័រ http://cambodia.ohchr.org) លើកលែងតែរឿងក្តីនៅតុលាការកំពូលបារាំងចាប់ពីមុនឆ្នាំ១៩៦២មក ដោយសារយើងមិនអាចទទួលបាននូវរឿងក្តីទាំងនេះ តាមរយៈប្រព័ន្ធអ៊ីនធើណេត និងដោយសារតែយើងអាចទទួលបានឯកសារចងក្រងរបស់បណ្ណាល័យមួយចំនួនតូចប៉ុណ្ណោះ។

# វិធានទូទៅ និងវិធានពាក់ព័ន្ធនឹងដំណាក់កាលមុនការជំនុំជម្រះ

ផ្នែកនេះ មានរួមបញ្ចូលសេចក្តីពន្យល់បន្ថែមលើមាត្រានានានៅក្នុង *ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា* (ក្រម):

- មាត្រា ២ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី
- មាត្រា ៧ ការរលត់នៃបណ្តឹងអាជ្ញា
- មាត្រា ១២ អាជ្ញាអស់ជំនុំ
- មាត្រា ១៣ បណ្តឹងរដ្ឋប្បវេណី និងព្យសនកម្ម
- មាត្រា ១៦ បណ្តឹងរដ្ឋប្បវេណីរបស់សិទ្ធិវ័ន្តនៃជនរងគ្រោះ
- មាត្រា ៤៤ ការបើកការស៊ើបសួរ
- មាត្រា ៩៣ កំណត់ហេតុលើការស្តាប់ចម្លើយ
- មាត្រា ៩៦ ការឃាត់ខ្លួន
- មាត្រា ១២១ ការសម្ងាត់នៃការស៊ើបសួរ
- មាត្រា ១២៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- មាត្រា ១២៥ វិសាលភាពនៃការប្តឹង
- មាត្រា ១២៦ ការដាក់ជនសង្ស័យឲ្យស្ថិតក្រោមការពិនិត្យ
- មាត្រា ១២៧ ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក
- មាត្រា ១២៩ មុខងាររបស់ក្រឡាបញ្ជី
- មាត្រា ១៣២ ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា
- មាត្រា ១៣៣ ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ
- មាត្រា ១៣៤ ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី
- មាត្រា ១៣៧ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍
- មាត្រា ១៣៨ បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
- មាត្រា ១៣៩ ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា

- មាត្រា ១៤៣ ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ
- មាត្រា ១៤៥ វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ
- មាត្រា ១៥០ ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- មាត្រា ១៥៤ សម្បថរបស់សាក្សី
- មាត្រា ១៥៦ សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ
- មាត្រា ១៥៧ ភាពគ្មានលទ្ធភាពស្តាប់ចម្លើយរបស់សាក្សីមួយចំនួន
- មាត្រា ១៦២ ភាពចាំបាច់នៃការធ្វើកោសលវិច័យ
- មាត្រា ១៦៥ ដីកាចាត់តាំងអ្នកជំនាញ
- មាត្រា ១៦៩ ការចាត់តាំងអ្នកជំនាញច្រើនរូប
- មាត្រា ១៧០ ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ
- មាត្រា ១៩៧ ដីកាបង្គាប់ឲ្យចាប់ខ្លួន និងយោបល់របស់ព្រះរាជអាជ្ញា
- មាត្រា ១៩៨ និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឲ្យចាប់ខ្លួន
- មាត្រា ២០៣ គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន
- មាត្រា ២០៥ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន
- មាត្រា ២០៦ កំណត់សម្គាល់របស់ជនត្រូវចោទ និងការប្រាប់ហេតុផលនៃដីកា
- មាត្រា ២១០ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាអាទិ៍
- មាត្រា ២១១ ការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្ន
- មាត្រា ២១៧ ការដោះលែងឱ្យនៅក្រៅឃុំតាមបណ្តឹងរបស់ជនត្រូវចោទ
- មាត្រា ២២៣ កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ
- មាត្រា ២៤៦ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា
- មាត្រា ២៤៧ ដីកាដំណោះស្រាយ
- មាត្រា ២៤៩ សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ
- មាត្រា ២៥០ ការបញ្ជូនដើម្បីបើកសវនាការជំនុំជម្រះ
- មាត្រា ២៥២ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ
- មាត្រា ២៥៣ ការប្តឹងទៅសភាស៊ើបសួរ
- មាត្រា ២៥៧ បញ្ជីបណ្តឹងឧទ្ធរណ៍ និងពាក្យសុំ
- មាត្រា ២៥៩ ការពិគ្រោះសំណុំរឿង និងសារណា

- មាត្រា ២៦០ ដំណើរការនៃកិច្ចពិភាក្សាដេញដោល
- មាត្រា ២៦១ ការពិនិត្យលើនិយ័តភាពនៃនីតិវិធី
- មាត្រា ២៦៦ បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា
- មាត្រា ២៦៧ បណ្ដឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ
- មាត្រា ២៦៨ បណ្ដឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ ដោយដើមបណ្ដឹងរដ្ឋប្បវេណី
- មាត្រា ២៧១ សមត្ថកិច្ចរបស់សភាស៊ើបសួរ
- មាត្រា ២៧៨ សាលដីកាដែលសម្រេចលើការឃុំខ្លួនបណ្ដោះអាសន្ន
- មាត្រា ២៧៩ ភាពដែលមិនអាចទទួលយកបាននៃពាក្យប្ដឹងសុំមោឃកម្ម
- មាត្រា ២៨០ អានុភាពនៃមោឃកម្ម

# មាត្រា ២៖ បណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី

*បណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី គឺជាបណ្ដឹងពីរផ្សេងគ្នា។*

*បណ្ដឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឱ្យឃើញពិរុទ្ធភាព នៃជនល្មើសឧក្រិដ្ឋ និងផ្ដន្ទាទោសជននេះតាមច្បាប់កំណត់។*

*បណ្ដឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជំងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។*

## *ការអនុវត្តក្នុង អ.វ.ត.ក*

**បណ្ដឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធជាក់លាក់ទៅនឹងសំណង៖** បណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធជាក់លាក់ទៅនឹងការទាមទារសំណង របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះការខូចខាត ដែលបបណ្ដាលមកពីឧក្រិដ្ឋកម្ម ដូចបានចោទប្រកាន់នៅក្នុងបណ្ដឹងអាជ្ញា។

*រឿងក្ដីឌុច៖ សាលក្រម អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូង (អ.ជ.ស.ដ) ២៦ កក្កដា ២០១០ កថាខណ្ឌ៦៦០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន២៣ ២៣ស្ទួន ២៣ស្ទួនបួន និងវិធាន១០០។ វិធាន២៣ចែងថា គោលបំណងមួយផ្នែករបស់បណ្ដឹងរដ្ឋប្បវេណី គឺដើម្បីទាមទារសំណង។ វិធាន២៣ស្ទួន (៥) ចែងថា ការបោះបង់បណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ពុំមានអានុភាពប៉ះពាល់រឿងក្ដីព្រហ្មទណ្ឌឡើយ។ វិធាន២៣ ស្ទួនបួនទាមទារលក្ខខណ្ឌថា សំណងគឺជាការទទួលស្គាល់នូវព្យសនកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរង និងជាការជួសជុលនូវការខូចខាតនេះ។ វិធាន១០០នៃវិធានផ្ទៃក្នុងចែងដោយប្រយោលថា សាលក្រមនៅក្នុងរឿងក្ដីតែមួយត្រូវធ្វើឡើងចំនួនពីរ ប៉ុន្តែពុំមែនធ្វើឡើងដាច់ដោយឡែកពីគ្នាទាំងស្រុង ដូចមានចែងនៅក្នុងមាត្រា២នោះទេ ពីព្រោះថាសាលក្រមសម្រេចអំពីបណ្ដឹងរដ្ឋប្បវេណី ត្រូវស្របជាមួយនឹងសាលក្រមសម្រេចអំពីបណ្ដឹងអាជ្ញា ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***
*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ជនរងគ្រោះ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី៖** ជនរងគ្រោះនៃបទល្មើសមួយអាចតាំងខ្លួនឯង ជាដើមបណ្តឹងរដ្ឋប្បវេណីបាន។

*លេខ69-92311ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៨២ តុលាការកំពូលបារាំង ៨ មិថុនា ១៩៧១។*

**ភាពដាច់ដោយឡែកនៃបណ្តឹង៖** បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងដាច់ដោយឡែកពីគ្នា។

*លេខ88-86499 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៤៤១ តុលាការកំពូលបារាំង ២៨ វិច្ឆិកា ១៩៨៩។*

**សិទ្ធទទួលបានសំណងចំពោះការខូចខាត៖** ជនទាំងឡាយដែលបានទទួលរងដោយផ្ទាល់ ចំពោះការខូចខាតបណ្តាលមកពីបទល្មើស មានសិទ្ធិទទួលបានសំណងពីជនដែលបានបង្កនូវការខូចខាតនេះ។

*លេខ91-85925 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ៣៤៩ តុលាការកំពូលបារាំង ២៨ តុលា ១៩៩២។*

**នៅពេលជនជាប់ចោទ ត្រូវបានសម្រេចឲ្យរួចផុតពីបទចោទនៅចំពោះមុខតុលាការព្រហ្មទណ្ឌ តុលាការរដ្ឋប្បវេណី ត្រូវពិចារណាលើបទល្មើសដែលត្រូវបានប្រព្រឹត្ត៖** ពោលគឺត្រូវសម្រេចលើការទាមទារសំណងរបស់ជនរងគ្រោះ។

*លេខ00-86244 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣២ តុលាការកំពូលបារាំង ១៩ កុម្ភៈ ២០០២។*

**ចំណងទាក់ទងដោយផ្ទាល់រវាងព្យសនកម្ម និងបទល្មើស៖** ព្យសនកម្មដូចបានចោទប្រកាន់ ត្រូវតែមានចំណងទាក់ទងដោយផ្ទាល់ទៅនឹងបទល្មើសដូចបានចោទប្រកាន់។

*លេខ02-81514 តុលាការកំពូលបារាំង ២៦ កញ្ញា ២០០២។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា១ និងមាត្រា២។ មាត្រាទាំងនេះចែងអំពីការអនុវត្តបណ្តឹងអាជ្ញាប្រឆាំងនឹងបទល្មើសណាមួយ ដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម (មាត្រា១) និងការអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសារជនរងគ្រោះបានទទួលរងការខូចខាត (មាត្រា២)។

# មាត្រា ៧៖ ការរលត់នៃបណ្តឹងអាជ្ញា

*មូលហេតុនៃការរលត់បណ្តឹងអាជ្ញា មានដូចតទៅគឺ៖*

*១- មរណភាពនៃជនល្មើស*

*២- ការផុតអាជ្ញាយុកាល*

*៣- ការលើកលែងទោសជាទូទៅ*

*៤- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ*

*៥- អាជ្ញាអស់ជំនុំ*

*កាលណាបណ្តឹងអាជ្ញាផុតរលត់ហើយ ការចោទប្រកាន់ខាងព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។*

## ការអនុវត្តក្នុង អ.វ.ត

ការលើកលែងទោស មិនអាចរារាំងដល់ការផ្តន្ទាទោសឧក្រិដ្ឋកម្មអន្តរជាតិ និងការរំលោភបំពានសិទ្ធិមនុស្ស ដែលត្រូវបានគេគិតថា ជាបទដ្ឋាន *មិនអាចដកហូតបាន*៖ ការលើកលែងទោសដែលធ្វើឡើង ក្នុងបរិបទជាតិ ក្នុងការរារាំងការផ្តន្ទាទោសឧក្រិដ្ឋកម្មអន្តរជាតិគឺមានវិសមិតភាព ជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់ដល់ជនរងគ្រោះ ដោយសារឧក្រិដ្ឋកម្មទាំងនេះនូវដំណោះស្រាយមួយ ប្រកបដោយប្រសិទ្ធភាព។ ការលើកលែងទោសទាំងស្រុងចំពោះឧក្រិដ្ឋកម្មអន្តរជាតិដែលធ្ងន់ធ្ងរ គឺជាការរំលោភបំពានលើបទដ្ឋានច្បាប់អន្តរជាតិ។

*រឿងក្តីអៀង សារី៖ សេចក្តីសម្រេចលើបណ្តឹងរបស់អៀង សារី ស្តីពីការបដិសេធន៍បឋមតាមវិធាន៨៩ អ.វ.ត.ក អ.ជ.ស.ជ ៣ វិច្ឆិកា ២០១១ កថាខណ្ឌ ៤២..*

**មរណភាពរបស់ជនជាប់ចោទ គឺជាការរលត់នូវបណ្តឹងអាជ្ញាប្រឆាំងនឹងជននោះ៖** ក្នុងករណីណាដែលអង្គជំនុំជម្រះ មានលិខិតបញ្ជាក់ពីពេទ្យស្តីពីមរណភាព របស់ជនជាប់ចោទដែលប្រការនេះ អាចបណ្តាលឲ្យរលត់បណ្តឹងអាជ្ញាប្រឆាំងនឹងជននេះបាន។ ការណ៍នេះ មិនរារាំងដល់បណ្តឹងរដ្ឋប្បវេណី ប្រឆាំងទៅនឹងជនជាប់ចោទឡើយ។

*រឿងក្តីអៀង សារី៖ ការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី អ.វ.ត.ក អ.ជ.ស.ជ ១៤ មីនា ២០១៣ កថាខណ្ឌ៣ រឿងក្តីអៀង សារី៖ ការបដិសេធបណ្តឹងឧទ្ធរណ៍របស់អៀងសារី ក្រោយមរណភាពរបស់គាត់ អ.វ.ត.ក អ.ជ.ត.ក ២១ មីនា ២០១៣ កថាខណ្ឌ២។*

… **ឧក្រិដ្ឋកម្មបានចោទប្រកាន់ ត្រូវតែស្តែងឡើងឲ្យដូចគ្នាទៅនឹងការផ្តន្ទាទោស/ការលើកលែងការចោទពីមុន៖** ការអនុវត្ត***អាជ្ញាអស់ជំនុំ***។ គោលការណ៍នៃអាជ្ញាអស់ជំនុំ ស្ថិតក្រោមច្បាប់កម្ពុជា រារាំងតុលាការ ដល់កិច្ចដំណើរការនីតិវិធីថ្មីសម្រាប់កិច្ចដូចគ្នា (តែផ្ទុយទៅនឹងបទល្មើសដូចគ្នា)។ ការណ៍នេះ តម្រូវឲ្យមានការបង្ហាញឲ្យឃើញថា បទចោទដែលត្រូវបានចោទប្រកាន់ គឺស្តែងឲ្យឃើញដូចគ្នាទៅនឹងបទចោទទាំងឡាយ ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស ឬលើកលែងការចោទប្រកាន់។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ១៧ តុលា ២០០៨ កថាខណ្ឌ៤១-៥៣។ រឿងក្តីអៀង សារី៖ សេចក្តីសម្រេចលើបណ្តឹងរបស់អៀង សារី ស្តីពីការបដិសេធបឋមតាមវិធាន៨៩ អ.វ.ត.ក អ.ជ.ស.ជ ៣ វិច្ឆិកា ២០១១ កថាខណ្ឌ ២៧។ រឿងក្តីនួន ជា និងខៀវ សំផន៖ សេចក្តីសម្រេចលើបណ្តឹងខៀវ សំផន ដែលស្នើសុំពន្យារពេលចាប់ផ្តើមដំណើរការសវនាការ សំណុំរឿង០០២/០២ រហូតដល់សាលដីកាស្ថាពរ នៃសំណុំរឿង០០២/០១ ត្រូវបានប្រកាស អ.ជ.ស.ជ ២១ មីនា ២០១៤ កថាខណ្ឌ។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធានផ្ទៃក្នុង៨៩។ វិធាននេះចែងច្បាស់ថា ការបដិសេធន៍បឋមលើបញ្ហាណាមួយ ដែលតម្រូវឲ្យមានការបញ្ចប់ការផ្តន្ទាទោសនោះ អាចត្រូវបានគេលើកឡើងមិនឲ្យលើសពីរយៈពេល ៣០ថ្ងៃទេ បន្ទាប់ពីដីកាដំណោះស្រាយបានចូលស្ថាពរ។ រីឯមរណភាពរបស់ជនជាប់ចោទវិញ អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ផ្អែកលើមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដើម្បីប្រកាសអំពីមរណភាពរបស់ជនជាប់ចោទ នៅអំឡុងពេលនៃកិច្ចដំណើរការជំនុំជម្រះក្តី។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលប្បញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ជាទូទៅ ការលើកលែងទោសគឺមានវិសមិតភាពជាមួយនឹងករណីយកិច្ច ដើម្បីស៊ើបអង្កេតអំពើទារុណកម្ម៖** រដ្ឋភាគីតម្រូវឲ្យផ្តល់ ដល់ជនរងគ្រោះនូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព៖

*រឿងក្តី BASILIO LAUREANO ATACHAHUA ទល់នឹងប្រទេសប៉េរូ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២២ មីនា ១៩៩៦ កថាខណ្ឌ១០។*

**ការលើកលែងទោស ចំពោះការរំលោភបំពានលើសិទ្ធិមនុស្សធ្ងន់ធ្ងរ គឺមានវិសមិតភាពជាមួយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** រដ្ឋភាគីមិនត្រូវបន្ធូរបន្ថយដល់ចារីទាំងឡាយ ពីការទទួលខុសត្រូវជាបុគ្គល តាមរយៈការប្រើប្រាស់ការលើកលែងទោស។

*រឿងក្តី BASILIO LAUREANO ATACHAHUA ទល់នឹងប្រទេសអូរូហ្គាយ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៩ កក្កដា ១៩៩៤ កថាខណ្ឌ១២.៤។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖*** មាត្រា២ ចែងថា រដ្ឋភាគីមានកាតព្វកិច្ចក្នុងការធានាថា បុគ្គលណាម្នាក់ដែលសិទ្ធិរបស់ខ្លួនដូចបានចែងក្នុងកតិកាសញ្ញាត្រូវបានរំលោភបំពាន ត្រូវមានសិទ្ធិទទួលបាននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ការលើកលែងទោស មិនត្រូវបានអនុញ្ញាត សម្រាប់បទល្មើសឧក្រិដ្ឋ និងអំពើទារុណកម្មឡើយ៖** ក្នុងករណីដែលភ្នាក់ងាររដ្ឋត្រូវបានចោទប្រកាន់ អំពីឧក្រិដ្ឋកម្មដែលពាក់ព័ន្ធអំពើទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញ។ ប្រការសំខាន់បំផុត គឺសម្រាប់គោលបំណង ក្នុងការផ្តល់នូវដំណោះស្រាយមួយ ប្រកបដោយប្រសិទ្ធភាព ហើយ កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងការផ្តន្ទាទោសមិនត្រូវបានរារាំង ដោយសារការកន្លងផុតទៅនៃពេលវេលាឡើយ ហើយថាការផ្តល់ការលើកលែងទោស ឬ និទ្ទោសកម្មមិនត្រូវបានអនុញ្ញាតឡើយ។

*រឿងក្តី* ABDULSAMET YAMAN *ទល់នឹងប្រទេសតួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២* TUNA *ទល់នឹងប្រទេសតួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៩ មករា ២០១០ កថាខណ្ឌ ៧១។ រឿងក្តី* OULD DAH *ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៧ មីនា ២០០៩ (ជាទូទៅ ការពិចារណាលើច្បាប់ ស្តីពីការលើកលែងទោស គឺមានវិសមិតភាពជាមួយនឹងករណីយកិច្ចរបស់រដ្ឋ ក្នុងការស៊ើបអង្កេតអំពីអំពើទារុណកម្ម)។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖* មាត្រា១៤ នៃពិធីសារលេខ៧ ត្រូវតែអានរួមគ្នាជាមួយនឹងមាត្រា១៣ នៃ*អនុសញ្ញា* ក៏ដូចជាច្បាប់ទំនៀមទំលាប់អន្តរជាតិផងដែរ។

# មាត្រា ១២៖ អាជ្ញាអស់ជំនុំ

*ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួន ជាស្ថាពរហើយតាមសាលក្រមរបស់តុលាការ ជននោះមិនអាចត្រូវចោទប្រកាន់ចំពោះអំពើដដែលទៀតទេ ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។*

## ការអនុវត្តក្នុង អ.វ.ត.ក

**បទល្មើសដូចបានចោទប្រកាន់ គឺត្រូវតែដូចគ្នាយ៉ាងជាក់លាក់ ទៅនឹងការសម្រេចឲ្យជាប់ពិរុទ្ធភាព/ ការសម្រេចឲ្យរួចផុតពីបទចោទនាពេលកន្លងមក៖** គោលការណ៍នៃអាជ្ញាអស់ជំនុំនៅក្នុងច្បាប់កម្ពុជា រារាំងការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីថ្មី ចំពោះអំពើដូចគ្នា (ប៉ុន្តែពុំមែនចំពោះបទល្មើសដូចគ្នានោះទេ)។ ករណីនេះទាមទារឲ្យបង្ហាញថា បទចោទដូចដែលបានចោទប្រកាន់ ត្រូវតែដូចគ្នាយ៉ាងជាក់លាក់ទៅនឹងបទល្មើសទាំងឡាយ ដែលជនជាប់ចោទត្រូវបានសម្រេចឲ្យជាប់ពិរុទ្ធភាព ឬឲ្យរួចផុតពីបទចោទ នាពេលកន្លងមក។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អង្គបុរេជំនុំជម្រះ (អ.ប.ជ) ១៧ តុលា ២០០៨ កថាខណ្ឌ ៤១-៥៣។ រឿងក្តីអៀង សារី៖ សេចក្តីសម្រេចលើបណ្តឹងរបស់អៀង សារី ស្តីពីការបដិសេធន៍បឋមតាមវិធាន៨៩ អ.វ.ត.ក អ.ជ.ស.ជ ៣ វិច្ឆិកា ២០១១ កថាខណ្ឌ២៧។ រឿងក្តីនួន ជានិងខៀវ សំផន៖ សេចក្តីសម្រេចលើបណ្តឹងខៀវ សំផន ស្នើសុំពន្យារពេល ក្នុងការចាប់ផ្តើមដំណើរការសវនាការលើសំណុំរឿង ០០២/០២ រហូតដល់សាលដីកាស្ថាពរ នៃសំណុំរឿង០០២/០១ ត្រូវបានប្រកាស អ.ជ.ស.ជ ២១ មីនា ២០១៤ កថាខណ្ឌ៨។*

**គោលការណ៍ *គ្មានបទល្មើស គឺគ្មានទោស៖* មិនហាមប្រាមការផ្តន្ទាទោស ទៅលើឧក្រិដ្ឋកម្មអន្តរជាតិនោះឡើយ។** រដ្ឋនីមួយៗមិនអាចសំអាងតែទៅលើគោលការណ៍នេះបានទេ ក្នុងគោលបំណង ដើម្បីបដិសេធការស៊ើបអង្កេតឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

*រឿងក្តីអៀង សារី៖ សេចក្តីសម្រេចលើបណ្តឹងរបស់អៀង សារី ស្តីពីការបដិសេធន៍បឋមតាមវិធាន៨៩ អ.វ.ត.ក អ.ជ.ស.ជ ៣ វិច្ឆិកា ២០១១ កថាខណ្ឌ៣៣-៣៦។*

**គេអាចហៅម្យ៉ាងទៀតថា ជាគោលការណ៍គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (*ne bis in idem*)។ល។៖** គោលការណ៍នេះ (ពុំមានជនណាម្នាក់ អាចត្រូវបានកាត់ទោសទៅលើបទល្មើស ដែលខ្លួនត្រូវបានសម្រេចឲ្យជាប់ពិរុទ្ធភាព ឬឲ្យរួចផុតពីបទចោទរួចហើយនោះទេ) ក៏អាចហៅបានម្យ៉ាងទៀតថា ជាអាជ្ញាអស់ជំនុំ (*res judicata*), *autrefois acquit/autrefois convict* (គ្មានការកាត់ទោសពីរដង) និង*double jeopardy* (គ្មានការកាត់ទោសពីរដង)។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ លេខយោងជើងទំព័រ២៩។*

**គោលការណ៍ *គ្មានបទល្មើសគឺគ្មានទោស* គឺមិនអាចអនុវត្តបានទេ ក្នុងករណីមានវិការៈនៅពេលជំនុំជម្រះ៖** ក្នុងករណីមានវិការៈជាមូលដ្ឋានកើតមានឡើងក្នុងកិច្ចដំណើរការនីតិវិធី *គោលការណ៍នេះ* មិនអនុវត្តបានឡើយ។

**អាជ្ញាអស់ជំនុំ ជាប់ទាក់ទងគ្នាយ៉ាងជិតដិតទៅនឹងគោលការណ៍គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (*Ne bis in idem*)៖** នៅក្នុងករណីឃុំខ្លួនបណ្តោះអាសន្ន អាជ្ញាអស់ជំនុំ អាចជាហេតុផលសម្រាប់ការច្រានចោល នូវកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ចំណែក *Ne bis in idem* គឺជាការរារាំងយុត្តាធិការ។ ប្រសិនបើ អង្គជំនុំជម្រះបញ្ជូនជនណាម្នាក់ ទៅជំនុំជម្រះកិច្ចនេះ មិនគួរត្រូវបានច្រានចោលឡើយ ហើយកិច្ចនេះបានតម្កល់យុត្តាធិការ លើជនជាប់ចោទរួចហើយ។ ដូច្នេះ វាធ្វើឲ្យបាត់នូវអានុភាព នៃការទាមទារលើ *Ne bis in idem* ឬអាជ្ញាអស់ជំនុំ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ ៦១-៦២ និង៦៥-៦៦។*

**សំអាងហេតុ មិនចំណុះឲ្យអាជ្ញាអស់ជំនុំនោះទេ៖** សំអាងហេតុនៃសេចក្តីសម្រេច មិនចំណុះឲ្យអាជ្ញាអស់ជំនុំនោះឡើយ ដោយសារតែសំអាងហេតុនេះ មិនអាចត្រូវបានគេអនុវត្ត ឬយកមកបំពេញកិច្ចបានឡើយ។

*រឿងក្តីនួន ជា៖ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យពិចារណាឡើងវិញ អ.វ.ត.ក អ.ប.ជ ២៦ កុម្ភៈ ២០០៩ កថាខណ្ឌ១០-១១។*

**សេចក្តីសម្រេចបឋម មិនចំណុះឲ្យអាជ្ញាអស់ជំនុំទេ៖** ក្នុងករណីដែលអង្គជំនុំជម្រះ ធ្វើសេចក្តីសម្រេចបឋមលើនីត្យានុកូលភាព នៃដីកាចាប់ខ្លួន ដោយផ្អែកទៅលើព័ត៌មានតិចតួច និងក្នុងករណីដែលអង្គជំនុំជម្រះ បានផ្តល់ឱកាសឲ្យជនជាប់ចោទតវ៉ាលើបញ្ហាទាំងនេះ នៅក្នុងកិច្ចដំណើរការនីតិវិធី ក្នុងដំណាក់កាលក្រោយ នោះសេចក្តីសម្រេចចុង

ក្រោយ ពុំត្រូវបានរារាំងដោយអាជ្ញាអស់ជំនុំ ក្នុងការលើកឡើង អំពីបញ្ហាទាំងនេះ នៅក្នុងដំណាក់កាលក្រោយនោះទេ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ៦៧។*

**ការពិចារណាសារជាថ្មី នៃការសម្រេចឲ្យជាប់ពិរុទ្ធភាព មិនចំណុះឲ្យអាជ្ញាអស់ជំនុំទេ៖** មាត្រា១២ រារាំងការប្រើប្រាស់អាជ្ញាអស់ជំនុំ នៅពេលដែលធ្វើការពិចារណាសារជាថ្មី អំពីការសម្រេចឲ្យជាប់ពិរុទ្ធភាព។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ១២៣-១២៤។*

**ដីកាសម្រេចអំពីភាពអាចទទួលយកបាន គឺមិនចំណុះឲ្យអាជ្ញាអស់ជំនុំទេ៖** ដីកាសម្រេចអំពីភាពអាចទទួលយកបាននៃសំណើសុំ មិនមែនជាដីកាសម្រេចលើអង្គសេចក្តី នៃសំណើសុំឡើយ។ ហេតុដូច្នេះ ដីកាសម្រេចអំពីភាពអាចទទួលយកបាន មិនមែនជាសេចក្តីសម្រេចស្ថាពរ ដែលអាចអនុវត្តអាជ្ញាអស់ជំនុំឡើយ។

*រឿងក្តីខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសំណើសុំមោឃភាព អ.វ.ត.ក អ.ប.ជ ៤ ឧសភា ២០១០ កថាខណ្ឌ១៣។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៨៩។ វិធាននេះបញ្ជាក់ច្បាស់ថាអាជ្ញាអស់ជំនុំ មិនអនុវត្តលើសេចក្តីសម្រេចលើកចោលបណ្តឹងនោះឡើយ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

ជនណាម្នាក់ ដែលត្រូវបានសម្រេចឲ្យមានពិរុទ្ធភាពពីបទល្មើសណាមួយ មិនអាចត្រូវបានជំនុំជម្រះលើបទល្មើសនេះសារជាថ្មីបានទេ ជាពិសេសនៅពេលជំនុំជម្រះ រួមជាមួយនឹងបទល្មើសផ្សេងទៀត៖ នេះគឺជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយការរំលោភបែបនេះកាន់តែមានភាពធ្ងន់ធ្ងរ នៅពេលដែលយកមកជំនុំជម្រះឡើងវិញ ជាមួយនឹងបទល្មើសធ្ងន់ធ្ងរមួយចំនួនផ្សេងទៀត ពីព្រោះថា គណៈវិនិច្ឆ័យបានស្តាប់ព័ត៌-

មានលម្អៀង ដែលពុំពាក់ព័ន្ធនឹងបទចោទដែលជនរូបនេះ ត្រូវបានជំនុំជម្រះយ៉ាងត្រឹមត្រូវរួចហើយ។

*រឿងក្តី BABKIN ទល់នឹងសហព័ន្ធរុស្ស៊ីគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣ មេសា ២០០៨ កថាខណ្ឌ១៣.៦។*

**គ្មានការរំលោភសិទ្ធិ ប្រសិនបើការសម្រេចឲ្យរួចផុតពីបទចោទត្រូវបានគេច្រានចោល មុនពេលចូលជាស្ថាពរ៖** សិទ្ធិពុំត្រូវបានគេជំនុំជម្រះពីរដង ចំពោះបទល្មើសដដែល ពុំត្រូវបានរំលោភឡើយ នៅពេលសាលាក្តីជាន់ខ្ពស់ បានច្រានចោលការសម្រេចឲ្យរួចផុតពីបទចោទ មុនពេលមានការសម្រេចឲ្យរួចផុតពីបទចោទនេះចូលជាស្ថាពរ។ ហេតុដូច្នេះ បណ្តឹងសាទុក្ខ មិនរំលោភលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ។

*រឿងក្តី BABKIN ទល់នឹងសហព័ន្ធរុស្ស៊ីគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣ មេសា ២០០៨ កថាខណ្ឌ១៣.៥។*

**ការរំលោភសិទ្ធិ៖ ការច្រានចោលសេចក្តីសម្រេចឲ្យរួចផុតពីបទចោទ ដោយអនុវត្តច្បាប់តាមអានុភាពប្រតិសកម្ម៖** សិទ្ធិពុំត្រូវបានកាត់ទោសពីរដងចំពោះបទល្មើសដដែល ត្រូវបានគេរំលោភ នៅពេលដែលតុលាការច្រានចោលសេចក្តីសម្រេចឲ្យរួចផុតពីបទចោទ ដោយផ្អែកលើមូលដ្ឋាននៃការអនុវត្តច្បាប់តាមអានុភាពប្រតិសកម្ម ចំពោះអង្គហេតុ ដែលពុំបានបង្កើតជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលដែលអំពើសកម្ម/អំពើអកម្មបានកើតឡើង។

*រឿងក្តី SOBHRAJ ទល់នឹងប្រទេសណេប៉ាល់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ កក្កដា ២០១០ កថាខណ្ឌ៧.៦។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា១៤(៧)។ មាត្រានេះចែងអំពីសិទ្ធិពុំត្រូវបានកាត់ទោសពីរដងចំពោះបទល្មើសដដែល។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុប ត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**អាជ្ញាអស់ជំនុំ ត្រូវអនុវត្តនៅពេលនិយមន័យ ប្រភេទ និងគោលបំណងនៃបទល្មើសមានលក្ខណៈខុសគ្នារវាងក្រមនៅក្នុងប្រព័ន្ធតុលាការតែមួយ៖** នៅពេលសេចក្តីសម្រេចពីរ បានផ្អែកលើមូលដ្ឋាននៃអំពើដដែល ដែលនាំដល់ការប្រព្រឹត្តបទល្មើសតែមួយ នៅក្នុងរឿងក្តីទាំងពីរ នៅពេលនោះវាជាការរំលោភលើអាជ្ញាអស់ជំនុំ។

*រឿងក្តី GRADINGER ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៣ តុលា ១៩៩៥ កថាខណ្ឌ៥៥។*

**នៅក្នុងករណីអំពើតែមួយ បង្កើតជាបទល្មើសផ្សេងៗគ្នា ជនជាប់ចោទ អាចត្រូវបានថ្កោលទោសពីបទល្មើសច្រើនខុសៗគ្នា៖** នៅក្នុងករណីបែបនេះ វាពុំមានការរំលោភអាជ្ញាអស់ជំនុំឡើយ។ ទោសធ្ងន់នឹងត្រូវស្រូបទោសស្រាល។

*រឿងក្តី OLIVEIRA ទល់នឹងប្រទេសស្វីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ៣០ កក្កដា ១៩៩៨ កថាខណ្ឌ២៦។*

**នៅក្នុងករណីអំពើតែមួយ បង្កើតជាបទល្មើសផ្សេងៗគ្នា ការអនុវត្តអាជ្ញាអស់ជំនុំ អាស្រ័យលើទំនាក់ទំនងរវាងបទល្មើសផ្សេងៗគ្នា ដែលបានកើតចេញពីអំពើដដែល៖** នៅពេលបទល្មើសផ្សេងៗគ្នាដែលកើតចេញពីអំពើព្រហ្មទណ្ឌតែមួយ ពុំមានភាពខុសគ្នានៅក្នុងធាតុផ្សំសំខាន់ៗទេនោះ ជនជាប់ចោទ មិនអាចត្រូវបានជំនុំជម្រះពីរដង ចំពោះបទល្មើសមួយ និងបន្ទាប់មកត្រូវបានជំនុំជម្រះចំពោះបទល្មើសមួយផ្សេងទៀតឡើយ។

*រឿងក្តី FRANZ FISCHER ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៩ ឧសភា ២០០១ កថាខណ្ឌ២៩។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុប ស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៤ នៅក្នុងពិធីសារលេខ៧។ មាត្រានេះបានបង្កើតគោលការណ៍អាជ្ញាអស់ជំនុំ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**តុលាការបារាំង ពុំអាចរារាំងការអនុវត្តអាជ្ញាអស់ជំនុំនោះទេ លើកលែងតែនៅក្នុងករណីដែលកាលៈទេសៈដែលផ្លាស់ប្តូរ ការកំណត់បទល្មើសកើតឡើងក្រោយជនណាម្នាក់ ត្រូវគេបានសម្រេចឲ្យមានពិរុទ្ធភាពរួចហើយ៖** វាពុំអាចឲ្យតុលាការបារាំងចោទប្រកាន់ជនម្នាក់ពីរដង ចំពោះអំពើដូចគ្នានោះបានទេ ទោះបីជាអំពើនេះ អាចត្រូវបានគេកំណត់បទចោទផ្សេងក៏ដោយ។ ទោះបីជាយ៉ាងនេះក្តីនៅពេលជនណាម្នាក់ ត្រូវបានសម្រេចឲ្យមានពិរុទ្ធភាពលើបទល្មើសណាមួយ នៅមុនពេលរកឃើញអំពីកាលៈ-ទេសៈ ដែលផ្លាស់ប្តូរការកំណត់បទល្មើសនេះ ជននោះអាចត្រូវបានជំនុំជម្រះ ពីបទល្មើសដែលទើបត្រូវបានកំណត់ថ្មីៗបាន។

*D. 1957. 33 តុលាការកំពូលបារាំង ២០ មីនា ១៩៥៦ (តុលាការមិនអាចដាក់កំហិត ការអនុ-*

*វត្តអាជ្ញាអស់ជំនុំឡើយ)។ ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៤២១ តុលាការកំពូលបារាំង២៩ មីនា ១៩៩៤ (ចោទប្រកាន់បុគ្គលណាម្នាក់នៅក្នុងករណី ដែលកាលៈទេសៈផ្លាស់ប្តូរការកំណត់បទល្មើស)។*

**ជនបរទេសរួចផុតពីអាជ្ញាអស់ជំនុំ នៅក្នុងប្រទេសបារាំង នៅក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសបារាំង៖** នៅពេលជនបរទេសត្រូវបានសម្រេចឲ្យមានពិរុទ្ធភាព នៅក្នុងប្រទេសរបស់ខ្លួនក្រោយពីមានបណ្តឹងបរិហារផ្លូវការ ពីអាជ្ញាធរបារាំង អំពីអំពើព្រហ្មទណ្ឌដែលជនបរទេសរូបនេះបានប្រព្រឹត្តនៅក្នុងប្រទេសបារាំង អាជ្ញាអស់ជំនុំ ពុំអនុវត្តនៅក្នុងប្រទេសបារាំងឡើយ។ ដូច្នេះ ជនបរទេសរូបនេះក៏អាចត្រូវបានចោទប្រកាន់ នៅក្នុងប្រទេសបារាំងផងដែរ។

*លេខ98-80413 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៤៤ តុលាការកំពូលបារាំង ១៧ មីនា ១៩៩៩។*

**អាជ្ញាអស់ជំនុំ អនុវត្តចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តឡើងនៅក្រៅប្រទេសបារាំង៖** នៅក្នុងករណីជនណាម្នាក់ ត្រូវបានជំនុំជម្រះនៅបរទេសចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តឡើង នៅក្រៅដែនដីបារាំង។

*លេខ97-82424 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣៣១ តុលាការកំពូលបារាំង ៣ ធ្នូ ១៩៩៨។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៦ មាត្រា៣៦៨ និងមាត្រា៦៩២។ មាត្រាទាំងនេះបង្កើតគោលការណ៍អាជ្ញាអស់ជំនុំ និងលទ្ធភាពពុំអាចចោទប្រកាន់ជនជាប់ចោទពីរដងចំពោះអំពើតែមួយ។

# មាត្រា ១៣៖ បណ្តឹងរដ្ឋប្បវេណី និងព្យសនកម្ម

*បណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុវត្តដោយជនរងគ្រោះនៃបទល្មើស។ ដើម្បីទទួលការជួសជុលបាន ព្យសនកម្មត្រូវតែ:*

*- ជាផលវិបាកផ្ទាល់នៃបទល្មើស*

*- ជាព្យសនកម្មផ្ទាល់ខ្លួន*

*- បានកើតឡើងពិប្រាកដ និងនាពេលបច្ចុប្បន្ន។*

*ព្យសនកម្ម អាចជាព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬខាងផ្លូវចិត្ត។*

## ការអនុវត្តក្នុង អ.វ.ត.ក

**ព្យសនកម្មពុំចាំបាច់កើតឡើង ដោយផ្ទាល់នោះទេ៖** ព្យសនកម្ម នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែកើតឡើងជាលក្ខណៈបុគ្គល ប៉ុន្តែពុំចាំបាច់កើតឡើងដោយផ្ទាល់នោះទេ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៨៣។ រឿងក្តីឌុច៖ សាលដីកា អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ៤១៨។*

**បណ្តឹងរដ្ឋប្បវេណី តាមរយៈព្យសនកម្មដោយប្រយោល ពុំកម្រិតត្រឹមប្រភេទបុគ្គលជាក់លាក់ឡើយ៖** ជាឧទាហរណ៍ ពុំត្រូវបានកម្រិតត្រឹមសមាជិកគ្រួសារនោះទេ ក៏ប៉ុន្តែនៅក្នុងប្រព័ន្ធច្បាប់ខំមិនឡ វាអាចរួមបញ្ចូលទាំងសហព័ទ្ធ សាច់ញាតិសាច់ឆ្ងាយ មិត្តភ័ក្រ្ត និងឪពុកម្តាយ ឬកូនចិញ្ចឹមជាក់ស្តែង និងសិទ្ធិវ័ន្ត។

*រឿងក្តីឌុច៖ សាលដីកា អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ៤១៨។*

**ការបង្ហាញភស្តុតាង អំពីផលប៉ះពាល់ដោយផ្ទាល់លើជនរងគ្រោះមិនផ្ទាល់៖** ជនរងគ្រោះមិនផ្ទាល់ ត្រូវបង្ហាញចំណងនៃសេចក្តីស្រលាញ់ពិសេស និងការពឹងផ្អែក ដែលពាក់ព័ន្ធនឹងខ្លួនតាមផ្លូវអារម្មណ៍ផ្លូវកាយ ឬសេដ្ឋកិច្ចជាមួយនឹងជនរងគ្រោះផ្ទាល់។ ប្រសិនបើពុំមានចំណងនេះទេ ក៏គ្មានព្យសនកម្មណាមួយនឹងអាចកើតចេញ ពីការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយឡើយ។

*រឿងក្តីឌុចៈ សាលដីកា អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ៤៤៧។*

**ព្យសនកម្ម ត្រូវតែជាលទ្ធផលផ្ទាល់ពីអំពើរបស់ជនជាប់ចោទ៖** អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបង្ហាញនូវព្យសនកម្ម ដែលជាលទ្ធផលដោយផ្ទាល់ពីអំពើរបស់ជនជាប់ចោទ ដែលកំពុងតែស្ថិតនៅក្រោមការស៊ើបអង្កេត។

*រឿងក្តីឌុចៈ សាលក្រម អ.វ.ត.ក អ.ជ.ស.ដ ២៦ កក្កដា ២០១០ កថាខណ្ឌ៦៤៧។*

**ការច្រាលចោលពាក្យស្នើសុំ ដែលពុំបានបង្ហាញនូវព្យសនកម្មដោយផ្ទាល់៖** ចៅក្រមស៊ើបសួរអាចច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ប្រសិនបើគេរកឃើញថាពាក្យសុំទាំងនោះ ពុំបានបង្ហាញព្យសនកម្ម ដោយផ្ទាល់ពីសកម្មភាព ដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៧ មេសា ២០១០ កថាខណ្ឌ៤៨។*

**ការអនុវត្តសិទ្ធិរបស់ជនរងគ្រោះមិនផ្ទាល់ដោយស្វ័យភាពពីសិទ្ធិរបស់ជនរងគ្រោះដោយផ្ទាល់៖** ដូច្នេះជនរងគ្រោះមិនផ្ទាល់ អាចទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងករណីដែលជនរងគ្រោះដោយផ្ទាល់នោះ នៅរស់រានមានជីវិត និងពុំបន្តធ្វើបណ្តឹងរបស់ខ្លួនដោយខ្លួនឯង។

*រឿងក្តីឌុចៈ សាលដីកា អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ៤១៨។*

**ជនរងគ្រោះ ដែលចោទប្រកាន់អង្គហេតុថ្មី៖** ជនរងគ្រោះ ដែលមានបំណងស្នើសុំឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចចោទប្រកាន់លើអង្គហេតុថ្មី ក្នុងគោលបំណងឲ្យមានការស៊ើបអង្កេតឡើយ ប៉ុន្តែអាចចោទប្រកាន់អង្គហេតុថ្មី ដែលទំនងជាអាចបង្ហាញចំណងហេតុ និងបច្ច័យរវាងការខូចខាត ដែលទទួលរងដោយជនរងគ្រោះ និងយ៉ាងហោចណាស់ឧក្រិដ្ឋកម្មមួយ ដែលត្រូវបានចោទប្រកាន់ដាក់បន្ទុក លើជនត្រូវចោទ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរួចស្រាប់ហើយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៤២។*

**ទំនាក់ទំនងហេតុ និងបច្ច័យលើជនត្រូវចោទរួមជាសមូហភាព អាចមានលក្ខណៈគ្រប់គ្រាន់៖** នៅក្នុងបណ្តឹងទាមទារ ពីជនជាប់ចោទច្រើននាក់ក្នុងនាមបុគ្គល និងក្នុងនាមជាក្រុមសមូហភាព ដែលបានធ្វើសកម្មភាពរួមគ្នា នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម (ឬទម្រង់ នៃការទទួលខុសត្រូវផ្សេងៗទៀត) អ្នកដាក់ពាក្យសុំក៏អាច

បង្ហាញចំណងហេតុ និងបច្ច័យ ជាមួយនឹងជនត្រូវបានចោទរួមជាសមូហភាព ជាជាងជាមួយនឹងជនត្រូវចោទម្នាក់ៗ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៧១-៧៣។*

**ព្យសនកម្មផ្លូវចិត្តត្រូវបានសន្មត ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើ អ្នកដាក់ពាក្យសុំ ជាសមាជិកនៅក្នុងក្រុម ដែលត្រូវបានដៅទុក៖** ក្នុងករណីពាក់ព័ន្ធ ទៅនឹងឧក្រិដ្ឋកម្មទាំងឡាយ ដូចជាអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ នៅពេលអ្នកដាក់ពាក្យសុំ ជាជនរងគ្រោះមិនផ្ទាល់ (ឧទាហរណ៍ ជាសាក្សី ឬបុគ្គលដែលបានដឹងអំពីឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់) ព្យសនកម្មផ្លូវចិត្តត្រូវបានសន្មតថា បានកើតឡើងលើបុគ្គលនេះ ប្រសិនបើអ្នកដាក់ពាក្យសុំ ទំនងជាសមាជិកនៅក្នុងក្រុម ឬសហគមន៍ត្រូវបានដៅទុក បើទោះពុំមែនជាជនរងគ្រោះដោយផ្ទាល់ក៏ដោយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៩៣។*

**ព្យសនកម្មខាងសម្ភារៈ៖** ព្យសនកម្មរួមបញ្ចូលទាំងការបាត់បង់ទ្រព្យសម្បត្តិ ឬចំណូល។

*រឿងក្តីឌុច៖ សាលក្រម អ.វ.ត.ក អ.ជ.ស.ដ ២៦ កក្កដា ២០១០ កថាខណ្ឌ៦៤១។*

**ព្យសនកម្មខាងផ្លូវចិត្ត៖** ព្យសនកម្មអាចរួមទាំងបញ្ចូលវិបល្លាសស្មារតីឬជំងឺផ្លូវចិត្ត ដូចជាជំងឺបាក់ស្បាត។

*រឿងក្តីឌុច៖ សាលក្រម អ.វ.ត.ក អ.ជ.ស.ដ ២៦ កក្កដា ២០១០ កថាខណ្ឌ៦៤១។ រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៨៣។*

**ការខូចខាតខាងផ្លូវចិត្ត អាចកើតចេញពីឧក្រិដ្ឋកម្មប្រឆាំងគ្រួសារសាច់ជិត និងបុគ្គលច្រើនទៀត ៖** ការខូចខាតខាងផ្លូវចិត្ត ពុំគួរត្រូវបានគេបកស្រាយដោយចង្អៀតថា កើតចេញពីឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវបានប្រព្រឹត្តមកលើសមាជិកគ្រួសារសាច់ជិតនោះទេ។ ប៉ុន្តែ បុគ្គលជាច្រើននាក់ទៀត ព្រមទាំងរួមបញ្ចូលទាំងគ្រួសារសាច់ឆ្ងាយ មិត្តភ័ក្រ្ត អ្នកជិតខាង និងអ្នកទាំងឡាយ ដែលបានបង្ហាញពីចំណងទាក់ទងផ្សេងទៀតនៅក្នុងវប្បធម៌ និងសង្គមកម្ពុជា។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជា*

*ដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៤៩ ៨៧ និង៨៨។*

**ភាពរងគ្រោះខាងផ្លូវចិត្ត ត្រូវពិចារណាទៅតាមបរិបទ៖** ក្នុងការវាយតម្លៃ អំពីព្យសនកម្មខាងផ្លូវចិត្ត នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វាមានភាពចាំបាច់ដែលគេត្រូវតែពិចារណាលើភាពរងគ្រោះ នៅក្នុងបរិបទសង្គម និងវប្បធម៌ នៅពេលដែលឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នោះបានកើតឡើង។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៨៣ និង៨៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន២៣ និងវិធាន២៣ស្ទួន។ វិធាន២៣ ចែងអំពី"គោលការណ៍ទូទៅ"នៃការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក ដោយប្បញ្ញត្តិថា ការចូលរួមនេះមានគោលបំណងទាមទារសំណងផ្លូវចិត្ត និងសំណងជាសមូហភាព។ វិធាន២៣ស្ទួន មានបទប្បញ្ញត្តិស្រដៀងគ្នាខ្លាំងទៅនឹងមាត្រា១៣ ស្តីពីបទដ្ឋាននៃភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក៏ប៉ុន្តែវិធាន២៣ស្ទួននេះ ពុំបានចែងអំពីលក្ខខណ្ឌទាមទារថា ព្យសនកម្មពិតជាបានកើតឡើង និងកើតមាននៅពេលបច្ចុប្បន្នឡើយ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ផ្អែកលើមូលដ្ឋាននៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បារាំង ពោលគឺតុលាការកំពូល។*

**ព្យសនកម្មដែលជនរងគ្រោះបានចោទប្រកាន់ ត្រូវតែជាប់ទាក់ទងដោយផ្ទាល់ទៅនឹងបទល្មើស ដែលត្រូវបានចោទប្រកាន់៖** ដើម្បីទាមទារសំណង។

*លេខ 00-86244 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៤ តុលាការកំពូលបារាំង ១៩ កុម្ភៈ ២០០២។*

**បុគ្គលទាំងឡាយដែលទទួលរងការខូចខាត ដោយផ្ទាល់ខ្លួនពីបទល្មើស មានសិទ្ធិទទួលបានសំណង៖** ករណីនេះ មិនគិតពីលក្ខណៈនៃការខូចខាត ឬបុគ្គលដែលបង្កការខូចខាតឡើយ។

*លេខ 91-85925 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៤៩ តុលាការកំពូលបារាំង ២៨ តុលា ១៩៩២។*

**ព្យសនកម្ម ដែលកើតឡើងត្រូវតែជាក់លាក់ និងកើតមាននៅក្នុងពេលបច្ចុប្បន្ន ដើម្បីទទួលបានសំណង៖** ទោះបីជាយ៉ាងនេះក្តី តុលាការក៏អាចសម្រេចផ្តល់នូវសំណង ចំពោះការខូចខាត នាពេលអនាគត ដែលបណ្តាលមកពីព្យសនកម្មលើជនរងគ្រោះ។

*លេខ 80-92326 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៩៨ តុលាការកំពូលបារាំង ១៦ កុម្ភៈ ១៩៨១ (ព្យសនកម្ម ត្រូវកើតឡើងជាក់លាក់ និងកើតមាននៅពេលបច្ចុប្បន្ន)។ លេខ 86-91206 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៨០ តុលាការកំពូលបារាំង ៦ ឧសភា ១៩៨៧ (ព្យសនកម្មនាពេលអនាគត)។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា២។ មាត្រានេះ បង្កើតបានជាសិទ្ធិដាក់បណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណង ចំពោះការខូចខាតដែលបានទទួលរងដោយសារបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។

# មាត្រា ១៦៖ បណ្ដឹងរដ្ឋប្បវេណីរបស់សិទ្ធិវ័ន្តនៃជនរងគ្រោះ

*ក្នុងករណីមរណភាពនៃជនរងគ្រោះ បណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានផ្ដើមធ្វើ ឬបន្តបានដោយសិទ្ធិវ័ន្ត។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**សិទ្ធិវ័ន្ត ក៏អាចបន្តបណ្ដឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ ដែលបានទទួលមរណភាពបាន៖** ច្បាប់កម្ពុជា អនុញ្ញាតឲ្យសិទ្ធិវ័ន្តរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានទទួលមរណភាព បន្តនូវបណ្ដឹងរដ្ឋប្បវេណី ក្នុងនាមនៃភាគីដែលបានទទួលមរណភាពនេះបាន។

*រឿងក្ដីឌុចៈ ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានទទួលមរណភាព អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០០៩ កថាខណ្ឌ១០។*

**សិទ្ធិវ័ន្ត អាចដាក់បណ្ដឹងរដ្ឋប្បវេណី ក្នុងនាមខ្លួនឯងបាន ប្រសិនបើមរណភាពរបស់ជនរងគ្រោះជាប់ទាក់ទងនឹងបទល្មើស៖** ប្រសិនបើសិទ្ធិវ័ន្តមិនអាចបង្ហាញថា ជនរងគ្រោះបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មុនពេលទទួលមរណភាព សិទ្ធិវ័ន្តរូបនេះ អាចដាក់នូវបណ្ដឹងក្នុងនាមខ្លួនឯង ដើម្បីទាមទារសំណងចំពោះការខូចខាតផ្ទាល់ខ្លួន ដោយសារមរណភាពនៃជនរងគ្រោះនេះបាន ដរាបណាមរណភាពនេះ ជាប់ទាក់ទងដោយផ្ទាល់នឹងបទល្មើស ដែលជនត្រូវចោទត្រូវបានចោទប្រកាន់។

*រឿងក្ដីឌុចៈ ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានទទួលមរណភាព អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០០៩ កថាខណ្ឌ១២។ រឿងក្ដីនួន ជា និង ខៀវ សំផន៖ ការស្នងតំណែងដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវទទួលមរណភាពឈ្មោះ វ៉ាន់ សារី នៅក្នុងសំណុំរឿង ០០២ អ.វ.ត.ក អ.ជ.ស.ជ ១៦ កញ្ញា ២០១៣ កថាខណ្ឌ១-៣។ ការស្នងតំណែង ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានទទួលមរណភាព នៅក្នុងសំណុំរឿង ០០២ អ.វ.ត.ក អ.ជ.ស.ជ ២១ ឧសភា ២០១៣ កថាខណ្ឌ៦។ ការស្នងតំណែងដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលមរណភាព ឈ្មោះ ម៉ៅ សុន នៅក្នុងសំណុំរឿង ០០២ អ.វ.ត.ក អ.ជ.ស.ជ ២៣ មករា ២០១៤ កថាខណ្ឌ៣។ រឿងក្ដីនួន ជា និងខៀវ សំផន៖ ការស្នងតំណែងដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលមរណភាព ឈ្មោះ មាស ធុនជ័យ នៅក្នុងសំណុំរឿង ០០២ អ.វ.ត.ក អ.ជ.ស.ជ ២៦ កុម្ភៈ ២០១៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធានផ្ទៃក្នុងនៃអ.វ.ត.ក ពុំមានចែងវិធានដូចគ្នានេះទេ។ ទោះបីជាយ៉ាងនេះក្តី គោលការណ៍នេះ ត្រូវបានបង្កើតឡើងនៅក្នុងករណីយុត្តិសាស្ត្រនៃអ.វ.ត.ក។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ផ្អែកលើមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍ បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បារាំង ពោលគឺតុលាការកំពូល។*

**សិទ្ធិវន្តអាចផ្តួចផ្តើម បណ្តឹងរដ្ឋប្បវេណីបាន៖** ទោះបីជាសិទ្ធិវន្តនៃជនរងគ្រោះ ដែលបានទទួលមរណភាពមិនអាចធ្វើសំណើ ដោយផ្ទាល់ ក្នុងការស្នើសុំឲ្យដំណើរការបណ្តឹងអាជ្ញា ក៏ដោយសិទ្ធិវន្តអាច នៅផ្តួចផ្តើមបណ្តឹងរដ្ឋប្បវេណីបានដដែល។

*លេខ 03-87065 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៩៦ តុលាការកំពូលបារាំង ២៧ មេសា ២០០៤ (សិទ្ធិវន្តមិនអាចធ្វើ សំណើសុំឲ្យដំណើរការបណ្តឹងអាជ្ញានោះទេ)។ លេខ05-87379 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១ តុលាការកំពូលបារាំង ៩ ឧសភា ២០០៨ (អាចផ្តួចផ្តើមបណ្តឹងរដ្ឋប្បវេណីបាន)។*

**ភាពអាចផ្ទេរបាន នៃបណ្តឹងរដ្ឋប្បវេណី៖** បណ្តឹងរដ្ឋប្បវេណីដែលត្រូវបានផ្តួចផ្តើម ដោយជនរងគ្រោះនៅមុនពេលមរណភាព របស់ខ្លួនអាចផ្ទេរទៅឲ្យសិទ្ធិវន្តរបស់មរណជននេះបាន។

*លេខ 84-90584 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣០៩ តុលាការកំពូលបារាំង ៩ តុលា ១៩៨៥។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា២។ មាត្រានេះបង្កើតបានជាសិទ្ធិដើម្បីដាក់បណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងចំពោះការខូចខាត ដែលបានទទួលរងដោយសារបទឧក្រិដ្ឋ មជ្ឈិម ឬបទលហុ។

# មាត្រា ៤៤៖ ការបើកការស៊ើបសួរ

*ក្នុងករណីបទឧក្រិដ្ឋព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។ ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។*

*ដីកាបញ្ជូនរឿងឱ្យស៊ើបសួរចេញដោយព្រះរាជអាជ្ញារួមមានៈ*

*- សេចក្ដីសង្ខេបនៃអង្គហេតុ*

*- ការកំណត់ឈ្មោះបទល្មើស*

*- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ និង*

*- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរប្រសិនបើអាចកំណត់បាន។*

*ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។*

*ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។*

## ការអនុវត្តក្នុង អ.វ.ត.ក

**ចៅក្រមស៊ើបសួរ មានឆន្ទានុសិទ្ធិធំធេងលើកិច្ចស៊ើបសួរ៖** ចៅក្រមស៊ើបសួរមានអំណាចក្នុងការសម្រេចលើភាពចាំបាច់ ឬកាលានុវត្តភាពក្នុងការសម្រេចកិច្ចស៊ើបសួររបស់ខ្លួន។

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និងឌុចៈ បណ្ដឹងឧទ្ធរណ៍លើកំណត់ហេតុនៃការស្ដាប់ចម្លើយ ស្ដីពីការរៀបការដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ អ.វ.ត.ក អ.ប.ជ ២១ កក្កដា ២០១០ កថាខណ្ឌ១៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៣។ វិធាននេះស្រដៀងនឹងមាត្រា៤៤ ប៉ុន្តែវាទាមទារឲ្យព្រះរាជអាជ្ញាជូនដំណឹងចៅក្រមស៊ើបសួរអំពីភស្តុតាងដោះបន្ទុក។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផ្អែកលើមូលដ្ឋាននៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បារាំងពោលគឺតុលាការកំពូល។*

**បណ្តឹងអាជ្ញា ត្រូវបានផ្តួចផ្តើមឡើងយ៉ាងពេញលេញតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់រដ្ឋអាជ្ញា៖** បណ្តឹងអាជ្ញានេះ គេអាចផ្តួចផ្តើមឡើងបាន ទោះបីជាពាក្យសុំតាំងខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងបណ្តឹងអាជ្ញានេះ ត្រូវបានប្រកាសមិនអាចទទួលយកបានក៏ដោយ។

*លេខ 83-92667 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៩០ តុលាការកំពូលបារាំង ៨ វិច្ឆិកា ១៩៨៣ ។*

**វិសាលភាពដ៏កម្រិត នៃចៅក្រមស៊ើបសួរ៖** អាចត្រឹមតែស៊ើបអង្កេតអង្គហេតុ ដែលត្រូវបានរៀបរាប់ជាក់លាក់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលខ្លួនបានទទួលប៉ុណ្ណោះ។

*លេខ73-90372 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២១៧ តុលាការកំពូលបារាំង ១០ ឧសភា ១៩-៧៣។*

**ការលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អាចត្រូវបានលុបចោល ប្រសិនបើដីកានោះ ពុំបានបំពេញនូវលក្ខខណ្ឌនីត្យានុកូលចាំបាច់នៃអត្ថិភាពរបស់វា។

*លេខ 01-87656 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១២៩ តុលាការកំពូលបារាំង ៥ មិថុនា ២០០២។*

**ចៅក្រមស៊ើបសួរ ត្រូវចោទប្រកាន់ជនណាម្នាក់ដែលមានឈ្មោះជាក់លាក់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ៖** ប្រសិនបើ ចៅក្រមស៊ើបសួរចង់ស្តាប់ចម្លើយជនរូបនេះ។

*លេខ83-94762 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៥៨ តុលាការកំពូលបារាំង ១៤ កុម្ភៈ ១៩៨៤។*

**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវធ្វើឡើងដោយរដ្ឋអាជ្ញា ដើម្បីកម្រិតអំពីវិសាលភាពនៃចៅក្រមស៊ើបសួរ នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបែបនេះ ពុំមានអានុភាពទេ។

*លេខ76-91442 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១១២ តុលាការកំពូលបារាំង ២៤ មីនា ១៩៧-៧។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៨០។ មាត្រានេះ អនុញ្ញាតឲ្យអនុវត្តបណ្តឹងអាជ្ញានៅក្នុងដំណាក់កាលមុនអង្គសេចក្តី រួមទាំងវិសាលភាពនៃការស៊ើបសួរ ដូចបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលធ្វើឡើងដោយរដ្ឋអាជ្ញា។

# មាត្រា ៩៣៖ កំណត់ហេតុលើការស្តាប់ចម្លើយ

*មន្ត្រីនគរបាលយុត្តិធម៌អាចបង្គាប់ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូប ដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស្តាប់ចម្លើយជនទាំងនោះ។ ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ។*

*កំណត់ហេតុជាលាយលក្ខណ៍អក្សរ ត្រូវដកស្រង់តាមដោយត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់បុគ្គលដែលបានផ្តល់ចម្លើយ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែ ដែលស្បថថា និយាយការពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន។ អ្នកបកប្រែ មិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាលកងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងក្តីជាមួយគ្នាបានទេ។*

*ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយបុគ្គល ដែលបានឆ្លើយមុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ។ មន្ត្រីនគរបាលយុត្តិធម៌ អាចស្នើសុំអ្នកបកប្រែបាន។ កាលណាបុគ្គលនោះ មិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**សំណើសុំឲ្យពិនិត្យមើលឡើងវិញ លើកំហុសនៃការបកប្រែ៖** ការបកប្រែខុស ដែលត្រូវបានរកឃើញ ពុំចាំបាច់តម្រូវឲ្យពិនិត្យមើលឡើងវិញដើម្បីរកកំហុស នៅក្នុងចម្លើយរបស់សាក្សីទាំងអស់នោះទេ។ ដើម្បីដោះស្រាយផលប៉ះពាល់ដែលអាចកើតឡើង ដោយសារការបកប្រែខុស អង្គជំនុំជម្រះ គួរតែថ្លឹងថ្លែងធនធានដែលមានស្រាប់ ទំហំនៃលទ្ធភាពពិនិត្យឡើងវិញ និងព្យសនកម្ម ដែលប៉ះពាល់ដល់ភាគីស្នើសុំពិនិត្យមើលឡើងវិញ។

*រឿងក្តីអៀង ធីរិទ្ធ៖ ការជូនដំណឹងនៃកំហុសនៅក្នុងឯកសារបកប្រែ អ.វ.ត.ក អ.ប.ជ ១៧ ធ្នូ ២០១០ កថាខណ្ឌ៧-៨ និងកថាខណ្ឌ១០-១១។*

**ជនត្រូវចោទអាចពិនិត្យមើល ឡើងវិញនូវលទ្ធផលនៃការស៊ើបអង្កេត ប៉ុន្តែពុំមែននីតិវិធីនៃការស៊ើបសួរឡើយ៖** ជនត្រូវចោទមានសិទ្ធិពិនិត្យមើលឡើងវិញនូវលទ្ធផលនៃការស៊ើបអង្កេតពោលគឺជាលទ្ធផលនៃការស៊ើបអង្កេតពុំមែនពិនិត្យមើលឡើងវិញនូវនីតិវិធី ដែលត្រូវ

បានប្រើប្រាស់ដោយ អាជ្ញាធរស៊ើបសួរនោះទេ។

*រឿងក្តីអៀង សារី៖ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងកស្តុតាងទទួលបានតាមរយៈពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ៣១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន២៥ និងវិធាន៦២។ វិធាន២៥នៃវិធានផ្ទៃក្នុង ចែងអំពីកំណត់ហេតុនៃការស្តាប់ចម្លើយ និងបានបញ្ញត្តិបន្ថែមទៀតថា ក្នុងករណីដែលអាចធ្វើទៅបានការសម្ភាសន៍ជាមួយនឹងជនសង្ស័យ ឬជនត្រូវចោទ គួរត្រូវថតខ្សែអាត់ឬខ្សែវីដេអូផងដែរ។ វិធាន៦២នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យចៅក្រមស៊ើបសួរ ធ្វើប្រតិភូកម្មអំណាចស៊ើបសួរឲ្យទៅអង្គភាពក្រោមបង្គាប់នៃអ.វ.ត.ក ដូចជានគរបាលយុត្តិធម៌ និងតម្រូវឲ្យនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុនៃការបំពេញកិច្ចស៊ើបសួរ ដែលត្រូវបានធ្វើប្រតិភូកម្មជូនខ្លួន។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ការសួរចម្លើយ គឺជាវិធានការស៊ើបសួរមួយ ដែលមានគោលបំណង ប្រមូលចងក្រងភស្តុតាង៖** ភស្តុតាងបែបនេះ នឹងកំណត់ក្របខណ្ឌ នៃបទល្មើសដូចបានចោទប្រកាន់ នឹងត្រូវយកមកពិចារណានៅក្នុងពេលជំនុំជម្រះ។

*រឿងក្តី CAN ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ១២ កក្កដា ១៩៨៤ កថាខណ្ឌ៥០។*

**សិទ្ធិរបស់ជនដែលត្រូវបានសួរចម្លើយ៖** ជនដែលត្រូវបានគេសួរចម្លើយ ត្រូវបានការពារដោយសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូចជាសិទ្ធិទទួលបានជំនួយតាមផ្លូវច្បាប់ សិទ្ធិនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

*រឿងក្តី IMBRIOSCIA ទល់នឹងប្រទេសស្វីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៤ វិច្ឆិកា ១៩៩៣ កថាខណ្ឌ៣៦ (សិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានជំនួយតាមផ្លូវច្បាប់ ត្រូវអនុវត្តភ្លាមៗ នៅពេលមានបទចោទជាធរមាន)។ រឿងក្តីJALLOH ទល់នឹងប្រទេសអាល្លឺម៉ង់ តុលាការសិទ្ធិមនុស្សអឺរ៉ុប ១១ កក្កដា ២០០៦ កថាខណ្ឌ១០០ (សិទ្ធិនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺជាសិទ្ធិមូលដ្ឋាន*

*នៃនីតិវិធីតាមផ្លូវច្បាប់ដ៏យុត្តិធម៌)។*

**ការប្រឹក្សាផ្លូវច្បាប់ មានសារៈសំខាន់ជាមូលដ្ឋាននៅក្នុងអំឡុងពេលសួរចម្លើយ៖** ការផ្តល់ជំនួយមេធាវីគួរតែទទួលបាន ចាប់តាំងពីពេលសួរចម្លើយជនសង្ស័យលើកដំបូង លើកលែងតែមានហេតុផលចាប់បង្ខំណាមួយនៅក្នុងការកំហិតសិទ្ធិនេះ។ សិទ្ធិទទួលបាននូវជំនួយផ្លូវច្បាប់ គឺកាន់តែមានសារៈសំខាន់ជាងនេះទៀតគឺ នៅពេលជនជាប់ចោទពុំត្រូវបានអាជ្ញាធរមានសមត្ថកិច្ចជូនដំណឹងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

*រឿងក្តីSALDUZទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ វិច្ឆិកា ២០០៨ កថាខណ្ឌ៥៥ (ការផ្តល់ជំនួយនេះគួរទទួលបានតាំងពីពេលសួរចម្លើយលើកដំបូងលើកលែងតែមានហេតុផល ចាប់បង្ខំណាមួយ)។ រឿងក្តី BRUSCO ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៤ តុលា ២០១០ កថាខណ្ឌ៤៥ (ការខកខានក្នុងការជូនដំណឹង អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប)។*

**សិទ្ធិទទួលជំនួយពីអ្នកបកប្រែ គឺចាំបាច់ត្រូវផ្តល់ឲ្យជាក់ស្តែង និងដោយប្រសិទ្ធភាព៖** កាតព្វកិច្ចនៃអាជ្ញាធរមានសមត្ថកិច្ច ពុំបានកម្រិតត្រឹមការចាត់តាំងអ្នកបកប្រែប៉ុណ្ណោះទេ ប៉ុន្តែវាអាចពង្រីករហូតដល់កម្រិតនៃការគ្រប់គ្រង នាពេលក្រោយៗលើភាពត្រឹមត្រូវនៃការបកប្រែដែលបានផ្តល់ជូន។

*រឿងក្តី HERMI ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៨ តុលា ២០០៦ កថាខណ្ឌ៧០។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៦(១)។ មាត្រានេះការពារសិទ្ធិផ្សេងៗរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានសវនាការសាធារណៈ និងយុត្តិធម៌ នៅក្នុងពេលមួយសមស្រប។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ផ្អែកលើមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍ បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បារាំង ពោលគឺតុលាការកំពូល។*

**ការសួរចម្លើយ និងកិច្ចទាំងឡាយដែលត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ពុំគួរចាត់ទុកជាមោឃៈឡើយ ប្រសិនបើជនដែលត្រូវបានសួរចម្លើយ ត្រូវបានស្តាប់ស្របតាមនីតិវិធីចាំបាច់ នៅមុនពេលឃុំខ្លួន៖** ករណីនេះរួមទាំងការជូនដំណឹង អំពីសិទ្ធិពាក់ព័ន្ធទៅនឹងស្ថានភាពនេះ។ ការពិតនៅពីក្រោយបទល្មើសដែលត្រូវបានសង្ស័យនេះត្រូវតែធ្វើការផ្ទៀងផ្ទាត់។

*លេខ95-84446/96-85915 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៦៦ តុលាការកំពូលបារាំង ១៩ កុម្ភៈ ១៩៩៧។*

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរចម្លើយ ត្រូវចាត់ទុកជាមោឃៈ នៅពេលដែលកត់ត្រាទុកចម្លើយផ្ទាល់មាត់ទាំងឡាយណា ដែលពុំចាំបាច់៖** ចម្លើយទាំងនេះ គឺជាចម្លើយរបស់ជនស្ថិតនៅក្នុងការឃុំខ្លួន ដែលពុំយល់ព្រមឲ្យដាក់បញ្ចូល នៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ។

*លេខ 07-80807 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១០២ តុលាការកំពូលបារាំង ៣ មេសា ២០០៧។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៦១។ មាត្រានេះចែងអំពីនីតិវិធីឃុំខ្លួននៅក្នុងអំឡុងពេលស៊ើបអង្កេត ជាពិសេសរួមទាំងនីតិវិធីទាញយកចម្លើយផ្ទាល់មាត់ និងនីតិវិធីកត់ត្រាទុកនៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។

# មាត្រា ៩៦៖ ការឃាត់ខ្លួន

*ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ ក៏អាចឃាត់ខ្លួនបុគ្គល ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញៈ*

*- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន*
*- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។*

*មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញានូវវិធានណាមួយនៃការឃាត់ខ្លួន ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ។*

*ការឃាត់ខ្លួន មានថិរវេលាអតិបរមា៤៨ (សែសិបប្រាំបី) ម៉ោង។ ថិរវេលា ត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។*

*ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។ ការពន្យារពេលនេះ ត្រូវសុំទៅព្រះរាជអាជ្ញាជាមុន ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព។ ការអនុញ្ញាតឱ្យពន្យារពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ការពន្យារ គឺជាវិធានការពិសេស។ ការពន្យារនេះ មិនអាចឱ្យលើសពី២៤ (ម្ភៃបួន) ម៉ោងឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។*

*ការពន្យារ មិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន។*
*ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ម៉ោងឡើយ។*

*ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ម៉ោងឡើយ។*

*ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ម៉ោងឡើយ។*

*ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ម៉ោងឡើយ។*
*អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ។*

# ការអនុវត្តក្នុង អ.វ.ត.ក

**ការដោះលែង ដោយហេតុផលមនុស្សធម៌៖** បុគ្គលទាំងឡាយ អាចត្រូវបានដោះលែងពីការឃុំខ្លួន ដោយហេតុផលមនុស្សធម៌ ក្នុងករណីដែលមានភស្តុតាងបង្ហាញថា ស្ថានភាពសុខភាពរបស់ជននេះ ពុំមានវិសមិតភាពនឹងការឃុំខ្លួនទេនោះ។

*រឿងក្តីខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងការពន្យារពេលឃុំខ្លួន បណ្តោះអាសន្ន និងបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការបដិសេធសំណើសុំ អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ៨១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥១។ វិធាននេះ មានបទប្បញ្ញត្តិស្រដៀងគ្នាមែនទែនទៅនឹងមាត្រា៩៦ ប៉ុន្តែវិធាននេះ ចែងអំពីនីតិវិធីរៀបចំជាក់លាក់សម្រាប់ការពិនិត្យសុខភាព និងសម្រាប់ការធ្វើរបាយការណ៍នៃការឃាត់ខ្លួន ហើយវិធាននេះ បានដាក់កំហិតចំពោះការឃុំខ្លួនជនសង្ស័យ។ ចំណែកមាត្រា៩៦ អនុញ្ញាតឲ្យឃាត់ខ្លួនសាក្សី និងចែងអំពីប្រព្រឹត្តកម្មពិសេសចំពោះអនីតិជន។

# ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងយុត្តាធិការផ្សេងទៀត

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលប្បញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការរំលោភ៖ ការចាប់ខ្លួនដោយគ្មានដីកា គ្មានហេតុផល និងដោយពុំបាននាំខ្លួនភ្លាមៗមក ចំពោះមុខចៅក្រម៖** សិទ្ធិទាំងឡាយត្រូវបានរំលោភបំពាននៅក្នុងករណីដែលជនសង្ស័យ ត្រូវបានចាប់ខ្លួនដោយគ្មានដីកា គ្មានការជូនដំណឹងអំពីមូលហេតុ នៃការចាប់ខ្លួន និងដោយពុំបាននាំខ្លួនភ្លាមៗ មកចំពោះមុខចៅក្រមក្រោយពេលចាប់ខ្លួន។

*រឿងក្តី WILSON ទល់នឹងប្រទេសហ្វីលីពីន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣០ តុលា ២០០៣ កថាខណ្ឌ៧.៥។*

**ការរំលោភ៖ ជាប់ឃុំរយៈពេល៧ថ្ងៃ ដោយពុំមានដីកាចាប់ខ្លួន ឬដោយពុំបាននាំខ្លួនមកចំពោះមុខចៅក្រម៖** ក្រោយពេលចាប់ខ្លួន សិទ្ធិរបស់ជនសង្ស័យ ក្នុងការទទួលបានការជូនដំណឹងភ្លាមៗ អំពីបទចោទដាក់បន្ទុកមកលើខ្លួន និងក្នុងការនាំខ្លួនភ្លាមៗមកចំពោះមុខចៅក្រម ត្រូវបានរំលោភបំពាន នៅពេលដែលជននោះ ត្រូវបានឃុំខ្លួនរយៈ

ពេល៧ថ្ងៃ ដោយពុំមានដីកាចាប់ខ្លួន ឬដោយពុំត្រូវបាននាំមកចំពោះមុខចៅក្រម។

*រឿងក្តី KURBANOVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៦ វិច្ឆិកា ២០០៣ កថាខណ្ឌ៧.២។*

**ការរំលោភ៖ ជាប់ឃុំរយៈពេល៧ថ្ងៃហួសរយៈពេលកំណត់តាមផ្លូវច្បាប់ ដោយពុំមានដីកាចាប់ខ្លួន៖** សិទ្ធិមានសេរីភាព សន្តិសុខ និងសិទ្ធិត្រូវនាំខ្លួនភ្លាមៗមកចំពោះមុខចៅក្រម ក្រោយពីពេលត្រូវចាប់ខ្លួន និងក្រោយពេលឃុំខ្លួន មានអានុភាពនៅពេលជនសង្ស័យ ត្រូវបានចាប់ខ្លួន ដោយពុំមានដីកាឃុំខ្លួន និងត្រូវបានឃុំខ្លួនហួសរយៈពេល ១៥ថ្ងៃ ដូចមានចែងតាមផ្លូវច្បាប់។

*រឿងក្តី CASAFRANCA DE GÓMEZ ទល់នឹងប្រទេសប៉េរូ គណៈកម្មាធិការ សិទ្ធិមនុស្ស អ.ស.ប ២២ កក្កដា ២០០៣ កថាខណ្ឌ ៧.២។*

**ការរំលោភ៖ ដីកាឃុំខ្លួន បានចេញក្រោយរយៈពេលកំណត់តាមផ្លូវច្បាប់៖** សិទ្ធិមានសេរីភាពត្រូវបានរំលោភបំពាន នៅពេលដីកាបានចេញលើសរយៈពេល៣ថ្ងៃ ក្រោយពេលជនសង្ស័យ ត្រូវបានចាប់ខ្លួនដោយផ្ទុយនឹងច្បាប់ក្នុងស្រុក ដែលកំណត់លក្ខខណ្ឌទាមទារឲ្យចេញដីកា ក្នុងរយៈពេល៧២ម៉ោង ក្រោយពេលចាប់ខ្លួន។

*រឿងក្តី GRIDIN ទល់នឹងសហព័ន្ធរុស្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ កក្កដា ២០០០ កថាខណ្ឌ៨.១។*

**ការរំលោភ៖ ការឃុំខ្លួនលើសរយៈពេលកំណត់ដោយពុំមានហេតុផល នៅមុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖** ការហាមឃាត់ការឃុំខ្លួនតាមទំនើងចិត្ត ត្រូវបានរំលោភបំពាន នៅពេលដែលជនណាម្នាក់នៅមុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានឃុំខ្លួនលើសរយៈពេល ដូចមានចែងនៅក្នុងច្បាប់ ដោយពុំបានផ្តល់ហេតុផល អំពីភាពចាំបាច់នៃការពន្យារពេលឃុំខ្លួន។

*រឿងក្តី BOLAÑOS ទល់នឹងប្រទេសអេក្វាឌ័រ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៦ កក្កដា ១៩៨៩ កថាខណ្ឌ៨.៣ និង៩។*

**ការរំលោភ៖ ការឆ្មក់ចូលក្នុងគេហដ្ឋាន និងការឃុំខ្លួនដោយពុំមានដីកាចាប់ខ្លួន៖** ការឆ្មក់ចូលទៅក្នុងគេហដ្ឋានឯកជន និងការឃុំខ្លួនជនណាម្នាក់ នាពេលក្រោយមក គឺជាការរំលោភសិទ្ធិ ដោយសារតែគ្មានដីកាឆែកឆេរ ឬដីកាចាប់ខ្លួនតាមផ្លូវច្បាប់នោះទេ។

*រឿងក្តី CORONEL និងជនផ្សេងទៀតទល់នឹងប្រទេសកូឡុំប៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៤ តុលា ២០០២ កថាខណ្ឌ៩.២ និង៩.៧។*

**ការរំលោភ៖ ការពន្យាររយៈពេល ១ ខែ នៅក្នុងការនាំជនជាប់ចោទមកចំពោះមុខចៅក្រម៖** ការពន្យាររយៈពេលជាងមួយខែ នៅក្នុងការនាំជនជាប់ចោទមក ចំពោះមុខចៅក្រម គឺជាការរំលោភលក្ខខណ្ឌដែលទាមទារឲ្យនាំខ្លួនជនណាម្នាក់ ដែលត្រូវបានចាប់ខ្លួន ឬឲ្យនាំខ្លួនជនជាប់ចោទមកភ្លាមៗ នៅចំពោះមុខចៅក្រម ដែលមានសមត្ថកិច្ចសម្រេចលើភាពស្របច្បាប់ នៃការឃុំខ្លួនជនជាប់ចោទ។

*រឿងក្តី KELLY ទល់នឹងប្រទេសចាម៉ៃកា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៨ មេសា*

*១៩៩១ កថាខណ្ឌ៥.៦។*

**ការរំលោភ៖ ការឃុំខ្លួនរយៈពេល២ខែ មុនពេលនាំខ្លួនមកចំពោះមុខចៅក្រម៖** ការនាំខ្លួនជនជាប់ឃុំមកចំពោះមុខចៅក្រម ២ខែ ក្រោយការចាប់ខ្លួន គឺពុំមែនជាការនាំខ្លួនមកចំពោះមុខចៅក្រមភ្លាមៗទេ។

*រឿងក្ដី BIRINDWA និង TSHISEKEDI ទល់នឹងប្រទេសហ្សាអៀ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៤ មេសា ១៩៨៩ កថាខណ្ឌ១២.៧ និង១៣ (ខ)។*

**ការរំលោភ៖ ការឃុំខ្លួនរយៈពេល៥ឆ្នាំ មុនពេលជំនុំជម្រះ៖** ការឃុំខ្លួនរយៈពេល៥ឆ្នាំ មុនពេលផ្ដួចផ្ដើមកិច្ចដំណើរការនីតិវិធី ប្រឆាំងនឹងជនណាម្នាក់ គឺជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយការពន្យារពេលពុំសមហេតុផល។

*រឿងក្ដី BOLAÑOS ទល់នឹងប្រទេសអេក្វាឌ័រ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៦ កក្កដា ១៩៨៩ កថាខណ្ឌ៨.៤ និង៩។*

**ការរំលោភ៖ ការបន្តការឃុំខ្លួនក្រោយពេលអនុញ្ញាតឲ្យដោះលែងមានសេរីភាព៖** ការរំលោភសិទ្ធិមានសេរីភាព ចំពោះការដកហូតសេរីភាព នៅក្រៅវិសាលភាពនៃនីតិវិធីច្បាប់ ជាធរមានមានអានុភាព នៅក្នុងករណី ដែលក្រោយពេលឃុំខ្លួន រយៈពេល ១ឆ្នាំ ចៅក្រម បានអនុញ្ញាតដោះលែងជនជាប់ឃុំឲ្យមានសេរីភាព ដោយមានលក្ខខណ្ឌ ប៉ុន្តែការឃុំខ្លួននៅតែបន្តបន្ថែម រហូតដល់ពេលការជំនុំជម្រះចាប់ផ្ដើម។

*រឿងក្ដី BAZZANO ទល់នឹងប្រទេសអ៊ុយរ៉ាហ្គាយ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៥ សីហា ១៩៧៩ កថាខណ្ឌ១០(i)។*

**កិច្ចការពារពិសេសដល់អនីតិជន៖** ជនជាប់ចោទជាអនីតិជន ត្រូវទទួលបានវិធានការពិសេស ស្ដីពីកិច្ចការពារ រួមទាំងការដោះលែងឲ្យមានសេរីភាពជាបណ្ដោះអាសន្ន និងកិច្ចប្រឹងប្រែងក្នុងការធានាសន្តិសុខ និងសុខុមាលភាព។

*រឿងក្ដី LAUREANO ATACHAHUA ទល់នឹងប្រទេសប៉េរូ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៥ មីនា ១៩៩៦ កថាខណ្ឌ៨.៧។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា៩(១) មាត្រា៩(២) និងមាត្រា១៧។ មាត្រា៩(១) និង៩(២) ការពារសិទ្ធិមានសេរីភាពនិងសន្តិសុខ និងសិទ្ធិទទួលបានការជូនដំណឹងអំពីហេតុផលនៃការចាប់ខ្លួន និងបទចោទ។ មាត្រា១៧ ចែងអំពីសិទ្ធិទាំងនេះដោយការពារប្រជាពលរដ្ឋពីការជ្រៀតជ្រែកដោយខុសច្បាប់ និងតាមទំនើងចិត្ត។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***
*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ត្រូវមានមូលដ្ឋានតាមផ្លូវច្បាប់ ចំពោះការដកហូតសេរីភាព៖** មូលដ្ឋានច្បាប់ នៃការដកហូតសេរីភាពត្រូវធ្វើយ៉ាងណា ឲ្យអាចទទួលយកបានពេញលេញ និងផ្អែកលើច្បាប់ជាក់លាក់ ដែលកំណត់និយមន័យអំពីបទល្មើសដើម្បីជៀសវាង នូវហានិភ័យនៃភាពធ្វើតាមទំនើងចិត្ត។

*រឿងក្តី AMUUR ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៥ មិថុនា ១៩៩៦ កថាខណ្ឌ៥០។*

**ចំណងទាក់ទងនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ៖** ការដកហូតសេរីភាព គឺអាចធ្វើទៅបានក្នុងករណីដែលជាប់ទាក់ទង ទៅនឹងកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ។

*រឿងក្តី CIULLA ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២២ កុម្ភៈ ១៩៨៩ កថាខណ្ឌ៣៨។*

**ត្រូវមានភាពសង្ស័យសមហេតុផលថា ជនជាប់ឃុំណាម្នាក់បានប្រព្រឹត្តបទល្មើស៖** លក្ខខណ្ឌនៃភាពសមហេតុសមផល ជាលក្ខខណ្ឌតម្រូវសន្មត អំពីអត្ថិភាពនៃអង្គហេតុ ឬព័ត៌មានដែលនឹងឲ្យអ្នកសង្កេតការណ៍ ដោយមិនលម្អៀងជឿជាក់ថា ជនដែលជាប់ពាក់ព័ន្ធនៃការសន្និដ្ឋាននេះ អាចធ្លាប់បានប្រព្រឹត្តបទល្មើស។ អ្វីដែលគេអាចចាត់ទុកថាជាភាពសមហេតុសមផលនោះ គឺវាអាស្រ័យលើកាលៈទេសៈទាំងអស់។

*រឿងក្តី FOX, CAMPBELL និងHARTLEYទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ៣០ សីហា ១៩៩០ កថាខណ្ឌ៣២។*

**កម្រិតនៃភាពសង្ស័យថា ជនណាម្នាក់អាចធ្លាប់បានប្រព្រឹត្តបទល្មើស៖** អង្គហេតុពុំចាំបាច់មានកម្រិតដូចគ្នានឹងអង្គហេតុទាំងឡាយណា ដែលចាំបាច់ដើម្បីផ្តល់យុត្តិកម្ម លើការសម្រេចឲ្យជាប់ពិរុទ្ធភាព ឬលើការចោទប្រកាន់ ដែលជាដំណាក់កាលបន្ទាប់មកទៀត នៅក្នុងការស៊ើបអង្កេតនោះទេ។

*រឿងក្តី MURRAY ទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៨ តុលា ១៩៩៤ កថាខណ្ឌ៥៥។*

**រយៈពេលនៃភាពសង្ស័យ៖** ភាពសង្ស័យថា ជនណាម្នាក់បានប្រព្រឹត្តបទល្មើស ត្រូវតែនៅមានអត្ថិភាពដោយហេតុថា ជននោះត្រូវបានគេឃាត់ខ្លួនដោយនគរបាល។ នេះជាលក្ខខណ្ឌតម្រូវមួយ សម្រាប់ការបន្តការឃុំខ្លួន។

*រឿងក្តី STÖGMÜLLER ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ១០ វិច្ឆិកា ១៩៦៩ កថាខណ្ឌ៤។ រឿងក្តី DE JONG, BAIJET និង VAN DEN BRINK ទល់នឹងប្រទេសហូឡង់*

*តុលាការសិទ្ធិមនុស្សអឺរ៉ុប ២២ ឧសភា ១៩៨៤ កថាខណ្ឌ៤៤។*

**ការនាំខ្លួនមក នៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចភ្លាមៗ៖** ជនជាប់ឃុំ ត្រូវនាំយកមកដោយស្វ័យប្រវត្តិ នៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចភ្លាមៗ ។ ការធ្វើដូច្នេះ គឺដើម្បីការពារកុំឲ្យមានការធ្វើទុក្ខបុកម្នេញមកលើជនជាប់ឃុំ និងការបំពានអំណាចដោយអាជ្ញាធរ។ កម្រិតនៃភាពបត់បែនពាក់ព័ន្ធនឹងសញ្ញាណនៃភាពបន្ទាន់ភ្លាមៗនេះ មានលក្ខណៈកម្រិត។

*រឿងក្តី MCKAY ទល់នឹងចក្រភពអង់គ្លេស*

*តុលាការសិទ្ធិមនុស្សអឺរ៉ុប ៣ តុលា ២០០៦ កថាខណ្ឌ៣២ (ទាមទារលក្ខខណ្ឌ នៃការនាំខ្លួនជាបន្ទាន់ ការពិនិត្យមើលឡើងវិញដោយស្វ័យប្រវត្តិ)។ រឿងក្តីBROGANនិង ជនផ្សេងទៀតទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៩ វិច្ឆិកា ១៩៨៨ កថាខណ្ឌ ៥៩ (ភាពបត់បែននៅក្នុងភាពបន្ទាន់ភ្លាមៗ មានលក្ខណៈកម្រិត)។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន៖*** មាត្រា៥(១)។ មាត្រានេះធានានូវសិទ្ធិមានសេរីភាព និងសន្តិសុខរបស់បុគ្គលទាំងឡាយរួមទាំងសិទ្ធិទទួលការចាប់ខ្លួន និងការឃុំខ្លួនជនណាម្នាក់ដោយស្របច្បាប់។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ផ្អែកលើមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍ បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បារាំង ពោលគឺតុលាការកំពូល។*

**គោលបំណងនៃការឃាត់ខ្លួន៖** ដើម្បីឲ្យមន្ត្រីនគរបាលយុត្តិធម៌ សួរចម្លើយជនដែលត្រូវបានឃាត់ខ្លួននេះ។

*លេខ 94-82220 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៧៣ តុលាការកំពូលបារាំង ១១ កក្កដា ១៩៩៤។*

**មិនត្រូវឃាត់ខ្លួនជនណាដែលពុំមែនជា ឬពុំត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស៖** អំណាចរបស់មន្ត្រីនគរបាលរដ្ឋបាល ក្នុងការត្រួតពិនិត្យអត្តសញ្ញាណពុំអាចលាតសន្ធឹង រហូតដល់ករណីនេះឡើយ។

*លេខ 72-90278 ព្រឹត្តិបត្រព្រហ្មទណ្ឌ ៧*

*តុលាការកំពូលបារាំង ៥ មករា ១៩៧៣។*

**ជនដែលត្រូវបានឃាត់ខ្លួន អាចត្រូវគេស្តាប់ចម្លើយអំពីអង្គហេតុផ្សេងទៀត ក្រៅពីអង្គហេតុដែលចាប់ផ្តើមវិធានការនេះ៖** ករណីនេះកើតឡើងនៅពេលដែលអង្គហេតុទាំងឡាយ ពុំបានប៉ះពាល់ដល់ទម្រង់បែបបទ នៃវិធានការឃាត់ខ្លួន។

*លេខ04-83030 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៦២០០៥ តុលាការកំពូលបារាំង ១២ មករា ២០០៥។*

**ការឃាត់ខ្លួន ពុំចាំបាច់ធ្វើឡើងទេ នៅពេលដែលជនណាម្នាក់ស្ម័គ្រចិត្តចូលខ្លួន នៅចំពោះមុខនគរបាល៖** ការចូលខ្លួនបែបនេះ គឺធ្វើឡើងដើម្បីឲ្យគេស្តាប់ភាពចាំបាច់ក្នុងការស៊ើបសួរតែប៉ុណ្ណោះ។

*លេខ08-81771 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៣៨ តុលាការកំពូលបារាំង ៣ មិថុនា ២០០៨។*

**ការឃាត់ខ្លួន ពុំមានលក្ខណៈហួសហេតុឡើយ ប្រ-សិនបើ ពុំលើសពីរយៈពេលស្របច្បាប់ ចំនួន ២៤ ម៉ោង៖** ធ្វើដូច្នេះបានតែចំពោះកិច្ចដែលត្រូវបំពេញនៅក្នុងរយៈពេលនោះ គឺដើម្បីស្តាប់ជនត្រូវចោទតែប៉ុណ្ណោះ។

*លេខ98-50007 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៥៧ តុលាការកំពូលបារាំង ៧ កក្កដា ២០០០។*

**ចំពោះអង្គហេតុផ្សេងៗគ្នា ជនណាម្នាក់អាចស្ថិតនៅក្រោមវិធាននៃការឃាត់ខ្លួនភ្លាមៗជាប់ៗគ្នា ឬដោយដាច់ចេញពីគ្នា៖** ទោះបីជាយ៉ាងនេះក្តីជនណាម្នាក់ មិនអាចត្រូវបានបន្តឃាត់ខ្លួនជាប់ៗគ្នាលើសពីរយៈពេលអតិបរិមា ដែលមានកំណត់នៅក្នុងច្បាប់នោះឡើយ។

*លេខ03-87739 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៦៩ តុលាការកំពូលបារាំង ១៧ មីនា ២០០៤។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា៦២ និងមាត្រា៦៣។ មាត្រាទាំងនេះចែងអំពីនីតិវិធីឃាត់ខ្លួនរួមទាំងលក្ខណៈ និងគោលបំណងនៃការឃាត់ខ្លួន និងលទ្ធភាពនៃការបន្តឃាត់ខ្លួនផងដែរ។

# មាត្រា ១២១៖ ការសម្ងាត់នៃការស៊ើបសួរ

*ការស៊ើបសួរ ត្រូវតែជាការសម្ងាត់។*

*បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេសព្រះរាជអាជ្ញា ចៅក្រម មេធាវី ក្រឡាបញ្ជី មន្ត្រីនគរបាលយុត្តិធម៌ និងកងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចចែងក្នុងមាត្រា៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ។*

*ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ។*

*ម្យ៉ាងទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងក្ដីណាមួយនោះ ជាព័ត៌មានមិនពិត។*

*ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសមជ្ឈិម ដែលត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**ការដកចេញសេចក្ដីសម្រេច ដើម្បីធានាថាការស៊ើបសួរ មិនត្រូវបានប៉ះពាល់៖** អង្គបុរេជំនុំជម្រះ មានសិទ្ធិដកចេញនូវសម្រង់សេចក្ដីសម្រេចពីសំណៅនៃសេចក្ដីសម្រេច ជាសាធារណៈដើម្បីធានាថាកិច្ចស៊ើបសួរ មិនត្រូវបានប៉ះពាល់នោះ ទេ។

*រឿងក្ដី អៀង សារី៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ២៥។*

**កិច្ចស៊ើបសួរ និងភស្តុតាង មិនត្រូវបង្ហាញជាសាធារណៈទេ៖** កិច្ចស៊ើបសួរ មិនត្រូវធ្វើជាសាធារណៈឡើយ។ ភស្តុតាងក្នុងសំណុំរឿងមិនត្រូវបង្ហាញជាសាធារណៈ។ បុគ្គលទាំងអស់ ដែលបានចូលរួមនៅក្នុងកិច្ចស៊ើបសួរ ត្រូវតែរក្សាឱ្យបាននូវការសម្ងាត់។ ប៉ុន្តែសវនាការត្រូវធ្វើឡើងជាសាធារណៈ។

*រឿងក្ដីខៀវ សំផន៖ សំណើសុំសវនាការជាសាធារណៈ អ.វ.ត.ក អ.ប.ជ ៣ មីនា ២០០៨ កថាខណ្ឌ៨-១១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៦ និង៥៤។ វិធាន៥៦ គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា១២១ ប៉ុន្តែក្នុងកាលៈទេសៈពិសេស វិធាននេះបានផ្ដល់សមត្ថកិច្ចឱ្យចៅក្រមស៊ើបសួរ អនុញ្ញាតឱ្យអ្នកដទៃទៀតដែលមិនមែនជាភាគីមានលទ្ធភាពពិនិត្យកិច្ចស៊ើបសួរដោយមានកម្រិត។ លើសពីនេះ វិធាន៥៤ អនុញ្ញាតឱ្យ

ព្រះរាជអាជ្ញាជូនដំណឹងដល់សាធារណៈជន អំពីព័ត៌មានសង្ខេបដោយមិនលម្អៀង ដូចមានចែង នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរ ដែលបានធ្វើឡើងដោយព្រះរាជអាជ្ញា។

## *ការអនុវត្តមាត្រាស្រដៀងគ្នាក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការ-ពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**មេធាវី អាចមានសិទ្ធិពិនិត្យមើលសំណុំរឿងស៊ើបសួរបាន៖** នេះគឺដោយសារតែជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី គឺជាបុគ្គលឯកជន ដែលមិនស្ថិតនៅក្រោមវិធានរក្សាការសម្ងាត់ទេ។ ប៉ុន្តែប្រសិនបើ ជនត្រូវចោទជ្រើសរើសមិនឱ្យមានមេធាវីធ្វើជាតំណាងទេ ការបដិសេធមិនឱ្យជនត្រូវចោទនេះ មានសិទ្ធិពនិត្យសំណុំរឿង នឹងក្លាយជាការបំពានសិទ្ធិរបស់ជនត្រូវចោទ។

*រឿងក្តីMENETទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៤ មិថុនា ២០០៥ ករណីដែលមិនបានរាយការណ៍ (សិទ្ធិនេះនឹងត្រូវបានរក្សាទុកជូនមេធាវី)។ រឿងក្តីFOUCHER ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៨ មីនា ១៩៩៧ កថាខណ្ឌ៣៦ (ករណីជនត្រូវចោទមិនមានមេធាវីតំណាង)។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៦(១)។មាត្រានេះចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមមានសិទ្ធិទទួលបានសវនាការជាសាធារណៈ និងដោយយុត្តិធម៌ក្នុងពេលវេលាមួយសមស្រប។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ផ្អែកលើមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បារាំង ពោលគឺតុលាការកំពូល។*

**ចៅក្រមស៊ើបសួរ អាចផ្តល់សក្ខីកម្មដូចសាក្សីដែរ ក្នុងរឿងក្តីដែលខ្លួនបានស៊ើបអង្កេត៖** ទោះជាយ៉ាងណាក្តី ដោយសារកាតព្វកិច្ចនៃការរក្សាការសម្ងាត់វិជ្ជាជីវៈ ចៅក្រមស៊ើបសួរ មិនត្រូវលាតត្រដាងនូវព័ត៌មានអំពីនីតិវិធីណាមួយផ្សេងទៀត ក្រៅតែពីនីតិវិធីដែលចោទជាបញ្ហានោះទេ។

*តុលាការកំពូលបារាំង ៥ វិច្ឆិកា ១៩០៣។*

**ការរក្សាការសម្ងាត់លើការស្រាវជ្រាវ និងការស៊ើបសួរ ត្រូវបានបំពាន តាមរយៈការលាតត្រដាងឯកសារដែលខ្លួនទទួលបាន ដោយមិនតាមស្របច្បាប់៖** វាក៏ជាការបំពានផងដែរ ទោះបីជាបញ្ហានេះ ត្រូវបានច្រានចោលក៏ដោយ។

*លេខ90-83520 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២០០ តុលាការកំពូលបារាំង ១៣ ឧសភា ១៩៩១។*

**ព័ត៌មានដែលនាំដល់ការកំណត់អំពីអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ នៅក្នុងការស៊ើបអង្កេត មិនត្រូវលាតត្រដាងឡើយ៖** ចំណុចនេះ ត្រូវបានចាត់ទុកថាជាអំពើឆ្វេសប្រហែសយ៉ាងខ្លាំង។

*លេខ96-16560 ព្រឹត្តិបត្ររដ្ឋប្បវេណី I.៨២ តុលាការកំពូលបារាំង ៩ មីនា ១៩៩៩។*

**ដើមបណ្តឹងរដ្ឋប្បវេណី មិនស្ថិតនៅក្រោមកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈទេ៖** គោលការណ៍នេះ ត្រូវបានបង្កើតឡើងដោយករណីយុត្តិសាស្ត្រ។

*លេខ 76-92075 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៦៣ តុលាការកំពូលបារាំង ៩ តុលា ១៩៧៨។*

**មេធាវី មិនត្រូវបំពានលើទំនុកចិត្តចំពោះការរក្សានូវការសម្ងាត់វិជ្ជាជីវៈ៖** មេធាវី ត្រូវតែគោរពការរក្សាការសម្ងាត់នៃការស៊ើបសួរ និងឧទាហរណ៍ មិនត្រូវបញ្ចេញព័ត៌មានលម្អិតអំពីរឿងក្តីទៅតតិយជនទេ ទោះបីកូនក្តីអនុញ្ញាតឱ្យលាតត្រដាងក៏ដោយ។

*លេខ 04-81513 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៥៩ តុលាការកំពូលបារាំង ២៧ តុលា ២០០៤។*

**ជនត្រូវចោទ ឬជនសង្ស័យ មិនអាចពិនិត្យសំណុំរឿងដោយផ្ទាល់ទេ ប៉ុន្តែអាចស្នើសុំឲ្យបញ្ជូនឯកសារថតចម្លងដើម្បីដាក់បញ្ចូល ក្នុងសំណុំរឿងសម្រាប់បញ្ជូនទៅតុលាការ៖** ការស្នើសុំនេះ ត្រូវធ្វើឡើងតាមរយៈមេធាវីរបស់ពួកគេ ហើយការចំណាយគឺជាបន្ទុករបស់ជនត្រូវចោទ ឬជនសង្ស័យ។

*លេខ96-80219 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៤៨ តុលាការកំពូលបារាំង ១២ មិថុនា ១៩៩៦។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖ មាត្រា១១។ មាត្រានេះ ចែងអំពីការរក្សាការសម្ងាត់នៃកិច្ចដំណើរការនីតិវិធីស្រាវជ្រាវ និងស៊ើបអង្កេត រួមទាំងអត្ថន័យមិនច្បាស់លាស់រវាងការរក្សាការសម្ងាត់នៃនីតិវិធីស៊ើបសួរ និងការរក្សាការសម្ងាត់វិជ្ជាជីវៈ។

# មាត្រា ១២៤៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

*អនុលោមតាមមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ ការស៊ើបសួរ ត្រូវបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។*

*ដោយអនុលោមតាមវាក្យខណ្ឌទី ២ នៃមាត្រា ៤៤ (ការបើកការស៊ើបសួរ) ការស៊ើបសួរ អាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន។*

*ចៅក្រមស៊ើបសួរ មិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ។*

*កាលបើចៅក្រមស៊ើបសួរទទួលពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរ ត្រូវធ្វើតាមនីតិវិធី ដូចដែលមានចែងក្នុងមាត្រា ១៣៩ (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក)។*

*កាលណាទទួលពាក្យប្ដឹងសាមញ្ញ ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនពាក្យប្ដឹងនោះទៅព្រះរាជអាជ្ញា។*

## ការអនុវត្តនៅ អ.វ.ត.ក

**ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវសង្ខេបអំពីអង្គហេតុ និងបទចោទ ដែលបានស៊ើបសួរ** ៖ សិទ្ធិទទួលបាន នូវការជូនដំណឹងអំពីការចោទប្រកាន់ គឺជាសិទ្ធិមូលដ្ឋានរបស់បុគ្គលត្រូវចោទ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវសង្ខេបអំពីអង្គហេតុ និងប្រភេទនៃបទល្មើស ដែលបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ។ អង្គហេតុជាក់លាក់ ដូចបានសង្ខេបនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវមានសុពលភាព និងត្រូវអះអាងក្នុងដីកាដំណោះស្រាយ។ ការធ្វើបែបនេះ គឺដើម្បីធានាថាមេធាវីការពារក្ដី ទទួលបានការជូនដំណឹងគ្រប់គ្រាន់អំពីបទចោទ ដែលនឹងត្រូវជំនុំជម្រះ។

*រឿងក្ដីអៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ ៖ បណ្ដឹងឧទ្ធរណ៍ លើភាពអាចអនុវត្តបាននូវសហកម្មឧក្រិដ្ឋកម្មរួម អ.វ.ត.ក អ.ប.ជ ២០ ឧសភា ២០១០ កថាខណ្ឌ៩២ និង៩៥។*

**ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្នើសុំឲ្យចៅក្រមស៊ើបសួរ បើកការស៊ើបសួរលើរឿងក្ដី** ៖ នៅពេលដំណាលគ្នានេះដែរ ដំណាក់កាលនេះបញ្ចប់នូវអំណាចរបស់ព្រះរាជអាជ្ញា ដើម្បីស៊ើបសួរនូវអង្គហេតុដូចគ្នា។

*រឿងក្តីនួន ជា អៀង សារី និងអៀង ធីរិទ្ធះ ដីកាស្នើសុំឲ្យបំពេញកិច្ច ស៊ើបសួរបន្ថែមទាក់ទងនឹងភស្តុតាងដោះបន្ទុក អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបសួរ ១៩ មិថុនា ២០០៩ កថាខណ្ឌ១៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.កៈ** វិធាន៥៣ និង៥៥។ វិធាន៥៣(២) តម្រូវឱ្យព្រះរាជអាជ្ញាដាក់ភស្តុតាងទាំងអស់ (រួមទាំងភស្តុតាងដោះបន្ទុក) នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ វិធាន៥៥ បានបកស្រាយពីទំនាក់ទំនងរវាងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ។

## *ការអនុវត្តមាត្រាស្រដៀងគ្នាក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**មោឃភាព នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវតែលើកឡើងជាអញ្ញត្រកម្មៈ ពោលគឺមុនពេលឈានដល់ការពិភាក្សាណាមួយលើអង្គសេចក្តី។**

*លេខ 94-81397 តុលាការកំពូលបារាំង ១៩ តុលា ១៩៩៥។*

**រាល់សំណើណាមួយ ដែលមិនមានកាលបរិច្ឆេទ ត្រូវចាត់ទុកជាមោឃៈ ព្រោះថា កាលបរិច្ឆេទនៅលើសំណើគឺមានសារៈសំខាន់ចំពោះបណ្តឹង។**

*លេខ70-92577 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១៨ តុលាការកំពូលបារាំង ២៣ មេសា ១៩៧១។*

**ចៅក្រមស៊ើបសួរ អាចធ្វើការស៊ើបសួរ តែអង្គហេតុណា ដែលមានបញ្ជាក់ជាក់លាក់ នៅក្នុងបណ្តឹងដែលបានដាក់ជូនតែប៉ុណ្ណោះៈ ពោលគឺអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។**

*លេខ73-90372 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២១៧ តុលាការកំពូលបារាំង ១០ ឧសភា ១៩៧៣។ លេខ95-84041 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៦០ តុលាការកំពូលបារាំង ៦ កុម្ភៈ ១៩៩៦។*

**ចៅក្រមស៊ើបសួរ ត្រូវចោទប្រកាន់រាល់បុគ្គលដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានៈ នៅក្នុងករណីនៃការសួរចម្លើយ។**

*លេខ83-94762 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៥៨ តុលាការកំពូលបារាំង ១៤ កុម្ភៈ ១៩៨៤។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៨០ និង៨២។ មាត្រា៨០ តម្រូវឱ្យចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរ ស្របតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ខណៈដែលមាត្រា៨២ ផ្តល់សិទ្ធិអំណាចជូនរដ្ឋអាជ្ញាក្នុងការស្នើសុំឱ្យចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរជាក់លាក់ ដើម្បីជាចំណែកមួយនៃកិច្ចស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

# មាត្រា ១២៥៖ វិសាលភាពនៃការប្ដឹង

*ចៅក្រមស៊ើបសួរ ទទួលបណ្ដឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ ត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ។*

*ប្រសិនបើ មានលេចអង្គហេតុថ្មីដែលជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា អាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរ គ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។*

*ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង។*

## ការអនុវត្តនៅ អ.វ.ត.ក

**និយមន័យនៃសំណើសុំបំពេញកិច្ចស៊ើបសួរ៖** សំណើសុំបំពេញកិច្ចស៊ើបសួរ ត្រូវបានកំណត់និយមន័យថា ជាសំណើសុំបំពេញកិច្ច ដែលនឹងត្រូវធ្វើឡើង ដោយចៅក្រមស៊ើបសួរ ឬតាមរយៈការធ្វើប្រតិភូកម្ម សំណើសុំបំពេញកិច្ចនេះត្រូវធ្វើឡើង ដោយអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក ឬដោយនគរបាលយុត្តិធម៌ ដើម្បីធ្វើការប្រមូលព័ត៌មាន ដែលឈានដល់ការបញ្ជាក់ការពិត។

*រឿងក្ដីអៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងកស្តុតាង ដែលអាចទទួលបានដោយអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១៨ ធ្នូ ២០០៩ កថាខណ្ឌ១៨។ រឿងក្ដី ខៀវ សំផន៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងកស្តុតាង ដែលអាចទទួលបាន ដោយអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ២៧ មករា ២០១០ កថាខណ្ឌ១៦។*

**គ្រប់ភាគីទាំងអស់ អាចស្នើសុំការបំពេញកិច្ចស៊ើបសួរ៖** គ្រប់ភាគីទាំងអស់ មានសិទ្ធិអាចស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ។ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ត្រូវបានបកស្រាយថា ជាការស្នើសុំឱ្យចៅក្រមស៊ើបសួរ ចាត់វិធានការដើម្បីប្រមូលយកព័ត៌មាន ដែលអាចឈានដល់ការបញ្ជាក់ការពិត។

*រឿងក្ដីអៀង សារី៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ លើកស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ១៧ និង១៨។*

**ចៅក្រមស៊ើបសួរ មានឆន្ទានុសិទ្ធិធំធេងក្នុងការសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ៖** ចៅក្រមស៊ើបសួរ មានសិទ្ធិសម្រេចលើភស្តុតាង ដែលមានសារៈប្រយោជន៍ ឬលើឱកាសបំពេញកិច្ចស៊ើបសួរណាមួយ។ ភាគីអាចស្នើសុំ តែមិនមែនដាក់កាតព្វកិច្ចឱ្យចៅក្រមធ្វើការស៊ើបសួរឡើយ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសំណើសុំឲ្យបំពេញ កិច្ចស៊ើបសួរទៅលើភស្តុតាងដោះបន្ទុក អ.វ. ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ២១។ រឿងក្តីនួន ជា ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើភស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១៨ វិច្ឆិកា ២០០៩ កថាខណ្ឌ ១៧ ១៨ និង២២ (ឆន្ទានុសិទ្ធិដ៏ធំធេង និងភាគីអាចស្នើសុំបាន ប៉ុន្តែមិនមែនដាក់កាតព្វកិច្ចលើសហចៅក្រមស៊ើបសួរឡើយ) និងរឿងក្តីនួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និង ឌុច៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងកិច្ចសម្ភាសន៍ ចំពោះការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អ.វ.ត.ក អ.ប.ជ ២១ កក្កដា ២០១០ កថាខណ្ឌ១៤ (អ.វ.ត.ក អ.ប.ជ មិនត្រូវបង្គាប់ឱ្យបំពេញកិច្ចស៊ើបសួរនោះទេ)។*

**ការត្រួតពិនិត្យឡើងវិញ លើភស្តុតាងជាសម្ភារៈដែលមិនមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ៖** សំណើសុំឱ្យត្រួតពិនិត្យឡើងវិញលើភស្តុតាងសម្ភារៈ ដែលមិនមានបញ្ជាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវតែច្បាស់លាស់ និងត្រូវមានភាពជាប់ទាក់ទងទៅនឹងការបញ្ជាក់រកការពិត។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ លើភស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ៣៣ ៤៤ និង៤៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៣ និងវិធាន៥៥។ វិធានទាំងនេះ គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា១២៥ លើកលែងតែក្រៅពីពុំតម្រូវឱ្យមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើអង្គហេតុថ្មី ដែលជាស្ថានទម្ងន់ទោសនៃអង្គហេតុ ដែលមានកំនត់ក្នុងដីកាសន្និដ្ឋានដែលមានស្រាប់ វិធានទាំងពីរនេះ ក៏ពុំទាមទារឱ្យចៅក្រមស៊ើបសួរ ធ្វើការជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីអង្គហេតុថ្មីៗទាំងនេះដែរ។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការ-ពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេស*

*កម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**រាល់អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវទទួលបន្ទុកធ្វើសេចក្តីសម្រេច នៅដំណាក់កាលស៊ើបសួរ គឺត្រូវតែឯករាជ្យ និងមិនលម្អៀង៖** ទោះបីអាជ្ញាធរទាំងនេះជាចៅក្រម ឬក៏រដ្ឋអាជ្ញាក៏ដោយ។

*រឿងក្តី PANTEA ទល់នឹងប្រទេសរ៉ូម៉ានី តុលាការសិទ្ធិមនុស្សអឺរ៉ុប ៣ មិថុនា ២០០៣ កថាខណ្ឌ២៣៨។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មាត្រា៦(១)។ មាត្រានេះ ផ្តល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមមានសិទ្ធិទទួលបានសវនាការជាសាធារណៈ និងដោយយុត្តិធម៌ ក្នុងពេលវេលាមួយសមស្រប។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផ្អែកលើមូលដ្ឋាន នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បារាំងពោលគឺតុលាការកំពូល។*

**ជាទូទៅ ចៅក្រមស៊ើបសួរ ត្រូវបានកំណត់ត្រឹមតែអង្គហេតុដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ៖** ប៉ុន្តែក្នុងករណី ដែលចៅក្រមស៊ើបសួរបានរកឃើញនូវអង្គហេតុថ្មី ចៅក្រមស៊ើបសួរ អាចដាក់បញ្ចូលនូវអង្គហេតុថ្មីៗទាំងនោះ ក្នុងកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី មុននឹងជូនដំណឹងដល់រដ្ឋអាជ្ញា និងក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវតបន្តវាយតម្លៃ ដោយសង្ខេបលើភវនីយភាពនៃអង្គហេតុទាំងនេះជាបន្ទាន់។ ទោះបីជាយ៉ាងនេះក្តី ក៏ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចដោយចាប់បង្ខំ ដែលតម្រូវឱ្យមានការជាប់ពាក់ព័ន្ធពីស្ថាប័នអយ្យការ ចំពោះអង្គហេតុនេះឡើយ។

*លេខ 95-84041 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៦០ តុលាការកំពូលបារាំង ៦ កុម្ភៈ ១៩៩៦។*

**កត្តាចាំបាច់សម្រាប់បញ្ជាក់ពីកិច្ចដែលត្រូវបំពេញជាបន្ទាន់៖** កិច្ចទាំងនេះមិនត្រូវបំពេញ ដោយបង្ខំនោះទេ ក៏ប៉ុន្តែត្រូវបំពេញឱ្យចប់រួចរាល់ ក្នុងរយៈពេល៣ថ្ងៃ និងត្រូវដាក់បញ្ចូលក្នុងកំណត់ហេតុ នៃកិច្ចដំណើរការនីតិវិធី។

*លេខ99-81426 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៧៦ តុលាការកំពូលប្រទេសបារាំង ៣០ មិថុនា ១៩៩៩។*

**បុគ្គលដែលមិនមានឈ្មោះ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ៖** បុគ្គលទាំងនេះ គឺដាច់ខាតមិនត្រូវបានកោះ ឬឃុំខ្លួនឡើយ។

*លេខ 97-84372 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១២៤ តុលាការកំពូលបារាំង ១ មេសា ១៩៩៨។*

**រដ្ឋអាជ្ញាមិនអាចកំណត់វិសាលភាពនៃសំណើបានទេ នៅពេលដែលការស៊ើបសួរបានចាប់ផ្ដើមរួចហើយ ៖** ចៅក្រមស៊ើបសួរ ត្រូវពិចារណាលើរាល់អង្គហេតុទាំងអស់ ដែលខ្លួនទទួលបាន។

*លេខ76-91442 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១១២ តុលាការកំពូលបារាំង ២៤ មីនា ១៩៧៧។*

**ស្ថានភាពដែលចៅក្រមស៊ើបសួរ អាចស៊ើបសួរអង្គហេតុថ្មី ដែលត្រូវបានដាក់បញ្ចូលក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី៖** តែក្នុងករណីដែលរដ្ឋអជ្ញាសម្រេចបញ្ជូនអង្គហេតុថ្មីៗទាំងនោះ ឱ្យធ្វើការស៊ើបសួរតែប៉ុណ្ណោះ។

*លេខ 00-82107 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៧៧ ២៦ កញ្ញា ២០០០។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៨០ និងមាត្រា៨២។ មាត្រា៨០ តម្រូវឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ដោយស្របតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ខណៈដែលមាត្រា៨២ ផ្ដល់សិទ្ធិឱ្យរដ្ឋអាជ្ញាស្នើសុំឱ្យចៅ-ក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួន ដែលជាផ្នែកមួយនៃការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

# មាត្រា ១២៦៖ ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ

*ចៅក្រមស៊ើបសួរ ត្រូវដាក់ឲ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលណា ដែលមានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។*

*ចៅក្រមស៊ើបសួរ មានអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ។*

*ចៅក្រមស៊ើបសួរ អាចដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈជាចារី ជាអ្នកផ្ដើមគំនិត ឬជាអ្នកសមគំនិត។*

## ការអនុវត្តនៅ អ.វ.ត.ក

**ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ គឺជាសេចក្ដីសម្រេចមួយ ដោយផ្អែកលើភស្តុតាង៖ គឺជាសេចក្ដីសម្រេចរបស់តុលាការ ធ្វើឡើងដោយចៅក្រមស៊ើបសួរ នៅពេលណាដែលមានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នា នៅក្នុងការទទួលខុសត្រូវខាងព្រហ្មទណ្ឌប្រឆាំងទៅនឹងបុគ្គលណាម្នាក់ ហើយវាមិនមែនជាទម្រង់ការខាងនីតិវិធីនោះទេ។**

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និងឌុច៖ ដីកាបដិសេធន៍ការចោទប្រកាន់បន្ថែម អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបសួរ ១៦ កុម្ភៈ ២០១០ កថាខណ្ឌ១៣។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៥(៤)។ វិធាននេះ គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ១២៦ លើកលែងតែករណីដែលវិធានផ្ទៃក្នុងនេះចែងថា ធ្វើការចោទប្រកាន់ដោយមិនដាក់ឲ្យស្ថិតក្រោមការពិនិត្យឡើយ ហើយទាមទារឲ្យមានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នា ជាជាងភស្តុតាងជាក់លាក់ និងទាក់ទងគ្នា ព្រមទាំងមិនបានបញ្ជាក់អំពីទម្រង់ផ្សេងៗ ដែលបុគ្គលណាម្នាក់ត្រូវបានចោទប្រកាន់។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានបកស្រាយ និង អនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បារាំង ពោលគឺតុលាការកំពូល។*

**បណ្ដឹងអាជ្ញា គឺជាបណ្ដឹងផ្ដួចផ្ដើមឡើងពេញលេញដោយការចោទប្រកាន់ជាបឋមរបស់ព្រះរាជអាជ្ញា៖** ករណីនេះ ទោះបីជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានប្រកាសមិនទទួលយកក៏ដោយ។

*លេខ 83-92677 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៩០ តុលាការកំពូលបារាំង ៨ វិច្ឆិកា ១៩៨៣។*

**វិសាលភាពដ៏មានព្រំដែន របស់ចៅក្រមស៊ើបសួរ៖** ចៅក្រមស៊ើបសួរ អាចស៊ើបសួរបានត្រឹមតែអង្គហេតុណា ដែលបានលើកឡើងយ៉ាងច្បាស់ នៅក្នុងដីកាចោទប្រកាន់ប្រឆាំងនឹងជននោះប៉ុណ្ណោះ។

*លេខ 73-90372 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២១៧ តុលាការកំពូលបារាំង ១០ ឧសភា ១៩៧៣។*

**ការចាត់ទុកជាមោឃៈ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អាចត្រូវបានទុកជាមោឃៈ ប្រសិនបើដីកានោះ មិនបំពេញបាននូវលក្ខខណ្ឌតម្រូវផ្នែកច្បាប់ចាំបាច់ នៃអត្ថិភាពរបស់ខ្លួនទេនោះ។

*លេខ 01-87656 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១២៩ តុលាការកំពូលបារាំង ៥ មិថុនា ២០០២។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា៨០ និង៨០-១។ មាត្រា៨០ តម្រូវឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ដោយអនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រីឯមាត្រា ៨០-១ តម្រូវឲ្យចៅក្រមស៊ើបសួរ ដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះបុគ្គលទាំងឡាយណា ដែលមានភស្តុតាងប្រឆាំងរឹងមាំ និងស៊ីសង្វាក់គ្នាអំពីការចូលរួមរបស់គេបានចោទប្រកាន់។

# មាត្រា ១២៧៖ ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក

*ចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់។*

*ចៅក្រមស៊ើបសួរ មានករណីកិច្ចស៊ើបសួរទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។*

## ការអនុវត្តនៅ អ.វ.ត.ក

**អាចបំពេញរាល់កិច្ចស៊ើបសួរបាន៖** ចៅក្រមស៊ើបសួរ អាចបំពេញរាល់កិច្ចស៊ើបសួរ ដើម្បីអាចស្វែងរកការពិត។ ចៅក្រមស៊ើបសួរ អាចរក្សាសិទ្ធិ ដើម្បីធ្វើការពិចារណា នៅលើសារៈប្រយោជន៍នៃភស្តុតាង ឬឱកាស ដើម្បីអាចបំពេញរាល់កិច្ចស៊ើបសួរណាមួយ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ លើភស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ២១ (សិទ្ធិសម្រេច នៅពេលការបំពេញកិច្ច ឈានដល់ការស្វែងរកការពិត)។ រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសិទ្ធិស្តីពីការបកប្រែ អ.វ.ត.ក អ.ប.ជ ២០ កុម្ភៈ ២០០៩ កថាខណ្ឌ១៩ (អាចបំពេញរាល់កិច្ចទាំងឡាយ ដែលអាចឈានដល់ការស្វែងរកការពិត)។*

**កាតព្វកិច្ចក្នុងការត្រួតពិនិត្យ លើរាល់ភស្តុតាងទាំងអស់ឡើងវិញ៖** ចៅក្រមស៊ើបសួរ មានកាតព្វកិច្ចក្នុងការត្រួតពិនិត្យលើរាល់ភស្តុតាងទាំងអស់ឡើងវិញ រួមទាំងភស្តុតាងដោះបន្ទុក មុននឹងសម្រេចបិទកិច្ចស៊ើបសួរ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ លើភស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ៣៥។*

**ចៅក្រមស៊ើបសួរ ត្រូវតែដំណើរការកិច្ចស៊ើបសួរឲ្យបានពេញលេញ៖** ចៅក្រម ពុំចាំបាច់ធ្វើការស៊ើបសួរឲ្យហួសពីវិសាលភាពនៃរឿងក្តីក្នុងការស្វែងរកភស្តុតាងដោះបន្ទុកនោះទេ។

*រឿងក្តីនួន ជា អៀង សារី និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ លើភស្តុតាងដោះបន្ទុក អ.វ.ត.ក ការិយាល័យសហ ចៅក្រមស៊ើបសួរ ១៩ មិថុនា ២០០៩ កថាខណ្ឌ១៥។*

**សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ គឺជាសំណើសុំឱ្យស្វែងរកភស្តុតាង៖** រាល់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ គួរត្រូវបានបកស្រាយថាជាសំណើសុំឱ្យសហចៅក្រមស៊ើបសួរ ធ្វើការប្រមូល និងការវិភាគលើភស្តុតាង ក្នុងគោល

បំណងស្វែងរកការពិត។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសំណើសុំឱ្យបំពេញ កិច្ចស៊ើបសួររកភស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ១៨-១៩។*

**ការបកប្រែ មិនមែនជាកិច្ចស៊ើបសួរទេ៖** សំណើសុំឱ្យធ្វើការបកប្រែភស្តុតាង មិនមែនជាសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទេ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសិទ្ធិស្តីពីការបកប្រែ អ.វ.ត.ក អ.ប.ជ ២០ កុម្ភៈ ២០០៩ កថាខណ្ឌ២៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៥(៥)។ វិធាននេះ គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ១២៧ លើកលែងតែករណីដែលវិធានផ្ទៃក្នុងនេះ បកស្រាយពីរបៀបដែលចៅក្រមស៊ើបសួរអាចបំពេញកាតព្វកិច្ចទាំងនេះ រួមមានការចេញដីកាកោះ និងការសួរចម្លើយជនសង្ស័យ និងជនត្រូវចោទ ការស្តាប់ចម្លើយជនរងគ្រោះ និងសាក្សី និងការដកហូតវត្ថុតាងជាអាទិ៍។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិ ស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការរំលោភ៖ ការខកខាន ក្នុងការបង្កើតឯកសារនៅក្នុងដំណាក់កាលនគរបាល៖** ការខកខានក្នុងការបង្កើតឯកសារ នៅក្នុងដំណាក់កាលនគរបាលដែលអាចរួមមានភស្តុតាងដោះបន្ទុក គឺជាការរំលោភសិទ្ធិជនត្រូវចោទ ដោយសារទង្វើនេះ អាចរារាំងដល់ការរៀបចំកិច្ចការពារខ្លួន របស់ជនត្រូវចោទ។

*រឿងក្តី YASSEEN និងTHOMAS ទល់នឹងប្រទេសហ្គុយយ៉ាណា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣០ មីនា ១៩៩៨ កថាខណ្ឌ ៧.១០។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា១៤។ មាត្រានេះត្រូវបានបកស្រាយថា ជាលក្ខខណ្ឌទាមទារឱ្យបង្កើតឯកសារដោះបន្ទុក។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការ-ពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ការលួចស្តាប់កិច្ចសន្ទនាតាមទូរសព្ទ ត្រូវតែមានមូលដ្ឋានច្បាប់ ច្បាស់លាស់ពិតប្រាកដ៖** ព្រោះតែទង្វើនេះ បានបង្ហាញពីការជ្រៀតជ្រែកយ៉ាងធ្ងន់ធ្ងរក្នុងជីវិតឯកជន និងការប្រាស្រ័យទាក់ទងជាឯកជន។ ច្បាប់ស្តីពីការឃ្លាំតាមដានលើការសម្ងាត់ ត្រូវតែមានភាពច្បាស់លាស់ គ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋ ដើម្បីអាចឱ្យប្រជាពលរដ្ឋបានដឹងថា នៅពេលណាដែលការតាមដានបែបនេះ អាចត្រូវបានធ្វើឡើងដោយស្របច្បាប់។

*រឿងក្តី HUVIG ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៤ មេសា ១៩៩០ កថាខណ្ឌ៣២ (ភាពជាក់លាក់នៃច្បាប់ការជ្រៀតជ្រែកយ៉ាងធ្ងន់ធ្ងរ)។ រឿងក្តីMALONEទល់ នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្ស អឺរ៉ុប ២ សីហា ១៩៨៤ កថាខណ្ឌ៦៧ (ប្រជាពលរដ្ឋត្រូវតែបានដឹងអំពីច្បាប់)។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៨(១)។ មាត្រានេះចែងអំពីសិទ្ធិគោរពជីវិតឯកជន និងជីវិតគ្រួសារឯកជន ដែលរួមមានការគោរពនូវលិខិតឆ្លងឆ្លើយ និងលំនៅឋានរបស់បុគ្គល។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បារាំង ពោលគឺតុលាការកំពូល។*

**ការថតសម្លេងកិច្ចសន្ទនារបស់ជនត្រូវចោទនៅក្នុងបន្ទប់ឃុំខ្លួន ដែលមានរបាំងបិទ៖** កិច្ចទាំងនេះ អាចត្រូវបានបង្គាប់ដោយចៅក្រមស៊ើបសួរ ប្រសិនបើ ជនត្រូវចោទទាំងនោះ ស្ថិតក្រោមសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ និងក្នុងករណីដែលមិនបានរំលោភសិទ្ធិរបស់ជនត្រូវចោទ។

*លេខ 00-83852 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៦៩ តុលាការកំពូលបារាំង ១២ ធ្នូ ២០០០។*

**ការថតសម្លេងកិច្ចសន្ទនាតាមទូរសព្ទ៖** ចៅក្រមស៊ើបសួរជារឿយៗ អាចទាមទារឱ្យថតសម្លេងកិច្ច

សន្ទនាតាមទូរសព្ទឲ្យបានទៀងទាត់ និងបង្គាប់ឲ្យធ្វើប្រតិចារឹក។

*លេខ99-85045 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២ ១០ តុលាការកំពូលបារាំង ៦ តុលា ១៩៩៩។*

**ការរក្សាការសម្ងាត់វិជ្ជាជីវៈ នៃការងារជាវិជ្ជាជីវៈមួយចំនួន គឺជាគោលការណ៍ទូទៅ និងដាច់ខាត៖** ឧទាហរណ៍ គ្រូពេទ្យជាអាទិ៍។ គ្មានករណីណាដែលអាចអនុញ្ញាតឱ្យគ្រូពេទ្យ រួចផុតពីកាតព្វកិច្ចនេះឡើយ។ ប៉ុន្តែចៅក្រមស៊ើបសួរ អាចរឹបអូសយកភស្តុតាងដែលខ្លួនយល់ឃើញថា មានភាពចាំបាច់ក្នុងការស៊ើបសួរ។

*ព្រឹត្តិបត្រ ព្រហ្មទណ្ឌលេខ១២៤ តុលាការកំពូលបារាំង ៨ ឧសភា ១៩៤៧ (ការរក្សាការសម្ងាត់វិជ្ជាជីវៈ)។ លេខ66-90067 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ១៦៧ តុលាការកំពូលបារាំង ៨ មិថុនា ១៩៩៦ (ការរឹបអូសភស្តុតាង)។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៨១។ មាត្រានេះ បានអនុញ្ញាតឱ្យចៅក្រមស៊ើបសួរអាចបំពេញកិច្ចណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ក្នុងការស្វែងរកការពិត។ មាត្រានេះ ចងកាតព្វកិច្ចចៅក្រមស៊ើបសួរឲ្យស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។

# មាត្រា ១២៩៖ មុខងាររបស់ក្រឡាបញ្ជី

*សំណុំរឿងស៊ើបសួរ ត្រូវរក្សាទុកដោយក្រឡាបញ្ជី។ ក្រឡាបញ្ជីចម្លងលិខិតនីមួយៗនៃសំណុំរឿងតាមលទ្ធភាពដែលអាចធ្វើបាន។ លិខិតចម្លងនេះ ត្រូវតែបញ្ជាក់ថាត្រឹមត្រូវតាមលិខិតដើមដោយក្រឡាបញ្ជី សេចក្តីចម្លង ត្រូវរៀបចំទុកនៅក្នុងសំណុំរឿងបង្ការទុក។*

*គ្រប់លិខិតនៃសំណុំរឿង ត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ។*

*សំណុំរឿង និងសំណុំលិខិតដែលបង្ការទុក ត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជី នៅមន្ទីរចៅក្រមស៊ើបសួរ ឬនៅក្នុងបន្ទប់ណាមួយនៃតុលាការដែលមានលក្ខខណ្ឌសន្តិសុខគ្រប់គ្រាន់។*

*មេធាវី ឬលេខាធិការរបស់មេធាវី ត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរឱ្យធ្វើការថតចម្លងដោយខ្លួនជាអ្នកចេញសោហ៊ុយ និងក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**សិទ្ធិនីតិវិធីរបស់ជនត្រូវចោទនៅដំណាក់កាលស៊ើបសួរ រួមទាំងការពិនិត្យឡើងវិញលើឯកសារសំណុំរឿង៖** ចាប់តាំងពីពេលចាប់ផ្តើមនូវកិច្ចស៊ើបសួរ ជនត្រូវចោទទទួលបានសិទ្ធិនីតិវិធីដែលរួមទាំងសិទ្ធិពិនិត្យឯកសារ ដើម្បីឲ្យបានដឹងអំពីបទចោទដាក់បន្ទុកលើខ្លួនឯង ដើម្បីរៀបចំកិច្ចការពារខ្លួន និងដើម្បីការពារខ្លួន។

> *រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចាត់តាំងអ្នកជំនាញ អ.វ.ត.ក អ.ប.ជ ២២ តុលា ២០០៨ កថាខណ្ឌ២៥ និងលេខយោងជើងទំព័រ២៤។*

**មេធាវីរបស់ជនជាប់ចោទ អាចពិនិត្យសំណុំរឿងបាន៖** ក្រោយពេលចេញដីកាដំណោះស្រាយ ប្រសិនបើមានដីកាបញ្ជូនកូនក្តីរបស់ខ្លួនទៅជំនុំជម្រះ មេធាវីរបស់ជនជាប់ចោទអាចរៀបចំដំណាក់កាលជំនុំជម្រះរបស់ខ្លួនបាន ដោយធ្វើការពិនិត្យភស្តុតាងដែលមានស្រាប់ចំពោះមុខ រួមទាំងសំណុំរឿងដែលរក្សាទុកដោយក្រឡាបញ្ជី។

> *រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងភាពអាចទទួលយកបាន នៃភស្តុតាងដែលទទួលបាន តាមរយៈអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ ៣៣ និងលេខយោងជើងទំព័រ២៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៥(៦)។ វិធាននេះ គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ១២៩ លើកលែងតែករណីដែលក្រឡាបញ្ជីរបស់ចៅក្រមស៊ើបសួរ ជាអ្នករក្សាសំណុំរឿងជាលាយលក្ខណ៍អក្សរ។ វិធានផ្ទៃក្នុងផ្សេងទៀត ចែងបញ្ជាក់បន្ថែមអំពីបទប្បញ្ញត្តិទាំងនេះ រួមទាំងវិធាន១០(៤) ដែលចែងអំពីភាពចាំបាច់ក្នុងការរក្សាទុកសំណុំរឿងអេឡិចត្រូនិក និងវិធាន៩(៥) ដែលចែងអំពីការរក្សាទុកទិន្នន័យសំណុំរឿង និងវិធាន១៤(២) ១៧(៣) និង៣៣(២) ដែលបញ្ជាក់បន្ថែមអំពីបទប្បញ្ញត្តិទាំងនេះ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ភាគីទាំងអស់ នៅក្នុងការជំនុំជម្រះ ត្រូវមានឱកាសដឹង និងផ្តល់មតិយោបល់លើភស្តុតាងទាំងអស់ដែលប្រមូលបាន ឬធ្វើការដាក់ជូនសេចក្តីសង្កេត៖** នេះរួមទាំងភស្តុតាង/សេចក្តីសង្កេត របស់សមាជិកឯករាជ្យនៃស្ថាប័នច្បាប់ជាតិ។ បទប្បញ្ញត្តិនេះចេញពីគោលការណ៍ នៃដំណើរការក្តីចំពោះមុខ។

*រឿងក្តី MACHADO ទល់នឹងប្រទេសព័រទុយហ្កាល់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ កុម្ភៈ ១៩៩៦ កថាខណ្ឌ៣១។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៦(១)។ មាត្រានេះចែងពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលរួមបញ្ចូលទាំងសិទ្ធិទទួលបានសមភាពនៃអំណាចរវាងភាគី។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ឯកសារទាំងអស់ក្នុងសំណុំរឿង ត្រូវចុះលេខដោយក្រឡាបញ្ជី ក្នុងខណៈដែលឯកសារនេះ ត្រូវបានព្រាង ឬត្រូវបានទទួលដោយចៅក្រមស៊ើបសួរ៖** ឯកសារនេះ ដែលត្រូវបានព្រាងដោយចៅក្រម

ស៊ើបសួរ និង/ឬដោយបុគ្គល ដែលទទួលបានការចាត់តាំងពីចៅក្រម ព្រមទាំងឯកសារ ដែលត្រូវបានដាក់ជូនចៅក្រមស៊ើបសួរនឹងត្រូវដាក់ចូលក្នុងសំណុំរឿង។

*ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ 400 តុលាការកំពូលបារាំង ១៩ ឧសភា ១៩៥៨។*

**ក្រឡាបញ្ជី ត្រូវបញ្ជាក់ថា ឯកសារសំណុំរឿងថតចម្លង គឺបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម៖** ច្បាប់ចម្លងនៃឯកសារមួយ ដែលមិនមានហត្ថលេខាដើម របស់អ្នកនិពន្ធឯកសារនោះ និងគ្មានការបញ្ជាក់របស់ក្រឡាបញ្ជី មិនមានយថាភាពទេ។

*លេខ87-85018 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៧៦ តុលាការកំពូលបារាំង ១៧ មិថុនា ១៩៨៨។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៨១។ មាត្រានេះកំណត់ពីលក្ខខណ្ឌតម្រូវពិស្តារសម្រាប់ក្រឡាបញ្ជីក្នុងការរក្សាទុកសំណុំរឿង។

# មាត្រា ១៣២៖ ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា

*នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។*

*ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ ដីកានេះ ត្រូវមានសំអាងហេតុក្នុងការបដិសេធន៍ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។*

*ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។*

## ការអនុវត្តនៅ អ.វ.ត.ក

**សំណើសុំ ត្រូវតែបញ្ជាក់ពីមូលហេតុផ្អែកតាមអង្គហេតុ៖** សំណើសុំឱ្យបើកកិច្ចស៊ើបសួរណាមួយ ត្រូវតែមានការបញ្ជាក់ពីមូលហេតុនៃភាពចាំបាច់ ដើម្បីគាំទ្រសំណើររបស់ខ្លួន។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឲ្យប្រមូលភស្តុតាងដោះបន្ទុកអ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ៤៣។*

**សំណើសុំ ត្រូវតែពាក់ព័ន្ធនឹងបទឧក្រិដ្ឋ ដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ៖** សំណើសុំបើកកិច្ចស៊ើបសួរ ត្រូវតែបញ្ជាក់ពីកម្មវត្ថុដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ។

*រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឲ្យស៊ើបសួរទី១១ អ.វ.ត.ក អ.ប.ជ ១៨ សីហា ២០០៩ កថាខណ្ឌ២៤។*

**សំណើសុំ ត្រូវតែស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ៖** សំណើសុំបើកកិច្ចស៊ើបសួរ មានសុពលភាពក្នុងករណីដែលកិច្ចស៊ើបសួរដែលត្រូវបានស្នើសុំ គឺស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង/ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

*រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឲ្យស៊ើបសួរ ទ្រព្យសម្បត្តិរបស់ជនត្រូវចោទ អ.វ.ត.ក អ.ប.ជ ៤ សីហា ២០១០ កថាខណ្ឌ១៤។*

**សំណើសុំ ត្រូវតែចង្អុលបង្ហាញឲ្យបានច្បាស់លាស់អំពីកិច្ចស៊ើបសួរ និងមូលហេតុ៖** សំណើសុំឲ្យបើកកិច្ចស៊ើបសួរ ត្រូវតែមានភាពជាក់លាក់គ្រប់គ្រាន់និងចង្អុលបង្ហាញឲ្យបានច្បាស់

ពីកិច្ចស៊ើបសួរ ដែលត្រូវធ្វើ និងមូលហេតុនៃកិច្ចស៊ើបសួរទាំងនោះ។ លក្ខខណ្ឌតម្រូវនេះ ដើម្បីធានានូវកិច្ចដំណើរការនីតិវិធី មិនត្រូវបានពន្យារ ដោយគ្មានមូលហេតុ និងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះទាន់ពេលវេលាត្រូវបានការពារ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផនៈ បណ្តឹងឧទ្ធរណ៍ ស្តីពីភស្តុតាងបញ្ជាក់ថា ជនត្រូវចោទដឹងឮពីបទល្មើស អ.វ.ត.ក អ.ប.ជ ២៧ សីហា ២០១០ កថាខណ្ឌ៥៣។*

**កិច្ចស៊ើបសួរមាន គោលបំណងប្រមូលភស្តុតាងដែលមានប្រយោជន៍ នៅក្នុងការស្វែងរកការពិតៈ** កិច្ចស៊ើបសួរ គឺជាកិច្ចការដែលត្រូវបានធ្វើឡើង ដោយចៅក្រមស៊ើបសួរ ឬផ្ទេរទៅឲ្យនគរបាលយុត្តិធម៌ដើម្បីប្រមូលភស្តុតាងដែលមានផលប្រយោជន៍ ក្នុងការស្វែងរកការពិត។

*រឿងក្តី អៀង សារីៈ បណ្តឹងឧទ្ធរណ៍ស្តីពីសិទ្ធិទាក់ទងនឹងការបកប្រែ អ.វ.ត.ក អ.ប.ជ ២០ កុម្ភៈ ២០០៩ កថាខណ្ឌ២០ និង២៣។*

**សិទ្ធិរបស់ភាគីនានា ដើម្បីដឹងអំពីមូលហេតុនៃសេចក្តីសម្រេចៈ** រាល់ដីការបស់ចៅក្រមស៊ើបសួរលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ត្រូវបញ្ជាក់ពីមូលហេតុគាំទ្រ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធៈ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឯកសារភស្តុតាងបន្ថែម អ.វ.ត.ក អ.ប.ជ ១៩ មិថុនា ២០១០ កថាខណ្ឌ២៣-២៦។*

**ចៅក្រម ត្រូវបញ្ជាក់ពីមូលហេតុរួមនៃព័ត៌មានគាំទ្រសេចក្តីសម្រេចៈ** លក្ខខណ្ឌដែលតម្រូវឲ្យចៅក្រមចេញនូវសេចក្តីសម្រេច ដោយមានសំអាងហេតុ នៅពេលដែលបានខ្លួនបដិសេធសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ មានន័យថាចៅក្រម ត្រូវតែបញ្ជាក់ពីមូលហេតុរួមនៃព័ត៌មានគាំទ្រសេចក្តីសម្រេចរបស់គេ ដោយមិនចាំបាច់ពន្យល់គ្រប់ផ្នែកនោះទេ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធៈ បណ្តឹងឧទ្ធរណ៍ ស្តីពីការទទួលយកនូវពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៣៨។*

**ចៅក្រមស៊ើបសួរ មានឆន្ទានុសិទ្ធិនៅក្នុងការសម្រេច លើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរៈ** ចៅក្រមស៊ើបសួរ មានឯករាជភាពនៅក្នុងការអនុវត្តកិច្ចស៊ើបសួររបស់ខ្លួន។ ហេតុដូច្នេះកាលណាមិនមានការណែនាំជាក់លាក់ នៅក្នុងច្បាប់ទេ ចៅក្រមស៊ើបសួរ មានឆន្ទានុសិទ្ធិក្នុងការកំណត់ពីភាពមានប្រយោជន៍នៃសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ។ សំណើសុំ គឺជាការស្នើផ្តល់យោបល់ មិនមែនជាការបញ្ជាទេ ។

*រឿងក្តីអៀង សារីៈ បណ្តឹងឧទ្ធរណ៍ស្តីពីការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ ទាក់ទងទៅនឹងភស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ២១។*

ចៅក្រមស៊ើបសួរ ត្រូវតែច្រានចោលការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយសារសំណើទាំងនោះមិនត្រូវបានជឿជាក់ថា នាំមកនូវក្នុងការស្វែងរកការពិតទេ៖ ការណ៍នេះ ដោយសារតែករណីយកិច្ចរបស់គេ មិនត្រូវបន្តកិច្ចស៊ើបសួរហួសរយៈពេលកំណត់ពិតប្រាកដទេ ដើម្បីចៀសវាង អំពីការរំលោភបំពានភាពត្រឹមត្រូវនៃដំណើរការជំនុំជម្រះ។

*រឿងក្ដី នួន ជា អៀង សារី និងអៀង ធីរិទ្ធ៖ ដីកា ស្ដីពីការស្នើសុំ ឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងទៅនឹងភស្តុតាងដោះបន្ទុក អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបសួរ ១៩ មិថុនា ២០០៩ កថាខណ្ឌ១០។*

**ក្រៅពីភាពពាក់ព័ន្ធ ការកម្រិតលើឆន្ទានុសិទ្ធិមិនត្រូវបានគេអនុញ្ញាតឡើយ៖** រាល់ការកម្រិតលើឆន្ទានុសិទ្ធិក្នុងការទទួលយក ឬបដិសេធចោលសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរណាមួយក្រៅពីភាពពាក់ព័ន្ធ នៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ មិនត្រូវបានអនុញ្ញាតឡើយ។

*រឿងក្ដីនួន ជា អៀង សារី និងខៀវ សំផន៖ បណ្ដឹងឧទ្ធរណ៍ ស្ដីពីភស្តុតាងបញ្ជាក់ពីការដឹងឮអំពីឧក្រិដ្ឋកម្មរបស់ជនត្រូវចោទ អ.វ.ត.ក អ.ប.ជ ២៧ កញ្ញា ២០១០ កថាខណ្ឌ៦០-៦២។*

**សំណើសុំដាក់ភស្តុតាងចូលក្នុងសំណុំរឿង មិនមែនជាសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរឡើយ៖** សំណើបែបនេះ គឺសម្រាប់តែឲ្យចៅក្រមស៊ើបសួរ ចេញដីកាដែលចាំបាច់សម្រាប់នីតិវិធីសួរតែប៉ុណ្ណោះ។

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន៖ បណ្ដឹងឧទ្ធរណ៍ ស្ដីពីភស្តុតាងបញ្ជាក់ពីការដឹងឮអំពីឧក្រិដ្ឋកម្មរបស់ជនត្រូវចោទ អ.វ.ត.ក អ.ប.ជ ២៧ សីហា ២០១០ កថាខណ្ឌ៧។*

**សំណើសុំឲ្យបំពេញកិច្ចក្នុងអនាគត ក្រៅពីកិច្ចស៊ើបសួរ មិនត្រូវបានអនុញ្ញាតឡើយ៖** សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដែលមានសុពលភាព មិនត្រូវព្យាយាមបង្ខំឲ្យចៅក្រមអនុវត្តឆន្ទានុសិទ្ធិ នាពេលអនាគតឡើយ។ ប្រសិនបើសំណើមិនស្នើសុំដីកា ឬកិច្ចស៊ើបសួរណាមួយទេ ប៉ុន្តែដាក់កាតព្វកិច្ចឲ្យចៅក្រមស៊ើបសួរ បំពេញកិច្ចការក្រៅពីកិច្ចស៊ើបសួរសំណើបែបនេះ មិនត្រូវបានអនុញ្ញាតឡើយ ទោះបីជាកិច្ចការនោះស្ថិតក្នុងបរិបទនៃកិច្ចស៊ើបសួរក៏ដោយ។

*រឿងក្ដីអៀង សារី៖ បណ្ដឹងឧទ្ធរណ៍ ស្ដីពីសំណើសុំបញ្ជីវិភាគភស្តុតាង អ.វ.ត.ក អ.ប.ជ ៨ មិថុនា ២០១០ កថាខណ្ឌ១-៤។*

**សំណើសុំដែលធ្វើឡើងក្រោយការបិទការស៊ើបសួរ អាចទទួលយកបាន៖** សំណើសុំបំពេញនូវកិច្ចស៊ើបសួរបន្ថែម ដែលត្រូវបានដាក់ឡើងក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីការបិទការកិច្ចស៊ើបសួរ ត្រូវបានអនុញ្ញាត។

*រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍ស្ដីពីសំណើសុំ*

*ឯកសារភស្តុតាង អ.វ.ត.ក អ.ប.ជ ១៩ មិថុនា ២០១០ កថាខណ្ឌ១៣។*

**បទដ្ឋាននៃការពិនិត្យសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរឡើងវិញ៖** បទដ្ឋានពិនិត្យត្រឹមត្រូវ ដែលចៅក្រមស៊ើបសួរប្រើ ដើម្បីកំណត់ឆន្ទានុសិទ្ធិក្នុងការទទួលយក ឬបដិសេធសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ គឺថាតើសំណើនេះពាក់ព័ន្ធទៅនឹងវិសាលភាព នៃកិច្ចស៊ើបសួរដែរឬទេ ដើម្បីបញ្ជាក់ការពិត។

*រឿងក្តីនួន ជា អៀង សារី និងខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ស្តីពីភស្តុតាង បញ្ជាក់ថា ជនត្រូវចោទបានដឹងឮអំពីក្រិដ្ឋកម្ម អ.វ.ត.ក អ.ប.ជ ២៧ កញ្ញា ២០១០ កថាខណ្ឌ៤២-៤៥។*

**ភាពជាក់លាក់ និងភាពពាក់ព័ន្ធមិនគ្រប់គ្រាន់ក្នុងការបង្ហាញ ពីការប្រើឆន្ទានុសិទ្ធិមិនត្រឹមត្រូវ៖** អង្គហេតុដែលបានបង្ហាញថា សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដែលត្រូវបានគេបដិសេធបំពេញលក្ខខណ្ឌស្តីពីភាពជាក់លាក់ និងភាពពាក់ព័ន្ធ គឺមិនគ្រប់គ្រាន់ក្នុងការបង្ហាញថាការបដិសេធ គឺជាការប្រើឆន្ទានុសិទ្ធិមិនត្រឹមត្រូវឡើយ។

*រឿងក្តីនួន ជា អៀង សារី និងខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ស្តីពីភស្តុតាងបញ្ជាក់ថា ជនត្រូវចោទដឹងឮពីបទល្មើស អ.វ.ត.ក អ.ប.ជ ២៧ កញ្ញា ២០១០ កថាខណ្ឌ៥៧។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៥(១០) ៦៦(១) និង៦៦(៣)។ វិធាន៥៥(១០) គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា១៣២ ប៉ុន្តែក៏មិនបានកំណត់នូវរយៈពេល១៥ថ្ងៃ សម្រាប់ធ្វើដីកាសម្រេចបដិសេធទេ និងបានចែងយ៉ាងច្បាស់ថា ដីកាសម្រេចនេះ ជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍។ វិធាន៦៦(១) ផ្តល់នូវលទ្ធភាពឲ្យព្រះរាជអាជ្ញាស្នើសុំកិច្ចស៊ើបសួរបន្ថែម បន្ទាប់ពីមានសេចក្តីជូនដំណឹងបិទកិច្ចស៊ើបសួរ រីឯវិធាន៦៦(៣) អនុញ្ញាតឲ្យមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបិទកិច្ចស៊ើបសួរ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ភាគីមិនអាចស្នើសុំឲ្យសាក្សីផ្តល់ឯកសារមកឲ្យខ្លួនទេ៖** ភាគីអាចស្នើសុំឯកសារ ពីភាគីផ្សេងទៀតនៃរឿងក្តី។

*លេខ96-83118 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១៨ តុលាការកំពូលបារាំង ២៥ មីនា ១៩៩៧។*

**ប្រសិនបើចៅក្រមស៊ើបសួរ មិនចេញដីកាឆ្លើយតបទៅនឹងសំណើរបស់រដ្ឋអាជ្ញា៖** រដ្ឋអាជ្ញាអាចបញ្ជូនសំណើនេះទៅសភាស៊ើបសួរ ដោយផ្ទាល់បាន។

*លេខ02-82017 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៩១ តុលាការកំពូលបារាំង ៣០ មេសា ២០០២។*

**ចៅក្រមស៊ើបសួរ មានឆន្ទានុសិទ្ធិបដិសេធសំណើរបស់ភាគី៖** តុលាការកំពូលមិនអាចត្រួតត្រាបញ្ហានេះបានទេ។

*លេខ96-83118 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១៨ តុលាការកំពូលបារាំង ២៥ មីនា ១៩៩៧។*

**មេធាវីរបស់ភាគី អាចចូលរួមក្នុងកិច្ចដែលចៅក្រមស៊ើបសួរធ្វើការពិនិត្យអ្នកជំនាញ តាមសំណើរបស់រដ្ឋអាជ្ញា៖** បទប្បញ្ញត្តិនេះកើតចេញពីគោលការណ៍ស្តីពីសមភាព នៃសិទ្ធិអំណាចរបស់ភាគី ក្នុងរឿងក្តី។

*លេខ10-81313 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៧៨ តុលាការកំពូលបារាំង ១១ ឧសភា ២០១០។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៨០.៣ និង៨២។ មាត្រា៨០.៣ កំណត់ពីកាលៈទេសៈ និងនីតិវិធីជាធរមានសម្រាប់ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម រីឯមាត្រា៨២ ចែងអំពីនីតិវិធីសម្រាប់ឲ្យរដ្ឋអាជ្ញាដាក់សំណើសុំកិច្ចស៊ើបសួរជូនទៅចៅក្រមស៊ើបសួរ និងមានសិទ្ធិបញ្ជូនរឿងក្តីនេះទៅសភាស៊ើបសួរ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនចេញដីកាសម្រេចលើរឿងក្តីនេះ។

# មាត្រា ១៣៣៖ ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ

*នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីសួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។*

*ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធ នៅក្នុងថិរវេលា ១ (មួយ) ខែបន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះ ត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។*

*ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងថិរវេលា ១ (មួយ) ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**សំណើសុំត្រូវតែបញ្ជាក់ពីការសុំឲ្យប្រមូលនូវភស្តុតាង ដែលមានប្រយោជន៍ក្នុងការស្វែងរកការពិត៖** សំណើសុំកិច្ចស៊ើបសួរ របស់ជនត្រូវចោទត្រូវតែបញ្ជាក់ អំពីការស្នើសុំឲ្យប្រមូលព័ត៌មាន ដែលមានប្រយោជន៍ក្នុងការស្វែងរកការពិត។

> *រឿងក្តីអៀង សារី៖ ការទទួលយកបាននូវបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងភស្តុតាង ដែលទទួលបានពីអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ២២-២៣។*

**សំណើសុំត្រូវតែ មានភាពច្បាស់លាស់ ជាក់-លាក់ និងពាក់ព័ន្ធ៖** សំណើសុំឲ្យបើកកិច្ចស៊ើបសួរត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់ ពីកិច្ចស៊ើបសួរដែលត្រូវស្នើសុំ និងពន្យល់អំពីមូលហេតុដែលខ្លួនយល់ថា ចាំបាច់ត្រូវតែស៊ើបសួរ។

> *រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំប្រមូលភស្តុតាង ដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ៤៣។*

**សំណើសុំ ត្រូវតែបញ្ជាក់ពីចំណុចសំខាន់ៗនៃកិច្ចស៊ើបសួរ និងពន្យល់អំពីភាពពាក់ព័ន្ធគ្នា។ ចៅក្រម អាចបដិសេធ កាលណាកិច្ចនោះ ដូចគ្នាទៅនឹងបញ្ហាដែលបានស៊ើបសួររួចហើយ៖** សំណើសុំឲ្យបើកកិច្ចស៊ើបសួរ ត្រូវតែបញ្ជាក់អំពីចំណុចសំខាន់ៗ នៃកិច្ចស៊ើបសួរឲ្យបានពិស្តារច្បាស់លាស់ និងពន្យល់ឲ្យល្អិតល្អន់អំពីមូលហេតុថា ការស្នើសុំនេះ គឺពាក់ព័ន្ធទៅនឹងការស្វែងរកការពិត (លក្ខខណ្ឌតម្រូវ ស្តីពីភស្តុតាងពាក់ព័ន្ធ ដែលបានឃើញ ឬដឹងពុជាបឋម)។ លក្ខខណ្ឌ ស្តីពីសេចក្តីបញ្ជាក់ពីភាពពាក់ព័ន្ធមានអនុលក្ខខណ្ឌពីរ៖ (១) ព័ត៌មាន

ត្រូវតែស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ និង (២) ត្រូវតែមានទំនាក់ទំនងជាក់ស្តែងរវាងកិច្ចដែលបានស្នើសុំ និងបញ្ហាដែលស្ថិតក្រោមការស៊ើបសួរ រួមបញ្ចូលទាំងបទល្មើស ដែលត្រូវបានចោទប្រកាន់។ កម្រិតនៃភាពលំអិតត្រូវមាន គឺអាស្រ័យលើអង្គហេតុជាក់លាក់នៃរឿងក្តី ប៉ុន្តែត្រូវមានទំនាក់ទំនងផ្ទាល់ទៅនឹងបទចោទដែលមាន។ ជាចុងក្រោយ ចៅក្រមអាចបដិសេធបំពេញកិច្ចស៊ើបសួរ ប្រសិនបើគាត់យល់ថា កិច្ចស៊ើបសួរ ដែលបានស្នើឡើងនោះ គឺដូចគ្នាទៅនឹងបញ្ហាដែលបានស៊ើបសួររួចហើយ។

*រឿងក្តីនួន ជា អៀង សារី និងខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ ស្តីពីកស្តុតាងបញ្ជាក់ថា ជនត្រូវចោទដឹងឮពីបទល្មើស អ.វ.ត.ក អ.ប.ជ ២៧ កញ្ញា ២០១០ កថាខណ្ឌ៤៧-៥២ និង ៥៧។*

**ចៅក្រមស៊ើបសួរ ត្រូវតែច្រានចោលការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយសារសំណើទាំងនោះមិនត្រូវបានជឿជាក់ថា នាំមកនូវក្នុងការស្វែងរកការពិតទេ៖** ការណ៍នេះ ដោយសារតែករណីយកិច្ចរបស់គេ មិនត្រូវបន្តកិច្ចស៊ើបសួរហួសរយៈពេលបានកំណត់ពិតប្រាកដ ដើម្បីចៀសវាងនូវការរំលោភបំពានទៅលើភាពត្រឹមត្រូវនៃដំណើរការជំនុំជម្រះ។

*រឿងក្តីនួន ជា អៀង សារី និងអៀង ធីរិទ្ធ៖ ដីកាស្តីពីការស្នើសុំ ឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងកស្តុតាងដោះបន្ទុក អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបសួរ ១៩ មិថុនា ២០០៩ កថាខណ្ឌ១០។*

**សំណើសុំ គ្រាន់តែជាការស្នើនូវយោបល់ការពិនិត្យឡើងវិញ លើការបដិសេធត្រូវបានកំរិតត្រឹមតែបញ្ហាថា តើឆន្ទានុសិទ្ធិត្រូវបានប្រើសមស្រប និងត្រឹមត្រូវតាមច្បាប់ឬទេ៖** សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ មិនមែនជាការបង្ខំឲ្យបើកកិច្ចស៊ើបសួរទេ ហើយចៅក្រមស៊ើបសួរមានឆន្ទានុសិទ្ធិដ៏ទូលាយ នៅក្នុងការសម្រេចអំពីភាពមានប្រយោជន៍ និងចាត់ការទៅលើសំណើនេះ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឲ្យបំពេញនូវកិច្ចស៊ើបសួរ ទាក់ទងទៅនឹងកស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ២១ និង២៦។*

**វិការៈនៃនីតិវិធីអំពើពុករលួយ មិនត្រូវបានអនុញ្ញាតឲ្យឡើយ៖** ភាគី មិនអាចប្រើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស៊ើបសួរអំពីការជ្រៀតជ្រែកខាងរដ្ឋបាលតុលាការ ឬអំពើពុករលួយនៅក្នុងតុលាការបានទេ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ លើកទី១១ របស់នួន ជា អ.វ.ត.ក អ.ប.ជ ២៥ សីហា ២០០៩ កថាខណ្ឌ២៥-២៦។ រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ លើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ លើកទី១១ អ.វ.ត.ក អ.ប.ជ ១៨ សីហា ២០០៩ កថាខណ្ឌ២៨។*

**មានតែចៅក្រមទេ ដែលមានអំណាចអនុវត្តកិច្ចស៊ើបសួរ៖** ភាគី មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងកិច្ចស៊ើបសួរទេ ប៉ុន្តែអាចធ្វើការអង្កេតបឋមបាន ដើម្បីកំណត់ថា តើគួរតែធ្វើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយតុលាការឬទេ ដោយរួមបញ្ចូលទាំងការពិនិត្យលើប្រភពសាធារណៈពាក់ព័ន្ធ ដែលមានសក្តានុពល។ ទោះបីជាយ៉ាងណាក្តី ភាគី ក៏មិនត្រូវបានគេអនុញ្ញាតឲ្យអង្កេតចូលទៅក្នុងប្រភពដែលមិនសាធារណៈឡើយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីការស្នើសុំឯកសារភស្តុតាងបន្ថែម អ.វ. ត.ក អ.ប.ជ ១៥ មិថុនា ២០១០ កថាខណ្ឌ១០-១២។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៥(១០) ៥៨ ៦៦(១) និង៦៦(៣)។ វិធាន៥៥(១០) គឺស្រដៀងគ្នាមែនទែនទៅនឹងបទប្បញ្ញត្តិនៃមាត្រា១៣៣ ប៉ុន្តែមិនបានកំណត់រយៈពេល ១៥ថ្ងៃ សម្រាប់ធ្វើដីកាសម្រេចបដិសេធទេ និងចែងយ៉ាងច្បាស់ថា ដីកាសម្រេចនេះ ជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍។ វិធាន៦៦(១) ផ្តល់លទ្ធភាពឲ្យជនត្រូវចោទស្នើសុំកិច្ចស៊ើបសួរបន្ថែម បន្ទាប់ពីមានសេចក្តីជូនដំណឹងបិទកិច្ចស៊ើបសួរ រីឯវិធាន៦៦(៣) អនុញ្ញាតឲ្យមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបិទកិច្ចស៊ើបសួរ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

### *គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប*

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការរំលោភ៖ ការបដិសេធមិនឲ្យជនត្រូវចោទកោះហៅសាក្សីដែលពាក់ព័ន្ធ៖** ទោះបីជាសិទ្ធិក្នុងការបង្ហាញភស្តុតាងដោយខ្លួនឯង មិននាំឲ្យជនត្រូវចោទមានសិទ្ធិដែលគ្មានព្រំដែន ក្នុងការពិនិត្យតទល់ទៅនឹងសាក្សីដោយខ្លួនឯងក៏ដោយ ក៏ការបដិសេធមិនឲ្យជនត្រូវចោទកោះហៅសាក្សីដែលពាក់ព័ន្ធ ជាការរំលោភដែរ។

*រឿងក្តី KHUSEYNOVA និងBUTAEVIA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ តុលា ២០០៨ កថាខណ្ឌ៨.៥។*

**មិនអាចដកហូតសិទ្ធិជនត្រូវចោទ នៅក្នុងការបង្ហាញ និងពិនិត្យភស្តុតាងបានឡើយ៖** ទោះបីជា រដ្ឋអាចបង្កើតវិធានស្តីពីភស្តុតាង នៅក្នុងច្បាប់របស់ខ្លួនក៏ដោយ វិធានច្បាប់ជាតិ មិនអាចបំបាត់សិទ្ធិ

របស់ជនត្រូវចោទក្នុងការបង្ខំឲ្យសាក្សីមានវត្តមាន និងសួរផ្ចាញ់សាក្សីទាំងនោះ ដូចដែលខាងតំណាងអយ្យការមានសិទ្ធិធ្វើដូច្នោះដែរនោះទេ។

*រឿងក្តី INDIEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣១ មីនា ២០០៩ កថាខណ្ឌ ៩.៦។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ៖*** មាត្រា១៤(៣) (ង)។ មាត្រានេះការពារសិទ្ធិរបស់ជនត្រូវចោទ ក្នុងការពិនិត្យតទល់សាក្សីប្រឆាំងនឹងខ្លួន និងពិនិត្យតទល់នឹងសាក្សីដោយខ្លួនឯង។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ជនត្រូវចោទ មានសិទ្ធិកោះហៅ ពិនិត្យតទល់ ឬបានពិនិត្យសាក្សី ក្នុងលក្ខខណ្ឌដូចគ្នានឹងរដ្ឋអាជ្ញាដែរ៖** វិធាននេះក៏អនុវត្តផងដែរក្នុងនីតិវិធីស៊ើបសួរ។

*រឿងក្តី BÖNISCH ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ៦ ឧសភា ១៩៨៥ កថាខណ្ឌ៣៣។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** ៦(៣)។ មាត្រានេះផ្តល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលរួមទាំងសិទ្ធិជនត្រូវចោទក្នុងអំឡុងពេលជំនុំជម្រះ ជាពិសេសរួមទាំងសិទ្ធិកោះហៅពិនិត្យតទល់ ឬបានពិនិត្យសាក្សី ក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងភាគីដែលចោទប្រកាន់ខ្លួនដែរ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ភាគីមិនអាចស្នើសុំឲ្យសាក្សី ផ្តល់ឯកសារមកឲ្យខ្លួនទេ៖** ភាគីអាចស្នើសុំឯកសារ ពីភាគីផ្សេងទៀតនៃរឿងក្តី។

*លេខ96-83118 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១៨ តុលាការកំពូលបារាំង ២៥ មីនា ១៩៩៧។*

**ចៅក្រមស៊ើបសួរ មានឆន្ទានុសិទ្ធិបដិសេធនូវសំណើរបស់ភាគី៖** តុលាការកំពូល មិនអាចត្រួតត្រាបញ្ហានេះបានទេ។

*លេខ96-83118 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១៨ តុលាការកំពូលបារាំង ២៥ មីនា ១៩៩៧។*

**មេធាវីរបស់ភាគី អាចចូលរួម នៅពេលចៅក្រមស៊ើបសួរធ្វើការពិនិត្យអ្នកជំនាញ តាមសំណើរបស់រដ្ឋអាជ្ញា៖** បទប្បញ្ញត្តិនេះ កើតចេញមកពីគោលការណ៍ស្តីពីសមភាពនៃសិទ្ធិអំណាច របស់ភាគីនៅក្នុងរឿងក្តី។

*លេខ10-81313 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៧៨ តុលាការកំពូលបារាំង ១១ ឧសភា ២០១០។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា៨២(១)។ មាត្រានេះ ផ្តល់សិទ្ធិឲ្យភាគីស្នើសុំឲ្យចៅក្រមស៊ើបសួរ បើកកិច្ចស៊ើបសួរ និងផ្តល់អំណាចឲ្យចៅក្រមស៊ើបសួរអនុវត្ត ឬបដិសេធកិច្ចទាំងនោះ តាមរយៈដីកាសម្រេចដែលមានសំអាងហេតុ។

# មាត្រា ១៣៤៖ ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី

*នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្ដឹងរដ្ឋប្បវេណី អាចសុំដល់ចៅក្រមស៊ើបសួរឱ្យស្ដាប់ចម្លើយខ្លួន ស្ដាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។*

*ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធក្នុងថិរវេលា១ (មួយ) ខែ ក្រោយពេលទទួលពាក្យសុំ។ ដីកានេះ ត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្ដឹងរដ្ឋប្បវេណី។*

*ប្រសិនបើ ចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងថិរវេលា១ (មួយ) ខែទេ ដើមបណ្ដឹងរដ្ឋប្បវេណី អាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។*

## ការអនុវត្តនៅ អ.វ.ត.ក

**ការអង្កេតបឋម លើប្រភពសាធារណៈត្រូវបានអនុញ្ញាត៖** ភាគីនានា អាចធ្វើការអង្កេតបឋមលើប្រភពសាធារណៈ ដែលចាំបាច់សម្រាប់ការអនុវត្តនូវសិទ្ធិរបស់ខ្លួនឲ្យមានប្រសិទ្ធភាព ដើម្បីស្នើឲ្យសុំឲ្យបំពេញកិច្ចស៊ើបសួរ។

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន៖ បណ្ដឹងឧទ្ធរណ៍ ស្ដីពីសំណើសុំឯកសារភស្តុតាងបន្ថែម អ.វ.ត.ក អ.ប.ជ ១៥ មិថុនា ២០១០ កថាខណ្ឌ១១-១២។*

**សិទ្ធិស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ លើអង្គហេតុថ្មី បើអង្គហេតុនោះមាន នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម៖** ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនមានសិទ្ធិក្នុងការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរលើអង្គហេតុថ្មី នៅក្នុងកាលៈទេសៈដែលមានស្ថានទម្ងន់បានទេ លើកលែងតែអង្គហេតុទាំងនោះ ត្រូវបានព្រះរាជអាជ្ញាកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និងឌុច៖ បណ្ដឹងឧទ្ធរណ៍ ស្ដីពីការសួរយកចម្លើយ ករណីអាពាហ៍ពិពាហ៍ ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ អ.វ.ត.ក អ.ប.ជ ២១ កក្កដា ២០១០ កថាខណ្ឌ១១។*

**ភាពពាក់ព័ន្ធ៖ ភស្តុតាង ត្រូវស្ថិតក្នុង និងទាក់ទងទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរ៖** ដើម្បីបង្ហាញភស្តុតាងបានឃើញ ឬដឹងលឺជាបឋមថាសំណើសុំបើកកិច្ចស៊ើបសួរ មានភាពពាក់ព័ន្ធ ទៅនឹងការស្វែងរកការពិត ភាគីដែលស្នើ

សុំត្រូវបង្ហាញថា (១)សំណើរបស់ខ្លួនស្ថិតនៅក្នុងវិសាលភាព នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និង(២) នាំឲ្យមានការស្វែងរកការពិត។ ដើម្បីបង្ហាញថាសំណើនោះនឹងជួយដល់ការស្វែងរកការពិត សំណើនោះ ត្រូវបង្ហាញអំពីទំនាក់ទំនងរវាងព័ត៌មាន ដែលខ្លួនស្វែងរកតាមរយៈកិច្ច និងបញ្ហាដែលស្ថិតនៅក្នុងវិសាលភាព នៃកិច្ចស៊ើបសួរ។ ការលើកឡើងនូវអំណះអំណាងពីភាពពាក់ព័ន្ធគ្នា ឬភាពចាំបាច់គឺមិនគ្រប់គ្រាន់ឡើយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ ស្តីពីភស្តុតាងបញ្ជាក់ថា ជនត្រូវចោទដឹងឮពីបទល្មើស អ.វ.ត.ក អ.ប.ជ ២៧ កញ្ញា ២០១០ កថាខណ្ឌ៤៩-៥០។*

**ចៅក្រមស៊ើបសួរ មានឆន្ទានុសិទ្ធិទូលាយ ក្នុងការសម្រេចអំពីសំណុំសុំកិច្ចស៊ើបសួរ៖** ភាគីស្នើជាយោបល់ ប៉ុន្តែមិនដាក់កាតព្វកិច្ចឲ្យចៅក្រមស៊ើបសួរ អនុវត្តកិច្ចស៊ើបសួរ ដើម្បីស្វែងរកការពិត។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីការសុំឲ្យបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងភស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ២១។*

**បទដ្ឋានសមស្របក្នុងការកំណត់អំពីសំណើសុំកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងការស្វែងរកការពិត៖** បទដ្ឋាន ដើម្បីកំណត់ថាតើសំណើមានពាក់ព័ន្ធទៅនឹងវិសាលភាព នៃកិច្ចស៊ើបសួរ គឺដើម្បីស្វែងរកការពិត ដោយមិនចាំបាច់តែពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលមានតម្លៃជាភស្តុតាងទេ។ ការកម្រិតឲ្យពិចារណាលើអង្គហេតុ ដែលមានតម្លៃជាភស្តុតាង ចៅក្រមស៊ើបសួរអាចដកចេញបាននូវភស្តុតាងដែលពាក់ព័ន្ធ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ ស្តីពីភស្តុតាងបញ្ជាក់ថា ជនត្រូវចោទដឹងឮពីឧក្រិដ្ឋកម្ម អ.វ.ត.ក អ.ប.ជ ២៧ កញ្ញា ២០១០ កថាខណ្ឌ៦០-៦១។*

**ចៅក្រមស៊ើបសួរ ត្រូវតែច្រានចោលការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយសារសំណើទាំងនោះមិនត្រូវបានជឿជាក់ថា នាំមកនូវក្នុងការស្វែងរកការពិតទេ៖** ការណ៍នេះ ដោយសារតែករណីយកិច្ចរបស់គេ មិនត្រូវបន្តកិច្ចស៊ើបសួរហួសរយៈពេលកំណត់ពិតប្រាកដ ដើម្បីចៀសវាងក្នុងការរំលោភបំពាន អំពីភាពត្រឹមត្រូវ នៃដំណើរការជំនុំជម្រះ។

*រឿងក្តីនួន ជា អៀង សារី និងអៀង ធីរិទ្ធ៖ ដីកា ស្តីពីការស្នើសុំ ឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងទៅនឹងភស្តុតាងដោះបន្ទុក អ.វ.ត.ក ការិយាល័យ សហចៅក្រមស៊ើបសួរ ១៩ មិថុនា ២០០៩ កថាខណ្ឌ១០។*

**កត្តាដែលចៅក្រមស៊ើបសួរ អាចយកជាសំអាងសម្រាប់ការប្រើឆន្ទានុសិទ្ធិ បដិសេធសំណើសុំកិច្ចស៊ើបសួរ៖** កត្តាទាំងនេះត្រូវរាប់បញ្ចូល

ទាំងការរកឃើញ ដែលថា សំណើមិនពាក់ព័ន្ធរវាងឯកសារទៅនឹងកិច្ចស៊ើបសួរ ឬការសម្រេចថា ចៅក្រមបានអនុវត្តកិច្ច ដែលបានស្នើសុំនេះរួចហើយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផនៈ បណ្តឹងឧទ្ធរណ៍ ស្តីពីភស្តុតាងបញ្ជាក់ថា ជនត្រូវចោទដឹងឮពីបទល្មើស អ.វ.ត.ក អ.ប.ជ ២៧ កញ្ញា ២០១០ កថាខណ្ឌ៥៦ និង៥៧។*

**ការមិនបានបំពេញ តាមលក្ខខណ្ឌតម្រូវមួយនៃការបញ្ជាក់ ពីភស្តុតាងពាក់ព័ន្ធ ដែលបានឃើញ ឬដឹងលឺជាបឋម គឺជាមូលហេតុគ្រាប់គ្រាន់សម្រាប់បដិសេធសំណើសុំ៖** សំណើសុំដែលមានសុពលភាព ត្រូវតែកំណត់អំពីអត្តសញ្ញាណ នៃកិច្ចស៊ើបសួរឲ្យបានច្បាស់លាស់ និងបញ្ជាក់ ពីមូលហេតុពិស្តារ ដែលថាកិច្ចស៊ើបសួរនេះពាក់ព័ន្ធ ទៅនឹងការស្វែងរកការពិត។ ទោះបីជា បានបំពេញតាមលក្ខខណ្ឌទៃទៀតក្តី បើភាគីស្នើសុំមិនបានបំពេញតាមលក្ខខណ្ឌតម្រូវណាមួយនោះទេ ការខកខាននេះ បង្កើតបានជាមូលហេតុ ដែលមានសុពលភាព និងគ្រប់គ្រាន់ សម្រាប់ឲ្យចៅក្រមស៊ើបសួរបដិសេធសំណើសុំបាន។

*រឿងក្តីនួន ជា អៀង សារី ខៀវសំផនៈ បណ្តឹងឧទ្ធរណ៍ ស្តីពីភស្តុតាងបញ្ជាក់ថា ជនត្រូវចោទដឹងឮពីបទល្មើស អ.វ.ត.ក អ.ប.ជ ២៧ កញ្ញា ២០១០ កថាខណ្ឌ៤៧ និង៥២។*

**វិការៈនៃនីតិវិធី អំពើពុករលួយមិនត្រូវបានអនុញ្ញាតឡើយ៖** ភាគីមិនអាចប្រើសំណើសុំឲ្យបើកកិច្ចស៊ើបសួរ ដើម្បីស៊ើបសួរកំហុសនីតិវិធី ឬអំពើពុករលួយនៅក្នុងតុលាការបានទេ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យបើកកិច្ចស៊ើបសួរ លើកទី១១ របស់នួន ជា អ.វ.ត.ក អ.ប.ជ ២៥ សីហា ២០០៩ កថាខណ្ឌ២៦។ រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំ ឲ្យបំពេញកិច្ចស៊ើបសួរលើកទីដប់មួយ អ.វ.ត.ក អ.ប.ជ ១៨ សីហា ២០០៩ កថាខណ្ឌ២៨។*

**ដីកាសម្រេចបដិសេធ ត្រូវតែមានសំអាងហេតុ៖** រាល់ពេលដែលខ្លួនបដិសេធនូវសំណើសុំកិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវតែបញ្ជាក់អំពីសំអាងហេតុ នៅក្នុងការបដិសេធនោះ។ តម្រូវការបែបនេះ គឺដើម្បីធានាថា ភាគីត្រូវបានជូនដំណឹងពីមូលដ្ឋាននៃសេចក្តីសម្រេច ដូច្នេះភាគីនឹងមានព័ត៌មានគ្រប់គ្រាន់ ដើម្បីសម្រេចថាតើគួរត្រូវប្តឹងឧទ្ធរណ៍ ឬអត់ និងដោយយោងលើសំអាងហេតុបែបណា។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីការស្នើសុំឯកសារភស្តុតាងបន្ថែម អ.វ.ត.ក អ.ប.ជ ១៩ មិថុនា ២០១០ កថាខណ្ឌ២៣-២៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៥៥(១០) ៦៦(១) និង៦៦(៣)។ វិធាន៥៥(១០) ស្រដៀងគ្នាមែនទែនទៅនឹងបទប្បញ្ញត្តិនៃមាត្រា១៣៣ ប៉ុន្តែមិនបានកំណត់រយៈពេល ១៥ថ្ងៃ សម្រាប់ធ្វើដីកាសម្រេចបដិសេធទេ និងចែងយ៉ាងច្បាស់ថាដីកាសម្រេចនេះ ជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍។ វិធាន៦៦(១) ផ្តល់លទ្ធភាពឲ្យភាគីស្នើសុំកិច្ចស៊ើបសួរបន្ថែម បន្ទាប់ពីមានសេចក្តីជូនដំណឹងបិទកិច្ចស៊ើបសួរ ប៉ុន្តែវិធាន៦៦(៣) អនុញ្ញាតឲ្យមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបិទកិច្ចស៊ើបសួរ។

## ***ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត***

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ភាគីមិនអាចស្នើសុំឲ្យសាក្សី ផ្តល់ឯកសារមកឲ្យខ្លួនទេ៖** ភាគីអាចស្នើសុំឯកសារ ពីភាគីផ្សេងទៀតនៃរឿងក្តី។

*លេខ96-83118 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១៨ តុលាការកំពូលបារាំង ២៥ មីនា ១៩៩៧។*

**ដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំកិច្ចស៊ើបសួរបន្ទាប់ពីការបើកកិច្ចស៊ើបសួរប៉ុណ្ណោះ៖** ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចបង្ខំឲ្យចៅក្រមស៊ើបសួរអនុវត្តកិច្ចស៊ើបសួរបានទេ កាលណារដ្ឋអាជ្ញាបានទទួលពាក្យបណ្តឹង ក៏ប៉ុន្តែមិនទាន់បានធ្វើការចោទប្រកាន់នៅឡើយ។

*លេខ05-82807 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣០៤ តុលាការកំពូលបារាំង ២២ វិច្ឆិកា ២០០៥។*

**ចៅក្រមស៊ើបសួរ មានឆន្ទានុសិទ្ធិបដិសេធសំណើសុំរបស់ភាគី៖** តុលាការកំពូល មិនអាចត្រួតត្រាលើបញ្ហានេះបានទេ។

*លេខ96-83118 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១៨ តុលាការកំពូលបារាំង ២៥ មីនា ១៩៩៧។*

**មេធាវីរបស់ភាគី អាចចូលរួមក្នុងការពិនិត្យអ្នកជំនាញ ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ បន្ទាប់ពីមានសំណើរបស់រដ្ឋអាជ្ញា៖** បទប្បញ្ញត្តិនេះ កើតចេញមកពីគោលការណ៍ស្តីពីសមភាពនៃសិទ្ធិអំណាច របស់ភាគីក្នុងរឿងក្តី។

*លេខ10-81313 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៧៨ តុលាការកំពូលបារាំង ១១ ឧសភា ២០១០។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៨២(១)។ មាត្រានេះ ផ្តល់សិទ្ធិឲ្យភាគីស្នើសុំចៅក្រមស៊ើបសួរបើកកិច្ចស៊ើបសួរ និងផ្តល់អំណាចឲ្យចៅក្រមស៊ើបសួរអនុវត្ត ឬបដិសេធកិច្ចទាំងនោះ តាមរយៈដីកាសម្រេចដែលមានសំអាងហេតុ។

# មាត្រា ១៣៧៖ ការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍

*កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថាជាជនរងគ្រោះ អាចសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ បានគ្រប់ពេលវេលា។*

*ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ធ្វើឡើងដោយគ្មានតម្រូវតាមទម្រង់ណាមួយឡើយ។*

*កាលណាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងតាមលិខិត លិខិតនេះត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។ កាលណាការតាំងខ្លួនត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ។*

*ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងអំពីការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។*

## ***ការអនុវត្តនៅ អ.វ.ត.ក***

**លទ្ធភាពរបស់ជនរងគ្រោះ ដ៏មានកំរិតក្នុងការចោទប្រកាន់ពីអង្គហេតុថ្មី៖** ជនរងគ្រោះដែលស្វែងរកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចលើកឡើងពីអង្គហេតុថ្មី នៅក្នុងពាក្យសុំក្នុងគោលបំណង នៃកិច្ចស៊ើបសួរបានទេ ប៉ុន្តែអាចលើកឡើងពីអង្គហេតុថ្មី ដែលអាចបង្ហាញពីទំនាក់ទំនងហេតុ/ផល ព្យសនកម្មដែលជនរងគ្រោះបានទទួលរង និងយ៉ាងហោចណាស់ ក៏ភ្ជាប់ទៅនឹងបទល្មើសមួយ ដែលត្រូវបានចោទប្រកាន់ ប្រឆាំងនឹងជនត្រូវចោទក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៤២។*

**ចៅក្រមស៊ើបសួរ ត្រូវទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី កាលណាគេរកឃើញមានមូលដ្ឋានបង្កើតបានជាអង្គហេតុ ដើម្បីបញ្ជាក់អំពីហានិភ័យបានទទួលរង ទាក់ទងនឹងអង្គហេតុនានាស្ថិតក្រោមការស៊ើបសួរ៖** ចៅក្រមស៊ើបសួរ មិនធ្វើសេចក្តីសម្រេចចុងក្រោយលើហា-

និភ័យ ដែលទទួលរង ដោយជនរងគ្រោះទេ តែសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ ដីកា ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបសួរ ២៥ សីហា ២០១០ កថាខណ្ឌ៩។*

**ភាគីត្រូវតែធ្វើឲ្យអង្គជំនុំជម្រះ ជឿជាក់ទៅលើការណ៍ ដែលទំនងជាពិត ដែលគាំទ្រអង្គហេតុទាំងនោះយ៉ាងពិតប្រាកដ៖** ក្នុងពេលពិចារណាលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ភាគីត្រូវតែធ្វើឲ្យអង្គបុរេជំនុំជម្រះជឿជាក់ថា អង្គហេតុដែលបានលើកឡើង ដើម្បីគាំទ្រពាក្យសុំ មានព័ត៌មានពិត ច្រើនជាងការមិនពិត។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីការទទួលយកពាក្យសុំ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្ប វេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៩២។*

**អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ ត្រូវតែទទួលបាននូវសេចក្តីសម្រេចជាក់លាក់ និងជាលក្ខណៈបុគ្គល៖** ចៅក្រមស៊ើបសួរ ត្រូវតែបញ្ជាក់ពីការពិនិត្យលើពាក្យសុំនីមួយៗ។ សេចក្តីសម្រេចអាចមានលក្ខណៈជាទម្រង់រួម ក៏ប៉ុន្តែ មិនអាចប្រើសំអាងហេតុដូចគ្នា សម្រាប់ពាក្យសុំទាំងអស់ទេ និងមិនជាក់លាក់ ចំពោះពាក្យសុំនីមួយៗឡើយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីការទទួលយកពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៣៧ និង៣៩។*

**ភស្តុតាងអំពីអត្តសញ្ញាណ អាចបត់បែនបាន៖** វិធីសាស្ត្រអាចបត់បែនទៅបាន ត្រូវបានអនុវត្តចំពោះលក្ខខណ្ឌ ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញយ៉ាងច្បាស់អំពីអត្តសញ្ញាណរបស់ខ្លួន ឧ. សេចក្តីប្រកាសពីមេភូមិ ឬប្រធានឃុំ អាចទទួលយកបានថា ជាភស្តុតាងបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៩៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន២៣ស្ទួន។ វិធាននេះខុសពីមាត្រា១៣៧ ក្នុងខ្លឹមសារដែលថា ជនរងគ្រោះដែលចង់ចូលរួមក្នុងរឿងក្តី ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ មិនឲ្យលើសពី១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីចៅក្រមស៊ើបសួរជូនដំណឹងទៅភាគីអំពីការបិទកិច្ចស៊ើបសួរ។ វិធាន២៣ស្ទួន (២) ក៏បានចែងផងដែរថា ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និងជនត្រូវចោទ អំពីពាក្យសុំតាំងខ្លួនជា

ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែត្រូវអនុវត្តវិធាននេះ ដោយពិចារណាលើភាពចាំបាច់នៃការការពារជនរងគ្រោះ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុប ត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**កាលណាតុលាការរកឃើញថា ជនជាប់ចោទគ្មានការទទួលខុសត្រូវព្រហ្មទណ្ឌទេ អ្នកដាក់ពាក្យសុំនឹងត្រូវអស់សិទ្ធិទាមទារសំណង ក្នុងតុលាការរដ្ឋប្បវេណីផងដែរ ៖** វិធាននេះ អនុវត្តចំពោះស្ថានភាពដែលអ្នកដាក់ពាក្យសុំ បានចាប់ផ្តើមនូវនីតិវិធីព្រហ្មទណ្ឌ ដើម្បីទទួលបាននូវការផ្តន្ទាទោសមួយ។ លទ្ធផលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺជាកត្តាផ្ទាល់ក្នុងការសម្រេចលើសិទ្ធិរបស់អ្នកដាក់ពាក្យក្នុងការទទួលបានសំណង ក្នុងតុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី។

*រឿងក្តី ACQUAVIVA ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ វិច្ឆិកា ១៩៩៥ កថាខណ្ឌ៤៧។*

**សិទ្ធិរបស់ជនរងគ្រោះ ក្នុងការធានាការចោទប្រកាន់ព្រហ្មទណ្ឌ ឬការកំណត់ទោសរបស់ភាគីទីបី មិនអាចបំបែកចេញ ពីសិទ្ធិក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីក្នុងច្បាប់ជាតិបានទេ៖** សិទ្ធិក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណី និងការដាក់ជូននូវសេចក្តីអង្កេត ដែលខ្លួនយល់ថា ពាក់ព័ន្ធទៅនឹងរឿងក្តីស្ថិតនៅក្នុងវិសាលភាពនៃអនុសញ្ញា។ ប៉ុន្តែតុលាការមិនអាចសម្រេចលើបញ្ហា ដែលតម្រូវឲ្យមានការបកស្រាយច្បាប់ជាតិបានទេ លើកលែងតែ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ច្បាប់ទាំងនេះ រំលោភសិទ្ធិ និងសេរីភាព ដែលបានការពារនៅក្នុងអនុសញ្ញា។

*រឿងក្តី PEREZ ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១២ កុម្ភៈ ២០០៤ កថាខណ្ឌ ៧០-៧២ និងកថាខណ្ឌ៨០-៨៤។*

**រដ្ឋ ត្រូវតែធានាឲ្យមានការគោរពអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌៖** កាតព្វកិច្ចនេះពន្លាតវិសាលភាពទៅដល់នីតិវិធីនៃច្បាប់ជាតិ ដែលអនុញ្ញាតឲ្យមានការទាមទារសំណង ដូចជាបណ្តឹងទាមទារក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

*រឿងក្តី ATANASOVA ទល់នឹងប្រទេសប៊ុលហ្គារី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២ តុលា ២០០៨ កថាខណ្ឌ៤៦។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖* មាត្រា៦(១)។ មាត្រានេះ ចែងពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលរួមទាំងសិទ្ធិជនជាប់ចោទ និងចែងពីបណ្ដឹងរដ្ឋប្បវេណីដោយបានចែងយោងទៅរកកាតព្វកិច្ចរដ្ឋប្បវេណីរបស់ជនជាប់ចោទផងដែរ។

*តុលាការកំពូលបារាំង*

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**តាមរយៈការអន្តរាគមន៍របស់ខ្លួន ជនរងគ្រោះ អាចស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះបទល្មើសមជ្ឈិម និងបទលហុ៖** វិធាននេះត្រូវអនុវត្តក្នុងអំឡុងពេលស៊ើបអង្កេតរបស់រដ្ឋអាជ្ញា។

*លេខ74-91732 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣០៤ តុលាការកំពូលបារាំង ២៨ តុលា ១៩៧៤។*

**គ្មានអ្វីអាចរារាំងជនរងគ្រោះ មិនឲ្យដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានឡើយ៖** វិធាននេះ ត្រូវអនុវត្តផងដែរចំពោះស្ថានភាព ដែលមានជនរងគ្រោះម្នាក់ បានដាក់ពាក្យរួចហើយ ចំពោះអង្គហេតុតែមួយ។

*លេខ81-91392 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៨៤ តុលាការកំពូលបារាំង ៩ កក្កដា ១៩៨២។*

**ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចទទួលយកបានតែក្នុងករណីដែលពាក្យសុំនេះ បានផ្អែកលើអង្គហេតុដែលពាក់ព័ន្ធ៖** មានន័យថា អង្គហេតុស្ថិតក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ/ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

*លេខ94-85057 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣៨៥ តុលាការកំពូលបារាំង ៩ វិច្ឆិកា ១៩៩៥។*

**ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចដាក់ជាលិខិតធម្មតាបាន៖** គេអាចធ្វើបែបនេះបាន ដរាបណាគ្មានការតវ៉ាទៅនឹងលិខិតយថាភូតនេះ។

*លេខ78-93560 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៦៥ តុលាការកំពូលបារាំង ២ តុលា ១៩៧៩។*

**ដើមបណ្ដឹង ដែលមិនបានដាក់ពាក្យនៅចំពោះមុខចៅក្រមស៊ើបសួរ នៅតែអាចដាក់ពាក្យសុំនេះបាននៅចំពោះមុខសភាស៊ើបសួរ៖** ដរាបណាកិច្ចស៊ើបសួរមិនត្រូវបានបិទ។

*DP 1938 តុលាការកំពូលបារាំង ២៥ មិថុនា ១៩៣៧។*

**ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលដាក់ពាក្យសុំ៖** ដើមបណ្ដឹងទទួលបានឋានៈរបស់ខ្លួនភ្លាមៗ បន្ទាប់ពីបានដាក់ពាក្យសុំ ចំពោះមុខចៅក្រមស៊ើបសួរ។

*លេខ67-90121 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៧៦ តុលាការកំពូលបារាំង ២៨ ឧសភា ១៩៦៨។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ៨៧។ មាត្រានេះ អនុញ្ញាតឲ្យដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលណាក៏បាន ក្នុងអំឡុងពេលស៊ើបសួរ និងចែងពីបទប្បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងការជំទាស់ពាក្យសុំនេះ។

# មាត្រា ១៣៨៖ បណ្តឹងដោយមានការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

*ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យបណ្តឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ច ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ពាក្យបណ្តឹង អាចដាក់ក្នុងនាមជនរងគ្រោះ ដោយមេធាវី។*

## ការអនុវត្តនៅ អ.វ.ត.ក

**ភាគីត្រូវដាក់ពាក្យសុំ ឲ្យបានមុនកាលកំណត់៖** ភាគី ត្រូវដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឲ្យបានមុនពេលផុតកាលកំណត់ឲ្យពាក្យសុំតាំងខ្លួន។

*រឿងក្តីឌុចៈ បណ្តឹងឧទ្ធរណ៍ ស្តីពីការសុំពន្យាររយៈពេលដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ជ.ស.ជ ១០ មីនា ២០០៩ កថាខណ្ឌ៧។*

**ដើមបណ្តឹងរដ្ឋប្បវេណី គឺជាជនរងគ្រោះដែលតុលាការបានទទួលស្គាល់ តាមពាក្យសុំ៖** ចៅក្រមស៊ើបសួរ ត្រូវធ្វើការសម្រេចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធានផ្ទៃក្នុង។

*រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំចូលរួមសវនាការក្នុងរយៈពេលឃុំខ្លួន បណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ ២៦។ រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៨៣។*

**លទ្ធភាពរបស់ជនរងគ្រោះមានកំរិត ក្នុងការចោទប្រកាន់ពីអង្គហេតុថ្មី៖** ជនរងគ្រោះដែលស្វែងរកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចលើកឡើងពីអង្គហេតុថ្មី នៅក្នុងពាក្យសុំ ក្នុងគោលបំណងនៃកិច្ចស៊ើបសួរបានទេ ប៉ុន្តែអាចលើកឡើងពីអង្គហេតុថ្មី ដែលអាចបង្ហាញពីទំនាក់ទំនងហេតុ/ផលព្យសនកម្ម ដែលជនរងគ្រោះបានទទួលរង និងយ៉ាងហោចណាស់ភ្ជាប់ទៅនឹងបទល្មើសមួយ ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៤២។*

**ទំនាក់ទំនងហេតុ/ផល ទៅនឹងជនត្រូវចោទរួម អាចជាការគ្រប់គ្រាន់៖** កាលណាការចោទ

ប្រឆាំងនឹងជនត្រូវចោទច្រើន ទាំងជាបុគ្គល និងជារួមក្នុងក្រុម ដែលប្រព្រឹត្តបទល្មើសនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម (និងទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀត) អ្នកដាក់ពាក្យសុំត្រូវបង្ហាញទំនាក់ទំនងហេតុ/ផល ទៅជនត្រូវចោទរួម ដោយមិនសំដៅតែជនត្រូវចោទជាបុគ្គលឡើយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីការទទួលយកពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៧១-៧៣។*

**ភស្តុតាងអំពីអត្តសញ្ញាណ អាចបត់បែនបាន៖** វិធីសាស្ត្រអាចបត់បែនបាន ត្រូវអនុវត្តចំពោះលក្ខខណ្ឌ ដែលអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញយ៉ាងច្បាស់ពីអត្តសញ្ញាណរបស់ខ្លួន ឧទាហរណ៍ សេចក្តីប្រកាសពីមេភូមិ ឬប្រធានឃុំអាចទទួលយកបានថា ជាភស្តុតាងបញ្ជាក់ អំពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីការទទួលយកពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៩៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន ២៣ស្ទួន និង ២៣ស្ទួនពីរ។ ប៉ុន្តែវិធានផ្ទៃក្នុង អ.វ.ត.ក ខុសគ្នាពីមាត្រា១៣៨ ដោយសារវិធានផ្ទៃក្នុង ២៣ស្ទួនពីរ តម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណី មានមេធាវីតំណាង ផ្ទុយទៅវិញ មាត្រា ១៣៨ គ្រាន់តែតម្រូវឲ្យមានតំណាងប៉ុណ្ណោះ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**កាលណាតុលាការរកឃើញថា ជនជាប់ចោទគ្មានការទទួលខុសត្រូវទេ អ្នកដាក់ពាក្យសុំ នឹងត្រូវអស់សិទ្ធិទាមទារសំណងរដ្ឋប្បវេណីផងដែរ៖** វិធាននេះអនុវត្តចំពោះស្ថានភាព ដែលអ្នកដាក់ពាក្យសុំបានចាប់ផ្តើមនីតិវិធីព្រហ្មទណ្ឌ និងមានបំណងទាមទារនូវសំណងរដ្ឋប្បវេណី នៅពេលដែលមានសេចក្តីសម្រេចផ្នែកព្រហ្មទណ្ឌ កំណត់ការទទួលខុសត្រូវនៅក្នុងនីតិវិធីរដ្ឋប្បវេណី និងដោយអនុលោម ទៅ

តាមសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ផងដែរ។

*រឿងក្តី ACQUAVIVA ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ វិច្ឆិកា ១៩៩៥ កថាខណ្ឌ៤៧។*

**រដ្ឋត្រូវតែធានាឲ្យមានការគោរពសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌៖** កាតព្វកិច្ចនេះពន្លាតវិសាលភាពទៅដល់នីតិវិធីច្បាប់ជាតិ ដែលអនុញ្ញាតឲ្យមានការទាមទារសំណង ដូចជាបណ្តឹងទាមទារនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

*រឿងក្តី ATANASOVA ទល់នឹងប្រទេសប៊ុលហ្គារី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២ តុលា ២០០៨ កថាខណ្ឌ៤៦។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៦(១)។ មាត្រានេះចែងពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលរួមទាំងសិទ្ធិជនជាប់ចោទ និងចែងពីបណ្តឹងរដ្ឋប្បវេណីដោយបានចែងយោងទៅរកកាតព្វកិច្ចរដ្ឋប្បវេណីរបស់ជនជាប់ចោទផងដែរ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**បុគ្គលដែលអះអាងថាខ្លួនជាជនរងគ្រោះ អាចដាក់ពាក្យបណ្តឹងនៅចំពោះមុខចៅក្រមស៊ើបសួរ៖** ពាក្យបណ្តឹងនេះ មានអានុភាពស្មើនឹងសេចក្តីសន្និដ្ឋានរបស់រដ្ឋអាជ្ញាដែរ។ ប៉ុន្តែភាគី មិនអាចប្រើនីតិវិធីនេះសម្រាប់បទលហុបានទេ។

*DP1907 តុលាការកំពូលបារាំង ៨ ធ្នូ ១៩០៦ ។ លេខ97-92180 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៥៦ តុលាការកំពូលបារាំង ២១ កុម្ភៈ ១៩៦៨ (អានុភាពស្មើនឹងសេចក្តីសន្និដ្ឋានរបស់រដ្ឋអាជ្ញាដែរ)។ DP1930.1.40 តុលាការកំពូលបារាំង ១៨ មេសា ១៩២៩ (វិធានគ្មានសុពលភាពចំពោះបទលហុ)។*

**ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ទទួលបាននៅពេលដាក់ពាក្យសុំ នៅចំពោះមុខតុលាការមួយដែលមានសមត្ថកិច្ច៖** អ្នកប្តឹង ត្រូវតែបញ្ជាក់ឲ្យបានច្បាស់ពីចេតនាចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អ្នកប្តឹង ត្រូវតែបង់ប្រាក់ប្រដាប់ក្តី នៅពេលដាក់ពាក្យបណ្តឹង។

*លេខ83-91925 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៣៨ តុលាការកំពូលបារាំង ១៣ ធ្នូ ១៩៨៣ (ត្រូវដាក់ពាក្យបណ្តឹង ជាចាំបាច់)។ លេខ 69-93357 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២១៨ តុលាការកំពូលបារាំង ២៥ មិថុនា ១៩៧០ (មិនតម្រូវឲ្យមានទម្រង់ជាក់លាក់ទេ)។ លេខ 78-93-560 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៦៥*

*តុលាការកំពូលបារាំង ២ តុលា ១៩៧៩ (ចេតនាច្បាស់លាស់)។*

**គឺត្រូវមានការពិចារណាថា យ៉ាងហោចណាស់ក៏មានលទ្ធភាពនៃទំនាក់ទំនងហេតុ/ផលផ្ទាល់ រវាងព្យសនកម្មទៅនឹងបទល្មើស៖** ដើម្បីអនុញ្ញាតឲ្យជនរងគ្រោះចាប់ផ្តើមការធ្វើបណ្តឹង និងការស៊ើបសួរ។

*លេខ66-91626 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៦ តុលាការកំពូលបារាំង ១៣ តុលា ១៩៦៧។*

**ចៅក្រមស៊ើបសួរ ត្រូវតែស៊ើបសួរគ្រប់អង្គហេតុដែលជនរងគ្រោះបានរាយការណ៍ជូន ក្នុងបណ្តឹងទីមួយ ឬបណ្តឹងបន្ថែម៖** ចៅក្រម ត្រូវអនុវត្តកាតព្វកិច្ចនេះ ទោះបីជាគ្មានសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់រដ្ឋអាជ្ញាក៏ដោយ។

*លេខ95-82256 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៣០ តុលាការកំពូលបារាំង ៤ មិថុនា ១៩៩៦។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា ៨៧។ មាត្រានេះ អនុញ្ញាតឲ្យដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលណាក៏បានក្នុងអំឡុងពេលស៊ើបសួរ និងចែងពីបទប្បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងការជំទាស់ពាក្យសុំនេះ។

# មាត្រា ១៣៩៖ ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា

*ចៅក្រមស៊ើបសួរ ធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា។ ចៅក្រមស៊ើបសួរ បញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។*

*ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា ត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះអាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។*

*ព្រះរាជអាជ្ញា អាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើអំពើនោះ មិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។*

*ក្នុងករណីដែលចៅក្រមស៊ើបសួរ សម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញនូវដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។*

*ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។*

## ការអនុវត្តនៅ អ.វ.ត.ក

**ការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានធ្វើឡើងបន្ទាប់ពីការចាប់ផ្តើមកិច្ចស៊ើបសួរ៖** ការចូលរួមត្រូវបានអនុញ្ញាត នៅពេលដែលជនត្រូវចោទបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន ព្រោះបណ្តឹងឧទ្ធរណ៍នេះ ជាផ្នែកមួយនៃនីតិវិធីព្រហ្មទណ្ឌ។

*រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី សុំចូលរួមសវនាការក្នុងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ៤១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន ៤៩។ វិធាននេះ ចែងបញ្ជាក់ច្បាស់ថាការចោទប្រកាន់បទល្មើសក្នុងយុត្តាធិការនៃ អ.វ.ត.ក អាចត្រូវបានចាប់ផ្តើមតែដោយព្រះរាជអាជ្ញា ទោះបីជាតាមឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមមូលដ្ឋាននៃបណ្តឹងក្តី។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***
*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ចៅក្រមស៊ើបសួរ ត្រូវតែស៊ើបសួរពីមូលហេតុនានាក្នុងសេចក្តីជូនដំណឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានសុពលភាព ដោយមិនគិតពីសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់រដ្ឋអាជ្ញាឡើយ៖** កាតព្វកិច្ចនេះត្រូវបានចប់ ប្រសិនបើគ្មានការចោទប្រកាន់លើអង្គហេតុដែលបានអះអាង ឬមិនមានការកំណត់បទចោទលើអង្គហេតុនេះ។ អវត្តមាននៃកិច្ចស៊ើបសួរ អាចត្រូវបានបកស្រាយថា ជាការបដិសេធកិច្ចស៊ើបសួរ។

> *លេខ98-84800 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៥៩ តុលាការកំពូលបារាំង ១៦ វិច្ឆិកា ១៩៩៩ (កាតព្វកិច្ចស៊ើបសួរ លើកលែងតែគ្មានការចោទប្រកាន់ គ្មានការកំណត់បទចោទ)។ លេខ00-80748 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៥ តុលាការកំពូលបារាំង ១១ មករា ២០០១ (កាតព្វកិច្ចផ្ទៀងផ្ទាត់ពីអត្ថិភាពនៃអង្គហេតុដែលបានចោទប្រកាន់ និងការកំណត់បទចោទដែលមានសក្តានុពល)។ លេខ9983418 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៧ តុលាការកំពូលបារាំង ១១ មករា ២០០០ (អវត្តមាននៃកិច្ចស៊ើបសួរ ត្រូវបានគេបកស្រាយថា ជាការបដិសេធកិច្ចស៊ើបសួរ)។*

**មូលហេតុដែលមិនមានសុពលភាព ក្នុងការបដិសេធមិនព្រមធ្វើការស៊ើបសួរ៖** អាស្រ័យដោយធាតុផ្សំផ្នែកអង្គហេតុ ដែលត្រូវពិនិត្យផ្ទៀងផ្ទាត់ក្នុងកិច្ចស៊ើបសួរ និងដោយសារធាតុផ្សំនៃនីតិវិធីស៊ើបសួរត្រូវបានអនុវត្តនៅក្នុងរឿងក្តីផ្សេង។

> *លេខ69-91579 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៤៦ តុលាការកំពូលបារាំង ៣ កុម្ភៈ ១៩៧០ (ជាតុផ្សំនៃអង្គហេតុ ដែលត្រូវផ្ទៀងផ្ទាត់)។ លេខ07-86077 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៨ តុលាការកំពូលបារាំង ១៥ មករា ២០០៨ (នីតិវិធីស៊ើបសួរដែលបានអនុវត្តនៅក្នុងរឿងក្តីផ្សេង)។*

**មូលដ្ឋានដ៏ត្រឹមត្រូវ ដែលនាំឲ្យបដិសេធមិនបើកការស៊ើបសួរ៖** កាលណាគ្មានការរំលោភច្បាប់ ដែលកើតចេញពីអង្គហេតុដូចបានចោទប្រកាន់នោះទេ និងបន្ទាប់ពីកិច្ចស៊ើបសួរ កាលណាមានភស្តុតាងបញ្ជាក់ថា អង្គហេតុដែលបានចោទប្រកាន់មិនត្រូវបានប្រព្រឹត្ត។

> *លេខ 79-90062 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២០៥ តុលាការកំពូលបារាំង ១២ មិថុនា ១៩៧៩ (គ្មានការរំលោភច្បាប់ ត្រូវបានរកឃើញទេ)។ លេខ 09-80720 ព្រឹត្តិបត្រព្រហ្មទណ្ឌ*

*លេខ១៦៤ តុលាការកំពូលបារាំង ៦ តុលា ២០០៩។*

**នៅពេលចៅក្រមស៊ើបសួរ ចង់បើកការស៊ើបសួរ ទោះបីការសន្និដ្ឋានរបស់រដ្ឋអាជ្ញា មិនចង់ចាត់ការក៏ដោយ៖** ក្នុងកាលៈទេសៈដូច្នេះ ចៅក្រមស៊ើបសួរត្រូវតែឆ្លើយតបតាមដីកាសម្រេច ដែលមានសំអាងហេតុ ទៅនឹងសេចក្ដីសន្និដ្ឋានរបស់រដ្ឋអាជ្ញា។

*លេខ88-82856 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៧៨ តុលាការកំពូលបារាំង ២០ មិថុនា ១៩៨៨។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ៨៦។ មាត្រានេះ កំណត់អំពីតួនាទីរបស់រដ្ឋអាជ្ញាក្នុងកិច្ចស៊ើបសួរលើពាក្យបណ្ដឹងណាមួយ ដែលបានដាក់ដោយដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ និងការឆ្លើយតបតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ មាត្រានេះ ក៏កំណត់ផងដែរនូវតួនាទីរបស់ចៅក្រមស៊ើបសួរ ក្នុងការកំណត់ថា តើត្រូវចាត់ការស៊ើបសួរ ឬមិនចាត់ការ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់រដ្ឋអាជ្ញា ដែលបានធ្វើឡើងបន្ទាប់ពីមានពាក្យបណ្ដឹង។

# មាត្រា ១៤៣៖ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ

*នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរ ពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឲ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើស ដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរ ប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះ ត្រូវចុះក្នុងកំណត់ហេតុ នៅពេលចូលបង្ហាញខ្លួនលើកដំបូង។*

*ប្រសិនបើជនត្រូវចោទចង់ឆ្លើយ នោះចៅក្រមស៊ើបសួរ ត្រូវទទួលចម្លើយនោះភ្លាម។*

*ចៅក្រមស៊ើបសួរ ប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួន ក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។*

*ជនត្រូវចោទជាអនីតិជន ត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌ ដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី។*

*ក្រោយពីចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនេះ ត្រូវបានទទួលដំណឹងថាៈ*

*- ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ នៅពេលណាដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន*

*- គ្រប់ការឲ្យដំណឹង ដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះ ត្រូវចាត់ទុកថាបានធ្វើឡើងដល់សាម៉ីខ្លួនផ្ទាល់។*

*ការឲ្យដំណឹង ព្រមទាំងការប្រកាសស្តីអំពីការផ្លាស់ប្តូរអាសយដ្ឋាន ត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**សិទ្ធិដឹងពីបទចោទប្រកាន់៖** ជនត្រូវចោទ មានសិទ្ធិទទួលបានការជូនដំណឹង ទាន់ពេលវេលា និងលម្អិត អំពីបទចោទប្រឆាំងនឹងខ្លួន តាមរយៈភាសាដែលគាត់យល់ដឹងបាន។

*រឿងក្តីខៀវ សំផន៖ សំណើសុំឯកសារគាំទ្រដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១៥ ធ្នូ ២០១០ កថាខណ្ឌ៧។*

**សិទ្ធិនៅស្ងៀមមិនឆ្លើយតប៖** ជនត្រូវចោទត្រូវតែទទួលបានការរំលឹក អំពីសិទ្ធិរបស់គាត់ នៅ គ្រប់ដំណាក់កាល នៃនីតិវិធីប្រឆាំងនឹងគាត់ ដើម្បីអនុវត្តសិទ្ធិនេះ។

*រឿងក្តី ឌុច៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន បណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ៩១០។*

**សិទ្ធិការពារខ្លួន៖** ជនត្រូវចោទត្រូវមានសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន។

*រឿងក្តីឌុច៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ១១។*

**ការកំណត់ចរិកលក្ខណៈ នៃអង្គហេតុស្របច្បាប់មានលក្ខណៈជាបណ្តោះអាសន្នប៉ុណ្ណោះ៖** ចរិកលក្ខណៈផ្លូវច្បាប់ គឺតែងតែជាចរិកលក្ខណៈបណ្តោះអាសន្នស្ថិតក្នុងដំណាក់កាលស៊ើបសួរ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និងឌុច៖ ដីកាស្តីពីការស្នើសុំធ្វើការបំភ្លឺលើបទចោទនានា អ.វ.ត.ក ការិយាល័យសហព្រះរាជអាជ្ញា ២០ វិច្ឆិកា ២០០៩ កថាខណ្ឌ១០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន២១(១)(ឃ) និង៥៧។ វិធាន២១(១)(ឃ) ស្រដៀងគ្នាមែនទែនទៅនឹងកថាខណ្ឌទីមួយនៃមាត្រា ១៤៣ ប៉ុន្តែអ្វីដែលខុសគ្នានៅក្នុងមាត្រា ១៤៣ គឺមានតែលក្ខខណ្ឌតម្រូវឲ្យចៅក្រមស៊ើបសួរ ជូនដំណឹងដល់ជនត្រូវចោទ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់នៅពេលសវនាការបឋម។ វិធាន៥៧ បញ្ជាក់សារជាថ្មីអំពីសិទ្ធិទាំងនេះដែលចែងថា ប្រសិនបើជនត្រូវចោទយល់ព្រមឲ្យសួរនៅពេលបង្ហាញខ្លួនលើកដំបូងចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុជាបន្ទាន់ ប៉ុន្តែជនត្រូវចោទ មានសិទ្ធិពិគ្រោះជាមួយមេធាវីរបស់ខ្លួនជាមុនសិន។

# *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងយុត្តាធិការដទៃទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលប្បញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**កំហុសក្នុងការកោះហៅ មិនមែនជាការរំលោភលើសិទ្ធិទទួលបាននូវការជូនដំណឹងអំពីបទចោទទេះ** កំហុសខាងអង្គហេតុនៅក្នុងការកោះហៅ មិនមែនជាការរំលោភលើសិទ្ធិរបស់បុគ្គល ដើម្បីទទួលបានការជូនដំណឹងអំពីបទចោទប្រឆាំងទៅនឹងខ្លួនគាត់ឡើយ ដរាបណាការកោះហៅនោះ ត្រូវបានកែប្រែទាន់ពេល និងគ្មានការយល់ច្រឡំ ដែលមិនត្រឹមត្រូវ។ សិទ្ធិក្នុងការទទួលបានការជូនដំណឹង របស់បុគ្គលអំពីប្រភេទ និងមូលហេតុនៃបទចោទប្រឆាំងនឹងរូបគាត់ រួមមានការជូនដំណឹងអំពីច្បាប់ពាក់ព័ន្ធដែលរូបគាត់ត្រូវបានចោទប្រកាន់ថា បានរំលោភ និងអង្គហេតុទូទៅ ដែលបានចោទប្រកាន់ ដែលនាំឲ្យមានបទចោទប្រកាន់នេះឡើង។

> *រឿងក្តី J. O. ទល់នឹងប្រទេសបារាំង គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ មីនា ២០១១ កថាខណ្ឌ៩.២-៩.៣។*

**សិទ្ធិមិនត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងះ** សិទ្ធិនេះមានន័យថា អាជ្ញាធរមិនអាចដាក់បុគ្គលណាម្នាក់ឲ្យស្ថិត ក្រោមការបង្ខិតបង្ខំ ខាងផ្លូវកាយ ផ្លូវចិត្ត ឬខាងស្មារតី ទោះបីជា ដោយផ្ទាល់/ប្រយោលក្តី ដើម្បីទទួលបានការសារភាពពីបុគ្គលនោះឡើយ។

> *រឿងក្តី SHARIFOVA និងគូកនទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការ សិទ្ធិមនុស្ស អ.ស.ប ១ មេសា ២០០៨ កថាខណ្ឌ៦.៣។ រឿងក្តី KHUSEYNOVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ តុលា ២០០៨ កថាខណ្ឌ៨.៣។ រឿងក្តី IDIEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣១ មីនា ២០០៩ កថាខណ្ឌ៩.៣ ។ រឿងក្តី BUTOVENKO ទល់នឹងប្រទេសអ៊ុយក្រែន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៩ កក្កដា ២០១១ កថាខណ្ឌ៧.៤។*

**យុត្តិកម្មនៃករណីលើកលែង ចំពោះវិធានទូទៅដែលចែងថា បុគ្គលដែលកំពុងរង់ចាំការជំនុំជម្រះ មិនត្រូវបានឃុំខ្លួនឡើយះ** រដ្ឋត្រូវតែរៀបរាប់ឲ្យបានពិស្តារអំពីកង្វល់ផ្សេងៗ ដែលផ្តល់យុត្តិកម្មសម្រាប់បន្តការឃុំខ្លួន និងមូលហេតុ ដែលកង្វល់ទាំងនេះ មិនអាចដោះស្រាយបាន តាមរយៈលក្ខខណ្ឌតម្រូវនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬលក្ខខណ្ឌដោះលែងដែលតឹងរ៉ឹងផ្សេងទៀត។

*រឿងក្តី SMANTSER ទល់នឹងប្រទេសបេលឡារូស គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៨ កថាខណ្ឌ១០.៣។*

**ការការពារអនីតិជន ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ៖** ត្រូវមានការបញ្ជាក់ជាពិសេសអំពីការការពារអនីតិជន ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ឪពុក ម្តាយ ឬអាណាព្យាបាលរបស់អនីតិជន គួរទទួលបានការជូនដំណឹងអំពីបទចោទប្រឆាំងនឹងអនីតិជននោះ។ អនីតិជន មានតម្រូវការជាពិសេស នូវជំនួយក្នុងការរៀបចំ និងបង្ហាញការការពារខ្លួន។ អនីតិជន គួរទទួលបាននូវវិធានការការពារពិសេស រួមទាំងការដោះលែងជាបណ្តោះអាសន្ន និងកិច្ចប្រឹងប្រែងក្នុងការធានាលើបញ្ហាសន្តិសុខ និងសុខុមាលភាពរបស់ពួកគេ។

*រឿងក្តី SHARIFOVA និងគូកនទល់នឹងប្រទេសតាជីគីស្តាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១ មេសា ២០០៨ កថាខណ្ឌ៦.៦ (ការជូនដំណឹងអំពីបទចោទ ជំនួយក្នុងការរៀបចំការការពារក្តី)។ រឿងក្តី LAUREANO ATACHA HUA ទល់នឹងប្រទេសប៉េរូ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៥ មីនា ១៩៩៦ កថាខណ្ឌ៨.៧ (វិធានការការពារពិសេស)។*

**មាត្រាស្រដៀងគ្នានៅក្នុង*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*៖** មាត្រា៩(៣) ១៤(៣) (ក) ១៤ (៣) (ខ) ១៤(៣) (ឆ) និង១៤ (៤)។ មាត្រា១៤(៣) (ក) កំណត់អំពីសិទ្ធិបុគ្គលក្នុងការទទួលបាន "ការជូនដំណឹងទាន់ពេលវេលា" នូវបទចោទប្រឆាំងនឹងរូបគាត់។ មាត្រា១៤(៣)(ឆ) ចែងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយមាត្រា១៤(៣)(ខ) កំណត់អំពីសិទ្ធិក្នុងការប្រាស្រ័យទាក់ទងជាមួយមេធាវីរបស់ខ្លួន តាមការជ្រើសរើសដោយខ្លួនគាត់ផ្ទាល់។ មាត្រា ១៤ (៣) (ឆ) ចែងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយ មាត្រា១៤ (៣) (ខ) ចែងអំពីសិទ្ធិក្នុងការប្រាស្រ័យទាក់ទងជាមួយមេធាវី តាមការជ្រើសរើសរបស់ខ្លួន មាត្រា១៤(៤) តម្រូវឲ្យមាននីតិវិធី ដែលមានការយកចិត្តទុកដាក់ ចំពោះអាយុរបស់អនីតិជនហើយ មាត្រា៩(៣) តម្រូវឲ្យជនដែលត្រូវបានដោះលែងដែលស្ថិតក្រោមការស៊ើបអង្កេត ជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការផ្លាស់ប្តូរអាសយដ្ឋាន។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការ-ពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ត្រូវអនុវត្តក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល៖** ជាពិសេសនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។

*រឿងក្តី IMBRIOSCIA ទល់នឹងប្រទេសស្វីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៤ វិច្ឆិកា*

*១៩៩៣ កថាខណ្ឌ៣៨ (ការខ្វែងយោបល់របស់ចៅក្រម LOPER ROCHA J.)។*

**ជនត្រូវចោទ ត្រូវទទួលបាននូវជំនួយផ្នែកច្បាប់ចាប់ពីដំណាក់កាលដំបូងបង្អស់៖** មានន័យថាចាប់ពីពេលនគរបាលធ្វើកំណត់ហេតុ ឬចាប់ពីពេលត្រូវឃាត់ខ្លួន។

*រឿងក្តី SALDUZ ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ វិច្ឆិកា ២០០៨ កថាខណ្ឌ ៥២ (ជំនួយពីមេធាវី ចាប់ពីដំណាក់កាលដំបូងបង្អស់)។ រឿងក្តី DAYANAN ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៣ តុលា ២០០៩ កថាខណ្ឌ៣១ (ការចាប់ផ្តើមការឃាត់ខ្លួន)។*

**តំណាងផ្នែកច្បាប់ មិនត្រូវបានបដិសេធចោលឡើយ** ៖ ជនត្រូវចោទ ត្រូវតែទទួលបាននូវការការពារខ្លួនតាមស្ថានភាពជាក់ស្តែង និងដោយប្រសិទ្ធភាព។

*រឿងក្តី TWALIBទល់នឹងប្រទេសក្រិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ៩ មិថុនា ១៩៩៨ កថាខណ្ឌ ៤៦ (តំណាងផ្នែកច្បាប់)។ រឿងក្តី ARTICO ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៣ ឧសភា ១៩៨០ កថាខណ្ឌ៣៣ (ការការពារខ្លួន តាមទម្លាប់នៃការអនុវត្ត និងដោយមានប្រសិទ្ធភាព)។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មាត្រា៦(១)។ មាត្រានេះ ចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិការពារខ្លួនតាមរយៈជំនួយផ្នែកច្បាប់ ដែលជ្រើសរើសដោយខ្លួនឯងផ្ទាល់ ឬប្រសិនបើគាត់មិនមានមធ្យោបាយដើម្បីទទួលបានជំនួយនេះទេ ត្រូវផ្តល់ជូនគាត់ដោយមិនគិតកម្រៃ បើសិនជាផលប្រយោជន៍នៃយុត្តិធម៌តម្រូវឲ្យមានបែបនេះ។

# មាត្រា ១៤៥៖ វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ

*កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត៥ (ប្រាំ) ថ្ងៃ មុនការសួរចម្លើយ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី។*

*ជនត្រូវចោទ អាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្តីអំពីអវត្តមាននេះ ត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ។*

*ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទ ដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់ស្តែងនូវវត្តមានរបស់មេធាវីខ្លួន។ ការបោះបង់ចោលនេះ ត្រូវចុះនៅក្នុងកំណត់ហេតុមួយផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ។*

*ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរ ក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះ ត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។*

*ចៅក្រមស៊ើបសួរ អាចហៅរកអ្នកប្រែ ដូចមានចែងនៅក្នុងមាត្រា១៤៤ (ជំនួយរបស់អ្នកបកប្រែ) នៃក្រមនេះ។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**សិទ្ធិមានវត្តមានរបស់មេធាវីដែលត្រូវទទួលបានការជូនដំណឹងជាមុន៖** ជនត្រូវចោទមានសិទ្ធិឲ្យមេធាវីមានវត្តមាន នៅពេលគាត់ត្រូវបានសួរចម្លើយ ប្រសិនបើគាត់មានមេធាវីរួចហើយ។ មេធាវីត្រូវបានគេជូនដំណឹង៥ថ្ងៃ មុនការសួរចម្លើយចាប់ផ្តើម ដើម្បីឲ្យមេធាវីអាចពិនិត្យមើលសំណុំរឿង និងត្រៀមខ្លួនសម្រាប់ការសួរចម្លើយ។

*រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ស្តីពីការបដិសេធលើពាក្យសុំមោឃភាព អ.វ.ត.ក អ.ប.ជ ២៦ សីហា ២០០៨ កថាខណ្ឌ៤៦-៤៩។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៨(១) ៥៨(២) ៥៨(៣) និង៣០។ វិធាន៥៨(១) ដល់៥៨(៣) មានលក្ខណៈស្រដៀងគ្នាមែនទែនទៅនឹងមាត្រា១៤៥ លើកលែងតែមាត្រា៥៨(៣) ដែលអនុញ្ញាតឲ្យមានការសួរចម្លើយជនត្រូវចោទ ដោយអវត្តមានរបស់មេធាវីខ្លួនក្នុងពេលបន្ទាន់ គឺពេលមានភវនីយភាពខ្ពស់ដែលថា ភស្តុតាងដែលនឹងត្រូវបាត់បង់មិនអាចរកមកវិញបាន នៅក្នុងអំឡុងពេលនៃការរង់ចាំមេធាវី ហើយដែលក្នុងស្ថានភាពដូច្នេះតម្រូវឲ្យមានការយល់ព្រមពីជនត្រូវចោទ។ ការបកស្រាយបទប្បញ្ញត្តិនៃវិធាន៣០ ក៏ស្រដៀងគ្នាដែរ លើកលែងតែថា សាក្សី ឬភាគីអាចស្នើសុំអ្នកបកប្រែបាននៅពេលចាំបាច់។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងយុត្តាធិការដទៃទៀត

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការរំលោភ៖ គឺការមិនអនុញ្ញាតឲ្យមានមេធាវី តាមសំណើ៖** សិទ្ធិមានមេធាវីត្រូវបានរំលោភ នៅពេលណារដ្ឋសួរចម្លើយជនសង្ស័យ ដែលពុំទទួលបាននូវការអនុញ្ញាតតាមសំណើ ដើម្បីជួបមេធាវីរបស់គាត់។

> *រឿងក្តី GRIDIN ទល់នឹងសហព័ន្ធរុស្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ កក្កដា ២០០០ កថាខណ្ឌ៨.៥។*

**ការរំលោភ៖ ការដាក់សម្ពាធ ដោយផ្ទាល់ / ដោយប្រយោលខាងផ្លូវកាយ ឬផ្លូវចិត្តលើជនត្រូវចោទ៖** វត្តមាននៃសម្ពាធណាមួយ ពីសំណាក់អាជ្ញាធរស៊ើបសួរ ទៅលើជនត្រូវចោទក្នុងគំនិត ដើម្បីទទួលបានចម្លើយសារភាពអំពីពិរុទ្ធភាព គឺជាការរំលោភ ដែលការរំលោភនោះ បានបង្ខំឲ្យចុងចោទធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬដើម្បីឲ្យឆ្លើយសារភាពអំពីពិរុទ្ធភាព។

> *រឿងក្តី KELLY ទល់នឹងប្រទេសចាម៉ៃកា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៨ មេសា ១៩៩១ កថាខណ្ឌ៥.៥។*

**ការរំលោភ៖ ការសួរចម្លើយ ដោយគ្មានវត្តមានរបស់មេធាវី៖** ការសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានមេធាវី និងដែលពុំមានការគោរពឲ្យបានពេញលេញនូវវិធានស្តីអំពីដំណើរការឆាប់រហ័ស នៅមុនពេលធ្វើការចោទប្រកាន់ជនត្រូវចោទ គឺជាការរំលោភបទប្បញ្ញត្តិ ដែលហាមឃាត់ការឃុំខ្លួនតាមទំនើងចិត្ត។

> *រឿងក្តី CHAPARRO និងគូកនទល់នឹងប្រទេសកូឡុំប៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៩ កក្កដា ១៩៩៧ កថាខណ្ឌ៨.៧។*

**មាត្រាស្រដៀងគ្នានៅក្នុងអនុ*សញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៩ និង១៤(៣)(ខ)។ មាត្រា៩ ហាមឃាត់ការឃុំខ្លួនតាមទំនើងចិត្ត ខណៈមាត្រា១៤(៣)(ខ) ការពារសិទ្ធិជនត្រូវចោទក្នុងការប្រាស្រ័យទាក់ទងជាមួយមេធាវីដែលខ្លួនបានជ្រើសរើស។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**មេធាវីការពារ ត្រូវតែមានពេលវេលាគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំឲ្យបានត្រឹមត្រូវ៖** ឧទាហរណ៍ រយៈពេលពីរសប្តាហ៍ សម្រាប់ការរៀបចំឯកសារចំនួន ១៧,០០០ ទំព័រ ត្រូវបានតុលាការរកឃើញថា ជាពេលវេលាមិនគ្រប់គ្រាន់។

*រឿងក្តី ÖCALAN ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១២ ឧសភា ២០០៥ កថាខណ្ឌ ១៤២-១៤៨។*

**សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ត្រូវអនុវត្តនៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងមូល៖** ជាពិសេសនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។

*រឿងក្តី IMBRIOSCIA ទល់នឹងប្រទេសទូរ៉េលហ្សេឡង់ តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៤ វិច្ឆិកា ១៩៩៣ កថាខណ្ឌ ៣៨ (មតិខ្វែងយោបល់របស់ចៅក្រម LOPER ROCHA J.)។*

**ជនជាប់ចោទ ត្រូវតែទទួលបានជំនួយផ្នែកច្បាប់ចាប់ពីដំណាក់កាលដំបូងបង្អស់៖** មានន័យថាចាប់ពីពេលសួរចម្លើយ ឬចាប់ពីពេលឃាត់ខ្លួនដោយនគរបាល។

*រឿងក្តី SALDUZ ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ វិច្ឆិកា ២០០៨ កថាខណ្ឌ៥២ (ជំនួយពីមេធាវី ចាប់ពីដំណាក់កាលដំបូងបង្អស់)។ រឿងក្តីDAYANANទល់ទៅនឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៣ តុលា ២០០៩ កថាខណ្ឌ៣១ (ការចាប់ផ្តើមការឃាត់ខ្លួន)។*

**តំណាងផ្នែកច្បាប់ មិនត្រូវបានបដិសេធជាដាច់ខាត៖** ជនត្រូវចោទ ត្រូវតែទទួលបានការការពារខ្លួនតាមស្ថានភាពជាក់ស្តែង និងដោយមានប្រសិទ្ធភាព។

*រឿងក្តី TWALIB ទល់នឹងប្រទេសក្រិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ៩មិថុនា ១៩៩៨ កថាខណ្ឌ ៤៦ (តំណាងផ្នែកច្បាប់)។ រឿងក្តី ARTICO ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៣ ឧសភា ១៩៨០ កថាខណ្ឌ៣៣ (ការការពារខ្លួន តាមទម្ងាប់នៃការអនុវត្ត និងដោយមានប្រសិទ្ធភាព)។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖* មាត្រា៦(១)។ មាត្រានេះ ចែងអំពីសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ រួមទាំងសិទ្ធិការពារខ្លួនតាមរយៈជំនួយផ្នែកច្បាប់ ដែលជ្រើសរើសដោយខ្លួនឯងផ្ទាល់ ឬប្រសិនបើគាត់មិនមានមធ្យោបាយដើម្បីទទួលបានជំនួយនេះទេ ត្រូវផ្តល់ជូនគាត់ដោយមិនគិតកម្រៃ បើសិនជាផលប្រយោជន៍នៃយុត្តិធម៌តម្រូវឲ្យមានបែបនេះ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**និយ័តភាពនៃការកោះហៅមេធាវី៖** ការណ៍នេះ ត្រូវតែវាយតម្លៃនៅថ្ងៃចេញដីកាកោះ។

*លេខ07-88451 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៤៩ តុលាការកំពូលបារាំង ២៦ កុម្ភៈ ២០០៨។*

**មោឃភាពនៃការកោះហៅមេធាវី៖** ប្រសិនបើ ចិរវេលាប្រាំថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃចេញដីកាកោះហៅមេធាវី ដល់ថ្ងៃសួរចម្លើយ មិនត្រូវបានគោរពនោះទេ ដីកាកោះត្រូវបានចាត់ទុកជា មោឃៈ។

*លេខ086-93266 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៤៩ តុលាការកំពូលបារាំង ២ កញ្ញា ១៩៨៦។*

**ការរំលោភ៖ ការខកខានមិនបានកោះអញ្ជើញមេធាវី សម្រាប់ការសួរដេញដោលចំពោះមុខ៖** នេះគឺជាការរំលោភសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានជំនួយដើម្បីការការពារខ្លួន។

*លេខ 07-86794 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៩៧ តុលាការកំពូលបារាំង ៤ ធ្នូ ២០០៧។*

**ការកោះហៅមេធាវី ត្រូវធ្វើគ្រប់ពេល ដែលជនត្រូវចោទត្រូវបានគេស្តាប់ចម្លើយ៖** ដីកាកោះពុំចាំបាច់បញ្ជាក់អំពីកម្មវត្ថុទេ។

*លេខ85-94010 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៨៨ តុលាការកំពូលបារាំង ១ តុលា ១៩៨៥។*

**ការពិនិត្យមើលសំណុំរឿង៖** ការណ៍នេះអាចធ្វើទៅបានចំពោះតែមេធាវីរបស់ភាគីតែប៉ុណ្ណោះ ហើយសំណុំរឿង ត្រូវតែពេញលេញ និងមានឯកសារនីតិវិធីទាំងអស់ ក្នុងពេលនៃការពិនិត្យ ដើម្បីចៀសវាងមោឃភាព។

*លេខ00-82215 តុលាការកំពូលបារាំង ២២ មករា ២០០២ (ការពិនិត្យមើលសំណុំរឿង របស់មេធាវី)។ DP. 1937 តុលាការកំពូលបារាំង ៣ សីហា ១៩៣៥ (សំណុំរឿងត្រូវតែពេញលេញ)។*

**ឯកសារដែលត្រូវចេញ នៅចន្លោះថ្ងៃនៃការពិនិត្យសំណុំរឿង និងការសួរចម្លើយ៖** ដោយសារតែកិច្ចស៊ើបសួរកំពុងដំណើរការ ឯកសារដែលចេញក្នុងចន្លោះថ្ងៃនៃការពិនិត្យសំណុំរឿង និងថ្ងៃសួរចម្លើយ

អាចត្រូវបានបូកបន្ថែម ទៅក្នុងសំណុំរឿង ដរាបណាជនត្រូវចោទ និងមេធាវីរបស់គាត់ត្រូវបានជូនដំណឹងជាមុន។

*លេខ89-86666 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៨ ៦ តុលាការកំពូលបារាំង ២០ កុម្ភៈ ១៩៩០។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ១១៤។ មាត្រានេះ ចែងអំពីសិទ្ធិរបស់ជនត្រូវចោទ រួមទាំងសិទ្ធិទទួលបានជំនួយពីមេធាវីក្នុងពេលសួរចម្លើយ។

# មាត្រា ១៥០៖ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

*ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានអមដោយមេធាវី។*

*ក្នុងករណីនេះ ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ាងតិចបំផុត ៥(ប្រាំ) ថ្ងៃមុនការស្តាប់ចម្លើយ។ នៅក្នុងចំរវេលានេះ មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។*

*ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខរបស់មេធាវីខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវី ដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលមកបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរ អាចសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្តីពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។*

*ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបាន ដោយមិនចាំបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋវេណីបោះបង់ចោលយ៉ាងជាក់ស្តែង នូវវត្តមានរបស់មេធាវីខ្លួន។ ការបោះបង់ចោលនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយ ដោយឡែកពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី។*

*ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរ ក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះ អាចបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីហានិភ័យនៃបាត់បង់តម្រុយភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។*

*ចៅក្រមស៊ើបសួរ អាចស្នើសុំអ្នកប្រែ ដូចមានចែងនៅក្នុងមាត្រា១៤៤ (ជំនួយរបស់អ្នកបកប្រែ) នៃក្រមនេះ។*

## ការអនុវត្តនៅ អ.វ.ត.ក

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានស្តាប់ចម្លើយ ស្របតាមវិធានស្តីពីដើមបណ្តឹងរដ្ឋប្បវេណី៖ វិធានដែលគ្រប់គ្រងលើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គឺជាវិធានដែលគ្រប់គ្រងលើការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគាត់ត្រូវបានចាត់ទុកថា ជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ពេលមានសេចក្តីសម្រេចចុងក្រោយ លើពាក្យសុំរបស់ពួកគាត់។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្ប-វេណី (មតិរបស់ចៅក្រមន័យ ថុល ចៅក្រម*

*CATHERINE MARCHI-UHEL និងចៅក្រម ហួត វុទ្ធី នៅក្នុងសាលដីកា ស្តីពីការប្រកាសមិនទទួលយកដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយក) អ.វ.ត.ក អ.ប.ជ ២៧ មេសា ២០១០ កថាខណ្ឌ៩។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៥៩(១) ៥៩(២) ៥៩(៣) និង៣០។ វិធាន៥៩ មានលក្ខណៈស្រដៀងគ្នាទៅនឹងមាត្រា១៥០ លើកលែងតែថាមាត្រា៥៩(៣) អនុញ្ញាតឲ្យមានសួរដេញដោលការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយមានវត្តមានរបស់ភាគីដទៃទៀត នៅពេលចៅក្រមសម្រេចឲ្យធ្វើការតទល់គ្នារវាងសាក្សីនឹងសាក្សី ហើយវិធាន៥៩(៦) អនុញ្ញាតឲ្យចៅក្រម ផ្ទេរអំណាចនៃកិច្ចស៊ើបសួររបស់ខ្លួនទៅឲ្យអ្នកស៊ើបសួរតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស។ ការបកស្រាយបទប្បញ្ញត្តិនៃវិធាន៣០ក៏ស្រដៀងគ្នានឹងមាត្រា១៥០ដែរ លើកលែងតែថាសាក្សី ឬភាគីអាចស្នើសុំអ្នកបកប្រែបាននៅពេលចាំបាច់។

# មាត្រា ១៥៤៖ សម្បថរបស់សាក្សី

*មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីម្នាក់ៗត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា និយាយតែការពិត។ ទម្រង់នៃសម្បថ ត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនេះ។*

## ការអនុវត្តនៅ អ.វ.ត.ក

**គ្រប់សាក្សីទាំងអស់ ត្រូវតែធ្វើសម្បថ៖** ជនណាដែលចូលបង្ហាញខ្លួន ក្នុងនាមជាសាក្សី ត្រូវតែធ្វើសម្បថថា ខ្លួននិយាយតែការណ៍ណាដែលពិតប៉ុណ្ណោះ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ សេចក្តីណែនាំ ស្តីពីកិច្ចប្រជុំរៀបចំសវនាការ អ.វ.ត.ក អ.ប.ជ ៨ មេសា ២០១១ ទំព័រ១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន២៤។ វិធាននេះមានលក្ខណៈស្រដៀងគ្នាមែនទែនទៅនឹង មាត្រា១៥៤ លើកលែងតែមាត្រានេះបន្ថែមថា សាក្សី ត្រូវធ្វើសម្បថនៅពេលផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ ព្រមទាំងនៅមុនពេលស្តាប់ចម្លើយ។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**អ្នកផ្តល់ព័ត៌មានអនាមិក អាចត្រូវបានប្រើជាប្រភពក្នុងអំឡុងពេលស៊ើបសួរ៖** ប៉ុន្តែការប្រើកំណត់ហេតុរបស់ពួកគេ ជាបន្តបន្ទាប់ដោយតុលាការ ដើម្បីកំណត់ការផ្តន្ទាទោស អាចបង្កើតឲ្យមានបញ្ហាមួយចំនួន។

*រឿងក្តី DOORSON ទល់នឹងប្រទេសហូឡង់ តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មីនា ១៩៩៦ កថាខណ្ឌ៦៩។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖ មាត្រា៦(៣)។ មាត្រានេះចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិរបស់ជនត្រូវចោទក្នុងការសួរដេញដោល ឬបានសួរដេញដោលសាក្សីប្រឆាំងនឹងខ្លួន។

*តុលាការកំពូលបារាំង*

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ឪពុកម្តាយ និងសម្ព័ន្ធរបស់ជនត្រូវចោទ៖** ត្រូវធ្វើសម្បថនៅចំពោះមុខចៅក្រមស៊ើបសួរ។

*លេខ83-90217 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៨៧ តុលាការកំពូលបារាំង ២២ មីនា ១៩៨៣។*

**ការលុបចោលសម្បថ ឬការធ្វើសម្បថ ត្រូវបានពន្យារពេល៖** មិនត្រូវជាមូលហេតុ នៃមោឃភាពនោះឡើយ កាលណាមិនធ្វើឲ្យខូចដល់សិទ្ធិនានារបស់ជនត្រូវចោទ។

*លេខ90-84412 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣២៧ តុលាការកំពូលបារាំង ២ តុលា ១៩៩០។*

**អនាមិកភាពរបស់សាក្សី៖** ជនណាដែលធ្វើសម្បថមិនអាចរក្សាអនាមិកភាពបានឡើយ។

*លេខ83-91283 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៤៤ តុលាការកំពូលបារាំង ២៦ មិថុនា ១៩៨៤។*

**ពេលដែលសាក្សីមិនស្បថ នៅចំពោះមុខចៅក្រមស៊ើបសួរ៖** ការណ៍នេះមិនបានលុបចោលការស្តាប់ចម្លើយទេ។

*លេខ 80-94473 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១១០ តុលាការកំពូលបារាំង ៣១ មីនា ១៩៨១។ លេខ83-90217 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៨៧ តុលាការកំពូលបារាំង ២២ មីនា ១៩៨៣។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖ មាត្រា១០៣ ១០៨ ១០៩ ១១៣-៧ និង១៥៣។ មាត្រាទាំងនេះ កំណត់អំពីនីតិវិធីសម្រាប់ការស្តាប់ចម្លើយសាក្សី រួមទាំងបញ្ហានៃសម្បថរបស់សាក្សី។

# មាត្រា ១៥៦៖ សាក្សីដែលអនុញ្ញាតឲ្យរួចពីសម្បថ

*ត្រូវបានស្តាប់ចម្លើយ ដោយមិនចាំបាច់ធ្វើសម្បថចំពោះសាក្សីដូចតទៅនេះ៖*
*១- ឪពុកម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ។*
*២- កូនប្រុសកូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ។*
*៣- បងប្អូនប្រុសស្រីរបស់ជនត្រូវចោទ។*
*៤- បងប្អូនថ្លៃប្រុសស្រីរបស់ជនត្រូវចោទ។*
*៥- ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ។*
*៦- កុមារអាយុតិចជាង១៤ឆ្នាំ។*

## ការអនុវត្តនៅ អ.វ.ត.ក

**សាក្សីដែលរួចពីសម្បថ អាចផ្តល់សក្ខីកម្មមុន៖** សក្ខីកម្មដូច្នេះ ត្រូវតែដាក់នៅចំពោះមុខនៃអង្គជំនុំជម្រះជាភស្តុតាង និងត្រូវវាយតម្លៃអំពីភាពពាក់ព័ន្ធ និងតម្លៃភវនីយភាព។

*រឿងក្តីឌុច៖ សាលក្រម អ.វ.ត.ក អ.ជ.ស.ដ ២៦ កក្កដា ២០១០ កថាខណ្ឌ៥២។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន២៤។ វិធាននេះមានលក្ខណៈស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ១៥៦ លើកលែងតែថាមាត្រា ២៤(៣) ដាក់លក្ខខណ្ឌតម្រូវជាច្បាស់លាស់ឲ្យចៅក្រមស៊ើបសួរ កំណត់ថា តើទំនាក់ទំនងផ្នែកគុណវុឌ្ឍិមានអត្ថិភាព ឬអត់។ វិធាន២៤ រួមបញ្ចូលទាំងឈ្មោះសាច់ញាតិរបស់ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**សម្បថរបស់ឪពុកម្តាយនៃចុងចោទ៖** ឪពុកម្តាយមិនធ្វើសម្បថ នៅចំពោះមុខសាលាដំបូងទេ ប៉ុន្តែមិនមែនឲ្យរួចពីការធ្វើសម្បថ ក្នុងអំឡុងនៃកិច្ចស៊ើបសួរឡើយ។

*លេខ83-90217 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៨៧ តុលាការកំពូលបារាំង ២២ មីនា ១៩៨៣។*

**អនីតិជនមានអាយុក្រោម ១៦ ឆ្នាំ ត្រូវបានស្នើសុំឲ្យធ្វើសម្បថ៖** ការណ៍នេះមិនមែនជាមូលហេតុនៃមោឃភាពទេ។

*ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ២២៧ តុលាការកំពូលបារាំង ២៥ សីហា ១៩៥៣។ ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៨៥ តុលាការកំពូលបារាំង ៣០ សីហា ១៩០០។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា១០៣ ១០៨ ១០៩ ១១៣-៧ និង១៥៣។ មាត្រាទាំងនេះ កំណត់អំពីនីតិវិធីសម្រាប់ស្តាប់ចម្លើយសាក្សី រួមទាំងបញ្ហានៃសម្បថរបស់សាក្សី។

# មាត្រា ១៥៧៖ ភាពគ្មានលទ្ធភាពស្តាប់ចម្លើយរបស់សាក្សីមួយចំនួន

*ដើម្បីជាផលប្រយោជន៍ ដល់ការគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរ មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ។ ក្នុងករណីនេះ ចៅក្រមត្រូវយកនីតិវិធីនៃមាត្រា១៤៣ (ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនេះមកអនុវត្ត។*

## *ការអនុវត្តនៅ អ.វ.ត.ក*

ការហាមឃាត់ ចំពោះការកោះហៅសាក្សីដែលមានភស្តុតាងដាក់បន្ទុក ប្រឆាំងនឹងបុគ្គលនោះ មិនពន្លាតទៅដល់បុគ្គល ដែលត្រូវបានគេផ្តន្ទាទោសពីមុនទេ៖ ទោះជាការផ្តន្ទាទោសនោះស្ថិតក្រោមបណ្តឹងសាទុក្ខក៏ដោយ។ បើសិនបណ្តឹងសាទុក្ខនោះ មិនទាន់បញ្ចប់នៅឡើយ នៅពេលដែលជននោះមកបំភ្លឺ អង្គជំនុំជម្រះនៅតែអាចស្តាប់សក្ខីកម្មរបស់ជននោះបាន តាមរយៈនៃការផ្តល់ការណែនាំជាក់លាក់ ដើម្បីការពារសិទ្ធិរបស់សាក្សីរូបនោះ កុំឲ្យធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ សេចក្តីណែនាំស្តីពីកិច្ចប្រជុំរៀបចំសវនាការ អ.វ.ត.ក អ.ជ.ស.ជ ៨ មេសា ២០១១ ទំព័រ១-២។*

បុគ្គលអាចផ្តល់សក្ខីកម្មបាន ចំពោះតែអ្វីដែលខ្លួនបានឃើញ ឬបានឮ ក្រៅអំពីការពាក់ព័ន្ធរបស់ខ្លួន៖ ប្រសិនបើ សក្ខីកម្មរបស់ជនណាម្នាក់ ដែលមានភស្តុតាងដាក់បន្ទុកប្រឆាំងនឹងខ្លួន ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬសកម្មភាពរបស់ខ្លួនក្នុងពេលនោះ សាក្សីរូបនោះ មិនចាំបាច់ឆ្លើយនឹងសំណួរណាមួយ ឬធ្វើសេចក្តីថ្លែងណាមួយ ទាក់ទងនឹងអង្គហេតុនោះឡើយ។ ប៉ុន្តែសាក្សី អាចផ្តល់ហេតុផលផ្សេងចំពោះអ្វីដែលខ្លួនបានឃើញ ឬបានឮ ក្រៅពីសកម្មភាពទាំងឡាយដែលខ្លួនបានធ្វើ។

*រឿងក្តីឌុច៖ ប្រតិចារឹកសវនាការ ថ្ងៃសវនាការទី៨ អ.វ.ត.ក អ.ជ.ស.ជ ២០ មេសា ២០០៩ ទំព័រ៥ បន្ទាត់១-៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន២៤ និងវិធាន២៨។ វិធានទាំងនេះមានលក្ខណៈស្រដៀងគ្នាមែនទែនទៅនឹងមាត្រា១៥៧ លើកលែងតែវិធាន២៨ មានព័ត៌មានលម្អិតជាង អំពីសិទ្ធិរបស់សាក្សីមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង និងកត្តាមួយចំនួនដែលត្រូវពិចារណា ក្នុងការកំណត់ថា តើសាក្សីគួរត្រូវបង្ខំឲ្យឆ្លើយ ឬក៏អត់ រួមទាំងសារៈសំខាន់/លក្ខណៈពិសេសតែមួយគត់នៃភស្តុតាង និងវិធានការការពារដែលមានចំពោះសាក្សី។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**បុគ្គលដែលមានភស្តុតាងដាក់បន្ទុក បង្ហាញថាខ្លួនមានពាក់ព័ន្ធនៅក្នុងបទល្មើស ដែលកំពុងតែស្ថិតនៅក្រោមការស៊ើបសួរ មិនត្រូវកោះហៅមកធ្វើជាសាក្សីឡើយ នៅពេលដែលកិច្ចស៊ើបសួរ បានចាប់ផ្តើម៖** ក៏ប៉ុន្តែបុគ្គលរូបនេះ អាចត្រូវបានគេកោះហៅមកសួរនាំផ្តល់បទសម្ភាសន៍ និងពិភាក្សាបាននៅក្នុងអំឡុងនៃកិច្ចស៊ើបសួរបឋម។

*លេខ 86-93091 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៤៧ តុលាការកំពូលបារាំង ២០ សីហា ១៩៨៦។*

**ចៅក្រមស៊ើបសួរ អាចចោទប្រកាន់លើបុគ្គលណាម្នាក់បាន តែក្នុងករណីណាដែលភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ បង្ហាញអំពីការចូលរួមរបស់បុគ្គលនោះក្នុងបទល្មើសត្រូវបានប្រមូល៖** ភស្តុតាងនេះ អាចត្រូវបានប្រមូល តាមរយៈដំណើរការស៊ើបសួរ រួមទាំងការសួរចម្លើយបុគ្គលនោះ ក្នុងនាមជាសាក្សី ទោះបីជាបុគ្គលនោះ អាចឆ្លើយប្រឆាំងនឹងខ្លួនឯង នៅក្នុងអំឡុងពេល នៃការសួរចម្លើយនោះក៏ដោយចុះ។

*លេខ02-88194 តុលាការកំពូលបារាំង ២១ មករា ២០០៤។*

**ក្នុងស្ថានភាពដែលបុគ្គលម្នាក់ ត្រូវបានស្តាប់ចម្លើយក្នុងនាមជាសាក្សី បន្ទាប់មកសារភាពថា ខ្លួនគឺជាមេគំនិតនៃអំពើឧក្រិដ្ឋដែលពាក់ព័ន្ធ៖** ត្រង់ចំណុចនេះ អ្នកធ្វើសម្ភាសន៍ត្រូវបញ្ឈប់ជាបន្ទាន់។

*លេខ 70-92605 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៧៨ តុលាការកំពូលបារាំង ២៤ កុម្ភៈ ១៩៧២។*

**ក្នុងស្ថានភាពដែលបុគ្គលម្នាក់ ដែលកំពុងស្ថិតក្នុងការឃាត់ខ្លួន តាមដីកាចាត់ឲ្យស៊ើបសួរជំនួស អាចត្រូវបានស្តាប់ចម្លើយដោយមន្ត្រីនគរបាលយុត្តិធម៌៖** បុគ្គលរូបនេះ អាចត្រូវបានគេស្តាប់ចម្លើយ បន្ទាប់ពីបានធ្វើសម្បថ ដរាបណា គេពុំមានភស្តុតាងប្រាកដប្រជា ឬភស្តុតាងបមានីករណ៍ ដែលបានបញ្ជាក់ថាគាត់បានចូលរួមក្នុងបទល្មើស ដែលបានដាក់ជូនចៅក្រមស៊ើបសួរ ហើយឈ្មោះរបស់គាត់មិនមាន នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

*លេខ 04-80753 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១០២ តុលាការកំពូលបារាំង ២៨ មេសា ២០០៤។*

**សេចក្តីប្រកាស នៃការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សីដែលកើតឡើងដោយឯកឯង៖** មន្ត្រីនគរបាលយុត្តិធម៌ អាចប្រមូលភស្តុតាងណាដែលប្រាកដប្រជា អំពីការចូលរួមក្នុងបទល្មើសណាមួយប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលបានស្តាប់ចម្លើយក្នុងនាមជាសាក្សី ប្រសិនបើ សំណួរទាំងនោះគ្រាន់

តែជាសេចក្ដីសង្ខេបនៃសេចក្ដីប្រកាសធ្វើឡើង ដោយឯកឯងរបស់បុគ្គលនោះ ហើយចម្លើយតប នានា មិនបានផ្ដល់នូវធាតុផ្សំថ្មីណាមួយទេ។

*លេខ 85-92518/87-83370 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣០៨ តុលាការកំពូលបារាំង ៍ ១ កញ្ញា ១៩៨៧។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា១០១ និង១០៥។ មាត្រា១០១ចែងអំពីការស្ដាប់ចម្លើយសាក្សីចំណែកមាត្រា១០៥ ចែងអំពីការហាមឃាត់ការស្ដាប់ចម្លើយបុគ្គលជាសាក្សី ដែលមានភស្ដុតាងប្រាកដប្រជា និងភស្ដុតាងបមានីករណ៍បញ្ជាក់អំពីការចូលរួមក្នុងអំពើព្រហ្មទណ្ឌដែលពាក់ព័ន្ធ។

# មាត្រា ១៦២៖ ភាពចាំបាច់នៃការធ្វើកោសលវិច័យ

*នៅក្នុងករណី ដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរ អាចបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។*

*កាលណាចៅក្រមស៊ើបសួរ បដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរ ត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកា ត្រូវសម្រេចក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង១ (មួយ) ខែ ប្រសិនបើពាក្យសុំនោះចេញមកពីជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងឲ្យដល់អ្នកប្ដឹងសុំជាបន្ទាន់។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**បញ្ហាបច្ចេកទេស រួមទាំងបញ្ហាសម្បទារបស់ជនជាប់ចោទ ឬជនត្រូវចោទ៖** អ្នកជំនាញក៏អាចបំពេញលើការងារពិនិត្យ ខាងផ្នែកវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រលើជនជាប់ចោទ ឬជនត្រូវចោទ ដើម្បីកំណត់អំពីសម្បទា ក្នុងការចូលរួមសវនាការរបស់ពួកគេ។ ជនជាប់ចោទ ឬជនត្រូវចោទ ត្រូវមានសមត្ថភាពដើម្បីចូលរួមដោយប្រសិទ្ធភាព នៅក្នុងដំណើរការនីតិវិធី ហើយអ្នកជំនាញ ត្រូវធ្វើការវាយតម្លៃលើសមត្ថភាពនេះ នៅពេលមានសំណើ ហើយសំណើនោះត្រូវមានយុត្តិកម្មត្រឹមត្រូវ។

*រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ ស្តីពីការចាត់តាំងអ្នកជំនាញ អ.វ.ត.ក អ.ប.ជ ២២ តុលា ២០០៨ កថាខណ្ឌ១៨-១៩ និង២៦-២៧។ រឿងក្តី នួន ជា៖ សេចក្តីសម្រេចស្តីពីសម្បទាចូលរួមសវនាការ និងបណ្តឹងក្រុមមេធាវីការពារក្តីស្នើសុំ អ្នកជំនាញផ្នែកវេជ្ជសាស្ត្របន្ថែម អ.វ.ត.ក អ.ជ.ស.ជ ១៥ វិច្ឆិកា ២០១១ កថាខណ្ឌ១៤។ រឿងក្តី អៀង ធីរិទ្ធ៖ សេចក្តីសម្រេច ស្តីពីសម្បទាចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ១០។ រឿងក្តី អៀង សារី៖ សេចក្តីសម្រេចលើបណ្តឹងរបស់អៀង សារី ស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៩ ធ្នូ ២០១២ កថាខណ្ឌ៩។ រឿងក្តី នួន ជា និងខៀវ សំផន៖ សាលក្រមលើសំណុំរឿង ០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១កថាខណ្ឌ៦៧។*

**ចៅក្រមស៊ើបសួរ ត្រូវឆ្លើយតបទៅនឹងសំណើសុំចាត់តាំងអ្នកជំនាញឲ្យបានឆាប់ តាមអាចធ្វើទៅបាន៖** ជាអប្បបរមា សំណើបែបនេះត្រូវបានសម្រេចឡើង នៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ជនត្រូវចោទ អាចដាក់សំណើផ្ទាល់ទៅសភាស៊ើបសួរ ក្នុងករណីណាដែលចៅក្រមស៊ើបសួរមិនបានធ្វើការឆ្លើយតប នឹងសំណើសុំចាត់តាំងអ្នកជំនាញ នៅក្នុងរយៈពេល ៣០ថ្ងៃ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីអ្នកជំនាញចិត្តសាស្ត្រ អ.វ.ត.ក អ.ប.ជ ២១ តុលា ២០០៨ កថាខណ្ឌ២១-២២។*

**ការខកខានរបស់ចៅក្រមស៊ើបសួរ ក្នុងការធ្វើសេចក្តីសម្រេចទាន់ពេលវេលា លើសំណើសុំចាត់តាំងអ្នកជំនាញ ដោយចៅក្រមស៊ើបសួរ អាចត្រូវបានបកស្រាយថា ជាការបដិសេធ៖** បើការពន្យារពេលធ្វើសេចក្តីសម្រេច ធ្វើឲ្យប៉ះពាល់សិទ្ធិរបស់ជនត្រូវចោទនូវលទ្ធភាពទទួលបានផលប្រយោជន៍ ដែលខ្លួនស្វែងរកការពន្យារពេលនេះចាត់ទុកដូចជា ការបដិសេធការស្នើសុំ ដែលអាចប្តឹងឧទ្ធរណ៍បាន ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីអ្នកជំនាញចិត្តសាស្ត្រ អ.វ.ត.ក អ.ប.ជ ២១ តុលា ២០០៨ កថាខណ្ឌ២៣-២៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៣១(១) ៣១(១០) និង៥៥(៥)(ក)។ វិធានទាំងនេះមានលក្ខណៈទូលំទូលាយជាងមាត្រា១៦២ ដោយនៅក្នុងវិធាន៣១(១)ចែងថា កោសលវិច័យ អាចត្រូវបានស្នើឡើងអំពីកម្មវត្ថុណាមួយដែលខ្លួនយល់ថាចាំបាច់ដល់កិច្ចស៊ើបសួរ ឬកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ វិធានទាំងនេះ

ក៏មានការកំហិតជាង ដោយវិធាន៣១(១០) កំហិតចំពោះសំណើរបស់ភាគី ជាជាងសំណើរបស់ចៅក្រមស៊ើបសួរ ឬ អង្គជំនុំជម្រះ ចំពោះអ្នកជំនាញដែលនឹងត្រូវដឹកនាំធ្វើការពិនិត្យ ឬពិនិត្យឡើងវិញលើបញ្ហា ដែលជាកម្មវត្ថុនៃកោសលវិច័យរួចហើយ ខណៈដែលវិធាន៥៥(៥)(ក) ចែងថា ចៅក្រមស៊ើបសួរ អាចចាត់វិធានការស៊ើបសួរ ដែលនាំទៅរកការបង្ហាញការពិត រួមទាំងការទទួលបានកោសលវិច័យនៅពេលសមស្រប។

## ***ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត***

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលប្បញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការបដិសេធមិនឲ្យចេញដីកាបង្គាប់ឲ្យអ្នកជំនាញសំខាន់ៗផ្តល់សក្ខីកម្ម គឺជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌៖** ពេលណាសក្ខីកម្មរបស់អ្នកជំនាញមានសារៈសំខាន់យ៉ាងខ្លាំងដល់រឿងក្តី ការបដិសេធរបស់តុលាការ មិនចេញដីកាបង្គាប់ឲ្យផ្តល់សក្ខីកម្មទាំងនោះគឺជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

*រឿងក្តី GARCÍA FUENZALIDA ទល់នឹងប្រទេសអេក្វាឌ័រ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១២ កក្កដា ១៩៩៦ កថាខណ្ឌ៩.៥។*

**មាត្រាស្រដៀងគ្នានៅក្នុង*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*៖** មាត្រា១៤(៣)(ខ) និង១៤(៣)(ង)។ មាត្រា១៤(៣)(ខ) តម្រូវថាជនត្រូវចោទមានពេលវេលា និងឧបករណ៍គ្រប់គ្រាន់ ក្នុងការត្រៀមរៀបចំការការពារខ្លួនគាត់ ចំណែកមាត្រា១៤(៣)(ង) ផ្តល់សិទ្ធិស្មើភាពគ្នាក្នុងការទទួលបាន និងការសួរដេញដោលសាក្សី។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ការលើកឡើងពីសំណើ ដែលសុំចាត់តាំងអ្នកជំនាញ៖** សំណើធ្វើឡើងដោយភាគីនៃរឿងក្តី ពុំចាំបាច់ត្រូវបញ្ជូនទៅឲ្យរដ្ឋអាជ្ញាទេ។

*លេខ 79-90313 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១០០ តុលាការ កំពូលបារាំង ២៥ មីនា ១៩-៨០។*

**ការផ្ទេរកិច្ចការ ដែលមានសណ្ឋាន ដូចអ្នកជំនាញនៃការិយាល័យអយ្យការ នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរបឋម៖** រដ្ឋអាជ្ញា អាចផ្ទេរទៅឲ្យបុគ្គលមានគុណវុឌ្ឍិ ដើម្បីបំពេញកិច្ចការដែលមានលក្ខណៈស្រដៀងគ្នានឹងកិច្ចការរបស់អ្នកជំនាញ ដែលបានចាត់តាំងដោយចៅក្រម ស៊ើបសួរ។

*លេខ05-84021 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៦ តុលាការកំពូលបារាំង ១៤ កញ្ញា ២០០៥។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា១៥៦។ មាត្រានេះ ចែងអំពីការចាត់តាំងអ្នកជំនាញដើម្បីពិនិត្យលើបញ្ហាបច្ចេកទេសដែលកើតចេញ ពីសំណើសុំរបស់អង្គជំនុំជម្រះដែលពាក់ព័ន្ធ ឬតាមសំណើសុំរបស់រដ្ឋអាជ្ញា ឬរបស់ភាគីណាមួយ។

# មាត្រា ១៦៥៖ ដីកាចាត់តាំងអ្នកជំនាញ

*អ្នកជំនាញ ត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរ។ ដីកា ត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញ ព្រមទាំងរយៈពេលដែលត្រូវបំពេញបេសកកម្មនេះ។*

*បេសកកម្ម អាចទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។*

*ប្រសិនបើជាការគួរ ចៅក្រមស៊ើបសួរ ប្រគល់វត្ថុដែលចាប់បានមួយផ្នែក ឬទាំងអស់នោះជូនអ្នកជំនាញ។ ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្ដីពីការប្រគល់វត្ថុដែលចាប់បាន។ អ្នកជំនាញ អាចបំបែកស្លាកដែលបិទ ដើម្បីអាចបំពេញការងារជាអ្នកជំនាញបាន។ ប្រសិនបើ កោសល្យវិច័យនេះអាចធ្វើឲ្យខូចខាត ឬវិនាសដល់វត្ថុដែលចាប់បាននោះ អ្នកជំនាញ ត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមនេះ មុននឹងផ្ដើមប្រតិបត្តិការរបស់ខ្លួន។*

## ការអនុវត្តនៅ អ.វ.ត.ក

**បញ្ហាបច្ចេកទេស រួមទាំងសម្បទារបស់ជនជាប់ចោទ ឬជនត្រូវចោទ៖** អ្នកជំនាញអាចធ្វើការពិនិត្យផ្នែកវេជ្ជសាស្ត្រ និងចិត្តសាស្ត្រដល់ជនជាប់ចោទ ឬជនត្រូវចោទ ដើម្បីកំណត់អំពីសម្បទាក្នុងការចូលរួមសវនាការ។ ជនជាប់ចោទ ឬជនត្រូវចោទ មានសិទ្ធិស្នើឲ្យមានការវាយតម្លៃដោយអ្នកជំនាញ លើសមត្ថភាពរបស់ខ្លួនក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយប្រសិទ្ធភាព ប្រសិនបើសំណើរបស់ខ្លួនមានយុត្តិកម្មត្រឹមត្រូវ។

*រឿងក្ដីនួន ជា៖ បណ្ដឹងឧទ្ធរណ៍អំពីការចាត់តាំងអ្នកជំនាញ អ.វ.ត.ក អ.ប.ជ ២២ តុលា ២០០៨ កថាខណ្ឌ១៨-១៩ និង២៦-២៧។ រឿងក្ដីនួន ជា៖ សេចក្ដីសម្រេច ស្ដីពីសម្បទាក្នុងការចូលរួមសវនាការ ព្រមទាំងបណ្ដឹងរបស់ក្រុមមេធាវីការពារ ស្នើសុំអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ អ.វ.ត.ក អ.ជ.ស.ជ ១៩ វិច្ឆិកា ២០១១ កថាខណ្ឌ១៤ ។ រឿងក្ដីអៀង ធីរិទ្ធ៖ សេចក្ដីសម្រេច ស្ដីពីសម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ១០។ រឿងក្ដីអៀង សារី៖ សេចក្ដីសម្រេច ស្ដីពីការស្នើសុំរបស់អៀង សារី ឲ្យអង្គជំនុំជម្រះសាលាដំបូង ពិចារណាឡើងវិញលើសេចក្ដីសម្រេច ស្ដីពីសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៩ ធ្នូ ២០១២ កថាខណ្ឌ៩។ រឿងក្ដី នួន ជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ។*

**សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ត្រូវតែឯករាជ្យ៖** សារណាទាំងនោះ អាចដាក់ដោយអ្នកជំនាញ ដែលមិនមានសម្ព័ន្ធភាពជាមួយតុលាការ ឬការិយាល័យរបស់តុលាការ។ សារណានេះ មិនអាចត្រូវបានគេប្រើជំនួសឲ្យមេធាវីអន្តរជាតិទេ។

*រឿងក្តីឌុច៖ សំណើស្តីពីសារណារបស់អ្នកដែលមិនមែនជាភាគី ក្នុងរឿងក្តី អ.វ.ត.ក អ.ជ.ត.ក ០៩ ធ្នូ ២០១០ កថាខណ្ឌ៨-៩។*

**នៅពេលណាអាយុ ឬសមត្ថភាពរបស់ជនត្រូវចោទមានបញ្ហាចោទឡើង អ្នកជំនាញផ្នែកវេជ្ជសាស្ត្រអាចត្រូវបានតែងតាំងដើម្បីធ្វើការពិនិត្យមើលអំពីសម្បទា របស់ជនត្រូវចោទនៅក្នុងការចូលរួមសវនាការ៖** នៅពេលណាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រត្រូវបានតែងតាំង គោលការណ៍ក្នុងការសម្រេច ថាតើជនត្រូវចោទអាចអនុវត្តសិទ្ធិរបស់ខ្លួនបានដោយប្រសិទ្ធភាព នៅក្នុងរឿងក្តីប្រឆាំងនឹងខ្លួនឬទេ។ សិទ្ធិទាំងឡាយរបស់ជនត្រូវចោទ ជារួមមាន (១) សិទ្ធិប្តឹងផ្តល់ (២) សិទ្ធិយល់ដឹងអំពីប្រភេទនៃបទចោទ (៣) សិទ្ធិយល់ដឹងអំពីដំណើរការនៃកិច្ចដំណើរការនីតិវិធី (៤) សិទ្ធិយល់ដឹងពិស្តារ អំពីភស្តុតាង (៥) សិទ្ធិផ្តួចផ្តើមគំនិតដល់មេធាវី (៦) សិទ្ធិយល់ដឹងអំពីផលវិបាកនៃកិច្ចដំណើរការនីតិវិធី និង (៧) សិទ្ធិផ្តល់សក្ខីកម្ម។

*រឿងក្តីនួន ជា៖ សេចក្តីសម្រេច ស្តីពីសម្បទាក្នុងការចូលរួមសវនាការ និងបណ្តឹងរបស់មេធាវីការពារក្តី ស្នើសុំអ្នកជំនាញផ្នែកវេជ្ជសាស្ត្របន្ថែម អ.វ.ត.ក អ.ជ.ស.ជ ១៥ វិច្ឆិកា ២០១១ កថាខណ្ឌ១៤។ រឿងក្តីអៀង ធីរិទ្ធ៖ សេចក្តីសម្រេច ស្តីពីសម្បទាក្នុងការចូលរួមសវនាការ និងបណ្តឹងរបស់មេធាវីការពារស្នើសុំអ្នកជំនាញផ្នែកវេជ្ជសាស្ត្របន្ថែម អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ១០។ រឿងក្តីនួន ជា៖ សេចក្តីសម្រេច ស្តីពីសម្បទារបស់នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២៤ មេសា ២០១២ កថាខណ្ឌ៦។ រឿងក្តីខៀវ សំផន៖ សេចក្តីសម្រេចស្តីពីសម្បទារបស់ខៀវ សំផន ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២៤ មេសា ២០១២ កថាខណ្ឌ៦។*

**ត្រូវតែមានមូលហេតុគ្រប់គ្រាន់ ដើម្បីផ្តល់នូវយុត្តិកម្មក្នុងការសាកសួរបន្ថែម អំពីសម្បទានៃជនត្រូវចោទ៖** កាលណាគេចង់ធ្វើការវាយតម្លៃឡើងវិញ នោះគឺជាបន្ទុករបស់ភាគីទទួលរងនូវផលប៉ះពាល់នានា ដើម្បីបង្ហាញអំពីភាពចាំបាច់។

*រឿងក្តីអៀង ធីរិទ្ធ៖ សេចក្តីសម្រេចស្តីពីសម្បទា ក្នុងការចូលរួមសវនាការ និងបណ្តឹងរបស់មេធាវីការពារ ស្នើសុំអ្នកជំនាញ ផ្នែក*

*វេជ្ជសាស្ត្របន្ថែម អ.វ.ត.ក អ.ជ.ស.ជ ១៩ វិច្ឆិកា ២០១១ កថាខណ្ឌ ២០។ រឿងក្តីនួន ជា និងខៀវ សំផន៖ សេចក្តីសម្រេចស្តីពីសម្បទារបស់ជនត្រូវចោទ ក្នុងការចូលរួមសវនាការ និងដីកាបង្គាប់ ក្នុងការចាត់តាំងអ្នកជំនាញ អ.វ.ត.ក អ.ជ.ស.ជ ១៧ កុម្ភៈ ២០១៤ កថាខណ្ឌ៥។ រឿងក្តីនួន ជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ៧..*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៣១(៣) ៣២ និង៣៣។ វិធាន៣១(៣) មានលក្ខណៈ ស្រដៀងគ្នាមែនទែនទៅនឹងមាត្រា១៦៥ លើកលែងតែមាត្រានេះ មិនកម្រិតត្រឹមទិដ្ឋភាពបច្ចេកទេសទេ។ វិធាន៣២ អនុញ្ញាតជាពិសេសឲ្យមានការពិនិត្យផ្នែកវេជ្ជសាស្ត្រ និងចិត្តសាស្ត្រដល់ជនជាប់ចោទ ឬជនត្រូវចោទ ដើម្បីកំណត់ថាតើបុគ្គលនោះមានសមត្ថភាពក្នុងការចូលរួមសវនាការ ឬអត់ ឬសម្រាប់មូលហេតុផ្សេងទៀត។ វិធាន៣៣(១) ចែងថា ចៅក្រមស៊ើបសួរ ឬអង្គជំនុំជម្រះ អាចស្នើឬអនុញ្ញាតឲ្យអង្គការ ឬបុគ្គលណាមួយ ដាក់ជូនសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីបាន។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ការពិនិត្យផ្នែកវិកលចរិកពេញលេញ ដល់ជនត្រូវចោទ ក្នុងបំណងច្រានចោលនូវការទទួលខុសត្រូវរបស់ជននេះ មិនរារាំងអ្នកជំនាញឲ្យធ្វើការពិនិត្យអង្គហេតុផ្សេងៗឡើយ៖** អ្នកជំនាញ នៅតែអាចពិចារណាអំពីពិរុទ្ធភាព និងលទ្ធភាពនៃទោសព្រហ្មទណ្ឌបានដដែល។

*លេខ91-80614 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១-៦៩ តុលាការកំពូលបារាំង ៩ មេសា ១៩៩១។*

**អ្នកជំនាញ ត្រូវតែធ្វើរបាយការណ៍ជូនទៅចៅក្រមស៊ើបសួរ អំពីអង្គហេតុដែលសង្ស័យ ដែលបានកត់សម្គាល់ក្នុងអំឡុងពេលនៃការពិនិត្យឯកសារដែលបានផ្តល់ជូនដល់គាត់៖** ចៅក្រមស៊ើបសួរ អាចចាត់វិធានការចាំបាច់នានា រួមទាំងការពង្រីកនូវវិសាលភាពបេសកកម្មរបស់អ្នកជំនាញ។

*លេខ66-90922 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១ តុលាការ កំពូលបារាំង ១០ មករា ១៩៦៧។*

**ពេលណាបញ្ជីឯកសារជាលាយលក្ខណ៍អក្សរមានរួចស្រេច នៅមុនពេលត្រូវបានផ្តល់ជូនអ្នកជំនាញ៖** នៅក្នុងកាលៈទេសៈដូច្នេះ ចៅក្រមស៊ើបសួរមិនចាំបាច់ធ្វើបញ្ជីឯកសារដូច្នេះទៀតទេ។

*លេខ 02-80721 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១១១ តុលាការកំពូលបារាំង ១៤ ឧសភា ២០០៤។*

**មាត្រាស្រដៀងគ្នា នៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*** ៖ មាត្រា១៥៨ ១៥៩ ១៦១ និង១៦៣។ មាត្រា១៥៨ កំណត់អំពីតួនាទីរបស់អ្នកជំនាញ។ មាត្រា១៥៩ ចែងអំពីការផ្តល់អំណាចជូនចៅក្រមស៊ើបសួរ ក្នុងការចាត់តាំងអ្នកជំនាញមួយរូប ឬច្រើនរូប។ មាត្រា១៦១ កំណត់អំពីនីតិវិធីសម្រាប់អ្នកជំនាញ ដែលត្រូវចូលរួមបំពេញការពិនិត្យ និងធ្វើរបាយការណ៍របស់ខ្លួន។ មាត្រា១៦៣ ទាក់ទងនឹងការបញ្ជូនភស្តុតាងទៅឲ្យអ្នកជំនាញដើម្បីធ្វើការពិនិត្យ។

# មាត្រា ១៦៩៖ ការចាត់តាំងអ្នកជំនាញច្រើនរូប

*ប្រសិនបើកាលៈទេសៈតម្រូវ ចៅក្រមស៊ើបសួរ អាចចាត់តាំងអ្នកជំនាញច្រើននាក់។*

*នៅក្នុងករណីនេះ ប្រសិនបើ អ្នកជំនាញនេះមានយោបល់ខុសគ្នានោះ ម្នាក់ៗត្រូវសរសេរអំពីយោបល់របស់ខ្លួនផ្ទាល់ ឬការមិនយល់ព្រមរបស់ខ្លួន។*

## ការអនុវត្តនៅ អ.វ.ត.ក

**អ្នកជំនាញបន្ថែម ឬប្រតិអ្នកជំនាញ អាចត្រូវបានកោះអញ្ជើញដោយភាគីនៃរឿងក្តី បន្ទាប់ពីបានដឹងអំពីខ្លឹមសារនៃកោសលវិច័យ៖** មេធាវីរបស់ភាគី អាចដាក់សំណើសុំឲ្យតែងតាំងអ្នកជំនាញបន្ថែម ដើម្បីពិនិត្យឡើងវិញនូវខ្លឹមសារនៃរបាយការណ៍កោសលវិច័យ ដែលបានដាក់ជូនតុលាការរួច។ ភាគីនានា អាចអនុវត្តសិទ្ធិនេះបាន នៅពេលដែលពួកគេមានកង្វល់ពីរបាយការណ៍កោសលវិច័យ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឲ្យតែងតាំងអ្នកជំនាញប្រជាសាស្ត្របន្ថែម អ.វ.ត.ក អ.ប.ជ ២៨ មិថុនា ២០១០ កថាខណ្ឌ១៤។ រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឲ្យតែងតាំងអ្នកជំនាញប្រជា-សាស្ត្របន្ថែម អ.វ.ត.ក អ.ប.ជ ០១ កក្កដា ២០១០ កថាខណ្ឌ១៥។*

**សំណើសុំឲ្យតែងតាំងអ្នកជំនាញបន្ថែម ត្រូវតែធ្វើឡើងឲ្យបានទាន់ពេល៖** នៅពេលមេធាវីការពារ មានបំណងឲ្យមានការកែប្រែ នៅលើដីកាចាត់តាំងអ្នកជំនាញបន្ថែម មេធាវីនោះត្រូវលើកឡើងពីភាពកង្វល់នេះភ្លាមៗ ក្រោយពីដីកាស្នើសុំបានចេញ។

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឲ្យតែងតាំងអ្នកជំនាញប្រជាសាស្ត្របន្ថែម អ.វ.ត.ក អ.ប.ជ ០១ កក្កដា ២០១០ កថាខណ្ឌ២៣-២៤។(សំណើនេះត្រូវ បានបដិសេធដោយដីកា ត្រូវបានចេញជិតមួយឆ្នាំមុន)។*

*រឿងក្តីនួន ជា៖ សេចក្តីសម្រេចស្តីពីសម្បទាក្នុងការចូលរួមសវនាការ និងបណ្តឹងរបស់មេធាវីការពារ ស្នើសុំអ្នកជំនាញ ផ្នែកវេជ្ជ-សាស្ត្របន្ថែម អ.វ.ត.ក អ.ជ.ស.ជ ១៥ វិច្ឆិកា ២០១១ កថាខណ្ឌ៣៦-៣៧ (ការបដិសេធសំណើ ត្រូវបានធ្វើឡើងកាលណាកិច្ចខិតខំប្រឹងប្រែង ត្រូវបានធ្វើឡើង ដើម្បីតតាំងគ្នាអំពីភាពគួរឲ្យជឿជាក់បាននៃអ្នកជំនាញ បន្ទាប់ពីរបាយការណ៍របស់គេត្រូវបានដាក់ជូនតុលាការ)។*

**សំណើសុំអ្នកជំនាញផ្នែកវេជ្ជសាស្ត្របន្ថែម ត្រូវរាប់បញ្ចូលទាំងមូលហេតុជាក់ស្តែងទាំងឡាយសម្រាប់តម្រូវការ ឬកាលៈទេសៈថ្មីៗរបស់គេ ដែលគាំទ្រដល់ការរាប់បញ្ចូលរបស់គេ៖** មេធាវីមិនអាចស្នើសុំអ្នកជំនាញបន្ថែមទេ ក្នុងកាលៈ-ទេសៈ ដែលសេចក្តីសម្រេច ត្រូវបានធ្វើឡើងដើម្បីសម្រេចថា អ្នកជំនាញទាំងនោះមិនចាំ-បាច់នោះទេ នៅក្នុងករណីណាដែលមិនមានកាលៈទេសៈថ្មីៗ ដើម្បីផ្តល់យុត្តិកម្មដល់ការរាប់បញ្ចូលនោះ។

*រឿងក្តីអៀង សារី៖ សេចក្តីសម្រេចស្តីពីសំណើរបស់អៀង សារី ឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការពិចារណាឡើងវិញ លើសេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៩ ធ្នូ ២០១២ កថាខណ្ឌ៩-១០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៣១(៩) និង៣១ (១០)។ វិធាន៣១(៩) មានលក្ខណៈស្រដៀងគ្នាមែនទែនទៅនឹងមាត្រា១៦៩ លើកលែងតែមាត្រានេះ កម្រិតចំនួនអ្នកជំនាញត្រឹមចំនួនមួយសមស្រប និងដាក់នូវលក្ខខណ្ឌតម្រូវឲ្យអ្នកជំនាញ ដែលមានយោបល់មិនយល់ស្រប ផ្តល់ហេតុផលរបស់ខ្លួន។ វិធាន៣១(១០) អនុញ្ញាតឲ្យភាគីស្នើសុំឲ្យតែងតាំងអ្នកជំនាញបន្ថែម ដើម្បីដឹកនាំការពិនិត្យជាថ្មី ឬពិនិត្យឡើងវិញលើកម្មវត្ថុនៃរបាយការណ៍កោសលវិច័យ ដែលបានដល់ចំពោះមុខតុលាការរួចហើយ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ការប្រតិបត្តិការងារ ដោយអ្នកជំនាញតែមួយរូបក្នុងចំណោមអ្នកជំនាញពីររូប ដែលបានចាត់តាំង អាចមិនមែនជាការរំលោភសិទ្ធិ ក្នុងការការពារខ្លួនឡើយ៖** បើសិនជាមានការព្រមព្រៀងតុណ្ហី របស់ចៅក្រមស៊ើបសួរ។

*លេខ 99-87081 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៤៩ តុលាការកំពូលបារាំង ១ កុម្ភៈ ២០០០។*

**នៅពេលអ្នកជំនាញមួយរូប ក្នុងចំណោមអ្នកជំនាញពីររូបដែលបានចាត់តាំង បានស្លាប់នៅក្នុងអំឡុងនៃដំណើរការពិនិត្យរបស់ខ្លួន៖** របាយការណ៍ពិនិត្យមួយដែលបានធ្វើឡើងដោយអ្នកជំនាញតែម្នាក់នោះ មិនអាចត្រូវបានលុបចោលទេ បើសិនចៅក្រមស៊ើបសួរបានដឹងអំពីស្ថានការណ៍ ហើយអាចគ្រប់គ្រងលើការវិវឌ្ឍន៍នៃការពិនិត្យនោះ។ ការសម្រេច

ដើម្បីចាត់តាំងអ្នកជំនាញទីពីរ ពុំមែនជាការចាប់បង្ខំឡើយ។

*លេខ 02-83270 តុលាការកំពូលបារាំង ២៤ កក្កដា ២០០២។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា១៥៦។ មាត្រានេះ ប្រគល់អំណាចឲ្យចៅក្រមស៊ើបសួរ ដើម្បីចាត់តាំងអ្នកជំនាញមួយរូប ឬច្រើនរូប។

# មាត្រា ១៧០៖ ការជូនដំណឹងអំពីសេចក្ដីសន្និដ្ឋាននៃកោសលវិច័យ

*កាលណារបាយការណ៍កោសលវិច័យ ត្រូវបានដាក់ជូនរួចហើយ ចៅក្រមស៊ើបសួរ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាអំពីរបាយការណ៍នេះ។*

*របាយការណ៍កោសលវិច័យ ត្រូវដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ។*

*ចៅក្រមស៊ើបសួរ កោះហៅជនត្រូវចោទ និងមេធាវី ដើម្បីប្រាប់ឲ្យដឹងពីសេចក្ដីសន្និដ្ឋាននៃកោសលវិច័យនេះ។*

*ចៅក្រមស៊ើបសួរ អាចកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីផងដែរ ដើម្បីប្រាប់ឲ្យដឹងពី សេចក្ដីសន្និដ្ឋាននៃកោសលវិច័យ។*

*ចៅក្រមស៊ើបសួរ កំណត់រយៈពេលដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ចាត់តាំង ឬប្រតិកោសលវិច័យ។ រយៈពេលនេះ មិនអាចតិចជាង១០(ដប់) ថ្ងៃទេ។ ក្នុងរយៈពេលនេះ សំណុំរឿងដែលរួមមានរបាយការណ៍កោសលវិច័យ អាចត្រូវបានពិនិត្យមើលដោយមេធាវី។*

*គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ ត្រូវតែមានសំអាងហេតុ និងធ្វើឡើងជាលាយលក្ខណ៍អក្សរ។*

*កាលណាចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរ ត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកា ត្រូវសម្រេចក្នុងរយៈពេល៥(ប្រាំ) ថ្ងៃប្រសិនបើពាក្យសុំ ចេញមកពីព្រះរាជអាជ្ញា និង១ (មួយ) ខែ ប្រសិនបើពាក្យសុំនេះ ចេញពីជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។ ដីកា ត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងសុំ។*

*គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ ដែលធ្វើឡើងក្រោយផុតរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។*

*ប្រសិនបើចៅក្រមស៊ើបសួរ ដែលបានទទួលពាក្យសុំឲ្យតែងតាំងអ្នកជំនាញ ស្នើសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ មិនព្រមសម្រេចក្នុងរយៈពេលដែលបានចែងក្នុងកថាខណ្ឌ២ នៃមាត្រា ១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ) នៃក្រមនេះ ឬចែងក្នុងមាត្រានេះ អ្នកសុំ អាចធ្វើពាក្យប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។*

## ***ការអនុវត្តនៅ អ.វ.ត.ក***

**សិទ្ធិឯកជនរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងព័ត៌មានវេជ្ជសាស្ត្រ ស្តីពីសម្បទាក្នុងការចូលរួមសវនាការ៖** នៅពេលជនជាប់ចោទ ជំទាស់ទៅនឹងសម្បទា នៅក្នុងការចូលរួមសវនាការ សិទ្ធិរក្សាភាពឯកជន នៃព័ត៌មានផ្នែកវេជ្ជសា-ស្ត្រ ត្រូវមានតុល្យភាព ជាមួយនឹងសិទ្ធិរបស់សាធារណជន ដើម្បីឲ្យដឹងអំពីមូលដ្ឋាននៃសេចក្តីសម្រេចលើការជំទាស់នឹងសម្បទា។ ក្នុងករណីបែបនេះ ភាគីទាំងអស់ ត្រូវមានឱកាសដើម្បីគាំទ្រ ឬជំទាស់ទៅនឹងការរកឃើញក្នុងកោសលវិច័យ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ អនុស្សរណៈ ជូនចំពោះមេធាវីរបស់ភាគី អ.វ.ត.ក អ.ជ.ស.ជ ៦ កក្កដា ២០១១ ទំព័រ១-២។*

**ចៅក្រមស៊ើបសួរ ត្រូវតែឆ្លើយតបទៅនឹងសំណើសុំតែងតាំងអ្នកជំនាញ ឲ្យបានឆាប់តាមដែលអាចធ្វើបាន៖** ជាអប្បបរមា សំណើនេះត្រូវសម្រេចនៅមុនពេល បញ្ចប់ចិរវេលានៃកិច្ចស៊ើបសួរ។ ជនត្រូវចោទអាចដាក់សំណើផ្ទាល់ទៅសភាស៊ើបសួរ ប្រសិនបើចៅក្រមស៊ើបសួរបានខកខានមិនបានឆ្លើយតប ទៅនឹងសំណើសុំតែងតាំងអ្នកជំនាញក្នុងរយៈពេល៣០ថ្ងៃ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីអ្នកជំនាញចិត្តសាស្ត្រ អ.វ.ត.ក អ.ប.ជ ២១ តុលា ២០០៨ កថាខណ្ឌ២១-២២។*

**សំណើសុំឲ្យតែងតាំងអ្នកជំនាញបន្ថែម ឬប្រតិអ្នកជំនាញ មិនអាចកើតមានឡើងមុនការបង្ហាញកោសលវិច័យដំបូងបានឡើយ៖** មាត្រា ១៧០ ក៏ផ្តល់អត្ថន័យបង្កប់ផងដែរថាតាមច្បាប់កម្ពុជា មិនមែនជារឿងធម្មតាទេ ដែលសំណើសុំដូច្នេះត្រូវបានដាក់មុនពេលមានរបាយ-ការណ៍កោសលវិច័យបឋមនោះ។ បន្ទាប់ពីរបាយការណ៍កោសលវិច័យបឋម ត្រូវបានដាក់រួចហើយ ចៅក្រមស៊ើបសួរ ក៏អាចកំណត់នូវកាលវិភាគសម្រាប់អ្នកជំនាញបន្ថែម ឬប្រតិអ្នកជំនាញ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំ ឲ្យតែងតាំងអ្នកជំនាញបន្ថែម អ.វ.ត.ក អ.ប.ជ ១៤ ធ្នូ ២០០៩ កថាខណ្ឌ១២-១៦។*

**ការតវ៉ាចំពោះគុណវុឌ្ឍិរបស់អ្នកជំនាញ ដែលបានចាត់តាំង៖** ជាទូទៅការជំទាស់នេះ អាចអនុញ្ញាតបានបន្ទាប់ពីមានការបង្ហាញរបាយការណ៍របស់អ្នកជំនាញប៉ុណ្ណោះ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឲ្យតែងតាំង អ្នកជំនាញបន្ថែម អ.វ.ត.ក អ.ប.ជ ១៤ ធ្នូ ២០០៩ កថាខណ្ឌ១៧។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន៣១(៧) ៣១(៨) និង៣១(១០)។ វិធានទាំងនេះ មានលក្ខណៈស្រដៀងគ្នាជាទូទៅទៅនឹងមាត្រា ១៧០ ទោះបីវិធានផ្ទៃក្នុងទាំងនេះ មិនតម្រូវឲ្យចៅក្រមស៊ើបសួរ កោះហៅភាគីណាមួយមកស្តាប់លទ្ធផល ក្នុងរបាយការណ៍កោសលវិច័យណាមួយក៏ដោយ ផ្ទុយទៅវិញចៅក្រមស៊ើបសួរ អាចជូនដំណឹងដល់ភាគីទាំងឡាយ តាមរយៈតែការដាក់បញ្ចូលរបាយការណ៍នេះទៅក្នុងសំណុំរឿង ឬកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ (វិធាន៣១(៧) ៣១(៨))។ សំណើដែលធ្វើឡើងដោយអយ្យការ មេធាវីការពារក្តី ឬដើមបណ្តឹងរដ្ឋប្បវេណី សុំធ្វើកោសលវិច័យបន្ថែម ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ និងគ្រាន់តែ"បញ្ជាក់មូលហេតុ" (វិធាន៣១(១០))។ ខណៈដែលគ្មានការដាក់កំហិតចំពោះពេលវេលា វិធាន៣១(១០) តម្រូវថា ចៅក្រមស៊ើបសួរ ឬអង្គជំនុំជម្រះ ត្រូវសម្រេចលើសំណើសុំឲ្យបានឆាប់តាមដែលអាចធ្វើបាន និងនៅមុនពេលបញ្ចប់នៃកិច្ចស៊ើបសួរ ឬកិច្ចដំណើរការនីតិវិធី។ សំណើដែលត្រូវបានបដិសេធ អាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

## ***ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត***

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុប ត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ឱកាសក្នុងការជេញដោលភស្តុតាង ដែលពាក់ព័ន្ធ៖** ភាគីនៃរឿងក្តី ត្រូវមានឱកាសក្នុងការដឹង និងផ្តល់យោបល់នៅលើគ្រប់ភស្តុតាង ដែលបានលើកសំអាង ឬសេចក្តីសង្កេតដែលបានដាក់ទាំងអស់ និងចូលរួមដោយផ្ទាល់ ក្នុងពេលស្តាប់ចម្លើយអ្នកជំនាញ។

> *រឿងក្តី RUIZ MATEOS ទល់នឹងប្រទេសអេស្ប៉ាញ តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៣ មិថុនា ១៩៩៣ កថាខណ្ឌ៦៣ (ដឹង និងផ្តល់យោបល់លើភស្តុតាង ឬសេចក្តីសង្កេតផ្សេងៗ)។ រឿងក្តី MANTO-VANELLI ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៨ មីនា ១៩៩៧ កថាខណ្ឌ៣ (ចូលរួមក្នុងកិច្ចសម្ភាសន៍)។*

**អ្នកផ្លាស់ប្តូរមតិអ្នកជំនាញ ក្នុងអំឡុងពេលសវនាការ៖** នៅពេលដែលអ្នកជំនាញ របស់ជនជាប់ចោទប្តូរមតិរបស់ខ្លួន នៅពេលជំនុំជម្រះក្តី ដោយប្រកាន់យកនូវជំហរមិនគាំទ្រជនជាប់ចោទ ហើយផ្ទុយទៅនឹងមតិដែលមានក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ សិទ្ធិរបស់ជនជាប់ចោទ ដើម្បីទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ អាចត្រូវបានរំលោភបំពាន។

> *រឿងក្តី G.B. ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២ តុលា ២០០១ កថាខណ្ឌ ៦៩-៧០។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៦(១)។ មាត្រានេះ ចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានសវនាការមួយដែលត្រឹមត្រូវ និងមានពេលវេលា និងឧបករណ៍គ្រប់គ្រាន់ សម្រាប់ការត្រៀមរៀបចំការការពារខ្លួន។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ទោះបីចៅក្រមស៊ើបសួរ មានកាតព្វកិច្ចជូនដំណឹងដល់ភាគី អំពីសេចក្តីសន្និដ្ឋានក្នុងកោសលវិច័យក៏ដោយ កង្វះការជូនដំណឹងដូច្នេះ មិនមែនជាការរំលោភសិទ្ធិរបស់បុគ្គល ដែលស្ថិតក្រោមការពិនិត្យនោះឡើយ៖** នេះដោយសារថា ការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរផ្តល់សិទ្ធិដល់ភាគីក្នុងរយៈពេល២០ថ្ងៃ នូវសិទ្ធិស្នើសុំធ្វើកោសលវិច័យ (រួមទាំងកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ)។

*លេខ 05-86773 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៤៦ តុលាការកំពូលបារាំង ១៥ កុម្ភៈ ២០០៦។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា១៦៧។ មាត្រានេះ កំណត់អំពីនីតិវិធីសម្រាប់ធ្វើការជូនដំណឹងអំពីសេចក្តីសន្និដ្ឋានលើកោសលវិច័យ និងសម្រាប់ធ្វើសំណើសុំកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ។

# មាត្រា ១៩៧៖ ដីកាបង្គាប់ឲ្យចាប់ខ្លួន និងយោបល់របស់ព្រះរាជអាជ្ញា

*មុននឹងចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ចៅក្រមស៊ើបសួរ ត្រូវតែទទួលយកយោបល់របស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ ត្រូវចេញដីកានេះដោយមានថែងមូលហេតុ ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា។*

*ព្រះរាជអាជ្ញា ធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។*

## ការអនុវត្តនៅអ.វ.ត.ក

**ចៅក្រមស៊ើបសួរ មានសេរីភាពដើម្បីកំណត់ចរិកលក្ខណៈ នៃអង្គហេតុទាំងឡាយ ដែលខ្លួនយល់ឃើញថាសមស្រប៖** ចៅក្រមស៊ើបសួរ មិនជាប់កាតព្វកិច្ចទាក់ទងនឹងការកំណត់ចរិកលក្ខណៈនៃអង្គហេតុដោយព្រះរាជអាជ្ញាឡើយ ទោះបីជាពួកគេ ត្រូវធ្វើសេចក្តីសម្រេចអំពីការកំណត់ចរិកលក្ខណៈនោះក៏ឡើយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធិ និងឌុច៖ ដីកាស្តីពីការស្នើសុំធ្វើការបំភ្លឺបញ្ហាក់ អំពីបទទាំងឡាយ អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបសួរ ២០ វិច្ឆិកា ២០០៩ កថាខណ្ឌ១០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធានផ្ទៃក្នុង៤៤។ វិធាននេះស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ១៩៧។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ចៅក្រមស៊ើបសួរ មានអំណាចក្នុងការចេញដីកាបង្គាប់ឲ្យចាប់ខ្លួន៖** អំណាចនេះអាចអនុវត្តទៅបានបន្ទាប់ពីការបញ្ចប់រាល់កិច្ចស៊ើបសួរចាំបាច់ទាំងអស់។

*លេខ83-94762 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៥៨ តុលាការកំពូលបារាំង ១៤ កុម្ភៈ ១៩៨៤។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង* ៖ មាត្រា៨០ ៨២ និង១២២។ មាត្រា ៨០ តម្រូវឲ្យចៅក្រមស៊ើបសួរបើកកិច្ចស៊ើបសួរ ដោយអនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រីឯមាត្រា ៨២ ផ្តល់សិទ្ធិដល់ព្រះរាជអាជ្ញាសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចណាមួយជាក់លាក់ ដែលជាផ្នែកមួយនៃកិច្ចស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយមាត្រា ១២២ ចែងអំពីអំណាចរបស់ចៅក្រមស៊ើបសួរ ក្នុងការចេញដីកាបង្គាប់ឲ្យចាប់ខ្លួន។

# មាត្រា ១៩៨៖ និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឲ្យចាប់ខ្លួន

*ដីកាបង្គាប់ឲ្យចាប់ខ្លួនមាននិទ្ទេសដូចតទៅ៖*

*- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ*
*- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើសនេះ*
*- ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា*

*ដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង។*

## *ការអនុវត្តនៅអ.វ.ត.ក*

ចៅក្រមស៊ើបសួរ មានសេរីភាពដើម្បីកំណត់ចរិកលក្ខណៈនៃអង្គហេតុទាំងឡាយ ដែលខ្លួនយល់ឃើញថាសមស្រប៖ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចទាក់ទងទៅនឹងការកំណត់ចរិកលក្ខណៈនៃអង្គហេតុ ដោយព្រះរាជអាជ្ញាឡើយ ទោះបីជាពួកគេ ត្រូវធ្វើសេចក្ដីសម្រេចអំពីការកំណត់ចរិកលក្ខណៈនោះក៏ឡើយ។

> *រឿងក្តីនួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធិ និងឌុច៖ ដីកាស្តីពីការស្នើសុំធ្វើការបំភ្លឺបញ្ជាក់ អំពីបទទាំងឡាយ អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបសួរ ២០ វិច្ឆិកា ២០០៩ កថាខណ្ឌ១០។*

ការកំណត់ចរិកលក្ខណៈនៃអង្គហេតុស្របច្បាប់មានលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះ៖ ចរិកលក្ខណៈផ្លូវច្បាប់ គឺតែងតែជាចរិកលក្ខណៈបណ្ដោះអាសន្ន ស្ថិតក្នុងដំណាក់កាលស៊ើបសួរ។

> *រឿងក្តី ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធិ និងឌុច៖ ដីកាស្តីពីការស្នើសុំធ្វើការបំភ្លឺបញ្ជាក់អំពីបទទាំងឡាយ អ.វ.ត.ក ការិយាល័យ សហចៅក្រមស៊ើបសួរ ២០ វិច្ឆិកា ២០០៩ កថាខណ្ឌ១០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធានផ្ទៃក្នុង៤៥។ វិធាននេះ ស្រដៀងមែនទែនទៅនឹងមាត្រា ១៩៨ តែខុសគ្នាត្រង់ចែងថា ព័ត៌មានចាំបាច់ទាក់ទងនឹងអត្តសញ្ញាណតាមតែអាចធ្វើបាន ជារួមមានថ្ងៃ ខែ ឆ្នាំ កំណើត អាស័យដ្ឋាន និងព័ត៌មានដទៃទៀតទាក់ទងនឹងការកំណត់អត្តសញ្ញាណ។ វិធានផ្ទៃក្នុង ៤៥ ក៏ត្រូវការចាំបាច់ព័ត៌មានបន្ថែមច្រើនទៀតផងដែរ ដូចជា (១) យោងតាមដីកា និងបទចោទពាក់ព័ន្ធ (២) ទីកន្លែង ពេលវេលា និងកាលបរិច្ឆេទសវនា

ការ តាមករណីសមស្របនិមួយៗ និង (៣) បញ្ជាក់ថា បុគ្គលនោះមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ និងកិច្ចការពារដទៃទៀត។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលប្បញ្ញត្តិអំពីគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការរំលោភបំពាន៖ ការចាប់ខ្លួនដោយគ្មានដីកាចាប់ខ្លួន និងមូលហេតុ៖** សិទ្ធិទទួលបានសេរីភាព និងសន្តិសុខ ត្រូវបានបំពាននៅពេលដែលជនត្រូវចោទត្រូវបានចាប់ខ្លួនដោយបង្ខំ ដោយគ្មានដីកាចាប់ខ្លួន ព្រមទាំងមិនមានការពន្យល់គ្រប់គ្រាន់ អំពីការចាប់ខ្លួននោះ។

*រឿងក្តី MEDJNOUNE ទល់នឹងប្រទេសអាល់-ហ្សេរី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៤ កក្កដា ២០០៦ កថាខណ្ឌ៨.៥។*

**ការរំលោភបំពាន៖ ទោះជាមានមូលដ្ឋានច្បាប់ ការរំលោភបំពានកើតមាន កាលណាមានការចាប់ខ្លួនដោយភ្ជង់កាំភ្លើង និងឃុំខ្លួនដោយមិនបញ្ជាក់ពីហេតុផលនៃការចាប់ខ្លួន៖** ការចាប់ខ្លួន ត្រូវចាត់ទុកថាជាការចាប់ខ្លួនតាមទំនើងចិត្តបាន ទោះបីជាមានមូលដ្ឋានច្បាប់ក្នុងការចាប់ខ្លួនក៏ដោយ កាលណាជនត្រូវចោទមិនត្រូវបានជូនដំណឹងអំពីហេតុផល នៅពេលចាប់ខ្លួន និងការចាប់ខ្លួនមិនចាំបាច់ធ្វើដោយភ្ជង់នឹងកាំភ្លើង ដោយនគរបាល ២០នាក់។

*រឿងក្តី RAFAEL MARQUES DE MORAIS ទល់នឹងប្រទេសអង់ហ្គោឡា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៩ មីនា ២០០៥ កថាខណ្ឌ៦.១។*

**ការរំលោភបំពាន៖ ការចាប់ខ្លួនដោយគ្មានដីកាចាប់ខ្លួន និងឃុំខ្លួនអស់រយៈពេល៧ថ្ងៃ ដោយមិនចោទប្រកាន់៖** ដីកាបង្គាប់ឲ្យចាប់ខ្លួន បានចេញក្រោយការចាប់ខ្លួន និងឃុំខ្លួន៧ថ្ងៃ គឺជាការរំលោភសិទ្ធិ ដោយសារអវត្តមាននៃដីកាបង្គាប់ឲ្យចាប់ខ្លួន ដែលជាលក្ខ័ណ្ឌតម្រូវផ្លូវច្បាប់។ ការពន្យាររយៈពេល៧ថ្ងៃ មុនពេលជនសង្ស័យត្រូវឃុំខ្លួនត្រូវបានចោទ គឺជាការរំលោភសិទ្ធិត្រូវនាំមកចំពោះមុខចៅក្រមភ្លាមៗ បន្ទាប់ពីការចាប់ខ្លួន។

*រឿងក្តី SAFARMO KURBANOVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៦ វិច្ឆិកា ២០០៣ កថាខណ្ឌ៧.២។*

**ការរំលោភបំពាន៖** ការខកខានជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួន និងការឃុំខ្លួន រហូតដល់នាំមក

**ចំពោះមុខចៅក្រម ក្នុងរយៈពេល៨ខែក្រោយមក៖** សិទ្ធិរបស់ជនត្រូវជាប់ចោទ ត្រូវជូនដំណឹងអំពីមូលហេតុនៅពេលចាប់ខ្លួន និងនាំមកចំពោះមុខចៅក្រម កើតមានតែបន្ទាប់ពីរយៈពេល២១៨ថ្ងៃ នៃការជាប់ឃុំ ដោយមិនមានមធ្យោបាយ ឬសិទ្ធិប្រាស្រ័យទាក់ទង។

*រឿងក្តី MEDJNOUNE ទល់នឹងប្រទេសអាល់ហ្សេរី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៤ កក្កដា ២០០៦ កថាខណ្ឌ៨.៦។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា៩.១ និង២ និង១៤ (៣)(ក)។ មាត្រា៩.១ ចែងអំពីសិទ្ធិទូទៅទទួលបានសេរីភាព និងសន្តិសុខបុគ្គល ដោយហេតុថា គ្មានជនណាម្នាក់ ត្រូវបានគេចាប់ ឬឃុំខ្លួនតាមទំនើងចិត្ត ហើយថា ការដកហូតសេរីភាព អាចធ្វើទៅបានលុះត្រាណា មានមូលដ្ឋានចែងដោយច្បាប់ រីឯមាត្រា ៩ (២) ចែងថា ត្រូវជូនដំណឹងដល់បុគ្គលអំពីហេតុផលនៃការចាប់ខ្លួនរបស់គេ និងបទចោទប្រឆាំងនឹងបុគ្គលនោះ។ មាត្រា១៤(៣) (ក) ចែងអំពីសិទ្ធិរបស់បុគ្គល ត្រូវជូនដំណឹងភ្លាមៗអំពីការចោទប្រកាន់ប្រឆាំងនឹងជននោះ។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុប ត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**អង្គហេតុដែលត្រូវផ្តល់យុត្តិកម្ម លើការចាប់ខ្លួនមិនចាំបាច់មានកំរិតដូចគ្នាទៅនឹងកំរិត សម្រាប់ការចោទប្រកាន់ ឬការផ្តន្ទាទោសឡើយ៖** នេះគឺជាដំណាក់កាលបន្ទាប់នៃកិច្ចស៊ើបសួរ។

*រឿងក្តី MURRAY ទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ២៨ តុលា ១៩៩៤ កថាខណ្ឌ៥៥ និង៧៨។*

**ការរំលោភបំពាន៖ ហេតុផលផ្ទាល់មាត់ និងហេតុផលតាមគោលនយោបាយទូលំទូលាយ មិនមានលក្ខណៈពេញលេញឡើយ៖** សិទ្ធិជូនដំណឹងភ្លាមៗអំពីហេតុផល នៃការចាប់ខ្លួន/ឃុំខ្លួន មិនត្រូវបានលើកកម្ពស់ឲ្យបានពេញលេញ ដោយគ្រាន់តែយោងដល់ការប្រកាស អំពីគោលនយោបាយ ឬការផ្តល់ហេតុផលផ្ទាល់មាត់រយៈពេលត្រឹមតែ៧៦ម៉ោង នៃការឃុំខ្លួន បន្ទាប់ពីចាប់ខ្លួន។

*រឿងក្តី SAADI ទល់នឹងប្រទេសអង់គ្លេស តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ២៩ មករា ២០០៨ កថាខណ្ឌ៨៤។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៥ (២)។ មាត្រានេះចែងថា ជនណាដែលត្រូវបានចាប់ខ្លួននឹងត្រូវជូនដំណឹងភ្លាមៗ អំពីហេតុផលនានាសម្រាប់ការចាប់ខ្លួនរបស់គេ និងបទចោទណាមួយប្រឆាំងនឹងរូបគេតាមភាសា ដែលគេអាចយល់បាន។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ចៅក្រមស៊ើបសួរមានអំណាច នៅក្នុងការចេញដីកាចាប់ខ្លួន៖** អំណាចនេះអាចអនុវត្តទៅបាន បន្ទាប់ពីការបញ្ចប់រាល់កិច្ចស៊ើបសួរចាំបាច់ទាំងអស់។

*លេខ83-94762 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៥៨ តុលាការ កំពូលបារាំង ១៤ កុម្ភៈ ១៩៨៤។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា៨០ ៨២ និង១២២។ មាត្រា៨០ តម្រូវឲ្យចៅក្រមស៊ើបសួរបើកកិច្ចស៊ើបសួរ ដោយអនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រីឯមាត្រា៨២ ផ្តល់សិទ្ធិដល់ព្រះរាជអាជ្ញា សុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចណាមួយជាក់លាក់ ដែលជាផ្នែកមួយនៃកិច្ចស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយមាត្រា១២២ ចែងអំពីអំណាចរបស់ចៅក្រមស៊ើបសួរ ក្នុងការចេញដីកាចាប់ខ្លួន។

# មាត្រា ២០៣៖ គោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន

*ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទ អាចត្រូវឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ។*

## ការអនុវត្តនៅអ.វ.ត.ក

**ភាពចាំបាច់ ដើម្បីធ្វើឲ្យមានតុល្យភាពរវាងការឃុំខ្លួន និងសេរីភាព៖** តុលាការត្រូវតែថ្លឹងថ្លែងអំពីមូលហេតុនានានៃការឃុំខ្លួន និងសិទ្ធិទាក់ទងនឹងសេរីភាពរបស់បុគ្គល។ សច្ចធារណ៍នៃសេរីភាព តម្រូវឲ្យការឃុំខ្លួនមានមូលដ្ឋានលើសេចក្ដីសម្រេច តាមផ្លូវតុលាការ ដែលបានសម្រេចចេញ ដោយអនុលោមតាមនីតិវិធី និងលក្ខខណ្ឌផ្សេងៗតាមផ្លូវច្បាប់។

*រឿងក្ដីខៀវ សំផន៖ បណ្ដឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៧ និង៥៦។ រឿងក្ដីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ២២។ រឿងក្ដីនួន ជា៖ សេចក្ដីសម្រេចលើកទី២ ស្ដីពីសម្បទារបស់នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ១៦។ រឿងក្ដីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្ដីសម្រេច របស់អង្គជំនុំជម្រះ តុលាការកំពូល) អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១៣ កថាខណ្ឌ១។ រឿងក្ដីអៀង ធីរិទ្ធ៖ សេចក្ដីសម្រេច លើបណ្ដឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់ របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកនូវលក្ខ័ណ្ឌនៃកិច្ចដំណើរការនីតិវិធី ការដោះលែងដោយគ្មានលក្ខ័ណ្ឌនៃបុគ្គល ពាក់ព័ន្ធ គឺជាមានផលវិបាកណាមួយ ចៀសមិនផុតឡើយ)។ រឿងក្ដីនួន ជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ៦-៧។*

**សច្ចធារណ៍ ជាគុណប្រយោជន៍ដល់ការដោះលែង៖** នេះគឺជាគោលការណ៍ជាសារវ័ន្ត ដែលគ្រប់គ្រងលើការឃុំខ្លួន មុនសវនាការលើអង្គសេចក្ដី។

*រឿងក្ដីខៀវ សំផន៖ បណ្ដឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៥៦។*

**ជនត្រូវចោទអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន តែនៅក្រោយពេលសវនាការតទល់គ្នាប៉ុណ្ណោះ**

៖ បើសិនជាការឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវបានបង្គាប់ បន្ទាប់ពីសវនាការនោះទេ គេត្រូវតែដោះលែងជនត្រូវចោទ។ សវនាការតទល់គ្នា គឺមានបំណងខុសគ្នា ពីសួរចម្លើយជនត្រូវចោទ។ ជាពិសេសសវនាការតទល់គ្នាផ្តល់ ឱកាសឲ្យជនត្រូវចោទ ធ្វើការឆ្លើយតបទៅកាន់ព្រះរាជអាជ្ញា ឯការសួរចម្លើយត្រូវបានធ្វើឡើង ក្នុងគោលបំណងដើម្បីស្វែងរកការពិត និងទទួលបានកំណត់ហេតុសួរចម្លើយពីជនត្រូវចោទ ដែលអាចប្រើប្រឆាំងនឹងខ្លួនគាត់។

*រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ១៣ ១៧ និង៣២។*

កាលណាជនជាប់ចោទ ត្រូវបានរកឃើញថាមិនមានសម្បទា ក្នុងការចូលរួមសវនាការទេ គោលការណ៍ នៃការសន្មត់ជាមុនអំពីសេរីភាពតម្រូវថា ជននោះត្រូវដោះលែង ពីការឃុំឃាំង ការឃុំខ្លួនបន្ត ឬការឃុំខ្លួនដោយបង្ខំក្នុងកាលៈទេសៈផ្សេងៗ ក្នុងករណីមិនច្បាស់លាស់ ថាតើការជំនុំជម្រះក្តី នឹងត្រូវកោះហៅ ឬអត់នោះ គឺជាការរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសេរីភាព។ កាលណាបណ្តឹង មិនត្រូវបានរលត់នៅឡើយក្រោមមាត្រា៧ នៃក្រមនេះ ជនជាប់ចោទ អាចត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលដែលជននោះមានសម្បទា ក្នុងការចូលរួមសវនាការ ឬបណ្តឹងត្រូវបានផុតរលត់ ដោយអនុលោមតាម ច្បាប់។

*រឿងក្តីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ៨០។ រឿងក្តីអៀង ធីរិទ្ធ៖ សម្បទា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ២២។ រឿងក្តីអៀង ធីរិទ្ធ៖ សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះ សាលាដំបូងឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២១-២៦ ( ដោយកត់សំគាល់ថា ការរក្សាទុកនូវលក្ខ័ណ្ឌ នៃកិច្ចដំណើរការនីតិវិធី ការដោះលែងដោយគ្មានលក្ខ័ណ្ឌនៃបុគ្គលពាក់ព័ន្ធនានា គឺថាមានផលវិបាកណាមួយចៀសមិនផុតឡើយ)។ រឿងក្តីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (សេចក្តីសម្រេច លើសំណើរបស់សហព្រះរាជអាជ្ញាឲ្យរក្សាទុកជនជាប់ចោទ ប្រឆាំងនឹងដីកាបង្គាប់ ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ) អ.ជ.ត.ក ១៧ កញ្ញា ២០១២ កថាខណ្ឌ៧-៨។ រឿងក្តីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេច*

*ក្តីរបស់អង្គជំនុំជម្រះ តុលាការកំពូល) អ.ជ.ស.ជ ២៦ មនា ឆ្នាំ២០១៣ កថាខណ្ឌ១។ រឿងក្តីអៀង ធីរិទ្ធ៖ ការស្នើសុំនៃមេធាវីការពារក្តីឲ្យធ្វើការបញ្ជាក់ អំពីការអនុវត្តសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខ័ណ្ឌ អ.វ.ត.ក អ.ជ.ស.ជ ២៧ មិថុនា ២០១៣។ រឿងក្តីអៀង ធីរិទ្ធ៖ សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់ អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខ័ណ្ឌ អ.វ.ត.ក អ.ជ.ត.ក ១៤ ធ្នូ ២០១២ កថាខណ្ឌ៣៧-៣៩។ រឿក្តីនួន ជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខ័ណ្ឌ៦.១ រឿងក្តីអៀង ធីរិទ្ធ៖ ការស្នើសុំនៃមេធាវីការពារក្តីឲ្យធ្វើការបញ្ជាក់ អំពីការអនុវត្តនូវសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងទៅនឹងដីកាបង្គាប់ របស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខ័ណ្ឌ អ.វ.ត.ក អ.ជ.ស.ជ ២៧ មិថុនា ២០១៣។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** ពុំមានវិធានណាមួយនៃវិធានផ្ទៃក្នុងដែលត្រូវគ្នាយ៉ាងជាក់លាក់ទៅនឹងមាត្រា២០៣នេះទេ ទោះបីជាវិធាន៦៣(៣) រៀបរាប់អំពីមូលហេតុស្រដៀងគ្នាជាច្រើន ដែលគេអាចបង្គាប់ឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ដូចមាត្រា២០៥ ក៏ដោយ។

## ***ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត***

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជាគឺជាភាគី នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបញ្ញត្តិអំពីគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយ នៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការឃុំខ្លួនមុនសវនាការ គឺជាករណីលើកលែង៖** ការឃុំខ្លួនមុនសវនាការ លើអង្គសេចក្តីគឺជាករណីលើកលែង ដែលត្រូវធ្វើក្នុងរយៈពេលខ្លី តាមដែលអាចធ្វើទៅបាន។

*រឿងក្តី CAGAS BUTIN និង ASTILLERO ទល់នឹងប្រទេសហ្វីលីពីន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៤ កថាខណ្ឌ៧.៤។*

**ដើម្បីធ្វើយុត្តិកម្មលើការឃុំខ្លួន គេត្រូវតែបង្ហាញពីកង្វល់ ដែលគេមិនអាចដោះស្រាយបាន តាមរយៈការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ /លក្ខខ័ណ្ឌ នានានៃការដោះលែង៖** ដើម្បីធ្វើយុត្តិកម្មទៅលើការឃុំខ្លួនមុនសវនាការ រដ្ឋត្រូវពិពណ៌នាឲ្យបានពិស្តារ អំពីកង្វល់នានា ដែលធ្វើយុត្តិកម្មលើការបន្តការឃុំខ្លួន និងអំពីមូលហេតុដែលកង្វល់ទាំងនេះ មិនអាចដោះស្រាយបានតាមរយៈការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬតាមរយៈការដោះលែងតាមលក្ខខ័ណ្ឌដ៏តឹងរ៉ឹងផ្សេងៗទៀត។ ពាក់ព័ន្ធនឹងយុត្តិកម្ម លើការដោះលែងមុនសវនាការ ជារួមមានការដាក់ឥទ្ធិពលលើសាក្សី ការក្លែងភស្តុតាង និងការរត់គេចពីដែនសមត្ថកិច្ច។

*រឿងក្តី SMANSTER ទល់នឹងប្រទេសបេលឡារុស គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៨ កថាខណ្ឌ១០.៣។*

**ការឃុំខ្លួន អាចស្របច្បាប់បានលុះត្រាតែច្បាប់មានចែងពីការឃាត់ខ្លួន ចំពោះបទល្មើសដែលបានចោទប្រកាន់ប៉ុណ្ណោះ៖** ជនត្រូវចោទ អាចមិនត្រូវបានឃុំខ្លួនឡើយ បើសិនជាបទល្មើសដែលគេជឿថាបានប្រព្រឹត្តនោះ គឺជាបទល្មើសមួយ ដែលច្បាប់របស់រដ្ឋ មិនបានចែងឲ្យមានការឃាត់ខ្លួននោះ។

*រឿងក្តី LATIFULIN ទល់នឹងប្រទេសគៀកជីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១០ មីនា ២០១០ កថាខណ្ឌ៨.២។*

**យុត្តិកម្មចាំបាច់ សម្រាប់ការពន្យារការឃុំខ្លួន៖** ការឃុំខ្លួន រួមទាំងការឃាត់ខ្លួនក្នុងផ្ទះផងដែរ អាចត្រូវបានចាត់ទុកថា ធ្វើឡើងតាមទំនើងចិត្ត បើរដ្ឋនោះមិនអាចផ្តល់នូវទឡ្ហីករណ៍ឲ្យបានជាក់លាក់ ទៅតាមករណីនីមួយៗ ដើម្បីជាយុត្តិកម្មនៃការបន្តការឃុំខ្លួនទេនោះ។

*រឿងក្តី KWOK ទល់នឹងប្រទេសអូស្ត្រាលី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៩ កថាខណ្ឌ៩.៣។ រឿងក្តី ABBASSI ទល់នឹងប្រទេសអាល់ហ្សេរី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៨ មីនា ២០០៧ កថាខណ្ឌ៨.៤ (ការឃាត់ខ្លួនក្នុងគេហដ្ឋាន)។*

**ការបញ្ជូនត្រឡប់មកឃុំខ្លួនវិញ ត្រូវតែស្របច្បាប់ សមហេតុផល និងចាំបាច់៖** សិទ្ធិក្នុងការមានសេរីភាព តម្រូវឲ្យកាលៈទេសៈនៃការឃុំខ្លួនបុគ្គលត្រូវតែស្របច្បាប់ សមហេតុផល និងចាំបាច់នៅគ្រប់កាលៈទេសៈ ដូចជា ដើម្បីទប់ស្កាត់ការរត់គេចខ្លួន ការជ្រៀតជ្រែកលើភស្តុតាង ឬការកើតឡើងវិញនៃបទឧក្រិដ្ឋ។

*រឿងក្តី KULOV ទល់នឹងប្រទេសគៀកជីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៦ កក្កដា ២០១០ កថាខណ្ឌ៨.៣។*

**ជនជាប់ចោទ ត្រូវតែទទួលបានការជំនុំជម្រះក្តីឲ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន គេតម្រូវឲ្យមានមូលហេតុដែលគួរឲ្យជឿបំផុត ចំពោះការ**

**ពន្យារលើសនីតិវិធី នៅមុនពេលសវនាការ៖** ខណៈដែលជនត្រូវចោទ ត្រូវបានបដិសេធមិនឲ្យមានការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយមកពីភាពធ្ងន់ធ្ងរនៃបទល្មើស និងដោយសារអវត្តមាននៃមូលហេតុ ដែលគួរឲ្យជឿបំផុត បើពុំនោះទេ គេត្រូវតែធ្វើការកាត់សេចក្តីទៅលើជននោះឲ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន។ មូលហេតុដែលគួរឲ្យជឿបំផុត ចំពោះការពន្យារពេលដ៏យូរ ឧទាហរណ៍ ប្រមាណជា ៦ ឆ្នាំ។

*រឿងក្តី MEDJNOUNE ទល់នឹងប្រទេសអាល់ហ្សេរី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១២ កក្កដា ២០០៦ កថាខណ្ឌ៨.៩។*

**ការឃុំខ្លួនលើសនីតិវិធី រំលោភគោលការណ៍សច្ចធារណ៍នៃនិរទោស៖** ក្នុងករណីនៃការបដិសេធមិនឲ្យដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ មិនមែនជាការប៉ះពាល់ដំបូង ទៅលើគោលការណ៍សច្ចធារណ៍នៃនិរទោសនោះទេ ការឃុំខ្លួនលើសនីតិវិធី នៅមុនសវនាការលើអង្គសេចក្តី ជាឧទាហរណ៍ លើសពី៩ឆ្នាំ គឺជាការរំលោភទៅលើសិទ្ធិនេះ។

*រឿងក្តី CAGAS, BUTIN និង ASTILLEROV ទល់នឹងប្រទេសហ្វីលីពីន គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប ២៣ តុលា ២០០៤ កថាខណ្ឌ៧.៣។*

**ការឃុំខ្លួនលើសនីតិវិធី គឺជាការរំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌៖** ការឃុំខ្លួនដោយពុំបានធ្វើយុត្តិកម្ម នៅមុនសវនាការលើអង្គសេចក្តី លើសនីតិវិធីរយៈពេលប្រាំបួនឆ្នាំ គឺប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើភាពត្រឹមត្រូវនៃដំណើរការជំនុំជម្រះក្តី និងការពន្យារពេលដែលមិនសមហេតុផល។

*រឿងក្តី CAGAS, BUTIN និង ASTILLEROV ទល់នឹងប្រទេសហ្វីលីពីន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៤ កថាខណ្ឌ៧.៤។*

**ការឃុំខ្លួនដប់ប្រាំបីខែ ចាប់ពីពេលចាប់ខ្លួនរហូតដល់ពេលធ្វើសវនាការ ពុំមែនជាការពន្យារពេលដ៏ហួសហេតុមិនចាំបាច់ទេ៖** លើកលែងតែមានភស្តុតាងបង្ហាញថា កិច្ចស៊ើបសួរ អាចត្រូវបានបញ្ចប់ នៅមុនពេលសវនាការនោះឲ្យបានឆាប់ជាងនេះ ឬលើកលែង តែជនត្រូវចោទប្តឹង ពីការពន្យារពេលនេះទៅអាជ្ញាធរមានសមត្ថកិច្ច រយៈពេលមួយឆ្នាំកន្លះ ចាប់ពីពេលចាប់ខ្លួន ដល់ពេលសវនាការជំនុំជម្រះ មិនមែនជាការពន្យារពេលហួសហេតុទេ។

*រឿងក្តី KELLY ទល់នឹងប្រទេសចាម៉ៃកា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៨ មេសា ១៩៩១ កថាខណ្ឌ៥.១១។*

**ការប្រមូលភស្តុតាង ជាយុត្តិកម្មមិនគ្រប់គ្រាន់សម្រាប់ការឃុំខ្លួនដែលពន្យារពេល៖** ដោយសារតែកត្តាកំណត់ពេលវេលាសមហេតុផល សម្រាប់ការឃុំខ្លួន ត្រូវបានកំណត់ដោយផ្អែកទៅលើកាលៈទេសៈនៃករណីនីមួយៗ ការពិចារណាទៅលើការប្រមូលភស្តុតាង មិនបានផ្តល់ជាយុត្តិកម្មសម្រាប់ការឃុំខ្លួនដែលត្រូវបានពន្យារពេល ឧទាហរណ៍ រយៈពេលបួនឆ្នាំ។

*រឿងក្តី FILLASTRE ទល់នឹងប្រទេសបូលីវី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៥ វិច្ឆិកា ១៩៩១ កថាខណ្ឌ៦.៥។*

**ការខ្វះខាតធនធាន ជាយុត្តិកម្មមិនគ្រប់គ្រាន់សម្រាប់ការពន្យារពេលដែលមិនសមហេតុផល៖** ការខ្វះខាតមិនមានថវិកាបំរុងទុកឲ្យបានគ្រប់គ្រាន់ សម្រាប់ការគ្រប់គ្រងលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ មិនអាចធ្វើយុត្តិកម្មឲ្យបានសមហេតុសមផល លើការពន្យារពេល ក្នុងការនាំខ្លួនជនជាប់ចោទទៅជំនុំជម្រះក្តីបានទេ។

*រឿងក្តី FILLASTRE ទល់នឹងប្រទេសបូលីវី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៥ វិច្ឆិកា ១៩៩១ កថាខណ្ឌ៦.៥។*

**កិច្ចដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរ គឺជាយុត្តិកម្មមិនគ្រប់គ្រាន់ សម្រាប់ការពន្យារពេល ដែលមិនសមហេតុផល៖** អង្គហេតុដែលថា ការស៊ើបអង្កេតខាងព្រហ្មទណ្ឌបានដំណើរការទៅតាមកិច្ចដំណើរការនីតិវិធី ជាលាយលក្ខណ៍អក្សរ មិនធ្វើយុត្តិកម្មឲ្យបានសមហេតុផល លើការពន្យារពេលក្នុងការនាំខ្លួនជនជាប់ចោទ ទៅជំនុំជម្រះក្តីបាននោះទេ។

*រឿងក្តី FILLASTRE ទល់នឹងប្រទេសបូលីវី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៥ វិច្ឆិកា ១៩៩១ កថាខណ្ឌ៦.៥។*

**ការរំលោភបំពាន៖ ការឃុំខ្លួនណា ដែលពន្យារពេលបន្ទាប់ពីមានដីកាបង្គាប់ឲ្យដោះលែង៖** កាពន្យារពេលឃុំខ្លួនបុគ្គល អស់រយៈពេលមួយឆ្នាំ បន្ទាប់ពីមានការចេញដីកាបង្គាប់ឲ្យដោះលែង រួមទាំងដីកាបង្គាប់ឲ្យដោះលែងមានលក្ខខ័ណ្ឌ បង្កើតបានជាការឃុំខ្លួនដោយខុសច្បាប់។

*រឿងក្តី TERÁN JUĆN និងTERÁN JUĆN ទល់នឹងប្រទេសអេក្វាឌ័រ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៦ មីនា ១៩៩២ កថាខណ្ឌ៦.៣។ ប្រទេសអ៊ុយរូហ្គាយ គណៈកម្មាធិការ សិទ្ធិមនុស្ស អ.ស.ប ១៥ សីហា ១៩៧៩ កថាខណ្ឌ២ និង១០(ឈ) (ដីកាបង្គាប់ឲ្យដោះលែងមានលក្ខខ័ណ្ឌ)។*

**ការឃាត់ខ្លួនក្នុងផ្ទះ តម្រូវឲ្យមាននីតិវិធី និងមូលដ្ឋានស្របច្បាប់៖** ការឃាត់ខ្លួនក្នុងផ្ទះ គឺជាការដកហូតសេរីភាព ដែលត្រូវតែមានមូលដ្ឋានច្បាប់ និងត្រូវតែបានអនុវត្ត ដោយអនុលោមតាមនីតិវិធី ដែលបានបង្កើតឡើងតាមច្បាប់។

*រឿងក្តី YKLYMOVA ទល់នឹងប្រទេសទួគមេនីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ កក្កដា ២០០៩ កថាខណ្ឌ៧.២។*

**ការឃាត់ខ្លួនក្នុងផ្ទះ ដែលមិនបានផ្អែកទៅលើមូលដ្ឋានច្បាប់ គឺជាការដកហូតសេរីភាព៖** ការដាក់បុគ្គលឲ្យស្ថិតនៅក្រោមការឃាត់ខ្លួន ក្នុងគេហដ្ឋានដោយគ្មានផ្តល់ការជូនដំណឹង ជាលាយលក្ខណ៍អក្សរអំពីមូលហេតុស្របច្បាប់ នៃការឃាត់ខ្លួនបែបដូច្នោះទេ គឺជាការបង្កើតបានការឃុំខ្លួនតាមទំនើងចិត្ត និងជាការដកហូតសិទ្ធិសេរីភាព របស់បុគ្គល។

*រឿងក្តី ABBASSI ទល់នឹងប្រទេសអាល់ហ្សេរី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៨ មីនា ២០០៧ កថាខណ្ឌ៨.២-៨.៣។*

**យុត្តិកម្មគ្រប់គ្រាន់សម្រាប់ការឃុំខ្លួនមុនពេល នៃការជំនុំជម្រះក្តី រួមមានការរត់គេចខ្លួនពីពេលមុនៗ ចេញពីប្រទេស ការបញ្ជូនត្រឡប់មកវិញ តាមរយៈបត្យាប័ន៖** កាលៈទេសៈ ដែលធ្វើយុត្តិកម្មដល់ការឃុំខ្លួន មុនសវនាការលើអង្គសេចក្តី រួមមានអង្គហេតុដែលជនជាប់ចោទរត់គេចទៅក្រៅប្រទេស និងបញ្ជូនត្រឡប់មកវិញតែ តាមរយៈនីតិវិធីបត្យាប័នប៉ុណ្ណោះ តែមិនស្ម័គ្រចិត្តទេ។

*រឿងក្តី BASSO ទល់នឹងប្រទេសអ៊ុយរុយហ្គាយ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៩ តុលា ២០១០ កថាខណ្ឌ១០.២។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា ៩.១ ៩.៣ ៩.៤ ១៤.២ និង ១៤.៣(គ)។ ដោយឡែកមាត្រា៩.៣ ចែងថា មិនត្រូវឲ្យមានបទបញ្ញាជាទូទៅណាមួយថា ជនដែលនៅរង់ចាំការជំនុំជម្រះទោសត្រូវបានឃុំខ្លួនឡើយ។ បទប្បញ្ញត្តិដទៃទៀតនៅក្នុងមាត្រា ៩ ប្រឹងប្រែងឲ្យមានការធានាផ្សេងៗទាក់ទងទៅនឹងការឃុំខ្លួន ខណៈមាត្រា ១៤.២ បង្កើតបានជាគោលការណ៍សច្ចធារណ៍នៃនិរទោស និងមាត្រា ១៤.៣ (គ) ការពារនូវសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តី ដោយពុំមានការពន្យារពេលមិនត្រឹមត្រូវ។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ចំណងទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ៖** ការដកហូតសេរីភាព ត្រូវបានអនុញ្ញាត លុះត្រាតែមានទំនាក់ទំនង ទៅនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប៉ុណ្ណោះ។

*រឿងក្តី CIULLA ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២២ កុម្ភៈ ១៩៨៩ កថាខណ្ឌ៣៨។*

**ការដកហូតសេរីភាព ត្រូវតែអាចកែប្រែបានចំពោះការពិនិត្យពិច័យតាមផ្លូវតុលាការ ដោយឯករាជ្យ៖** ដើម្បីការពារបុគ្គល ពីការដកហូតសេរីភាពតាមទំនើងចិត្ត ទង្វើនៃការដកហូតសេរីភាព គឺជាកម្មវត្ថុនៃការពិនិត្យពិច័យតាមផ្លូវតុលាការដោយឯករាជ្យ ហើយអាជ្ញាធរត្រូវទទួលខុសត្រូវ ចំពោះសកម្មភាពទាំងនោះ។

*រឿងក្តី KURT ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៥ ឧសភា ១៩៩៨ កថាខណ្ឌ ១២៣។*

**មូលដ្ឋានពាក់ព័ន្ធ និងគ្រប់គ្រាន់ ជាលក្ខខ័ណ្ឌតម្រូវសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលវែង៖** ការសង្ស័យសមហេតុផល អំពីការប្រព្រឹត្តបទល្មើសណាមួយ គឺជាលក្ខខ័ណ្ឌចាំបាច់ (Sine qua non) មួយ សម្រាប់បន្តធ្វើការឃុំខ្លួនដែលមានសុពលភាព ប៉ុន្តែបន្ទាប់ពីមួយរយៈពេល អាចថា វានឹងមិនគ្រប់គ្រាន់ទេ។ បន្ទាប់មក តុលាការត្រូវកំណត់ថា តើទឡ្ហីករណ៍ដទៃទៀត ដែលបានផ្តល់ដោយអាជ្ញាធរនោះ ជាយុត្តិកម្មលើការបន្តដកហូតសេរីភាពដែរឬទេ។ បើសិនជាមូលដ្ឋាន ដែលបានផ្តល់ដោយអាជ្ញាធរ ហាក់ដូចជាពាក់ព័ន្ធ និងគ្រប់គ្រាន់ តុលាការ ក៏ត្រូវកំណត់ថាតើ អាជ្ញាធរបានបង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់ពិសេសដែរឬទេ ដែលការណ៍នេះ រួមមានទាំងការពិចារណា អំពីភាពស្មុគស្មាញ និងចរិតលក្ខណៈពិសេសនៃកិច្ចស៊ើបសួរ។ ភាពធ្ងន់ធ្ងរនៃបទចោទ ប្រតិកម្មជាសារធារណ ចំពោះបទចោទទាំងនេះ និងភាពធ្ងន់ធ្ងរ នៃការកាត់ទោស អាចត្រូវបានពិចារណា ក្នុងការសម្រេចឃុំខ្លួនជនជាប់ចោទ ប៉ុន្តែ មូលហេតុទាំងអស់នេះ មិនអាចផ្តល់យុត្តិកម្មដោយផ្ទាល់សម្រាប់ការឃុំខ្លួនរយៈពេលយូរបានទេ ។

*រឿងក្តី TOMASI ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ សីហា ១៩៩២ កថាខណ្ឌ៨៤។ រឿងក្តី SULAOJA ទល់នឹងប្រទេសអេស្តូនី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៥ កុម្ភៈ ២០០៥ កថាខណ្ឌ៦២។ រឿងក្តីLETELLIER ទល់ទៅនឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មិថុនា ១៩៩១ កថាខណ្ឌ៣៥។ រឿងក្តី KHUDOROYOV ទល់នឹងប្រទេសរុស៊ី តុលាការសិទ្ធិមនុស្សអឺរ៉ុប ៨ វិច្ឆិកា ២០០៥ កថាខណ្ឌ ១៨០។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖ មាត្រា៥។ មាត្រានេះចែងអំពីសិទ្ធិក្នុងការមានសេរីភាព និងសន្តិសុខ រួមទាំងសិទ្ធិក្នុងពេលត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយស្របច្បាប់ផង។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**កាលៈទេសៈថ្មីៗ នៅក្នុងរឿងក្តីអាចធ្វើជាយុត្តិកម្មបានទៅលើការឃុំខ្លួនបណ្តោះអាសន្ន៖** ជនត្រូវចោទដែលបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចត្រូវបានយកទៅឃុំខ្លួនជាបណ្តោះអាសន្នបាន ចំពោះអង្គហេតុតែមួយដូចគ្នា និងក្នុងករណីនៃកាលៈទេសៈថ្មីៗ។

*លេខ 04-87392 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១ មីនា ២០០៥។ លេខ 07-87802 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២១ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ២៩ មករា ២០០៨។*

**សេចក្តីសម្រេចមិនធ្វើការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ៖** សេចក្តីសម្រេចបែបនេះ គឺធ្វើឡើងតាមឆន្ទានុសិទ្ធិ។

*លេខ 90-85415 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៦៤ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ៣០ តុលា ១៩៩០។*

**មូលហេតុនានា ក្នុងការធ្វើសេចក្តីសម្រេចឃុំខ្លួនជនត្រូវចោទ៖** មូលហេតុទាំងនេះ ត្រូវពន្យល់ថា តើហេតុអ្វីបានជាការត្រួតពិនិត្យតាមផ្លូវតុលាការនៅមិនទាន់គ្រប់គ្រាន់។

*លេខ 97-82539 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១៦ កក្កដា ១៩៩៧ លេខ95-82561 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៦៤ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ៨ សីហា ១៩៩៥។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖ មាត្រា ១៣៧។ មាត្រានេះ ចែងអំពីការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី ក្នុងអំឡុងពេលស៊ើបអង្កេត ដោយរួមទាំងការបញ្ជូនត្រឡប់ទៅឲ្យឃាត់ខ្លួន ដែលជាវិធានការប្រុងប្រយ័ត្នមួយផង។

# មាត្រា ២០៥៖ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

*ការឃុំខ្លួនបណ្ដោះអាសន្ន អាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះ ជាការចាំបាច់៖*
*១- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី*
*២- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត*
*៣- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ*
*៤- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី*
*៥- ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ*
*៦- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស*

## ការអនុវត្តនៅអ.វ.ត.ក

**ភាពចាំបាច់ ដើម្បីធ្វើឲ្យមានតុល្យភាពរវាងការឃុំខ្លួន និងសេរីភាព៖** តុលាការ ត្រូវតែថ្លឹងថ្លែងពីមូលហេតុនៃការឃុំខ្លួន និងសិទ្ធិទាក់ទងនឹងសេរីភាពរបស់បុគ្គល។ សច្ចធារណ៍នៃសេរីភាព តម្រូវឲ្យការឃុំខ្លួនមានមូលដ្ឋាន លើសេចក្តីសម្រេចតាមផ្លូវតុលាការ ដែលបានចេញដោយអនុលោមតាមនីតិវិធីនិងលក្ខខណ្ឌផ្សេងៗតាមផ្លូវច្បាប់។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៧ និង៥៦។ រឿងក្តី អៀង សារី៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ២២។ រឿងក្តី នួន ជា៖ សេចក្តីសម្រេច លើកទី២ ស្តីពីសម្បទារបស់នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ ១៦។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល) អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១៣ កថាខណ្ឌ ១។ រឿងក្តី អៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទនៅក្នុងការឃុំឃាំង ដោយមានលក្ខខ័ណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធី និងការ*

*ដោះលែង ដោយគ្មានលក្ខខណ្ឌ គឺចៀសមិនផុតពីផលវិបាកឡើយ)។*

**ជនត្រូវចោទត្រូវបានឃុំខ្លួន ខណៈដែលមានការបង្ហាញខ្លួនដំបូង៖** ជនត្រូវចោទ ដែលត្រូវបានឃុំនៅក្នុងមន្ទីរឃុំខ្លួន ខណៈដែលមានការបង្ហាញខ្លួនដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំងបន្តទៀត រហូតដល់អង្គជំនុំជម្រះចេញសាលក្រមឲ្យតែការឃុំខ្លួននោះ មានមូលដ្ឋានស្របច្បាប់ពីអាជ្ញាធរតុលាការ។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៧-៤៩។*

**លក្ខខណ្ឌនៃការឃុំខ្លួន សន្មតថាត្រឹមត្រូវ កាលណាពុំមានសំណើសុំឲ្យដោះលែង៖** កាលណាជនត្រូវចោទ មិនបានដាក់សំណើសុំដើម្បីឲ្យដោះលែង នៅពេលមានការបង្ហាញខ្លួនដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ អង្គជំនុំជម្រះនោះ មានអំណាចនៅក្នុងការសន្មតថា លក្ខខណ្ឌតាមផ្លូវច្បាប់ សម្រាប់ធ្វើការឃុំខ្លួននោះ នៅតែមានលក្ខណៈត្រឹមត្រូវដដែល។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៩។*

**ការជ្រៀតជ្រែកលើសាក្សី ការបំផ្លាញភស្តុតាង ដែលគាំទ្រ ទៅដល់ការឃុំខ្លួនបណ្តោះអាសន្ន៖** សេចក្តីថ្លែងការណ៍ និងសកម្មភាពសាធារណៈ ដែលធ្វើឡើង ដោយជនត្រូវចោទ ដែលនាំឲ្យមានការជ្រៀតជ្រែកលើសាក្សី ឬការបំផ្លាញភស្តុតាង (ឧទាហរណ៍៖ ការបង្ហាញពីអរិភាពការលើកឡើងពីការសងសឹក) គាំទ្រដល់ការឃុំខ្លួនបណ្តោះអាសន្ន។

*រឿងក្តីអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ៤៣-៥២។*

**ការឃុំខ្លួន អាចជាការចាំបាច់ ដើម្បីការពារសាក្សី ទោះជាក្រោយពេលបង្ហាញសំណុំរឿងហើយក៏ដោយ៖** ការជ្រៀតជ្រែកជាសក្តានុពលលើសាក្សី មិនបានបញ្ចប់ទេ នៅពេលបានបង្ហាញសំណុំរឿងដល់ជនត្រូវចោទ។ ការឃុំខ្លួនជាបណ្តោះអាសន្ន អាចនៅតែជាការចាំបាច់ ដើម្បីការពារនូវការយាយីដល់សាក្សី ពីព្រោះថាគេអាចឲ្យសាក្សីផ្តល់សក្ខីកម្ម នៅក្នុងការស៊ើបសួរ ឬក្នុងសវនាការនាពេលក្រោយទៀត បើមិនដូច្នេះទេ សាក្សីនោះអាចនឹងស្ថិតនៅក្រោមការភ័យខ្លាច ឬការគាបសង្កត់។

*រឿងក្តីឌុច៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ៣៥-៣៦ (មានការចូលបង្ហាញខ្លួន ទោះជា បានផ្តល់សក្ខីកម្មពីមុនក៏ដោយ បើដូច្នេះ នៅតែស្ថិតនៅក្រោមការគំរាមកំហែង)។ រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក*

*អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ៦០-៦៤ (សេចក្ដីថ្លែងពីមុនៗ បានបញ្ជាក់ថា អាចនឹងមានការសម្លុតគំរាមសាក្សី)។*

**ត្រូវមានការយល់ឃើញ អំពីបរិបទនៃការការពារសាក្សី៖** ការការពារសាក្សី ជាពិសេសទាក់ទងទៅនឹងការភ័យខ្លាច ក្នុងការផ្ដល់សក្ខីកម្ម ត្រូវតែមើលឃើញ នៅក្នុងបរិបទសង្គមកម្ពុជា។ វិធានការការពារសាក្សី នៅប្រទេសកម្ពុជាអាចនឹងនៅមានកម្រិត ហើយមានភាពងាយស្រួលក្នុងការរកអាវុធ។ ដូច្នេះ ការដោះលែងជនត្រូវចោទពីការឃុំខ្លួនបណ្ដោះអាសន្ន អាចធ្វើឲ្យសាក្សីមានការភ័យខ្លាច ចំពោះការសងសឹក ឬការគាបសង្កត់ ពីសំណាក់ជនត្រូវចោទ ឬពីគ្រួសាររបស់គាត់ ហើយក៏អាចនឹងរារាំងដល់ការផ្ដល់សក្ខីកម្មផងដែរ។

*រឿងក្ដីឌុចៈ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ៣៣។*

**សេរីភាព អាចនឹងមិនអាចទទួលយកបាននោះទេ កាលណាជនត្រូវចោទ កាន់កាប់មុខតំណែងខ្ពស់៖** វត្តមានរបស់ជនត្រូវចោទ នៅក្នុងសង្គម អាចនឹងមិនអាចទទួលយកបានទេ កាលណាគាត់កាន់កាប់មុខតំណែងខ្ពស់ណាមួយ នៅក្នុងចលនានយោបាយ ហើយនៅបន្តមានឥទ្ធិពលទៅលើសង្គម សូម្បីតែលែងកាន់កាប់មុខតំណែងបែបនោះក៏ដោយ។ វត្តមានរបស់ជនត្រូវចោទ អាចនឹងបង្កើតឲ្យមានការភ័យខ្លាច ដែលធ្វើឲ្យសាក្សីមិនមានបំណងដើម្បីផ្ដល់សក្ខីកម្ម។

*រឿងក្ដីនួន ជាៈ បណ្ដឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ៦២។ រឿងក្ដីអៀង ធីរិទ្ធៈ បណ្ដឹងឧទ្ធរណ៍ លើការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ ៤៥។ រឿងក្ដីអៀង សារីៈ បណ្ដឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ១៧ តុលា ២០០៨ កថាខណ្ឌ៩៧ (មុខតំណែងដែលមានអំណាច មានឥទ្ធិពលមិនឈប់ឈរ បន្ទាប់ពីមុខតំណែងនោះចប់ក៏ដោយ)។ រឿងក្ដី ឌុចៈ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ៣១-៣៤ (វត្តមាននៅក្នុងសង្គម អាចនឹងដាក់សម្ពាធ ទៅលើសាក្សី ប្រវត្តិនៃការគំរាមកំហែង សម្រាប់សាក្សីមានសក្ដានុពល)។*

**ការឃុំខ្លួនបណ្ដោះអាសន្ន មានមូលដ្ឋានគ្រប់គ្រាន់ កាលណាមានហានិភ័យ ដែលថា ជនត្រូវចោទមិនអាចមកបង្ហាញខ្លួនបាន នៅពេលមានសវនាការ៖** ការឃុំខ្លួនជាបណ្ដោះអាសន្ន មានមូលដ្ឋានគ្រប់គ្រាន់ កាលណាមានកំណត់ត្រាបង្ហាញថា ជនត្រូវចោទបានក្លាយទៅជាហានិភ័យ ក្នុងការមិនអាចមកបង្ហាញខ្លួនបាន ពេលសវនាការ និងបានរារាំងដល់កិច្ចដំណើរការនីតិវិធីឆាប់រហ័ស (ដោយការលាក់ខ្លួនដោយការមិនធ្វើតាមដីកាកោះ ឬដោយត្រូវបានរារាំង

ជាបណ្តោះអាសន្ន មិនឲ្យចូលរួមបានក្នុងសវនាការ)។ អង្គជំនុំជម្រះសាលាដំបូង ត្រូវតែធ្វើការវាយតម្លៃលើវិសាលភាព ដែលហានិភ័យអាចនឹងត្រូវបានកាត់បន្ថយ ដោយវិធានការមិនឃុំខ្លួន តាមរយៈនៃការពិនិត្យយ៉ាងត្រឹមត្រូវ ទៅលើកត្តាពាក់ព័ន្ធទាំងអស់ និងអង្គហេតុនានា ដែលបានដាក់បង្ហាញនៅក្នុងការជជែកតទល់គ្នា។

*រឿងក្តីខៀវ សំផនៈ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៥៤។*

**តុល្យភាពរវាងលក្ខខ័ណ្ឌ នៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលបានស្នើដោយជនត្រូវចោទ និងមូលហេតុនានានៃការឃុំខ្លួនៈ** ការឃុំខ្លួនបណ្តោះអាសន្ន អាចជាការចាំបាច់ កាលណាលក្ខខ័ណ្ឌនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការស្នើដោយជនត្រូវចោទ ត្រូវបានលុបលើដោយភាពចាំបាច់ក្នុងការឃុំខ្លួនគាត់។

*រឿងក្តីអៀង ធីរិទ្ធៈ បណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ៧៤។ រឿងក្តី ឌុចៈ បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ៥៩។*

**កត្តាផ្សេងៗ ដែលបង្ហាញថា ជនត្រូវចោទ អាចនឹងរត់គេចៈ** កត្តាទាំងនោះរួមមាន វិធានការដែលកំពុងតែបំពេញមុខងារ ដើម្បីបិទបាំងអតីតភាពរបស់ខ្លួន ការប្រើប្រាស់ឈ្មោះក្លែង ការប្តូរការងារ ឬប្តូរទីកន្លែងជាច្រើនដង ការផ្តល់ព័ត៌មានមិនពិត ការបាត់ខ្លួនពីមុនៗ ការរស់នៅក្នុងតំបន់មួយ ដែលមានអ្នកគាំទ្រច្រើន និងមានការទាក់ទង ជាសក្តានុពល ការធ្វើដំណើរទៅក្រៅប្រទេសជាញឹកញាប់ និង/ឬមធ្យោបាយផ្នែកហិរញ្ញវត្ថុ និងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី និងភាពប្រហាក់ប្រហែលក្នុងការផ្តន្ទាទោស។

*រឿងក្តីឌុចៈ បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ៣៧-៤០ (ឈ្មោះក្លែង និងការធ្វើដំណើរ)។ រឿងក្តីអៀង ធីរិទ្ធៈ បណ្តឹងឧទ្ធរណ៍ លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ ៥៤-៥៦ (ការរស់នៅក្នុងតំបន់មួយដែលមានអ្នកគាំទ្រច្រើន និងមានការទាក់ទងជាសក្តានុពល ការធ្វើដំណើរទៅក្រៅប្រទេស ជាញឹកញាប់ និង/ឬមធ្យោបាយផ្នែកហិរញ្ញវត្ថុ)។ រឿងក្តីអៀង សារីៈ បណ្តឹងឧទ្ធរណ៍ លើការឃុំខ្លួនបណ្តោះ អាសន្ន អ.វ.ត.ក អ.ប.ជ ១៧ តុលា ២០០៨ កថាខណ្ឌ១០២-១០៤ (ការធ្វើដំណើរទៅក្រៅប្រទេស ជាញឹកញាប់ មធ្យោបាយផ្នែកហិរញ្ញវត្ថុត្រូវបានដឹង និងត្រូវបានសង្ស័យថា មានការទាក់ទង ផ្នែកនយោបាយ)។ រឿងក្តី ខៀវ សំផនៈ បណ្តឹងស្នើសុំឲ្យមានការដោះលែងភ្លាមៗ អ.វ.ត.ក អ.ជ.ស.ជ ២៦ មេសា ២០១៣ កថាខណ្ឌ ៣២ (ដោយ*

*កត់សំគាល់ថា ជនជាប់ចោទអាចមានហេតុផលច្រើន ដើម្បីនឹងរត់គេចខ្លួន នៅដំណាក់កាលជិតចុងបញ្ចប់ នៃសវនាការ) រឿងក្តី ខៀវ សំផន៖ បណ្តឹងស្នើសុំឲ្យមានការដោះលែងភ្លាមៗ អ.វ.ត.ក អ.ជ.ត.ក ២២ សីហា ២០១៣ កថាខណ្ឌ ៣០-៣២។*

**ការពុំមានលិខិតឆ្លងដែន ឬពុំមានមធ្យោបាយផ្នែកហិរញ្ញវត្ថុ មិនអាចនឹងរារាំងដល់ការរត់គេចបានឡើយ៖** ជនត្រូវចោទ ពុំចាំបាច់ត្រូវបានរារាំងមិនឲ្យមានការរត់គេច ដោយការមិនមានលិខិតឆ្លងដែន ឬក៏មិនមានមធ្យោបាយផ្នែកហិរញ្ញវត្ថុនោះទេ ព្រោះថា គេនៅតែអាចលាក់ខ្លួនក្នុងប្រទេស ឬអាចឆ្លងដែនដោយខុសច្បាប់បាន។

*រឿងក្តីឌុច៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ៤០ (បានលាក់ខ្លួនពីមុននៅក្នុងប្រទេសកម្ពុជា)។ រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ៦៧ (មិនមានលិខិតឆ្លងដែន និងហានិភ័យនៃការឆ្លងដែនដោយខុសច្បាប់)។*

**អាយុ ការឃុំខ្លួនសហព័ទ្ធ លក្ខខ័ណ្ឌវេជ្ជសាស្ត្រ មិនអាចរារាំង ដល់ការរត់គេចនោះទេ៖** អាយុច្រើនរបស់ជនត្រូវចោទ ការឃុំខ្លួនសហព័ទ្ធ ឬលក្ខខ័ណ្ឌវេជ្ជសាស្ត្ររបស់បុគ្គល អាចនឹងមិនលុបលើភវនីយភាព នៃការរត់គេចរបស់ជនត្រូវចោទទេ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍លើការពន្យារការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២៦ មិថុនា ២០០៩ កថាខណ្ឌ២៨ (មិនមានភស្តុតាងថា ជនជរាមិនមានលទ្ធភាពអាចធ្វើដំណើរបាននោះទេ)។ រឿងក្តីអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ លើការពន្យារការឃុំខ្លួន ជាបណ្តោះអាសន្ននៅលើកទីពីរ អ.វ.ត.ក អ.ប.ជ ៣០ មេសា ២០១០ កថាខណ្ឌ៣៧ (លក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រ)។*

**អាយុ សុខភាព ការចល័តដែលមានកម្រិត មិនមិនមែនជាមូលហេតុស្របច្បាប់ ក្នុងការមិនរត់គេចនោះទេ៖** បើមានហានិភ័យ ដែលជនត្រូវចោទនឹងត្រូវរត់គេចខ្លួននោះ តុលាការនឹងមិនផ្តល់ជាវិមតិសង្ស័យឲ្យដល់ជនត្រូវចោទទេ។ អង្គជំនុំជម្រះ មិនទទួលយកអាយុ សុខភាព ឬការចល័តដែលមានកម្រិត របស់ជនត្រូវចោទ មកធ្វើជាមូលហេតុស្របច្បាប់ សម្រាប់ការមិនរត់គេចនោះទេ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍លើការពន្យារការឃុំខ្លួន បណ្តោះអាសន្នលើកទីពីរ អ.វ.ត.ក អ.ប.ជ ៣០ មេសា ២០១០ កថាខណ្ឌ៣៥-៣៩។*

**អំណាចនៃដីកាបង្គាប់ឲ្យនាំខ្លួន មិនបានកាត់បន្ថយហានិភ័យ នៃការរត់គេចនោះទេ៖** សិទ្ធិអំណាចនៃការចេញដីកាបង្គាប់ឲ្យនាំខ្លួន មិនបានកាត់បន្ថយហានិភ័យ ដែលជនត្រូវចោទត្រូវរត់គេច ឬមិនរត់គេចនោះទេ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍លើការពន្យារការឃុំខ្លួន បណ្តោះអាសន្នលើកទីពីរ អ.វ.ត.ក អ.ប.ជ ៣០ មេសា ២០១០ កថាខណ្ឌ៣៥-៣៩។*

**កត្តាផ្សេងៗ ដែលបង្ហាញថា ជនត្រូវចោទអាច នឹងចាំបាច់ត្រូវធ្វើការឃុំខ្លួន ដើម្បីការពារពួកគេ៖** កត្តាទាំងនោះ ជារួមមានសេចក្តីថ្លែងជាសាធារណៈ ដែលបញ្ជាក់ពីបំណងរបស់ជនត្រូវចោទក្នុងការដាក់ពិរុទ្ធភាព ដល់បុគ្គលដទៃទៀត ការភ័យខ្លាច ដែលបានបញ្ជាក់ច្បាស់លាស់ ដោយជនត្រូវចោទ ឬដោយស្ថាប័នមួយផ្សេងទៀត អំពីសុវត្ថិភាពរបស់ជនត្រូវចោទ ការគំរាមកំហែងអំពីការសងសឹក ដែលធ្វើឡើងដោយគ្រួសាររបស់ជនរងគ្រោះ ការយាមកាមគេហដ្ឋានរបស់ជនត្រូវចោទ ឬភស្តុតាងស្តីពីស្នាមរបួស ឬពីការប៉ះពាល់ ខាងផ្លូវចិត្តទៅលើប្រជាជន ដែលត្រូវបានទទួលរងដោយសារការជំនុំជម្រះ។

*រឿងក្តីឌុច៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ ៤២-៤៨ (ឆន្ទៈនៃការដាក់ពិរុទ្ធភាព ដល់បុគ្គលដទៃទៀត ការភ័យខ្លាចអំពីសុវត្ថិភាពរបស់ជនត្រូវចោទ)។ រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ៧១-៧២ (ការគំរាមកំហែងអំពីការសងសឹក ការយាមកាមគេហដ្ឋានរបស់ជនត្រូវចោទ)។ រឿងក្តីអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ៦៤-៧២ (ភស្តុតាង ស្តីពីស្នាមរបួស ឬពីការប៉ះពាល់ខាងផ្លូវចិត្តទៅលើប្រជាជន ដែលត្រូវបានទទួលរងដោយសារការជំនុំជម្រះ)។*

**ការរំពឹងទុក ពីការគំរាមកំហែងជាក់លាក់ ទៅលើជនត្រូវចោទ៖** កាលណាមិនមានភស្តុតាងដែលគេមិនអាចរំពឹងទុកថា នឹងមានការគំរាមកំហែងជាក់លាក់ ទៅលើសន្តិសុខរបស់ជនត្រូវចោទទេនោះ គេមិនអាចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន នៅតាមមូលដ្ឋាននេះបានឡើយ។

*រឿងក្តីអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ៦០-៦៣។*

**ការឃុំខ្លួនដើម្បីរក្សា ឬការពារសណ្តាប់ធ្នាប់សាធារណៈ៖** ការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ អាចជាការចាំបាច់ ដើម្បីរក្សា ឬការពារសណ្តាប់ធ្នាប់សាធារណៈ។ ដើម្បីឲ្យត្រូវតាមមូលដ្ឋាននេះ អង្គហេតុនានាត្រូវតែបង្ហាញឲ្យឃើញថា ការដោះលែងជនត្រូវចោទ ពិតជាបានធ្វើឲ្យមានការរំខានយ៉ាងជាក់ស្តែង ដល់សណ្តាប់ធ្នាប់សាធារណៈ។ នៅទីនេះ ការឃុំខ្លួនជាបណ្តោះអាសន្ន ត្រូវអាស្រ័យលើកង្វល់ជាសាធារណៈចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ លើភាពញឹកញាប់ នៃភាពច្របូកច្របល់ ឬឧក្រិដ្ឋកម្មឃោរឃៅនៅក្នុង

សង្គម និងសក្ដានុពលចំពោះអស្ថិរភាព ដែលបណ្ដាលមកពីនយោបាយ។

*រឿងក្ដីនួន ជា៖ បណ្ដឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ៧៩-៨១។ រឿងក្ដីអៀងធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍ លើការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ៦៤-៧២។ រឿងក្ដីអៀង សារី៖ បណ្ដឹងឧទ្ធរណ៍ លើការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ១៧ តុលា ២០០៨ កថាខណ្ឌ ១១៥-១១៧ (ឧក្រិដ្ឋកម្មប្រចាំថ្ងៃ កុប្បកម្មនយោបាយ)។ រឿងក្ដីឌុច៖ បណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះ អាសន្ន អ.វ.ត.ក អ.ប.ជ ៣ ធ្នូ ២០០៧ កថាខណ្ឌ៥០-៥៦ (កិច្ចដំណើរការនីតិវិធី អាចបណ្ដាលឲ្យសេចក្ដីអន្ទះអន្ទែងចង់ដឹង ដែលមានស្រាប់នៅក្នុងសង្គម លេចចេញមកសារជាថ្មីម្ដងទៀត)។ រឿងក្ដីខៀវ សំផន៖ បណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងការពន្យារពេលការឃុំខ្លួន ជាបណ្ដោះអាសន្នលើកទីពីរ អ.វ.ត.ក អ.ប.ជ ៣០ មេសា ២០១០ កថាខណ្ឌ៣៦-៣៩ (ស្នាមរបួស និងការប៉ះពាល់ផ្លូវចិត្ត នៃកិច្ចដំណើរការនីតិវិធី ទៅលើមហាជនទាំងមូល ការបង្ការកុំឲ្យមានទូវភាពច្របូកច្របល់ នៅក្នុងសង្គម)។*

**កាលណាជនត្រូវចោទ ត្រូវបានគេរកឃើញថាមិនមានសម្បទា ក្នុងការចូលរួមសវនាការនោះទេ គោលការណ៍នៃការសន្មត់ទុកជាមុនអំពីសេរីភាព តម្រូវថា ជននោះ ត្រូវបានដោះលែងពីការឃុំឃាំង៖** ការឃុំខ្លួនបន្ត ឬការឃុំខ្លួនដោយបង្ខំ ក្នុងករណីដែលការឃុំខ្លួននោះមិនមានលក្ខណៈច្បាស់លាស់ ថាតើការជំនុំជម្រះនោះនឹងត្រូវគេដំណើរការឬទេ នោះជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងសិទ្ធិទទួលបានសេរីភាព។ កាលណាបណ្ដឹង មិនទាន់ត្រូវបានផុតរលត់ដូចបាននៅចែងត្រង់មាត្រា ៧ នៃក្រមនេះ ជនត្រូវចោទនោះ អាចត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលដែលជននោះមានសម្បទា ក្នុងការចូលរួមសវនាការ ឬពេលណាដែលបណ្ដឹងនោះ ត្រូវបានផុតរលត់ដោយអនុលោមតាមច្បាប់។

*រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ២២។ រឿងក្ដី អៀង ធីរិទ្ធ៖ សេចក្ដីសម្រេច លើបណ្ដឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងទៅនឹងដីកាបង្គាប់ របស់អង្គជំនុំជម្រះសាលាដំបូងឲ្យ ដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទដោយមានលក្ខខណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធីការដោះលែង ដោយឥតលក្ខខណ្ឌ*

*ចំពោះបុគ្គលពាក់ព័ន្ធនោះ គឺចៀសមិនផុតពីផលវិបាកឡើយ។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាឲ្យរក្សាទុកជនជាប់ចោទ ក្នុងការឃុំឃាំងប្រឆាំងនឹងដីកាបង្គាប់ឲ្យដោះលែង អៀង ធីរិទ្ធ) អ.ជ.ត.ក ១៧ កញ្ញា ២០១២ កថាខណ្ឌ ៧-៨។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល) អ.ជ.ស.ជ ២៦ មីនា ២០១៣ កថាខណ្ឌ ១។ រឿងក្តី អៀង ធីរិទ្ធ៖ សំណើរបស់ក្រុមមេធាវីការពារសុំឲ្យធ្វើការបញ្ជាក់ឲ្យបានច្បាស់ អំពីការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ស.ជ ២៧ មិថុនា ២០១៣។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ត.ក ១៤ ធ្នូ ២០១២ កថាខណ្ឌ ៣៧-៣៩។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៣.៣។ វិធាននេះ គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២០៥ លើកលែងតែនៅក្នុងវិធាន ៦៣.៣(ក) លក្ខខណ្ឌតម្រូវទីមួយសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន គឺមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បន្ថែមលើនេះវិធាន ៦៣.៣(ខ) មានការរក្សាសណ្តាប់ធ្នាប់សាធារណៈនៅក្នុងបញ្ជីមូលហេតុ សម្រាប់ធ្វើការឃុំខ្លួនបណ្តោះអាសន្ន ខណៈដែលមាត្រា ២០៥ មិនមានចែងដូច្នេះទេ។ ផ្ទុយទៅវិញ មាត្រា ២០៥ មានរួមបញ្ចូលនូវការបញ្ចប់ ឬការបង្ការបទល្មើសកុំឲ្យកើតជាថ្មីជាមូលហេតុ ខណៈដែលវិធាន ៦៣.៣ (ខ) មិនមានចែងដូច្នេះទេ។

## ***ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត***

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលបញ្ញត្តិអំពីគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប*

*ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវតែសមហេតុផល និងចាំបាច់ មិនមែនតាមទំនើងចិត្តនោះទេ៖** ភាពតាមទំនើងចិត្ត មិនមែនស្មើនឹង "ប្រឆាំងនឹងច្បាប់នោះទេ" ប៉ុន្តែគេត្រូវតែធ្វើការបកស្រាយវាឲ្យបានកាន់តែទូលំទូលាយ ដើម្បីរួមបញ្ចូលនូវធាតុផ្សំទាំងឡាយនៃភាពមិនសមស្រប អយុត្តិធម៌ កង្វះខាតនូវការព្យាករណ៍ និងកង្វះដំណើរការត្រឹមត្រូវតាមច្បាប់។ ដូច្នេះ ការឃុំខ្លួនបណ្ដោះអាសន្ន គឺត្រូវតែសមហេតុផល និងចាំបាច់នៅគ្រប់កាលៈទេសៈ ដូចជា ដើម្បីបង្ការកុំឲ្យមានការរត់គេច ឬកុំឲ្យមានកើតបទល្មើសជាថ្មីឡើងវិញ ឬដើម្បីរក្សាភស្តុតាង។

> *រឿងក្តី MARQUES ទល់នឹងប្រទេសអង់ហ្គោឡា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៩ មីនា ២០០៥ កថាខណ្ឌ៦.១ (រឿងក្តីVANALPHEN ទល់នឹងប្រទេសហូឡង់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ កក្កដា ១៩៩០ កថាខណ្ឌ ៥.៨។ រឿងក្តី MUKONG ទល់នឹងប្រទេសកាមេរូន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២១ កក្កដា ១៩៩៤ កថាខណ្ឌ៩.៨។ រឿងក្តីA ទល់នឹងប្រទេសអូស្ត្រាលី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣ មេសា ១៩៩៧ កថាខណ្ឌ៩.២)។ រឿងក្តីGORJI DINKA ទល់នឹងប្រទេសកាមេរូន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៧ មីនា ២០០៥ កថាខណ្ឌ៥.១។*

**កាលណាការឃុំខ្លួន មិនសមហេតុសមផល ឬមិនចាំបាច់ ប៉ុន្តែជាទណ្ឌកម្ម ដូច្នេះហើយជាការធ្វើតាមទំនើងចិត្ត៖** កាលណាជនត្រូវចោទ ដែលត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ត្រូវបានចាប់ខ្លួនដោយមន្ត្រីនគរបាលប្រដាប់អាវុធ ចំនួន២០នាក់ ហើយត្រូវស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នចំនួន ៤០ថ្ងៃ ដោយរួមទាំងចំនួន១០ថ្ងៃ ដែលជនត្រូវចោទ ត្រូវបានដាក់មិនឲ្យមានការប្រាស្រ័យទាក់ទង នោះការចាប់ខ្លួន និងការឃុំខ្លួនដូច្នេះ គឺមិនសមហេតុផល និងមិនចាំបាច់ទេ ក៏ប៉ុន្តែនៅក្នុងវិសាលភាពមួយនៃការដាក់ទណ្ឌកម្ម ហើយបើដូច្នេះ គឺជាការធ្វើតាមទំនើងចិត្ត។

> *រឿងក្តី MARQUES ទល់នឹងប្រទេសអង់ហ្គោឡា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៩ មីនា ២០០៥ កថាខណ្ឌ៦.១។*

**ការឃុំខ្លួនមិនសមហេតុផល ឬមិនចាំបាច់ នៅពេលណាការចោទប្រកាន់ ត្រូវបានធ្វើឡើង ដោយមិនមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ និងដើម្បីជះឥទ្ធិពលទៅលើកិច្ចដំណើរការនីតិវិធីដទៃទៀត៖** ការឃុំខ្លួន គឺមិនសមហេតុផល និងមិនចាំបាច់ ដូច្នេះហើយវារំលោភទៅលើសិទ្ធិមានសេរីភាព និងសន្តិសុខរបស់បុគ្គល កាលណាការចោទប្រកាន់ព្រហ្មទណ្ឌ ត្រូវបានធ្វើ បន្ទាប់ពីការចាប់ខ្លួនលើកទីពីរ ដែលត្រូវបានអះអាងថា ពុំមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ និងមានចេតនាជះឥទ្ធិពល ទៅលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការយោធា។

> *រឿងក្តី GORJI DINKA ទល់នឹងប្រទេសកាមេរូន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៧ មីនា ២០០៥ កថាខណ្ឌ៥.១។*

**ការបញ្ជូនត្រឡប់មកឃុំឃាំងវិញ ត្រូវតែត្រឹមត្រូវតាមច្បាប់ សមហេតុផល និងចាំបាច់៖** សិទ្ធិក្នុងការទទួលបាននូវសេរីភាព តម្រូវឲ្យកាលៈទេសៈនៃការឃុំខ្លួនបុគ្គល ត្រូវតែត្រឹមត្រូវទៅតាមច្បាប់ សមហេតុផល និងចាំបាច់នៅគ្រប់កាលៈទេសៈ ដូចជា ដើម្បីបង្ការការរត់គេចការជ្រៀតជ្រែក លើភស្តុតាង ឬការកើតឡើងវិញនៃបទល្មើស។

*រឿងក្តី KULOV ទល់នឹងប្រទេសគៀកជីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៦ កក្កដា ២០១០ កថាខណ្ឌ៨.៣។*

**គេត្រូវប្រើការឃុំខ្លួនមុនសវនាការលើអង្គសេចក្តីតែក្នុងកាលៈទេសៈដែលមានកម្រិតតែប៉ុណ្ណោះ៖** គេមិនត្រូវប្រើការឃុំខ្លួនមុនសវនាការលើអង្គសេចក្តីនោះទេ ហើយត្រូវអនុញ្ញាតឲ្យមានការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លើកលែងតែកាលណាមាន "ភាពទំនងដែលថាជនត្រូវចោទនោះគេចខ្លួន ឬបំផ្លាញភស្តុតាង ជះឥទ្ធិពលទៅលើសាក្សី ឬរត់គេចចេញពីយុត្តាធិការនៃរដ្ឋនោះ" ឬបានរត់គេចខ្លួនទៅក្រៅប្រទេស និងវិលត្រឡប់វិញ តែតាមរយៈនីតិវិធីបត្យាប័នប៉ុណ្ណោះ។

*រឿងក្តី HILL និងHILL ទល់នឹងប្រទេសអេស្ប៉ាញ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២ មេសា ១៩៩៧ កថាខណ្ឌ១២.៣ (ភាពទំនង)។រឿងក្តី BASSO ទល់នឹងប្រទេស អ៊ុយរុយហ្គាយ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៩ តុលា ២០១០ កថាខណ្ឌ១០.២ (បត្យាប័ន)។*

**រដ្ឋត្រូវតែធ្វើយុត្តិកម្ម លើលក្ខខ័ណ្ឌតម្រូវនៃការឃុំខ្លួនបន្ត និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬលក្ខខ័ណ្ឌដ៏តឹងរ៉ឹងនៃការដោះលែង៖** ដើម្បីធ្វើយុត្តិកម្ម លើករណីលើកលែងមួយ ពីវិធានទូទៅ ដែលបុគ្គលកំពុងរង់ចាំការជំនុំជម្រះ មិនត្រូវឃុំខ្លួនទេ រដ្ឋភាគី ត្រូវតែពិពណ៌នាឲ្យបានពេញលេញនូវកង្វល់ទាំងឡាយ ដែលនឹងធ្វើយុត្តិកម្មដល់ការឃុំខ្លួនបន្ត ហើយថាតើហេតុអ្វីបានជាកង្វល់ទាំងនេះ មិនអាចដោះស្រាយបានទៅតាមលក្ខខ័ណ្ឌតម្រូវនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬលក្ខខណ្ឌដ៏តឹងរ៉ឹងនៃការដោះលែងដទៃទៀត។

*រឿងក្តី SMANSTER ទល់នឹងប្រទេសបេលឡារុស គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៨ កថាខណ្ឌ១០.៣។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា ៩.១ និង ៩.៣។ មាត្រា ៩.១ ចែងអំពីសិទ្ធិទូទៅក្នុងការទទួលបានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួនរបស់បុគ្គល ដោយហេតុថា គ្មានបុគ្គលណាម្នាក់ត្រូវបានចាប់ចង ឬឃុំខ្លួនតាមអំពើចិត្តឡើយ ហើយថាការដកហូតសេរីភាព ត្រូវមានហេតុផលដែលបានបង្កើតឡើងដោយច្បាប់តែប៉ុណ្ណោះ។ មាត្រា ៩.៣ ដែលពាក់ព័ន្ធបំផុតនោះចែងថា មិនត្រូវឲ្យមានបទបញ្ញាជាទូទៅណាមួយថា ជនដែលនៅរង់ចាំការជំនុំជម្រះ ត្រូវតែដាក់ក្នុងមន្ទីរឃុំឃាំងនោះឡើយ។

*តុលាការសិទ្ធិមនុស្សអឺរ៉ុប*
*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**គ្រោះថ្នាក់ នៃការរត់គេច អាចធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្នបាន៖** គ្រោះថ្នាក់នៃការរត់គេចអាចធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្នបាន កាលណាមានអំណះអំណាងគ្រប់គ្រាន់។

> *រឿងក្តី TOTH ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ១២ ធ្នូ ១៩៩១ កថាខណ្ឌ៧១ និង៧២។*

**ហានិភ័យ នៃការគាបសង្កត់លើសាក្សី ការស៊ីគ្រលំរវាងអ្នកសមគំនិត ការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ និងគ្រោះថ្នាក់ នៃការខូចខាតភស្តុតាង៖** ទាំងអស់នេះជាមូលហេតុ ដែលអាចធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្នបាន។ យ៉ាងណាក៏ដោយ ហេតុផលទាំងនេះ ត្រូវថយចុះ ដោយចៀសមិនរួចខណៈដែលពេលវេលា ក្នុងការឃុំខ្លួនកន្លងផុតទៅ។

> *រឿងក្តី TOMASI ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ សីហា ១៩៩២ កថាខណ្ឌ៨៥-៩៩។ រឿងក្តី LETELLIER ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មិថុនា ១៩៩១ កថាខណ្ឌ៤៣។ រឿងក្តី LABITA ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ៦ មេសា ២០០០ កថាខណ្ឌ ១៦៣។*

**លទ្ធភាព នៃការប្រព្រឹត្តបទល្មើសជាថ្មី ផ្អែកលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដែលបានចោទប្រកាន់៖** ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ អាចគាំទ្រដល់ការឃុំខ្លួន ដើម្បីបង្ការលទ្ធភាពនៃការប្រព្រឹត្តបទល្មើសជាថ្មី ក៏ប៉ុន្តែ គ្រោះថ្នាក់នៃការប្រព្រឹត្តបទល្មើសសាជាថ្មី ត្រូវតែគួរឲ្យជឿជាក់បាន ហើយនិងវិធានការនៃឃុំខ្លួន ត្រូវតែមានលក្ខណៈសមស្របសម្រាប់កាលៈទេសៈ នៃរឿងក្តីប្រវត្តិព្រហ្មទណ្ឌពីអតីតកាល និងបុគ្គលភាពរបស់ជនត្រូវចោទ។

> *រឿងក្តី CLOOTH ទល់នឹងប្រទេសប៊ែលហ្ស៊ិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ១២ ធ្នូ ១៩៩១ កថាខណ្ឌ៣៨-៤០។*

**អវត្តមាននៃចំណងសង្គម គឺមិនគ្រប់គ្រាន់ដល់ការធ្វើយុត្តិកម្ម លើការឃុំខ្លួនជាបណ្តោះអាសន្នឡើយ៖** អវត្តមានជាប់លាប់ពីលំនៅឋាន ការងារ ឬគ្រួសារមិនគ្រប់គ្រាន់ក្នុងការធ្វើយុត្តិកម្ម ទៅលើការឃុំខ្លួនបណ្តោះអាសន្ននោះទេ។

> *រឿងក្តី SULAOJA ទល់នឹងប្រទេសអេស្តូនី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៥ កុម្ភៈ ២០០៥ កថាខណ្ឌ៦៤។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖ មាត្រា ៥.១។ មាត្រានេះចែងអំពីសិទ្ធិមានសេរីភាព និងសន្តិសុខ រួមទាំងសិទ្ធិក្នុងការត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយស្របច្បាប់ផង។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**កាលៈទេសៈថ្មីៗ នៅក្នុងរឿងក្តីអាចធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្នបាន៖** ជនត្រូវចោទដែលបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចយកទៅដាក់ឃុំជាបណ្តោះអាសន្នបាន សម្រាប់អង្គហេតុតែមួយដូចគ្នា និងនៅក្នុងករណីនៃកាលៈទេសៈថ្មីៗ។

> *លេខ 04-87392 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១ មីនា ២០០៥។ លេខ07-87802 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២១ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ២៩ មករា ២០០៨។*

**មូលហេតុមិនសមស្រប នៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានជំនួស នៅពេលប្តឹងឧទ្ធរណ៍៖** នៅពេលប្តឹងឧទ្ធរណ៍ ចំពោះសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន យុត្តាធិការដែលមានសមត្ថកិច្ចនៅក្នុងការអះអាង ពីការឃុំខ្លួនបណ្តោះអាសន្ន គឺអាចដាក់ជំនួសវិញនូវមូលហេតុ ដែលមិនសមស្របរបស់ចៅក្រមដំបូង ដោយមូលហេតុគ្រប់គ្រាន់វិញបាន។

> *លេខ 09-87206 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៨ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១៩ មករា ២០១០។*

**ការរំខានសណ្តាប់ធ្នាប់សាធារណៈ៖** ទាំងនេះមិនត្រូវបានគេកម្រិត នៅត្រឹមតែការណ៍ ដែលបានកើតឡើងនៅក្នុងប្រទេសបារាំងនោះទេ។

> *លេខ85-94474 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣១៣ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១៥ តុលា ១៩៨៥។*

**ការរំខានសណ្តាប់ធ្នាប់សាធារណៈ ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម៖** ការរំខានសណ្តាប់ធ្នាប់សាធារណៈ ដែលពាក់ព័ន្ធ គឺជាការរំខានទាំងឡាយណា ដែលបានបង្កើតឡើង ដោយឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់។

> *លេខ85-96526 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៩៤ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ៦ មីនា ១៩៨៦។*

**សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទដោយទាក់ទង ទៅនឹងការកាត់ឲ្យជាប់ទោសនៅពេលសវនាការ មិនល្មើសនឹងសច្ចធារណ៍នៃនិរទោសទេ៖** សេចក្តីសម្រេចណា ដែលពិនិត្យពីអត្ថិភាពនៃការកាត់ឲ្យជាប់ទោស ដោយតុលាការដែលធ្វើសវនាការ និងប្រកាសពីការឃុំខ្លួនបណ្តោះអាសន្នថា ជាមធ្យោបាយតែមួយគត់ ដើម្បីបង្ការកុំឲ្យមានការគាបសង្កត់ទៅលើសាក្សី និងជនរងគ្រោះ

ហើយធានាថាជន ដែលស្ថិតនៅក្រោមការពិនិត្យរបស់តុលាការ នៅតែស្ថិតនៅក្រោមច្បាប់ដដែល គឺមិនល្មើសនឹងសច្ចធារណ៍នៃនិរទោសទេ។

*លេខ 01-84736 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៨៥ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១៩ កញ្ញា ២០០១។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ១៤៤។ មាត្រានេះចែងអំពីការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី ដោយរួមទាំងមូលហេតុក្នុងការបង្គាប់ ឬពន្យារការឃុំខ្លួននោះផង។

# មាត្រា ២០៦៖ កំណត់សម្គាល់របស់ជនត្រូវចោទ និងការប្រាប់ហេតុផលនៃដីកា

*កាលណា ចៅក្រមស៊ើបសួរ សម្រេចថានឹងត្រូវឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ដោយគំនិតផ្ដើមរបស់ខ្លួនផ្ទាល់ ឬតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឲ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។*

*ចៅក្រមស៊ើបសួរ សម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន តាមដីកាដោយមានសំអាងហេតុ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិ នៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ។ ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។*

*ចៅក្រមស៊ើបសួរ ចេញដីកាបង្គាប់ឲ្យឃុំខ្លួន ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា ២២០ (និយមន័យដីកាបង្គាប់ឲ្យឃុំខ្លួន) មាត្រា ២២១ (និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឲ្យឃុំខ្លួន) និងមាត្រា ២២២ (ការអនុវត្តដីកាបង្គាប់ឲ្យឃុំខ្លួន) នៃក្រមនេះ។*

## *ការអនុវត្តនៅអ.វ.ត.*

**ជនត្រូវចោទ ត្រូវបានឃុំខ្លួនខណៈដែលមានការបង្ហាញខ្លួនដំបូង៖** ជនត្រូវចោទ ដែលត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំង នៅពេលដែលបង្ហាញខ្លួនដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នឹងត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំង រហូតដល់អង្គជំនុំជម្រះចេញសេចក្តីសម្រេច ឲ្យតែការឃុំខ្លួននោះ មានមូលដ្ឋានស្របច្បាប់។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៧-៤៩។*

**ជនត្រូវចោទ អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នតែនៅក្រោយពេលសវនាការតទល់គ្នាប៉ុណ្ណោះ៖** បើសិនដីកាឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវបានគេបង្គាប់ បន្ទាប់ពីសវនាការនោះទេ គេត្រូវតែដោះលែងជនត្រូវចោទ។ សវនាការតទល់គ្នា គឺមានបំណងខុសគ្នា ពីការសួរចម្លើយជនត្រូវចោទ។ ជាពិសេស សវនាការតទល់គ្នា ផ្តល់ឱកាសឲ្យជនត្រូវចោទ ធ្វើការឆ្លើយតបទៅកាន់ព្រះរាជអាជ្ញា រីឯការសួរចម្លើយ គឺត្រូវបានធ្វើឡើងក្នុងគោលបំណង ដើម្បីស្វែងរកការពិត និងទទួលបានកំណត់ហេតុសួរចម្លើយពីជនត្រូវចោទដែលអាចប្រើប្រឆាំងនឹងខ្លួនគាត់។

*រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ១៣ ១៧ និង៣២។*

**ហានិភ័យ របស់ជនត្រូវចោទដែលក្លាយទៅជាលែងមានសម្រាប់សវនាការ អាចនឹងត្រូវបានកាត់បន្ថយ**

**ភាពចាំបាច់ ដើម្បីធ្វើឲ្យមានតុល្យភាពរវាងការឃុំខ្លួន និងសេរីភាព៖** តុលាការ ត្រូវថ្លឹងថ្លែងពីមូលហេតុនៃការឃុំខ្លួន និងសិទ្ធិទាក់ទងនឹងសេរីភាពរបស់បុគ្គល។ សច្ចធារណ៍នៃសេរីភាព តម្រូវឲ្យការឃុំខ្លួនមានមូលដ្ឋានលើសេចក្តីសម្រេចតាមផ្លូវតុលាការ ដែលបានចេញដោយអនុលោមតាមនីតិវិធី និងលក្ខខ័ណ្ឌផ្សេងៗតាមផ្លូវច្បាប់។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៧ និង៥៦។ រឿងក្តីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ៨០។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ២២។ រឿងក្តី នួន ជា៖ សេចក្តីសម្រេចលើកទី២ ស្តីពីសម្បទា របស់នួន ជាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១៣ កថាខណ្ឌ១។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់ របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែងអៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទដោយមានលក្ខ័ណ្ឌសម្រាប់កិច្ចដំណើរការនីតិវិធី ការដោះលែងដោយឥតលក្ខ័ណ្ឌ ចំពោះបុគ្គលពាក់ព័ន្ធនោះ គឺចៀសមិនផុតពីផលវិបាកឡើយ។*

**បន្ថយ ដោយវិធានការនានា ដែលផ្អែកលើការឃុំខ្លួន៖** អង្គជំនុំជម្រះសាលាដំបូង ត្រូវតែវាយតម្លៃលើវិសាលភាព ដែលអាចបន្ថយហានិភ័យនេះបាន តាមរយៈការពិនិត្យឲ្យបានត្រឹមត្រូវទៅលើកត្តា និងអង្គហេតុពាក់ព័ន្ធទាំងអស់ដែលបានបង្ហាញ នៅក្នុងការជំទាស់ដេញដោល។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៤។*

**សច្ចធារណ៍ជាគុណប្រយោជន៍ដល់ការដោះលែង៖** នេះគឺគោលការណ៍ជាសារវ័ន្តដែលគ្រប់គ្រងលើការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៦។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ៨០។*

**ចុងចោទ អាចស្នើសុំឲ្យផ្អាករឿងក្តី ទៅថ្ងៃក្រោយបាន បើគាត់ជឿជាក់ថា មេធាវីរបស់គាត់កំពុងដកហូតសេរីភាពពីគាត់៖** នៅពេលដែលមេធាវីការពារក្តី បដិសេធមិនចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ហើយរារាំងដល់សិទ្ធិរបស់ចុងចោទក្នុងការមានតំណាង ឬក្នុងការជំនុំជម្រះក្តីឲ្យបានទាន់ពេលវេលា គឺអាចជាមូលដ្ឋានសម្រាប់ផ្អាកកិច្ចដំណើរការនីតិវិធីទៅថ្ងៃក្រោយ។

*រឿងក្តីខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍សុំផ្អាកការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២៣ មេសា ២០០៨ កថាខណ្ឌ៩-១១។*

**កាលណាជនត្រូវចោទ ត្រូវបានរកឃើញថា មិនមានសម្បទា ក្នុងការចូលរួមសវនាការទេ គោលការណ៍នៃការសន្មត់ ទុកជាមុនអំពីសេរីភាពតម្រូវថា ជននោះត្រូវបានដោះលែង ពីការឃុំឃាំង៖** ការឃុំខ្លួនបន្ត ឬការឃុំខ្លួនដោយបង្ខំ ក្នុងករណីដែលការឃុំខ្លួននោះ មិនមានលក្ខណៈច្បាស់លាស់ ថាតើការជំនុំជម្រះនោះនឹងត្រូវគេដំណើរការឬទេ នោះជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសិទ្ធិទទួលបានសេរីភាព។ កាលណាបណ្តឹង មិនទាន់ត្រូវបានផុតរលត់ ដូចមានចែងត្រង់មាត្រា ៧ នៃក្រមនេះ ជនត្រូវចោទ អាចត្រូវបានគេដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលដែលជននោះ មានសម្បទាក្នុងការចូលរួមសវនាការ ឬពេលដែលបណ្តឹងនោះ ត្រូវបានផុតរលត់ដោយអនុលោមតាមច្បាប់។

*រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ៨០។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ២២។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ*

*៨០។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ២២។ រឿងក្តី អៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទដោយមានលក្ខខណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធី ការដោះលែងដោយឥតលក្ខខណ្ឌចំពោះបុគ្គលពាក់ព័ន្ធនោះ គឺចៀសមិនផុតពីផលវិបាកឡើយ)។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ឲ្យរក្សាទុកជនជាប់ចោទ ក្នុងការឃុំឃាំងប្រឆាំងនឹងដីកាបង្គាប់ឲ្យដោះលែង អៀង ធីរិទ្ធ) អ.ជ.ត.ក ១៧ កញ្ញា ២០១២ កថាខណ្ឌ៧-៨។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល) អ.ជ.ស.ជ ២៦ មីនា ២០១៣ កថាខណ្ឌ១។ រឿងក្តី អៀង ធីរិទ្ធ៖ សំណើរបស់ក្រុមមេធាវីការពារឲ្យធ្វើការបញ្ជាក់ឲ្យបានច្បាស់អំពីការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ស.ជ ២៧ មិថុនា ២០១៣។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ត.ក ១៤ ធ្នូ ២០១២ កថាខណ្ឌ៣៧-៣៩។ រឿងក្តី នួន ជា និង ខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៣.១ ៦៣.២ ៦៣.៥ និង៦៣.៧។ វិធានទាំងនេះ គឺស្រដៀងគ្នាទៅនឹងមាត្រា ២០៦ លើកលែងតែនៅក្នុងវិធាន៦៣.១(ខ) ដែលមានបទប្បញ្ញត្តិពិស្តារសម្រាប់ជនត្រូវចោទច្រើនជាង ដើម្បីត្រៀមរៀបចំការការពារខ្លួន និងវិធាន ៦៣.២ ដែលចែងយ៉ាងច្បាស់ថា ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នត្រូវតាក់តែងឡើងដោយមានបញ្ជាក់អំពីអង្គហេតុ និងអង្គច្បាប់សម្រាប់ការឃុំខ្លួនរយៈពេលអតិបរមាដំបូងនៃការឃុំខ្លួន និងសិទ្ធិរបស់ជនត្រូវចោទ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្ដីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី គឺជាករណីលើកលែង៖** ការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី គឺជាករណីលើកលែង ហើយបើគិតពីថិរវេលាត្រូវតែមានរយៈពេលខ្លី តាមដែលអាចធ្វើទៅបាន។

*រឿងក្តី CAGAS និងគូកនទល់នឹងប្រទេសហ្វីលីពីន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៤ កថាខណ្ឌ៧.៤។*

**ដើម្បីផ្តល់យុត្តិកម្មលើការឃុំខ្លួន គេត្រូវតែបង្ហាញពីកង្វល់ ដែលគេមិនអាចដោះស្រាយបាន ដោយការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ/ លក្ខខណ្ឌនានានៃការដោះលែង៖** ដើម្បីធ្វើយុត្តិកម្មលើការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី រដ្ឋនោះត្រូវពិពណ៌នាឲ្យបានពេញលេញពីកង្វល់នានា ដែលធ្វើយុត្តិកម្មលើការបន្តការឃុំខ្លួន និងមូលហេតុអ្វី បានជាគេមិនអាចដោះស្រាយកង្វល់ទាំងនេះបាន ដោយការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការ ឬដោយការដោះលែងតាមលក្ខខណ្ឌដ៏តឹងរ៉ឹងផ្សេងៗទៀត។ ពាក់ព័ន្ធនឹងយុត្តិកម្មទៅលើការដោះលែង មុនសវនាការលើអង្គសេចក្តី រួមមានការដាក់ឥទ្ធិពល លើសាក្សី ការក្លែងភស្តុតាង ឬការរត់គេចខ្លួនពីដែនសមត្ថកិច្ច។

*រឿងក្តី SMANSTER ទល់នឹងប្រទេសបេលឡារុស គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៨ កថាខណ្ឌ១០.៣។*

**ការឃុំខ្លួន អាចមានលក្ខណៈស្របច្បាប់ទៅបានលុះត្រាតែច្បាប់បានចែង អំពីការឃាត់ខ្លួន ចំពោះឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ប៉ុណ្ណោះ៖** សូម្បីតែមានទឡ្ហីករណ៍សំខាន់ ដែលគេជឿជាក់បានថា បទល្មើសព្រហ្មទណ្ឌ ត្រូវបានប្រព្រឹត្តក៏ដោយ ក៏គេអាចនឹងមិនធ្វើការឃុំខ្លួនបុគ្គលនោះទេ លុះត្រាតែឧក្រិដ្ឋជននោះ ត្រូវគេជឿជាក់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ដែលច្បាប់របស់រដ្ឋបានចែងឲ្យមានការឃាត់ខ្លួន។

*រឿងក្តី LATIFULIN ទល់នឹងប្រទេសគៀកជីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១០ មីនា ២០១០ កថាខណ្ឌ៨.២។*

**លំនួខណ្ឌតម្រូវ ក្នុងការផ្តល់យុត្តិកម្ម សម្រាប់ការពន្យារការឃុំខ្លួន៖** ការឃុំខ្លួន រួមទាំងការឃាត់ខ្លួនក្នុងផ្ទះផងដែរ អាចត្រូវបានចាត់ទុកថាធ្វើឡើងតាមទំនើងចិត្ត បើរដ្ឋនោះ មិនអាចផ្តល់ទឡ្ហីករណ៍ឲ្យបានជាក់លាក់ ទៅតាមរឿងក្តីនីមួយៗ ដើម្បីជាយុត្តិកម្មនៃការបន្តការឃុំខ្លួននោះទេ។

*រឿងក្តី KWORK ទល់នឹងប្រទេសអូស្ត្រាលី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៩ កថាខណ្ឌ៩.៣។ រឿងក្តី ABBASSI ទល់នឹងប្រទេសអាល់ហ្សេរី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៨ មីនា២០០៧ កថាខណ្ឌ ៨.៤ (ការឃាត់ខ្លួនក្នុងគេហដ្ឋាន)។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា ៩.១ ៩.៣ ៩.៤ ១៤.២ និង១៤.៣(គ)។ ដោយឡែកមាត្រា ៩.៣ ចែងថា មិនត្រូវឲ្យមានបទបញ្ញាជាទូទៅណាមួយថា ជនដែលនៅរង់ចាំការជំនុំជម្រះ ត្រូវតែដាក់ក្នុងមន្ទីរឃុំឃាំងនោះឡើយ។ បទប្បញ្ញត្តិដទៃទៀត នៅក្នុងមាត្រា ៩ ប្រឹងប្រែងឲ្យមានការធានាផ្សេងៗទាក់ទងទៅនឹងការឃុំខ្លួន ខណៈដែលមាត្រា ១៤.២ បង្កើតនូវសច្ចធារណ៍នៃនិរទោស និងមាត្រា ១៤.៣ (គ) ការពារនូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តី ដោយពុំមានការពន្យារពេលមិនត្រឹមត្រូវ។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**បុគ្គលដែលត្រូវឃុំខ្លួនមានសិទ្ធិចូលរួម ក្នុងសវនាការដេញដោលតទល់គ្នា នៅចំពោះមុខចៅក្រម ដែលត្រូវធ្វើសេចក្តីសម្រេច ថាតើចាំបាច់ត្រូវមានការឃុំខ្លួនបណ្តោះអាសន្នឬទេ៖** សវនាការដេញដោលត្រូវពាក់ព័ន្ធទៅនឹងការមានតំណាងស្របច្បាប់ និងលទ្ធភាពនៅក្នុងការកោះហៅ និងសួរដេញដោលសាក្សី។

*រឿងក្តី KAMPANIS ទល់នឹងប្រទេសក្រិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៣ កក្កដា ១៩៩៥ កថាខណ្ឌ៤៦-៤៧។ រឿងក្តី HUSSAIN ទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ កុម្ភៈ ១៩៩៦ កថាខណ្ឌ៦០។ រឿងក្តី SINGHទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ កុម្ភៈ ១៩៩៦ កថាខណ្ឌ៦៨។ រឿងក្តី SVIPSTA ទល់នឹងប្រទេសឡាត់វៀ តុលាការសិទ្ធិមនុស្សអឺរ៉ុប ៩ មីនា ២០០៦ កថាខណ្ឌ១២៩(ង)។*

**ប្រភេទតុលាការ ដែលជនត្រូវចោទអាចតវ៉ា ចំពោះនីត្យានុកូលភាពនៃការឃុំខ្លួន៖** ការឃុំខ្លួន ត្រូវតែជាកម្មវត្ថុ នៃការពិនិត្យឡើងវិញរបស់អាជ្ញាធរ ដែលមានអំណាចតុលាការឯករាជ្យ ពីអំណាចនីតិប្រតិបត្តិ និងភាគីនានានៃរឿងក្តី។ ការពិនិត្យឡើងវិញត្រូវតែធ្វើឲ្យបានឆាប់រហ័ស។

*រឿងក្តី NEUMEISTER ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ មិថុនា ១៩៦៨ កថាខណ្ឌ២៤។*

**បណ្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក៏នៅតែអាចសួរដេញដោលបានផងដែរ៖** ជនត្រូវចោទ មានសិទ្ធិឲ្យគេស្តាប់ចម្លើយ។

*រឿងក្តី SANCHEZ-REISSE ទល់នឹងប្រទេសស្វីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ តុលា ១៩៨៦ កថាខណ្ឌ៩១។ រឿងក្តី TOTH ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ១២ ធ្នូ ១៩៩១ កថាខណ្ឌ៨៤។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មាត្រា ៥។ មាត្រានេះចែងអំពីសិទ្ធិមានសេរីភាព និងសន្តិសុខរបស់បុគ្គល រួមទាំងសិទ្ធិក្នុងការត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយស្របច្បាប់ផង។ ដោយឡែកមាត្រា ៥.៤ ចែងជាពិសេសពីសិទ្ធិរបស់ជនត្រូវចោទក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដើម្បីធ្វើការវាយតម្លៃមួយឲ្យបានឆាប់រហ័ស អំពីភាពស្របច្បាប់ និងការឃុំខ្លួនរបស់គាត់។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែបានធ្វើយុត្តិកម្មលើអង្គហេតុផ្សេងៗ នៃរឿងក្តីនោះ៖** ដីកាសម្រេចមួយ ដែលគ្រាន់តែសរសេរជាពាក្យទូទៅ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឡើងវិញ ឬសេចក្តីសម្រេចពីមុនណាមួយ ដោយពុំបានយោងទៅដល់រឿងក្តីនោះទេ គឺត្រូវទុកជាមោឃៈ។

*លេខ71-91006 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២០៩ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ២៤ មិថុនា ១៩៧១ (ពាក្យទូទៅនៃក្រម)។ លេខ84-93516 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៩១ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ៩ តុលា ១៩៨៤ (ការយោងទៅដល់រឿងក្តីពីមុន)។*

**ការផ្តល់សំអាងហេតុ ក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន៖** ដីកាសម្រេច ត្រូវមានបញ្ជាក់ពីមូលហេតុស្តីពីអង្គច្បាប់ និងអង្គហេតុលើភាពមិនគ្រប់គ្រាន់នៃការត្រួតពិនិត្យរបស់តុលាការ។

*លេខ97-82539 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១៦កក្កដា ១៩៩៧។ លេខ97-83425 ព្រឹត្តិបត្រព្រហ្ម*

*ទណ្ឌលេខ២៤៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១៦ កញ្ញា ១៩៩៧។*

**នៅពេលដែលដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នមោឃៈ៖** គឺមានតែនៅក្នុងករណី ដែលមានកំហុសដ៏សំខាន់ ឬកាលណាកិច្ចដំណើរការនីតិវិធី ដែលបង្កើតដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន មិនបានសួរដេញដោលប៉ុណ្ណោះ។ បើចាំបាច់ កិច្ចដំណើរការនីតិវិធីបែបនេះ អាចនឹងកើតឡើង នៅខាងក្រៅការិយាល័យរបស់ចៅក្រមស៊ើបសួរ។

*លេខ03-81482 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១១២ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ៣ មិថុនា ២០០៣ (កំហុសដ៏សំខាន់)។ លេខ 90-84129 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣១៧ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១៩ កញ្ញា ១៩៩០។ លេខ 85-94010 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៤៨ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១ តុលា ១៩៨៥ (ការដេញដោលត្រូវតែ មានលក្ខណៈតទល់គ្នា)។ លេខ05-80014 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៤៨៧ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១៥ មីនា ២០០៥ (សវនាការនៅខាងក្រៅការិយាល័យ)។*

**ការពិភាក្សា ដោយមិនមានការសួរដេញដោលតទល់គ្នា អាចនឹងត្រូវបានធ្វើយុត្តិកម្ម៖** កាលណាមានកាលៈ ទេសៈដែលមិនអាចជំនះបានតែប៉ុណ្ណោះ។

*លេខ00-85227 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣១៤ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ២៥ តុលា ២០០០។*

**មាត្រាស្រដៀងគ្នានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖** មាត្រា ១៤៥។ មាត្រានេះ ចែងអំពីការឃុំខ្លួនមុនសវនាការលើអង្គសេចក្ដី ដោយរួមទាំងកិច្ចដំណើរការនីតិវិធី ដែលត្រូវបន្តក្នុងការឃាត់ខ្លួនក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។

# មាត្រា ២១០៖ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាអាទិ៍

*ក្នុងករណីដែលមានការចោទប្រកាន់ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋកម្មសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១(មួយ)ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យារការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ១(មួយ)ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។*

*ចៅក្រមស៊ើបសួរ អាចបង្គាប់ឲ្យពន្យារការឃុំខ្លួនបណ្តោះអាសន្ននេះបានតែ២ (ពីរ) ដងគត់។*

## ការអនុវត្តនៅអ.វ.ត.ក

**ការពន្យារពេលលើការឃុំខ្លួន មិនចំណុះឲ្យការឃុំខ្លួនបណ្តោះអាសន្ន កម្រិតសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ៖** ការបន្តការឃុំខ្លួនបណ្តោះអាសន្ន សម្រាប់រយៈពេលបួនខែដែលបានចេញ ជាមួយនឹងដីកាដំណោះស្រាយ គឺមិនចំណុះឲ្យពេលវេលាអតិបរមាកម្រិតចំនួនបីឆ្នាំ ដែលបានចែងក្នុងការការឃុំខ្លួនបណ្តោះអាសន្ន ទាក់ទងទៅនឹងអំពើប្រល័យពូសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ និងរយៈពេលចំនួនបួនខែបន្ថែមទៀត សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន ដែលអាចត្រូវបានបង្គាប់ដោយអង្គបុរេជំនុំជម្រះ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

*រឿងក្តីអៀង សារី៖ សំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ស.ជ ១២ ឧសភា ២០១១ កថាខណ្ឌ១០។*

**ភាពចាំបាច់ ដើម្បីធ្វើឲ្យមានតុល្យភាពរវាងការឃុំខ្លួន និងសេរីភាព៖** តុលាការ ត្រូវតែថ្លឹងថ្លែងពីមូលហេតុនៃការឃុំខ្លួន និងសិទ្ធិទាក់ទងទៅនឹងសេរីភាពរបស់បុគ្គល។ សច្ចធារណ៍នៃសេរីភាព តម្រូវឲ្យការឃុំខ្លួនមានមូលដ្ឋាននៅលើសេចក្តីសម្រេចតាមផ្លូវតុលាការ ដែលត្រូវបានចេញ ដោយអនុលោមទៅតាមនីតិវិធី និងលក្ខខណ្ឌផ្សេងៗតាមផ្លូវច្បាប់។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៧ និង៥៦។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ៨០។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ២២។ រឿងក្តី នួន ជា៖ សេចក្តីសម្រេចលើកទី២ ស្តីពីសម្បទារបស់ នួន ជា*

*ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ ១៦។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តនូវសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល) អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១១ កថាខណ្ឌ១។ រឿងក្តី អៀង ធីរិទ្ធ៖ សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់ របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទដោយមានលក្ខណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធី ការដោះលែង ដោយឥតលក្ខ័ណ្ឌចំពោះបុគ្គលពាក់ព័ន្ធនោះ គឺចៀសមិនផុតអំពីផលវិបាកឡើយ)។*

**លក្ខណៈវិនិច្ឆ័យ ដែលចៅក្រមស៊ើបសួរ ត្រូវពិនិត្យ នៅពេលធ្វើការពិចារណា ថាតើរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន សមហេតុផលដែរឬទេ៖** ការរួមបញ្ចូលទាំងរយៈពេល នៃការឃុំខ្លួនដ៏មានប្រសិទ្ធភាព រយៈពេលនៃការឃុំខ្លួនដែលទាក់ទងនឹងចរិតនៃឧក្រិដ្ឋកម្ម ផលវិបាកខាងផ្លូវកាយ និងផ្លូវចិត្តនៃការឃុំខ្លួនទៅលើជនជាប់ឃុំ ភាពស្មុគស្មាញនៃរឿងក្តី និងការស៊ើបអង្កេត និងដំណើរការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីទាំងមូល។ បន្ថែមលើនេះ គឺទំនាក់ទំនងរវាង រយៈពេលដែលចុងចោទស្ថិតនៅក្នុងការឃុំខ្លួន និងការព្យាយាមដែលបានបង្ហាញ នៅក្នុងការដំណើរការស៊ើបអង្កេត គឺមានការពាក់ព័ន្ធគ្នា។

*រឿងក្តី ខៀវ សំផន៖ ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន និងសំណើសុំបដិសេធបណ្តឹងឧទ្ធរណ៍ អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ៦៨-៧០។ រឿងក្តីខៀវ សំផន៖ បណ្តឹងរបស់ ខៀវ សំផន ស្នើសុំដោះលែងភ្លាមៗ អ.វ.ត.ក អ.ជ.ស.ជ ២៦ មេសា ២០១៣ កថាខណ្ឌ៣២ (ដោយកត់សំគាល់ថា ជនជាប់ចោទអាចរត់គេចខ្លួន។*

**កាលណាជនត្រូវចោទ ត្រូវបានគេរកឃើញថាមិនមានសម្បទាក្នុងការចូលរួមសវនាការទេ គោលការណ៍នៃការសន្មត់ទុកជាមុនអំពីសេរីភាព តម្រូវថា ជននោះត្រូវបានដោះលែងពីការឃុំឃាំង៖** ការឃុំខ្លួនបន្ត ឬការឃុំខ្លួនដោយបង្ខំ ក្នុងករណីដែលការឃុំខ្លួននោះមិនមានលក្ខណៈច្បាស់លាស់ថា តើការជំនុំជម្រះនោះនឹងត្រូវគេដំណើរការឬទេ នោះជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសិទ្ធិទទួលបានសេរីភាព។ កាលណាបណ្តឹង មិនទាន់ត្រូវបានផុតរលត់ ដូចមានចែងត្រង់មាត្រា ៧ នៃក្រមនេះ ជនត្រូវចោទ អាចត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលដែលជននោះមានសម្បទាក្នុងការចូលរួមសវនាការ ឬពេលដែលបណ្តឹងនោះ ត្រូវបានផុតរលត់ ដោយអនុលោមតាមច្បាប់។

*រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ៨០។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ២២។ រឿងក្តី អៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទដោយមានលក្ខខណ្ឌ សម្រាប់កិច្ចដំណើរការនៃនីតិវិធីការដោះលែងដោយឥតលក្ខខណ្ឌ ចំពោះបុគ្គលពាក់ព័ន្ធនោះ គឺចៀសមិនផុតអំពីផលវិបាកឡើយ)។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ឲ្យរក្សាទុកជនជាប់ចោទ ក្នុងការឃុំឃាំងប្រឆាំងនឹងដីកាបង្គាប់ឲ្យដោះលែង អៀង ធីរិទ្ធ) អ.ជ.ត.ក ១៧ កញ្ញា ២០១២ កថាខណ្ឌ៧-៨។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល) អ.ជ.ស.ជ ២៦ មីនា ២០១៣ កថាខណ្ឌ១។ រឿងក្តី អៀង ធីរិទ្ធ៖ សំណើរបស់ក្រុមមេធាវីការពារ ឲ្យធ្វើការបញ្ជាក់ឲ្យច្បាស់អំពីការអនុវត្តនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ស.ជ ២៧ មិថុនា ២០១៣។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់ របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ត.ក ១៤ ធ្នូ ២០១២ កថាខណ្ឌ៣៧-៣៩។ រឿងក្តី នួន ជា និង ខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៣.៦ ៦៣.៧ និង ៨២។ វិធានទាំងនេះ គឺស្រដៀងគ្នាមែនទែន លើកលែងតែវិធាន ៦៣.៧ ដែលបានចែងយ៉ាងច្បាស់ថា ជនត្រូវចោទ និងមេធាវីរបស់គាត់ ត្រូវទុកពេលឲ្យដាក់ពាក្យប្តឹងជំទាស់ទៅចៅក្រមស៊ើបសួរ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**កាលណាមានការពន្យារពេលដោយឡែកនោះ ការឃុំខ្លួន អាចនឹងត្រូវបានធ្វើយុត្តិកម្ម៖** នៅពេលដែលរឿងក្តីមានលក្ខណៈស្មុគស្មាញប្លែកពីធម្មតា។

*រឿងក្តី WEMHOFF ទល់នឹងប្រទេសអាល្លឺម៉ង់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ មិថុនា ១៩៦៨ កថាខណ្ឌ១៧។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា ៥។ មាត្រានេះចែងអំពីសិទ្ធិមានសេរីភាព និងសន្តិសុខ រួមទាំងសិទ្ធិក្នុងការត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយស្របច្បាប់ផង។

# មាត្រា ២១១៖ ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

*កាលណាចៅក្រមស៊ើបសួរ សម្រេចថាពន្យារពេលឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរ ត្រូវឲ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ កាលណាជនត្រូវចោទមានមេធាវីអមនោះ មេធាវី ត្រូវបង្ហាញមធ្យោបាយការពារខ្លួនកូនក្តីរបស់ខ្លួន។*

*ចៅក្រមស៊ើបសួរ ពន្យារការឃុំខ្លួនបណ្តោះអាសន្នតាមដីកា ដោយមានសំអាងហេតុ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរ ត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ។ ដីកានេះ ត្រូវឲ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ។*

## *ការអនុវត្តនៅអ.វ.ត.ក*

**ភាពចាំបាច់ ដើម្បីធ្វើឲ្យមានតុល្យភាពរវាងការឃុំខ្លួន និងសេរីភាព៖** តុលាការ ត្រូវថ្លឹងថ្លែងពីមូលហេតុនៃការឃុំខ្លួន និងសិទ្ធិទាក់ទងនឹងសេរីភាពរបស់បុគ្គល។ សច្ចធារណ៍នៃសេរីភាព តម្រូវឲ្យការឃុំខ្លួនមានមូលដ្ឋាននៅលើសេចក្តីសម្រេចតាមផ្លូវតុលាការ ដែលបានចេញ ដោយអនុលោមទៅតាមនីតិវិធី និងលក្ខខណ្ឌផ្សេងៗតាមផ្លូវច្បាប់។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្នាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៧ និង៥៦។ រឿងក្តីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ៨០។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ២២។ រឿងក្តី នួន ជា៖ សេចក្តីសម្រេចលើកទី២ ស្តីពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ១៦។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទា ក្នុងការចូលរួមសវនាការ (ការអនុវត្តនូវសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល) អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១៣ កថាខណ្ឌ១។ រឿងក្តី អៀង ធីរិទ្ធ៖ សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់ របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទដោយមានលក្ខខណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធី ការដោះលែង ដោយឥតលក្ខខណ្ឌ ចំពោះបុគ្គលពាក់ព័ន្ធនោះ គឺចៀសមិនផុតពីផលវិបាកឡើយ)។*

**សច្ចធារណ៍ជាគុណប្រយោជន៍ដល់ការដោះលែង៖** នេះ គឺគោលការណ៍ជាសារវ័ន្ត ដែលគ្រប់គ្រងលើការឃុំខ្លួន មុនសវនាការលើអង្គសេចក្តី។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៥៦។*

**លក្ខណៈវិនិច្ឆ័យ ដែលចៅក្រមស៊ើបសួរត្រូវពិនិត្យនៅពេលធ្វើការពិចារណាថា តើរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន សមហេតុផលដែរឬទេ៖** រួមបញ្ចូលទាំងរយៈពេល នៃការឃុំខ្លួនដ៏មានប្រសិទ្ធភាព រយៈពេលនៃការឃុំខ្លួនដែលទាក់ទងទៅនឹងចរិតនៃឧក្រិដ្ឋកម្ម ផលវិបាកខាងផ្លូវកាយ និងផ្លូវចិត្តនៃការឃុំខ្លួន ទៅលើជនជាប់ឃុំ ភាពស្មុគស្មាញនៃរឿងក្តី និងការស៊ើបអង្កេត និងដំណើរការប្រព្រឹត្តទៅ នៃកិច្ចដំណើរការនីតិវិធីទាំងមូល។ បន្ថែមពីលើនេះគឺ ទំនាក់ទំនងរវាងរយៈពេល ដែលចុងចោទស្ថិតនៅក្នុងការឃុំខ្លួន និងការព្យាយាមដែលបង្ហាញ នៅក្នុងដំណើរការស៊ើបអង្កេតគឺមានការពាក់ព័ន្ធគ្នា។

*រឿងក្តី ខៀវ សំផន៖ ការពន្យាររយៈពេលឃុំខ្លួនបណ្តោះអាសន្ន និងសំណើសុំបដិសេធបណ្តឹងឧទ្ធរណ៍ អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ៦៨-៧០។ រឿងក្តីខៀវ សំផន៖ បណ្តឹងរបស់ ខៀវ សំផន ស្នើសុំដោះលែងភ្លាមៗ អ.វ.ត.ក អ.ជ.ស.ជ ២៦ មេសា ២០១៣ កថាខណ្ឌ៣២ (ដោយកត់សំគាល់ថា ជនជាប់ចោទអាចមានហេតុផលជាច្រើនទៀត ដើម្បីរត់គេចខ្លួន ពេលដែលការជំនុំជម្រះ ខិតជិតមកដល់ដំណាក់កាលបញ្ចប់។*

កាលណាអង្គជំនុំជម្រះ ធ្វើការពិនិត្យឡើងវិញអំពីមូលហេតុនានា នៅក្នុងការរក្សាទុកជនជាប់ចោទក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន មូលដ្ឋាននានា ត្រូវបានលើកឡើងជាសំអាងហេតុដើម្បីបន្តផ្តល់យុត្តិកម្ម ក្នុងការដកហូតសេរីភាពនោះ គេត្រូវតែធ្វើការវាយតម្លៃម្តងទៀត ចំពោះដំណាក់កាលនីមួយៗ នៃកិច្ចដំណើរការនីតិវិធី៖ តុលាការ ត្រូវតែប្រាកដថា មូលដ្ឋាននានាដែលលើកឡើងជាសំអាងហេតុ ត្រូវបន្តមានព្រមទាំងមូលហេតុ ដែលផ្តល់យុត្តិកម្ម ក្នុងការដកហូតសេរីភាពនេះ។

*រឿងក្តីខៀវ សំផន៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងទៅនឹងសេចក្តីសម្រេចនៃ អង្គជំនុំជម្រះសាលាដំបូង លើការស្នើសុំឲ្យមាន ការដោះលែងភ្លាមៗរបស់ខៀវ សំផន អ.វ.ត.ក អ.ជ.ត.ក ២៣ សីហា ២០១៣ កថាខណ្ឌ៣៤។*

**ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក្រោយដីកាដំណោះស្រាយ មិនចំណុះឲ្យគ្នាទេ៖** ដីកាសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្ន នៅក្រោយពេលចេញដីកាដំណោះស្រាយ គឺមិនចំណុះឲ្យពេលវេលាកម្រិតដទៃទៀត ដែលបានដាក់ទៅលើការឃុំខ្លួនបណ្តោះអាសន្នទេ។

*រឿងក្តីអៀង សារី៖ សំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ស.ជ ១២ ឧសភា ២០១១ កថាខណ្ឌ១០។ រឿងក្តីនួន ជា និងអៀង ធីរិទ្ធ៖ សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ភ្លាមៗដាក់ដោយនួន ជា និងអៀង ធីរិទ្ធ ស្តីពីការស្នើសុំឲ្យមាន ការដោះលែងភ្លាមៗ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ៣៧។*

**កាលណាជនត្រូវចោទ ត្រូវបានគេរកឃើញថា មិនមានសម្បទា នៅក្នុងការចូលរួមសវនាការទេ គោលការណ៍នៃការសន្មត់ទុកជាមុនអំពីសេរីភាព តម្រូវថា ជននោះត្រូវបានដោះលែង ពីការឃុំឃាំង៖** ការឃុំខ្លួនបន្ត ឬការឃុំខ្លួនដោយបង្ខំ ក្នុងករណីដែលការឃុំខ្លួននោះមិនមានលក្ខណៈច្បាស់លាស់ ថាតើការជំនុំជម្រះនោះនឹងត្រូវគេដំណើរការឬទេ នោះជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌ និងសិទ្ធិទទួលបានសេរីភាព។ កាលណាបណ្តឹង មិនទាន់ត្រូវបានផុតរលត់ ដូចមានចែងត្រង់មាត្រា ៧ នៃក្រមនេះ ជនត្រូវចោទអាចត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលដែលជននោះមានសម្បទាក្នុងការចូលរួមសវនាការ ឬពេលដែលបណ្តឹងនោះ ត្រូវបានផុតរលត់ ដោយអនុលោមតាមច្បាប់។

*រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ៨០។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ២២។ រឿងក្តីអៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យ ដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទ ដោយមានដាក់លក្ខ័ណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធី គឺជាការដោះលែង ដោយឥតលក្ខ័ណ្ឌ ចំពោះបុគ្គលពាក់ព័ន្ធនោះ គឺចៀសមិនផុតអំពីផលវិបាកឡើយ)។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (សេចក្តីសម្រេចលើ សំណើរបស់សហព្រះរាជអាជ្ញា ឲ្យរក្សាទុកជនជាប់ចោទ ក្នុងការឃុំឃាំងប្រឆាំងនឹងដីកាបង្គាប់ឲ្យដោះលែង អៀង ធីរិទ្ធ) អ.ជ.ត.ក ១៧ កញ្ញា ២០១២ កថាខណ្ឌ៧-៨។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល) អ.ជ.ស.ជ ២៦ មីនា ២០១៣ កថាខណ្ឌ១។ រឿងក្តី អៀង ធីរិទ្ធ៖ សំណើរបស់ក្រុមមេធាវីការពារ ឲ្យធ្វើការបញ្ជាក់ឲ្យច្បាស់អំពីការអនុវត្តនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើបណ្តឹងឧទ្ធរណ៍*

*ភ្នាមៗ ប្រឆាំងទៅនឹងដីកាបង្គាប់ របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ស.ជ ២៧ មិថុនា ២០១៣។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ភ្នាមៗ ប្រឆាំងទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ត.ក ១៤ ធ្នូ ២០១២ កថាខណ្ឌ៣៧-៣៩។ រឿងក្តី នួន ជា និង ខៀវ សំផន៖ សាលក្រមសំណុំរឿង០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៣.៧។ វិធាននេះគឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២១១ លើកលែងតែវាបានបញ្ជាក់យ៉ាងច្បាស់លាស់ថា គ្រប់ដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន ត្រូវស្ថិតនៅក្រោមការប្តឹងឧទ្ធរណ៍ ហើយបញ្ជាក់ថាកាលណាចៅក្រមស៊ើបសួរ បានជូនដំណឹងពីការពន្យារពេល នោះជនត្រូវចោទ មានរយៈពេលចំនួន១៥ថ្ងៃ ដើម្បីដាក់ពាក្យប្តឹងតវ៉ា។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការឃុំខ្លួន គឺជាករណីលើកលែង៖** ការឃុំខ្លួននៅមុនសវនាការលើអង្គសេចក្តី គឺជាករណីលើកលែង ហើយត្រូវមានរយៈពេលខ្លី តាមដែលអាចធ្វើទៅបាន។

*រឿងក្តី CAGAS និងគូកនទល់នឹងប្រទេសហ្វីលីពីន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ២០០៤ កថាខណ្ឌ៧.៤។*

**ដើម្បីធ្វើយុត្តិកម្មលើការឃុំខ្លួន គេត្រូវតែបង្ហាញពីកង្វល់ ដែលគេមិនអាចដោះស្រាយបាន ដោយសារការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ/ លក្ខខ័ណ្ឌនានានៃការដោះលែង៖** ដើម្បីធ្វើយុត្តិកម្មលើករណីលើកលែង ទៅនឹងវិធានទូទៅដែលថា គេមិនត្រូវឃុំខ្លួនបុគ្គលដែលកំពុងតែរង់ចាំការជំនុំជម្រះក្តី រដ្ឋនោះ ត្រូវតែពិពណ៌នាឲ្យបានគ្រប់គ្រាន់ ពីកង្វល់នានា ដែលធ្វើយុត្តិកម្មលើការបន្តការឃុំខ្លួន និងមូលហេតុ ដែលគេមិនអាចដោះ

ស្រាយ នូវកង្វល់ទាំងនេះបាន ដោយការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬលក្ខខ័ណ្ឌដ៏តឹងរ៉ឹងផ្សេងៗទៀតនៃការដោះលែង។

*រឿងក្តី SMANSTER ទល់នឹងប្រទេសបែលឡារុស គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប ២៣ តុលា ២០០៨ កថាខណ្ឌ១០.៣។*

**ការឃុំខ្លួន អាចស្របច្បាប់បាន លុះត្រាតែច្បាប់បានចែងពីការឃាត់ខ្លួននោះ ចំពោះបទល្មើស ដែលបានចោទប្រកាន់នោះប៉ុណ្ណោះ៖** សូម្បីតែមានមូលដ្ឋានសំខាន់ៗ ដែលគេជឿជាក់បានថា បទល្មើសព្រហ្មទណ្ឌ ត្រូវបានប្រព្រឹត្តក៏ដោយ ក៏គេអាចនឹងមិនធ្វើការឃុំខ្លួនបុគ្គលនោះទេ លុះត្រាតែបទល្មើសដែលបានចោទប្រកាន់នោះ មានចែងឲ្យធ្វើការឃាត់ខ្លួនតាមច្បាប់របស់រដ្ឋ។

*រឿងក្តី LATIFULIN ទល់នឹងប្រទេសតៀកជីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១០ មីនា ២០១០ កថាខណ្ឌ៨.២។*

**លក្ខខ័ណ្ឌតម្រូវក្នុងការផ្តល់យុត្តិកម្ម សម្រាប់ការពន្យាការឃុំខ្លួន៖** ការឃុំខ្លួន រួមទាំងការឃាត់ខ្លួននៅក្នុងផ្ទះផង អាចត្រូវបានចាត់ទុកថា ធ្វើឡើងតាមទំនើងចិត្ត បើសិនរដ្ឋនោះមិនអាចផ្តល់ទឡ្ហីករណ៍ឲ្យបានជាក់លាក់ ទៅតាមរឿងក្តីនីមួយៗ ដើម្បីជាយុត្តិកម្មនៃការបន្តការឃុំខ្លួននោះទេ។

*រឿងក្តី KWOK ទល់នឹងប្រទេសអូស្ត្រាលី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប២៣តុលា ២០០៩ កថាខណ្ឌ៩.៣។ រឿងក្តី ABBASSI ទល់នឹងប្រទេសអាល់ហ្សេរី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៨ មីនា ២០០៧ កថាខណ្ឌ៨.៤ (ការឃាត់ខ្លួនក្នុងគេហដ្ឋាន)។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា ៩.១ ៩.៣ ៩.៤ ១៤.២ និង ១៤.៣.គ។ ដោយឡែកមាត្រា ៩.៣ ចែងថា មិនត្រូវឲ្យមានបទបញ្ញាជាទូទៅណាមួយថា ជនដែលនៅរង់ចាំការជំនុំជម្រះត្រូវតែដាក់ក្នុងមន្ទីរឃុំឃាំងនោះឡើយ។ បទប្បញ្ញត្តិដទៃទៀតនៅក្នុងមាត្រា ៩ ផ្តល់នូវការធានាផ្សេងៗទាក់ទងទៅនឹងការឃុំខ្លួន ខណៈដែលមាត្រា ១៤.២ ចែងអំពីគោលការណ៍សច្ចធារណ៍នៃនិរទោស និងមាត្រា ១៤.៣(គ) ការពារនូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តី ដោយពុំមានការពន្យារពេលមិនត្រឹមត្រូវ។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុប ត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែអនុលោមតាមសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌៖** ជាផលវិបាក កាលណាអាជ្ញាធរជាតិ ខកខានមិនបានផ្តល់ទឡ្ហីករណ៍សម្រាប់ការឃុំខ្លួនទេ តុលាការ

នឹងរកឃើញថា មានការរំលោភទៅលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌។ ត្រូវមានការអនុវត្តដូចគ្នានេះ ចំពោះការបន្តការឃុំខ្លួនជាបណ្តោះអាសន្ន។

*រឿងក្តី KURT ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៥ ឧសភា ១៩៩៨ កថាខណ្ឌ១២២។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មាត្រា ៥។ មាត្រានេះចែងអំពីសិទ្ធិមានសេរីភាព និងសន្តិសុខរបស់បុគ្គល រួមទាំងសិទ្ធិក្នុងការត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយស្របច្បាប់ផង។ ដោយឡែកមាត្រា ៥.៤ ចែងពីសិទ្ធិរបស់ជនត្រូវចោទ ក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដើម្បីធ្វើការវាយតម្លៃឲ្យបានឆាប់រហ័សអំពីភាពស្របច្បាប់នៃការឃុំខ្លួនរបស់គាត់។

# មាត្រា ២១៧៖ ការដោះលែងឲ្យនៅក្រៅឃុំតាមបណ្តឹងរបស់ជនត្រូវចោទ

*ជនត្រូវចោទ អាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរ បញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យ។ ព្រះរាជអាជ្ញា ត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរ សម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។*

*ជនត្រូវចោទ អាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរ ក្នុងរយៈពេល ១(មួយ)ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។*

*ដីកាដែលមិនព្រមដោះលែងឲ្យនៅក្រៅឃុំ ត្រូវតែមានសំអាងហេតុ។*

*ប្រសិនបើចៅក្រមស៊ើបសួរមិន បានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។*

## *ការអនុវត្តនៅអ.វ.ត.ក*

**ត្រូវមានមូលហេតុសម្រាប់ការឃុំខ្លួន៖** កាលណាស្វែងរកការដោះលែងជនដែលត្រូវជាប់ឃុំ មេធាវីការពារក្តី ត្រូវតែបង្ហាញនូវមូលហេតុដែលគាំទ្រដល់ការឃុំខ្លួន គឺលែងមានទៀតហើយ។

*រឿងក្តីខៀវ សំផន៖ ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន និងសំណើសុំបដិសេធបណ្តឹងឧទ្ធរណ៍ អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ២១-២២។ រឿងក្តីខៀវ សំផន៖ ការស្នើសុំឲ្យមានការដោះលែងភ្លាមៗ អ.វ.ត.ក អ.ជ.ស.ជ ២៦ មេសា ២០១៣ កថាខណ្ឌ៨-១០។*

**លក្ខណៈវិនិច្ឆ័យដែលចៅក្រមស៊ើបសួរ ត្រូវតែពិនិត្យ នៅពេលធ្វើការពិចារណា ថាតើរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន សមហេតុផលដែរឬទេ៖** រួមបញ្ចូលទាំងរយៈពេលឃុំខ្លួនដ៏មានប្រសិទ្ធភាព រយៈពេលនៃការឃុំខ្លួនដែលទាក់ទងទៅនឹងចរិតនៃឧក្រិដ្ឋកម្ម ផលវិបាកខាងផ្លូវកាយ និងផ្លូវចិត្តនៃការឃុំខ្លួនទៅលើជនជាប់ឃុំ ភាពស្មុគស្មាញនៃរឿងក្តី និង

ការស៊ើបអង្កេត ព្រមទាំងដំណើរការប្រព្រឹត្តទៅ នៃកិច្ចដំណើរការនីតិវិធីទាំងមូល។ បន្ថែមពីលើនេះ គឺទំនាក់ទំនងរវាងរយៈពេល ដែលចុងចោទស្ថិត នៅក្នុងការឃុំខ្លួន និងការព្យាយាមដែលបានបង្ហាញ នៅក្នុងដំណើរការនៃស៊ើបអង្កេត គឺមានការពាក់ព័ន្ធគ្នា។

*រឿងក្តីខៀវ សំផន៖ ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន និងសំណើសុំបដិសេធបណ្តឹងឧទ្ធរណ៍ អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ៦៨-៧០។*

**កាលណាសុខភាពរបស់ជនត្រូវចោទ មិនស៊ីគ្នានឹងការឃុំខ្លួន៖** បើមេធាវីការពារក្តីអាចបង្ហាញពីស្ថានភាពសុខភាព របស់ជនត្រូវចោទបានថា មិនស៊ីគ្នានឹងការឃុំខ្លួននោះ គាត់អាចនឹងត្រូវបានដោះលែង ដោយផ្អែកលើមូលហេតុមនុស្សធម៌។

*រឿងក្តីខៀវ សំផន៖ ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន និងសំណើសុំបដិសេធបណ្តឹងឧទ្ធរណ៍ អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ៧៦ និង៨១-៨២។*

**ការយឺតយ៉ាវនៃការការពារខ្លួន មិនប៉ះពាល់ដល់នីត្យានុកូលភាពនៃការឃុំខ្លួនទេ៖** ការយឺតយ៉ាវដែលបណ្តាលមកពីមិនមានសកម្មភាព ក្នុងការការពារខ្លួន គឺមិនប៉ះពាល់ដល់នីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្ន ក្នុងការធ្វើយុត្តិកម្មលើការដោះលែងនោះទេ។

*រឿងក្តីខៀវសំផន៖ ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន និងសំណើសុំបដិសេធបណ្តឹងឧទ្ធរណ៍ អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ៣០។*

**ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន៖** រយៈពេល និងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ជាប់ឃុំ ត្រូវតែមានតុល្យភាព ជាមួយនឹងហានិភ័យ នៃការដកហូតសេរីភាពរយៈពេលយូរ និងគ្មានកំណត់ដោយឥតហេតុផលទេ។ ភាពសមហេតុផលនៃការបន្តឃុំខ្លួន ត្រូវតែធ្វើការវាយតម្លៃឡើងវិញ ចំពោះកាលៈទេសៈ នៃករណីនីមួយៗ។

*រឿងក្តីខៀវសំផន៖ បណ្តឹងស្នើសុំឲ្យមានការដោះលែងភ្លាមៗ អ.វ.ត.ក អ.ជ.ស.ជ ២៦ មេសា ២០១៣ កថាខណ្ឌ១៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៤។ វិធាននេះគឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២១៧ លើកលែងតែវា (i) តម្រូវឲ្យជនត្រូវចោទរង់ចាំយ៉ាងហោចណាស់ ៣(បី)ខែ បន្ទាប់ពីមានការសម្រេចចុងក្រោយលើពាក្យសុំឲ្យដោះលែង មុនដាក់ពាក្យសុំដោះលែងណាមួយបន្ថែមទៀត (ii) អនុញ្ញាតឲ្យដាក់ពាក្យសុំឲ្យដោះលែងតែក្នុងករណីដែលកាលៈទេសៈរបស់អ្នកដាក់ពាក្យសុំ មានការផ្លាស់ប្តូរតែប៉ុណ្ណោះ តាំងពីការដាក់ពាក្យសុំលើកមុនរបស់

ខ្លួន និង(iii) បញ្ជាក់ច្បាស់លាស់តាមវិធាន៦៤.២ ថា ដីកាសម្រេចដែលបានចេញដោយចៅក្រមស៊ើបសួរ ដែលជាការឆ្លើយតបទៅនឹងពាក្យសុំបែបនេះ គឺបើកផ្លូវឲ្យប្ដឹងឧទ្ធរណ៍។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការប្ដឹងឧទ្ធរណ៍ នៅចំពោះមុខរដ្ឋអាជ្ញាតែឯង គឺជាការរំលោភ៖** ការកម្រិតលទ្ធភាពរបស់បុគ្គលក្នុងការតវ៉ាពីភាពស្របច្បាប់ នៃការឃុំខ្លួនរបស់គាត់ ដើម្បីដាក់បណ្ដឹងឧទ្ធរណ៍ ជាមួយនឹងរដ្ឋអាជ្ញា នាំឲ្យមានជាការរំលោភទៅលើសិទ្ធិរបស់បុគ្គលនោះ ក្នុងការតវ៉ាអំពីភាពស្របច្បាប់ នៃការឃុំខ្លួនរបស់គាត់។

*រឿងក្ដី UMAROVA ទល់នឹងប្រទេសអ៊ុយបេគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៩ តុលា ២០១០ កថាខណ្ឌ៨.៦។*

**តម្រូវការឲ្យមានការពិនិត្យឡើងវិញ ដោយអាជ្ញាធរតុលាការ៖** ការពិនិត្យឡើងវិញ លើភាពស្របច្បាប់ នៃការឃុំខ្លួនបុគ្គល ត្រូវតែបានបំពេញដោយអាជ្ញាធរតុលាការ ដែលមានលទ្ធភាពអាចចេញបានដីកាបង្គាប់ឲ្យដោះលែងបុគ្គល ដែលកំពុងត្រូវបានជាប់ឃុំនោះ បើអាជ្ញាធរតុលាការ កំណត់ថា ការឃុំខ្លួនបុគ្គលនោះមិនស្របច្បាប់។

*រឿងក្ដី YKLYMOVA ទល់នឹងប្រទេសទួគមេនីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ កក្កដា ២០០៩ កថាខណ្ឌ៧.៤។ ត្រូវបានសម្រេចតាម នៅក្នុងរឿងក្ដី ABBOUSSEDRA ទល់នឹងប្រទេសLIBYAN ARAB JAMAHIRIYA គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៥ តុលា ២០១០ កថាខណ្ឌ៧.៦។*

**លក្ខខណ្ឌតម្រូវ សម្រាប់ការពិនិត្យកម្មវត្ថុ តាមផ្លូវតុលាការ ដ៏មានប្រសិទ្ធភាព លើសេចក្ដីសម្រេចនានារបស់រដ្ឋអាជ្ញា៖** ភាពស្របច្បាប់នៃការឃុំខ្លួន គឺជាកម្មវត្ថុនៅក្នុងការពិនិត្យឡើងវិញ ដោយតុលាការ។ កាលណាការតវ៉ា អំពីភាពស្របច្បាប់នៃការឃុំខ្លួន ត្រូវបានបដិសេធដោយរដ្ឋអាជ្ញា ភាពអាចធ្វើទៅបាននៃការពិនិត្យឡើងវិញ ទៅតាមផ្លូវតុលាការលើសេចក្ដីសម្រេចនានារបស់រដ្ឋអាជ្ញា គឺអាចនៅតែរំលោភលើសិទ្ធិរបស់ជនជាប់ឃុំ បើសិនជាជនជាប់ឃុំនោះអាចបង្ហាញបានថា ការពិនិត្យឡើងវិញតាមផ្លូវតុលាការនោះ នឹងមិនមានប្រសិទ្ធភាព។

*រឿងក្ដី KULOV ទល់នឹងប្រទេសគៀកជីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៦ កក្កដា ២០១០ កថាខណ្ឌ៨.៥។*

**មាត្រាស្រដៀងគ្នានៅក្នុង*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*៖** មាត្រា ៩.៤។ មាត្រានេះ ចែងថាជនដែលត្រូវគេដកហូតសេរីភាពដោយការចាប់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិទទួលបានកិច្ចដំណើរការនីតិវិធីនានាមកចំពោះមុខតុលាការ ដើម្បីពិនិត្យលើភាពស្របច្បាប់នៃការឃុំខ្លួនបែបនេះ។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌ ស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុប ត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ការវាយតម្លៃសាជាថ្មីឡើងវិញ ពីភាពត្រូវច្បាប់នៃការឃុំខ្លួនបណ្តោះអាសន្ន ដោយតុលាការ៖** ការវាយតម្លៃបែបនេះ ត្រូវតែធ្វើឡើងឲ្យបានឆាប់រហ័ស។

> *រឿងក្តី TOMASI ទល់នឹងប្រទេសបារាំង តុលា ការសិទ្ធិមនុស្សអឺរ៉ុប ២៧ សីហា ១៩៩២ កថាខណ្ឌ៨៤ និង១០២។ រឿងក្តី KOVAKIC ទល់នឹងប្រទេសស្លូវ៉ាគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៩ កុម្ភៈ ២០១២ កថាខណ្ឌ៦៩ និង ៧៧។*

**ប្រភេទតុលាការ ដែលជនត្រូវចោទ អាចតវ៉ាចំពោះនីត្យានុកូលភាពនៃការឃុំខ្លួន៖** ការឃុំខ្លួន ត្រូវតែជាកម្មវត្ថុនៃការពិនិត្យឡើងវិញរបស់អាជ្ញាធរ ដែលមានអំណាចតុលាការឯករាជ្យ ពីអំណាចនីតិប្រតិបត្តិ និងភាគីនានានៃរឿងក្តី។ ការពិនិត្យឡើងវិញត្រូវតែធ្វើឲ្យបានឆាប់រហ័ស។

> *រឿងក្តី NEUMEISTER ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ មិថុនា ១៩៦៨ កថាខណ្ឌ២៤។*

**ការពិនិត្យឡើងវិញ ក្នុងកម្រិតទីពីរតាមជម្រើស លើការឃុំខ្លួន ត្រូវតែស្ថិតក្នុងលក្ខខណ្ឌតម្រូវដូចគ្នា៖** រដ្ឋមិនតម្រូវឲ្យបង្កើតឲ្យមានការពិនិត្យ ក្នុងកម្រិតទីពីរលើពាក្យស្នើសុំឲ្យដោះលែង ពីការឃុំខ្លួននោះទេ។ យ៉ាងណាក៏ដោយ បើសិនជារដ្ឋបានបង្កើតឲ្យមានការពិនិត្យឡើងវិញ ក្នុងកម្រិតទីពីរនោះ ខ្លួនត្រូវតែធានាថា ជនជាប់ឃុំ ត្រូវមានការធានារ៉ាប់រងដូចគ្នា លើការធ្វើបណ្តឹងឧទ្ធរណ៍ ដូចនៅសាលាដំបូងដែរ។

> *រឿងក្តី TOTH ទល់នឹងប្រទេសអូទ្រីស តុលា-ការសិទ្ធិមនុស្សអឺរ៉ុប ១២ ធ្នូ ១៩៩១ កថាខណ្ឌ៨៤។*

**ការពិចារណា ក្នុងការដោះលែងពីការឃុំខ្លួនបណ្តោះអាសន្ន៖** ការដោះលែងមិនមែនបានន័យថា ការឃុំខ្លួននោះខុសច្បាប់ទេ។

> *រឿងក្តី STEPHENS ទល់នឹងប្រទេសម៉ាល់តា (ទី១) តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ មេសា ២០០៩ កថាខណ្ឌ១០២។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖ មាត្រា ៥.៤។ មាត្រានេះចែងអំពីសិទ្ធិក្នុងការទទួលបានសេរីភាព និងសន្តិសុខរបស់បុគ្គល រួមទាំងសិទ្ធិរបស់បុគ្គល ដែលត្រូវបានគេដកហូតសេរីភាពដោយការចាប់ខ្លួន ឬឃុំខ្លួន ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដែលតាមដំណើរការនោះ ភាពស្របច្បាប់នៃការឃុំខ្លួនរបស់គាត់ ត្រូវតែបានសម្រេចឲ្យបានឆាប់រហ័សដោយតុលាការ ហើយត្រូវតែចេញដីកាបង្គាប់ឲ្យដោះលែងរូបគាត់ បើការឃុំខ្លួននោះមិនស្របច្បាប់។

*តុលាការកំពូលបារាំង*

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**និយមន័យនៃថិរវេលា៥ថ្ងៃ ដើម្បីសម្រេចលើសំណើសុំដោះលែងជនជាប់ឃុំ៖** ថ្ងៃដែលចៅក្រមស៊ើបសួរបញ្ជូនសំណើទៅរដ្ឋអាជ្ញា មិនត្រូវបានរាប់បញ្ចូលទៅក្នុងថិរវេលា៥ថ្ងៃនោះទេ។

*លេខ85-90391 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១៤ តុលាការកំពូលបារាំង ១៩ មីនា ១៩៨៥។*

**មូលដ្ឋាននៃសេចក្តីសម្រេច លើសំណើសុំដោះលែង៖** សេចក្តីសម្រេចនេះ ត្រូវតែមានមូលដ្ឋាននៅលើការពិចារណាលើអង្គច្បាប់ និងអង្គហេតុយ៉ាងត្រឹមត្រូវ។

*លេខ97-82683 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៧៦ តុលាការកំពូលបារាំង ២២ កក្កដា ១៩៩៧។*

**កាលណាជនត្រូវចោទ មិនអាចប្តឹងទៅសភាស៊ើបសួរដោយផ្ទាល់បាន៖** នៅពេលដែលជនត្រូវចោទ មិនអាចដាក់សំណើសុំដោះលែងរបស់ខ្លួន ជាទម្រង់ត្រឹមត្រូវជូនទៅចៅក្រមស៊ើបសួរបាន ដែលក្រោយមកចៅក្រមស៊ើបសួរមិនបានឆ្លើយតប។

*លេខ02-86030 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២០៨ តុលាការកំពូលបារាំង ១៩ វិច្ឆិកា ២០០២។*

**ការចេញដីកាជូនដំណឹង លើសំណើសុំឲ្យដោះលែង៖** ចៅក្រម ត្រូវតែចេញដីកាសម្រេចឲ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន។

*លេខ85-90523 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១២២ តុលាការកំពូលបារាំង ២៥ មីនា ១៩៨៥។*

**កាលណាសេចក្តីសម្រេចទាក់ទងទៅនឹងសំណើសុំឲ្យដោះលែង មិនបានធ្វើទៅតាមថិរវេលាដែលបានចែង៖** ជនជាប់ឃុំ អាចប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរបាន។

*លេខ06-87705 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២ តុលាការកំពូលបារាំង ៩ មករា ២០០៧។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖ មាត្រា ១៤៨។ មាត្រានេះ ចែងពីការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី រួមទាំងលទ្ធភាពក្នុងការបញ្ជូនបុគ្គលនោះត្រឡប់ទៅឲ្យគេឃុំខ្លួនវិញ ដើម្បីធ្វើសំណើសុំឲ្យដោះលែងនៅចំពោះមុខចៅក្រម។

# មាត្រា ២២៣៖ ភាតព្វកិច្ចក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

*ចៅក្រមស៊ើបសួរ អាចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ បានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះ ត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ។*

*ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំ ឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖*

*(១) មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ*

*(២) មិនត្រូវ ផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ*

*(៣) មិនត្រូវទៅទីកន្លែងខ្លះ ដែលកំណត់ ដោយចៅក្រមស៊ើបសួរ*

*(៤) ត្រូវចូលបង្ហាញខ្លួនតាមការកំណត់ នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ*

*(៥) ត្រូវឆ្លើយតបទៅនឹងការកោះហៅពីបុគ្គល ដែលចាត់តាំង ដោយចៅក្រមស៊ើបសួរ*

*(៦) ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ*

*(៧) មិនត្រូវបើកបររថយន្ត*

*(៨) មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រម ស៊ើបសួរ*

*(៩) ដាក់ប្រាក់ធានា ដែលចំនួនប្រាក់ធានា និងបរិវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅ- ក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ*

*(១០) មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវ អាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី នូវអាវុធដែលជនត្រូវចោទកាន់កាប់*

*(១១) ត្រូវប្រគល់ ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ*

*(១២) មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។*

*ដើម្បីអនុវត្តចំណុចទី១២ ខាងលើ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្ត នូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ។*

## *ការអនុវត្តនៅអ.វ.ត.ក*

នៅដំណាក់កាលណាមួយ ក្នុងកិច្ចដំណើរការនីតិវិធី កាលណាជនត្រូវចោទ ត្រូវបានគេរកឃើញថា មិនមានសម្បទា ក្នុងការចូលរួមសវនាការទេ ជននោះអាចត្រូវបានគេដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការ៖ អានុភាព នៃការដាក់ឲ្យស្ថិត នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺដើម្បីព្យួរនូវកិច្ចដំណើរការនៃនីតិវិធី ប្រឆាំងនឹងជនត្រូវចោទ រហូតដល់ពេលដែល សម្បទារបស់ជននោះ ត្រូវបានស្តារឡើងវិញ ដើម្បីឲ្យកិច្ចដំណើរការនីតិវិធីអាចប្រព្រឹត្តទៅបាន ឬកិច្ចដំណើរការនីតិវិធី ត្រូវបានបញ្ចប់ សម្រាប់មូលហេតុណាមួយ ដូចបានចែងយ៉ាង ច្បាស់ត្រង់មាត្រា ៧ នៃក្រមនេះ (គឺថា នៅពេល ទទួលមរណភាព)។

*រឿងក្តីអៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះ សាលាដំបូងឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៤ ធ្នូ ២០១២ កថាខណ្ឌ៣៧-៣៩។ រឿងក្តីអៀង ធីរិទ្ធ៖ ការស្នើសុំ របស់ក្រុមមេធាវីការពារឲ្យបញ្ជាក់ឲ្យបានច្បាស់ អំពីការអនុវត្តនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះ សាលាដំបូងឲ្យដោះលែង ដោយឥតលក្ខខណ្ឌ ជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ២៧ មិថុនា ២០១២។ រឿងក្តី នួន ជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ៦។*

នៅពេលវាយតម្លៃ អំពីវិធានការនានា ដែលត្រូវដាក់ឡើង ក្នុងគោលបំណងដើម្បីឲ្យការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការមានអានុភាពទៅបាន គឺថាចៅក្រមត្រូវតែអនុវត្តនូវគោលការណ៍ នៃភាពចាំបាច់ និងភាពសមាមាត្រ៖ កាលណាចៅក្រម បានសម្រេចពីភាពចាំបាច់នៃបទប្បញ្ញត្តិទាំងនោះ លក្ខខណ្ឌតម្រូវ នៃភាពសមាមាត្រ បានពិចារណាទៅលើទំនាក់ទំនង រវាងការដាក់កម្រិតវិសាលភាព និងគោលបំណងរបស់វា។ អាស្រ័យហេតុនេះ វិធានការនានា ក្នុងការដាក់នៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការ គឺជាវិធានការ ដែល

អាចទស្សទាយបាន ឬមិនដែលលើសនីតិវិធី ហើយជាវិធានការ ដែលការសណ្តោសប្រណី

*រឿងក្តីអៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗប្រឆាំងនឹងដីកាបង្គាប់ របស់អង្គជំនុំ ជម្រះសាលាដំបូងឲ្យ ដោះលែងជនជាប់ចោទអៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ត.ក ១៤ ធ្នូ ២០១២ កថាខណ្ឌ៥៧។ រឿងក្តី នួនជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ៦។*

**ភាពចាំបាច់នៃវិធានការនានា ត្រូវតែមានតុល្យ-ភាព ជាមួយនឹងសិទ្ធិរបស់ជនត្រូវចោទ៖** ការអនុវត្តនូវវិធានការនានា នៅត្រង់មាត្រា២២៣ (១១) ក្នុងការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវតែពិចារណា អំពីសិទ្ធិរបស់ជនត្រូវចោទ ក្នុង ការទទួលបាននូវសេរីភាពក្នុងការដើរហើរ និង សេរីភាពបុគ្គល ដូចបានការពារត្រង់មាត្រា១២ និង១៧ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោ-បាយ ។

*រឿងក្តីអៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះ សាលាដំបូងឲ្យដោះលែងជនជាប់ចោទអៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.ជ.ត.ក ១៤ ធ្នូ ២០១២ កថាខណ្ឌ៥។*

ច្រើនអាចធ្វើទៅបាន គឺថាវិធានការនេះត្រូវតែអនុវត្ត។

**សកម្មភាពណាមួយ ដែលមានការរំលោភបំពានយ៉ាងច្បាស់លើលក្ខខណ្ឌនានា ក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការចាំ បាច់ត្រូវបានគេសាកល្បង សម្រាប់វត្តមាននៃធាតុផ្សំ ដែលមានលក្ខណៈលំអៀង៖** ក្នុងករណីដែលជនណាម្នាក់ មានមុខងារទទួលខុសត្រូវ នៅក្នុងការយល់ដឹងខ្សោយ ចំពោះការរំលោភបំពានបែបនោះ គឺថាត្រូវបានដាក់លក្ខខណ្ឌដល់សមត្ថភាព ក្នុងការអនុវត្តជាក់ស្តែងក្នុងការយល់ និងត្រួតពិនិត្យសកម្មភាពរបស់មនុស្សម្នាក់ នៅពេលនៃការលុបចោលការចោទសួរ។

*រឿងក្តី អៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹង ឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងសេចក្តី សម្រេចស្តីពី ការស្នើសុំ ដោយអង្គជំនុំជម្រះសាលាដំបូង និង ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ សម្រាប់ការ ណែនាំ និងការបញ្ជាក់ឲ្យច្បាស់ អ.វ.ត.ក អ.ជ. ត.ក ៣១ ធ្នូ ២០១៣ កថាខណ្ឌ១៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអកៈ.ត.វ.** វិធាន ៦៥ (១)។ សំណៅជាភាសាបារាំង និងខ្មែរនៃវិធាននេះ បញ្ជាក់យ៉ាងច្បាស់អំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ទោះបីជា ការពិតថា ក្នុងសំណៅជាភាសាអង់គ្លេស ពាក្យដែលគេប្រើប្រាស់ គឺដីកាសម្រេចឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ (ជាអាទិ៍មាន ដីកាសម្រេចរបស់តុលាការ ដែលជនត្រូវចោទនៅតែមានសេរីភាព ឬត្រូវបានដោះលែងពីការឃុំឃាំង ដោយសារតែសាលក្រមសវនាការមិនទាន់បានសម្រេច ផ្អែកលើលក្ខខណ្ឌថា ជននោះជាប់កាតព្វកិច្ចបង់ប្រាក់ធានា និង/ឬគោរពនូវលក្ខខណ្ឌនានា ដែលបានបញ្ជាក់ក្នុងដីកាសម្រេច)។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលប្បញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌ ស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុប ត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ក្នុងករណីដែលជនត្រូវចោទមិនទំនងទាល់តែថា នឹងមានសម្បទា ក្នុងការចូលរួមសវនាការទេ ដីកាសម្រេចក្នុងការព្យួរកិច្ចដំណើរការនីតិវិធីនឹងមិនត្រូវបានចាត់ទុកថា ជាការរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តី ក្នុងរង្វង់នៃថិរវេលាមួយ ដ៏សមហេតុផលនោះទេ៖** ការរំលោភបំពាន ទៅលើលក្ខខណ្ឌតម្រូវ នៃពេលវេលាមួយដ៏សមហេតុផល ដូចបានចែងត្រង់មាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្សតម្រូវថា ការពន្យារពេលណាមួយ គឺបណ្តាលមកពីតុលាការ តែមិនមែនដោយ សារសុខភាពរបស់ជនត្រូវចោទឡើយ។

*រឿងក្តី* KRAKOLING *ទល់នឹងប្រទេសអូស្ត្រាលី តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ១០ ឧសភា ២០១២ កថាខណ្ឌ៧ និង១០១។ រឿងក្តី* NICHIT AYLOV *ទល់នឹងប្រទេសអ៊ុយក្រែន តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ១៩ មករា ២០១០ កថាខណ្ឌ៣៦។ សូមមើលផង ដែរ រឿងក្តី* ANTOINE *ទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ១៣ ឧសភា ២០១០។*

# មាត្រា ២៤៦៖ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

*កាលណាចៅក្រមស៊ើបសួរ យល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរ ជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី។*

*២ (ពីរ) ថ្ងៃក្រោយមក ចៅក្រមស៊ើបសួរ បញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ។ ប្រសិនបើព្រះរាជអាជ្ញា យល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរជាថ្មីទៀតនោះ ព្រះរាជអាជ្ញា ត្រូវធ្វើតាមមាត្រា ១៣២ (ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា) នៃក្រមនេះ។*

*ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង១(មួយ)ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់មកជាមួយផង។ ថិរវេលា ត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។*

*ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញា អាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរ សម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។*

## *ការអនុវត្តនៅអ.វ.ត.ក*

**គ្មានភស្តុតាងបន្ថែម អាចដាក់បញ្ចូលទៅក្នុងសំណុំរឿងបានឡើយ បន្ទាប់ពីការជូនដំណឹងស្ដីពីការបិទកិច្ចស៊ើបសួរបានធ្វើឡើង៖** កាលណាចៅក្រមស៊ើបសួរ យល់ឃើញថាមានភាពចាំបាច់ត្រូវដាក់បញ្ចូលភស្តុតាងបន្ថែម ទៅក្នុងសំណុំរឿង បន្ទាប់ពីការចេញសេចក្ដីជូនដំណឹងនោះ ចៅក្រមស៊ើបសួរត្រូវចេញនូវសេចក្ដីជូនដំណឹងថ្មីស្ដីពីការបិទកិច្ចស៊ើបសួរ។

*រឿងក្ដីនួនជា អៀងសារី ខៀវសំផន អៀងធីរិទ្ធ និងឌុច៖ ដីកាស្ដីពីវិធានការខាងនីតិវិធី ជាក់លាក់ អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបសួរ ២៥ វិច្ឆិកា ២០០៩ កថាខណ្ឌ៩។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៦។ វិធាននេះស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៤៦ លើកលែងតែ (១) វិធាននេះបញ្ញត្តិយ៉ាងច្បាស់ថា សេចក្ដីសម្រេចអំពីការបិទកិច្ចស៊ើបសួរ ត្រូវធ្វើជាសាធារណៈ (២) ភាគីពាក់ព័ន្ធទាំងអស់អាចធ្វើការស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមបាន ក្រៅពីព្រះរាជអាជ្ញា ព្រមទាំងអាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេច ចំពោះការច្រានចោលការពំពេញកិច្ចស៊ើបសួរបន្ថែមបាននោះទៀតផង និង(៣) ផ្ដល់នូវ

ពេលវេលារយៈពេលយូរសម្រាប់ព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ការបិទកិច្ចស៊ើបសួរ៖** ចៅក្រមស៊ើបសួរ មានសិទ្ធិ និងករណីយកិច្ចក្នុងការបិទកិច្ចស៊ើបសួរ នៅពេលណាដែលគាត់យល់ឃើញថា កិច្ចស៊ើបសួរនោះបានចប់ទាំងស្រុង។

*លេខ 65-92493 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៤៦ តុលាការកំពូលបារាំង ២៣ វិច្ឆិកា ១៩៦៥។*

**ចៅក្រមស៊ើបសួរ ត្រូវតែពិចារណាលើរាល់សេចក្តីសន្និដ្ឋានរបស់ភាគីទាំងអស់ នៅដែលពេលរៀបចំដីកាដំណោះស្រាយ៖** ចៅក្រមស៊ើបសួរ គប្បីចៀសវាង ដោយគ្រាន់តែចម្លង តាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា។

*លេខ 10-85678 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១ តុលាការកំពូលបារាំង ១៥ មិថុនា ២០១២។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង***៖ មាត្រា ១៧៥។ មាត្រានេះ ចែងអំពីនីតិវិធីត្រូវដំណើរការ ចាប់តាំងពីដំណាក់កាលនៃការបិទកិច្ចស៊ើបសួរ ជារួមមាន ការចេញដីកាសន្និដ្ឋានស្ថាពរដោយព្រះរាជអាជ្ញា។

# មាត្រា ២៤៧៖ ដីកាដំណោះស្រាយ

*ចៅក្រមស៊ើបសួរ បិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះ អាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់។*

*ប្រសិនបើយល់ឃើញថា អំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរ សម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកា ត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។*

*ចៅក្រមស៊ើបសួរ ចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ:*

*១. អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ*

*២. ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់*

*៣. គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ*

*ដីកាដំណោះស្រាយ ជានិច្ចកាលត្រូវតែមានសំអាងហេតុ។ ចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ច គោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកា អាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះ ចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត។*

*ដីកាដំណោះស្រាយ ត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។*

## *ការអនុវត្តនៅអ.វ.ត.ក*

**ដីកាដំណោះស្រាយត្រូវតែកម្រិត ចំពោះអង្គហេតុ ដែលនៅក្រោមការស៊ើបសួរ៖** ចៅក្រមស៊ើបសួរ អាចលើកលែងចោទរឿងក្តី ដោយផ្អែកលើអង្គហេតុទាំងនេះ ឬអាចបញ្ជូនរឿងក្តីទៅជំនុំជម្រះ ប៉ុន្តែក្នុងករណីណាមួយក៏ដោយ សេចក្តីសម្រេច ត្រូវតែគាំទ្រ ដោយសំអាងហេតុ។

*រឿងក្តីឌុច៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ៥ ធ្នូ ២០០៨ កថាខណ្ឌ៣៧-៣៨។*

**អង្គបុរេជំនុំជម្រះ អាចបន្ថែមបទល្មើស ទម្រង់នៃការទទួលខុសត្រូវចូលទៅក្នុងដីកាដំណោះស្រាយបាន៖** ក្នុងការសម្រេចថា តើត្រូវបញ្ចូលបទល្មើស និងទម្រង់នៃការទទួល

ខុសត្រូវដែលព្រះរាជអាជ្ញាបានស្នើសុំ ឬមួយយ៉ាងណានោះ អង្គបុរេជំនុំជម្រះ មានសិទ្ធិធ្វើការសម្រេចដោយឯករាជ្យ នៅលើការកំណត់បទចោទ ដែលជាផ្នែកនៃការស៊ើបសួរ។ យ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះ មានកាតព្វកិច្ចអនុវត្តតាមវិធានដូចគ្នានឹងចៅក្រមស៊ើបសួរដែរ និងទៅតាមវិសាលភាពនៃកិច្ចស៊ើបសួរ។

*រឿងក្តី ឌុចៈ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ៥ ធ្នូ ២០០៨ កថាខណ្ឌ៤០ និង ៤៣-៤៤។*

**ដីកាដំណោះស្រាយ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍លើមូលដ្ឋានយុត្តាធិការ តែប៉ុណ្ណោះ៖** ការចេញដីកាដំណោះស្រាយ ដោយចៅក្រមស៊ើបសួរ គឺជាប្រធានបទនៃបណ្តឹងឧទ្ធរណ៍ ដែលអាចធ្វើដោយជនត្រូវចោទ ឬជនជាប់ចោទ។ ការជំទាស់ខាងយុត្តាធិការ គឺជាបណ្តឹងឧទ្ធរណ៍ដែលអាចទទួលយកបាន នៅដំណាក់កាលនេះតែប៉ុណ្ណោះ។ ការជំទាស់នឹងអង្គហេតុជាក់ស្តែងដូចជា និយមន័យ និងការអនុវត្តធាតុផ្សំនានានៃបទល្មើស ដែលបានចោទប្រកាន់ជាដើម ព្រមទាំងការជំទាស់ ដែលបានលើកឡើងចោទប្រកាន់ពីវិការៈក្នុងទម្រង់ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺមិនអាចទទួលយកបានទេ នៅក្នុងដំណាក់កាលសវនាការមុនអង្គសេចក្តី។

*រឿងក្តីនួន ជា និងអៀង ធីរិទ្ធៈ បណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១៥ កុម្ភៈ ២០១១ កថាខណ្ឌ ៥៩-៦៣។ រឿងក្តី អៀងសារីៈ បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ៤៤-៤៧។*

**អង្គជំនុំជម្រះសាលាដំបូង នៅតែអាចទទួលរឿងក្តី ទោះជាមានវិការៈ នៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក៏ដោយ៖** អង្គជំនុំជម្រះសាលាដំបូង នៅតែអាចទទួលរឿងក្តី បន្ទាប់ពីបានទទួលការជូនដំណឹងពីសេចក្តីសម្រេច របស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ។ លទ្ធផលនេះ មិនត្រូវបានប្រែប្រួលដោយសារតែការពន្យារពេលផ្តល់សំអាងហេតុនៃសេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ របស់អង្គបុរេជំនុំជម្រះទេ កាលណាលក្ខខណ្ឌតម្រូវ ស្តីពីពេលវេលាដទៃទៀតទាំងអស់ត្រូវបានបំពេញ។

*រឿងក្តី អៀង សារីៈ សំណើសុំដោះលែង អ.វ.ត.ក អ.ជ.ស.ដ ១២ ឧសភា ២០១១ កថាខណ្ឌ១០-១២។*

**អង្គជំនុំជម្រះ អាចចេញនូវសេចក្តីសម្រេចចុងក្រោយ ដោយមិនមានសំអាងហេតុ ដែលសំអាងហេតុនោះ ត្រូវបានដាក់ចេញតាមកាលបរិច្ឆេទ នៅពេលក្រោយ៖** អង្គបុរេជំនុំជម្រះ អាចធ្វើដូច្នេះ ដោយមិនមានការបំពានលើវិធានទាក់ទងនឹងការឃុំខ្លួនណាមួយឡើយ ដរាបណាសំអាងហេតុ ត្រូវបានដាក់បញ្ចូលតាម

ក្រោយ ក្នុងចិរវេលាមួយ ដែលវិធានផ្ទៃក្នុង អនុញ្ញាត សម្រាប់ការចេញសេចក្ដីសម្រេច មានសំអាងហេតុ។

*រឿងក្ដីខៀវ សំផនៈ បណ្ដឹងសាទុក្ខភ្ជាមៗលើ សំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ២២ និង៣៧។*

**ចៅក្រមស៊ើបសួរ ត្រូវតែផ្ដល់សំអាងហេតុៈ** ទោះបីជាចៅក្រមស៊ើបសួរ មិនបានត្រូវបាន តម្រូវឲ្យបញ្ជាក់ពីការយល់ឃើញលើកត្ដាទាំង អស់ ដែលបានពិចារណា ក្នុងដំណាក់កាល នៃការធ្វើសេចក្ដីសម្រេចរបស់ខ្លួន ចៅក្រម ស៊ើបសួរ ត្រូវតែផ្ដល់សំអាងហេតុសម្រាប់ សេចក្ដីសម្រេចរបស់ខ្លួន ដើម្បីឲ្យអ្នកដាក់ ពាក្យប្ដឹង អាចមានលទ្ធភាពធ្វើការកំណត់ ថា តើត្រូវប្ដឹងឧទ្ធរណ៍ និងផ្អែកលើមូលដ្ឋានអ្វី មួយ ដើម្បីឲ្យអង្គបុរេជំនុំជម្រះ អាចធ្វើការ ពិនិត្យលើបណ្ដឹងឧទ្ធរណ៍ឡើងវិញបាន ដោយ ប្រសិទ្ធភាព។

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធៈ បណ្ដឹងឧទ្ធរណ៍ស្ដីពីភាពទទួល យកបាននៃពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹង រដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៣៨។*

**"ភស្ដុតាងគ្រប់គ្រាន់" ដើម្បីចេញដីកាបញ្ជូនរឿង ទៅជំនុំជម្រះនោះ ទាមទារឲ្យមានលក្ខខណ្ឌអំពី លទ្ធភាពនៃភាពមានទោសៈ** អនុលោមតាម ការឆ្លុះបញ្ចាំងពីទំលាប់អនុវត្ដ ក្នុងបរិបទអន្ដរ ជាតិ និងជាតិ ការកំណត់ថា កាលណាមាន ភស្ដុតាងគ្រប់គ្រាន់នោះ អាចចេញដីកាបញ្ជូន រឿងទៅជំនុំជម្រះបាន ទាមទារឲ្យមានលក្ខ-ខណ្ឌអំពីលទ្ធភាពនៃភាពមានទោសនោះ គឺថា ភស្ដុតាង ត្រូវមានលក្ខណៈប្រាកដប្រជាគ្រប់ គ្រាន់ ព្រមទាំងអាចបញ្ជាក់បាន ក្នុងការ កំណត់អំពីកំរិតពិតប្រាកដ នៃអានុភាពចង្អុល បង្ហាញភស្ដុតាង។

**ដីកាដំណោះស្រាយ ជួយបំពេញនូវភាព ចន្លោះប្រហោងនៅអំឡុងពេលនៃដំណាក់ កាលស៊ើបអង្កេតៈ** ផ្ដល់នូវកិច្ចធានាខាងនីតិ វិធីដ៏ត្រឹមត្រូវដែលមានស្រាប់ តាមរយៈនៃ ដំណើរការស៊ើបអង្កេតទាំងមូល ដើម្បីការពារ ផលប្រយោជន៍ជនជាប់ចោទ និងធានានូវការ ស្វែងរកការពិត ព្រមទាំងផ្ដល់នូវឱកាសគ្រប់ គ្រាន់ដល់ភាគីនានា នៅអំឡុងពេលមុនការ ជំនុំជម្រះក្ដី ដើម្បីលើកឡើងនូវភាពចន្លោះ ប្រហោងណាមួយក្នុងការស៊ើបអង្កេត អង្គជំនុំ ជម្រះសាលាដំបូង នឹងមិនពិចារណាទៅលើ ភាពចន្លោះប្រហោង ដែលគេបានអះអាងថា បានកើតមានឡើងនៅអំឡុងពេល នៃដំណាក់ កាលស៊ើបអង្កេតនោះទេ ដោយសារតែបញ្ហា ទាំងនេះ ត្រូវបានគេចាត់ទុកថាបានកើតមាន ឡើង ដោយដីកាដំណោះស្រាយ។

*រឿងក្ដី នួន ជា អៀង សារី និងខៀវ សំផនៈ សេចក្ដីសម្រេច លើការស្នើសុំនៃក្រុមមេធាវី*

*ការពារទាក់ទង ទៅនឹងភាពមិនប្រក្រតីបាន អះអាងថា បានកើតមានឡើងអំឡុងពេលនៃការស៊ើបអង្កេត តាមផ្លូវតុលាការអ.វ.ត.ក អ.ជ.ស.ជ ១៥ ធ្នូ ២០១២ កថាខណ្ឌ ២១។*

*រឿងក្តី នួន ជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ ៤២។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក៖** វិធាន ៦៧។ វិធាននេះស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៤៧ លើកលែងតែវិធាន ៦៧(៤) ចែងពីសិទ្ធិរបស់ចៅក្រមស៊ើបសួរ ដែលមិនត្រឹមតែអាចបញ្ជូនផ្នែកនៃរឿងក្តីទៅជំនុំជម្រះទេ ប៉ុន្តែថែមទាំងអាចបញ្ជូនរឿងក្តីទៅជំនុំជម្រះចំពោះបុគ្គលមួយចំនួន និងអាចជាដីកាលើកលែងចោទប្រកាន់ ចំពោះបុគ្គលដទៃទៀត។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ការបញ្ចប់កិច្ចស៊ើបសួរ៖** ចៅក្រមស៊ើបសួរមានសិទ្ធិ និងករណីកិច្ចបញ្ចប់កិច្ចស៊ើបសួរ កាលណាខ្លួនយល់ឃើញថា បានបំពេញចប់ហើយ។

*លេខ65-92493 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ២៤៦ តុលាការកំពូលបារាំង ២៣ វិច្ឆិកា ១៩៦៥។*

**ចៅក្រមស៊ើបសួរ មិនត្រូវបានតម្រូវឲ្យដាក់បទចោទនៅមុនការចេញដីកាលើកលែងចោទប្រកាន់ទេ៖** កាលណាមានការលេចចេញយ៉ាងច្បាស់ ចំពោះចៅក្រមស៊ើបសួរថា បុគ្គលនោះមិនមានពិរុទ្ធភាពទេ។

*លេខ65-92493 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៤៦ តុលាការកំពូលបារាំង ២៧ វិច្ឆិកា ១៩៦៣។*

**កាលណាចៅក្រមស៊ើបសួរ យល់ថាការស៊ើបសួរបានបញ្ចប់៖** ចៅក្រមស៊ើបសួរ អាចផ្តល់ជាព័ត៌មានអំពីដីកាដំណោះស្រាយ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។

*លេខ65-90127 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៥០ តុលាការកំពូលបារាំង ១៧ ឧសភា ១៩៦៦។*

**ផលវិបាក នៃអវត្តមានដីកាដំណោះស្រាយ នៅមុនពេលចៅក្រម សម្រេចបញ្ជូនបុគ្គលនោះ ទៅចំពោះមុខអង្គជំនុំជម្រះ៖** ករណីនេះអនុញ្ញាតឲ្យចុងចោទប្តឹងពីនីតិវិធីស៊ើបសួរ ថាមិនមានសុពលភាព។

*លេខ 02-85180/03-83598 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៨០ តុលាការកំពូលបារាំង ៣០ មីនា ២០០៤។*

**ដីកាសម្រេច ដែលបដិសេធតែគុណវុឌ្ឍិនៃអង្គហេតុនៅក្នុងសេចក្ដីសន្និដ្ឋានរបស់រដ្ឋអាជ្ញា មិនអាចត្រូវបានចាត់ទុកថា ជាដីកាសម្រេចលើកលែងការចោទប្រកាន់បាននោះទេ៖** អង្គជំនុំជម្រះ មិនត្រូវបានភ្ជាប់កាតព្វកិច្ចទៅនឹងគុណវុឌ្ឍិ ដែលបានផ្ដល់ឲ្យដោយចៅក្រមស៊ើបសួរ ចំពោះអង្គហេតុនោះទេ។

*ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១០ តុលាការកំពូលបារាំង ១២ មករា១៩៨៤។*

**ចៅក្រមស៊ើបសួរ ត្រូវពិចារណាលើរាល់សេចក្ដីសន្និដ្ឋានរបស់ភាគីទាំងអស់ នៅពេលរៀបចំដីកាដំណោះស្រាយ៖** ចៅក្រមស៊ើបសួរ គប្បីចៀសវាងគ្រាន់តែចម្លងតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា។

*លេខ10-85678 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ១ តុលាការកំពូលបារាំង ១៩ មិថុនា ២០១២។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖ មាត្រា១៧៥ ១៧៧ និង១៨០។ មាត្រាទាំងនេះ បង្កើតនីតិវិធីនៅពេលបញ្ចប់កិច្ចស៊ើបសួរ រួមទាំងការចេញដីកាដំណោះស្រាយផង។

# មាត្រា ២៤៩៖ សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ

*ដីកាដំណោះស្រាយ បញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន។ ក្នុងករណីនេះ បទប្បញ្ញត្តិនៃមាត្រា ២៧៦ (ការដោះលែងជនត្រូវចោទដែលជាប់ឃុំឱ្យមានសេរីភាព) នៃក្រមនេះ ត្រូវយកមកអនុវត្ត។*

*ប៉ុន្តែ តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរ អាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរ ត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ។*

*សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្តោះអាសន្ន លែងមានអានុភាពក្នុងរយៈពេល ៤(បួន)ខែ។ ប្រសិនបើជនត្រូវចោទ មិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤(បួន)ខែនោះទេ ជនត្រូវចោទនេះ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង។*

*ដីកាដំណោះស្រាយ បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។*

*កាលណាចៅក្រមស៊ើបសួរ បានដាក់កំហិតដល់ជនត្រូវចោទ ឱ្យបង់ប្រាក់ធានាឱ្យប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬឱ្យប្រគល់អាវុធ ដែលមិនទាក់ទងនឹងបទល្មើស ប្រាក់ធានា ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬអាវុធនោះ ត្រូវប្រគល់សងសាមីខ្លួនវិញដោយក្រឡាបញ្ជី ដោយមានបង្កាន់ដៃទទួលដែលចុះហត្ថលេខាដោយជនត្រូវចោទទុកជាសំគាល់។*

*ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរ អាចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួន នៅចំពោះមុខតុលាការ។*

## ការអនុវត្តនៅអ.វ.ត.ក

**ដីកាឃុំខ្លួនបណ្តោះអាសន្ន ដែលបានចេញក្រោយដីកាដំណោះស្រាយ គឺមិនចំណុះដីកាដំណោះស្រាយទេ៖** ចិរវេលាកម្រិតរយៈពេល ៤ខែ សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នក្រោយពេលចេញដីកាដំណោះស្រាយ គឺត្រូវបានគិតដាច់ដោយឡែក ពីចិរវេលាកម្រិតលើការឃុំខ្លួនដទៃទៀត។

*រឿងក្តីអៀង សារី៖ សំណើសុំដោះលែង អ.វ.ត.ក អ.ជ.ស.ជ ១២ ឧសភា ២០១១ កថាខណ្ឌ១០។*

**ដីកាសម្រេចឃុំខ្លួន ត្រូវតែមានសំអាងហេតុ៖** កាលណាមានដីកាសម្រេចពន្យារការឃុំខ្លួន ភ្ជាប់មកជាមួយនឹងដីកាដំណោះស្រាយ ដីកានោះត្រូវតែមានសំអាងហេតុ សម្រាប់ការពន្យារការឃុំខ្លួន។ បើដីកានោះ មិនមានសំអាងហេតុទេ នោះសិទ្ធិរបស់ជនត្រូវចោទត្រូវបានបំពានហើយ។

*រឿងក្តី អៀង សារី៖ សំណើសុំដោះលែង អ.វ.ត.ក អ.ជ.ស.ជ ១២ ឧសភា ២០១១ កថាខណ្ឌ១១-១២។*

**ការដោះលែងភ្លាមៗ មិនអាចជួសជុលការខកខានមិនបានបញ្ចូលនូវសំអាងហេតុទេ៖** កាលណាមានដីកាសម្រេចពន្យារពេលការឃុំខ្លួន ដែលមិនមានសំអាងហេតុ កំហុសនៃអង្គច្បាប់នេះ មិនអាចត្រូវបានជួសជុលជាចាំបាច់ ដោយការដោះលែងភ្លាមៗឡើយ។ ដំណោះស្រាយក៏អាចត្រូវបានពិចារណានៅចុងបញ្ចប់នៃការជំនុំជម្រះ។

*រឿងក្តីអៀង សារី៖ សំណើសុំដោះលែង អ.វ.ត.ក អ.ជ.ស.ជ ១២ ឧសភា ២០១១ កថាខណ្ឌ ១២។*

**នៅក្នុងការចេញដីកាសម្រេចពន្យារពេលការឃុំបណ្តោះអាសន្ន មិនចាំបាច់មានកត្តាទាំងអស់ដែលមានចែង នៅក្នុងមាត្រា ២០៥ នោះទេ៖** ដីកាសម្រេចពន្យារពេលការឃុំខ្លួន មិនមែនមិនសមស្របនោះទេ ព្រោះថាមានកត្តាមួយចំនួនប៉ុណ្ណោះ ដែលមិនអនុវត្តចំពោះការពន្យារចិរវេលា។

*រឿងក្តីឌុច៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ៥ ធ្នូ ២០០៨ កថាខណ្ឌ១៤៥-១៤៧។*

**សេចក្តីសម្រេចពីមុនៗ ក៏អាចត្រូវបានយកមកពិចារណាទាក់ទងនឹងការបន្តការឃុំខ្លួន៖** នៅពេលដែលមានការកំណត់ ថាតើអង្គហេតុនានានៅក្នុងរឿងក្តីមួយ បង្កើតបានជាមូលហេតុមានសុពល ដើម្បីបន្តការឃុំខ្លួនបណ្តោះអាសន្ន ឬយ៉ាងណានោះ អង្គជំនុំជម្រះអាចនឹងពិចារណាលើសេចក្តីសម្រេចពីមុនៗ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន ក្នុងដីកាដំណោះស្រាយ*

*អ.វ.ត.ក អ.ប.ជ ២១ មករា ២០១១ កថាខណ្ឌ ៣២។*

**ភាពចាំបាច់ ដើម្បីថ្លឹងថ្លែងអំពីការឃុំខ្លួនទៅនឹងសេរីភាព៖** តុលាការ ត្រូវតែថ្លឹងថ្លែងទៅលើមូលហេតុ សម្រាប់ការឃុំខ្លួនបណ្ដោះអាសន្ន ដោយត្រូវប្រៀបធៀបជាមួយនឹងសិទ្ធិមានសេរីភាពផ្ទាល់ខ្លួន។ សច្ចធារណ៍នៃសេរីភាពតម្រូវឲ្យការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវតែមានមូលដ្ឋាន នៅក្នុងសេចក្ដីសម្រេចរបស់តុលាការដែលបានចេញស្របនឹងនីតិវិធី និងលក្ខខណ្ឌដែលច្បាប់តម្រូវ។

*រឿងក្ដីខៀវ សំផន៖ បណ្ដឹងសាទុក្ខក្ខាមៗស្ដីពីការស្នើសុំឲ្យដោះលែង នៅក្រៅឃុំជាបណ្ដោះអាសន្ន៖ អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៧ និង៥៦។ រឿងក្ដីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ៨០។ រឿងក្ដីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ២២។ រឿងក្ដីនួន ជា៖ សេចក្ដីសម្រេចលើកទី២ ស្ដីពីសម្បទារបស់នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ១៦។ រឿងក្ដីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្ដីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល) អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១៣ កថាខណ្ឌ១។ រឿងក្ដីអៀង ធីរិទ្ធ៖ សេចក្ដីសម្រេច លើបណ្ដឹងឧទ្ធរណ៍ក្ខាមៗប្រឆាំងទៅនឹងដីកាសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទនៅក្នុងការឃុំឃាំង ដោយមានលក្ខណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធី និងការដោះលែង ដោយឥតលក្ខខណ្ឌ ចំពោះបុគ្គលពាក់ព័ន្ធ គឺចៀសមិនផុតពីផលវិបាកឡើយ)។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៨។ វិធាននេះស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៤៩ ទោះបីជាវិធាននេះ ចែងយ៉ាងច្បាស់អំពីស្ថានភាពដែលជនជាប់ចោទ មិនអាចចូលទៅបង្ហាញខ្លួន នៅចំពោះមុខតុលាការបាន ដោយសារតែកាលៈទេសៈលើកលែងមួយចំនួនក៏ដោយ ចំណែកមាត្រា ២៤៩ មានចែងពីបទប្បញ្ញត្តិលម្អិតទាក់ទងនឹងការប្រគល់ប្រាក់ធានាឲ្យនៅក្រៅឃុំ ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ និងអាវុធសងទៅឲ្យសាមីខ្លួនវិញ។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

**គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប**

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលប្បញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ការរំលោភបំពាន៖ ការបន្តឃុំខ្លួន បន្ទាប់ពីមានដីកាសម្រេចឲ្យដោះលែង៖** ការបន្តឃុំខ្លួនបុគ្គលណាម្នាក់ បន្ទាប់ពីការចេញដីកាសម្រេចដោះលែង រយៈពេលមួយឆ្នាំ រួមទាំងដីកាដោះលែងដោយមានលក្ខខណ្ឌ គឺជាការឃុំខ្លួនខុសច្បាប់។

> *រឿងក្តី TERÁN JIJÓN និងTERÁN JIJÓNទល់នឹងប្រទេសអេក្វាឌ័រ គណៈកម្មធិការសិទ្ធិមនុស្ស អ.ស.ប ២៦ មីនា ១៩៩២ កថាខណ្ឌ៦.៣ (គោលការណ៍ទូទៅ)។ រឿងក្តី BAZZANOទល់នឹងប្រទេស អ៊ុយរុយហ្គាយ គណៈកម្មធិការសិទ្ធិមនុស្ស អ.ស.ប ១៩ សីហា ១៩៧៩ កថាខណ្ឌ២ និង១០(i) (ដីកាដោះលែងដោយមានលក្ខខណ្ឌ)។*

**ការរំលោភបំពាន៖ ការពន្យារពេលបួនឆ្នាំ ដោយមិនបានពន្យល់អំពីហេតុផល ចន្លោះពីពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងពេលចេញសាលក្រមសាលាដំបូង៖** ការពន្យារពេលបួនឆ្នាំ ចន្លោះពីពេលដែលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការចេញសាលក្រមរបស់សាលាដំបូង ដោយមិនមានការពន្យល់អំពីភាពស្មុគស្មាញនៃរឿងក្តី ដែលចាំបាច់ដល់ការអូសបន្លាយ នូវពេលវេលាបែបនេះ គឺជាការរំលោភទៅលើលក្ខខណ្ឌ ដែលចែងថា ជនជាប់ចោទត្រូវទទួលបានការជំនុំជម្រះ ដោយមិនមានការអូសបន្លាយពេលវេលាយូរ។

> *រឿងក្តី FILLASTRE ទល់នឹងប្រទេសបូលីវី គណៈកម្មធិការសិទ្ធិមនុស្ស អ.ស.ប ៥ វិច្ឆិកា ១៩៩១ កថាខណ្ឌ៦.៦។*

**មាត្រាស្រដៀងគ្នានៅក្នុង*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*៖** មាត្រា ៩(១) មាត្រា ៩(៣) និងមាត្រា ១៤(៣)(គ)។ មាត្រា ៩(១) ហាមឃាត់មិនឲ្យឃុំខ្លួនតាមអំពើចិត្ត ចំណែកមាត្រា ៩(៣) តម្រូវឲ្យជនណាដែលត្រូវបានឃុំខ្លួនត្រូវនាំខ្លួនមកចំពោះមុខចៅក្រមភ្លាម។ មាត្រា ១៤(៣)(គ) តម្រូវឲ្យជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេលយូរហួសហេតុ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**សេចក្តីសម្រេចបន្តឃុំខ្លួន ជនត្រូវចោទជាបណ្តោះអាសន្ន ត្រូវចាត់ទុកជាមោឃៈ បន្ទាប់ពីកិច្ចស៊ើបសួរត្រូវបានបិទ ក្នុងរយៈពេលពីរខែរួចមក៖** រយៈពេលនេះ ចាប់គិតពីថ្ងៃចេញដីកាដំណោះស្រាយ ទោះបីជាដីកាដំណោះស្រាយនេះ ត្រូវបានប្តឹងឧទ្ធរណ៍ក៏ដោយ។

*លេខ10-83656 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១២៥ តុលាការកំពូលបារាំង ១៨ សីហា ២០១០ លេខ 01-80234/04-82857 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៧៩ តុលាការកំពូលបារាំង ៨ កក្កដា ២០០៤។ លេខ71-92789 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣៣៦ តុលាការកំពូលនៃបារាំង ២ ធ្នូ ១៩៧១។*

**ការឃុំខ្លួនជនត្រូវចោទត្រូវបញ្ចប់ បន្ទាប់ពីផុតរយៈពេលពីរខែ៖** ហើយប្រសិនបើជនត្រូវចោទ មិនបានចូលខ្លួនមកចំពោះមុខតុលាការ។

*លេខ 02-86951 តុលាការកំពូលបារាំង ១៥ មករា ២០០៣។*

**មានតែចៅក្រមស៊ើបសួរទេ ទើបអាចចេញដីកាបញ្ចប់ ឬពន្យារការឃុំខ្លួនបណ្តោះអាសន្នបាន៖** ចៅក្រមស៊ើបសួរ អាចធ្វើដូច្នេះបាន នៅពេលណាដែលគាត់បញ្ជូនសំណុំរឿង ទៅតុលាការអប់រំកែប្រែ។

*លេខ 85-95517 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៧ តុលាការកំពូលបារាំង ២១ មករា ១៩៨៦។*

**នៅពេលតុលាការ ពន្យារពេលសវនាការទៅថ្ងៃក្រោយទៀត ជនត្រូវចោទ ដែលចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវទទួលបានការដោះលែង៖** ប៉ុន្តែតុលាការ អាចបន្តឃុំខ្លួនជនត្រូវចោទបាន ក្នុងករណីដែលតុលាការសម្រេច និងផ្តល់យុត្តិកម្មចំពោះការសម្រេចបែបនេះ។

*លេខ77-92579 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៩២ តុលាការកំពូលបារាំង ១៣ មីនា ១៩៧៨។*

**ការពិនិត្យឡើងវិញជាស្វ័យប្រវត្តិ ក្នុងការការឃុំខ្លួនបណ្តោះអាសន្ន៖** បន្ទាប់ពីមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជនត្រូវចោទដែលបានឃុំខ្លួនបណ្តោះអាសន្ន ត្រូវចូលខ្លួនមកចំពោះមុខតុលាការព្រហ្មទណ្ឌ ឬត្រូវទទួលការបន្តឃុំខ្លួនបណ្តោះអាសន្នមួយឆ្នាំ គិតពីថ្ងៃដីកាដំណោះស្រាយចូលជាស្ថាពររួចមក។

*លេខ 05-86295 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣០៣ តុលាការកំពូលបារាំង ២៧ វិច្ឆិកា ២០០៥។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ១៧៩ និងមាត្រា ១៨១។ មាត្រាទាំងនេះ កំណត់អំពីលក្ខខណ្ឌតម្រូវនៃដីកាដំណោះស្រាយ រួមទាំងទំនាក់ទំនងនៃដីកាដំណោះស្រាយ ជាមួយនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ។

# មាត្រា ២៥០៖ ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

*បន្ទាប់ពីចៅក្រមស៊ើបសួរ សម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។*

## ការអនុវត្តនៅអ.វ.ត.ក

**អង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ក្នុងអំឡុងពេលប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖** ក្នុងករណីដែលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ អង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ក្នុងអំឡុងពេលមានការប្តឹងឧទ្ធរណ៍ ដើម្បីត្រៀមរៀបចំការបើកសវនាការ ទោះបីជាអង្គជំនុំជម្រះសាលាដំបូង មិនទាន់បានទទួលសំណុំរឿង រហូតដល់ពេលចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្តី។

*រឿងក្តីឌុចៈ សាលក្រម អ.វ.ត.ក អ.ជ.ស.ដ ២៦ កក្កដា ២០១០ កថាខណ្ឌ៣៧។*

**ឯកសារទាំងអស់ ត្រូវបានចាត់ទុកជាភស្តុតាងបាន លុះត្រាតែឯកសារនោះ ត្រូវបានបង្ហាញនូវអត្តសញ្ញាណកម្ម នៅក្នុងតុលាការ និងបានបំពេញបទដ្ឋានជាអប្បបរមាជាមុនសិន៖** ឯកសារនៅក្នុងសំណុំរឿង មិនត្រូវបានចាត់ទុកជាភស្តុតាងនៅឡើយទេ ទោះបីជាឯកសារនោះត្រូវបានបញ្ជូនមកឲ្យអង្គជំនុំជម្រះសាលាដំបូងក៏ដោយ រហូតទាល់តែ (i)ឯកសារនោះត្រូវបានអានជូនតុលាការស្តាប់ ឬត្រូវបានបង្ហាញអត្តសញ្ញាណយ៉ាងត្រឹមត្រូវ នៅក្នុងតុលាការ និង (ii) បានបំពេញនូវលក្ខខណ្ឌ អប្បបរមានៃភស្តុតាងរួចរាល់សិន។

*រឿងក្តីឌុចៈ សាលក្រម អ.វ.ត.ក អ.ជ.ស.ដ ២៦ កក្កដា ២០១០ កថាខណ្ឌ៤០ ដល់៤១។*

**ទិន្នន័យនៅក្នុងសំណុំរឿង អាចត្រូវបានបន្ថែម៖** ការបន្ថែមទិន្នន័យនេះ គឺអាចធ្វើបានទោះបីជាសំណុំរឿងត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងរួចហើយក៏ដោយ។

*រឿងក្តីឌុចៈ សាលក្រម អ.វ.ត.ក អ.ជ.ស.ដ ២៦ កក្កដា ២០១០ កថាខណ្ឌ៤០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៩។ វិធាននេះស្រដៀងគ្នាទៅនឹងមាត្រា ២៥០ លើកលែងតែត្រង់ចំណុចដែលថា វិធាននេះយោងលើនីតិវិធីក្នុងករណី ដែលមានការចេញដីកាលើកលែងការចោទប្រកាន់។ វិធាន ៦៩ ក៏ចែងផងដែរថា ត្រូវបោះត្រាលើសំណុំរឿង នៅពេលដែលគ្មានបណ្តឹងឧទ្ធរណ៍ ចំណែកឯមាត្រា ២៥០ មិនមានចែងអំពីបញ្ហានេះទេ។

# មាត្រា ២៥២៖ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

*វិធាន និងទម្រង់ការដែលចែងដោយមាត្រាខាងក្រោម ស្តីអំពីបទប្បញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នោះទេ នឹងនាំឱ្យមានមោឃភាពនៃនីតិវិធី៖*

- *មាត្រា ១២២ (ការបើកការស៊ើបសួរ)*
- *មាត្រា ១២៣ (សមត្ថកិច្ចដែនដី)*
- *កថាខណ្ឌទី៣ នៃមាត្រា ១២៤ (ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ)*
- *កថាខណ្ឌទី១ និងទី២នៃមាត្រា ១២៥ (វិសាលភាពនៃការប្តឹង)*
- *មាត្រា ១២៨ (ជំនួយការរបស់ក្រឡាបញ្ជី) នៃក្រមនេះ*

*នឹងនាំឱ្យមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌ ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ។ វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះ មានជាអាទិ៍គឺវិធានទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន។*

## ការអនុវត្តនៅអ.វ.ត.ក

**តុលាការមានកាតព្វកិច្ច ក្នុងការធានាការពារដល់ភាពត្រឹមត្រូវ នៃកិច្ចដំណើរការនីតិវិធី៖** ចំណុចនេះ ផ្តល់នូវអាណត្តិមួយផ្នែកឲ្យមានប្រព្រឹត្តកម្មដូចៗគ្នា នៅចំពោះមុខតុលាការ សម្រាប់អ្នកដែលស្ថិតក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីភាពទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៣៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ២១។ ជាទូទៅ វិធាននេះទាក់ទងនឹងមាត្រា ២៥២ ដែលចែងថា កិច្ចដំណើរការនីតិវិធីត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍តទល់គ្នា ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ហើយបុគ្គលដែលយល់ឃើញថា ខ្លួនស្ថិតនៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា និងដែលត្រូវបានចោទប្រកាន់ចំពោះបទល្មើសតែមួយដូចគ្នា ត្រូវទទួលបានការប្រព្រឹត្តឲ្យស្របនឹងវិធាននេះ។

# មាត្រា ២៥៣៖ ការប្តឹងទៅសភាស៊ើបសួរ

*មានតែសភាស៊ើបសួរប៉ុណ្ណោះ ដែលមានសមត្ថកិច្ច ដើម្បីពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី។ ប្រសិនបើចៅក្រមស៊ើបសួរ យល់ឃើញថា ផ្នែកណាមួយនៃនីតិវិធីមានមោឃភាព ចៅក្រមស៊ើបសួរនេះ ប្តឹងទៅសភាស៊ើបសួរតាមដីកាដោយមានសំអាងហេតុ និងជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី។*

*ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា ផ្នែក(លិខិត)ណាមួយនៃនីតិវិធីមានមោឃភាព ព្រះរាជអាជ្ញាធ្វើពាក្យសុំដោយមានសំអាងហេតុ បញ្ជូនទៅសភាស៊ើបសួរ និងជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ។*

*ប្រសិនបើជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា លិខិតណាមួយនៃនិតិវិធីមានមោឃភាព សាមីជនធ្វើពាក្យសុំដោយមានសំអាងហេតុជូនទៅសភាស៊ើបសួរ និងជូនដំណឹងដល់ចៅក្រមស៊ើបសួរ។ ពាក្យសុំអាចធ្វើដោយមេធាវីរបស់ជនត្រូវចោទ ឬរបស់ដើមបណ្តឹងរដ្ឋប្បវេណី។*

*ពាក្យសុំដែលចែងនៅក្នុងមាត្រានេះ ត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ភ្លាមនោះ ក្រឡាបញ្ជីសុំឱ្យចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងនៃនីតិវិធីមកឱ្យខ្លួនភ្លាម។*

*ដីកាដែលអាចត្រូវប្តឹងឧទ្ធរណ៍បាន មិនអាចធ្វើជាកម្មវត្ថុនៃបណ្តឹងសុំមោឃភាពបានឡើយ។*

## ការអនុវត្តនៅអ.វ.ត.ក

**សំណើសុំត្រូវតែបង្ហាញ ផ្នែកដែលមានកំហុសនៃកិច្ចដំណើរការនីតិវិធី និងផ្តល់ភស្តុតាងអំពីការរំលោភនោះ៖** សំណើសុំឲ្យធ្វើមោឃភាព មិនគ្រាន់តែចង្អុលបង្ហាញអំពីកំហុសខាងនីតិវិធីប៉ុណ្ណោះទេ ក៏ប៉ុន្តែ ត្រូវផ្តល់ជូននូវភស្តុតាង ដែលបង្ហាញថា កំហុសទាំងនោះបានបណ្តាលឲ្យមានការរំលោភសិទ្ធិ របស់ភាគីដែលស្នើសុំផងដែរ។ សំណើសុំក៏ត្រូវកំណត់អត្តសញ្ញាណពីផ្នែកនៃកិច្ចដំណើរការនីតិវិធី ដែលចោទថាមានកំហុស និងត្រូវផ្តល់ទឡ្ហីករណ៍ ចំពោះការអះអាងបែបនេះ។

*រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍សុំឲ្យធ្វើមោឃភាព អ.វ.ត.ក អ.ប.ជ ២៦ សីហា ២០០៨ កថាខណ្ឌ៣៤-៣៥។ រឿងក្តីនួន ជា និងអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីកោះហៅ សាក្សី អ.វ.ត.ក អ.ប.ជ ៨ មិថុនា ២០១០ កថាខណ្ឌ៣៨។ រឿងក្តីនួន ជា អៀង សារី និងខៀវ សំផន៖ ការស្នើសុំឲ្យមានកិច្ចស៊ើបអង្កេតតាមវិធាន៣៥ នៃវិធានផ្ទៃក្នុងដែលទាក់ទងទៅនឹងភាពមិនស៊ីសង្វាក់គ្នា ទៅនឹងកំណត់ហេតុជាសម្លេង និងជាលាយលក្ខណ៍*

*អក្សរ នៃការសម្ភាសន៍សាក្សី របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១២ កថាខណ្ឌ១០-១៨។*

ការស្នើសុំលុបចោលផ្នែកខ្លះៗ នៃសំណុំរឿង ត្រូវបានធ្វើឡើង នៅដំណាក់កាលស៊ើបអង្កេតៈ ភាពចន្លោះប្រហោងក្នុងការស៊ើបអង្កេត អាចត្រូវបានពិចារណា តែនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតប៉ុណ្ណោះ កាលណាភាគីមានបញ្ហាអាចបង្ហាញថា ខ្លួនមិនមានឱកាសនឹងរកឲ្យឃើញនូវចំណុចណាមួយ ដែលបានលើកឡើង ក្នុងការទាមទារឲ្យមានការលុបចោលមុនពេលដែលការជំនុំជម្រះក្ដី ត្រូវបានបើកដំណើរការ។

*រឿងក្ដីនួន ជាៈ អៀង សារី និងខៀវ សំផនៈ ការស្នើសុំឲ្យមានកិច្ចស៊ើបអង្កេត តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងដែលទាក់ទងទៅនឹងភាពមិនស៊ីសង្វាក់គ្នា ទៅនឹងកំណត់ហេតុជាសម្លេង និងជាលាយលក្ខណ៍អក្សរនៃការសម្ភាសន៍សាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១២ កថាខណ្ឌ១០-១៨។*

**ការរំលោភសិទ្ធិ ដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយៈ** ការរំលោភសិទ្ធិបែបនោះ អាចចាត់ទុកថាជាកំហុសនីតិវិធី។

*រឿងក្ដីនួន ជាៈ បណ្ដឹងឧទ្ធរណ៍សុំឲ្យធ្វើមោឃភាព អ.វ.ត.ក អ.ប.ជ ២៦ សីហា ២០០៨ កថាខណ្ឌ៤០។*

**ប្រសិនបើ សិទ្ធិណាមួយត្រូវបានរំលោភ នៅពេលទទួលបានភស្តុតាង ភស្តុតាងនោះមិនអាចបដិសេធ ដោយស្វ័យប្រវត្តិបានទេៈ** តែផ្ទុយទៅវិញ តុលាការនឹងថ្លឹងថ្លែងទៅលើកត្តាដាក់ទម្ងន់ផ្សេងៗ ឧទាហរណ៍ភាពគួរឲ្យជឿជាក់បាននៃភស្តុតាងនោះ និងការប៉ះពាល់ធ្ងន់ធ្ងរទៅលើរឿងក្ដី មុននឹងធ្វើការសម្រេចទៅលើភាពអាចទទួលយកបាននៃភស្តុតាងនោះ។

*រឿងក្ដីនួន ជាៈ បណ្ដឹងឧទ្ធរណ៍សុំឲ្យធ្វើមោឃភាព អ.វ.ត.ក អ.ប.ជ ២៦ សីហា ២០០៨ កថាខណ្ឌ៤១។*

**ការកំណត់ថា តើឯកសារនោះបង្កើតបានជា "ផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី" ដែរឬទេៈ** មាត្រា ២៥៣ចែងថាៈ "ផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី "អាចជាកម្មវត្ថុនៃការស្នើសុំឲ្យធ្វើមោឃភាព។ នេះជាការបកស្រាយមិនច្បាស់លាស់នៃពាក្យពេជន៍ ជាភាសាបារាំងថា"*Pièces de la Procédure*" តែទោះជាយ៉ាងណា គួរត្រូវបានយកមកអនុវត្ត។ "*Pièces de la Procédure*" កើតចេញពីកិច្ចដែលបំពេញឡើង ដោយចៅក្រមស៊ើបសួរតែឯង ឬពីតំណាងអាជ្ញាធរតុលាការ។ ឯកសារដែល

ជាក់ដោយភាគី ឬសាក្សីមិនបង្កើតបានជា *Pièces de la Procédure* នោះទេ ហើយហេតុដូច្នេះ មិនមែនជាកម្មវត្ថុនៃការធ្វើមោឃភាពនៅក្រោមមាត្រា២៥៣ទេ។

*រឿងក្តីឌុចៈ ភាពអាចទទួលយកបាន នៃភស្តុតាង អ.វ.ត.ក អ.ជ.ស.ជ ២៦ សីហា ២០០៨ កថាខណ្ឌ៩ ដល់១១។*

**សំណើសុំឲ្យធ្វើមោឃភាព ទៅលើកិច្ចស៊ើបសួរទាំងមូលៈ** សំណើសុំបែបនេះមិនអាចទទួលយកបានទេ។

*រឿងក្តីខៀវ សំផនៈ បណ្តឹងឧទ្ធរណ៍សុំឲ្យធ្វើមោឃភាព អ.វ.ត.ក អ.ប.ជ ៤ ឧសភា ២០១០ កថាខណ្ឌ២៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.កៈ** វិធាន ៤៨ ៧៣(ខ) ៧៦(១) ៧៦(២) ៧៦(៣) និងវិធាន ៧៦(៤)។ វិធានទាំងនេះ គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៥៣ លើកលែងតែវិធាន ៤៨ កំហិតយ៉ាងច្បាស់ចំពោះការដាក់ពាក្យសុំទាំងឡាយក្នុងករណីដែលសិទ្ធិរបស់ភាគីស្នើសុំ ត្រូវបានរំលោភដោយវិការៈនេះ ហើយវិធាន ៧៦(២) តម្រូវឲ្យដីកាបែបនេះ ត្រូវចេញឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងនៅមុនការចេញដីកាដំណោះស្រាយ ហើយក៏ត្រូវលើកឡើងឲ្យបានច្បាស់លាស់ផងដែរថា ដីកាបែបនេះ អាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បាន។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**កម្មវត្ថុនៃសំណើសុំឲ្យធ្វើមោឃភាព ដែលបានប្តឹងនៅចំពោះមុខសភាស៊ើបសួរៈ** សំណើបែបនេះ ត្រូវតែពាក់ព័ន្ធទៅនឹងទង្វើ ឬផ្នែកណាមួយនៃនីតិវិធី ហើយត្រូវតែមានមូលដ្ឋានទៅលើការរំលោភលក្ខខណ្ឌនៃកិច្ចដំណើរការនីតិវិធី។

*លេខ 08-83261 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ៦៧ តុលាការកំពូលបារាំង ៧ មេសា ២០០៩។*

**ផលប៉ះពាល់នៃការប្រកាសមោឃភាពៈ** ការបង្ហាញភស្តុតាងនៅក្នុងបណ្តឹង ដោយអ្នកដាក់សំណើសុំ និងការបង្ហាញព្យសនកម្មពិតប្រាកដដែល ប៉ះពាល់ដល់ផលប្រយោជន៍នៃការការពារក្តី។

*លេខ 99-82369 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ៣០៤ តុលាការកំពូលបារាំង ១៤ ធ្នូ ១៩៩៩។*

**ស្ថានភាព ដែលអាចផ្តល់យុត្តិកម្មបាន ចំពោះការធ្វើមោឃភាពៈ** ការខ្វះអនាគតិភាព ក្នុងកិច្ចស៊ើបសួរ ការមិនផ្តល់លទ្ធភាពឲ្យមេធាវីការពារក្តី ទទួលបានសំណុំរឿងទាំងមូល នៅពេលមានការស្នើសុំការ **ខកខានមិនបានផ្តល់ដំណឹង ដល់មេធាវី អំពីការ**

ពិភាក្សាដេញដោល ទៅលើការពន្យារការឃុំខ្លួន ភាពមិនប្រក្រតី នៃទង្វើទាក់ទងនឹងតតីយភាគីដែល យ៉ាងហោចណាស់ ក៏ទង្វើនោះបានបង្កព្យសនកម្ម ដល់ផលប្រយោជន៍របស់អ្នកដាក់សំណើសុំដែរ។

*តុលាការកំពូលបារាំងលេខ08-80483 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១១៥ ១៤ ឧសភា ២០០៨ (អនាគតិភាពនៃកិច្ចស៊ើបសួរ)។ លេខ81-94393 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៧១ តុលាការកំពូលបារាំង ៩ កុម្ភៈ ១៩៨២ (លទ្ធភាពដែលអាចទទួលបាន ចំពោះសំណុំរឿងទាំងមូល)។ លេខ 07-86794 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៩៧ តុលាការកំពូលបារាំង ៤ ធ្នូ ២០០៧ (ការជូនដំណឹង ដល់មេធាវី) លេខ06-84869 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២០៨ តុលាការកំពូលបារាំង ៦ កញ្ញា ២០០៦ (ទង្វើទាក់ទងទៅនឹងតតីយភាគី)។*

**ការរំលោភលក្ខខណ្ឌ ស្តីពីពេលវេលាសមស្រប៖** ការរំលោភបែបនេះ មិនធ្វើឲ្យកិច្ចដំណើរការនីតិវិធីមានមោឃភាពទេ។

*លេខ92-83443 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៥៧ តុលាការកំពូលបារាំង ៣ កុម្ភៈ ១៩៩៣។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា ១៧២ និងមាត្រា ១៧៣។ មាត្រាទាំងនេះ ចែងពីការបញ្ជូនសំណើសុំឲ្យធ្វើមោឃភាពទៅកាន់សភាស៊ើបសួរ និងភាពអាចទទួលយកបាននៃសំណើសុំបែបនេះ។

# មាត្រា ២៥៧៖ បញ្ជីបណ្តឹងឧទ្ធរណ៍ និងពាក្យសុំ

*ត្រូវបើកឱ្យមានការកាន់បញ្ជីបណ្តឹងឧទ្ធរណ៍ និងពាក្យសុំមួយនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បន្ទាប់ពីបានទទួលពាក្យប្តឹងឧទ្ធរណ៍ ឬពាក្យសុំ ក្រឡាបញ្ជីនៃសភាស៊ើបសួរ ត្រូវតែឱ្យដំណឹងភ្លាមទៅចៅក្រមស៊ើបសួរ។*

*កាលណាសភាស៊ើបសួរ ត្រូវបានប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំ ក្រឡាបញ្ជីនៃសភាស៊ើបសួរ សុំឱ្យក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ ផ្ញើមកឱ្យខ្លួននូវសំណុំរឿងនៃនីតិវិធី ឬសំណុំរឿងបង្ការទុក។*

## *ការអនុវត្តនៅអ.វ.ត.ក*

**មានតែភាគីប៉ុណ្ណោះ ទើបអាចស្តាប់ចម្លើយបាន៖** មានតែភាគីនៃរឿងក្តីប៉ុណ្ណោះ ទើបមានសិទ្ធិត្រូវបានស្តាប់ចម្លើយ នៅក្នុងបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ភាគីដែលគ្មានឈ្មោះ មិនមានសិទ្ធិដាក់សារណា នៅក្នុងបណ្តឹងឧទ្ធរណ៍ទេ។

*រឿងក្តីឌុច៖ សំណើរបស់អៀង សារី សុំដាក់សារណា អំពីសហកម្មឧក្រិដ្ឋកម្មរួម អ.វ.ត.ក អ.ប.ជ ៦ តុលា ២០០៨ កថាខណ្ឌ១០ និង ១៤។*

**អាចដកបណ្តឹងឧទ្ធរណ៍វិញ ដោយមិនចាំបាច់មានការអនុញ្ញាត៖** ដើមបណ្តឹងឧទ្ធរណ៍ អាចដកបណ្តឹងឧទ្ធរណ៍ នៅពេលណាក៏បាន មុនពេលបញ្ចប់ការជំទាស់តវ៉ា។ ទោះបីជាសិទ្ធិនេះ មិនមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏ដោយ ក៏វាជាទម្លាប់ និងជាការអនុវត្តរបស់តុលាការកម្ពុជា និងតុលាការអន្តរជាតិ។

*រឿងក្តីខៀវ សំផន៖ សំណើសុំដកបណ្តឹងឧទ្ធរណ៍ អ.វ.ត.ក អ.ប.ជ ១៥ តុលា ២០០៨ កថាខណ្ឌ១០ និង១១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៧(២)។ វិធាននេះ ស្រដៀងគ្នាទៅនឹងមាត្រា ២៥៧ លើកលែងតែថា មាត្រានេះ អនុញ្ញាតឲ្យមានការជូនដំណឹងដល់ចៅក្រមស៊ើបសួរ ក្នុងរយៈពេលប្រាំថ្ងៃ។

# មាត្រា ២៥៩៖ ការពិនិត្យសំណុំរឿង និងសារណា

*អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវី អាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ។*

*អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវប្រគល់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដល់ក្រឡាបញ្ជី យ៉ាងយូរបំផុត១(មួយ)ថ្ងៃ មុនពេលសវនាការ។*

*គូភាគី និងមេធាវី អាចប្រគល់សារណាដល់ក្រឡាបញ្ជី។*

*សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសារណា ត្រូវចុះទិដ្ឋាការដោយក្រឡាបញ្ជី ដោយមានចុះកាលបរិច្ឆេទ និងត្រូវបញ្ចូលក្នុងសំណុំរឿងភ្លាម។*

*គូភាគី និងមេធាវី ត្រូវបានអនុញ្ញាតឱ្យជូនសារណា រហូតដល់ពេលចាប់ផ្ដើមបើកសវនាការ។*

## ការអនុវត្តនៅអ.វ.ត.ក

**មានតែភាគីទេ ទើបមានសិទ្ធិ៖** ត្រូវតែជាភាគីនៃរឿងក្ដី ទើបមានសិទ្ធិដាក់សារណា។

*រឿងក្ដីអៀង សារី និងឌុចៈ បណ្ដឹងសុំប្ដឹងជិតចិត្តរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី អ.វ.ត.ក អ.ប.ជ ១៤ តុលា ២០០៨ កថាខណ្ឌ៣ ដល់៦។*

**ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឲ្យចូលរួមនៅគ្រប់ដំណាក់កាល នៃកិច្ចដំណើរការនីតិវិធី នៅពេលដែលពួកគេ ត្រូវបានទទួលស្គាល់រួចហើយ៖** នៅពេលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានគេទទួលស្គាល់នោះ ពួកគេមិនចាំបាច់ត្រូវបង្ហាញនូវផលប្រយោជន៍ពិសេសណាមួយទេ នៅក្នុងដំណាក់កាលពិសេស នៃកិច្ចដំណើរការនីតិវិធីនោះទេ តែផ្ទុយទៅវិញ ពួកគេ ក៏អាចចូលរួមបាន នៅគ្រប់ដំណាក់កាលទាំងអស់។

*រឿងក្ដីនួន ជាៈ ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសវនាការសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ៤១ និង៤៩។*

**ចម្លើយតបរបស់ព្រះរាជអាជ្ញា និងមេធាវីការពារក្ដីទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី៖** នៅពេលអ្នកដែលមិនមែនជាភាគីនៃរឿងក្ដី បានដាក់សារណា នៅក្នុងរឿងក្ដីនេះ នោះតុលាការ ត្រូវតែផ្ដល់ឱកាសទាំងព្រះរាជអាជ្ញា និងទាំងមេធាវីការពារក្ដីឲ្យដាក់ចម្លើយតបទៅតុលាការ។

*រឿងក្តីឌុចៈ សំណើសុំការអនុញ្ញាត ដើម្បីដាក់ចម្លើយតបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគី នៃរឿងក្តី អ.វ.ត.ក អ.ប.ជ ២៦ តុលា ២០០៧។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.កៈ** វិធាន ៧៧(៤) និងវិធាន ២៣។ វិធាន ៧៧(៤) ស្រដៀងគ្នាទៅនឹងមាត្រា ២៥៩ បើទោះបីជាវិធាននេះ អនុញ្ញាតឲ្យសេចក្តីណែនាំស្តីពីការដាក់ឯកសារសម្រេចជាលំអិតក៏ដោយ។ វិធាន ២៣ ចែងយ៉ាងច្បាស់ថា "ភាគីនានា" រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផង ហើយដើមបណ្តឹងរដ្ឋប្បវេណីនេះ មានសិទ្ធិពិនិត្យមើលសំណុំរឿង និងដាក់សារណាបាន ដូចគ្នាទៅនឹងជនជាប់ចោទដែរ នៅពេលដែលពួកគេត្រូវបានទទួលស្គាល់ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីរួចហើយនោះ។ ប៉ុន្តែសិទ្ធិនេះ អាចអនុវត្តបានតែក្រោយពីការចាប់ផ្តើមកិច្ចស៊ើបសួរ និងជាពិសេសក្រោយពីការចេញដីកាបង្គាប់ ដោយអនុលោមតាមវិធាន ៦៣ (ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន) តែប៉ុណ្ណោះ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**សិទ្ធិពិនិត្យមើលសំណុំរឿង របស់ជនជាប់ចោទដែលការពារខ្លួនដោយខ្លួនឯងៈ** បុគ្គលបែបនេះត្រូវទទួលបានសិទ្ធិពិនិត្យមើលសំណុំរឿង។

*រឿងក្តី FOUCHER ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៨ មីនា ១៩៩៧ កថាខណ្ឌ៣៥ដល់៣៦។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*ៈ** មាត្រា ៦។ មាត្រានេះចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាសាធារណៈក្នុងពេលវេលាមួយសមស្របនៅចំពោះមុខសាលាជម្រះក្តីមួយ ដែលឯករាជ្យ និងមិនលម្អៀងដែលបង្កើតឡើងដោយច្បាប់។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេ*

*បកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ផលវិបាក នៃការមិនអនុវត្តលក្ខខណ្ឌតម្រូវ ក្នុងការពិនិត្យមើលសំណុំរឿង និងសារណានានា៖** ចំណុចនេះ មិនបណ្តាលឲ្យមានមោឃភាពនោះទេ លើកលែងតែសិទ្ធិការពារខ្លួន ត្រូវបានរំលោភ។

*លេខ73-91411 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៧៣ តុលាការកំពូលបារាំង ៣ តុលា ១៩៧៤។*

**ឯកសារក្នុងសំណុំរឿង៖** រាល់កិច្ចនៃការស៊ើបសួរ និងឯកសារពាក់ព័ន្ធនឹងនីតិវិធីទាំងអស់។ ក៏ប៉ុន្តែ ឯកសារដែលចៅក្រមស៊ើបសួរ បានទទួល និងបានស្នើសុំដាក់ជាភស្តុតាង មិនមែនជាផ្នែកនៃសំណុំរឿងទេ។

*លេខ 89-81334 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២០៧ តុលាការកំពូលបារាំង ១៨ ឧសភា ១៩៨៩។ លេខ95-85279/95-85289 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៧ តុលាការកំពូលបារាំង ៩ មករា ១៩៩៦។*

**សំណុំរឿងទាំងមូល ត្រូវដាក់ជូនទៅរដ្ឋអាជ្ញា៖** នេះគឺដើម្បីគោរពសិទ្ធិការពារខ្លួន។ ឯកសារថ្មីៗ ដែលបានដាក់ជូនសភាស៊ើបសួរ នៅមុនសវនាការលើបណ្តឹងសាទុក្ខ ក៏ត្រូវផ្តល់ជូនផងដែរ។

*លេខ 06-85657 តុលាការកំពូលបារាំង ១៩ កញ្ញា ២០០៦។*

**ការដាក់ជូននូវសេចក្តីថ្លែងការណ៍៖** មានតែភាគី និងមេធាវីរបស់ពួកគេទេ ទើបត្រូវបានអនុញ្ញាតឲ្យដាក់សេចក្តីថ្លែងការណ៍។

*លេខ07-87882 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៧២ តុលាការកំពូលបារាំង ២ កញ្ញា ២០០៨។*

**ទម្រង់បែបបទនៃសារណា ដែលត្រូវបានដាក់ជូន៖** សារណា មិនចាំបាច់ដាក់ជូន ដោយមេធាវីផ្ទាល់នោះទេ ក៏ប៉ុន្តែ មិនអាចផ្ញើសារណាតាមលិខិតធម្មតាបានទេ លើកលែងតែសារណានោះ ត្រូវបានផ្ញើមកដោយ ជនជាប់ឃុំ។

*លេខ 98-81428 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២១៦ តុលាការកំពូលបារាំង ៤ សីហា ១៩៩៨ (មិនចាំបាច់ដាក់ដោយមេធាវី)។ លេខ96-83647 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ២១៦ តុលាការកំពូលបារាំង ៣ មិថុនា ១៩៩៧ (មិនអាចដាក់សារណា តាមរយៈលិខិតធម្មតាបានទេ)។ លេខ07-82392 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៥៩ តុលាការកំពូលបារាំង ១៣ មិថុនា ២០០៧ (លើកលែងតែសារណានោះ ដាក់ដោយជនជាប់ឃុំ)។*

**សារណា ដែលសភាស៊ើបសួរយោង និងឆ្លើយតប៖** គឺចំពោះសារណាទាំងឡាយណា ដែលត្រូវបានគេបង្កើតឡើង និងផ្តល់ជូននៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ។

*លេខ៨៩-៨២២២៦ ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២១៦ តុលាការកំពូលបារាំង ១៥ ឧសភា ១៩-៩០។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា១៩៤ និងមាត្រា១៩៦។ មាត្រាទាំងនេះបង្កើតបានជាលក្ខខណ្ឌសម្រាប់កិច្ចដំណើរការនីតិវិធី នៅចំពោះមុខសភាស៊ើបសួរ រួមទាំងការពិនិត្យមើលសំណុំរឿង និងសារណាផងដែរ។

# មាត្រា ២៦០៖ ដំណើរការនៃកិច្ចពិភាក្សាដេញដោល

*ការពិភាក្សាដេញដោល ត្រូវប្រព្រឹត្តទៅក្នុងបន្ទប់ពិភាក្សា។*

*ក្រោយពីរបាយការណ៍របស់ប្រធានសភាស៊ើបសួរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវីរបស់គូភាគី ធ្វើការកត់សម្គាល់របស់ខ្លួនដោយសង្ខេប។*

*សភាស៊ើបសួរ អាចបង្គាប់ឱ្យគូភាគី ព្រមទាំងជនត្រូវចោទជាប់ឃុំ ចូលមកបង្ហាញខ្លួនដោយផ្ទាល់ និងផ្តល់វត្តមាន។*

*កាលណាការពិភាក្សាដេញដោលបានបញ្ចប់ សភាស៊ើបសួរ ធ្វើការពិគ្រោះសម្រេចដោយគ្មានវត្តមានរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គូភាគី និងមេធាវីឡើយ។*

*សាលដីកា ត្រូវប្រកាសនៅពេលសវនាការអសាធារណៈនៅថ្ងៃនោះ ឬក៏នៅពេលសវនាការលើកក្រោយ។ សាលដីកា ត្រូវតែមានសំអាងហេតុ ហើយត្រូវតែមានធាតុដែលចាំបាច់ដល់ការត្រួតពិនិត្យរបស់តុលាការកំពូល។ សាលដីកា ត្រូវចុះហត្ថលេខាដោយប្រធានសភាស៊ើបសួរ។*

*សាលដីកា ត្រូវជូនដំណឹងដោយផ្ទាល់មាត់ក្នុងរយៈពេលខ្លីបំផុត ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ក្រឡាបញ្ជី ចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹងនៅរឹមទំព័រនៃសាលដីកា។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចុះហត្ថលេខាថាបានទទួល។*

*សាលដីកា ត្រូវជូនដំណឹងដល់គូភាគី និងមេធាវី ដូចដែលមានចែងក្នុងមាត្រា ២៣៨ (ការជូនដំណឹងអំពីដីកាសម្រេចដល់ជនត្រូវចោទ) នៃក្រមនេះ។*

## ការអនុវត្តនៅអ.វ.ត.ក

**ពេលវេលាដែលបានផ្តល់ជូន សម្រាប់ការដាក់សារណាផ្ទាល់មាត់ ផ្អែកលើការថ្លឹងថ្លែងអំពីសិទ្ធិរបស់គូភាគី៖** ចិរវេលា ដែលអង្គបុរេជំនុំជម្រះបែងចែកឲ្យភាគីនីមួយៗ ដើម្បីលើកឡើងពីសារណាផ្ទាល់មាត់ គឺផ្អែកលើការថ្លឹងថ្លែងអំពីសិទ្ធិរបស់គូភាគី។ មិនមានគោលការណ៍ណាដែលតម្រូវឲ្យភាគីទាំងអស់ ត្រូវតែទទួលបានពេលវេលាស្មើៗគ្នា សម្រាប់ធ្វើសារណាផ្ទាល់មាត់នោះទេ ឧ. ដើមបណ្តឹងរដ្ឋប្បវេណីកំពុងធ្វើសារណាផ្ទាល់មាត់ ដើម្បីគាំទ្រដល់សហព្រះរាជអាជ្ញា អាចពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចអំពីពេលវេលា ដែលត្រូវបានបែងចែកឲ្យសហព្រះរាជអាជ្ញា ធ្វើសេចក្តីសន្និដ្ឋាន។ អង្គបុរេជំនុំជម្រះ អាចបែងចែកពេលវេលាបន្ថែម

បាន ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់ និង អាចកាត់តម្រឹមពេលវេលាបាន ក្នុងករណីដែល សារណាទាំងនោះមិនពាក់ព័ន្ធ ឬច្រំដែល។

*រឿងក្តីអៀង សារី៖ ភាពអាចទទួលយកបាន នៃសេចក្តីអង្កេត របស់ដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤មិថុនា ២០០៨ កថាខណ្ឌ ៦។*

**ពេលវេលា សម្រាប់ការធ្វើសារណាផ្ទាល់មាត់ គឺអាស្រ័យលើស្ថានភាពពាក់ព័ន្ធរបស់ភាគី៖** ឧទាហរណ៍ នៅពេលដើមបណ្តឹងរដ្ឋប្បវេណី មានផលប្រយោជន៍ ដោយផ្ទាល់ដាច់ដោយឡែកពីផលប្រយោជន៍របស់ព្រះរាជអាជ្ញា និងជនជាប់ចោទនោះ អង្គជំនុំជម្រះអាចនឹងផ្តល់ពេលវេលាច្រើនឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសារណាផ្ទាល់មាត់ ទៅតាមការសមស្រប។

*រឿងក្តីអៀង សារី៖ អញ្ញត្រកម្មលើបណ្តឹងឧទ្ធរណ៍ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ១ កក្កដា ២០០៨ កថាខណ្ឌ៥ ដល់៦។*

**ការផ្អាកសវនាការ គឺអាចធ្វើទៅបាន នៅពេលថ្លឹងថ្លែងលើផលប្រយោជន៍ រួមទាំងការជំនុំជម្រះឲ្យបានឆាប់រហ័ស៖** នៅពេលសម្រេចទៅលើសំណើសុំឲ្យផ្អាកសវនាការនោះ តុលាការត្រូវតែពិចារណាពីផលប្រយោជន៍របស់ភាគី រួមទាំងផលប្រយោជន៍ នៅក្នុងការទទួលបានការជំនុំជម្រះឲ្យបានឆាប់រហ័ស។

*រឿងក្តីអៀង ធីរិទ្ធ៖ ការផ្អាកសវនាការ សម្រេចសេចក្តី ទៅលើបណ្តឹងឧទ្ធរណ៍ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ១ មេសា ២០០៨ កថាខណ្ឌ៥។*

**ដើមបណ្តឹងរដ្ឋប្បវេណី អាចចូលរួមក្នុងដំណាក់កាលស៊ើបសួរ នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ៖** ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលស៊ើបអង្កេត នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺត្រឹមត្រូវទៅអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុង ហើយការចូលរួមនេះ មិនមានទំនាស់ជាមួយនឹងច្បាប់អន្តរជាតិ និងការអនុវត្តនោះទេ។

*រឿងក្តីនួនជា៖ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការសម្រេចសេចក្តី អំពីការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប .ជ ២០ មីនា ២០០៨ កថាខណ្ឌ២១ ដល់ ៣៦។*

**ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានអនុញ្ញាតឲ្យចូលរួម នៅចំពោះមុខអង្គបុរេជំនុំជម្រះបាន ដោយមិនចាំបាច់មានមេធាវី ប៉ុន្តែអាចបាត់បង់សិទ្ធិទាមទារសំណង៖** វិធាន ២៣ នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចូលរួមនៅចំពោះមុខអង្គបុរេជំនុំជម្រះបាន។ សិទ្ធិនេះ ត្រូវបានកម្រិតនៅក្នុងវិធាន ៧៧ (១០) ដែលចែងថា មានតែមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ទើបមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បាន នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណី

មិនមានមេធាវី វិធានទាំងនេះនឹងមានវិវាទ ហើយការអនុវត្តវិធាន ៧៧(១០) អាចរារាំងមិនឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ទាមទារសំណងដែលខ្លួនអាចមានសិទ្ធិទាមទារបាន។

*រឿងក្ដីអៀង សារី៖ សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំបង្ហាញជូនតុលាការ ដោយផ្ទាល់ អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៨ កថាខណ្ឌ៣ (មតិជំទាស់របស់ចៅក្រម Downing)។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៧(៥) ៧៧(៦) ៧៧(១២) និងវិធាន៧៧(១៤)។ វិធាន ៧៧(៤) ស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៦០ លើកលែងតែថាវិធាន ៧៧(៦) ផ្ដល់សិទ្ធិឲ្យចៅក្រមណាម្នាក់ និងភាគីស្នើសុំនូវនីតិវិធីទាំងស្រុង ឬមួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ ជាពិសេសនៅពេលដែលរឿងក្ដីនោះអាចត្រូវបានបញ្ចប់ដោយសេចក្ដីសម្រេច ហើយអង្គជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការនោះទេ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជាគឺជា ភាគីនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្ដីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ មិនអនុវត្តចំពោះសេចក្ដីសម្រេចមុនសវនាការលើអង្គសេចក្ដីនោះទេ៖** សិទ្ធិទទួលបានការជំនុំជម្រះក្ដីជាសាធារណៈ អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ប៉ុន្តែមិនអនុវត្តចំពោះសេចក្ដីសម្រេចណា ដែលចេញដោយរដ្ឋអាជ្ញា និងអាជ្ញាធរសាធារណៈ នៅមុនពេលសវនាការលើអង្គសេចក្ដីនោះទេ។

*រឿងក្ដី KAVANAGH ទល់នឹងប្រទេសអៀកឡង់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៤ មេសា ២០០១ កថាខណ្ឌ១០.៤។*

**មាត្រាស្រដៀងគ្នានៅក្នុង*កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*៖** មាត្រាស្រដៀងគ្នានៃមាត្រា ១៤(១) និង ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ១៤(១) ចែងថាជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ ប៉ុន្តែសវនាការអាចធ្វើជាអសាធារណៈបានក្នុងករណីចាំបាច់ ដើម្បីមូលហេតុសីលធម៌សណ្ដាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ភាពឯកជន ឬក្នុងកាលៈទេសៈពិសេស។ មាត្រា ១៤(៣) (ឃ) ធានាថា ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយខ្លួនឯងផ្ទាល់។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ គឺជាសិទ្ធិមូលដ្ឋាន ក៏ប៉ុន្តែមិនដាច់ខាតនោះទេ៖** ក្នុងករណីមានការជំនុំជម្រះជាអសាធារណៈនោះ វាគឺជាការចាំបាច់ ដែលបុគ្គលពាក់ព័ន្ធនៅក្នុងរឿងក្តី មានលទ្ធភាពអាចស្នើសុំឲ្យមានការជំនុំជម្រះ ជាសាធារណៈ។

> *រឿងក្តី HÅKANSSON និងSTURESSON ទល់ទៅនឹងប្រទេសស៊ុយអែត តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ កុម្ភៈ ១៩៩០ កថាខណ្ឌ៦៦ (សិទ្ធិទទួលបាន នូវការជំនុំជម្រះជាសិទ្ធិមូលដ្ឋាន)។ រឿងក្តី GÜLMEZ ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២០ ឧសភា ២០០៨ កថាខណ្ឌ៣៥ (សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ មិនមែនជាសិទ្ធិដាច់ខាតនោះទេ)។ រឿងក្តី BOCELLARI និងRIZZA ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៣ វិច្ឆិកា ២០០៧ កថាខណ្ឌ៣៧ និង៤១ (លទ្ធភាពក្នុងការស្នើសុំឲ្យមានការជំនុំជម្រះជាសាធារណៈ)។*

**អវត្តមានរបស់ជនជាប់ចោទ ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីអាចទទួលយកបាន៖** សវនាការកំបាំងមុខមានលក្ខណៈគ្រប់គ្រាន់ ក្នុងករណីជនជាប់ចោទបោះបង់សិទ្ធិ មានវត្តមានរបស់ខ្លួន និងសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬមានបំណងគេចវេះពីយុត្តិធម៌។ ផ្ទុយទៅវិញ នៅពេលដែលរដ្ឋអាជ្ញាមានវត្តមាននៅពេលសវនាការ ប៉ុន្តែជនជាប់ចោទ ឬមេធាវីរបស់គេ មិនមានវត្តមានទេនោះ គឺជាការរំលោភលើគោលការណ៍សមភាព នៃសិទ្ធិអំណាចរបស់ភាគីក្នុងរឿងក្តី។

> *រឿងក្តី SEJDOVIC ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១ មីនា ២០០៦ កថាខណ្ឌ៨២ (ការលះបង់សិទ្ធិ និងការគេចវេះពីយុត្តិធម៌)។ រឿងក្តី GODD ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ៩ មេសា ១៩៨៤ កថាខណ្ឌ២៧ និងកថាខណ្ឌ៣០-៣១។ រឿងក្តី NEŠTÁK ទល់នឹងប្រទេសស្លូវ៉ាគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ កុម្ភៈ២០០៧ កថាខណ្ឌ៨១ ដល់៨៣។ រឿងក្តីSERIFISទល់នឹងប្រទេសក្រិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ២ វិច្ឆិកា ២០០៦ កថាខណ្ឌ៤០ (រដ្ឋអាជ្ញាមានវត្តមាន តែជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទមិនមានវត្តមាន)។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា ៥ និងមាត្រា ៦។ មាត្រាទាំងនេះ ចែងពីសិទ្ធិទទួលបានសេរីភាព និងសន្តិសុខ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ពាក្យសម្តីចុងក្រោយ៖** ជនជាប់ចោទ ត្រូវមានសិទ្ធិនិយាយជាចុងក្រោយ នៅពេលដែលខ្លួនមានវត្តមាននៅក្នុងការពិភាក្សាដេញដោល។

*លេខ83-93215ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣១២ តុលាការកំពូលបារាំង ២៨ កញ្ញា ១៩៨៣។*

**តម្រូវឲ្យអានដីកាចោទប្រកាន់ របស់រដ្ឋអាជ្ញា អំឡុងពេលសវនាការ៖** ប្រសិនបើ មិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវនេះទេ នោះសេចក្តីសម្រេច ត្រូវចាត់ទុកជាមោឃៈ។

*លេខ 84-95418 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២១៤ តុលាការកំពូលបារាំង ៤ មិថុនា ១៩៨៥។*

**ត្រូវបើកសវនាការជាសម្ងាត់ លើកលែងតែមានសំណើសុំឲ្យបើកសវនាការជាសាធារណៈ ត្រូវបានអនុញ្ញាត៖** សវនាការ និងការចេញសេចក្តីសម្រេច ត្រូវធ្វើឡើងជាសម្ងាត់។ ប៉ុន្តែ ក្នុងករណីដែលបុគ្គលស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬមេធាវីរបស់គេ ស្នើសុំឲ្យបើកសវនាការជាសាធារណៈ នោះអង្គជំនុំជម្រះ ក៏អាចបង្គាប់ឲ្យមានការពិភាក្សាដេញដោល និងចេញសេចក្តីសម្រេច នៅក្នុងសវនាការជាសាធារណៈ។

*លេខ94-83697ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣២២ តុលាការកំពូលបារាំង ១១ តុលា ១៩៩៤ (ភាពសម្ងាត់)។ លេខ90-83668 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣១២ តុលាការកំពូលបារាំង ៩ កញ្ញា ១៩៩០ (ការបង្គាប់ឲ្យបើកសវនាការ ជាសាធារណៈ)។*

**ការចូលខ្លួនដោយផ្ទាល់របស់ភាគី មិនមែនជាបញ្ហាច្បាប់នោះទេ (De jure)៖** សេចក្តីសម្រេចនេះ ទុកឲ្យអង្គជំនុំជម្រះសម្រេចតាមឆន្ទានុសិទ្ធិរបស់ខ្លួន ហើយក៏មិនមែនជាកម្មវត្ថុនៃការត្រួតពិនិត្យរបស់តុលាការកំពូលនោះទេ។

*លេខ96-84634 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៤៦៩ តុលាការកំពូលបារាំង ១៧ ធ្នូ ១៩៩៦។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ១៩៩ មាត្រា ២០០ និងមាត្រា ២១៦។ មាត្រាទាំងនេះ ចែងអំពីការបើកសវនាការនៅចំពោះមុខសភាស៊ើបសួរ។

# មាត្រា ២៦១៖ ការពិនិត្យលើនិយ័តភាពនៃនីតិវិធី

*នៅរាល់ពេលដែលបានទទួលបណ្តឹង សភាស៊ើបសួរ ពិនិត្យមើលពីនិយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តិទៅដ៏ល្អនៃកិច្ចដំណើរការនីតិវិធីនេះ។*

*កាលណាពិនិត្យឃើញថា មូលហេតុនៃមោឃភាព សភាស៊ើបសួរ អាចចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។ សភាស៊ើបសួរ ត្រូវធ្វើដូចដែលមានចែងនៅក្នុងមាត្រា ២៨០ (អានុភាពនៃមោឃកម្ម) នៃក្រមនេះ។*

## ការអនុវត្តនៅអ.វ.ត.ក

**បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានកម្រិតតែ ទៅលើចំណុចជាក់លាក់មួយចំនួន៖** នៅពេលមានបណ្តឹងឧទ្ធរណ៍ ទៅលើមូលដ្ឋាននៃនីតិវិធី ប្រឆាំងទៅនឹងដីកាដំណោះស្រាយនោះ អង្គបុរេជំនុំជម្រះត្រូវតែកម្រិតអំពីវិសាលភាព នៃការពិនិត្យ ទៅលើចំណុចជាក់លាក់មួយចំនួន នៃបណ្តឹងឧទ្ធរណ៍នេះ។

*រឿងក្តីឌុច៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ៥ ធ្នូ ២០០៨ កថាខណ្ឌ២៩។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៦(១) ៧៦(២) និង ៧៦(៤)។ វិធានទាំងនេះ ស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៦១ លើកលែងតែចំណុចដែលចែងថា វិធាន ៧៦(១) និង ៧៦(២) អនុញ្ញាតឲ្យទាំងសហចៅក្រមស៊ើបសួរ និងភាគីដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសភាស៊ើសួរ ស្នើសុំឲ្យពិនិត្យឡើងវិញលើនីយ័តភាពនៃនីតិវិធី ចំណែកឯមាត្រា ២៦១ វិញមិននិយាយថា តើនរណាអាចស្នើឲ្យសភាស៊ើបសួរពិនិត្យឡើងវិញនោះទេ។ លើសពីនេះទៅទៀត វិធាន ៧៦ បើកលទ្ធភាពឲ្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សភាស៊ើសួរលើនិយ័តភាពនៃកិច្ចដំណើរការនីតិវិធី ប៉ុន្តែមាត្រា ២៦១ មិននិយាយពីបញ្ហានេះទេ។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ការតែងតាំងមេធាវី ដើម្បីការពារជនជាប់ចោទ មិនអាចធានាឲ្យមានជំនួយ ប្រកបដោយប្រសិទ្ធភាពដល់ជនជាប់ចោទបានទេ៖** មេធាវី ត្រូវខិតខំប្រឹងប្រែងយ៉ាងសកម្ម ដើម្បីធានាឲ្យមានប្រសិទ្ធភាពដល់ការអនុវត្តសិទ្ធិទាំងនេះ។

*រឿងក្ដី TALAT TUNÇ ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ មីនា ២០០៧ កថាខណ្ឌ៦១។*

**ក្នុងករណីដែលចៅក្រមយល់ឃើញថា មេធាវីមិនអាចបំពេញតួនាទីរបស់ខ្លួនបាននោះទេ៖** ចៅក្រមត្រូវចាត់វិធានការណាដែលសមស្រប និងជាវិជ្ជមានទាំងអស់ រួមទាំងការផ្អាកសវនាការ ឬការតែងតាំងមេធាវីជំនួស។

*រឿងក្ដី ARTICO ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៣ ឧសភា ១៩៨០ កថាខណ្ឌ៣៦។ រឿងក្ដី SANNINO ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្ស អឺរ៉ុប ២៧ មេសា ២០០៦ កថាខណ្ឌ៤៣ និង៤៩។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖* មាត្រា ៦។ មាត្រានេះផ្ដល់ឲ្យជនជាប់ចោទនូវសិទ្ធិជាច្រើន ដើម្បីទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានជំនួយតាមផ្លូវច្បាប់នៅក្រោមមាត្រា ៦(៣)(គ) ទោះបីក្នុងករណីដែលជនជាប់ចោទ មិនមានមធ្យោបាយ ដើម្បីចំណាយដល់ការទទួលបានជំនួយបែបនេះក៏ដោយ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**សភាស៊ើបសួរ មានអំណាចដាច់មុខដើម្បីពិនិត្យទៅលើនីត្យានុកូលភាពរបស់ខ្លួន៖** ក្នុងអំឡុងពេលនៃការស៊ើបសួរ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការកំពូល។

*លេខ04-84922 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៤២ តុលាការកំពូលបារាំង ១៣ តុលា ២០០៤។*

**សភាស៊ើបសួរ ជាអ្នកសម្រេចថាតើកិច្ច ឬឯកសារពាក់ព័ន្ធទៅនឹងនីតិវិធី មានប្រក្រតីភាពដាច់មុខ និងវិសាលភាព នៃការសម្រេចមោឃភាពណាមួយ៖** សភាស៊ើបសួរ អាចសម្រេចបែបនេះបាននៅក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន និងដោយយោងទៅលើផ្នែកទាំងឡាយនៃសំណុំរឿង។ សភាស៊ើបសួរ ក៏អាចសម្រេចថា តើការធ្វើមោឃភាពបែបនោះពាក់ព័ន្ធតែនឹងកិច្ចស៊ើបសួរជាក់លាក់ណាមួយ ឬក៏ពាក់ព័ន្ធទៅនឹងផ្នែកទាំងអស់/ខ្លះ នៃដំណើរការនីតិវិធីជាបន្តទៅទៀតនោះ។

*លេខ96-80686 តុលាការកំពូលបារាំង ៦ ឧសភា ១៩៩៦ (អំណាចសម្រេចអំពីភាពមិនប្រក្រតី ទៅតាមឆន្ទានុសិទ្ធិដាច់មុខ របស់*

*ខ្លួន)។ លេខ83-91676 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ២០១ តុលា ការកំពូលបារាំង ២៨ មិថុនា ១៩៨៣ (វិសាលភាពនៃការផ្ញើមោយភាព)។*

**ក្រោយពីការផ្ញើមោយភាព ទៅលើវិធានការចម្រូងចម្រាស់នេះរួចមក សភាស៊ើបសួរ អាចផ្ទេរសំណុំរឿងមកខ្លួនឯងផ្ទាល់ ឬអាចផ្ទេរសំណុំរឿងទៅឲ្យចៅក្រមដែលបានស៊ើបអង្កេតបឋម ឬចៅក្រមស៊ើបសួរមួយផ្សេងទៀត៖** ការផ្ទេរ ឬការបញ្ជូនបែបនេះ ត្រូវបានកម្រិតត្រឹមការពិនិត្យលើដីកាពាក់ព័ន្ធប៉ុណ្ណោះ។

*លេខ 98-81213 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២១៨ តុលាការកំពូលបារាំង ២១ កក្កដា ១៩៩៨*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា ២០៦។ មាត្រាទាំងនេះ ចែងអំពីការបើកសវនាការនៅចំពោះមុខសភាស៊ើបសួរ ជាពិសេសការពិនិត្យឡើងវិញទៅលើភាពស្របច្បាប់ពេញលេញនៃកិច្ចដំណើរការនីតិវិធីដែលខ្លួនបានទទួល។

# មាត្រា ២៦៦៖ បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា

*អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញា អាចប្តឹងឧទ្ធរណ៍ ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន។*

## ការអនុវត្តនៅអ.វ.ត.ក

**ក្នុងការវាយតម្លៃលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះគួរពិនិត្យលើកត្តាមួយចំនួនដូចជា៖** នីតិវិធីដែលចៅក្រមស៊ើបសួរ បានបំពេញមុនពេលចេញដីកាឃុំខ្លួន ភាពគ្រប់គ្រាន់នៃអង្គហេតុទាំងឡាយ ដើម្បីបង្គាប់ឲ្យធ្វើការឃុំខ្លួនបណ្តោះអាសន្ន ថាតើកាលៈទេសៈដែលត្រូវបានយកមកសំអាង ដល់ការចេញដីកាឃុំខ្លួន នៅបន្តមានដល់សព្វថ្ងៃនេះដែរឬអត់ និងការអនុវត្តឆន្ទានុសិទ្ធិ ដោយចៅក្រមស៊ើបសួរ នៅក្នុងការអនុវត្តវិធាន ៦៣(៣)។

*រឿងក្តីនួន ជា៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ៩។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ១៥។*

**នៅក្នុងករណីលើកលែងមួយចំនួន ចៅក្រមអាចពិចារណាលើមូលហេតុ នៃការប្តឹងឧទ្ធរណ៍ដែលមិនបានចែង៖** បើទោះបីជា វិធានបានចែងពីមូលដ្ឋានផ្សេងៗ អាចអនុញ្ញាតឲ្យមានការប្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីការបស់ចៅក្រមស៊ើបសួរ អង្គបុរេជំនុំជម្រះ ក៏អាចពិចារណាទៅលើមូលហេតុនាំឲ្យមានការប្តឹងឧទ្ធរណ៍ ដែលមិនបានចែង ប្រសិនបើចាំបាច់ធានា ក្នុងការអនុវត្តទៅតាមគោលការណ៍ ដែលជាមូលដ្ឋានជាសារវន្តនៃប្រព័ន្ធតុលាការ ក៏ប៉ុន្តែតែក្នុងករណីលើកលែងដែលមានអង្គហេតុ និងកាលៈទេសៈពិសេសៗ ដែលតម្រូវឲ្យមានការបកស្រាយសិទ្ធិ ក្នុងការប្តឹងឧទ្ធរណ៍ឲ្យបានទូលំទូលាយតែប៉ុណ្ណោះ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ សារណាស្តីពីបណ្តឹងឧទ្ធរណ៍ទៅលើភាពសម្ងាត់ សមភាព និងភាពត្រឹមត្រូវ អ.វ.ត.ក អ.ប.ជ ២៩ មិថុនា ២០១១ កថាខណ្ឌ១០។ រឿងក្តីនួន ជា និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១៥ កុម្ភៈ ២០១១ កថាខណ្ឌ ៧១ និង៧៣។*

**បណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវបានកម្រិត ចំពោះបញ្ហាខាងយុត្តាធិការ៖** បណ្ដឹងទាំងនេះ ជារួមមាន ការជំទាស់ទាក់ទងទៅនឹងគោលការណ៍នីត្យានុកូលភាព។ តែផ្ទុយទៅវិញ ការជំទាស់តវ៉ាទាក់ទងនឹងប្រភេទជាក់លាក់នៃបទល្មើសសំខាន់ ឬទម្រង់នៃការទទួលខុសត្រូវ ត្រូវតែយកមកដោះស្រាយនៅក្នុងសវនាការ។

*រឿងក្ដីអៀង សារី៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ៤៤ ដល់៤៧។ រឿងក្ដី នួន ជា និងអៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១៥ កុម្ភៈ ២០១១ កថាខណ្ឌ៥៩ ដល់៦២។*

**ការជំទាស់ផ្នែកយុត្តាធិការ ទៅនឹងដីការបស់ចៅក្រមស៊ើបសួរ អាចប្ដឹងឧទ្ធរណ៍បាននៅចំពោះមុខអង្គបុរេជំនុំជម្រះ៖** ការជំទាស់តវ៉ាទាំងនេះ គឺមិនកម្រិតត្រឹមតែប៉ុណ្ណោះនោះទេ រួមមានការជំទាស់ ទៅនឹងដីការបស់ចៅក្រមស៊ើបសួរដោយសំអាង ទៅលើការរំលោភលើគោលការណ៍ដែលចែងថា ជនជាប់ចោទ មិនអាចត្រូវបានគេកាត់ទោសទ្វេដង ចំពោះបទល្មើសតែមួយ កង្វះយុត្តាធិការតាមរឿងក្ដីទៅលើជនត្រូវចោទ ចំពោះបទល្មើសជាតិ និងកង្វះអានុភាពនៃការលើកលែងទោស និងការអនុគ្រោះទោស ស្ដីពីសមត្ថកិច្ចតុលាការក្នុងការចោទប្រកាន់។

*រឿងក្ដីអៀង សារី៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ៤៥ ៦១ ៦៦ និង ៧៦។*

**ការទទួលយកនូវភស្ដុតាង ដែលមិនអាចប្ដឹងឧទ្ធរណ៍បាន៖** អង្គបុរេជំនុំជម្រះ មិនមានយុត្តាធិការទូទៅ ដើម្បីពិនិត្យឡើងវិញលើបញ្ហាដែលទាក់ទងទៅនឹងការវាយតម្លៃ ឬការទទួលយកភស្ដុតាងបានទេ។ ផ្ទុយទៅវិញ ភាគីអាចជំទាស់ទៅនឹងការទទួលយកភស្ដុតាង នៅក្នុងដំណាក់កាលសវនាការបាន។

*រឿងក្ដី អៀង សារី៖ ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ ទាក់ទងនឹងភស្ដុតាង ដែលទទួលបានពីអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ២៤។ រឿងក្ដីអៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍ ស្ដីពីភស្ដុតាងដែលទទួលបានពីការធ្វើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១៨ ធ្នូ ២០០៩ កថាខណ្ឌ២៦។ រឿងក្ដីខៀវ សំផន៖ ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ ស្ដីពីភស្ដុតាង ដែលទំនងជាទទួលបានពីអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ២៧ មករា ២០១០ កថាខណ្ឌ១៨។*

**ការជំទាស់តវ៉ាទៅលើវិការៈ បានចោទប្រកាន់នៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនជាបញ្ហាយុត្តាធិការទេ៖** ដូច្នេះ ការជំទាស់តវ៉ាទាំងនេះ គឺមិនអាចលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ នៅក្នុងទម្រង់នៃ

បណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយបានទេ។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ៤៧។ ប៉ុន្តែសូមមើលរឿងក្តីអៀង សារី ខៀវ សំផន និងអៀង-ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម អ.វ.ត.ក អ.ប.ជ ២០ ឧសភា ២០១០ កថាខណ្ឌ៣៣ ដល់៣៤ និងកថាខណ្ឌ៩០ ដល់៩៧ (ការពិនិត្យទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីផ្ទៀងផ្ទាត់ថា តើជនត្រូវចោទ បានទទួលការជូនដំណឹងគ្រប់គ្រាន់ពីចរិត នៃបទល្មើស ដែលបានចោទប្រកាន់នោះដែរឬអត់)។*

**ការបដិសេធសំណើសុំព័ត៌មាន ស្តីពីភាពលម្អៀង ដែលអាចមាន នៃបុគ្គលិករបស់ចៅក្រមស៊ើបសួរ មិនអាចប្តឹងឧទ្ធរណ៍បានទេ៖** អង្គបុរេជំនុំជម្រះ មិនមានយុត្តាធិការក្នុងការបើកសវនាការសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលបដិសេធសំណើរបស់ជនជាប់ចោទសុំឲ្យផ្តល់ព័ត៌មានទាក់ទងនឹងភាពលម្អៀង ដែលទំនងជាកើតមាន និងអត្ថិភាពសំខាន់ៗនៃទំនាស់ផលប្រយោជន៍របស់បុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបសួរបានទេ ដោយហេតុថាបណ្តឹងឧទ្ធរណ៍បែបនេះ គឺមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងទេ។

*រឿងក្តីអៀង សារី៖ សំណើសុំឲ្យផ្តល់ព័ត៌មានអំពី DAVID BOYLE អ.វ.ត.ក អ.ប.ជ ២៨ សីហា ២០០៨ កថាខណ្ឌ១ និង១៧។*

**បទដ្ឋានស្តីពីការពិនិត្យឡើងវិញ លើបណ្តឹងឧទ្ធរណ៍ ការពិនិត្យឡើងវិញលើកំហុសអង្គច្បាប់ និងភាពសមហេតុផល នៃកំហុសអង្គហេតុ៖** នៅក្រោមករណីយុត្តិសាស្ត្រអន្តរជាតិ កំហុសនៃអង្គច្បាប់ ដែលបានចោទប្រកាន់ ត្រូវបានពិនិត្យឡើងវិញ ហើយកំហុសអង្គហេតុដែលបានចោទប្រកាន់ ត្រូវបានពិនិត្យឡើងវិញនៅក្រោមបទដ្ឋាននៃភាពសមហេតុផល ដើម្បីសម្រេចថា គ្មានអ្នកវិនិច្ឆ័យដោយសមហេតុផលទៅលើអង្គហេតុ ឈានដល់ការសម្រេចសេចក្តីទៅលើបញ្ហានេះបែបនេះឡើយ។

*រឿងក្តី នួន ជា អៀងសារី ខៀវសំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីភាពទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៣៤។*

**ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន មានសុពលភាពរហូតដល់ពេល ដែលចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍៖** ដីការបស់ចៅក្រមស៊ើបសួរត្រូវបានចាត់ទុកថា មានសុពលភាព និងមានប្រសិទ្ធភាព រហូតដល់ពេលចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍លើការបដិសេធសំណើសុំ និងការបន្តឃុំខ្លួនបណ្តោះ-*

*អាសន្ន អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ២៩។*

**មិនត្រូវជំទាស់តវ៉ានឹងសេចក្ដីសម្រេច នៅក្នុងដីកា ដោយការដាក់សំណើសុំឡើងវិញនោះទេ៖** នីតិវិធីដែលត្រឹមត្រូវ ដើម្បីដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ នៅចំពោះមុខអង្គបុរេជំនុំជម្រះ គឺបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសេចក្ដីសម្រេច នៅក្នុងដីកា មិនមែនតាមរយៈសំណើសុំជាបន្តបន្ទាប់ ដែលលើកឡើងពីសំណើសុំដំបូង ដែលត្រូវបានដោះស្រាយរួចមកហើយនោះទេ។

*រឿងក្ដី អៀង ធីរិទ្ធ៖ ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងភស្តុតាងដែលទទួលបានពីអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ២០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៤(២)។ វិធាននេះ គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៦៦។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**បណ្ដឹងឧទ្ធរណ៍ ដែលដាក់ដោយរដ្ឋអាជ្ញា តាមរយៈក្រឡាបញ្ជីរបស់ចៅក្រមស៊ើបសួរ៖** បណ្ដឹងឧទ្ធរណ៍បែបនេះអាចទទួលយកបាន។

*លេខ 08-81582 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១២៦ តុលាការកំពូលបារាំង ២០ ឧសភា ២០០៨។*

**មាត្រាស្រដៀងគ្នា នៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ១៨៥។ មាត្រានេះ ចែងអំពីការដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ និងចៅក្រម សម្រេចពីសេរីភាព និងការឃុំខ្លួន រួមទាំងសិទ្ធិដាក់បណ្ដឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា។

# មាត្រា ២៦៧៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ចៅក្រមស៊ើបសួរ ដោយជនជាប់ចោទ

*ជនជាប់ចោទ អាចប្តឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ៖*

*- ដីកាបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរ ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣៣ (ការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរដោយជនជាប់ចោទ)*

*- ដីកាមិនព្រមប្រគល់វត្ថុ ដែលចាប់ទៅឲ្យម្ចាស់ដើមវិញ ដូចមានចែងក្នុងមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកទៅឲ្យម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) និងមាត្រា ២៤៨ (ការប្រគល់វត្ថុដែលចាប់យកទៅឲ្យម្ចាស់ដើមវិញ)*

*- ដីកាបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យ ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ)*

*- ដីកាបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យបន្ថែម ឬសុំឲ្យធ្វើប្រតិកោសលវិច័យដូចមានចែងក្នុងកថាខណ្ឌទី ៧ នៃមាត្រា ១៧០ (ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ) និង*

*- ដីកាស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចមានចែងក្នុងផ្នែកទី ៥ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងផ្នែកទី ៧ ស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ នៃជំពូកទី ៣ (ស្តីពីវិធានការសន្តិសុខនិវន្តរាយ ក្នុងមាតិកាទី ១ នៃគន្ថីនេះ និងមាត្រា ២៤៩ (សេចក្តីសម្រេចនៃដីកាដំណោះស្រាយ ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ។*

## ការអនុវត្តនៅអ.វ.ត.ក

**ការពន្យារការសម្រេចសេចក្តី ទៅលើសំណើសុំបង្កើតបានជាការបដិសេធ តាមការសន្មតមានលក្ខណៈវិជ្ជមាន អាចបើកផ្លូវប្តឹងឧទ្ធរណ៍បាន៖** ការខកខានរបស់ចៅក្រមស៊ើបសួរ មិនចេញសេចក្តីសម្រេចទៅលើសំណើសុំឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន បង្កើតបានជាការបដិសេធ ដែលអាចនាំឲ្យមានការប្តឹងឧទ្ធរណ៍បានក្នុងកាលៈទេសៈ ដែលការពន្យារបែបនេះបានដកហូតនូវផលប្រយោជន៍របស់ជនជាប់ចោទ ដែលគេមានសិទ្ធិទទួលបាន ប្រសិនបើសំណើនេះ ត្រូវបានទទួលរួចមកហើយនោះ។ ការពន្យារបែបនេះ បង្កើតបានជាការបដិសេធតាមការសន្មត។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីអ្នកជំនាញផ្នែកវិកលវិទ្យា អ.វ.ត.ក អ.ប.ជ ២១ តុលា ២០០៨ កថាខណ្ឌ ២៤។ រឿងក្តី អៀង សារី៖ សំណើសុំឲ្យផ្អាកសវនាការសម្រេច អំពីបញ្ហាយុត្តាធិការ អ.វ.ត.ក អ.ប.ជ ២ កក្កដា ២០០៨ កថាខណ្ឌ ៥។*

**ភាគី អាចប្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលបដិសេធសំណើសុំរបាយការណ៍ ពីអ្នកជំនាញបាន៖** ដូច្នេះ ជាឧទាហរណ៍ ជនជាប់ចោទអាចប្តឹងឧទ្ធរណ៍ជំទាស់នឹងការបដិសេធសំណើសុំឲ្យចៅក្រមស៊ើបសួរចាត់តាំងអ្នកជំនាញ ដើម្បីវាយតម្លៃអំពីសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ និងសមត្ថភាពរបស់ជនជាប់ចោទដើម្បីចូលរួម នៅក្នុងការពារក្តីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍ស្តីពីការស្នើសុំឲ្យចាត់តាំងអ្នកជំនាញ អ.វ.ត.ក អ.ប.ជ ២២ តុលា ២០០៨ កថាខណ្ឌ ១១២ និងកថាខណ្ឌ ១៦។*

**ដើម្បីវាយតម្លៃទៅលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះគួរពិចារណាទៅលើកត្តាមួយចំនួន៖** ក្នុងនោះជារួមមាន នីតិវិធីដែលបំពេញដោយចៅក្រមស៊ើបសួរមុននឹងចេញដីកាឃុំខ្លួន ភាពគ្រប់គ្រាន់នៃអង្គហេតុ ដែលនាំមានការសម្រេចការឃុំខ្លួនបណ្តោះអាសន្ន ថាតើកាលៈទេសៈដែលបានយកមកសំអាង នៅក្នុងការចេញសេចក្តីសម្រេចនេះ នៅតែមានរហូតដល់សព្វថ្ងៃនេះដែរឬអត់ និងការអនុវត្តឆន្ទានុសិទ្ធិដោយចៅក្រមស៊ើបសួរ នៅក្នុងការអនុវត្តវិធាន ៦៣(៣)។

*រឿងក្តី នួនជា៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០០៨ កថាខណ្ឌ ៩។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ ១៥។*

**ចៅក្រម អាចពិចារណាទៅលើមូលហេតុនៃការប្តឹងឧទ្ធរណ៍ ដែលមិនបានចែងក្នុងករណីលើកលែង៖** ទោះបីជាវិធានមានចែងពីមូលហេតុអាចអនុញ្ញាតឲ្យមានការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ចៅក្រមស៊ើបសួរ អង្គបុរេជំនុំជម្រះ ក៏អាចពិចារណាលើមូលហេតុនាំឲ្យមានការប្តឹងឧទ្ធរណ៍ ដែលមិនបានចែង ប្រសិនបើចាំបាច់ធានាក្នុងការអនុវត្តតាមគោលការណ៍ជាសារវ័ន្ត ដែលជាមូលដ្ឋាននៃប្រព័ន្ធតុលាការ ប៉ុន្តែតែក្នុងករណីលើកលែង ដែលមានអង្គហេតុ និងកាលៈទេសៈពិសេសៗ ដែលតម្រូវឲ្យមានការបកស្រាយអំពីសិទ្ធិ នៅក្នុងការប្តឹងឧទ្ធរណ៍ឲ្យបានទូលំទូលាយតែប៉ុណ្ណោះ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ សារណាស្តីពីបណ្តឹងឧទ្ធរណ៍ទៅលើភាពសម្ងាត់ សមភាព និងភាពត្រឹមត្រូវ អ.វ.ត.ក អ.ប.ជ ២៩ មិថុនា ២០១១កថាខណ្ឌ១០។ រឿងក្តី នួន ជា និង អៀង ធីរិទ្ធ៖*

*បណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១៥ កុម្ភៈ ២០១១ កថាខណ្ឌ ៧១ និង ៧៣។*

**បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវបានកម្រិត ចំពោះបញ្ហាយុត្តាធិការ៖** បណ្តឹងទាំងនេះ ជារួមមាន ការជំទាស់ទាក់ទងទៅនឹងគោលការណ៍នីត្យានុកូលភាព។ ផ្ទុយទៅវិញ ការជំទាស់តវ៉ា ទាក់ទងនឹងប្រភេទជាក់លាក់នៃបទល្មើសសំខាន់ ឬទម្រង់នៃការទទួលខុសត្រូវ ត្រូវតែយកមកពិភាក្សាដេញដោល នៅក្នុងសវនាការ។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ ៤៤ ដល់ ៤៧។ រឿងក្តី នួន ជា និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១៥ កុម្ភៈ ២០១១ កថាខណ្ឌ ៥៩ ដល់ ៦២។*

**ការជំទាស់ផ្នែកយុត្តាធិការ ទៅនឹងដីការបស់ចៅក្រមស៊ើបសួរ គឺអាចប្តឹងឧទ្ធរណ៍បាន នៅចំពោះមុខអង្គបុរេជំនុំជម្រះ៖** ការជំទាស់តវ៉ាទាំងនេះ ជារួមមាន ការជំទាស់ទៅនឹងដីការបស់ចៅក្រមស៊ើបសួរ ដោយសំអាងទៅលើការរំលោភលើគោលការណ៍ដែលចែងថា ជនជាប់ចោទ មិនអាចត្រូវបានកាត់ទោសទ្វេដងចំពោះបទល្មើសតែមួយ កង្វះយុត្តាធិការតាមរឿងក្តី ទៅលើជនត្រូវចោទ ចំពោះបទល្មើសជាតិ និងកង្វះអានុភាព នៃការលើកលែងទោស និងការអនុគ្រោះទោស ស្តីពីសមត្ថកិច្ចតុលាការក្នុងការចោទប្រកាន់ ក៏ប៉ុន្តែ មិនកម្រិតត្រឹមតែប៉ុណ្ណោះនោះទេ។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ ៤៥ ៦១ ៦៦ និង កថាខណ្ឌ ៧៦។*

**ការទទួលយកនូវភស្តុតាង ដែលមិនអាចប្តឹងឧទ្ធរណ៍បាន៖** អង្គបុរេជំនុំជម្រះ មិនមានយុត្តាធិការទូទៅដើម្បីពិនិត្យឡើងវិញទៅលើបញ្ហាទាក់ទងទៅនឹងការវាយតម្លៃ ឬការទទួលយកភស្តុតាងបានទេ។ ផ្ទុយទៅវិញ ភាគីអាចជំទាស់តវ៉ាទៅនឹងការទទួលយកនូវភស្តុតាង នៅក្នុងដំណាក់កាលសវនាការ។

*រឿងក្តី អៀង សារី៖ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ទាក់ទងទៅនឹងភស្តុតាងដែលទទួលបាន ដោយអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ ២៦។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីភស្តុតាង ដែលទំនងជាទទួលបាន ដោយការធ្វើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១៨ ធ្នូ ២០០៩ កថាខណ្ឌ ២០។ រឿងក្តីខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ស្តីពីភស្តុតាង ដែលទំនងជាទទួលបាន ដោយអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ២៧ មករា ២០១០ កថាខណ្ឌ ១៨។*

**ការជំទាស់តវ៉ាទៅលើវិការៈ នៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅស៊ើបសួរ គឺមិនមែនជាបញ្ហាយុត្តាធិការទេ៖** ដូច្នេះ ការជំទាស់តវ៉ាទាំងនេះ

មិនអាចលើកឡើង នៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងទម្រង់ជាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបានទេ។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ ៤៧។ ប៉ុន្តែសូមមើល រឿងក្តី អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម អ.វ.ត.ក អ.ប.ជ ២០ ឧសភា ២០១០ កថាខណ្ឌ ៣៣-៣៤ និងកថាខណ្ឌ ៩០ ដល់៩៧ (ការពិនិត្យទៅលើដីកាដំណោះស្រាយ ដើម្បីកំណត់ថា តើជនត្រូវចោទបានទទួលនូវការជូនដំណឹងគ្រប់គ្រាន់ពីចរិត នៃបទល្មើសដែលបានចោទប្រកាន់នោះដែរឬអត់)។*

**ការបដិសេធនូវសំណើសុំព័ត៌មាន ស្តីពីភាពលម្អៀងដែលអាចមាន នៃបុគ្គលិករបស់ចៅក្រមស៊ើបសួរ មិនអាចប្តឹងឧទ្ធរណ៍បានទេ៖** អង្គបុរេជំនុំជម្រះ មិនមានយុត្តាធិការបើកសវនាការសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលបដិសេធសំណើរបស់ជនជាប់ចោទសុំឲ្យផ្តល់ព័ត៌មាន ទាក់ទងទៅនឹងភាពលម្អៀង ដែលទំនងជាកើតមានឡើង និងអត្ថិភាពសំខាន់ៗនៃទំនាស់ផលប្រយោជន៍របស់បុគ្គលិក នៅក្នុងការិយាល័យនៃសហចៅក្រមស៊ើបសួរ ដោយហេតុថា បណ្តឹងឧទ្ធរណ៍បែបនេះ មិនមានចែងនៅក្នុងវិធានផ្ទៃក្នុងនោះទេ។

*រឿងក្តី អៀង សារី៖ សំណើសុំឲ្យផ្តល់ព័ត៌មាន អំពី DAVID BOYLE អ.វ.ត.ក អ.ប.ជ ២៨ សីហា ២០០៨ កថាខណ្ឌ ១ និង ១៧។*

**ការពិនិត្យឡើងវិញ ទៅលើបទដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ចំពោះកំហុសអង្គច្បាប់ និងភាពសមហេតុផលចំពោះកំហុសអង្គហេតុ៖** នៅក្រោមយុត្តិសាស្ត្រអន្តរជាតិ កំហុសអង្គច្បាប់ ដែលបានចោទប្រកាន់ ត្រូវបានពិនិត្យជាថ្មីឡើងវិញ ហើយកំហុសអង្គហេតុ ដែលបានចោទប្រកាន់ ត្រូវបានពិនិត្យឡើងវិញ នៅក្រោមបទដ្ឋាននៃភាពសមហេតុផល ដើម្បីសម្រេចថា មិនមានអ្នកវិនិច្ឆ័យដ៏សមហេតុផលលើអង្គហេតុអាចនាំឲ្យឈាន ដល់ការសម្រេចសេចក្តីទៅលើបញ្ហានេះដូច្នេះឡើយ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីភាពទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៣៤។*

**ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន មានសុពលភាព រហូតដល់ពេលចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍៖** ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ត្រូវចាត់ទុកថាមានសុពលភាព និងមានប្រសិទ្ធភាព រហូតដល់ពេលចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍។

*រឿងក្តី ខៀវ សំផន៖ ការពន្យារការឃុំខ្លួនបណ្តោះអាសន្ន និងបណ្តឹងឧទ្ធរណ៍លើ*

*ការបដិសេធសំណើសុំ អ.វ.ត.ក អ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ ២៩។*

**មិនត្រូវជំទាស់តវ៉ានឹងសេចក្តីសម្រេច នៅក្នុងដីកា តាមរយៈការដាក់សំណើសុំឡើងវិញនោះទេ៖** នីតិវិធីត្រឹមត្រូវ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ នៅចំពោះមុខនៃអង្គបុរេជំនុំជម្រះ គឺជាការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសេចក្តីសម្រេចនៅក្នុងដីកា ពោលគឺមិនមែនតាមរយៈសំណើសុំក្រោយៗ ដែលលើកបានឡើងដដែលៗ ពីសំណើសុំពីដំបូង ដែលត្រូវបានដោះស្រាយតាមលំដាប់លំដោយរួចមកហើយនោះទេ។

*រឿងក្តី អៀង ធីរិទ្ធ៖ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ទាក់ទងទៅនឹងភស្តុតាងដែល ទទួលបានដោយអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ ២០។*

**រឿងក្តីដែលមានជនត្រូវចោទច្រើននាក់៖ សិទ្ធិប្តឹងឧទ្ធរណ៍៖** ក្នុងករណីបែបនេះ ជនត្រូវចោទម្នាក់ៗ អាចប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលប៉ះពាល់ដល់ជនត្រូវចោទ ដោយមិនគិតថា តើដីកានោះគឺជាការឆ្លើយតបទៅនឹងសំណើសុំ ដែលបានដាក់ដោយជនត្រូវចោទរូបនោះ ឬថាតើសំណើសុំត្រូវបានយោងទៅដីកានោះឬយ៉ាងណានោះទេ។

*រឿងក្តី អៀង សារី៖ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងភស្តុតាងដែលទទួលបាន ដោយអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ ១៨។ រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ស្តីពីភស្តុតាង ដែលទំនងជាទទួលបានដោយការធ្វើទារុណកម្ម អ.វ.ត.ក អ.ប.ជ ២៧ មករា ២០១០ កថាខណ្ឌ ១៤។*

**អង្គជំនុំជម្រះសាលាដំបូង អាចវាយតម្លៃថាតើខ្លួនបានទទួលនូវសំណុំរឿងស្របច្បាប់ តាមរយៈសាលដីការបស់អង្គបុរេជំនុំជម្រះ ទៅលើដីកាដំណោះស្រាយដែរឬអត់៖** ទោះបីជាអង្គជំនុំជម្រះសាលាដំបូង មិនមានសមត្ថកិច្ចពិនិត្យមើលសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះឡើងវិញក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចវាយតម្លៃថា តើខ្លួនបានទទួលនូវសំណុំរឿងដោយស្របច្បាប់ដែរឬទេ តាមរយៈសាលដីការបស់អង្គបុរេជំនុំជម្រះទៅលើដីកាដំណោះស្រាយ ដែលបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រឆាំងទៅនឹងជនជាប់ចោទ និងថាតើសេចក្តីសម្រេចទាំងនោះ មានកំហុសនីតិវិធី ដែលអាចប៉ះពាល់ដល់ភាពស្របច្បាប់ ចំពោះការឃុំខ្លួនជនជាប់ចោទ ដោយយោងតាមផ្នែកទាក់ទងនឹងការឃុំខ្លួន នៃសេចក្តីសម្រេចទាំងនេះ។

*រឿងក្តី នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ៖ សំណើសុំឲ្យមានការដោះលែង ជាបន្ទាន់ អ.វ.ត.ក អ.ប.ជ ១៦ កុម្ភៈ ២០១១ កថាខណ្ឌ ២១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៣ ៦៥ និងវិធាន ៧៤។ វិធាន ៧៤(៣) គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៦៧ លើកលែងតែចំណុចដែលវិធាននេះ អនុញ្ញាតឲ្យជនត្រូវចោទ ឬជនជាប់ចោទ ប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកា និងសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលតម្កល់យុត្តាធិការរបស់អ.វ.ត.ក ដែលសម្រេចបដិសេធពាក្យសុំឲ្យប្ដឹងទៅអង្គបុរេជំនុំជម្រះ ដើម្បីធ្វើមោឃភាពកិច្ចស៊ើបសួរណាមួយ ដែលសម្រេចទាក់ទងនឹងវិធានការការពារ និងសម្រេចប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ សិទ្ធិរបស់ជនត្រូវចោទក្នុងការប្ដឹងឧទ្ធរណ៍តវ៉ានឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន នៅចំពោះមុខអង្គបុរេជំនុំជម្រះក៏មានចែងក្នុងវិធាន ៦៤(៤) ផងដែរ និងសិទ្ធិរបស់ជនត្រូវចោទ ក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក៏មានចែងនៅក្នុងវិធាន ៦៥(១)។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ការបដិសេធជាទូទៅ នៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធ ឬសម្រេចដកហូត៖** បណ្ដឹងឧទ្ធរណ៍បែបនោះ នឹងត្រូវបានច្រានចោល លើកលែងតែវាមានលក្ខណៈស្មុគស្មាញតែប៉ុណ្ណោះ។

> *លេខ 65-90080 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៧៦ តុលាការកំពូលបារាំង ១៥ កក្កដា ១៩៦៥ (ដីកាសម្រេចបដិសេធ)។ លេខ70-91964 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៨ តុលាការកំពូលបារាំង ១២ មករា ១៩៧១ (ដីកាសម្រេចដកហូត)។*

**ភាពអាចទទួលយកបាន នៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាបញ្ជូន ដែលមានលក្ខណៈស្មុគស្មាញ៖** ឧទាហរណ៍នៃបណ្ដឹងឧទ្ធរណ៍ ដែលអាចទទួលយករួមមានដីកាសម្រេចដោយប្រយោល ច្រានចោលសំណើសុំឲ្យតែងតាំងអ្នកជំនាញ និងដីកាសម្រេចដោយប្រយោលទទួលយក ដើមបណ្ដឹងរដ្ឋប្បវេណី ដែលការទទួលយកនេះ ត្រូវបានជំទាស់តវ៉ា។

> *លេខ66-93616 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៤៣ តុលាការកំពូលបារាំង ២ ឧសភា ១៩៦៧ (ដីកាបញ្ជូនដែលស្មុគស្មាញ និងការច្រានចោលសំណើសុំ ឲ្យតែងតាំងអ្នកជំនាញ)។ លេខ 82-90109 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៤៨ តុលាការកំពូលបារាំង ១៤ ធ្នូ ១៩៨២ (ដីកាសម្រេចទទួលយកដើមបណ្ដឹងរដ្ឋប្បវេណី)។*

**អំណាចរបស់ប្រធានសភាស៊ើបសួរ ក្នុងការចេញដីកាសម្រេចមិនទទួលយក៖** ប្រធាន អាចចេញដីកាបែបនេះ ទៅតាមការផ្ដួចផ្ដើមរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ចៅក្រមស៊ើបសួរ។

*លេខ 98-80446 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២០៧ តុលាការកំពូលបារាំង ២៤ មករា ១៩៩៨។*

**ដីកាសម្រេចដែលចេញដោយប្រធានសភាស៊ើបសួរ ជាទូទៅមិនអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បានទេ៖** ប្រធាន អាចសម្រេចបែបនេះបាន លើកលែងតែសេចក្តីសម្រេចពាក់ព័ន្ធ ដែលអាចប្រឡាក់ប្រឡូកទៅដោយការបំពានលើអំណាច។

*លេខ 03-85240 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២២២ តុលាការកំពូលបារាំង ២៦ វិច្ឆិកា ២០០៣ (ដីកាសម្រេចរបស់ប្រធានមិនអាចប្តឹងឧទ្ធរណ៍បាន)។ លេខ 07-80929 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១០៧ តុលាការកំពូលបារាំង ៤ មេសា ២០០៧ (ការបំពានលើអំណាច)។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖ គឺមាត្រា ១៨៦។ មាត្រាទាំងនេះ ផ្តល់អំណាចឲ្យជនត្រូវចោទប្តឹងឧទ្ធរណ៍ជំទាស់នឹងចៅក្រមស៊ើបសួរ និងចៅក្រមសម្រេចអំពីសេរីភាពនិងការឃុំខ្លួន។

# មាត្រា ២៦៨៖ បណ្តឹងឧទ្ធរណ៍ចំពោះដីកាសរបស់ចៅក្រមស៊ើបសួរ ដោយដើមបណ្តឹងរដ្ឋប្បវេណី

*ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ៖*

*- ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣៤ (ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី)*

*- ដីកាមិនព្រមស៊ើបសួរ ដូចដែលមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៣៩(ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា)*

*- ដីកាកំណត់ចំនួនប្រាក់កក់ ដូចដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៤០(ការបង់ប្រាក់តម្កល់ទុក)*

*- ដីកាប្រកាសមិនទទួលពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ*

*- ដីកាផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងមាត្រា ១៤១ (បណ្តឹងដោយបំពានឬបណ្តឹងដោយអូសបន្លាយពេលវេលា)*

*- ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យកទៅម្ចាស់ដើមវិញ ដូចដែលមានចែងក្នុងមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) និងមាត្រា ២៤៨ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ)*

*- ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ)*

*- ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬសុំឱ្យធ្វើប្រតិកោសលវិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ៧ នៃមាត្រា ១៧០ (ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ)*

*- ដីកាដំណោះស្រាយ ដូចដែលមានចែងក្នុងមាត្រា ២៤៧ (ដីកាដំណោះស្រាយ) នៃក្រមនេះ។*

## ការអនុវត្តនៅអ.វ.ត.ក

**ការពន្យាពេល ក្នុងការចេញសេចក្តីសម្រេចលើសំណើ អាចបង្កើតបានជាការបដិសេធតាមការសន្មត ភាគីអាចប្តឹងឧទ្ធរណ៍បាន៖** ការខកខានរបស់ចៅក្រមស៊ើបសួរ នៅក្នុងការសម្រេចលើសំណើឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន បង្កើតបានជាការបដិសេធ ដែលបើកផ្លូវឲ្យប្តឹងឧទ្ធរណ៍ ក្នុងកាលៈទេសៈដែលការពន្យារពេលនោះ នាំឲ្យជនជាប់ចោទបាត់បង់នូវផលប្រយោជន៍ ប្រសិនបើសំណើសុំនោះទទួលយកបាន។ ការពន្យារពេលដូច្នេះ បង្កើតបានជាការបដិសេធតាមការសន្មតលើពាក្យសុំ។

> *រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍អំពីគ្រូពេទ្យជំនាញវិកលវិទ្យា អ.វ.ត.ក អ.ប.ជ ២១ តុលា ២០០៨ កថាខណ្ឌ ២៤។ រឿងក្តី អៀង សារី៖ សំណើសុំផ្អាកសវនាការ លើយុត្តាធិការ អ.វ.ត.ក អ.ប.ជ ២ កក្កដា ២០០៨ កថាខណ្ឌ ៥។ រឿងក្តីអៀងសារី៖ បណ្តឹងឧទ្ធរណ៍អំពីសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ លើកទីបី អ.វ.ត.ក អ.ប.ជ ២២ ធ្នូ ២០០៩ កថាខណ្ឌ ៩។*

**ការពិចារណាឡើងវិញ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែមាននូវអំណះអំណាងយ៉ាងជាក់លាក់៖** សំណើសុំឲ្យចៅក្រមស៊ើបសួរ ធ្វើការពិចារណាឡើងវិញលើភាពអាចទទួលយកបាន ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អំណះអំណាងទូទៅ ដូចជាការគ្រាន់តែអះអាងរបស់មេធាវីថាកូនក្តីរបស់ខ្លួនជាជនរងគ្រោះនៃអំពើធ្វើទុក្ខបុកម្នេញ ដោយគ្មានអំណះអំណាងជាក់លាក់ អំពីអ្នកដាក់ពាក្យសុំនីមួយៗ មិនអាចគ្រប់គ្រាន់សម្រាប់កំណត់អំពីភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

> *រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ សំណើសុំឲ្យពិនិត្យឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ១ កក្កដា ២០១១ កថាខណ្ឌ ១០។*

**បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសំណើសុំឲ្យពិចារណាឡើងវិញ អាចត្រូវបានសម្រេចរួមគ្នា ទោះបីជាបណ្តឹងឧទ្ធរណ៍ទាំងនោះ ត្រូវបានធ្វើឡើងតាមមូលដ្ឋានផ្សេងៗគ្នាក៏ដោយ៖** ដើម្បីផលប្រយោជន៍ខាងយុត្តិធម៌ និងប្រសិទ្ធភាពរបស់តុលាការ បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះប្រឆាំងនឹងការបដិសេធលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយចៅក្រមស៊ើបសួរ អាចត្រូវបានពិនិត្យ និងសម្រេចរួមគ្នា ទោះបីជាបណ្តឹងឧទ្ធរណ៍ទាំងនោះ ត្រូវបានធ្វើឡើងតាមមូលដ្ឋានផ្សេងគ្នាក៏ដោយ ប្រសិនបើមានកំហុសឆ្គង ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ និងប្រសិនបើវាមានភាពពាក់ព័ន្ធទៅនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានច្រានចោល

និងភាពអយុត្តិធម៌ ជាដុំកំភួននឹងកើតឡើង ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបាន លើកឡើងពីកំហុសឆ្គង ដែលកំណត់ត្រូវ ដោយអង្គបុរេជំនុំជម្រះ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីភាពអាច ទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៣៥។*

**ភាគី អាចបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសេចក្តី សម្រេចរបស់ចៅក្រមស៊ើបសួរ ដែលបាន បដិសេធនូវសំណើសុំរបាយការណ៍អ្នកជំនាញ៖** ដូច្នេះជនត្រូវចោទ អាចបដិសេធបាននូវបណ្តឹង ឧទ្ធរណ៍ លើសំណើសុំឲ្យចៅក្រមស៊ើបសួរ តែងតាំងអ្នកជំនាញ ដើម្បីវាយតម្លៃពីសម្បទា របស់ជនត្រូវចោទ ក្នុងការចូលរួមក្នុងសវនាការ ព្រទាំងសមត្ថភាព ក្នុងការចូលរួមដោយមាន ប្រសិទ្ធភាព ក្នុងការការពាររឿងក្តីរបស់គាត់។

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍អំពីការតែង តាំងអ្នកជំនាញ អ.វ.ត.ក អ.ប.ជ ២២ តុលា ២០០៨ កថាខណ្ឌ ១ ១២ និង ១៦។*

**ការវាយតម្លៃលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹង ដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន។ កត្តា ដែលអង្គជំនុំជម្រះត្រូវពិនិត្យ៖** ជារួមមាន នីតិ វិធីរបស់ចៅក្រមស៊ើបសួរ មុនពេលចេញនូវ ដីកាសម្រេច ពីភាពគ្រប់គ្រាន់នៃអង្គហេតុ ដែលគាំទ្រដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះ អាសន្ន ថាតើមានកាលៈទេសៈជាមូលដ្ឋាននៃ ដីកាសម្រេច នៅមានរហូតដល់ថ្ងៃនេះឬទេ ហើយការប្រើឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើប សួរ ក្នុងការអនុវត្តវិធាន ៦៣(៣) នៃវិធានផ្ទៃ ក្នុង។

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍អំពីការឃុំ ខ្លួនបណ្តោះអាសន្ន អ.វ.ត.ក អ.ប.ជ ២០ មីនា ២០ ០៨ កថាខណ្ឌ ៩។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹង ឧទ្ធរណ៍ អំពីការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត .ក អ.ប.ជ ៩ កក្កដា ២០០៨ កថាខណ្ឌ ១៥។*

**ក្នុងកាលៈទេសៈពិសេស ចៅក្រមអាចពិចារណា លើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែលមិនបាន ចែង៖** ទោះបីវិធានចែងពីមូលដ្ឋាន ដែលអាច ឲ្យប្តឹងឧទ្ធរណ៍បាន ប្រឆាំងទៅនឹងដីការបស់ ចៅក្រមស៊ើបសួរក៏ដោយ អង្គបុរេជំនុំជម្រះ ក៏ អាចពិចារណាលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែលមិនបានចែងផងដែរ កាលណាមានភាព ចាំបាច់ដើម្បីធានាបាននូវការគោរពតាមគោល ការណ៍គ្រឹះនៃប្រព័ន្ធតុលាការ ក៏ប៉ុន្តែអាចធ្វើ បានតែក្នុងករណីលើកលែង ដែលអង្គហេតុ និងកាលៈទេសៈពិសេស តម្រូវឲ្យមានការបក ស្រាយទូលាយស្តីពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ប៉ុណ្ណោះ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីការរក្សាការ សម្ងាត់ សមភាព និងភាពយុត្តិធម៌ អ.វ.ត.ក អ.ប.ជ ២៩ មិថុនា ២០១១ កថាខណ្ឌ ១០។ រឿងក្តី នួន ជា និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរ-*

*ណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១៥ កុម្ភៈ ២០១១ កថាខណ្ឌ ៧១ និង ៧៣។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសំណើសុំឲ្យបង្អង់នីតិវិធី អ.វ.ត.ក អ.ប.ជ ១០ សីហា ២០១០ កថាខណ្ឌ ១៤។*

**បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កំរិតត្រឹមតែបញ្ហាយុត្តាធិការ៖** បណ្តឹងឧទ្ធរណ៍ទាំងនេះ គឺរួមបញ្ចូលទាំងការជំទាស់ទៅនឹងគោលការណ៍នីត្យានុកូលភាព។ ផ្ទុយទៅវិញ ភាគីត្រូវតែលើកពីការជំទាស់ទៅនឹងវិសាលភាពជាក់លាក់នៃបទល្មើសសំខាន់ៗ ឬទម្រង់នៃការទទួលខុសត្រូវនៅក្នុងសវនាការ។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍អំពីដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ ៤៤-៤៧។ រឿងក្តី នួន ជា និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១៥ កុម្ភៈ ២០១១ កថាខណ្ឌ ៥៩-៦២។*

**ការជំទាស់នឹងយុត្តាធិការ នៃដីការបស់ចៅក្រមស៊ើបសួរអាចប្តឹងឧទ្ធរណ៍បាន ចំពោះមុខអង្គបុរេជំនុំជម្រះ៖** ករណីបែបនេះ រួមបញ្ចូលទាំងការជំទាស់ទៅនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយផ្អែក លើការរំលោភលើគោលការណ៍ដែលចែងថា ជនជាប់ចោទ មិនអាចត្រូវបានជំនុំជម្រះពីរដងចំពោះបទល្មើសតែមួយ ការគ្មានយុត្តាធិការលើបុគ្គល និងភាពគ្មានប្រសិទ្ធភាពលើការលើកលែងទោស ទៅលើលទ្ធភាពនៃតុលាការក្នុងការចោទប្រកាន់។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍អំពីដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ ៤៥ ៦១ ៦៦ និង ៧៦។*

**ភាគីមិនអាចប្តឹងឧទ្ធរណ៍ ប្រឆាំងសេចក្តីសម្រេចលើភាពអាចទទួលយក នៃភស្តុតាងបានទេ៖** អង្គបុរេជំនុំជម្រះ គឺមិនមានយុត្តាធិការទូទៅ ដើម្បី ពិនិត្យឡើងវិញលើបញ្ហា ដែលទាក់ទងទៅនឹងការវាយតម្លៃ ឬភាពអាចទទួលយកបាននៃភស្តុតាងបានទេ។ ផ្ទុយទៅវិញ ភាគីអាចជំទាស់ ទៅនឹងភាពអាចទទួលយកបាននៃភស្តុតាង នៅដំណាក់កាលជំនុំជម្រះ។

*រឿងក្តី អៀង សារី៖ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍អំពីភស្តុតាង ដែលទទួលបានពីអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ ២៤។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ អំពីភស្តុតាងដែលទំនងជាទទួលបាន ពីអំពើទារុណកម្ម អ.វ. ត.ក អ.ប.ជ ១៨ ធ្នូ ២០០៩ កថាខណ្ឌ ២៤។ រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍អំពីភស្តុតាងដែលទទួលបានពី អំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ២៧ មករា ២០១០ កថាខណ្ឌ ១៨។*

**ការជំទាស់លើវិការៈ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនជាបញ្ហាយុត្តាធិការនោះទេ៖** ដូច្នេះភាគី មិនអាចលើកបញ្ហានេះ ចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងទម្រង់ជាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបានទេ។

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍អំពីដីកាដំណោះស្រាយ អ.វ.ត.ក អ.ប.ជ ១១*

*មេសា ២០១១ កថាខណ្ឌ ៤៧។ ប៉ុន្តែ ចូរអាន រឿងក្តី អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីសហកម្មឧក្រិដ្ឋកម្មរួម អ.វ.ត.ក អ.ប.ជ ២០ ឧសភា ២០១០ កថាខណ្ឌ ៣៣-៣៤ និង ៩០-៩៧ (ការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីផ្ទៀងផ្ទាត់ថា ជនត្រូវចោទបានទទួលសេចក្តីជូនដំណឹងគ្រប់គ្រាន់ អំពីបទល្មើស ដែលត្រូវបានចោទប្រកាន់)។*

**ភាគី មិនអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធសំណើសុំព័ត៌មាន អំពីភាពលម្អៀងរបស់បុគ្គលិករបស់ចៅក្រមស៊ើបសួរបានទេ៖** អង្គបុរេជំនុំជម្រះ មិនមានយុត្តាធិការបើកសវនាការលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលបដិសេធសំណើរបស់ជនជាប់ចោទ ស្នើសុំព័ត៌មានពាក់ព័ន្ធទៅនឹងភាពលម្អៀងជាក់ស្តែង និងសក្តានុពលនៃអត្ថិភាពនៃទំនាស់ផលប្រយោជន៍នៃបុគ្គលិករបស់ចៅក្រមស៊ើបសួរបាននោះទេ ដោយសារតែវិធានផ្ទៃក្នុង មិនបានចែងយោងដល់បញ្ហានេះ។

*រឿងក្តី អៀង សារី៖ ព័ត៌មានអំពី DAVID BOYLE អ.វ.ត.ក អ.ប.ជ ២៨ សីហា ២០០៨ កថាខណ្ឌ ១ និង ១៧។*

**សំណើសុំឲ្យពិចារណាឡើងវិញ លើពាក្យបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានពិនិត្យឡើងវិញ៖** ក្នុងការពិនិត្យពាក្យសុំដើម្បីពិចារណាឡើងវិញ លើភាពអាចទទួលយកបាន ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គបុរេជំនុំជម្រះពិនិត្យមើលពាក្យសុំដើមដំបូងសារជាថ្មី ដើម្បីកំណត់ថាតើអ្នកដាក់ពាក្យសុំនេះ បានចោទប្រកាន់ពីព្យសនកម្មដែលកើតចេញពីបទល្មើស ដែលបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជម្រះដែរឬទេ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងសំណើសុំឲ្យពិចារណាឡើងវិញ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ១ កក្កដា ២០១១ កថាខណ្ឌ ១០។*

**ការបដិសេធដីកាសម្រេច លើភាពអាចទទួលយកបានត្រូវបានអនុញ្ញាត កាលណាមានកំហុសអង្គហេតុ និងអង្គច្បាប់៖** អង្គបុរេជំនុំជម្រះ អាចបដិសេធចោល នូវដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ស្តីពីភាពអាចទទួលយកបាន ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណីដែលខ្លួនរកឃើញថា មានកំហុសអង្គហេតុ និង/ឬកំហុសអង្គច្បាប់។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍សុំឲ្យពិចារណាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើងវិញ អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៣៤។*

**ការពិចារណាឡើងវិញ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលគ្មានការជំទាស់**

**អាចត្រូវបានពិចារណា ទៅលើកំហុសឆ្គងជាមូលដ្ឋាន ដែលតែងកើតមានជាទូទៅ៖** កាលណាភាគីមិនជំទាស់ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងការបដិសេធ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តុលាការដែលពិនិត្យករណីនេះ អាចពិចារណាទៅលើកំហុសឆ្គងជាមូលដ្ឋានដែលជាមូលហេតុទូទៅ នៃការបដិសេធលើពាក្យសុំទាំងអស់ ទោះបីជាពាក្យសុំទាំងនេះ បាន ឬមិនបានលើកឡើងពីកំហុសឆ្គងជាក់លាក់ ដើម្បីជៀសវាងនូវភាពអយុត្តិធម៌ជាដុំកំភួន និងធានាថា បុគ្គលស្រដៀងគ្នានេះ ត្រូវបានប្រព្រឹត្តមកលើដោយស្មើភាព។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៣៥។*

**ដីកាសម្រេចមានសុពលភាព រហូតដល់ពេលមានសេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍៖** ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ត្រូវបន្តមានសុពលភាព និងមានប្រសិទ្ធភាពរហូតដល់មានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ស្តីពីការបដិសេធសំណើ និងការបន្តការឃុំខ្លួនបណ្តោះអាសន្ន អ.វ.ត.កអ.ប.ជ ៣ កក្កដា ២០០៩ កថាខណ្ឌ ២៩។*

**មិនត្រូវតវ៉ាចំពោះសេចក្តីសម្រេចក្នុងដីកា តាមរយៈការដាក់សំណើសុំ សារជាថ្មីឡើយ៖** នីតិវិធីត្រឹមត្រូវសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍របស់ចៅក្រមស៊ើបសួរទៅអង្គបុរេជំនុំជម្រះ ដើម្បីប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ គឺជាបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងចម្លើយក្នុងដីកានោះ មិនមែនតាមរយៈការដាក់សំណើជាបន្តបន្ទាប់ ដោយអះអាងដដែលៗនូវសំណើដំបូងៗ ដែលត្រូវបានសម្រេចរួចហើយក្នុងដីកានោះឡើយ។

*រឿងក្តី អៀង សារី៖ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ស្តីពីភស្តុតាង ដែលទទួលបានពីអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ ២០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៤(៤)។ វិធាន ៧៤(៤) មានបទប្បញ្ញត្តិមួយចំនួនដូចគ្នាខ្លាំងទៅនឹងមាត្រា ២៦៨។ ប៉ុន្តែចំណុចខុសគ្នាពីមាត្រា២៦៨ គឺវិធាន ៧៤(៤) អនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធ ក្នុងករណីដែលព្រះរាជអាជ្ញា បានប្តឹងឧទ្ធរណ៍ប្រឆាំងដីកាដែលបដិសេធពាក្យសុំកុំឲ្យអង្គជំនុំជម្រះប្រកាសលុបចោលកិច្ចស៊ើបសួរ និងដីកាពាក់ព័ន្ធនឹងវិធានការការពារ។ ផ្ទុយទៅវិញវិធានផ្ទៃក្នុង ៧៤(៤) មិនបានអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដីកាពាក់ព័ន្ធនឹងការបង់ប្រាក់តម្កល់ដោយដើមបណ្តឹងរដ្ឋប្បវេណី ឬដីកាដែលដាក់ពិន័យដើមបណ្តឹងរដ្ឋប្បវេណីដែលបានបំពាន ឬយឺតយ៉ាវក្នុងការដាក់សំណើ (ចំពោះការពិន័យដើមបណ្តឹងរដ្ឋប្បវេណី វិធានផ្ទៃក្នុងមិនមានចែងអំពីដីកាទាំងនេះទេ)។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងរាល់ដីការបស់ចៅក្រមស៊ើបសួរ ដែលប៉ះពាល់ផលប្រយោជន៍ខាងរដ្ឋប្បវេណីរបស់ខ្លួន៖** ករណីនេះរួមបញ្ចូលទាំង ដីកាប្រកាសមិនទទួលយកដើមបណ្តឹងរដ្ឋប្បវេណី។ ដីកា ត្រូវតែបំពេញតាមលក្ខខណ្ឌច្បាប់ជាជាងចរិតលក្ខណៈជារដ្ឋបាល។

*D. 1933. 1. 127 តុលាការកំពូលបារាំង ៤ មីនា ១៩៣២ (ដីកាដែលប៉ះពាល់ដល់ផលប្រយោជន៍រដ្ឋប្បវេណី)។ លេខ92-84778 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៤៧ តុលាការកំពូលបារាំង ៦ មេសា ១៩៩៣។*

**ដីកាត្រូវតែបង្កការខូចខាត ដោយផ្ទាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី៖** ដីកាបែបនេះទើបស្របច្បាប់។

*លេខ 69-91612 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៦២ តុលាការកំពូលបារាំង ២៣ ធ្នូ ១៩៦៩។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ១៨៦។ មាត្រានេះ ផ្តល់អំណាចឲ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ និងចៅក្រមដែលសម្រេចពីសេរីភាពនិងការឃុំខ្លួន។

# មាត្រា ២៧១៖ សមត្ថកិច្ចរបស់សភាស៊ើបសួរ

| |
|---|
| *បណ្តឹងឧទ្ធរណ៍ ត្រូវបញ្ជូនទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។* |

## *ការអនុវត្តនៅអ.វ.ត.ក*

**អង្គជំនុំជម្រះសាលាដំបូង មិនអាចកំណត់ពីភាពចាំបាច់ ភាពសមស្រប នៃដំណើរការនីតិវិធីរបស់អង្គបុរេជំនុំជម្រះឡើយ៖** អង្គជំនុំជម្រះសាលាដំបូង មិនមានយុត្តាធិការក្នុងការកំណត់ថាតើដំណើរការនីតិវិធី ចំពោះមុខអង្គបុរេជំនុំជម្រះគ្មានភាពចាំបាច់ ឬមិនសមហេតុផលឡើយ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ សំណើសុំឲ្យមានការលាតត្រដាងឯកសារទាំងអស់ នៅក្នុងរឿងក្តី អ.ប.ជ ០៨ អ.វ.ត.ក អ.ប.ជ ១៥ កក្កដា ២០១១ កថាខណ្ឌ ៥។*

**បទដ្ឋាននៃការពិនិត្យឡើងវិញ លើបណ្តឹងឧទ្ធរណ៍៖ ការពិនិត្យសារជាថ្មី ទៅលើកំហុសឆ្គងអង្គច្បាប់ និងបទដ្ឋាននៃភាពសមស្របស្តីពីកំហុសឆ្គងអង្គហេតុ៖** តាមករណីយុត្តិសាស្ត្រអន្តរជាតិ ការចោទប្រកាន់ពីកំហុសឆ្គងផ្នែកអង្គច្បាប់ត្រូវបានពិនិត្យសារជាថ្មី រីឯកំហុសឆ្គងខាងអង្គហេតុវិញ ត្រូវបានពិនិត្យឡើងវិញស្របតាមបទដ្ឋាន ស្តីពីភាពសមស្រប ដើម្បីកំណត់ថាមិនមានអ្នកវិនិច្ឆ័យសេចក្តីដោយសមហេតុផល ទៅលើអង្គហេតុអាចនាំឲ្យឈាន ដល់ការសម្រេច លើការស្វែងរកការពិតលើបញ្ហានេះ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីការទទួលយកពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៣៤។*

**មិនអាចចេញដីកាបង្គាប់ ឲ្យមានកិច្ចអ្វីបន្ថែមទេ៖** តួនាទីរបស់អង្គបុរេជំនុំជម្រះ កម្រិតត្រឹមតែសម្រេចលើបណ្តឹងឧទ្ធរណ៍។ អង្គបុរេជំនុំជម្រះមិនមានសិទ្ធិអំណាច បង្គាប់ឲ្យបើកកិច្ចស៊ើបសួរបន្ថែមឡើយ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និងឌុច៖ បណ្តឹងឧទ្ធរណ៍អំពីការសួរយកចម្លើយ ទាក់ទិននឹងអាពាហ៍ពិពាហ៍ ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ អ.វ.ត.ក អ.ប .ជ ២១ កក្កដា ២០១០ កថាខណ្ឌ ១៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៣។ វិធាននេះ ស្រដៀងគ្នានឹងមាត្រា ២៧១ ប៉ុន្តែវិធានបាន កំណត់ពីប្រភេទបណ្តឹងឧទ្ធរណ៍ទាំងអស់ ដែលអាចទទួលយកបាន។

# មាត្រា ២៧៨៖ សាលដីកាដែលសម្រេចលើការឃុំខ្លួនបណ្ដោះអាសន្ន

*ក្នុងរឿងឃុំខ្លួនបណ្ដោះអាសន្ន សាលដីការបស់សភាស៊ើបសួរ ត្រូវសម្រេចចេញ នៅក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលសំណុំរឿង នៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បើផុតរយៈពេលនេះ ជនត្រូវចោទ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ លើកលែងតែក្នុងករណីដែលបានចេញបង្គាប់ឱ្យបំពេញកិច្ចស៊ើបសួរ ឬក្នុងករណីមានកាលៈទេសៈ ដែលមិនអាចទស្សន៍ទាយបានជាមុន ឬមិនអាចជំនះបាននោះ បង្កជាឧបសគ្គមិនឱ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនេះ។*

*កាលណាសភាស៊ើបសួរ បង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន សភាស៊ើបសួរ ត្រូវសំអាងហេតុនៅក្នុងសាលដីការបស់ខ្លួន ដោយយោងតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ។ ប្រធានសភាស៊ើបសួរ ចេញដីកាបង្គាប់ឱ្យឃុំខ្លួន។*

*សំណុំរឿង ត្រូវបង្វិលជាបន្ទាន់ទៅចៅក្រមស៊ើបសួរវិញ ក្រោយពីបានអនុវត្តសាលដីការួច។*

## ការអនុវត្តនៅអ.វ.ត.ក

**ភាពចាំបាច់ ក្នុងការថ្លឹងថ្លែងរវាងការឃុំខ្លួន និងសេរីភាព៖** តុលាការត្រូវតែថ្លឹងថ្លែងពីមូលហេតុរវាងការឃុំខ្លួន និងសិទ្ធិរបស់បុគ្គល ក្នុងការមានសេរីភាព។ សច្ចធារណ៍ នៃសេរីភាព តម្រូវឲ្យមានមូលដ្ឋានគ្រប់គ្រាន់ ក្នុងសេចក្ដីសម្រេចតាមផ្លូវតុលាការ ស្ដីអំពីការឃុំខ្លួន និងត្រូវបានចេញ ដោយអនុលោមតាមនីតិវិធី និងលក្ខខណ្ឌច្បាប់។

*រឿងក្ដី ខៀវ សំផន៖ បណ្ដឹងឧទ្ធរណ៍ក្លាមៗស្នើសុំនៅក្រៅឃុំ អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៧ និង៥៦។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ៨០។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ២២។ រឿងក្ដី នួន ជា៖ សេចក្ដីសម្រេចលើកទី២ ស្ដីពីសម្បទារបស់នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ ១៦។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល) អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១៣ កថាខណ្ឌ ១។ រឿងក្ដី អៀង ធីរិទ្ធ៖ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ក្លាមៗប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជន*

*ជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទក្នុងការឃុំឃាំង ដោយមានលក្ខខណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធី និងការដោះលែងដោយឥតលក្ខខណ្ឌ ចំពោះបុគ្គលពាក់ព័ន្ធគឺចៀសមិនផុតពីផលវិបាកឡើយ)*

**ជនត្រូវចោទ ត្រូវបានឃុំខ្លួននៅពេលបង្ហាញខ្លួនជាលើកដំបូង៖** ជនត្រូវចោទត្រូវបានឃុំខ្លួន នៅពេលបង្ហាញខ្លួនលើកដំបូង នៅចំពោះមុខនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបន្តស្ថិតក្នុងការឃុំខ្លួន រហូតដល់ពេលអង្គជំនុំជម្រះចេញនូវសេចក្តីសម្រេច ដរាបណាអាជ្ញាតុលាការមានមូលដ្ឋានស្របច្បាប់សម្រាប់ឃុំខ្លួន។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ស្នើសុំនៅក្រៅឃុំ អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៧-៤៩។*

**ការបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្នបន្ទាប់ពីដីកាដំណោះស្រាយ មិនចំណុះឲ្យពេលវេលាផ្សេងទៀតទេ៖** ដីកាសម្រេចបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ន បន្ទាប់ពីការចេញដីកាដំណោះស្រាយ មិនចំណុះក្រោមនៃរយៈវេលាកំណត់ផ្សេងទៀតអំពីការឃុំខ្លួនបណ្តោះអាសន្នទេ។ មិនមានការកម្រិត នូវរយៈពេលឃុំខ្លួនបណ្តោះអាសន្ន ជាអតិបរមាបីឆ្នាំ សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នទេ។

*រឿងក្តី អៀង សារី៖ សំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ស.ជ ១២ ឧសភា ២០១១ កថាខណ្ឌ ១០។*

**ដីកាសម្រេចឃុំខ្លួន ត្រូវតែមានសំអាងហេតុ៖** ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន ត្រូវតែមានសំអាងហេតុ ក្នុងករណីដែលត្រូវបានគេចេញអមជាមួយនឹងដីកាដំណោះស្រាយនោះ។ សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទត្រូវបានបំពាន ដោយសារការយឺតយ៉ាវក្នុងការផ្តល់សំអាងហេតុ។

*រឿងក្តី អៀង សារី៖ សំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ស.ជ ១២ ឧសភា ២០១១ កថាខណ្ឌ ១២។*

**ការដោះលែងភ្លាមៗ គឺមិនអាចជួសជុលការយឺតយ៉ាវក្នុងការផ្តល់សំអាងហេតុទេ៖** កាលណាដីកាបន្តថិរវេលានៃឃុំខ្លួន មិនមានសំអាងហេតុទេ ការដោះលែងភ្លាមៗ មិនអាចជាឧបាស្រ័យសមស្របនៃកំហុសឆ្គងអង្គច្បាប់ទេ។ ឧបាស្រ័យ អាចត្រូវបានគេលើកយកមកដោះស្រាយ នៅចុងបញ្ចប់នៃការជំនុំជម្រះ។

*រឿងក្តី អៀង សារី៖ សំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ស.ជ ១២ ឧសភា ២០១១ កថាខណ្ឌ ១២។*

**ការចេញដីកាដាច់ដោយឡែក ពីសំអាងហេតុ មិនអាចចាត់ទុកថា ជាការបំពានបានទេ៖** ការកំណត់ថា តើការចេញសេចក្តីសម្រេច មុននឹង

ចេញសំអាងហេតុតាមក្រោយ គឺបង្កើតបានជាការបំពានលើនីតិវិធីតែក្នុងករណីដែលសេចក្ដីសម្រេច និងសំអាងហេតុ ត្រូវបានចេញខុសពីអំឡុងពេល ដែលបានកំណត់ដោយវិធានផ្ទៃក្នុង។ នៅក្នុងករណីដែលសេចក្ដីសម្រេច និងសំអាងហេតុ ត្រូវបានគេចេញក្នុងអំឡុងពេលដែលវិធានអនុញ្ញាតឲ្យ បញ្ហាដែលចេញខុសពេលគ្នា មិនមែនជាកំហុសទេ។

*រឿងក្ដី នួន ជា និងអៀង ធីរិទ្ធ៖ បណ្ដឹងសាទុក្ខភ្ជាមៗសុំឲ្យដោះលែង ជាបន្ទាន់ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ ៣១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៦៨(២) ៧៧(១៤) និង ៧៧(១៥)។ វិធាន ៧៧(១៥) គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៧៨ លើកលែងតែវិធាននេះ កម្រឹតត្រឹមតែស្ថានភាព ដែលដីការបស់ចៅក្រមស៊ើបសួរបង្គាប់ឲ្យដោះលែងជនត្រូវចោទ ឬលើកលែងការចោទប្រកាន់ និងព្រះរាជអាជ្ញាប្ដឹងសុំឲ្យផ្អាកនីតិវិធី។ ក្នុងស្ថានភាពផ្សេងទៀតវិធាន ៦៨(២) (ការឃុំខ្លួនកាលណាមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាបញ្ជូនរឿងទៅជម្រះ) ឬវិធាន ៧៧ (បណ្ដឹងឧទ្ធរណ៍ដទៃទៀតប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន) អនុវត្តជាទូទៅ។ វិធាន ៧៧(១៤) ចែងថារាល់សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះត្រូវតែមានសំអាងហេតុ។

## ***ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត***

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជាគឺជា ភាគីនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្ដីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ត្រូវតែមានយុត្តិកម្ម សម្រាប់បន្តការឃុំខ្លួន៖** ការឃុំខ្លួន រាប់បញ្ចូលទាំងការឃាត់ខ្លួនក្នុងគេហដ្ឋានផង អាចត្រូវបានចាត់ទុកថា តាមទំនើងចិត្ត ប្រសិនបើរដ្ឋមិនអាចបញ្ជាក់ពីមូលដ្ឋានជាក់លាក់ ជាយុត្តិកម្មនៃការបន្តការឃុំខ្លួន។

*រឿងក្ដី KWOK ទល់ទៅនឹងប្រទេសអូស្ត្រាលី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ តុលា ២០០៤ កថាខណ្ឌ ៩.៣ រឿងក្ដី ABBAS SI ទល់នឹងប្រទេសអាល់ហ្សេរី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៨ មីនា ២០០៧ កថាខណ្ឌ ៨.៤ គំហាត់លំនៅ។*

**ការឃុំខ្លួន ត្រូវតែស្របច្បាប់ សមហេតុផល និងមានការចាំបាច់៖** សិទ្ធិក្នុងការមានសេរីភាព តម្រូវឲ្យមានកាលៈទេសៈនៃការឃុំខ្លួន ដែលត្រូវតែស្របច្បាប់ សមហេតុផល និងចាំបាច់គ្រប់កាលៈទេសៈ ដូចជា ដើម្បីការពារការរត់គេចខ្លួន ការជ្រៀតជ្រែកខាងភស្តុតាង ឬការប្រព្រឹត្តបទល្មើសសារជាថ្មី។

*រឿងក្តី KULOV ទល់នឹងប្រទេសគីហ្សីស្ថាន គណៈកម្មាធិការ សិទ្ធិមនុស្ស អ.ស.ប ២៦ កក្កដា ២០១០ កថាខណ្ឌ ៨.៣។*

**មាត្រាស្រដៀងគ្នានៅក្នុង*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*៖** មាត្រា ៩(១) ៩(៣) ៩(៤) ១៤(២) និង ១៤(៣)(គ)។ ជាពិសេសមាត្រា ៩(៣) ចែងថាវាមិនអាចជាវិធានទូទៅបានទេ ដែលតម្រូវថា ត្រូវតែឃុំខ្លួនជនត្រូវចោទ ក្នុងពេលរង់ចាំការជំនុំជម្រះក្តី។ បទប្បញ្ញត្តិផ្សេងទៀតក្នុងមាត្រា ៩ ផ្តល់ការធានាពាក់ព័ន្ធទៅនឹងការឃុំខ្លួន ប៉ុន្តែមាត្រា ១៤(២) ចែងពីសច្ចធារណ៍និរទោស និងមាត្រា ១៤(៣) សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយមិនការពន្យាពេលមិនសមហេតុផល។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ការបន្តថិរវេលានៃការឃុំខ្លួន មុនសវនាការលើអង្គសេចក្តី៖** ចៅក្រម ត្រូវតែផ្តល់នូវយុត្តិកម្មលើហេតុផលនៃការបន្តការឃុំខ្លួន មុនសវនាការលើអង្គសេចក្តី លើបញ្ហាសេរីភាព និងការឃាត់ខ្លួន។

*លេខ 92-85534 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣២ តុលាការកំពូលបារាំង ២០ មករា ១៩-៩៣។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ១៤៥-១។ មាត្រានេះ ចែងពីការឃុំខ្លួនមុនសវនាការលើអង្គសេចក្តីដែលរួមទាំងមូលហេតុនៃការបន្តរយៈពេលឃុំខ្លួនផងដែរ។

# មាត្រា ២៧៩៖ ភាពមិនអាចទទួលយកបាននៃពាក្យបណ្ដឹងសុំមោឃកម្ម

*សភាស៊ើបសួរ អាចប្រកាសមិនទទួលពាក្យបណ្ដឹងសុំឱ្យមោឃកម្មនៅក្នុងករណីដូចតទៅ៖*
*- ពាក្យប្ដឹងសុំគ្មានសំអាងហេតុ*
*- ពាក្យប្ដឹងសុំទាក់ទងនឹងដីកាដែលអាចប្ដឹងឧទ្ធរណ៍បាន*
*- ពាក្យប្ដឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្ដែង*
*សេចក្ដីសម្រេចរបស់សភាស៊ើបសួរ មិនអាចតវ៉ាបានទេ។*

*កាលណាពាក្យប្ដឹងសុំ ត្រូវបានប្រកាសមិនអាចទទួលបានទេ សំណុំរឿងត្រូវបង្វិលភ្លាមទៅចៅក្រមស៊ើបសួរ។*

## ការអនុវត្តនៅអ.វ.ត.ក

**ខ្លឹមសារនៃសំណើសុំមោឃភាព៖** សំណើសុំមោឃភាព ត្រូវតែបញ្ជាក់ពីវិការៈនីតិវិធី។ វិការៈនេះ ត្រូវតែជាការបំពានទៅលើសិទ្ធិរបស់ម្ចាស់បណ្ដឹង។

*រឿងក្ដី នួន ជា៖ បណ្ដឹងឧទ្ធរណ៍ ស្ដីពីការបដិសេធសំណើសុំមោឃភាព អ.វ.ត.ក អ.ប.ជ ២៦ សីហា ២០០៨ កថាខណ្ឌ ៣៤-៣៥។ រឿងក្ដី នួន ជា និង អៀង សារី៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីកោះហៅសាក្សី អ.វ.ត.ក អ.ប.ជ ៨ មិថុនា ២០១០ កថាខណ្ឌ ៣៨។ រឿងក្ដី នួន ជា អៀង សារី និងខៀវ សំផន៖ ការស្នើសុំឲ្យមានកិច្ចស៊ើបអង្កេត តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងដែលទាក់ទងទៅនឹងភាពមិនស៊ីសង្វាក់គ្នា ទៅនឹងកំណត់ហេតុជាសម្លេង និងជាលាយលក្ខណ៍អក្សរ នៃការសម្ភាសន៍សាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១២ កថាខណ្ឌ ១០-១៤។*

**ការរំលោភលើសិទ្ធិក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ៖** ការរំលោភលើសិទ្ធិដែលត្រូវបានគេទទួលស្គាល់ដោយកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បង្កើតបានជាវិការៈនីតិវិធី ហើយអាចធ្វើឲ្យកិច្ចស៊ើបសួរ ឬកិច្ចរបស់ចៅក្រមស៊ើបសួរ ក្លាយទៅជាមោឃៈបាន។

*រឿងក្ដី នួន ជា៖ បណ្ដឹងឧទ្ធរណ៍ ស្ដីពីការបដិសេធមោឃភាពអ.វ.ត.ក អ.ប.ជ ២៦ សីហា ២០០៨ កថាខណ្ឌ ៤០។*

**ត្រូវតែបង្ហាញពីព្យសនកម្ម កាលណាគ្មានការរំលោភលើច្បាប់៖** កាលណាវិធានផ្ទៃក្នុង មិនបានចែងថា វិការៈនីតិវិធី ក្លាយជាមោឃៈ និងកាលណាគ្មានការរំលោភលើសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ម្ចាស់បណ្តឹង ត្រូវតែបង្ហាញថាផលប្រយោជន៍របស់ខ្លួនរងនូវការខូចខាតពីវិការៈនីតិវិធី។

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍ស្តីពីការបដិសេធមោឃភាព អ.វ.ត.ក អ.ប.ជ ២៦ សីហា ២០០៨ កថាខណ្ឌ ៤២។ រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីការសុំមោឃភាពកិច្ចស៊ើបសួរ អ.វ.ត.ក អ.ប.ជ ២៥ មិថុនា ២០១០ កថាខណ្ឌ ២១។*

**ភស្តុតាង មិនអាចទទួលយកដោយស្វ័យប្រវត្តិបានទេ៖** ប្រសិនបើ ភស្តុតាងត្រូវបានប្រមូលតាមវិធីដែលរំលោភលើសិទ្ធិ ភស្តុតាងនេះ មិនអាចទទួលយកបានដោយស្វ័យប្រវត្តិទេ។ កត្តាដែលត្រូវយកមកពិចារណា ជារួមមានវិធីប្រមូលយកភស្តុតាង ភាពអាចជឿជាក់បាននៃភស្តុតាង និងផលប៉ះពាល់ទៅលើសុចរិតភាពនៃដំណើរការនីតិវិធី។

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍ ស្តីពីសំណើសុំបដិសេធមោឃភាព អ.វ.ត.ក អ.ប.ជ ២៦ សីហា ២០០៨ កថា ខណ្ឌ ៤១។*

**សំណើសុំមោឃភាពកិច្ចស៊ើបសួរ និងកិច្ចទាំងអស់របស់ព្រះរាជអាជ្ញា ត្រូវបានបដិសេធ៖** នីតិវិធីមោឃភាព ត្រូវបានកំណត់ ដើម្បីធ្វើមោឃភាពលើផ្នែកជាក់លាក់ណាមួយ នៃដំណើរការនីតិវិធី ដែលធ្វើឲ្យខូចប្រយោជន៍របស់ជនត្រូវចោទ មិនមែនសម្រាប់ការធ្វើមោឃភាពកិច្ចស៊ើបសួរជាទូទៅទេ។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំមោឃភាព អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ ២៤។ រឿងក្តី នួន ជា អៀង សារី និង ខៀវ សំផន៖ ការស្នើសុំឲ្យមានកិច្ចស៊ើបអង្កេតតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលទាក់ទងទៅនឹងភាពមិនស៊ីសង្វាក់គ្នាទៅនឹងកំណត់ហេតុជាសម្លេង និងលាយលក្ខណ៍អក្សរ នៃការសម្ភាសន៍សាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អ.វ.ត.ក អ.ជ .ស.ជ ១៣ មីនា ២០១២ កថាខណ្ឌ ១០-១៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៦(៤) និង ៧៦(៧)។ វិធាន ៧៦(៤) គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៧៩ លើកលែងតែវិធាន ៧៦ (៤) នេះចែងបញ្ជាក់បន្ថែមថា ពាក្យសុំមិនអាចទទួលយកបានទេ ប្រសិនបើមិនមាន"មូលហេតុគ្រប់គ្រាន់"។ វិធាន ៧៦(៧) ចែងតម្រូវឲ្យភាគីដាក់សំណើសុំមោឃភាពឲ្យបានមុនដីកាដំណោះស្រាយ។ បើក្រោយរយៈពេលនេះ វិការៈនីតិវិធី ត្រូវបានចាត់ទុកថាបានជួសជុលរួច និងសំណើសុំមោឃភាពត្រូវបានចាត់ទុកថាគ្មានសុពលភាព។

# មាត្រា ២៨០៖ អានុភាពនៃមោឃកម្ម

*កាលណាបានទទួលបណ្តឹងសុំមោឃកម្មចំពោះកិច្ច ឬលិខិតណាមួយនៃនីតិវិធី ប្រសិនបើ សភាស៊ើបសួរ យល់ព្រមតាមពាក្យប្តឹងសុំនេះ សភាស៊ើបសួរ សម្រេចថាតើមោឃកម្មនេះ ត្រូវធ្វើទៅលើកិច្ច ឬលិខិតផ្សេងទៀតដែរឬទេ។*

*កិច្ច ឬលិខិត ដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។*

## *ការអនុវត្តនៅអ.វ.ត.ក*

**ឧបាស្រ័យនៃមោឃភាពដំណើរការនីតិវិធី ដែលជាបញ្ហាសារធាតុ៖** មោឃភាពផ្នែកសំខាន់មួយនៃដំណើរការនីតិវិធី ដែលជាបញ្ហាសារធាតុ អាចនាំឲ្យកិច្ចស៊ើបសួរទាំងមូល ក្លាយទៅជាមោឃៈ។ អង្គបុរេជំនុំជម្រះ ត្រូវកំណត់អំពីឧបាស្រ័យសម្រាប់វិការៈនីតិវិធី ដែលបានរកឃើញទៅតាមករណីនីមួយៗ។ មោឃភាពនៃកិច្ចស៊ើបសួរទាំងមូល គឺមិនរារាំងការដាក់ឯកសារ/ភស្តុតាងថ្មី និងគ្មានប្រឡាក់ប្រឡូកដែលកើតចេញពីកិច្ចស៊ើបសួរថ្មីចូលក្នុងសំណុំរឿងឡើយ។

*រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការសុំមោឃភាពកិច្ចស៊ើបសួរអ.វ.ត.ក អ.ប.ជ ២៥ មិថុនា ២០១០ កថាខណ្ឌ ២៦-២៧។*

**សំណើសុំមោឃភាពកិច្ច នៃស៊ើបសួរទាំងមូល និងកិច្ចរបស់ព្រះរាជអាជ្ញា ត្រូវបានបដិសេធ៖** នីតិវិធីមោឃភាព ត្រូវបានគេកំណត់ ដើម្បីធ្វើមោឃភាពផ្នែកជាក់លាក់ណាមួយនៃដំណើរការនីតិវិធីដែលធ្វើឲ្យខូចប្រយោជន៍របស់ជនត្រូវចោទមិនមែន សម្រាប់ធ្វើមោឃភាពកិច្ចស៊ើបសួរជាទូទៅទេ។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំមោឃភាព អ.វ.ត.ក អ.ប.ជ ៤ ឧសភា ២០១០ កថាខណ្ឌ ២៤។ រឿងក្តី នួន ជា អៀង សារី និងខៀវ សំផន៖ ការស្នើសុំឲ្យមានកិច្ចស៊ើបអង្កេតតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលទាក់ទងទៅនឹងភាពមិនស៊ីសង្វាក់គ្នា ទៅនឹងកំណត់ហេតុជាសម្លេង និងលាយលក្ខណ៍អក្សរ នៃការសម្ភាសន៍សាក្សីរបស់ការិយាល័យ សហចៅក្រមស៊ើបអង្កេត អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១២ កថាខណ្ឌ ១០-១៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៦(៥)។ វិធាននេះ គឺស្រដៀងគ្នាមែនទែន ទៅនឹងមាត្រា ២៨០ លើកលែងតែវិធាន ៧៦(៥) នេះចែងថា កាលណាមានតែផ្នែកមួយ ត្រូវបានទុកជាមោឃៈ ផ្នែកដែលបានមោឃៈនេះ ត្រូវបានទទួលស្គាល់ថាលុបចោល បន្ទាប់ពីបានទទួលច្បាប់ចម្លងដែលបញ្ជាក់ថាចម្លងត្រឹមត្រូវ និងទាំងស្រុងតាមដីកា ឬកិច្ចដើម ហើយគេបានហាមឃាត់មិនឲ្យមានការទាញសេចក្ដីសន្និដ្ឋានណាមួយចេញពីកិច្ច ឬដីកា ឬចេញពីផ្នែកដែលលុបចោលនោះមកប្រឆាំងភាគីនោះឡើយដោយភាគី ដែលចូលរួមក្នុងកិច្ចដែលជាកម្មវត្ថុនៃនីតិវិធីនៃការដាក់វិន័យ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**សភាស៊ើបសួរ ត្រូវតែកំណត់នៅរាល់កិច្ចដំណើរការនីតិវិធី ដែលមានទំនាក់ទំនងរវាងមូលហេតុទៅនឹងដំណើរការនីតិវិធី ដែលរងការជំទាស់៖** សភាស៊ើបសួរ ត្រូវតែប្រកាសមោឃភាពនៅរាល់កិច្ចស៊ើបសួរដែលកើតចេញពីកិច្ចដែលត្រូវបានគេប្រកាសថាមោឃៈ និងអសារឥតការ។

*លេខ69-91071 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៨៦ តុលាការកំពូលបារាំង ៤ មិថុនា ១៩៦៩។*

**អានុភាពនៃមោឃភាពនៃកិច្ចអង្កេតបឋម៖** អានុភាពនេះ មិននាំឲ្យមានមោឃភាពលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលផ្អែកលើឯកសារពាក់ព័ន្ធនឹងនីតិវិធីដទៃទៀតឡើយ។

*លេខ94-83490 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣១៣ តុលាការកំពូលបារាំង ៤ តុលា ១៩៩៤។*

**អានុភាពនៃមោឃភាពនៃកិច្ច ឬដីកាមួយទៅលើផ្នែកដទៃទៀត នៃដំណើរការនីតិវិធី៖** សភាស៊ើបសួរអាចសម្រេចបានដោយឯករាជ្យ យកវិធានការស៊ើបសួរដែលចាំបាច់ ដោយមិនគិតពីកិច្ច ឬដីការបស់ចៅក្រមស៊ើបអង្កេតក៏បាន។

*លេខ86-93988 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៧០ តុលាការកំពូលបារាំង ៦ តុលា ១៩៨៦។*

**កិច្ចដែលបានធ្វើមោឃភាព ត្រូវតែបានដកចេញពីសំណុំរឿង៖** ក្នុងអំឡុងពេលជំនុំជម្រះ គេមិនអាចទាញយកព័ត៌មានចេញពីកិច្ចទាំងនេះបានទេ។

*លេខ01-81054 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៧០ តុលាការកំពូលបារាំង ១៦ មករា ២០០២។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា ១៧៤ និងមាត្រា ២០៦។ មាត្រាទាំងនេះចែងពីការដឹកនាំធ្វើសវនាការចំពោះមុខសភាស៊ើបសួរ ដោយរាប់បញ្ចូលទាំងដំណើរការនីតិវិធី និងអានុភាពរបស់វាក្នុងករណីមានមោឃភាព។

# ការជំនុំជម្រះ

ផ្នែកនេះ ចែងពីសេចក្តីពន្យល់អំពីមាត្រាទាំងឡាយ នៃក្រមនីតិវិធីព្រហ្មកម្ពុជាដូចខាងក្រោមនេះ៖

- មាត្រា ២៨៩ សមត្ថកិច្ចរបស់សាលាដំបូង
- មាត្រា ២៩១ របៀបប្តឹងទៅតុលាការ
- មាត្រា ២៩៧ ការកោះហៅសាក្សី
- មាត្រា ២៩៩ ការបញ្ចូលនីតិវិធី
- មាត្រា ៣០០ ការចូលខ្លួនរបស់ជនជាប់ចោទ
- មាត្រា ៣០៥ ការបង្ហាញខ្លួនរបស់ជនជាប់ចោទតាមដីកាបញ្ជូន ឬសាលដីកាបញ្ជូន
- មាត្រា ៣០៦ ការដោះលែងជនជាប់ចោទដែលជាប់ឃុំឱ្យមានសេរីភាពដោយឯកឯង
- មាត្រា ៣០៧ បណ្តឹងសុំដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទដែលជាប់ឃុំ
- មាត្រា ៣១១ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការ
- មាត្រា ៣១៣ ជំនួយ និងការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- មាត្រា ៣១៥ ការចូលបង្ហាញខ្លួនរបស់សាក្សី
- មាត្រា ៣១៦ សាធារណភាពនៃកិច្ចពិភាក្សាដេញដោល និងភាពសម្ងាត់នៃកិច្ចពិភាក្សាដេញដោល
- មាត្រា ៣១៨ ការធានាសណ្តាប់ធ្នាប់នៃសវនាការ
- មាត្រា ៣២១ ការវាយតំលៃលើភស្តុតាងដោយតុលាការ
- មាត្រា ៣២២ វិធានទាក់ទងនឹងភាគី ដែលមានវត្តមាននៅក្នុងសវនាការ
- មាត្រា ៣២៥ ការសួរចម្លើយជនជាប់ចោទ
- មាត្រា ៣២៦ ការស្តាប់ចម្លើយរបស់ភាគី
- មាត្រា ៣៣០ ជំនួយ និងសម្បថរបស់អ្នកបកប្រែ
- មាត្រា ៣៣២ ការបង្ហាញវត្ថុតាង
- មាត្រា ៣៣៩ ព័ត៌មានបន្ថែមដែលបង្គាប់ដោយតុលាការ
- មាត្រា ៣៤២ សមត្ថកិច្ចរបស់តុលាការក្នុងរឿងអញ្ញត្រកម្ម

- មាត្រា ៣៥០ ការប្រកាសពីពិរុទ្ធភាព
- មាត្រា ៣៥៥ ការសម្រេចអំពីប្រយោជន៍ផ្នែករដ្ឋប្បវេណី

# មាត្រា ២៨៩៖ សមត្ថកិច្ចរបស់សាលាដំបូង

*សាលាដំបូង ជំនុំជម្រះបទឧក្រិដ្ឋទមជ្ឈិម និងបទលហុ។ សាលាដំបូង សម្រេចជាក្រុមសមូហភាពដែលមានចៅក្រម ៣ (បី) រូបចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុ ដែលជាប់ទាក់ទង។*

*សាលាដំបូង សម្រេចជាចៅក្រមទោលចំពោះបទមជ្ឈិម និងបទលហុ។*

## ការអនុវត្តនៅអ.វ.ត.ក

**អង្គជំនុំជម្រះសាលាដំបូង មិនអាចកំណត់អំពីភាពចាំបាច់ ភាពសមស្រប នៃដំណើរការនីតិវិធីរបស់អង្គបុរេជំនុំជម្រះបានឡើយ៖** អង្គជំនុំជម្រះសាលាដំបូង មិនមានយុត្តាធិការ ក្នុងការកំណត់ថាតើដំណើរការនីតិវិធី ចំពោះមុខអង្គបុរេជំនុំជម្រះមិន ឬមិនមានភាពចាំបាច់ ឬមិនសមស្របឡើយ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ សំណើសុំឲ្យមានការលោតត្រដាងឯកសារទាំងអស់ នៅក្នុងរឿងក្តី អ.ប.ជ ០៨ អ.វ.ត.ក អ.ប.ជ ១៥ កក្កដា ២០១១ កថាខណ្ឌ ៥។*

**សាលាក្តីត្រូវតែបដិសេធយុត្តាធិការ កាលណាការជំនុំជម្រះ អាចនឹងបំពានលើវិធាននៃច្បាប់។ ការបំពានទ្រឹស្តី នីតិវិធី ត្រូវបានបកស្រាយតាមន័យចង្អៀត៖** ការបំពានលើនីតិវិធី ដែលតម្រូវឲ្យសាលាក្តីបដិសេធ នូវការអនុវត្តយុត្តាធិការ គឺកម្រិតត្រឹមករណីទាំងឡាយ ដែលអំពើខុសច្បាប់នឹងនាំឲ្យមាន ការបំពានវិធាននៃច្បាប់ បើសិនតុលាការជំនុំជម្រះជនជាប់ចោទ។ កាលណាការបំពាន មិនចែងសម្រាប់តុលាការអន្តរជាតិទេ ទ្រឹស្តីនេះត្រូវបានកម្រឹតត្រឹមតែករណី នៃអំពើទារុណកម្ម ឬការធ្វើបាបធ្ងន់ធ្ងរ និងតែងតែអនុវត្តចំពោះនីតិវិធីនៃការចាប់ខ្លួន និងការបញ្ជូនខ្លួនជនត្រូវចោទ។

*រឿងក្តី ឌុច៖ សំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ស.ជ ១៥ មិថុនា ២០០៩ កថាខណ្ឌ ៣៣។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** មិនមានវិធានណាមួយស្រដៀងគ្នាទៅនឹងមាត្រា ២៨៩ ដោយផ្ទាល់ទេ។ ប៉ុន្តែ វិធាន ៧៩ ចែងពីបទប្បញ្ញត្តិទូទៅនៃដំណើរការនីតិវិធី ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងដកចេញនូវរាល់តួនាទីរបស់អង្គបុរេជំនុំជម្រះ លើកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍។

# មាត្រា ២៩១៖ របៀបប្ដឹងទៅតុលាការ

*ក្នុងរឿងព្រហ្មទណ្ឌ សាលាដំបូងត្រូវបានទទួលបណ្ដឹងដោយ៖*
*- ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ*
*- ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា*
*- កំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា*

*គ្រប់បុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការតាមនីតិវិធីណាមួយដូចខាងលើនេះ មានឈ្មោះថាជនជាប់ចោទ។*

*ជនរងគ្រោះនៃបទល្មើស អាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបាន នៅចំពោះមុខតុលាការ ប្រសិនបើខ្លួនពុំទាន់បានតាំងខ្លួននៅឡើយនៅមុខចៅក្រមស៊ើបសួរ។*

*មានឈ្មោះហៅថាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺបុគ្គលគ្រប់រូបដោយអនុវត្តតាមច្បាប់ ដែលត្រូវតែជួសជុលព្យសនកម្មដែលបណ្ដាលឱ្យមានដល់ជនរងគ្រោះនៃបទល្មើស។*

## ការអនុវត្តនៅអ.វ.ត.ក

**គ្មានមូលដ្ឋានណាមួយ ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យធ្វើវិសោធនកម្មលើដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ៖** អង្គជំនុំជម្រះសាលាដំបូង ក៏មិនអាចពិចារណាលើវិការៈ នៃនីតិវិធីក្នុងដំណើរការនៃកិច្ចស៊ើបសួរដែរ។

*រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ សេចក្ដីណែនាំអំពីកិច្ចប្រជុំរៀបចំសវនាការ ៨ មេសា ២០១១ កថាខណ្ឌ ២។*

**អង្គជំនុំជម្រះសាលាដំបូង ក៏អាចទទួលសំណុំរឿង ទោះបីជាស្ថិតនៅក្នុងពេលរង់ចាំសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ ដែលប្រឆាំងនឹងដីកាដំណោះស្រាយក៏ដោយ៖** ការបញ្ជូនរឿងក្ដីពីអង្គបុរេជំនុំជម្រះ តាមសំអាងហេតុនៃសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាដំណោះស្រាយ មិនមានផលប៉ះពាល់ទៅលើការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា ខ្លួនបានទទួលដីកាបញ្ជូនរឿងទៅជម្រះប្រឆាំងនឹងជនជាប់ចោទត្រឹមត្រូវ ក្នុងករណី ដែលបានបំពេញតាមលក្ខខណ្ឌនៃពេលវេលាកំណត់ទាំងអស់។

*រឿងក្ដី អៀង សារី៖ សំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ស.ដ ១២ ឧសភា ២០១១ កថាខណ្ឌ ១០-១២។*

**ព្យសនកម្មពុំចាំបាច់ ដោយផ្ទាល់នោះទេ៖** ព្យសនកម្មក្នុងពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែមានលក្ខណៈជាបុគ្គល ប៉ុន្តែមិនចាំបាច់ដោយផ្ទាល់ទេ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអ.វ.ត.ក អ.ជ.ស.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៨៣។*

**ព្យសនកម្ម លើសមាជិកគ្រួសារ៖** ព្យសនកម្មត្រូវតែមានលក្ខណៈជាបុគ្គល ប៉ុន្តែស្ថិតក្រោមកាលៈទេសៈពិសេសជាក់លាក់ អាចត្រូវបានបង្កដោយការអន្តរាយ ទៅលើសមាជិកគ្រួសារ។

*រឿងក្តី ឌុច៖ សាលក្រម អ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ ៦២១។*

**ភស្តុតាងបញ្ជាក់ ពីព្យសនកម្មផ្ទាល់លើសមាជិកគ្រួសារសាច់ឆ្ងាយ៖** ក្នុងករណី លើកលែងតែជនរងគ្រោះ ដែលជាសមាជិកគ្រួសារសាច់ឆ្ងាយ ដែលអាចបង្ហាញពីព្យសនកម្មផ្ទាល់ ពីបទល្មើសឧក្រិដ្ឋ ប្រសិនភាគីអាចបង្ហាញពីចំណងសាច់ញាតិ និងចំណងទាក់ទងពិសេសបាន។

*រឿងក្តី ឌុច៖ សាលក្រមអ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ ៦២៣។*

**ព្យសនកម្ម ត្រូវតែកើតចេញដោយផ្ទាល់ពីអំពើរបស់ជនជាប់ចោទ៖** អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបង្ហាញថា ព្យសនកម្ម គឺជាលទ្ធផលដោយផ្ទាល់នៃបទល្មើសរបស់ជនជាប់ចោទ ដែលកំពុងត្រូវបានស៊ើបសួរ។

*រឿងក្តី ឌុច៖ សាលក្រមអ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ ៦៤៧។*

**ការបដិសេធចោលនូវពាក្យសុំ ដែលមិនបានបង្ហាញពីព្យសនកម្មដោយផ្ទាល់៖** ចៅក្រមស៊ើបសួរ អាចបដិសេធចោលនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើខ្លួនពិនិត្យឃើញថា ពាក្យសុំនោះ មិនបានបង្ហាញថា ព្យសនោះកម្មនកើតចេញដោយផ្ទាល់ពីបទល្មើសរបស់ជនជាប់ចោទ ដែលរងការចោទប្រកាន់។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ អំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៧ មេសា ២០១០ កថាខណ្ឌ ៤៩។*

**ជនរងគ្រោះ ដែលចោទប្រកាន់ ពីអង្គហេតុថ្មី៖** ជនរងគ្រោះដែលចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចលើកឡើងពីអង្គហេតុថ្មីៗសម្រាប់គោលបំណងឲ្យស៊ើបសួរបានទេ ប៉ុន្តែអាចចោទប្រកាន់អង្គហេតុថ្មី ដែលអាចបង្ហាញពីទំនាក់ទំនងមូលហេតុ ភ្ជាប់ទៅនឹងព្យសនកម្មដែលខ្លួនបានទទួលរង ហើយយ៉ាងហោចណាស់ភ្ជាប់ទៅនឹងបទល្មើសមួយ ដែលបានចោទប្រកាន់ជនជាប់ចោទ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានស្រាប់។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ អំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៤២។*

**ទំនាក់ទំនងទៅនឹងជនត្រូវចោទរួម អាចជាការគ្រប់គ្រាន់៖** ក្នុងបណ្តឹងទាមទារប្រឆាំងនឹងជនជាប់ចោទច្រើននាក់ រាប់ទាំងករណីប្រឆាំងនឹងបុគ្គលនានា និងរួមគ្នាជាក្រុម ក្នុងសហកម្មឧក្រិដ្ឋកម្មរួម (ឬក្នុងទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀត) ម្ចាស់សំណើ ត្រូវតែបង្ហាញពីទំនាក់ទំនងទៅនឹងជនត្រូវចោទជារួម ជាជាងជនត្រូវចោទម្នាក់ៗ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ អំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៧១-៧៣។*

**ព្យសនកម្មផ្លូវចិត្ត ដែលកើតចេញពីអំពើប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើ ជនរងគ្រោះស្ថិតក្នុងក្រុមទិសដៅនៃការវាយប្រហារ៖** ក្នុងករណីមានឧក្រិដ្ឋកម្មដូចជា អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កាលណាអ្នកស្នើសុំនោះជាជនរងគ្រោះដោយប្រយោល (ឧទាហរណ៍ ជាសាក្សី ឬជាជនដែលបានដឹងពីបទឧក្រិដ្ឋដែលបានចោទប្រកាន់) ត្រូវចាត់ទុកថា មានព្យសនកម្មផ្លូវចិត្តដោយផ្ទាល់ ប្រសិនបើអ្នកស្នើសុំទំនងជាសមាជិក នៃក្រុមទិសដៅ ឬសហគមន៍ជាមួយជនរងគ្រោះដោយផ្ទាល់។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៩៣។*

**ព្យសនកម្មលើសម្ភារៈ៖** ព្យសនកម្មជារួមមានការបាត់បង់ទ្រព្យសម្បត្តិ ឬប្រាក់ចំណូល។

*រឿងក្តី ឌុចៈ សាលក្រមអ.វ.ត.ក អ.ជ.ស.ដ ២៦ កក្កដា ២០១០ កថាខណ្ឌ ៦៤១។*

**ព្យសនកម្មផ្លូវចិត្ត៖** ព្យសនកម្មខាងផ្លូវចិត្តអាចរួមទាំងជំងឺផ្លូវចិត្ត ឬវិកលចរិតពីការបាក់ស្បាតដូចជាជំងឺបាក់ស្បាត។

*រឿងក្តី ឌុចៈ សាលក្រម អ.វ.ត.ក អ.ជ.ស.ដ ២៦ កក្កដា ២០១០ កថាខណ្ឌ ៦៤១។ រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៨៣។*

**ព្យសនកម្មផ្លូវចិត្ត អាចកើតចេញពីបទឧក្រិដ្ឋប្រឆាំងនឹងគ្រួសារសាច់ជិត និងបុគ្គលដទៃមួយចំនួនទៀត៖** មិនគប្បីបកស្រាយព្យសនកម្មផ្លូវចិត្តក្នុងន័យតូចចង្អៀត ត្រឹមតែបទល្មើសដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងសមាជិកគ្រួសារសាច់ជិតទេ។ ប៉ុន្តែត្រូវគិតពីបុគ្គលច្រើនទៀត

ដូចជាសមាជិកគ្រួសារសាច់ឆ្ងាយ មិត្តភក្តិអ្នកជិតខាង និងជនទាំងឡាយ ដែលមានចំណងមនោសញ្ចេតនាតាមវប្បធម៌ និងសង្គមខ្មែរផងដែរ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីភាពអាចទទួលយកបាននៃពាក្យ សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៤៩ ៨៧ និង៨៨។*

**តុលាការ ត្រូវតែពិចារណាពីការបង្កឲ្យមានការរងគ្រោះខាងផ្លូវចិត្ត ទៅតាមបរិបទ៖** ក្នុងការវាយតម្លៃពីព្យសនកម្មផ្លូវចិត្ត ក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តុលាការ ចាំបាច់ត្រូវតែពិចារណាអំពីការបង្កឲ្យរងគ្រោះ នៅក្នុងបរិបទសង្គម និងវប្បធម៌ អំឡុងពេលមានបទល្មើស ដែលត្រូវបានចោទប្រកាន់។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៨៣ និង ៨៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៩។ វិធាននេះចែងថា អង្គជំនុំជម្រះសាលាដំបូងទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះពីចៅក្រមស៊ើបសួរ ឬអង្គបុរេជំនុំជម្រះ។ ខុសពីតុលាការកម្ពុជាផ្សេងទៀត អ.វ.ត.ក មិនអាចទទួលដីកានេះក្នុងមធ្យោបាយផ្សេងពីនេះទេ។ លើសពីនេះ នៅអ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រឹមដាក់ពាក្យសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរហូតដល់ ១៥ថ្ងៃ ក្រោយបញ្ចប់ការស៊ើបអង្កេត (វិធាន ២៣ស្ទួន)។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានសិទ្ធិចូលរួមនៅក្នុងការជំនុំជម្រះ៖** បុគ្គលទាំងនោះ ជារួមមានជនទាំងឡាយ ដែលចង់បានការជំនុំជម្រះមួយដោយយុត្តិធម៌ និងសវនាការជាសាធារណៈ ជាបុគ្គលដែលចោទប្រកាន់ភ្នាក់ងាររដ្ឋថា បានប្រព្រឹត្តអំពើធ្វើបាបមិនមែនជាបុគ្គល ដែលគ្រាន់តែចង់សម្រេចគោលបំណងសងសឹកផ្ទាល់ខ្លួនទេ និងបុគ្គលដែលចោទប្រកាន់លើការធ្វើទុក្ខបុកម្នេញ ដោយភ្នាក់ងាររដ្ឋ។

*រឿងក្ដី PEREZ ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១២ កុម្ភៈ ២០០៤ កថាខណ្ឌ៧៤-៧៩ (ដើមបណ្ដឹងរដ្ឋប្បវេណី ដែលចង់បានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងសវនាការជាសាធារណៈ) រឿងក្ដី SIGALAS ទល់នឹងប្រទេសក្រិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ២២ កញ្ញា ២០០៥ កថាខណ្ឌ ២៧ (បណ្ដឹងរដ្ឋប្បវេណី មិនមែនជាការសងសឹក) រឿងក្ដី AKSOY ទល់ទៅនឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៨ ធ្នូ ១៩៩៦ កថាខណ្ឌ ៩២ (បទល្មើសប្រព្រឹត្តដោយភ្នាក់ងាររដ្ឋ)។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុប ស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា ៦(១)។ មាត្រានេះចែងពីសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ រួមទាំងសិទ្ធិរបស់បុគ្គល ដែលទទួលរងការចោទ ប្រកាន់ពីបទល្មើសព្រហ្មទណ្ឌក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈក្នុងរយៈពេលសមស្រប នៅចំពោះមុខតុលាការឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំង ពោលគឺតុលាការកំពូល។*

**ទោះបីជាករណី ដែលតុលាការមិនមានសមត្ថកិច្ចជួសជុលការខូចខាត ដែលបង្កឡើងដោយជនជាប់ចោទក្ដី ក៏ខ្លួនអាចទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីបានដែរ៖** តុលាការ អាចធ្វើបែបនេះបាន កាលណាដើមបណ្ដឹងរដ្ឋប្បវេណី មានចេតនាបង្ហាញពីពិរុទ្ធភាពព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដើម្បីគាំទ្រពាក្យបណ្ដឹងរបស់ខ្លួន។

*លេខ 69-92311 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៨២ តុលាការកំពូលបារាំង ៨ មិថុនា១៩៧១។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា ២៣១ ៣៨៨ ៤១៨ និង៥៣១។ មាត្រាទាំងនេះ ចែងពីនីតិវិធី ដែលតុលាការផ្សេងៗគ្នា។ ក្នុងប្រព័ន្ធបារាំង អាចយកមកប្រើ និងកំណត់ពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន និងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណីនីមួយៗ។

# មាត្រា ២៩៧៖ ការកោះហៅសាក្សី

*សាក្សីខាងដាក់បន្ទុក ដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឲ្យចូលរួមក្នុងសវនាការ។*

## ការអនុវត្តនៅ អ.វ.ត.ក

កាលណាប្រតិចារឹត ឬចម្លើយក្លាយជាភស្តុតាងជាលាយលក្ខណ៍អក្សរ នៃអំពើណាមួយ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ឱកាសត្រូវតទល់នឹងភស្តុតាង ត្រូវតែលៃលកឲ្យបាន ចំពោះជននោះ៖ កាលណាឱកាសក្នុងការតទល់នឹងភស្តុតាងរបស់សាក្សី មិនអាចធ្វើទៅបានទេប្រឆាំងនឹងជនជាប់ចោទ ក្នុងអំឡុងពេលនៃដំណើរការនៃការស៊ើបអង្កេតទេ ជាពិសេស នៅពេលទាក់ទងទៅនឹងអំពើ ឬការប្រព្រឹត្តរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូង ត្រូវតែលៃលកធ្វើយ៉ាងណាឲ្យជនជាប់ចោទ មានឱកាសដោយផ្ទាល់ ដើម្បីតទល់ជាមួយនឹងភស្តុតាង នៅពេលដំណើរការជំនុំជម្រះ។

*រឿងក្តី នួន ជា អៀង សារី និងខៀវ សំផន៖ សេចក្តីសន្និដ្ឋាន របស់សហព្រះរាជអាជ្ញា ផ្អែកតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ចំពោះការទទួលយកចម្លើយរបស់សាក្សី និង ORS អ.វ.ត.ក អ.ជ.ស.ជ ១២ មិថុនា ២០១២ កថាខណ្ឌ ២១-២៥។ រឿងក្តី នួន ជា អៀង សារី និង ខៀវ សំផន៖ សេចក្តីសម្រេចលើការស្នើសុំ នៃក្រុមមេធាវីការពារទាក់ទងទៅនឹងភាពមិនប្រក្រតីបានអះអាងថាបានកើតមានឡើងនៅអំឡុងពេល នៃការស៊ើបអង្កេតតាមផ្លូវតុលាការ អ.ជ.ស.ជ ៧ ធ្នូ ២០១២ កថាខណ្ឌ ២៦។ រឿងក្តី នួន ជា និងខៀវ សំផន ៖ សេចក្តីសម្រេចស្តីពីការបដិសេធការទទួលស្គាល់សាក្សីចម្លើយជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អ.ជ.ស.ជ ១២ សីហា ២០១៣ កថាខណ្ឌ ១៧។ សេចក្តីសម្រេចស្ថាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវដំណើរការសវនាការក្នុងសំណុំរឿង ០០២/០១ អ.វ.ត.ក អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ២២-២៦។ រឿងក្តី នួន ជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.វ.ត.ក អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ ៥០-៥៣។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអកៈ.ត.វ.** វិធាន ៤១ និង ៨៤នៃវិធានផ្ទៃក្នុង អ.វ.ត.ក ។ វិធាន ៨៤ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ចែងអំពីសិទ្ធិរបស់ជនជាប់ចោទ ក្នុងការកោះហៅសាក្សីនៅក្នុងសវនាការជាដាច់ខាត ក្នុងករណីដែលជននោះមិនមានឱកាស ដើម្បីតទល់នឹងសាក្សីក្នុងអំឡុងពេលសវនាការមុនអង្គសេចក្តី។

# មាត្រា ២៩៩៖ ការបញ្ចូលនីតិវិធី

*កាលណាតុលាការបានទទួលនីតិវិធីច្រើន ដែលមានអង្គហេតុច្រើនជាប់ទាក់ទងគ្នា តុលាការអាចបង្គាប់ឱ្យបញ្ចូលនីតិវិធីទាំងនោះជាមួយគ្នាបាន។*

## ការអនុវត្តនៅអ.វ.ត.ក

បណ្តឹងឧទ្ធរណ៍សុំឲ្យពិចារណាឡើងវិញ អាចសម្រេចបានរួមគ្នាបាន បើទោះបីជាក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ ត្រូវបានគេធ្វើឡើងតាមមូលដ្ឋានផ្សេងគ្នាក្តី៖ ក្នុងប្រយោជន៍យុត្តិធម៌ និងប្រសិទ្ធភាពនៃតុលាការ បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងការច្រានចោលនូវពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ចៅក្រសុើបសួរ អាចត្រូវបានពិនិត្យនិងសម្រេចរួមគ្នាបាន ទោះបីជាក្នុងករណី ដែលបណ្តឹងឧទ្ធរណ៍ ត្រូវបានផ្តើមឡើងតាមមូលដ្ឋានផ្សេងគ្នាក្តី ប្រសិនបើមានកំហុសឆ្គងជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ និងប្រសិនបើកំហុសនោះមានភាពពាក់ព័ន្ធ ទៅនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវបានច្រានចោល និងប្រសិនបើភាពអយុត្តិធម៌ខ្លាំងកើតឡើង ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានច្រានចោល មិនបានលើកឡើង ពីកំហុសឆ្គងដែលរកឃើញដោយអង្គបុរេជំនុំជម្រះ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍អំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌទី ៣៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** មិនមានវិធានណាមួយស្រដៀងគ្នាទៅនឹងមាត្រានេះទេ។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំង គឺតុលាការកំពូល។*

**ទំនាក់ទំនងរវាងបទល្មើស និងបទល្មើសដែលចាំបាច់ត្រូវបញ្ចូលគ្នា៖** ចៅក្រម ត្រូវតែបង្ហាញពីទំនាក់ទំនងនេះ ដើម្បីបញ្ចូលរឿងក្តីរួមគ្នា។ ប៉ុន្តែចៅក្រម មិនចាំបាច់បង្ហាញពីការមិនដាក់រឿងក្តីរួមគ្នា នៅក្នុងសេចក្តីសម្រេចនោះទេ។

*លេខ 92-81941 តុលាការកំពូលបារាំង ២៧ កញ្ញា ១៩៩៥ (ទំនាក់ទំនងដែលចាំបាច់)។ លេខ 91-82210 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៥០ តុលាការកំពូលបារាំង ៧ មេសា ១៩៩២ (ភាពគ្មានទំនាក់ទំនង ដែលមិនមែនជាចាំបាច់ចំពោះសេចក្តីសម្រេចមិនដាក់រួមគ្នា)។*

**ការដាក់រឿងក្តីរួមគ្នា គឺជាវិធានការរដ្ឋបាល ដែលជាទូទៅមិនអាចជាកម្មវត្ថុ នៃមោឃភាពទេ៖** មានការលើកលែង ប្រសិនបើមានការរំលោភទៅលើសិទ្ធិការពារខ្លួន។

*ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ២៨៦ តុលាការកំពូលបារាំង ៣ មិថុនា ១៩៨៩។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** មាត្រា ២០៣។ មាត្រានេះចែងពីការដាក់បញ្ចូលរឿងក្តី កាលណាបទល្មើសទាក់ទងគ្នា រួមទាំងការចែងពីអ្វីដែលអាចជាបទល្មើសពាក់ព័ន្ធទៀតផង។

# មាត្រា ៣០០៖ ការចូលខ្លួនរបស់ជនជាប់ចោទ

*ជនជាប់ចោទ ត្រូវបង្ហាញខ្លួន នៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទ ត្រូវអម ដោយមេធាវីម្នាក់ ដែលខ្លួនបានជ្រើសរើស។ ជនជាប់ចោទ ក៏អាចសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរ នៅក្នុងលក្ខណ្ឌ ដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។*

## ការអនុវត្តនៅ អ.វ.ត.ក

ជនជាប់ចោទមានសិទ្ធិ មានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្ហាញខ្លួនអំឡុងពេលនៃដំណើរការនីតិវិធី៖ ជននោះអាចជ្រើសរើស ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីចម្ងាយ ដោយហេតុថា ជននោះមានតំណាងផ្លូវច្បាប់ពេញលេញនៅអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។

*រឿងក្តី អៀង សារី៖ សម្បទាក្នុងការចូលរួមក្នុងសវនាការ អ.វ.ត.ក អ.ជ.ស.ដ ២៦ វិច្ឆិកា ២០១២ កថាខណ្ឌ ១៩។ រឿងក្តី អៀង សារី៖ សេចក្តីសម្រេចស្តីពីការស្នើសុំរបស់មេធាវីការពារ អៀង សារី នូវកំណត់ហេតុជាសម្លេងនិងឬវិឌីអូ ដែល អៀង សារី ស្ថិតនៅក្នុងបន្ទប់ឃុំឃាំង អ.វ.ត.ក អ.ជ.ស.ដ ១៦ មករា ២០១៣ កថាខណ្ឌ ១៣-១៥។*

អវត្តមានរបស់ជនជាប់ចោទ ពីការចូលរួមក្នុងការជំនុំជម្រះ មិនអនុញ្ញាតឲ្យជនជាប់ចោទមានសិទ្ធិថតនៅក្នុងបន្ទប់របស់គាត់បានឡើយ៖ អវត្តមានដោយចេតនា របស់ជនជាប់ចោទពីកិច្ចដំណើរការនីតិវិធី បន្ទាប់ពីមានការវាយតម្លៃផ្នែកវេជ្ជសាស្ត្រសមស្រប ចំពោះសម្បទារបស់គាត់ នៅក្នុងការចូលរួមសវនាការរួចមក បានសន្និដ្ឋានថា គាត់មានសម្បទានៅក្នុងការចូលរួមនេះ នោះសិទ្ធិរបស់គាត់ក្នុងការថតជាសម្លេង ឬវីឌីអូ ក្នុងបន្ទប់របស់គាត់មិនត្រូវបានអនុញ្ញាតទេ ដើម្បីបង្កើតឲ្យមានឡើងវិញអំពីកង្វះនៃសម្បទា ដោយហេតុថាមានវិធានការផ្សេងៗ ដែលមានស្រាប់ ដើម្បីធានាថាសុខភាពរបស់គាត់ កំពុងត្រូវបានឃ្លាំមើលយ៉ាងយកចិត្តទុកដាក់។

*រឿងក្តី អៀង សារី៖ សេចក្តីសម្រេចស្តីពីការស្នើសុំរបស់មេធាវីការពារ អៀង សារី នូវកំណត់ហេតុជាសម្លេង និង ឬវិឌីអូ ដែល អៀង សារី ស្ថិតនៅក្នុងបន្ទប់ឃុំឃាំង អ.វ.ត.ក អ.ជ.ស.ដ ១៦ មករា ២០១៣ កថាខណ្ឌ ១៣-១៥។*

**កិច្ចខិតខំប្រឹងប្រែង យ៉ាងសមហេតុផលត្រូវតែធ្វើឡើង ដើម្បីតម្រូវតាមស្ថានភាពជម្ងឺផ្លូវកាយរបស់ជនជាប់ចោទ ក្នុងគោលបំណងធានា នូវការចូលរួមរបស់គាត់ក្នុងសវនាការ៖** កាលណាជនជាប់ចោទមានសម្បទាក្នុងការចូលរួមសវនាការ តែយ៉ាងណាក៏ដោយ សុខភាពរបស់គាត់ទន់ខ្សោយ ឬទទួលរងនូវជម្ងឺផ្លូវកាយ ឬផ្លូវចិត្ត នោះអង្គជំនុំជម្រះត្រូវខិតខំប្រឹងប្រែង ឲ្យបានគ្រប់ហេតុផលទាំងអស់ ដើម្បីធានាអំពីការចូលរួមរបស់គាត់ក្នុងដំណើរការសវនាការ។

*រឿងក្តី នួន ជា៖ សេចក្តីសម្រេចលើកទី២ ស្តីពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ដ ២ មេសា ២០១៣ កថាខណ្ឌ ២៨។*

ប្រធានអង្គជំនុំជម្រះ អាចដាក់ទណ្ឌកម្មលើកិរិយាមិនត្រឹមត្រូវរបស់ក្រុមមេធាវីការពារ ឬបដិសេធមិនឲ្យមេធាវីចូលរួមសវនាការ បន្ទាប់ពីការព្រមានត្រូវបានធ្វើឡើង ប្រសិនបើកិរិយារបស់មេធាវីមានលក្ខណៈប្រមាថ មើលងាយ ឬហួសប្រមាណ៖ ប្រធានអង្គជំនុំជម្រះ អាចយោងបន្ថែមដល់កិរិយាមិនត្រឹមត្រូវរបស់មេធាវីចំពោះស្ថាប័នវិជ្ជាជីវៈសមស្របណាមួយ។

*រឿងក្តីនួន ជា៖ សេចក្តីសម្រេច ស្តីពីកិរិយាមិនត្រឹមត្រូវរបស់មេធាវីការពារ នួន ជា អ.វ.ត.ក អ.ជ.ស.ដ ២៩ មិថុនា ២០១៣ កថាខណ្ឌ៣។*

***វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអកៈ.ត.វ.*** វិធាន២២។ វិធានផ្ទៃក្នុង អ.វ.ត.ក ចែងអំពីបទបញ្ញត្តិដ៏វែងអន្លាយទាក់ទងទៅនឹងការដាក់បញ្ចូលមេធាវីបរទេសទៅក្នុងក្រុមច្បាប់របស់អ.វ.ត.ក ព្រមទាំងវិធីសាស្រ្ត ដែលមេធាវីទាំងនោះត្រូវបំពេញករណីយកិច្ចរបស់គេ។

# មាត្រា ៣០៥៖ ការបង្ហាញខ្លួនរបស់ជនជាប់ចោទតាមដីកាបញ្ជូន ឬសាលដីកាបញ្ជូន

*ក្នុងករណីដែលតុលាការទទួលបណ្តឹង តាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី លើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរបានសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។*

*ព្រះរាជអាជ្ញា ចាត់វិធានការចាំបាច់ ដើម្បីឱ្យជនជាប់ចោទដែលត្រូវបានឃុំខ្លួន ត្រូវបាននាំទៅកាន់សវនាការដោយកងកម្លាំងសាធារណៈ។*

*ដូចដែលបានចែងនៅក្នុងមាត្រា ២៤៩ (សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ សេចក្តីសម្រេចរក្សាទុកខ្លួនជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ត្រូវអស់អានុភាពនៅពេលផុតចិរវេលា ៤ (បួន) ខែ។ ប្រសិនបើជនជាប់ចោទ មិនត្រូវបានឱ្យចូលទៅបង្ហាញខ្លួន នៅមុខតុលាការក្នុងរយៈពេលនេះទេ ជនជាប់ចោទ ត្រូវតែបានដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង។*

*សាលក្រមលើអង្គសេចក្តី ត្រូវធ្វើឡើងក្នុងរយៈពេលសមហេតុផល។*

*ជនជាប់ចោទដែលចូលបង្ហាញខ្លួននៅពេលសវនាការ ក្នុងឋានៈជាជនជាប់ឃុំនោះ នៅតែជាប់ឃុំដដែល រហូតដល់មានសាលក្រមលើអង្គសេចក្តី លើកលែងតែតុលាការបង្គាប់ឱ្យដោះលែងឱ្យមានសេរីភាពវិញ។*

## ***ការអនុវត្តនៅអ.វ.ត.ក***

**ភាពចាំបាច់ ក្នុងការថ្លឹងថ្លែងរវាងការឃុំខ្លួន និងសេរីភាព៖** តុលាការត្រូវតែថ្លឹងថ្លែង រវាងមូលហេតុសម្រាប់ឃុំខ្លួន និងសិទ្ធិសេរីភាពបុគ្គល។ សច្ចធារណ៍នៃសេរីភាព តម្រូវឲ្យសេចក្តីសម្រេចតុលាការក្នុងការឃុំខ្លួន មានមូលដ្ឋានគ្រប់គ្រាន់ និងត្រូវបានចេញ ដោយអនុលោមតាមនីតិវិធី និងលក្ខខណ្ឌច្បាប់។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗស្តីពីការស្នើសុំនៅក្រៅឃុំ អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌទី ៤៧ និង៥៦។*

*រឿងក្តី អៀង ធីរិទ្ធ៖ សម្បទានៅក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ៨០។ រឿងក្តីអៀង ធីរិទ្ធ៖*

*សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ២២។ រឿងក្តី នួន ជា៖ សេចក្តីសម្រេចលើកទី២ ស្តីពីសម្បទា របស់នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ ១៦។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ តុលាការកំពូល) អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១៣ កថាខណ្ឌ ១។ រឿងក្តី អៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹង ឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទក្នុងការឃុំឃាំងដោយមានលក្ខខណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធី និងការដោះលែងដោយឥតលក្ខខណ្ឌ ចំពោះបុគ្គលពាក់ព័ន្ធ គឺចៀសមិនផុតពីផលវិបាកឡើយ)។*

**ជនជាប់ចោទ ត្រូវបានឃុំខ្លួននៅពេលបង្ហាញខ្លួនលើកដំបូង៖** ជនជាប់ចោទ ដែលត្រូវបានឃុំខ្លួននៅពេលបង្ហាញខ្លួនលើកដំបូង ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ត្រូវបន្តស្ថិតក្នុងការឃុំខ្លួនរហូតដល់ពេល អង្គជំនុំជម្រះចេញសាលក្រម ដរាបណាតុលាការមានមូលដ្ឋានស្របច្បាប់ក្នុងការឃុំខ្លួន។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗស្តីពីការស្នើសុំនៅក្រៅឃុំ អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌទី ៤៧ -៤៩។*

**ត្រូវតែអានមាត្រាច្បាប់ នៅពេលពិនិត្យមើលពីសច្ចធារណ៍នៃសេរីភាព៖** ប្រព័ន្ធច្បាប់កម្ពុជា គឺជាមូលដ្ឋានគ្រឹះនៃការពារសិទ្ធិមានសេរីភាព ហើយត្រូវអានមាត្រា ៣០៥ ដល់ ៣០៧ នៅពេលពិនិត្យមើលសច្ចធារណ៍នៃសេរីភាព។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗស្តីពីបណ្តឹងសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌទី ៤៦។*

**ការសន្មតថា លក្ខខណ្ឌដែលធានាពីដំបូងថាត្រូវបន្តការឃុំខ្លួនបណ្តោះអាសន្ន គឺជាការសន្មតតាមអង្គហេតុ និងអាចជំទាស់បាន៖** ការសន្មតនេះមិនចងកាតព្វកិច្ច លើអង្គជំនុំជម្រះសាលាដំបូងឡើយ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង វាយតម្លៃពីភាពស្របច្បាប់នៃការឃុំខ្លួន តាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួននោះ ឬក៏តាមសំណើរបស់ជនជាប់ចោទ ការពិនិត្យឡើងវិញរបស់ខ្លួន ត្រូវតែបានធ្វើឡើងប្រកបដោយអត្ថន័យ។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗស្តីពីបណ្តឹងសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌទី ៤៨-៤៩។*

**ជនជាប់ចោទ មានបន្ទុកផ្តល់ភស្តុតាង ដើម្បីតវ៉ាចំពោះមូលហេតុនៃការឃុំខ្លួន៖** ចាប់ពីពេលនៃការបង្ហាញខ្លួនជាលើកដំបូង នៅចំពោះមុខ

អង្គជំនុំជម្រះសាលាដំបូង រហូតដល់ពេលអង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីសម្រេចរបស់ខ្លួន ជនជាប់ចោទមានបន្ទុកក្នុងការផ្តល់នូវភស្តុតាង ដើម្បីតវ៉ាចំពោះមូលហេតុនៃការឃុំខ្លួន ដោយការដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង។

*រឿងក្តី ខៀវ សំផនៈ បណ្តឹងឧទ្ធរណ៍ភ្លាមៗស្តីពីបណ្តឹងសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌទី ៤៨។*

**អង្គជំនុំជម្រះតុលាការកំពូល អាចផ្អែកលើការសន្មតនៃលក្ខខណ្ឌបន្តនៃការឃុំខ្លួន៖** កាលណាអង្គជំនុំជម្រះសាលាដំបូង ផ្តល់នូវសំអាងហេតុមិនគ្រប់គ្រាន់ ដើម្បីធ្វើជាយុត្តិកម្មភាពស្របច្បាប់នៃការឃុំខ្លួនជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូល អាចតម្កល់សុពលភាពនៃការឃុំខ្លួនដោយផ្អែកលើសច្ចធារណ៍នៃលក្ខខណ្ឌបន្តការឃុំខ្លួន ដែលអាចបដិសេធចោលបាន។

*រឿងក្តី ខៀវ សំផនៈ បណ្តឹងឧទ្ធរណ៍ភ្លាមៗស្តីពីបណ្តឹងសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌទី ៥៤។*

**ជនជាប់ចោទ ត្រូវតែផ្តល់ភស្តុតាងតាមកាលៈទេសៈ/លក្ខខណ្ឌដែលធានាឲ្យខ្លួនបាននៅក្រៅឃុំ៖** ជនជាប់ចោទ មានបន្ទុកក្នុងការផ្តល់ភស្តុតាងពីកាលៈទេសៈអង្គហេតុ និងលក្ខខណ្ឌដែលអាចធានាឲ្យខ្លួនបាននៅក្រៅឃុំ។ មានតែករណីដែលជនជាប់ចោទ បានបំពេញតាមលក្ខខណ្ឌនេះទេ ទើបតុលាការ ត្រូវវាយតម្លៃទៅលើភាពគ្រប់គ្រាន់ ក្នុងការដាក់នៅក្រៅឃុំ ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

*រឿងក្តី ខៀវ សំផនៈ បណ្តឹងឧទ្ធរណ៍ភ្លាមៗស្តីពីបណ្តឹងសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌទី ៥៧។*

**ករណីដែលសេចក្តីសម្រេច បដិសេធការឲ្យនៅក្រៅឃុំរបស់អង្គជំនុំជម្រះសាលាដំបូង នឹងត្រូវបានតម្កល់៖** កាលណាជនជាប់ចោទមិនបានផ្តល់នូវព័ត៌មានលំអិតដល់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងមធ្យោបាយ ដែលធានាពីវត្តមានរបស់ខ្លួននៅក្នុងតុលាការ។

*រឿងក្តី ខៀវ សំផនៈ បណ្តឹងឧទ្ធរណ៍ភ្លាមៗស្តីពីបណ្តឹងសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌទី ៥៧-៥៨។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៨២(១) និង ៦៨(៣)។ វិធាន ៨២(១) នេះគឺស្រដៀងគ្នាមែនទែនទៅនឹងបញ្ញត្តិដំបូង និងបញ្ញត្តិចុងក្រោយ នៃមាត្រា ៣០៥។ វិធាន ៦៨(៣) ស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ២៤៩ ដែលចែងពីការផុតរយៈពេលឃុំខ្លួនបណ្តោះអាសន្នក្នុងពេល ៤ខែ លើកលែងតែក្នុងអំឡុងពេលនេះ ជនជាប់ចោទ ត្រូវបាននាំទៅជំនុំជម្រះ នៅចំពោះមុខតុលាការជំនុំជម្រះលើអង្គសេចក្តី។

# ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***គណៈកម្មាធិការសិទ្ធមនុស្សអ.ស.ប***
*ប្រទេសកម្ពុជាគឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តពីគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប។*

**ការរំលោភ៖ ការបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវរង់ចាំជាច្រើនឆ្នាំ ដោយគ្មានការវិនិច្ឆ័យទោសចុងក្រោយ៖** ក្នុងស្ថានភាពនេះ ពេលដែលគ្មានការពន្យល់ពីរដ្ឋ អំពីយុត្តិកម្ម នៃការយឺតយ៉ាវនីតិវិធីទេ វាគឺជាការរំលោភទលើសិទ្ធិ នៃការទទួលបាននូវការជំនុំជម្រះ ដោយគ្មានការពន្យារពេល។

*រឿងក្តី KANKANAMGE ទល់នឹងប្រទេសស្រីលង្កា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ កក្កដា ២០០៤ កថាខណ្ឌទី ៩.២។*

**ការរំលោភ៖ ស្ថានភាពដែលភាពស្មុគស្មាញនៃរឿងក្តីគ្មានយុត្តិកម្ម សម្រាប់ការពន្យារពេល ៤ឆ្នាំ និង៤ខែចន្លោះពីការចាប់ផ្តើមនៃការកាត់សេចក្តី និងការផ្តន្ទាទោស៖** ការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល នឹងកើតមានឡើង កាលណាភាពស្មុគស្មាញ នៃសំណុំរឿងមិនបានផ្តល់នូវយុត្តិកម្ម នៃការពន្យាពេលរយៈពេល៤ឆ្នាំ និង៤ខែគិតចាប់ពីការចាប់ផ្តើមនៃការស៊ើបសួរ (ឬក៏ ៣ឆ្នាំ ២ខែ ចាប់ពីការរៀបចំរបាយការណ៍កោសលវិច័យផ្នែកពេទ្យ) រហូតដល់ពេលចេញនូវសេចក្តីសម្រេចផ្តន្ទាទោសដោយតុលាការ។

*រឿងក្តី FILIPOVICH ទល់នឹងប្រទេសលីស៊្វ-អានី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៤ សីហា ២០០៣ កថាខណ្ឌទី ៧.១។*

**ការរំលោភ៖ ការពន្យារពេលលើសពី៦ឆ្នាំ គិតចាប់ពីមានដីកាបង្គាប់ឲ្យជំនុំជម្រះឡើងវិញ រហូតដល់ពេលមានការបដិសេធចោល បណ្តឹងឧទ្ធរណ៍សុំឲ្យជំនុំជម្រះឡើងវិញ៖** ការពន្យារពេលនីតិវិធីលើសពី ៦ឆ្នាំ គិតចាប់ពីពេលចេញដីកាបង្គាប់ឲ្យជំនុំជម្រះឡើងវិញ រហូតដល់ពេលបដិសេធឧទ្ធរណ៍អំពីការជំនុំជម្រះឡើងវិញ គឺជាវិធានការមិនសមស្រប និងរំលោភលើសិទ្ធិរបស់ចុងចោទ ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល និងសិទ្ធិឲ្យតុលាការជាន់ខ្ពស់ពិនិត្យឡើងវិញ លើការសម្រេចសេចក្តី និងការកាត់ទោសដោយអនុលោមទៅតាមច្បាប់។

*រឿងក្តី KENNEDY ទល់នឹងប្រទេសទ្រីនីណាដ និងតូបាហ្គូ គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប ២៦ មីនា២០០២ កថាខណ្ឌ ៧.៥។*

**ការរាំងស្ទះខាងរដ្ឋបាល មិនមែនជាយុត្តិកម្មនោះទេ៖** រដ្ឋ មិនអាចយកការយឺតយ៉ាវនីតិវិធីយូរ ដោយសារខ្វះបុគ្គលិក និងការរាំងស្ទះខាងរដ្ឋបាលជាទូទៅ មកធ្វើជាយុត្តិកម្មបានទេ។

*រឿងក្ដី INTERIGHTS ទល់នឹងប្រទេសទ្រីនីណាដ និងតូបាហ្គូ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២១ មីនា ២០០២ កថាខណ្ឌ ១០.៥ រឿងក្ដី LUBUTO ទល់នឹង ZAMBIA គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣១ តុលា ១៩៩៥ កថាខណ្ឌទី ៧.៣។*

**ត្រូវតែជំនុំជម្រះចុងចោទឲ្យបានឆាប់ តាមដែលអាចធ្វើទៅបាន កាលណាបណ្ដឹងសុំនៅក្រៅឃុំ ត្រូវបានបដិសេធ៖** អនុលោមតាមសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល និងទទួលបានការដោះលែង កាលណាមានការពន្យារពេលនីតិវិធីតុលាការ ត្រូវតែជំនុំជម្រះចុងចោទឲ្យបានឆាប់តាមដែលអាចធ្វើបាន នៅពេលដែលសំណើសុំនៅក្រៅឃុំរបស់ជននេះត្រូវបានបដិសេធ ក្នុងករណីមានការចោទប្រកាន់ធ្ងន់ធ្ងរ ដូចជាមនុស្សឃាត ឬឃាតកម្ម។

*រឿងក្ដី SEXTUS ទល់នឹងប្រទេសទ្រីនីណាដ និងតូបាហ្គូ គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប ១៦ កក្កដា២០០១ កថាខណ្ឌ ៧.២។*

**ការរំលោភ៖ ការពន្យារពេល មុនសវនាការ២២ខែ ដែលមានយុត្តិកម្មថា មានបញ្ហា/អស្ថិរភាពជាទូទៅ បន្ទាប់ពីការប៉ុនប៉ងធ្វើរដ្ឋប្រហារ៖** សិទ្ធិទទួលបាននូវការជំនុំជម្រះដោយគ្មានការពន្យារពេលមិនសមហេតុផល និងទទួលបានការដោះលែងដោយសារមានការពន្យារពេល នីតិវិធីត្រូវបានរំលោភបំពាន កាលណា ជនជាប់ចោទបន្តស្ថិតក្នុងការឃុំខ្លួនក្នុងរយៈពេលនៃការពន្យារពេលមុនអង្គសេចក្ដី ២២ ខែ ហើយរដ្ឋធ្វើយុត្តិកម្មលើការពន្យារពេល ដោយផ្អែកលើតែទៅ "អស្ថិរភាព និងបញ្ហាជាទូទៅបន្ទាប់ពីមានការប៉ុនប៉ងរដ្ឋប្រហារ" តែមួយគត់។

*រឿងក្ដី SEXTUS ទល់នឹងប្រទេសទ្រីនីណាដ និងតូបាហ្គូ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៦ កក្កដា ២០០១ កថាខណ្ឌទី ៧.២។*

**ការរំលោភ៖ បណ្ដឹងឧទ្ធរណ៍ដែលមិនត្រូវបានដោះស្រាយរយៈពេល៣ឆ្នាំ បន្ទាប់ពីសំណុំរឿងដែលត្រូវបានលើកលែងការចោទប្រកាន់ បានបើកឡើងវិញ៖** សិទ្ធិទទួលបានការជំនុំជម្រះក្ដី ដោយគ្មានការពន្យារពេលមិនសមស្របត្រូវបានគេរំលោភ កាលណាបណ្ដឹងឧទ្ធរណ៍ មិនទាន់ត្រូវបានដោះស្រាយនៅក្នុងរយៈពេល ៣ឆ្នាំ បន្ទាប់ពីរដ្ឋអាជ្ញាសើរើ ការលើកលែងការចោទប្រកាន់ ដែលមានអាយុកាល ៨ឆ្នាំ។

*រឿងក្ដី ARRENDONDO ទល់នឹងប្រទេសប៉េរូ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ កក្កដា ២០០០ កថាខណ្ឌ ១០.៦។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា ៩ និង ១៤(៣)(គ)។ មាត្រា ៩ ការពារសិទ្ធិមានសេរីភាព និងជាពិសេសតាមរយៈមាត្រា ៩(៣) កតិកានេះចែងពីសិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈសមស្រប បើមិនដូច្នេះទេត្រូវដោះលែង។ មាត្រា ១៤(៣)(គ) ចែងគាំទ្រសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនសមស្រប។

*តុលាការសិទ្ធមនុស្សអឺរ៉ុប*
*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ការដោះលែងជនជាប់ចោទ ក្នុងពេលរង់ចាំការជំនុំជម្រះគឺជាសច្ចធារណ៍នៃសេរីភាព៖** ដូច្នេះ ការឃុំខ្លួនគឺជាការលើកលែង។

*រឿងក្តី MCKAY ទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ៣ តុលា ២០០៦ កថាខណ្ឌ ៤១។*

**ករណីដែលតម្រូវឲ្យមានការដោះលែងជាបណ្តោះអាសន្នក្នុងអំឡុងពេលជំនុំជម្រះ៖** កាលណាការឃុំខ្លួនលែងមានមូលហេតុសមស្រប។

*រឿងក្តី NEUMEISTER ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ មិថុនា ១៩៦៨ កថាខណ្ឌ ៤។*

**កាលណាផុតរយៈពេលឃុំខ្លួនបណ្តោះអាសន្ន៖** ថ្ងៃដែលសាលាដំបូងចេញសាលក្រម។

*រឿងក្តី WEMHOFF ទល់នឹងប្រទេសអាល្លឺម៉ង់ តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ មិថុនា ១៩៦៨ កថាខណ្ឌ ១៨-១៩។*

**ការសង្ស័យសមហេតុផល ដែលថាជនដែលត្រូវបានចាប់ខ្លួនបានប្រព្រឹត្តនូវបទល្មើស ជាលក្ខខណ្ឌដាច់ខាត** (Sine qua non) **សម្រាប់បន្តការឃុំខ្លួន ក៏ប៉ុន្តែ មិនអាចជាការគ្រប់គ្រាន់នោះទេ៖** បន្ទាប់ពីរយៈពេលមួយដ៏ជាក់លាក់ តុលាការ ត្រូវតែរកឲ្យឃើញថា តើមូលដ្ឋានដទៃទៀតដែលអាជ្ញាធរផ្ទែកតុលាការបានអះអាង គឺជាយុត្តិកម្មនៃការដកហូតសេរីភាពដែរឬទេ។

*រឿងក្តី SULAOJA ទល់នឹងប្រទេសអេស្តូនី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៥ កុម្ភៈ ២០០៥ កថាខណ្ឌ ៦២ រឿងក្តី YAGCI និងSARGIN ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ៨ មិថុនា ១៩៩៥ កថាខណ្ឌ ៥០ រឿងក្តី LETELLIER ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មិថុនា ១៩៩១ កថាខណ្ឌ ៣៥។*

**វិធីសាស្ត្រនៃការវាយតម្លៃ ពីភាពសមស្របនៃការឃុំខ្លួនបណ្តោះអាសន្ន៖** តុលាការត្រូវវាយតម្លៃតាមសំណុំរឿងនីមួយៗ។ ការឃុំខ្លួន មានយុត្តិកម្មតែក្នុងករណី ដែលប្រយោជន៍សាធារណៈមានប្រៀបលើសច្ចធារណ៍និរទោសតែប៉ុណ្ណោះ។

*រឿងក្តី WEMHOFF ទល់នឹងប្រទេសអាល្លឺម៉ង់ តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ មិថុនា ១៩៦៨ កថាខណ្ឌ ៥ (ការវាយតម្លៃតាម សំណុំរឿងនីមួយៗ)។ រឿងក្តី W.ទល់នឹងប្រទេសស្វីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មករា ១៩៩៣ កថាខណ្ឌ ៣០ (ប្រយោជន៍សាធារណៈមានប្រៀបទៅលើសច្ចធារណ៍និរទោស)។*

មាត្រាស្រដៀងគ្នា នៅក្នុង*អនុសញ្ញាការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖* មាត្រា ៥(១) និង (៤)។ មាត្រាទាំងនេះ ចែងពីសេរីភាព និងសន្តិសុខរបស់បុគ្គល ដែលរាប់បញ្ចូលទាំងក្នុងពេលឃុំខ្លួន និងពេលចាប់ខ្លួនដោយស្របច្បាប់ និងការដំណើរការនីតិវិធីឲ្យបានឆាប់ដើម្បីវាយតម្លៃពីភាពស្របច្បាប់នៃការឃុំខ្លួនពួកគេ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំង គឺតុលាការកំពូល។*

**សេចក្តីសម្រេចរក្សាជនត្រូវចោទ ឲ្យនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន បន្ទាប់ពីបិទកិច្ចសើបសួរ ត្រូវចាត់ទុកជាមោឃៈបន្ទាប់ពីផុតរយៈពេល ២ ខែ៖** ចិរវេលានេះ គិតចាប់ផ្តើមពីថ្ងៃចេញនៃដីកាដំណោះស្រាយ ទោះបីជាដីកានេះត្រូវបានប្តឹងឧទ្ធរណ៍ក៏ដោយ។

*លេខ 10-83656 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ១២៥ តុលាការកំពូលបារាំង ១៨ សីហា ២០១០ លេខ 01-80 234 /04-82857 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៧៩ តុលាការកំពូលបារាំង ៨ កក្កដា ២០០៤ លេខ 71-92789 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៣៦ តុលាការកំពូលបារាំង ២ ធ្នូ ១៩៧១។*

**ការឃុំខ្លួនរបស់ជនត្រូវចោទ ត្រូវបញ្ចប់ភ្លាមកាលណាអំឡុងពេល ២ ខែ បានកន្លងផុត៖** ប្រសិនបើជនត្រូវចោទមិនបានបង្ហាញខ្លួន នៅចំពោះមុខតុលាការ។

*លេខ 02-86951 តុលាការកំពូលបារាំង ១៥ មករា ២០០៣។*

**ការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន បន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖** នៅក្នុងកាលៈទេសៈពិសេស សភាស៊ើបសួរ អាចបន្តការឃុំខ្លួនជនត្រូវចោទលើសពី ១ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ។

*លេខ 09-83950 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៤៨ តុលាការកំពូលបារាំង ២ កញ្ញា២០០៩។*

**រយៈពេលអតិបរមា នៃការឃុំខ្លួនមុនពេលជំនុំជម្រះ៖** ចៅក្រម គឺមិនត្រូវកំណត់រយៈពេលឲ្យលើសពីរយៈពេលសមស្រប ដែលត្រូវបានកំណត់ដោយសភាស៊ើបសួរឡើយ។

*លេខ 02-84980 តុលាការកំពូលបារាំង ១ តុលា ២០០២។*

**ការបន្ថយចិរវេលានៃការឃុំខ្លួន មុនអង្គជំនុំជម្រះ៖** ចៅក្រម មិនត្រូវបន្ថយនូវចិរវេលានៃការឃុំខ្លួនមុនអង្គសេចក្តី អោយនៅតិចជាងរយៈពេលដែលកំណត់ដោយច្បាប់ឡើយ។

*លេខ 06-86937 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៩១ តុលាការកំពូលបារាំង ២១ វិច្ឆិកា ២០០៦។*

**មាត្រាស្រដៀងគ្នាក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** មាត្រា ៣១៨ ៣១៩ ៣២០ ១៧៩(៤) ១៧៩(៥) ១៨១ និង ១៤៤-១។ មាត្រា ៣១៨ ៣១៩ និង៣២០ ចែងពីការបង្ហាញខ្លួនជនត្រូវចោទ តាមដីកាបញ្ជូនរឿងទៅជំនុំជំម្រះនៅចំពោះមុខតុលាការ ដោយរាប់បញ្ចូលទាំងការមិនព្រមបង្ហាញខ្លួនផងដែរ រីឯមាត្រា ៣២០ ចែងពីការប្រើប្រាស់កម្លាំងដើម្បីបង្ខំឲ្យជនត្រូវចោទបង្ហាញខ្លួន។ មាត្រា ១៧៩(៤) ១៧៩(៥) ១៨១ និង ១៤៤ (១) ចែងពីការបង្ហាញខ្លួនជនត្រូវចោទ តាមដីកាបញ្ជូនរឿងទៅជំនុំជំម្រះក្នុងករណីនៃការឃុំខ្លួនបណ្តោះអាសន្ន និងអំឡុងពេលដែលជនត្រូវចោទអាចត្រូវបានឃុំខ្លួនមុនពេលនាំខ្លួនទៅកាន់តុលាការ។

# មាត្រា ៣០៦៖ ការដោះលែងជនជាប់ចោទដែលជាប់ឃុំឲ្យមានសេរីភាពដោយឯកឯង

*នៅគ្រប់ពេលវេលា តុលាការអាចបង្គាប់អោយដោះលែងជនជាប់ចោទដែលជាប់ឃុំឲ្យមានសេរីភាពវិញបាន ឬឲ្យបន្តការឃុំខ្លួនជនជាប់ចោទ ដោយយោងតាមមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ។*

*តុលាការ អាចសម្រេចក្រោយពីបានស្ដាប់ជនជាប់ចោទ មេធាវី និងព្រះរាជអាជ្ញា។*

## ការអនុវត្តនៅ អ.វ.ត.ក

**ភាពចាំបាច់ក្នុងការថ្លឹងថ្លែងរវាងការឃុំខ្លួន និងសេរីភាព៖** តុលាការ ត្រូវតែថ្លឹងថ្លែងអំពីមូលហេតុសម្រាប់ឃុំខ្លួន និងសិទ្ធិសេរីភាពបុគ្គល។ សច្ចធារណ៍នៃសេរីភាព តម្រូវឲ្យសេចក្ដីសម្រេចតាមផ្លូវតុលាការក្នុងការឃុំខ្លួន មានមូលដ្ឋានគ្រប់គ្រាន់ និងត្រូវបានចេញដោយអនុលោមតាមនីតិវិធី និងលក្ខខណ្ឌច្បាប់។

*រឿងក្ដី ខៀវ សំផន៖ បណ្ដឹងឧទ្ធរណ៍ភ្លាមៗស្ដីពីសំណើសុំនៅក្រៅឃុំ អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៧-៥៦។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ៨០។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ២២។ រឿងក្ដី នួន ជា៖ សេចក្ដីសម្រេចលើកទី២ ស្ដីពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ ១៦។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល) អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១៣ កថាខណ្ឌ ១។ រឿងក្ដី អៀង ធីរិទ្ធ៖ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទក្នុងការឃុំឃាំងដោយមានលក្ខខណ្ឌ សម្រាប់កិច្ចដំណើរការនីតិវិធី និងការដោះលែងដោយឥតលក្ខខណ្ឌនោះ ចំពោះបុគ្គលពាក់ព័ន្ធ គឺចៀសមិនផុតពីផលវិបាកឡើយ)។*

**ជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលបង្ហាញខ្លួនជាលើកដំបូង៖** ជនជាប់ចោទ ត្រូវបានឃុំខ្លួន នៅពេលបង្ហាញខ្លួនលើកដំបូងចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ត្រូវបន្តស្ថិតនៅក្នុងការឃុំខ្លួនរហូតដល់ពេលអង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីសម្រេច ដរាបណាអាជ្ញាធរតុលាការ មានមូលដ្ឋានស្របច្បាប់សម្រាប់ឃុំខ្លួន។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ស្តីពីសំណើសុំនៅក្រៅឃុំអ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៧-៤៩។*

**ត្រូវតែអានមាត្រាច្បាប់ នៅពេលពិនិត្យអំពីសច្ចធារណ៍នៃសេរីភាព៖** ប្រព័ន្ធច្បាប់កម្ពុជា គឺជាមូលដ្ឋានគ្រឹះការពារសិទ្ធិមានសេរីភាព ហើយត្រូវអាននូវមាត្រា ៣០៥ ដល់ ៣០៧ នៅពេលពិនិត្យសច្ចធារណ៍នៃសេរីភាព។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ស្តីពីសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត .ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៦។*

**ការសន្មតថា លក្ខខណ្ឌដើមដែលអនុញ្ញាតឲ្យបន្តការឃុំខ្លួនបណ្តោះអាសន្ន គឺជាការសន្មតទៅតាមអង្គហេតុ និងអាចជំទាស់បាន៖** ការសន្មតនេះ មិនចងកាតព្វកិច្ចលើអង្គជំនុំជម្រះសាលាដំបូងឡើយ។ ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង វាយតម្លៃពីភាពស្របច្បាប់នៃការឃុំខ្លួននោះតាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ឬតាមសំណើរបស់ជនជាប់ចោទ ការត្រួតពិនិត្យឡើងវិញរបស់ខ្លួននោះ ត្រូវតែប្រកបដោយអត្ថន័យ។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ស្តីពីសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៨-៤៩។*

**ជនជាប់ចោទ មានបន្ទុកផ្តល់ភស្តុតាង ដើម្បីតវ៉ាចំពោះមូលហេតុនៃការឃុំខ្លួន៖** ចាប់ពីការបង្ហាញខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង រហូតដល់ពេលអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចរបស់ខ្លួន ជនជាប់ចោទ មានបន្ទុកផ្តល់នូវភស្តុតាងដើម្បីតវ៉ាចំពោះមូលហេតុនៃការឃុំខ្លួនដោយដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត .ក ៦ មិថុនា ២០១១ កថាខណ្ឌ៤៨។*

**អង្គជំនុំជម្រះតុលាការកំពូល អាចផ្អែកលើការសន្មតលើលក្ខខណ្ឌបន្តការឃុំខ្លួន៖** កាលណាអង្គជំនុំជម្រះសាលាដំបូង ផ្តល់សំអាងហេតុមិនគ្រប់គ្រាន់ ដើម្បីធ្វើជាយុត្តិកម្មពីភាពស្របច្បាប់នៃការឃុំខ្លួនជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូល អាចតម្កល់សុពលភាពនៃការឃុំខ្លួន ដោយផ្អែកទៅលើការសន្មត ដែលអាចបដិសេធបានលើលក្ខខណ្ឌបន្តការឃុំខ្លួន។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗលើសំណើសុំឲ្យដោះលែងអ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៥២។*

**ជនជាប់ចោទ ត្រូវតែផ្តល់នូវមូលដ្ឋាននៃកាលៈទេសៈ/លក្ខខណ្ឌដែលធានាឲ្យខ្លួនបាននៅក្រៅឃុំ៖** ជនជាប់ចោទ មានបន្ទុកក្នុងការបញ្ជាក់ពីកាលៈទេសៈនៃអង្គហេតុ និងលក្ខខណ្ឌដែលអាចធានាឲ្យខ្លួនបាននៅក្រៅឃុំ។ គឺមានតែករណីដែលជនជាប់ចោទ បានបំពេញទៅតាមលក្ខខណ្ឌនេះទេ ទើបតុលាការ ត្រូវវាយតម្លៃទៅលើភាពគ្រប់គ្រាន់ នៃការដាក់ឲ្យនៅក្រៅឃុំ ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៥៧។*

**ករណីដែលសេចក្តីសម្រេច ក្នុងការបដិសេធការឲ្យនៅក្រៅឃុំរបស់អង្គជំនុំជម្រះសាលាដំបូង នឹងត្រូវបានតម្កល់៖** កាលណាជនជាប់ចោទ មិនបានផ្តល់ជូនដល់អង្គជំនុំជម្រះសាលាដំបូងនូវព័ត៌មានលំអិតពាក់ព័ន្ធ នឹងមធ្យោបាយដែលធានាពីវត្តមានរបស់ខ្លួននៅក្នុងតុលាការ។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍ភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៥៧-៥៨។*

កាលណាជនជាប់ចោទ ត្រូវបានរកឃើញថាមិនមានសម្បទា ក្នុងការចូលរួមសវនាការទេ គោលការណ៍នៃការសន្មត់ជាមុនពីសេរីភាពតម្រូវថា ជននោះត្រូវដោះលែងពីការឃុំឃាំង ការឃុំខ្លួនបន្ត ឬការឃុំខ្លួនដោយបង្ខំ នៅក្នុងកាលៈទេសៈផ្សេងៗ ក្នុងករណីមិនច្បាស់លាស់ថាតើការជំនុំជម្រះក្តីនឹងត្រូវកោះហៅ ឬអត់នោះ គឺជាការរំលោភបំពានលើសិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌និងសេរីភាព។ កាលណាបណ្តឹង មិនត្រូវបានរលត់នៅឡើយ នៅក្រោមមាត្រា ៧ នៃក្រមនេះ ជនជាប់ចោទអាចត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលដែលជននោះមានសម្បទាក្នុងការចូលរួមសវនាការ ឬបណ្តឹងត្រូវបានផុតរលត់ ដោយអនុលោមតាមច្បាប់។

*រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ៨០។ រឿងក្តី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ២២។ រឿងក្តី អៀង ធីរិទ្ធ៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាបង្គាប់ របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកនូវលក្ខខណ្ឌ នៃកិច្ចដំណើរការនីតិវិធី ការដោះលែងដោយឥតលក្ខខណ្ឌ នៃបុគ្គលពាក់ព័ន្ធ គឺមានផលវិបាកណាមួយដោយចៀសមិនផុតឡើយ)។ រឿងក្តី អៀង ធីរិទ្ធ៖*

*សម្បទានៅក្នុងការចូលរួមសវនាការមួយ (សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ឲ្យរក្សាទុកជនជាប់ចោទប្រឆាំងទៅនឹងដីកាបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ) អ.ជ.ត.ក ១៧ កញ្ញា ២០១២ កថាខណ្ឌ ៧-៨។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល) អ.ជ.ស.ជ ២៦ មីនា ២០១៣ កថាខណ្ឌ ១។*

**សម្រេចថាតើជនជាប់ចោទមានសម្បទា ក្នុងការចូលរួមសវនាការ ឬអត់នោះ គឺជាការចូលរួម ប្រកបដោយអត្ថន័យ៖** ថាតើជនជាប់ចោទអាចអនុវត្ត នូវសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ នៅក្នុងកម្រិតណាមួយ ដែលជននោះអាចចូលរួមបាន ប្រកបដោយប្រសិទ្ធភាព ក្នុងការជំនុំជម្រះ និងមានការយល់ដឹងអំពីសារសំខាន់នៃកិច្ចដំណើរការនីតិវិធី។ ក្នុងការធ្វើសេចក្ដីសម្រេច អំពីបញ្ហានេះ អង្គជំនុំជម្រះ ត្រូវពិចារណានូវរាល់គ្រប់បញ្ហា ដែលទាក់ទង និងកត្តាពាក់ព័ន្ធទាំងអស់ ជារួមមានលទ្ធភាពប្រើប្រាស់ នូវវិធានការអនុវត្តដ៏ជាក់ស្ដែងនានា ដែលអាចសម្រាលបាននូវផលប៉ះពាល់លើភាពអន់ថយណាមួយ។

*រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ៣៧។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទានក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ៥៥។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២២។ រឿងក្ដីអៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ត.ក ២៨ វិច្ឆិកា ២០១២ កថាខណ្ឌ ១៨។ រឿងក្ដី នួន ជា៖ សេចក្ដីសម្រេចលើកទី២ ស្ដីពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ ១៣។ រឿងក្ដី នួន ជា៖ សេចក្ដីសម្រេចស្ដីពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២៤ មេសា ២០១៤ កថាខណ្ឌ ៦។ រឿងក្ដី ខៀវ សំផន៖ សេចក្ដីសម្រេចស្ដីពីសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២៤ មេសា ២០១៤ កថាខណ្ឌ ៦។ រឿងក្ដី អៀង ធីរិទ្ធ៖ សេចក្ដីសម្រេច លើបណ្ដឹងឧទ្ធរណ៍ភ្លាមៗប្រឆាំងនឹងដីកាសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.វ.ត.ក អ.*

*ដ.ត.ក ១៤ ធ្នូ ២០១២ កថាខណ្ឌ៣៧- ៣៩។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៨២(២)។ វិធាននេះ គឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ៣០៦ លើកលែងតែបទប្បញ្ញត្តិនៃវិធាននេះ តម្រូវឲ្យព្រះរាជអាជ្ញា ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទផ្តល់សេចក្តីសន្និដ្ឋានមុនពេលចេញសេចក្តីសម្រេចនេះ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌ ស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញា អឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**អាជ្ញាធរតុលាការ ត្រូវតែពិនិត្យឲ្យគ្រប់មូលហេតុគាំទ្រ និងជំទាស់ ដោយការថ្លឹងថ្លែងជាមួយនឹងផលប្រយោជន៍សាធារណៈពិតប្រាកដ ដែលជាយុត្តិកម្មនៃការបន្តការឃុំខ្លួនជនត្រូវចោទ៖** កាលណាគ្មានមូលហេតុ ដែលជាយុត្តិកម្មនៃការឃុំខ្លួននោះទេ អាជ្ញាធរតុលាការ ត្រូវតែមានអំណាចបង្គាប់ឲ្យដោះលែងភ្លាមៗចំពោះជនជាប់ចោទដែលត្រូវបានឃុំខ្លួន។

*រឿងក្តី ASSENOV និងអ្នកដទៃទល់នឹងប្រទេសប៊ុលហ្គារី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៨ តុលា ១៩៩៨ កថាខណ្ឌ១៤៦ និង ១៥៤។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មាត្រា ៥។ មាត្រានេះការពារសេរីភាព និងសន្តិសុខដល់ជនជាប់ចោទ និងជាឧទាហរណ៍ ការពារសិទ្ធិរបស់ជនជាប់ចោទ ដើម្បីឲ្យគេនាំមកចំពោះមុខចៅក្រមឲ្យបានឆាប់រហ័ស និងសិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្រប ការដោះលែងក្នុងពេលរង់ចាំការជំនុំជម្រះ។ ការដោះលែង អាចមានលក្ខខណ្ឌដោយការធានាចំពោះការបង្ហាញខ្លួនក្នុងពេលជំនុំជម្រះ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានបកស្រាយ និង អនុវត្តនៅក្នុងតុលាការជាន់ខ្ពស់នៃប្រទេសបារាំង គឺតុលាការកំពូល។*

**រយៈពេលសមស្រប នៃការឃុំខ្លួនបណ្ដោះអាសន្នៈ រយៈពេលនេះ គឺស្ថិតនៅក្នុងយុត្តាធិការរបស់សភាស៊ើបសួរ។**

*លេខ 02-84980 តុលាការកំពូលបារាំង ១ តុលា ២០០២។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** មាត្រា ១៤៤-១។ មាត្រានេះ ចែងពីការបង្ហាញខ្លួនជនជាប់ចោទ ចំពោះមុខតុលាការក្នុងករណីនៃការឃុំខ្លួនបណ្ដោះអាសន្ន និង"រយៈពេលសមស្រប" ដែលក្នុងអំឡុងពេលនេះ តុលាការអាចរក្សាទុកជនជាប់ចោទក្នុងការឃុំខ្លួនមុនពេលនាំទៅតុលាការ។

# មាត្រា ៣០៧៖ បណ្ដឹងសុំដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទ ដែលជាប់ឃុំ

*ជនជាប់ចោទ ដែលត្រូវបានឃុំខ្លួន អាចសុំដល់តុលាការឱ្យដោះលែងខ្លួនឱ្យមានសេរីភាពវិញ ដោយផ្ទាល់មាត់នៅពេលសវនាការ ឬតាមលិខិតដែលផ្ញើជូនទៅក្រឡាបញ្ជី។*

*ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំ អាចធ្វើដោយមេធាវីរបស់ជនជាប់ចោទដែលត្រូវបានឃុំខ្លួន ដោយផ្ទាល់មាត់នៅពេលសវនាការ ឬតាមលិខិតដែលផ្ញើជូនទៅក្រឡាបញ្ជី។*

*កាលណាពាក្យសុំបានធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃសវនាការ។ កាលណាពាក្យសុំបានធ្វើតាមលិខិតក្រឡាបញ្ជីចុះនិទ្ទេស អំពីកាលបរិច្ឆេទទទួលនៅលើលិខិតនេះ ហើយបញ្ជូនជាបន្ទាន់ទៅដល់ប្រធានតុលាការ។*

*តុលាការ សម្រេចក្រោយពីបានស្ដាប់ជនជាប់ចោទ មេធាវី និងព្រះរាជអាជ្ញា។ តុលាការ ត្រូវសម្រេចនៅក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល១០ (ដប់) ថ្ងៃ ក្រោយពីការសុំដោយផ្ទាល់មាត់ ឬក្រោយពីទទួលពាក្យសុំ ដែលធ្វើជាលាយលក្ខណ៍អក្សរ។*

## ការអនុវត្តនៅអ.វ.ត.ក

**ភាពចាំបាច់នៃការថ្លឹងថ្លែងរវាងការឃុំខ្លួន និងសេរីភាព៖** តុលាការត្រូវថ្លឹងថ្លែង នូវមូលហេតុរវាងការឃុំខ្លួន និងសិទ្ធិសេរីភាពរបស់បុគ្គល។ សច្ចធារណ៍នៃសេរីភាព តម្រូវឲ្យមានមូលដ្ឋាននៅក្នុងការឃុំខ្លួន នៅក្នុងសេចក្ដីសម្រេចរបស់តុលាការ ដែលបានចេញអនុលោមតាមនីតិវិធី និងលក្ខខណ្ឌនៃច្បាប់។

*រឿងក្ដី ខៀវ សំផន៖ បណ្ដឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០ ១១ កថា ខណ្ឌ ៤៧ និង ៥៦។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ ៨០។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ២២។ រឿងក្ដី នួន ជា៖ សេចក្ដីសម្រេចលើកទី ២ ស្ដីពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ជ ២ មេសា ២០១៣ កថាខណ្ឌ ១៦។ រឿងក្ដី អៀង ធីរិទ្ធ៖ សម្បទាក្នុងការចូលរួមសវនាការ (ការអនុវត្តសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល) អ.វ.ត.ក អ.ជ.ស.ជ ១៣ មីនា ២០១៣ កថាខណ្ឌ ១។ រឿងក្ដី អៀង ធីរិទ្ធ៖ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ភ្លាមៗ*

*ប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អ.វ.ត.ក អ.ជ.ត.ក ១៣ ធ្នូ ២០១១ កថាខណ្ឌ ២១-២៦ (ដោយកត់សំគាល់ថា ការរក្សាទុកជនជាប់ចោទនៅក្នុងការឃុំឃាំង ដោយមានលក្ខខណ្ឌ គឺសម្រាប់កិច្ចដំណើរការនីតិវិធី និងការដោះលែងដោយឥតលក្ខខណ្ឌ ចំពោះបុគ្គលពាក់ព័ន្ធគឺចៀសមិនផុតពីផលវិបាកឡើយ)។*

**ជនជាប់ចោទដែលត្រូវបានឃុំខ្លួន នៅពេលចូលបង្ហាញខ្លួនលើកដំបូង៖** ជនជាប់ចោទដែលត្រូវបានឃុំខ្លួន នៅពេលត្រូវចូលបង្ហាញខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ត្រូវបន្តនៅក្នុងមន្ទីរឃុំឃាំង រហូតដល់ពេលអង្គជំនុំជម្រះចេញសាលក្រម ដរាបណាការឃុំខ្លួននោះធ្វើឡើង ស្របតាមមូលដ្ឋានច្បាប់ ដែលចេញពីអាជ្ញាធរតុលាការ។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៧-៤៩។*

**ត្រូវតែអាននូវមាត្រាច្បាប់ នៅពេលពិនិត្យពីសច្ចធារណ៍នៃសេរីភាព៖** ប្រព័ន្ធច្បាប់កម្ពុជាការពារជាសារវ័ន្ត ចំពោះសិទ្ធិមានសេរីភាព ហើយត្រូវតែអាន ពីមាត្រា ៣០៥ ដល់៣០៧ នៅពេលពិនិត្យអំពីសច្ចធារណ៍នៃសេរីភាព។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៦។*

**សច្ចធារណ៍ ដែលផ្តល់លក្ខខណ្ឌដើមដែលធានាឲ្យមានការឃុំខ្លួនបណ្តោះអាសន្នបន្ត គឺជាសច្ចធារណ៍នៃអង្គហេតុ ដែលអាចបដិសេធបាន៖** សច្ចធារណ៍នេះ មិនចងកាតព្វកិច្ចចំពោះអង្គជំនុំជម្រះសាលាដំបូងទេ។ ប្រសិនជាអង្គជំនុំជម្រះ វាយតម្លៃអំពីភាពស្របច្បាប់ នៃការឃុំឃាំងដោយឥតស្សរចិត្ត ឬតាមសំណើរបស់ជនជាប់ចោទ ការពិនិត្យរបស់អង្គជំនុំជម្រះត្រូវតែប្រកបដោយអត្ថន័យ។

*រឿងក្តី ខៀវ សំផន៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៨-៤៩។*

**ជនជាប់ចោទ មានបន្ទុកចង្អុលបង្ហាញភស្តុតាងដើម្បីជំទាស់នឹងអត្ថិភាព នៃមូលដ្ឋានក្នុងការឃុំខ្លួន៖** ចាប់តាំងពីពេលចូលបង្ហាញខ្លួនលើកដំបូង នៅចំពោះមុខនៃអង្គជំនុំជម្រះសាលាដំបូង រហូតដល់ពេលអង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីសម្រេចរបស់ខ្លួន ជនជាប់ចោទ មានបន្ទុកចង្អុលបង្ហាញភស្តុតាងដើម្បីជំទាស់ទៅនឹងអត្ថិភាពនៃមូលដ្ឋានក្នុងការឃុំខ្លួនតាមរយៈសំណើដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង។

*រឿងក្តី ខៀវ សំផនៈ បណ្តឹងសាទុក្ខភ្លាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៤៨។*

**អង្គជំនុំជម្រះតុលាការកំពូល អាចពឹងផ្អែកលើសច្ចធារណ៍នៃលក្ខខណ្ឌបន្តការឃុំខ្លួន៖** កាលណាអង្គជំនុំជម្រះសាលាដំបូង ផ្តល់សំអាងហេតុមិនគ្រប់គ្រាន់ ដែលបង្ហាញពីភាពស្របច្បាប់ នៃការឃុំខ្លួនជនជាប់ចោទ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូល អាចតម្កល់សុពលភាពនៃការឃុំខ្លួន ដោយផ្អែកទៅលើគោលការណ៍សច្ចធារណ៍ ដែលអាចតវ៉ាបាននៃលក្ខខណ្ឌបន្តការឃុំខ្លួន។

*រឿងក្តី ខៀវ សំផនៈ បណ្តឹងសាទុក្ខភ្លាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៥៤។*

**ជនជាប់ចោទ ត្រូវចង្អុលបង្ហាញភស្តុតាងបញ្ជាក់អំពីកាលៈទេសៈ និងលក្ខខណ្ឌផ្សេងៗ ដើម្បីទទួលបានការដោះលែងនៅក្រៅឃុំ៖** ជនជាប់ចោទ មានបន្ទុកនៅក្នុងការបង្ហាញភស្តុតាងពីកាលៈទេស និងលក្ខខណ្ឌផ្សេងៗ ដើម្បីបានទទួលនូវការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ វៀរលែងតែនៅពេលណា ដែលជនជាប់ចោទបានបំពេញបន្ទុកនេះប៉ុណ្ណោះ ទើបតុលាការ អាចវាយតម្លៃអំពីការដោះលែង តាមរយៈការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

*រឿងក្តី ខៀវ សំផនៈ បណ្តឹងសាទុក្ខភ្លាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៥៧។*

**ករណីដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធចោលការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នឹងត្រូវបានតម្កល់៖** គឺនៅពេលដែលជនជាប់ចោទខកខានមិនបានផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូង នូវសេចក្តីលម្អិតអំពីមធ្យោបាយផ្សេងៗដែលធានាដល់វត្តមានរបស់ខ្លួននៅតុលាការ។

*រឿងក្តី ខៀវ សំផនៈ បណ្តឹងសាទុក្ខភ្លាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ ៥៧-៥៨។*

**ការពន្យារពេលលើការធ្វើសេចក្តីសម្រេចស្តីពីការដោះលែងពីមន្ទីរឃុំឃាំង តាមកាលៈទេសៈពិសេស៖** អង្គជំនុំជម្រះសាលាដំបូង ផ្តល់ពេលវេលា ៤៥ថ្ងៃ សម្រាប់ការពន្យារពេលធ្វើសេចក្តីសម្រេចលើសំណើសុំការដោះលែងពីមន្ទីរឃុំឃាំង អាស្រ័យដោយផ្អែកចាំបាច់នៃសំណុំរឿងត្រូវបញ្ជូនទៅបកប្រែភាសា និងការឈប់សម្រាករយៈពេលយូររបស់តុលាការចំនួនពីរលើកកន្លងមក។

*រឿងក្តី ឌុចៈ ប្រតិចារិកសវនាការ ថ្ងៃជំនុំជម្រះទី១១ អ.វ.ត.ក អ.ជ.ស.ដ ២៣ មេសា ២០០៩ ទំព័រ ១-២ បន្ទាត់ ១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៨២(៣)។ វិធាននេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងមាត្រា ៣០៧ លើកលែងតែវិធាន ៨២(៣) ចែងពីពេលកំណត់ឲ្យតុលាការចេញសេចក្ដីសម្រេច ស្ដីពីការដោះលែងជនជាប់ចោទឲ្យបានឆាប់តាមដែលអាចធ្វើបាន និងទោះក្នុងករណីណាក៏ដោយ មិនឲ្យលើសពី ៣០ថ្ងៃឡើយ បន្ទាប់ពីទទួលបានពាក្យសុំផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ លើកលែងតែមានកាលៈទេសៈពិសេស ដែលតម្រូវឲ្យមានរយៈពេលយូរជាងនេះ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់នៃប្រទេសបារាំង គឺតុលាការកំពូល។*

**ការកំណត់ចិរវេលាប្រាំថ្ងៃ សម្រាប់ការសម្រេចសេចក្ដីលើពាក្យសុំឲ្យដោះលែងជនជាប់ឃុំ៖** ថ្ងៃដែលចៅក្រមស៊ើបសួរបញ្ជូនសំណើទៅរដ្ឋអាជ្ញា មិនរាប់បញ្ចូលក្នុងចិរវេលាប្រាំថ្ងៃនេះទេ។

*លេខ 85-90391 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១១៤ តុលាការកំពូលបារាំង ១៩ មីនា ១៩៨៥។*

**យុត្តិកម្មសម្រាប់ការបដិសេធសំណើសុំឲ្យដោះលែង៖** ត្រូវផ្អែកលើអង្គហេតុនានា នៃសំណុំរឿង។

*លេខ 85-94597 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៩៤ តុលាការកំពូលបារាំង ៦ មីនា ១៩៨៦។*

**ពេលវេលាសមស្រប សម្រាប់ការដោះលែងបណ្ដោះអាសន្ន៖** មានតែសភាស៊ើបសួរទេ ដែលជាអ្នកសម្រេច ពេលទទួលបានសំណើសុំថាតើការឃុំខ្លួនបណ្ដោះអាសន្ន លើសរយៈពេលសមស្របដែរឬទេ។ ចិរវេលានេះ គិតចាប់ពីថ្ងៃឃុំខ្លួន ឬចាប់ខ្លួន មិនមែនថ្ងៃដាក់សំណើសុំឲ្យដោះលែងទេ។

*លេខ 86-95501 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៨៦ តុលាការកំពូលបារាំង ២៣ ធ្នូ ១៩៨ (សភាស៊ើបសួរកំណត់ អំពីភាពសមហេតុផល)។ លេខ85-94597 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៩៤ តុលាការកំពូលបារាំង ៦ មីនា ១៩៨៦។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌ*** **បារាំង៖** មាត្រា ១៤៨។ មាត្រានេះ ចែងអំពីសំណើសុំដោះលែងជនជាប់ចោទដែលជាប់ឃុំឃាំង និងកិច្ចដំណើរការនីតិវិធីចាំបាច់ សម្រាប់ការពិចារណាលើពាក្យសុំនោះ។

# មាត្រា ៣១១៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការ

*ក្នុងពេលសវនាការ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធ្វើតាមការប្រកាសប្តឹងសាមញ្ញនៅចំពោះមុខក្រឡាបញ្ជី។ ការប្រកាសប្តឹងនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃសវនាការ។*

*ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលបានទេ ក្រោយពីសេចក្តីសន្និដ្ឋានសុំរបស់ព្រះរាជអាជ្ញាលើអង្គសេចក្តី។*

*ជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ នៅពេលស៊ើបសួរនោះមិនចាំបាច់បំពេញទម្រង់ការនេះជាថ្មីទៀតទេ នៅចំពោះមុខតុលាការ។*

## ការអនុវត្តនៅអ.វ.ត.ក

**ព្យសនកម្មពុំចាំបាច់ដោយផ្ទាល់ទេ៖** ព្យសនកម្មក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែជាលក្ខណៈបុគ្គល ប៉ុន្តែពុំចាំបាច់ដោយផ្ទាល់ឡើយ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៨៣។ រឿងក្តី ឌុច៖ សាលក្រមលើបណ្តឹងសាទុក្ខ អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ ៤១៨។*

**បណ្តឹងរដ្ឋប្បវេណី ដោយសារព្យសនកម្មដោយប្រយោល មិនកំហិតត្រឹមបុគ្គល ក្នុងឋានៈជាក់លាក់ណាមួយទេ៖** ជាឧទាហរណ៍ មិនកំហិតចំពោះតែសមាជិកគ្រួសារប៉ុណ្ណោះទេ ក៏ប៉ុន្តែផ្ទុយទៅវិញ អាចរាប់បញ្ចូលទាំងសហព័ទ្ធ តាមច្បាប់ខំមិនឡ (Common Law) ញាតិសាច់ឆ្ងាយ មិត្តភ័ក្រ្ត ឪពុកម្តាយ និងកូនចិញ្ចឹមជាក់ស្តែង និងអត្តាគាហក។

*រឿងក្តី ឌុច៖ សាលក្រមលើបណ្តឹងសាទុក្ខ អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ ៤១៨។*

**ភស្តុតាងបង្ហាញពីផលប៉ះពាល់ដោយផ្ទាល់ដោយជនរងគ្រោះមិនផ្ទាល់៖** ជនរងគ្រោះមិនផ្ទាល់ ត្រូវតែបង្ហាញឲ្យឃើញនូវចំណងពិសេសនៃសេចក្តីស្រឡាញ់ និងការពឹងផ្អែកដែលផ្សារភ្ជាប់ពួកគាត់ ទាំងខាងផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្លូវសេដ្ឋកិច្ច ចំពោះជនរងគ្រោះដោយផ្ទាល់។ បើសិនពុំមានចំណងបែបនេះទេ ការ

ខូចខាតបណ្ដាលមកពីការប្រព្រឹត្តបទល្មើស ក៏គ្មាននោះដែរ។

*រឿងក្ដី ឌុចៈ សាលក្រមលើបណ្ដឹងសាទុក្ខ អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ ៤៤៧។*

**ព្យសនកម្ម ត្រូវតែបណ្ដាលមកពីអំពើដោយផ្ទាល់របស់ជនជាប់ចោទៈ** អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវតែបង្ហាញឲ្យឃើញថាព្យសនកម្ម បណ្ដាលមកពីអំពើដោយផ្ទាល់របស់ជនជាប់ចោទ ដែលកំពុងស្ថិតក្រោមកិច្ចស៊ើបសួរ។

*រឿងក្ដី ឌុចៈ សាលក្រមអ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ ៦៤៧។*

**ការបដិសេធលើពាក្យសុំ ដែលខកខានពុំបានបង្ហាញនូវភស្ដុតាងនៃព្យសនកម្មដោយផ្ទាល់ៈ** ចៅក្រមស៊ើបសួរ អាចច្រានចោលពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណីបាន ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា ពាក្យសុំនោះខកខានពុំបានបង្ហាញនូវភស្ដុតាងអំពីព្យសន-កម្មដោយផ្ទាល់ បណ្ដាលមកពីអំពើរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់។

*រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធៈ បណ្ដឹងឧទ្ធរណ៍ស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៧ មេសា ២០១០ កថាខណ្ឌ ៤៨។*

**ការអនុវត្តសិទ្ធិរបស់ជនរងគ្រោះមិនផ្ទាល់ មានលក្ខណៈស្វ័យភាពពីសិទ្ធិរបស់ជនរងគ្រោះដោយផ្ទាល់ៈ** ដូច្នេះជនរងគ្រោះមិនផ្ទាល់ អាចត្រូវបានផ្ដល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី ទោះបីជាជនរងគ្រោះដោយផ្ទាល់ នៅរស់ និងមិនប្ដឹងដោយខ្លួនឯងផ្ទាល់ក៏ដោយ។

*រឿងក្ដី ឌុចៈ សាលក្រមលើបណ្ដឹងសាទុក្ខ អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ ៤១៨។*

**ជនរងគ្រោះដែលចោទប្រកាន់លើអង្គហេតុថ្មីៈ** ជនរងគ្រោះដែលស្នើសុំឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី គឺមិនអាចប្ដឹងចោទពីអង្គហេតុថ្មីសម្រាប់គោលបំណងនៃកិច្ចស៊ើបសួរឡើយ ក៏ប៉ុន្តែ ពួកគេអាចលើកឡើងពីអង្គហេតុថ្មីៗ ដែលទំនងជាបង្ហាញពីទំនាក់ទំនងរវាងហេតុ និងបច្ច័យ រវាងព្យសនកម្ម ដែលជនរងគ្រោះទទួលរង និងបទឧក្រិដ្ឋយ៉ាងហោចណាស់មួយ ដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ រួចហើយ នៅក្នុងដីកាចោទប្រកាន់ជាធរមាន។

*រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធៈ បណ្ដឹងឧទ្ធរណ៍ស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៤២។*

**ទំនាក់ទំនងរវាងហេតុ និងបច្ច័យចំពោះជនជាប់ចោទជាសមូហភាព អាចជាការគ្រប់គ្រាន់ៈ** ក្នុង បណ្ដឹងទាមទារមួយ ប្រឆាំងទៅនឹងជនជាប់

ចោទច្រើននាក់ ទាំងក្នុងនាមជាបុគ្គល និង សមូហភាពជាក្រុម ដែលប្រព្រឹត្តអំពើរួមគ្នា ក្នុងសហកម្មឧក្រិដ្ឋកម្មរួម (ឬទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត) អ្នកដាក់ពាក្យប្ដឹង អាចបង្ហាញពីទំនាក់ទំនងរវាងហេតុ និងបច្ច័យចំពោះជនជាប់ចោទជាសមូហភាព ជាជាងជនជាប់ចោទជាបុគ្គលម្នាក់ៗ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៧១-៧៣។*

**ព្យសនកម្មផ្លូវចិត្ត ត្រូវបានគេសន្មតថាជាអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងទៅនឹងមនុស្សជាតិ ប្រសិនបើ អ្នកដាក់ពាក្យប្ដឹងចេញពីក្រុមគោលដៅបានកំណត់៖** ក្នុងករណីមានការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដូចជាអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កាលណាអ្នកដាក់ពាក្យប្ដឹងនោះ គឺជាជនរងគ្រោះមិនផ្ទាល់ (ឧទាហរណ៍ ជាសាក្សី ឬជនដែលដឹងឮពីឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់) ព្យសនកម្មផ្លូវចិត្តដោយផ្ទាល់ ត្រូវបានសន្មតកាលណាអ្នកដាក់ពាក្យប្ដឹងនោះ មិនទំនងជាសមាជិកនៃក្រុម ឬសមាគមគោលដៅតែមួយ ឬសហគមន៍ ជាមួយជនរងគ្រោះដោយផ្ទាល់។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៩៣។*

**ព្យសនកម្មផ្នែកសម្ភារៈ៖** ព្យសនកម្មរាប់បញ្ចូលទាំងការបាត់បង់ទ្រព្យសម្បត្តិ ឬប្រាក់ចំណូល។

*រឿងក្តី ឌុច៖ សាលក្រមអ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ ៦៤១។*

**ព្យសនកម្មផ្លូវចិត្ត៖** ព្យសនកម្ម អាចរាប់បញ្ចូលទាំងជំងឺផ្លូវចិត្ត ឬជំងឺវិកលចរិកដូចជាជំងឺបាក់ស្បាត។

*រឿងក្តី ឌុច៖ សាលក្រមអ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ៦៤១។ រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៨៣។*

**ការខូចខាតផ្លូវចិត្ត គឺអាចបណ្តាលមកពីឧក្រិដ្ឋកម្មប្រឆាំងញាតិលោហិត និងមានវិសាលភាពទូលំទំលាយទៅលើមនុស្ស៖** ព្យសនកម្មផ្លូវចិត្តមិនត្រូវបកស្រាយក្នុងន័យចង្អៀត ដែលគ្រាន់តែបណ្តាលមកពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តប្រឆាំងនឹងញាតិលោហិតឡើយ ផ្ទុយទៅវិញត្រូវបានបកស្រាយ ក្នុងន័យទូលំទាយជាងនេះ ដោយរាប់បញ្ចូលទាំងមនុស្សផ្សេងទៀត ដូចជាញាតិព័ន្ធ មិត្តភ័ក្ត្រ និងអ្នកជិតខាង ព្រមទាំងអ្នកផ្សេងទៀត ដោយឆ្លុះបញ្ចាំងពីចំណងវប្បធម៌ និងសង្គមរបស់កម្ពុជា។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៤៩ ៨៧ និង៨៨។*

**តុលាការ ត្រូវតែពិចារណាការធ្វើឲ្យរងគ្រោះខាងផ្លូវចិត្តទៅតាមបរិបទ៖** ក្នុងការវាយតម្លៃចំពោះព្យសនកម្មខាងផ្លូវចិត្ត សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តុលាការត្រូវពិចារណាជាចាំបាច់ លើការធ្វើឲ្យរងគ្រោះទៅតាមបរិបទនៃសង្គម និងវប្បធម៌នៅពេលដែលឧក្រិដ្ឋកម្មនោះបានកើតឡើង។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៨៣ និង៨៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ២៣ស្ទួន(២)។ វិធាននេះ មានលក្ខណៈស្រដៀងទៅនឹងមាត្រា ៣១១ លើកលែងតែវិធាននេះចែងថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអ.វ.ត.ក ត្រូវដាក់ក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីការបញ្ចប់កិច្ចស៊ើបសួរ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់នៃប្រទេសបារាំង គឺតុលាការកំពូល។*

**ដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារនៅពេលការចោទប្រកាន់ត្រូវបានផ្តួចផ្តើមឡើង តាមរយៈពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖** ក្នុងស្ថានភាពដូច្នេះ ជនណាដែលអះអាងថា ខ្លួនបានទទួលរងព្យសនកម្មពីបទល្មើសអាចដាក់បណ្តឹងរដ្ឋប្បវេណីមកតុលាការតាមមធ្យោបាយអន្តរាគមន៍។

*លេខ 07-88222 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២២៧ តុលាការកំពូលបារាំង ១២ វិច្ឆិកា ២០០៨។*

**មាត្រាស្រដៀងគ្នានៅក្នុង *ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** មាត្រា ៤១៨ ៤១៩ ៤២០ និង៤២១។ មាត្រាទាំងនេះ ចែងអំពីបណ្តឹងទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងផលវិបាកផ្សេងៗរបស់ខ្លួន រួមទាំងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលជំនុំជម្រះ។

# មាត្រា ៣១៣៖ ជំនួយ និងការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

*ដើមបណ្តឹងរដ្ឋប្បវេណី ក៏អាចត្រូវបានអមដោយមេធាវី ដែលខ្លួនបានជ្រើសរើស។ ដើមបណ្តឹងរដ្ឋប្បវេណី ក៏អាចត្រូវបានតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ដែរ។ អ្នកតំណាងដែលមិនមែនជាមេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ។*

## ការអនុវត្តនៅអ.វ.ត.ក

អង្គជំនុំជម្រះសាលាដំបូង អាចអនុញ្ញាតក្នុងការអនុម័តលើការមានតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបាន ប៉ុន្តែមិនមែនជាល័ក្ខខ័ណ្ឌតម្រូវទេ៖ ប៉ុន្តែជាទូទៅអង្គជំនុំជម្រះ មិនត្រួតពិនិត្យការចាត់តាំង ឬការផ្លាស់ប្តូរការមានតំណាងទេ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណី មិនចាំបាច់លើកអំពីបញ្ហានេះ ជាមួយអង្គជំនុំជម្រះសាលាដំបូងឡើយ ។

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ តំណាងដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ជ.ស.ដ ៦ មេសា ២០១១ ទំព័រ១។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ២៣ ស្ទួន២។ វិធាននេះខុសពីមាត្រា ៣១៣ ដោយតម្រូវថា គ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ត្រូវតំណាងដោយមេធាវីមួយរូប ចាប់ពីពេលចេញដីកាដំណោះស្រាយតទៅ និងចែងថា ដើមបណ្តឹងរដ្ឋប្បវេណី អាចបង្កើតជាក្រុម និងជ្រើសរើសមេធាវីឲ្យធ្វើតំណាងក្រុមជារួម និងថា ចៅក្រមស៊ើបសួរ ឬអង្គជំនុំជម្រះ អាចរៀបចំឲ្យមានតំណាងដូច្នេះបាន។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌ ស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**លទ្ធភាពចូលពិនិត្យមើលសំណុំរឿង៖** ការបដិសេធមិនផ្តល់លទ្ធភាពឲ្យចូលពិនិត្យមើលសំណុំរឿងដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលគ្មានមេធាវី គឺមិនមែនជាការរំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌របស់គាត់ឡើយ។

*រឿងក្តី MENET ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៤ មិថុនា ២០០៥ កថាខណ្ឌ ៥២។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មិនមានមាត្រាស្រដៀងគ្នាទេ។

# មាត្រា ៣១៥៖ ការចូលបង្ហាញខ្លួនរបស់សាក្សី

*សាក្សី ត្រូវតែចូលមកបង្ហាញខ្លួន នៅមុខតុលាការតាមការកោះហៅ។ តុលាការ អាចប្រើកងកម្លាំងសាធារណៈ ដើម្បីបង្ខំសាក្សីឱ្យចូលបង្ហាញខ្លួន។*

## ការអនុវត្តនៅអ.វ.ត.ក

**ការប្រើរហស្សនាមសាក្សី បញ្ជីឈ្មោះសាក្សីសម្ងាត់៖** អង្គជំនុំជម្រះសាលាដំបូង សម្រេចប្រើប្រាស់រហស្សនាម ដើម្បីជៀសវាងនូវការលំបាកផ្សេងៗ។ មានការរំលឹកថា បញ្ជីសាក្សីគឺជាឯកសារសម្ងាត់ ដែលបានផ្តល់ជូនមេធាវីជនជាប់ចោទ ព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៤ អ.វ.ត.ក អ.ជ.ស.ដ ៦ មេសា ២០០៩ ទំព័រ៩៣ បន្ទាត់ ២-៨ ។*

**ភាគីនានា ដែលបានចូលរួមនៅក្នុងដំណើរការនៃការស៊ើបអង្កេត អាចត្រូវបានគេចាត់ទុកថាជាសាក្សីជំនាញ៖** កាលណាផលប្រយោជន៍យុត្តិធម៌តម្រូវ អង្គជំនុំជម្រះសាលាដំបូង អាចធ្វើការកោះហៅសាក្សីជំនាញ ដែលជាភាគីមួយដែលពីមុនបានចូលរួមនៅក្នុងដំណើរការស៊ើបអង្កេត។ ទោះបីជាយ៉ាងណាក៏ដោយ ទម្ងន់ណាមួយត្រូវដាក់មកលើសក្ខីកម្មរបស់សាក្សី ត្រូវតែពិចារណាចំពោះការចូលរួមរបស់គេនៅក្នុងការស៊ើបអង្កេត។

*រឿងក្តី នួន ជា និងខៀវ សំផនៈ សេចក្តីសម្រេច ស្តីពីការតែងតាំងអ្នកជំនាញ TCE-៣៣ អ.វ.ត.ក អ.ជ.ស.ដ ២៦ មេសា ២០១៣ កថាខណ្ឌ ១៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៨០(១)។ វិធាននេះចែងថា ព្រះរាជអាជ្ញាត្រូវដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងនូវបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែលខ្លួនមានបំណងកោះហៅក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាធរមាន និងការបញ្ជាក់ឲ្យដាក់ជូនបញ្ជីឈ្មោះបន្ថែម។

## *ការអនុវត្តមាត្រាដែលស្រដៀងគ្នានៅក្នុងយុត្តាធិការដទៃទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកំណត់អំពីគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីមាត្រាមួយចំនួននៃកតិកាសញ្ញា/CCPR ដែលត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។*

**សិទ្ធិជាធាតុផ្សំនៃសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌៖** រួមមាន ប៉ុន្តែមិនកម្រិតត្រឹមតែសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ដែលត្រូវដឹកនាំដោយចៅក្រមមិនអនាមិក ដែលគេអាចជំទាស់តវ៉ាបាន អំពីសិទ្ធិក្នុងការប្រាស្រ័យទាក់ទងជាមួយមេធាវី សិទ្ធិជំទាស់តវ៉ាសាក្សីដែលកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួន ជាផ្នែកនៃកិច្ចស៊ើបសួរនៃគរបាល និងសិទ្ធិកោះហៅមន្ត្រីនគរបាលស៊ើបសួរធ្វើជាសាក្សី។

*រឿងក្តី CARRANZA ALEGRE ទល់នឹងប្រទេសប៉េរូ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៨ តុលា ២០០៥ កថាខណ្ឌ ៧.៥។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា ១៤។ មាត្រា នេះចែងអំពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលមានការធានាដោយផ្នែក នៅក្នុងមាត្រា ៣១៥ ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋាន មកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់នៃប្រទេសបារាំង គឺតុលាការកំពូល។*

**សាក្សីមានគោលជំហរដូចគ្នា៖** សាក្សីទាំងឡាយណា ដែលបង្ហាញខ្លួនដោយស្ម័គ្រចិត្តតាមសម្បថ គឺស្ថិតក្នុងស្ថានភាពដូចគ្នានឹងសាក្សី ដែលត្រូវបានកោះហៅដែរ ហើយអាចត្រូវបានផ្តន្ទាទោសដូចគ្នា ចំពោះការបដិសេធ ពុំព្រមផ្តល់សក្ខីកម្ម។

*លេខ 70-91953 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣០១ តុលាការកំពូលបារាំង ៤ វិច្ឆិកា ១៩៧១។*

**សាក្សី ដែលបានទទួលដំណឹងជាទៀងទាត់ តែមិនមានវត្តមាន នៅពេលបើកសវនាការ ប៉ុន្តែក្រោយមកស្រាប់តែបង្ហាញខ្លួនក្នុងសវនាការ ការណ៍នេះមិនបានបញ្ឈប់គាត់ពីផ្នែកនៃសវនាការឡើយ៖** សាក្សីរូបនេះ អាចត្រូវបានស្តាប់ តាមរយៈការធ្វើសម្បថ។

*DP 1888. 1. 45 តុលាការកំពូលបារាំង ៦ មិថុនា ១៨៨៧។*

**ដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចត្រូវបានស្ដាប់សក្ខីកម្មក្នុងនាមជាសាក្សីឡើយ ប៉ុន្តែគាត់អាចបង្ហាញខ្លួននៅចំពោះមុខតុលាការបាន ពេលណាគាត់ត្រូវបានកោះហៅក្នុងនាមដូច្នេះ៖** បើសិនជាគាត់មិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានគេចាត់ទុកថាជាសាក្សីកំបាំងមុខ។

*DP 1913. 1. 275 តុលាការកំពូលបារាំង ៧ មិថុនា ១៩១២។*

**តុលាការអាចរំលងសក្ខីកម្មសាក្សី ដែលមិនបង្ហាញខ្លួន បន្ទាប់ពីដីកាកោះ៖** គឺនៅពេលដែលសាក្សីរូបនោះមិនមែនជាសាក្សីដែលសំខាន់ខ្លាំង សម្រាប់ការបង្ហាញការពិត។

*លេខ 87-80056/87-80057 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៤៣ តុលាការកំពូលបារាំង ៩ ធ្នូ ១៩៨៧។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖ មាត្រា ១០៩ ៣២៦(១) និង៣២៦(២)។ មាត្រាទាំងនេះចែងអំពីការបង្ហាញខ្លួនរបស់សាក្សីក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (មាត្រា១០៩) និងនៅចំពោះមុខសាលាឧក្រិដ្ឋ (មាត្រា ៣២៦)។

# មាត្រា ៣១៦៖ សាធារណភាពនៃកិច្ចពិភាក្សាដេញដោល និង ភាពសម្ងាត់នៃកិច្ចពិភាក្សាដេញដោល

*ការពិភាក្សាដេញដោល ប្រព្រឹត្តទៅនៅក្នុងពេលសវនាការសាធារណៈ។*

*ប៉ុន្តែបើតុលាការយល់ឃើញថា សាធារណភាពបង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់នោះ តុលាការតាមសេចក្តីសម្រេចមានសំអាងហេតុ អាចបង្គាប់ឱ្យការពិភាក្សាដេញដោលទាំងស្រុង ឬ មួយផ្នែកប្រព្រឹត្តទៅជាសម្ងាត់។ តុលាការសម្រេចតាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេស នៃសាលក្រមលើអង្គសេចក្តី។*

*សេចក្តីសម្រេចរបស់តុលាការ ដែលបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់មិនអាចតវ៉ាបានទេ។*

## ***ការអនុវត្តនៅអ.វ.ត.ក***

**ការច្រានចោលដើមបណ្តឹងរដ្ឋប្បវេណី៖** ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានគេច្រានចោលពីកិច្ចប្រជុំរៀបចំសវនាការ ដែលធ្វើឡើងជាសម្ងាត់។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះ ទី១៩ អ.វ.ត.ក អ.ជ.ស.ជ ២១ ឧសភា ២០០៩ ទំព័រ១ បន្ទាត់ ១២ ទំព័រ ២បន្ទាត់ ២។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៧៩។ វិធាននេះមានលក្ខណៈស្រដៀងគ្នាទៅនឹងមាត្រា ៣១៦ ដោយក្នុងនោះ អនុញ្ញាតឲ្យតុលាការធ្វើសវនាការជាសម្ងាត់ ស្របតាមសេចក្តីសម្រេចដែលមានសំអាងហេតុដែលត្រូវបានបិទផ្សាយរំលឹងសាទុក្ខ ប៉ុន្តែមិនដូចមាត្រា ៣១៦ទេ វិធាននេះចែងថា នៅពេលដែលគោលបំណងនៃដំណើរការនីតិវិធីជាសម្ងាត់ អាចត្រូវបានបង្កឲ្យមានផលប៉ះពាល់ ដោយការចូលរួមរបស់ភាគី អង្គជំនុំជម្រះ បន្ទាប់ពីពិគ្រោះយោបល់ជាមួយភាគី តាមសេចក្តីសម្រេចដោយមានសំអាងហេតុ អាចកម្រិតការចូលរួមរបស់ភាគីត្រឹមតែភាគីណាដែលចាំបាច់ដល់ដំណើរការនីតិវិធី និងអ្នកតំណាងចាំបាច់របស់ពួកគេប៉ុណ្ណោះ។

# *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប***

*ប្រទេសកម្ពុជាគឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកំណត់អំពីគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីមាត្រាមួយចំនួននៃកតិកាសញ្ញា ICCPR ដែលត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។*

**ការអនុវត្តសិទ្ធិទទួលបានសវនាការជាសាធារណៈត្រូវបានកំហិត៖** សិទ្ធិនេះអនុវត្តបានចំពោះតែកិច្ចដំណើរការនីតិវិធីសវនាការ ប៉ុន្តែមិនអនុវត្តចំពោះសេចក្តីសម្រេចមុនពេលជំនុំជម្រះ លើអង្គសេចក្តីដែលចេញដោយរដ្ឋអាជ្ញា និងអាជ្ញាធរសាធារណៈទេ។

*រឿងក្តី KAVANAGHទល់ នឹងប្រទេសអៀកឡង់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៤ មេសា ២០០១ កថាខណ្ឌ ១០.៤។*

**សារៈសំខាន់នៃសវនាការជាសាធារណៈ៖** ក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ដែលមានលក្ខណៈជាសាធារណៈ គឺជាផ្នែកដ៏សំខាន់នៃសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

*រឿងក្តី KARTTUNEN ទល់នឹងប្រទេសហ្វាំងឡង់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ១៩៩២ កថាខណ្ឌ ៧.២។*

**ការជំនុំជម្រះ មិនត្រូវប្រានចោលសាធារណជនពីកិច្ចដំណើរការនីតិវិធីឡើយ ហើយក៏មិនឲ្យចៅក្រមអនាមិកបំពេញការងារដែរ៖** ការអនុវត្តដូច្នេះ គឺជាការខកខានមិនបានធានា ចំពោះសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ សច្ចធារណ៍នៃនិរទោស និងឯករាជភាព និងអនាគតិរបស់តុលាការ។

*រឿងក្តី POLAY ទល់នឹងប្រទេសប៉េរូ គណៈ-កម្មាធិការសិទ្ធិមនុស្សអ.ស.ប ៦ វិច្ឆិកា ១៩៩៧ កថាខណ្ឌ ៨.៨។*

**សិទ្ធិគឺជាធាតុផ្សំ នៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌៖** រួមមាន ប៉ុន្តែមិនកំហិតត្រឹមសិទ្ធិដូចតទៅនេះទេ សិទ្ធិទទួលបានសវនាការជាសាធារណៈដែលដឹកនាំដោយចៅក្រមមិនអនាមិក ដែលគេអាចជំទាស់តវ៉ាបាន សិទ្ធិក្នុងការប្រាស្រ័យទាក់ទងជាមួយមេធាវី សិទ្ធិជំទាស់តវ៉ាសាក្សី ដែលកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួន គឺជាផ្នែកនៃកិច្ចស៊ើបសួរនៃនគរបាល និងសិទ្ធិកោះហៅមន្ត្រីនគរបាលស៊ើបសួរមកធ្វើជាសាក្សី។

*រឿងក្តី CARRANZA ALEGRE ទល់នឹងប្រទេសប៉េរូ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៨ តុលា ២០០៥ កថាខណ្ឌ ៧.៥។*

មាត្រាស្រដៀងគ្នានៅក្នុង*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖* មាត្រា ១៤(១)។ មាត្រានេះចែងអំពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ លើកលែងតែក្នុងកាលៈទេសៈកំហិតមួយចំនួន ដូចជាមូលហេតុសីលធម៌សណ្តាប់ធ្នាប់សាធារណៈសន្តិសុខសង្គម ឬនៅក្នុងកាលៈទេសៈផ្សេងទៀត។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែង អំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុ-សញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**គោលការណ៍ស្តីពីសវនាការជាសាធារណៈ គឺជាមូលដ្ឋាន និងជាលក្ខខណ្ឌតម្រូវ សម្រាប់គ្រប់តុលាការ ឬ សាលាក្តីនីមួយៗ៖** ជាការសំខាន់ សម្រាប់ការជំនុំជម្រះក្តីដោយយុត្តិធម៌ ការរួមចំណែកក្នុងការការពារគូក្តី និង ការពង្រឹងទំនុកចិត្តចំពោះយុត្តិធម៌។

*រឿងក្តី HÅKANSSON និងSTURESSONទល់នឹងប្រទេសស៊ុយអែត តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ កុម្ភៈ ១៩៩០ កថាខណ្ឌ៦៦ (គោលការណ៍ជាមូលដ្ឋាន)។ រឿងក្តី FISCHER ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មេសា ១៩៩៥ កថាខណ្ឌ២៧ (លក្ខខណ្ឌតម្រូវនៃតុលាការ ឬសាលាក្តីនីមួយៗ)។ រឿងក្តីOYMAN ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២០ កុម្ភៈ ២០០៧ កថាខណ្ឌ ១៨ (សារៈសំខាន់ នៃសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌)។*

**មានតែនៅចំពោះមុខសាលាដំបូងមួយគត់ ដែលសិទ្ធិទទួលបាន "សិទ្ធិទទួលបាននូវសវនាការសាធារណៈ" ជាល័ក្ខខ័ណ្ឌតម្រូវ ក្នុងការទទួលបាន "សវនាការដោយផ្ទាល់មាត់"៖** សិទ្ធិនេះត្រូវបានអនុវត្តដូច្នេះ វៀរលែងតែក្នុងកាលៈទេសៈ លើកលែងពិសេស។

*រឿងក្តី JACOBSSON ទល់នឹងប្រទេសស៊ុយអែត (លេខ២) តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៩ កុម្ភៈ១៩៩៨ កថាខណ្ឌ ៤៦។*

**សិទ្ធិទទួលបានសវនាការជាសាធារណៈមិនដាច់ខាត៖** សិទ្ធិទទួលបានសវនាការមួយជាសាធារណៈ មិនដាច់ខាតទេ។

*រឿងក្តី HELMERS ទល់នឹងប្រទេសស៊ុយអែត តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៩ តុលា ១៩៩១ កថាខណ្ឌ ៣៦។*

**អវត្តមាននៃការជជែកដេញដោល ជាសាធារណៈ ក្នុងកម្រិតនីតិវិធី៖** អវត្តមានដូច្នេះ ត្រូវបានជួសជុល ដោយការជជែកដេញដោលជាសាធារណៈ ក្នុងអំឡុងពេល នៃដំណាក់កាលណាមួយផ្សេង។

*រឿងក្តីALBERT និង LE COMPTEទល់នឹងប្រទេសបែលហ្សិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ១០ កុម្ភៈ ១៩៨៣ កថាខណ្ឌ ២៩។*

**លទ្ធភាពក្នុងការផ្តល់យុត្តិកម្ម ចំពោះអវត្តមាននៃការជជែកដេញដោលជាសាធារណៈ ពីការត្រួតពិនិត្យក្នុងកម្រិតទីពីរ និងទីបី៖** អវត្តមាននេះ អាចនឹងត្រូវបានធ្វើយុត្តិកម្ម នៅពេលការជជែកដេញដោលជាសាធារណៈ ដោយសាលាដំបូង និងអាស្រ័យលើលក្ខណៈពិសេសនៃនីតិវិធីនៅកម្រិតទីពីរ ឬទីបី។

*រឿងក្តី ANDERSSON ទល់នឹងប្រទេសស៊ុយអែត តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៩ តុលា ១៩៩១ កថាខណ្ឌ ២៧។*

**ការខកខានមិនបានធ្វើសវនាការជាសាធារណៈ នៅកម្រិតឧទ្ធរណ៍ អាចជាការរំលោភលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌៖** បើសិនជាសាលាឧទ្ធរណ៍ ត្រូវបានគេប្តឹងអំពីបញ្ហានៃអង្គហេតុ និងអង្គច្បាប់ ហើយបញ្ហានីតិវិធីមានលក្ខណៈធ្ងន់ធ្ងរជាក់លាក់សម្រាប់អ្នកជាក់ពាក្យប្តឹង។

*រឿងក្តី CONSTANTINESCU ទល់នឹងប្រទេសរ៉ូម៉ានី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ មិថុនា ២០០០ កថាខណ្ឌ ៥៣។*

**ជនល្មើសជាអនីតិជន៖** ក្នុងករណីមានការពាក់ព័ន្ធនឹងជនល្មើសវ័យក្មេង ដែលអាចញ៉ាំងឲ្យមានការចាប់អារម្មណ៍ខ្លាំងពីសាធារណជន ជាការសំខាន់ធ្វើយ៉ាងណាឲ្យកិច្ចដំណើរការនីតិវិធីធ្វើឡើង តាមមធ្យោបាយ ដែលនឹងធ្វើឲ្យអារម្មណ៍នៃការភ័យខ្លាចការអៀនខ្មាស និងការបំភិតបំភ័យរបស់អនីតិជនត្រូវបានកាត់បន្ថយជាអប្បបរមា។ ផលប្រយោជន៍ទូទៅ ក្នុងកិច្ចការរដ្ឋបាលយុត្តិធម៌ ដោយបើកចំហ និងជាសាធារណៈ អាចនឹងត្រូវបានបំពេញនៅក្នុងករណីជនល្មើសជាអនីតិជន តាមរយៈនីតិវិធីកែសម្រួល ដែលផ្តល់នូវសិទ្ធិមានវត្តមានទៅតាមការជ្រើសរើស និងការរាយការណ៍ដោយហ្មត់ចត់។

*រឿងក្តី T. V. ទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៦ ធ្នូ ១៩៩៩ កថាខណ្ឌ ៨៥-៨៧។*

**បុគ្គលអាចបោះបង់សិទ្ធិ ដោយស្ម័គ្រចិត្តទោះក្នុងន័យច្បាស់លាស់ ឬក្នុងន័យបង្កប់ក្តី នូវសិទ្ធិទទួលបានសវនាការជាសាធារណៈ៖** ការលះបង់សិទ្ធិដូច្នេះត្រូវតែច្បាស់លាស់ ដែលគ្មានលក្ខខណ្ឌ និងដែលមិនផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈសំខាន់ណាមួយឡើយ។

*រឿងក្តី ALBERT និង LE COMPTE ទល់នឹងប្រទេសបែលហ្សិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ១០ កុម្ភៈ ១៩៨៣ កថាខណ្ឌ ៣៥។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុប ស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖ មាត្រា ៦(១)។ មាត្រានេះចែងពីសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះក្តី និងសាលក្រម ដោយត្រូវយុត្តិធម៌ និងជាសាធារណៈ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានបកស្រាយ និងអនុ*

*វត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំង គឺតុលាការកំពូល។*

**សវនាការជាសម្ងាត់ គឺជាករណីលើកលែងពិសេសនៃគោលការណ៍សវនាការជាសាធារណៈ៖** ការបញ្ឈប់ និងការវិលទៅរកភាពជាសាធារណៈវិញ មិនបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិការពារខ្លួនឡើយ។

*លេខ 99-85061 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៩៦ តុលាការកំពូលបារាំង ១៩ មេសា ២០០០។*

**ការធ្វើកំណត់ហេតុ នៃសវនាការជាសម្ងាត់៖** ការធ្វើកំណត់ហេតុដូច្នេះ ត្រូវបានហាមឃាត់។

*លេខ២004-80530 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៦ តុលាការកំពូលបារាំង ៣ កុម្ភៈ ២០០៤។*

**សេចក្តីប្រកាសអំពីសាធារណភាព នៃការជជែកដេញដោល បើមានការអន្តរាយដល់សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌៖** តុលាការ មានបុព្វសិទ្ធិដាច់មុខក្នុងការប្រកាសអំពីសាធារណភាពនៃការជជែកដេញដោល បើមានការអន្តរាយដល់សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌។

*លេខ 85-93351 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៥៧ តុលាការកំពូលបារាំង ១៥ កុម្ភៈ ១៩៨៦។*

**សិទ្ធិជំទាស់ទៅនឹងសេចក្តីសម្រេច ធ្វើសវនាការជាសម្ងាត់៖** វិធានការដូច្នេះ គឺជាករណីលើកលែងពិសេស និងផ្តាច់មុខ ដែលរក្សាសិទ្ធិទុកសម្រាប់តែបុគ្គលដែលមានគុណភាព ជាជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី។

*លេខ៨5-92109 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣៣៧ តុលាការកំពូលបារាំង ៣០ តុលា ១៩៨៥។*

**គ្រប់ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិទទួលបានសវនាការជាសម្ងាត់៖** ករណីនេះអនុវត្តបាន ទោះបីក្នុងករណីមានដើមបណ្តឹងរដ្ឋប្បវេណីច្រើនក៏ដោយ។

*លេខ២02-80369 តុលាការកំពូលបារាំង ២៣ តុលា ២០០២។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** មាត្រា ៣០៦។ មាត្រានេះចែងអំពីប្រកាសផ្សាយនៃការជជែកដេញដោល វៀរលែងតែការប្រកាសផ្សាយនេះ បង្កឲ្យមានការអន្តរាយដល់របៀបរៀបរយ និងសីលធម៌ (រួមទាំងករណីពាក់ព័ន្ធនឹងអនីតិជន ឬជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ អំពើទារុណកម្ម ឬអំពើព្រៃផ្សៃផ្សេងៗ)។

# មាត្រា ៣១៨៖ ការធានាសណ្ដាប់ធ្នាប់នៃសវនាការ

*ប្រធានសវនាការដឹកនាំការពិភាក្សាដេញដោល។ ប្រធាន ត្រូវរ៉ាប់រងឱ្យសិទ្ធិខាងការការពារបានប្រព្រឹត្តទៅដោយសេរី។ ប៉ុន្តែ ប្រធានអាចបដិសេធចេញពីការពិភាក្សាដេញដោលនូវអ្វីដែលមានគោលបំណងអូសបន្លាយការពិភាក្សាដេញដោលនេះ ដោយឥតប្រយោជន៍ គ្មានរួមវិភាគទានអ្វីដល់ការសំដែងឱ្យឃើញការពិត។*

*ប្រធានសវនាការរ៉ាប់រងឱ្យមានសណ្ដាប់ធ្នាប់ល្អនៅពេលសវនាការ។*

*ប្រធានសវនាការអាចហាមឃាត់អនីតិជនខ្លះ ឬទាំងអស់ មិនឱ្យចូលក្នុងបន្ទប់សវនាការ។*

*ប្រធានសវនាការ អាចបង្គាប់ឱ្យបណ្ដេញបុគ្គលគ្រប់រូប ដែលបង្កឱ្យមានការច្របូកច្របល់ដល់របៀបរៀបរយនៃការពិភាក្សាដេញដោល។*

*ក្នុងការបំពេញមុខងាររបស់ខ្លួន ប្រធានសវនាការអាចប្រើប្រាស់កងកម្លាំងសាធារណៈ។*

## ការអនុវត្តនៅអ.វ.ត.ក

**ស្ថានភាពដែលចៅក្រមស៊ើបសួរមានឆន្ទានុសិទ្ធិ ក្នុងការបដិសេធសំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់ភាគី៖** កាលណាសំណើសុំពុំមានលក្ខណៈច្បាស់លាស់។ លក្ខខណ្ឌតម្រូវថា សំណើដូច្នេះ ត្រូវតែច្បាស់លាស់ដើម្បីធានាឲ្យកិច្ចដំណើរការនីតិវិធី ប្រព្រឹត្តទៅដោយពុំមានការពន្យារពេលដោយពុំត្រឹមត្រូវ និងថាត្រូវតែការពារសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឲ្យស្វែងរកនូវភស្តុតាងដោះបន្ទុក អ.វ.ត.ក អ.ជ.ស.ជ ១២ វិច្ឆិកា ២០០៩ កថាខណ្ឌ៤០ (ឆន្ទានុសិទ្ធិក្នុងការបដិសេធសំណើ) និងកថាខណ្ឌ៤៣ (លក្ខខណ្ឌតម្រូវថា សំណើត្រូវតែច្បាស់លាស់ ដើម្បីធានាថាកិច្ចដំណើរការនីតិវិធី មិនត្រូវពន្យារពេលមិនត្រឹមត្រូវ)។ រឿងក្តីនួន ជា ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ ស្តីពីសំណើសុំភស្តុតាង ដោះបន្ទុក អ.វ.ត.ក អ.ប.ជ ១៨ វិច្ឆិកា២០០៩ កថាខណ្ឌ ៤១ (ចៅក្រមស៊ើបសួរ ត្រូវវាយតម្លៃថាតើសំណើ មានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីវាយតម្លៃពីភាពសមស្រប ដែលពុំធ្វើឲ្យមានការពន្យារពេល ដែលមិនត្រឹមត្រូវដល់កិច្ចដំណើរការនីតិវិធី) និងកថាខណ្ឌ៤៤ (សំណើសុំជាក់លាក់ អនុញ្ញាតឲ្យមានការវាយតម្លៃថា តើសំណើសុំមានការពាក់ព័ន្ធ ឬអត់ដោយគោរព ចំពោះសិទ្ធិជនត្រូវចោទ ដូចមានចែងក្នុងកតិកាសញ្ញា ICCPR)។*

**ភាពមិនអាចរឹងរូសបាន ចំពោះបញ្ហា ឬលើកឡើងបញ្ហាច្រំដែលនៅក្នុងសវនាការ៖** អង្គជំនុំជម្រះ គឺមិនអនុញ្ញាតឲ្យភាគីដំណើរការលើបញ្ហាដដែលៗឡើយ បើគ្មានបញ្ហាបន្ថែមណាមួយក្រៅអំពីការរឹងរូស ឬលើកបញ្ហាច្រំដែល។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី ៩ អ.វ.ត.ក អ.ជ.ស.ជ ២១ មេសា ២០០៩ ទំព័រ ៦៩ បន្ទាត់ ២៤-២៥ និងទំព័រ ៧០ បន្ទាត់ ១-២។*

**លំដាប់នៃការបង្ហាញអង្គហេតុ សក្ខីកម្ម ការសួរដេញដោល៖** ការជំនុំជម្រះ ត្រូវអនុវត្តទៅតាមលំដាប់នៃអង្គហេតុ ក្នុងដីកាដំណោះស្រាយ។ ភាគីនឹងត្រូវបានជូនដំណឹង ប្រហែល២សប្តាហ៍ ជាមុនអំពីអង្គហេតុដែលត្រូវបានកំណត់ពេលសម្រាប់ថ្ងៃសវនាការ។ ចំពោះអង្គហេតុណាមួយក៏ដោយ អង្គជំនុំជម្រះនឹងស្តាប់ចម្លើយជនជាប់ចោទមុនគេ បន្ទាប់មកផ្តល់វេទិកាទៅឲ្យភាគីដើម្បីសួរជនជាប់ចោទ។ បន្ទាប់ពីនោះមកអង្គជំនុំជម្រះ នឹងកោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញដែលពាក់ព័ន្ធទៅនឹងអង្គហេតុជាក់លាក់នីមួយៗ ដើម្បីសួរដេញដោល។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី ៤ អ.វ.ត.ក អ.ជ.ស.ជ ៦ មេសា ២០០៩ ទំព័រ ២ បន្ទាត់ ៩-១៧។*

**ការសួរសាក្សីរបស់ភាគីបដិបក្ខ មិនសមស្របសម្រាប់ប្រព័ន្ធច្បាប់ស៊ីវិលឡ (Civil Law) ទេ៖** ការសួរសាក្សីរបស់ភាគីបដិបក្ខគឺលក្ខណៈនៃការសួរដេញដោល អំពីចរិកលក្ខណៈនៅក្នុងប្រព័ន្ធច្បាប់ខាំម៉ុនឡ (Common Law)។ កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវបានគ្រប់គ្រងជាចំបង ដោយប្រព័ន្ធច្បាប់ស៊ីវិលឡ។ ការសួរសាក្សីរបស់ភាគីបដិបក្ខក្នុងលក្ខណៈ ជាការសួរដេញដោល ដែលមិនសមស្របឡើយ សម្រាប់ប្រព័ន្ធច្បាប់ស៊ីវិលឡ។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី ៤ អ.វ.ត.ក អ.ជ.ស.ជ ៦ មេសា ២០០៩ ទំព័រ ៣ បន្ទាត់ ៦-១០។*

**សារៈសំខាន់នៃសេចក្តីសម្រេច របស់អង្គបុរេជំនុំជម្រះ៖** ទោះបីជា អង្គជំនុំជម្រះសាលាដំបូងតែងតែកត់សម្គាល់ ដោយការយកចិត្តទុកដាក់បំផុតចំពោះសេចក្តីសម្រេច ដែលចេញដោយអង្គបុរេជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង មិនជាប់កាតព្វកិច្ចចំពោះសេចក្តីសម្រេចទាំងនោះឡើយ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៤ អ.វ.ត.ក អ.ជ.ស.ជ ៦ មេសា ២០០៩ ទំព័រ៥ បន្ទាត់៣-១១។*

**ការផ្តល់ជូន និងការសម្ងាត់នៃបញ្ជីឈ្មោះសាក្សី៖** ដើម្បីឲ្យការគ្រប់គ្រងយុត្តិធម៌ ឲ្យបានត្រឹមត្រូវ ភាគី គួរត្រូវបានផ្តល់ជូននូវបញ្ជីឈ្មោះសាក្សីដែលបានកោះហៅមកបង្ហាញខ្លួន នៅចំពោះមុខតុលាការ ប៉ុន្តែកាលណាមានការរំលឹកថា នៅពេល ដែលសាក្សីទាំងនោះ មិនទាន់បាន

មកបង្ហាញខ្លួនឈ្មោះ របស់ពួកគាត់ត្រូវរក្សាជាការសម្ងាត់។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការថ្ងៃជំនុំជម្រះទី ៤ អ.វ.ត.ក អ.ជ.ស.ជ ៦ មេសា ២០០៩ ទំព័រ ៥២ បន្ទាត់ ២២-ទំព័រ ៥៣ បន្ទាត់ ១។*

**ពេលវេលាបន្ថែម សម្រាប់ការសួរដេញដោលៈ** ភាគីត្រូវប្រើប្រាស់ឲ្យបានសមស្របនូវឱកាសដែលបានផ្តល់ជូន សម្រាប់ការសួរដេញដោល។ បើសិនជា ភាគីយល់ឃើញថា ពេលវេលាដែលបានផ្តល់ឲ្យមិនសមស្របទេ នោះអង្គជំនុំជម្រះ អាចសម្រេចអនុញ្ញាតឲ្យសួរបន្ថែមនៅថ្ងៃក្រោយ។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី ៥ អ.វ.ត.ក អ.ជ.ស.ជ ៧ មេសា ២០០៩ ទំព័រ ១១០ បន្ទាត់ ១-៦។*

**សាក្សីមានបញ្ហាភ្នែក ត្រូវបានអនុញ្ញាតឲ្យកំណត់អំពីអត្តសញ្ញាណជនជាប់ចោទ នៅលើអេក្រង់ទូរទស្សន៍/កុំព្យូទ័រៈ** ការកំណត់អត្តសញ្ញាណត្រូវបានគេធ្វើឡើង តាមរយៈការទាញរូបភាពតាមម៉ាស៊ីនថតឲ្យមកជិត ដើម្បីឲ្យសាក្សីអាចមើលឃើញជនជាប់ចោទ ដែលនៅលើអេក្រង់ទូរទស្សន៍/កុំព្យូទ័ររបស់គាត់។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី ៧ អ.វ.ត.ក អ.ជ.ស.ជ ៩ មេសា ២០០៩ ទំព័រ ៥២ បន្ទាត់ ១០-១២។*

**ភាគីត្រូវតែប្រាកដថា តើខ្លួនមានសំណួរ ឬក៏អត់ៈ** ការណីនេះ គឺដើម្បីឲ្យអង្គជំនុំជម្រះអាចយល់ និងគ្រប់គ្រងសវនាការបាន។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី២៣ អ.វ.ត.ក អ.ជ.ស.ជ ២៨ ឧសភា ២០០៩ ទំព័រ៩៩បន្ទាត់២៥-ទំព័រ១០០បន្ទាត់៣។*

**ជនជាប់ចោទ មិនមានសិទ្ធិដាច់ខាតនៅក្នុងការស្នើសុំអង្គជំនុំជម្រះ ដើម្បីកោះហៅសាក្សីទេៈ** ក្នុងករណីនៃការបង្ហាញអំពីភស្តុតាងដោះបន្ទុក តុល្យភាពមួយត្រូវតែសម្រេចបាន រវាងសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ របស់ជនជាប់ចោទ និងប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី។

*រឿងក្តី នួន ជា អៀង សារី និងខៀវ សំផនៈ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៩២ ស្តីពីការទទួលយកចម្លើយ និង ORS របស់សាក្សី អ.វ.ត.ក អ.ជ.ស.ជ ១២ មិថុនា ២០១២ កថាខណ្ឌ ១៨ -២១។ រឿងក្តី នួន ជា និងខៀវ សំផនៈ សេចក្តីសម្រេចជាស្ថាពរស្តីពីការស្តាប់ការសួរដេញដោលសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២/០១ អ.វ.ត.ក អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ ២២-២៦។*

ប្រធានអង្គជំនុំជម្រះ អាចដាក់ទណ្ឌកម្ម លើកិរិយាមិនត្រឹមត្រូវរបស់ក្រុមមេធាវីការពារ ឬបដិសេធមិនឲ្យមេធាវីចូលរួមសវនាការ បន្ទាប់ពីការព្រមានត្រូវបានធ្វើឡើង ប្រសិនបើកិរិយារបស់មេធាវីមានលក្ខណៈប្រមាថមើលងាយ ឬហួសប្រមាណ៖ ប្រធានអង្គជំនុំជម្រះអាចយោងបន្ថែមដល់កិរិយាមិនត្រឹមត្រូវរបស់មេធាវី ចំពោះស្ថាប័ន វិជ្ជាជីវៈសមស្របណាមួយ។

*រឿងក្តី នួន ជា៖ សេចក្តីសម្រេច ស្តីពីកិរិយាមិនត្រឹមត្រូវរបស់មេធាវីការពារ នួន ជា អ.វ.ត.ក អ.ជ.ស.ជ ២៩ មិថុនា ២០១២ កថាខណ្ឌ ៣។*

សេចក្តីថ្លែងការណ៍ ស្តីពីផលប៉ះពាល់របស់ជនរងគ្រោះ អាចបង្កើតបានជាផ្នែកមួយនៃសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រោះថា ជនជាប់ចោទត្រូវបានផ្តល់សិទ្ធិ ដើម្បីឆ្លើយតប៖ ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍ ដែលរៀបរាប់អំពីបទនៃការឈឺចាប់ទាំងអស់របស់គេ។ ទោះបីជាយ៉ាងក៏ដោយ សេចក្តីថ្លែងការណ៍នោះ មិនត្រូវដាក់បញ្ចូលនូវការចោទប្រកាន់ថ្មីៗ ប្រឆាំងនឹងជនជាប់ចោទឡើយ។ លើសពីនេះទៀត ជនជាប់ចោទ ត្រូវទទួលបានជានិច្ចនូវសិទ្ធិតទល់ទៅនឹងសេចក្តីថ្លែងការណ៍ទាំងនេះ ជាពិសេសនៅពេលដែល សេចក្តីថ្លែងការណ៍ទាំងនេះទាក់ទងទៅនឹងភស្តុតាងដោះបន្ទុក។ ការតទល់ទាំងនោះត្រូវធ្វើឡើង ដោយអវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជៀសវាងនូវការឈឺចាប់បន្ថែមកើតមានឡើង។

*រឿងក្តី នួន ជា និងខៀវ សំផន៖ សេចក្តីសម្រេចលើសំណើសុំកោះហៅឡើងវិញ ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៨៧ និងសុំឱ្យពិនិត្យឡើងវិញ លើបែបបទពាក់ព័ន្ធទៅនឹងសេចក្តីថ្លែងការណ៍ស្តីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើសុំ និងការឆ្លើយតបពាក់ព័ន្ធ អ.ជ.ស.ជ ២ ឧសភា ២០១៣ កថាខណ្ឌ ១៩-២២។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៣៧ ៣៨ ៨៤(១) និង ៨៥។ វិធាន ៨៥ មានលក្ខណៈស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ៣១៨ លើកលែងតែវិធាននេះតម្រូវឲ្យអង្គជំនុំជម្រះចេញការព្រមានជាមុន ចំពោះបុគ្គលណាដែលរំខាន និងថា បើសិនបុគ្គលដែលត្រូវបានដកចេញពីសាលសវនាការជាជនជាប់ចោទ ជននេះត្រូវបានអនុញ្ញាតឲ្យសង្កេតការជំនុំជម្រះតាមទូរទស្សន៍ នៅកន្លែងបិទជិតតាមដែលអាចធ្វើបាន ហើយអាចរក្សាការទំនាក់ទំនងតាមទូរស័ព្ទបានគ្រប់ពេលវេលាជាមួយមេធាវីរបស់ខ្លួន និងថា កាលណាមានការរំខាន ដូចជាការបដិសេធដោយគិតទុកជាមុន មិនព្រមអនុវត្តតាមសេចក្តីសម្រេចផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះ និងការបង្គាប់ត្រូវអមដោយការព្រមានអំពីការដាក់ទណ្ឌកម្មណាមួយ ក្នុងករណីមានការបំពាន ដែលអង្គជំនុំជម្រះអាចចេញសេចក្តីបង្គាប់ដាក់ទណ្ឌកម្ម

ស្របតាមច្បាប់កម្ពុជា។ វិធាន ៣៨ គ្របដណ្តប់លើកំហុសវិជ្ជាជីវៈរបស់មេធាវី និងចែងយោងជាពិសេសពីរបៀបដែលតុលាការ អាចចាត់ការជាមួយមេធាវីដែលរំខាន។ វិធីសាស្ត្រទាំងនេះរួមមាន ការព្រមានចំពោះមេធាវី ការដាក់ទណ្ឌកម្ម និងការរាយការណ៍អំពីមេធាវីរូបនោះទៅអាជ្ញាធរសមស្រប។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកំណត់អំពីគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីមាត្រាមួយចំនួននៃកតិកាសញ្ញា ICCPR ដែលត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។*

**ការរំលោភ៖ ការខកខានមិនបានត្រួតត្រាលើបរិកាសអរិភាព ឬសម្ពាធ ដែលបានបង្កើតឡើងដោយវត្តមានរបស់សាធារណជន៖** បរិយាកាសដូច្នេះ គឺជាការបដិសេធមិនផ្តល់ឲ្យមេធាវីការពារក្តី នូវឱកាសគ្រប់គ្រាន់ ដើម្បីធ្វើការសួរសាក្សីរបស់ភាគីបដិបក្ខ និងការបង្ហាញរឿងក្តីរបស់គេ។

> *រឿងក្តី GRIDIN ទល់នឹងសហព័ន្ធរុស្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ កក្កដា ២០០០ កថាខណ្ឌ ៨.២។*

**ការរំលោភ៖ ទោសទណ្ឌធ្ងន់ធ្ងរ និងទណ្ឌកម្មគ្មានសំអាងហេតុ (ឧទាហរណ៍ ទោសទណ្ឌជាប់ពន្ធនាគារមួយឆ្នាំ ដោយបង្ខំឲ្យធ្វើការងារធ្ងន់ ចំពោះការដាក់សំណើច្រំដែលរបស់អ្នកដាក់ពាក្យសុំណាម្នាក់ ការបដិសេធមិនសុំទោស ចំពោះពាក្យសំដីគំហកកំហែងក្នុងតុលាការ)៖** ទោសទណ្ឌដូច្នេះ ហួសពីអំណាចរបស់តុលាការ នៅក្នុងការរក្សារកិច្ចដំណើរការនីតិវិធីឲ្យមានរបៀបរៀបរយ និងបង្កើតបានជាការដកហូតសិទ្ធិសេរីភាពតាមទំនើងចិត្ត។

> *រឿងក្តី FERNANDO ទល់នឹងប្រទេសស្រីលង្កា គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប ៣១ មីនា ២០០៥ កថាខណ្ឌ ៩.២។*

**ការរំលោភ៖ មន្ត្រីជាន់ខ្ពស់ធ្វើសេចក្តីថ្លែងការណ៍ដ៏ទូលំទូលាយផ្សព្វផ្សាយ ជាសាធារណៈអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ មុនលទ្ធផលជំនុំជម្រះ៖** សេចក្តីថ្លែងការណ៍ដូច្នេះ ដែលបានធ្វើឡើងក្នុងបុរេនិច្ឆ័យអំពីលទ្ធផលនៃការជំនុំជម្រះ គឺជាការរំលោភលើសច្ចធារណ៍នៃនិរទោស។

> *រឿងក្តី GRIDIN ទល់នឹងសហព័ន្ធរុស្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ កក្កដា ២០០០ កថាខណ្ឌ ៨.៣។*

**គ្មានការរំលោភ៖ កាលណាជនជាប់ចោទ ខកខានមិនបានស្នើឲ្យមានការលើកពេលសវនាការ ដើម្បីធានាឲ្យចំពោះតំណាងស្របច្បាប់ ដែលច្បាប់បានចែងអំពីសិទ្ធិនេះ៖** ទោះបីបុគ្គលរូបនោះត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការមានមេធាវី និងមាន

ពេលវេលា និងឧបករណ៍សម្រួលគ្រប់គ្រាន់សម្រាប់ការត្រៀមរៀបចំការការពារខ្លួនក៏ដោយ ក៏សិទ្ធិនេះមិនត្រូវបានរំលោភឡើយ បើសិនជា នីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនោះ អនុញ្ញាតឲ្យជនជាប់ចោទធ្វើការស្នើសុំការលើកពេលសវនាការ និងផ្តល់ពេលវេលាបន្ថែម ដើម្បីជានាឲ្យមានតំណាងស្របច្បាប់ ហើយជនជាប់ចោទខ្លួនឯងក៏ជាអ្នកខកខាន មិនបានប្រើប្រាស់ជាប្រយោជន៍ នូវឧបាស្រ័យទាំងអស់នេះ។

*រឿងក្តី BABKIN ទល់នឹងសហព័ន្ធរុស្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣ មេសា ២០០៨ កថាខណ្ឌ ១៣.៤។*

**គ្មានការរំលោភ៖ កាលណា មេធាវីការពារក្តីជនជាប់ចោទខកខានមិនបាន ប្រើប្រាស់ឲ្យបានល្អនូវពេលវេលាដែលមាន សម្រាប់ការត្រៀមរៀបចំការការពារខ្លួន៖** សិទ្ធិរបស់បុគ្គល ក្នុងការទទួលបានពេលវេលា និងឧបករណ៍សម្រួលគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការការពារខ្លួន មិនត្រូវបានរំលោភឡើយ បើសិនជាកង្វះនៃការការពារខ្លួនសមស្របនោះ បង្កដោយការខកខានរបស់មេធាវីការពារក្តីជននោះ នៅក្នុងការប្រើពេលវេលាដែលមានឲ្យបានល្អ សម្រាប់ការត្រៀមរៀបចំការការពារខ្លួន ជាជាងដោយសារសកម្មភាពណាមួយបង្កឡើងដោយរដ្ឋ។

*រឿងក្តី J.O. ទល់នឹងប្រទេសបារាំង គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ មីនា ២០១១ កថាខណ្ឌ ៩.៤។*

**សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះ ដោយគ្មានការពន្យារពេលមិនត្រឹមត្រូវ ការពារជនជាប់ចោទ អំពីភាពមិនប្រាកដប្រជាមិនចាំបាច់ចំពោះវាសនារបស់គាត់ និងពីការឃុំខ្លួនយូរជាងភាពចាំបាច់៖** រដ្ឋមានករណីយកិច្ច ក្នុងការកិច្ចរៀបចំប្រព័ន្ធតុលាការរបស់ខ្លួន ដែលមានការធានាថារឿងក្តីត្រូវបានដោះស្រាយបញ្ចប់ ដោយយុត្តិធម៌ និងឆាប់រហ័ស។ ការពន្យារពេលណាក៏ដោយ ក្នុងរយៈពេលប្រាំបីឆ្នាំ រវាងការចោទប្រកាន់ និងការកាត់ទោស និងការត្រួតពិនិត្យ លើបណ្តឹងឧទ្ធរណ៍គឺជាការមិនសមស្រប។

*រឿងក្តី LUMANOG និង SANTOS ទល់នឹងប្រទេសហ្វីលីពីន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ មីនា ២០០៨ កថាខណ្ឌ ៨.៣-៨.៦ ដែលបានយកមកអនុវត្តតាម នៅក្នុងរឿងក្តី SOBHRAJ ទល់នឹងប្រទេសណេប៉ាល់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ កក្កដា ២០១០ កថាខណ្ឌ ៧.៤។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ៖*** មាត្រា ៦(១)។ មាត្រានេះចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិក្នុងការទទួលបានសវនាការ និងសាលក្រមដោយយុត្តិធម៌ និងជាសាធារណៈ។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**គោលការណ៍ស្តីពីសវនាការជាសាធារណៈ គឺជាមូលដ្ឋាន និងជាលក្ខខណ្ឌតម្រូវ សម្រាប់គ្រប់តុលាការ ឬសាលាក្តីនីមួយៗ៖** ជាការសំខាន់សម្រាប់ការជំនុំជម្រះក្តីដោយយុត្តិធម៌ ដើម្បីរួមចំណែកក្នុងការការពារគូក្តី និងការពង្រឹងទំនុកចិត្តចំពោះយុត្តិធម៌។

*រឿងក្តី HÅKANSSON និង STURESSON ទល់នឹងប្រទេសស៊ុយអែត តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ កុម្ភៈ ១៩៩០ កថាខណ្ឌ ៦៦ (គោលការណ៍ជាមូលដ្ឋាន)។ រឿងក្តី FISCHER ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មេសា ១៩៩៥ កថាខណ្ឌ២៧ (ជាលក្ខខណ្ឌតម្រូវ នៅក្នុងតុលាការ ឬ សាលាក្តីនីមួយៗ)។ រឿងក្តី OYMAN ទល់នឹងប្រទេសទួគីតុលាការសិទ្ធិមនុស្សអឺរ៉ុប ២០ កុម្ភៈ ២០០៧ កថាខណ្ឌ១៨ (សារៈសំខាន់នៃសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌។ល)។*

**សិទ្ធិទទួលបានសវនការជាសាធារណៈមិនដាច់ខាត ៖** សិទ្ធិទទួលបានសវនការជាសាធារណៈមិនដាច់ខាតទេ។

*រឿងក្តី HELMERS ទល់នឹងប្រទេសស៊ុយអែត តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៩ តុលា ១៩៩១ កថាខណ្ឌ ៣៦។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មាត្រា ៦(១)។ មាត្រានេះ ចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងការប្រកាសផ្សាយនៃការពិភាក្សាដេញដោល និងការប្រកាសសាលក្រម។ ផ្ទុយទៅវិញ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសាធារណជនអាចត្រូវបានច្រានចោលដោយសារមូលហេតុដែលមានកំណត់។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំង ត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់នៃប្រទេសបារាំង គឺតុលាការកំពូល។*

**វិធានការដែលចៅក្រម អាចចាត់ការដើម្បីរក្សារបៀបរៀបរយនៅក្នុងសវនាការ៖** ការបណ្តេញចេញជនណា ដែលរំខានដល់ការពិភាក្សាដេញដោល ការបដិសេធមិនព្រមសួរសាក្សី តាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែមិនពាក់ព័ន្ធទៅនឹងសំណុំរឿង ហើយដែលនឹងនាំឲ្យមានការអូសបន្លាយពេល និងមិនអាចនាំទៅរកការពិតបានការបដិសេធមិនដាក់បញ្ចូលនូវឯកសារ ដែលបានផលិតដោយមេធាវីការពារក្តី ដោយសារតែវានឹងនាំឲ្យមានការអូសបន្លាយពេល និងមិនអាចនាំទៅរកការពិតបាន។

*លេខ84-90673 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ៣១៨ តុលាការកំពូលបារាំង ២៤ តុលា ១៩៨៤ (ការបណ្តេញចេញ)។ លេខ92-86470 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ២៥១ តុលាការកំពូលបារាំង ២៦ កក្កដា ១៩៩៣ (ការបដិសេធពុំព្រមសួរដេញដោលសាក្សី តាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី)។ លេខ96-82498 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ៣៨១ តុលាការកំពូលបារាំង ១២ វិច្ឆិកា ១៩៩៧។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ*បារាំង៖ មាត្រា ៣០៩។ មាត្រានេះចែងថា ប្រធានតុលាការមានអំណាចក្នុងការរក្សារបៀបរៀបរយក្នុងតុលាការ និងដឹកនាំកិច្ចដំណើរការនីតិវិធី។

# មាត្រា ៣២១៖ ការវាយតម្លៃលើភស្តុតាងដោយតុលាការ

*លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥតស្សរចិត្តអំពីតម្លៃភស្តុតាង ដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។*

*តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុភាង ដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ។*

*ការសារភាព ក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះគ្មានតម្លៃជាភស្តុតាងទេ។*

*ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួនមិនអាចយកមកធ្វើជាភស្តុតាងបានឡើយ។*

## ការអនុវត្តនៅអ.វ.ត.ក

**សេចក្តីសម្រេច ស្តីពីភាពអាចទទួលយកបាននៃភស្តុតាង ត្រូវបានធ្វើឡើងក្នុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ៖** អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការពិនិត្យលើបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងការវាយតម្លៃលើភស្តុតាងធ្វើឡើងដោយចៅក្រមស៊ើបសួរឡើយ ដោយហេតុថាសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃភស្តុតាង ត្រូវបានធ្វើឡើងក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី។

> *រឿងក្តី អៀង សារី៖ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងភស្តុតាងទទួលបានតាមរយៈអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ ២៤។*

**សំណើសុំខុសច្បាប់ អាចត្រូវបានច្រានចោល៖** អង្គជំនុំជម្រះសាលាដំបូង អាចច្រានចោលនូវសំណើសុំភស្តុតាង នៅពេលណាដែលការបំពេញលក្ខខណ្ឌសម្រាប់សំណើសុំ ដូច្នេះមិនត្រូវបានច្បាប់អនុញ្ញាត។

> *រឿងក្តី អៀង សារី៖ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងភស្តុតាងទទួលបានតាមរយៈអំពើទារុណកម្ម អ.វ.ត.ក អ.ប.ជ ១០ ឧសភា ២០១០ កថាខណ្ឌ ៣៥។*

**អង្គជំនុំជម្រះសាលាដំបូង នឹងបដិសេធសំណើសុំ កាលណាខ្លួនបានសម្រេចលើបញ្ហានេះរួចហើយ៖** ទោះបីជា មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យលើការអនុម័តរបស់ខ្លួន ស្តីពីការផ្សព្វផ្សាយឯកសាររបស់

ព្រះរាជអាជ្ញា ដោយឈរលើមូលដ្ឋាន នៃភាពលម្អៀងក្តី ក៏អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលសំណើនោះ ដោយសារតែបញ្ហានោះត្រូវបានសម្រេចរួចហើយ។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១១ អ.វ.ត.ក អ.ជ.ស.ជ ២៣ មេសា ២០០៩ ទំព័រ ៩ បន្ទាត់ ១២-១៣ និងទំព័រ ៣៨ បន្ទាត់ ១២-១៦។*

**តុលាការជាប់កាតព្វកិច្ច តាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មៈ** មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ហាមរដ្ឋមិនឲ្យយកកំណត់ហេតុ ដែលកើតចេញពីអំពើទារុណកម្ម ធ្វើជាភស្តុតាងទេ។ បទប្បញ្ញត្តិនេះ ត្រូវបានចែងបញ្ជាក់ ដោយមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី ២៣ អ.វ.ត.ក អ.ជ.ស.ជ ២៨ ឧសភា ២០០៩ ទំព័រ ៩ បន្ទាត់ ១-៦។*

**ខ្លឹមសារនៃចម្លើយសារភាព ដែលបានធ្វើឡើងក្រោមអំពើទារុណកម្ម មិនអាចទទួលយកធ្វើជាកំណត់ហេតុគួរឲ្យជឿបានឡើយៈ** បើសិនជាភាគីណាមួយ មានបំណងចង់យោងទៅរកភាពជឿជាក់លើខ្លឹមសារ នៃចម្លើយសារភាព ជាបំដូងគេត្រូវតែកំណត់ឲ្យបាន ថាតើចម្លើយសារភាពនោះត្រូវបានធ្វើឡើង នៅក្រោមអំពើទារុណកម្ម ឬការគំរាមកំហែងនៃអំពើទារុណកម្មដែរឬទេ។ ដោយសារមូលហេតុនេះ ភាគីគួរតែពិចារណាថា តើការសួរដេញដោលលើខ្លឹមសារ នៃចម្លើយសារភាពមានសារសំខាន់គ្រប់គ្រាន់ សម្រាប់ស្នើឲ្យមានការស្រាវជ្រាវទាក់ទងនឹងកាលៈទេសៈផ្សេង ៗ ដែលនាំឲ្យមានចម្លើយសារភាពនោះដែរឬទេ។

*រឿងក្តី ឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី ២៣ អ.វ.ត.ក អ.ជ.ស.ជ ២៨ ឧសភា ២០០៩ ទំព័រ ៩ បន្ទាត់ ១-១១។ រឿងក្តី នួន ជា ខៀវ សំផន និងអៀង សារីៈ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារ ដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ អ.វ.ត.ក អ.ជ.ស.ជ ៩ មេសា ២០១២ កថាខណ្ឌ ២១។*

**នៅពេលឯកសារ ត្រូវបានដាក់នៅចំពោះមុខតុលាការ គ្រប់ភាគីមានសិទ្ធិជំទាស់នឹងភាពអាចទទួលយកបាននៃឯកសារ បើសិនមានសំអាងហេតុត្រឹមត្រូវៈ** នេះគឺជាបុរេលក្ខខណ្ឌ ចំពោះការទទួលយករបស់ខ្លួន។ ភាគីក៏មានសិទ្ធិស្វែងរកព័ត៌មាន ឬការបំភ្លឺបន្ថែមទាក់ទងនឹងឯកសារ ដែលភាគីណាមួយបានស្នើដាក់នៅចំពោះមុខតុលាការដែរ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី ១៨ អ.វ.ត.ក អ.ជ.ស.ជ ២០ ឧសភា ២០០៩ ទំព័រ ៥ បន្ទាត់១៨-២២។ រឿងក្តីនួន ជា ខៀវ សំផន និងអៀង សារីៈ សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មី និងបញ្ហាពាក់ព័ន្ធដទៃទៀត*

*អ.វ.ត.ក អ.ជ.ស.ជ ៣០ មេសា ២០១២ កថាខណ្ឌ ១៨។*

**អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកបាននូវឯកសារថ្មីៗ ដែលមិនមាននៅក្នុងសំណុំរឿងតាំងពីដើម៖** តុលាការអាចធ្វើដូច្នេះបានដោយឥស្សរចិត្ត ឬតាមសំណើរបស់ភាគី។

*រឿងក្តី ឌុច៖ សាលក្រម អ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ ៤០។ រឿងក្តី នួន ជា ខៀវ សំផន និងអៀង សារី៖ សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មី និងបញ្ហាពាក់ព័ន្ធដទៃទៀត អ.វ.ត.ក អ.ជ.ស.ជ ៣០ មេសា ២០១២ កថាខណ្ឌ ១៧។*

**ឯកសារក្នុងសំណុំរឿង មិនត្រូវបានចាត់ទុកថាជាភស្តុតាងទេ រហូតដល់ពេលដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងជាកម្មវត្ថុនៃការដេញដោល៖** ឯកសារត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ លុះត្រាតែខ្លឹមសារនៃឯកសារនោះត្រូវបានសង្ខេបត្រូវបានអាន និងត្រូវបានកំណត់អត្តសញ្ញាណ យ៉ាងសមស្រប។ សម្ភារៈឯកសារ អាចត្រូវបានចាត់ទុកថាបានក្លាយជាកម្មវត្ថុនៃការដេញដោល លុះត្រាតែឱកាសត្រូវបានផ្តល់ឲ្យ ដើម្បីធ្វើអំណះអំណាងតទល់គ្នា ទោះបីជាភាគីមិនបានប្រើឱកាសនេះជាប្រយោជន៍របស់ខ្លួនក៏ដោយ។

*រឿងក្តីឌុច៖ ភាពអាចទទួលយកបាន នៃភស្តុតាងបន្ថែម អ.វ.ត.ក អ.ជ.ស.ជ ២៨ តុលា ២០០៩ កថាខណ្ឌ២។ រឿងក្តីឌុច៖ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១៨ អ.វ.ត.ក អ.ជ.ស.ជ ២០ ឧសភា ២០០៩ ទំព័រ៤ បន្ទាត់២៣-ទំព័រ៥ បន្ទាត់១២។*

**មានតែផ្នែកនៃឯកសារ ដែលបានធ្វើសង្ខេបតែប៉ុណ្ណោះត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខតុលាការ៖** ឧ. បើសិនជា មានតែមួយជំពូកនៃសៀវភៅត្រូវបានសង្ខេប គឺមានតែផ្នែកនេះប៉ុណ្ណោះត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខតុលាការ។ ប៉ុន្តែ បើសិនជាការពិភាក្សាលើឯកសារបានពង្រីក លើសពីសេចក្តីសង្ខេបបឋម នោះអង្គជំនុំជម្រះ សាលាដំបូងអាចប្រើកិច្ចពិភាក្សាទាំងមូលសម្រាប់ការសម្រេចសេចក្តីរបស់ខ្លួន។

*រឿងក្តីឌុច៖ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១៨ អ.វ.ត.ក អ.ជ.ស.ជ ២០ ឧសភា ២០០៩ ទំព័រ៥ បន្ទាត់៦-១២។*

**នៅពេលដាក់ឯកសារ នៅចំពោះមុខអង្គជំនុំជម្រះ ភាគីត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ ថាតើខ្លួនមានបំណងចង់ឲ្យពិចារណា ទៅលើឯកសារទាំងមូលដែរឬទេ៖** បើសិនជាភាគី ដែលមានបំណងដាក់បង្ហាញ តែផ្នែកណាមួយនៃឯកសារ ភាគីនោះត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ ពីភាពពាក់ព័ន្ធរបស់វា។

*រឿងក្តីឌុច៖ ភាពអាចទទួលយកបាន នៃភស្តុតាងបន្ថែម អ.វ.ត.ក អ.ជ.ស.ជ ២៨ តុលា ២០០៩ កថាខណ្ឌ៣។ រឿងក្តីឌុច៖ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១៨ អ.វ.ត.ក*

*អ.ជ.ស.ជ ២០ ឧសភា ២០០៩ ទំព័រ៥ បន្ទាត់ ១៣-១៦។ រឿងក្តីនួន ជា ខៀវ សំផន និង អៀង សារី៖ សេចក្តីសម្រេច ទាក់ទងនឹងឯកសារថ្មី និងបញ្ហាពាក់ព័ន្ធដទៃទៀត អ.វ.ត.ក អ.ជ.ស.ជ ៣០ មេសា ២០១២ កថាខណ្ឌ១៨។*

**ឯកសារបានចុះបញ្ជី ក្នុងឧបសម្ព័ន្ធនៃរបាយការណ៍របស់អ្នកជំនាញ ពុំចាំបាច់ធ្វើសង្ខេបម្តងមួយៗទេ៖** ឯកសារនោះអាចត្រូវបានគេមើលឃើញថា ជាផ្នែកដ៏សំខាន់ នៃរបាយការណ៍។ បើសិនជា ភាគីជំទាស់ទទួលស្គាល់ថា របាយការណ៍ ព្រមទាំងបញ្ជីឯកសារបានចុះបញ្ជីក្នុងឧបសម្ព័ន្ធត្រូវបានដាក់ នៅចំពោះមុខនៃអង្គជំនុំជម្រះនិងមិនមានការតវ៉ា ចំពោះរបាយការណ៍នេះជាការគ្រប់គ្រាន់ ត្រូវដាក់របាយការណ៍នេះចំពោះមុខអង្គជំនុំជម្រះ និងពុំចាំបាច់ធ្វើសង្ខេបនៅគ្រប់ឯកសារនីមួយៗ នៅក្នុងឧបសម្ព័ន្ធឡើយ។

*រឿងក្តីឧបត្ថម្ភ៖ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១៩ អ.វ.ត.ក អ.ជ.ស.ជ ២១ ឧសភា ២០០៩ ទំព័រ២ បន្ទាត់១៧-ទំព័រ៣ បន្ទាត់៤។*

**តម្លៃភវនីយភាពនៃឯកសារ និងទម្ងន់ភស្តុតាង៖** ករណីនេះនឹងត្រូវបានវាយតម្លៃ ជាចុងក្រោយដោយអង្គជំនុំជម្រះ។ មិនមានការសន្មត់ជាមុនអំពីគោលការណ៍ បង្ហាញភស្តុតាង ផ្អែកតាមអង្គហេតុបានឃើញជាបឋម (Facie Prima) ទៅនឹងតម្លៃភវនីយភាព ភាពពាក់ព័ន្ធ ឬភាពអាចទុកចិត្តបាននៃភស្តុតាង ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង។

*រឿងក្តីឧបត្ថម្ភ៖ សាលក្រមអ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ៤២។ រឿងក្តីនួន ជា ខៀវ សំផន និងអៀង សារី៖ សេចក្តីសម្រេច លើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់ នៅចំពោះមុខនៃអង្គជំនុំជម្រះ អ.ជ.ស.ជ ៩ មេសា ២០១២ កថាខណ្ឌ៣៤។ រឿងក្តីនួន ជា ខៀវ សំផន និងអៀង សារី៖ សាលក្រមសំណុំរឿងលេខ០០២/០១ អ.ជ.ស.ជ ៧ សីហា ២០១៤ កថខណ្ឌ២២-២៦។*

**ការចែកចាយឯកសាររូបថត ដោយភាគី៖** គ្រប់ភាគីទាំងអស់ មានសិទ្ធិចងក្រងឯកសាររូបថត ដើម្បីចែកចាយទៅអង្គជំនុំជម្រះ ឬភាគីដទៃទៀត ដើម្បីសម្រួលដល់នីតិវិធីសវនាការ។

*រឿងក្តីឧបត្ថម្ភ៖ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១២ អ.វ.ត.ក អ.ជ.ស.ជ ២៧ មេសា ២០០៩ ទំព័រ៣០ បន្ទាត់១៦-២៤។*

**ភាគីអាចជូនដំណឹងដល់ ក្រឡាបញ្ជីអំពីបំណងរបស់ខ្លួន ក្នុងការដាក់ឯកសារ នៅចំពោះមុខអង្គជំនុំជម្រះ៖** ករណីនេះ មិនមែនជាកាតព្វកិច្ចទេ។ ប៉ុន្តែជាករណីដែលភាគីអាចធ្វើបាន បើសិន ជាខ្លួនចង់ធ្វើដូច្នេះ។

*រឿងក្តីឧបត្ថម្ភ៖ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១២ អ.វ.ត.ក អ.ជ.ស.ជ ២៧ មេសា ២០០៩ ទំព័រ៣១ បន្ទាត់១៨-២០។*

**សេចក្ដីថ្លែងការណ៍ ស្ដីពីផលប៉ះពាល់របស់ជនរងគ្រោះអាចបង្កើតបាន ជាផ្នែកមួយនៃសេចក្ដីថ្លែងការណ៍ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រោះថា ជនជាប់ចោទត្រូវបានផ្ដល់សិទ្ធិ ដើម្បីឆ្លើយតប៖** ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិ ក្នុងការធ្វើសេចក្ដីថ្លែងការណ៍ ដែលរៀបរាប់អំពីបទនៃការឈឺចាប់ទាំងអស់របស់គេ។ ទោះបីជាយ៉ាងក៏ដោយ សេចក្ដីថ្លែងការណ៍នោះ មិនត្រូវដាក់បញ្ចូលនូវការចោទប្រកាន់ថ្មីៗ ប្រឆាំងនឹងជនជាប់ចោទឡើយ។ លើសពីនេះទៀត ជនជាប់ចោទត្រូវទទួលបានជានិច្ច នូវសិទ្ធិតទល់ទៅនឹងសេចក្ដីថ្លែងការណ៍ទាំងនេះ ជាពិសេសនៅពេលដែល សេចក្ដីថ្លែងការណ៍ទាំងនេះទាក់ទងទៅនឹងភស្តុតាងដោះបន្ទុក។ ការតទល់ទាំងនោះត្រូវតែធ្វើឡើង ដោយអវត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីជៀសវាងនូវការឈឺចាប់បន្ថែមកើតមានឡើង។

*រឿងក្ដី នួន ជា និងខៀវ សំផន៖ សេចក្ដីសម្រេចលើសំណើសុំ កោះហៅឡើងវិញដើមបណ្ដឹងរដ្ឋប្បវេណី TCCP-១៨៧ និងសុំឱ្យពិនិត្យឡើងវិញ លើបែបបទពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍ ស្ដីការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសំណើសុំពាក់ព័ន្ធ និងការឆ្លើយតប អ.ជ.ស.ដ ២ ឧសភា ២០១ ៣ កថាខណ្ឌ១៩-២២ ។*

**ភស្តុតាងដែលនាំមកនូវក្នុងការស្វែង រកការពិតគឺអាចទទួលយក៖** អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងទាំងអស់ ដែលខ្លួនចាត់ទុកថាពាក់ព័ន្ធ អាចទុកចិត្តបាន និងពិតប្រាកដ ព្រមទាំងនាំមកនូវក្នុងការស្វែងរកការពិត។ អង្គជំនុំជម្រះសាលាដំបូងអាចច្រានចោលការដាក់បញ្ចូលនៃភស្តុតាងណា ដែលរកឃើញជាន់គ្នា ភស្តុតាងដែលមិនអាចទទួលបាននៅក្នុងរយៈពេលមួយសមហេតុ ផលមួយ ឬអង្គហេតុណាដែលមិនសមស្រប សម្រាប់អង្គហេតុដែលខ្លួនមានបំណងបង្ហាញ។

*រឿងក្ដី នួន ជា និងខៀវ សំផន ៖សេចក្ដីសម្រេចលើសំណើ របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលសុំការដាក់ឯកសារថ្មី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងការឆ្លើយតបរបស់ខៀវ សំផន អ.ជ.ស.ដ ១៤ មិថុនា ២០១៣ កថាខណ្ឌ៣។ រឿងក្ដី នួន ជា៖ សេចក្ដីសម្រេចលើសំណើរបស់នួន ជា សុំឱ្យទទួលយកឯកសារថ្មី ឱ្យចាប់ផ្ដើមការស៊ើបអង្កេត និងឱ្យកោះហៅលោក Rob LEMKIN អ.ជ.ស.ដ ២៤ កក្កដា ២០១៣ កថាខណ្ឌ១០ (ភស្តុតាងដែលជាន់គ្នា ឬភស្តុតាងមិនអាចទទួលបាន នៅក្នុងរយៈពេលមួយសមហេតុផលនឹងមិនត្រូវបានទទួលយកឡើយ)។ រឿងក្ដីនួន ជា និងខៀវ សំផន៖ សេចក្ដីសម្រេច*

*លើសំណើ របស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ ចំពោះសេចក្ដីសម្រេចទាក់ទងនឹងការទទួលយក សារទូរលេខតាមផ្លូវការទូត របស់សហរដ្ឋអាមេរិករកបានថ្មី (E282/2/1) និងការឆ្លើយតបរបស់ ខៀវ សំផន (E282/2/1/1) អ.ជ.ស.ដ ១ សីហា ២០១៣ កថាខណ្ឌ ៤-៥។ រឿងក្ដី នួន ជា និងខៀវ សំផនៈ សេចក្ដីសម្រេចលើកទី៣ លើការជំទាស់នឹងឯកសារ ដែលបានស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះ សាលាដំបូង អ.ជ.ស.ដ ១២ សីហា ២០១៣ កថាខណ្ឌ ២០-២១។ រឿងក្ដីនួន ជា និងខៀវ សំផនៈ សេចក្ដីសម្រេច លើការជំទាស់ទៅនឹងការទទួលយកសេចក្ដីថ្លែងការណ៍របស់សាក្សី ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី របាយការណ៍ និងប្រតិចារឹក ក្នុងសំណុំរឿង០០១ ដែលត្រូវបានស្នើឡើង ដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាង ដើមបណ្ដឹងរដ្ឋប្បវេណី អ.ជ.ស.ដ ១៥ សីហា ២០១៣ កថាខណ្ឌ ១៧ (ប្រតិចារឹក និងសេចក្ដីថ្លែងការណ៍ ក៏អាចត្រូវបានទទួលយក កាលណាប្រតិចារឹក និងសេចក្ដីថ្លែងការណ៍ទាំងនេះពាក់ព័ន្ធនឹងបន្ទុក ក្នុងការបង្ហាញភស្តុតាងជាជាងអំពើ ឬការប្រព្រឹត្តរបស់ជនជាប់ចោទ)។*

**ក្នុងគោលបំណង ដើម្បីផ្ដន្ទាទោសជនជាប់ចោទ ការពិចារណាសមហេតុផលទាំងអស់ អាចត្រូវបានយកមកប្រើប្រាស់ ដោយផ្អែកលើភស្តុតាង តែត្រូវតែស៊ីសង្វាក់គ្នា នឹងទោសកំហុសរបស់ជនជាប់ចោទ។ លើសពីនេះទៀត ភស្តុតាងមួយចំនួនជាក់លាក់ ត្រូវបានទទួលស្គាល់ថាសម្រាប់គោលបំណង ដែលបានកំណត់ ដូចជាភស្តុតាងបញ្ជាក់ថា សេចក្ដីថ្លែងការណ៍មួយត្រូវបានទទួលយក តាមរយៈការធ្វើទារុណកម្មអាចត្រូវបានគេពឹងផ្អែកលើ សម្រាប់តែគោលបំណងដែលបានកំណត់ និងមិនមែនជាសេចក្ដីពិតនៃសេចក្ដីថ្លែងការណ៍នោះទេ។**

*រឿងក្ដី នួន ជា ខៀវ សំផនៈ សាលក្រមសំណុំរឿង ០០២/០១ អ.ជ.ស.ដ ៧ សីហា ២០១៤ កថាខណ្ឌ៣៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន ៨៧។ វិធាននេះមានលក្ខណៈស្រដៀងគ្នានឹងមាត្រា ៣២១ ដោយនៅក្នុងវិធាននោះចែងថា លើកលែងតែមានបទប្បញ្ញត្តិក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក។ ប៉ុន្តែមិនដូចមាត្រា ៣២១ ទេ វិធាន ៨៧ បញ្ជាក់ច្បាស់លាស់អំពីមូលហេតុមួយចំនួនដែលអង្គជំនុំជម្រះអាចបដិសេធក្នុងការទទួលយកភស្តុតាង ដូចជា បើសិនជាអង្គជំនុំជម្រះរកឃើញថា សម្ភារៈភស្តុតាងមិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នាមិនអាចរកបាន ក្នុងរយៈពេលសមស្របណាមួយមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងច្បាប់មិនអនុញ្ញាត ឬមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។ លើសពីនេះទៀត វិធាន ៨៧ បញ្ជាក់ច្បាស់លាស់ថាគ្រប់សេចក្តី សម្រេចរបស់អង្គជំនុំជម្រះត្រូវផ្អែកតែលើភស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះប៉ុណ្ណោះ ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការជជែកដេញដោល និងថាភស្តុតាងពីក្នុងសំណុំរឿងត្រូវបានពិចារណាថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ លុះត្រាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់អត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ។ វិធាន ៨៧ ក៏ខុសគ្នាពីមាត្រា ៣២១ ដែរ ដែលនៅក្នុងវិធាននោះ អនុញ្ញាតឲ្យអង្គជំនុំជម្រះប្រានចោលភស្តុតាងដែលច្បាប់មិនអនុញ្ញាត និងចែងថា អង្គជំនុំជម្រះអាចពិចារណាលើអង្គហេតុទាំងឡាយដែលបានស្នើសុំដោយភាគីដើម្បីបញ្ជាក់ភស្តុតាង។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជា គឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកំណត់អំពីគោល-ការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីមាត្រាមួយចំនួននៃកតិកាសញ្ញា ICCPR ដែលត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។*

**ការរំលោភបំពាន៖ ការខកខានមិនបានបង្ហាញនូវភស្តុតាង ដែលអាចមានអានុភាព លើលើការវិនិច្ឆ័យ/សាលក្រម៖** ក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ការខកខានរបស់តុលាការ ក្នុងការអនុញ្ញាតឲ្យមានការបង្ហាញ ភស្តុតាងណាមួយ ដល់ក្រុមគណៈវិនិច្ឆ័យ ដែលអាចដាក់ភស្តុតាងនោះជូនតុលាការបាន និងប្រសិនបើត្រូវបានបង្ហាញ ហើយអាចមានអានុភាពលើការវិនិច្ឆ័យ ឬសាលក្រមគឺជាការបដិសេធយុត្តិធម៌ ឬជាការរំលោភបំពាន។

*រឿងក្តី WRIGHT ទល់នឹងប្រទេសចាម៉ៃកា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ កក្កដា ១៩៩២ កថាខណ្ឌ៨.៣។*

**ភស្តុតាងជាឯកសារ ឬវេជ្ជសាស្ត្រ ស្តីពីការធ្វើទុក្ខបុកម្នេញ គឺជាលក្ខខណ្ឌតម្រូវ៖** ដើម្បីស្វែងរកឲ្យឃើញថាពិត ចំពោះការចោទប្រកាន់ អំពីការធ្វើទុក្ខបុកម្នេញ នៅពេលជាប់ឃុំឃាំង ដើមបណ្តឹងត្រូវតែបញ្ជាក់អំពីភាពស៊ីចង្វាក់ រវាងបទចោទនឹងភស្តុតាងជាឯកសារ ឬវេជ្ជសាស្ត្រ។

*រឿងក្តី WRIGHT ទល់នឹងប្រទេសចាម៉ៃកា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ កក្កដា ១៩៩២ កថាខណ្ឌ៨.៦។*

**ការរំលោភបំពាន៖ រដ្ឋដែលបង្កើតឲ្យមានឧបសគ្គផ្សេងៗ ក្នុងការប្រាស្រ័យទាក់ទងគ្នារវាងមេធាវី និងកូនក្តី៖** រដ្ឋត្រូវបានចាត់ទុកថា បានរំលោភសិទ្ធិរបស់បុគ្គល ក្នុងការប្រាស្រ័យទាក់ទង ជាមួយមេធាវីទៅតាមការជ្រើសរើសផ្ទាល់ខ្លួន បើសិនជារដ្ឋបង្កើតឲ្យមានឧបសគ្គជាសារវ័ន្ត ដែលនឹងធ្វើឲ្យខូចដល់ការប្រាស្រ័យទាក់ទងរវាងមេធាវី និងកូនក្តីយ៉ាងមានប្រសិទ្ធភាព ទោះបីជាគ្មានការហាមឃាត់ជាផ្លូវការក្នុងការប្រាស្រ័យទាក់ទងដូច្នេះក៏ដោយ។

*រឿងក្តីENGOទល់នឹងប្រទេសកាមេរូន គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប ២២ កក្កដា ២០០៩ កថាខណ្ឌ៧.៨។*

**ការរំលោភបំពាន៖ ការបដិសេធសិទ្ធិរបស់ជនជាប់ចោទ ដើម្បីបង្ហាញសាក្សីដែលពាក់ព័ន្ធ៖** ទោះបីជាសិទ្ធិក្នុងការបង្ហាញភស្តុតាង ក្នុងនាមខ្លួនមិនបង្កប់ន័យថា ជនជាប់ចោទមានសិទ្ធិ ដោយគ្មានព្រំដែនកំណត់ ក្នុងការដេញដោលសាក្សី ក្នុងនាមខ្លួនក្តីក៏ការបដិសេធសិទ្ធិរបស់ជនជាប់ចោទ ដើម្បីបង្ហាញសាក្សី និងភស្តុតាង ដែលពាក់ព័ន្ធគឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទ។

*រឿងក្តី KHUSEYNOVA និង BUTAEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប ២០ តុលា ២០០៨ កថាខណ្ឌ ៨.៥។*

**វិធានគ្រប់គ្រងភស្តុតាងផ្អែក លើច្បាប់ក្នុងស្រុកមិនអាចដកហូតសិទ្ធិបុគ្គល ក្នុងការបង្ហាញ ឬដេញដោលភស្តុតាងឡើយ៖** ទោះបីជាការទទួលខុសត្រូវជាចំបងក្នុងការបង្កើតវិធាន ស្តីពីភស្តុតាងធ្លាក់ទៅលើរដ្ឋ ដែលអាចតាក់តែងវិធាន នៃភស្តុតាងទាក់ទងនឹងសេរីភាពខ្លះៗ របស់ប្រទេសខ្លួនក៏ដោយ ក៏វិធានបែបនេះ មិនអាចដកហូតសិទ្ធិ របស់បុគ្គលក្នុងការបង្ហាញភស្តុតាង ក្នុងនាមផ្ទាល់ខ្លួន ឬដេញដោលភស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ។

*រឿងក្តី IDIEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣១ មីនា ២០០៩ កថាខណ្ឌ៩.៦។*

**រដ្ឋមិនអាចបង្ខិតបង្ខំបុគ្គលណាម្នាក់ ដើម្បីទទួលបានចម្លើយសារភាពទេ៖** សិទ្ធិរួចផុតពីការបង្ខំឲ្យផ្តល់ភស្តុតាងប្រឆាំងនឹងខ្លួនឯង មានន័យថា អាជ្ញាធរមិនអាចដាក់បុគ្គលណាម្នាក់ ក្នុងលក្ខណៈបង្ខិតបង្ខំតាមផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវអារម្មណ៍ ដើម្បីបានទទួលនូវចម្លើយសារភាពពីបុគ្គលនោះឡើយ។

*រឿងក្តី SHARIFOVA SAFAROV និង BURKHONOV ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១ មេសា ២០០៨ កថាខណ្ឌ៦.៣ ដែលបានយកមកអនុវត្តក្នុងរឿងក្តី KHUSEYNOVA និង BUTAEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ តុលា ២០០៨ កថាខណ្ឌ ៨.៣ និងរឿងក្តី BUTOVENKO ទល់នឹងប្រទេសអ៊ុយក្រែន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស .ប ១៩កក្កដា ២០១១ កថាខណ្ឌ៧.៤។*

**ទារុណកម្មមិនអាចត្រូវបានគេ ប្រើប្រាស់បានឡើយសម្រាប់កិច្ចស៊ើបសួរ៖** សិទ្ធិរួចផុតពីការបង្ខំឲ្យឆ្លើយសារភាពអំពីពិរុទ្ធភាព ហាមឃាត់ការប្រើទារុណកម្មក្នុងដំណាក់កាល នៃកិច្ចស៊ើបសួរនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ លើសពីនេះ រដ្ឋមានកាតព្វកិច្ចបើកការស៊ើបសួរ ដោយគ្មានលម្អៀងទៅលើពាក្យបណ្តឹងណាមួយ និងទាំងអស់អំពីការធ្វើទារុណកម្ម និងទម្រង់ផ្សេងទៀតនៃការប្រព្រឹត្តមិនត្រឹមត្រូវ។

> *រឿងក្តីSHARIFOVA, SAFAROV និង BURKHONOV ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១ មេសា ២០០៨ កថាខណ្ឌ៦.៣ ដែលបានយកមកអនុវត្តក្នុងរឿងក្តី ISAEVA ទល់នឹងប្រទេសអ៊ុយប៊ែគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ មីនា ២០០៩ កថាខណ្ឌ៩.២។ រឿងក្តី DUNAEV ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣០ មីនា ២០០៩ កថាខណ្ឌ៧.៣។ រឿងក្តី SATTOROVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣០ មីនា ២០០៩ កថាខណ្ឌ៨.២។ រឿងក្តី IDIEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣១ មីនា ២០០៩ កថាខណ្ឌ៩.៣។ រឿងក្តី TOLIPKHUZHAEV ទល់នឹងប្រទេសអ៊ុយប៊ែគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២២កក្កដា ២០០៩ កថាខណ្ឌ៨.៣។ រឿងក្តី KIRPO ទល់នឹងប្រទេស តាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ តុលា ២០០៩ កថាខណ្ឌ៦.២-៦.៣។ រឿងក្តី PUSTOVALOV ទល់នឹងសហព័ន្ធរុស្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ មីនា ២០១០ កថាខណ្ឌ ៨.២ និងរឿងក្តី USAEV ទល់នឹងសហព័ន្ធរុស្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៩ កក្កដា ២០១០ កថាខណ្ឌ៩.២-៩.៣។*

**ការផ្តល់ភស្តុតាងគឺជាបន្ទុក របស់រដ្ឋដើម្បីបង្ហាញថាកំណត់ហេតុត្រូវបានធ្វើឡើងដោយសេរី និងដោយស្ម័គ្រចិត្ត៖** បើសិនជាបុគ្គលណាម្នាក់ បានធ្វើការចោទប្រកាន់ ដោយមានសំអាងហេតុថា គាត់ត្រូវបានបង្ខំឲ្យផ្តល់ភស្តុតាង ប្រឆាំងនឹងខ្លួនឯង បន្ទុកនេះត្រូវធ្លាក់ទៅលើរដ្ឋ ដើម្បីបញ្ជាក់ថា កំណត់ហេតុទាំងឡាយ ត្រូវបានធ្វើឡើងដោយសេរី និងដោយស្ម័គ្រចិត្តដោយហេតុថា បុគ្គលនឹងមិនមានលទ្ធភាពដូចគ្នា ក្នុងការចូលពិនិត្យស្វែងរកភស្តុតាងចាំបាច់ ហើយរដ្ឋជាញឹកញាប់ គឺជាភាគីតែមួយគត់ ដែលមានលទ្ធភាពទទួលបានព័ត៌មាន ដែលពាក់ព័ន្ធ។

> *រឿងក្តី SHARIFOVA, SAFAROV និង BURKHONOV ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១ មេសា ២០០៨ កថាខណ្ឌ៦.៣ ដែលបានយកមកអនុវត្តនៅក្នុងរឿងក្តី IDIEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣១ មីនា ២០០៩ កថាខណ្ឌ៩.៣ (រដ្ឋត្រូវបញ្ជាក់ថា កំណត់ហេតុនានា ត្រូវបានធ្វើឡើងដោយសេរី និងស្ម័គ្រចិត្ត)។ រឿងក្តី DUNAEV ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣០ មីនា ២០០៩ កថាខណ្ឌ ៧.៣ ដែលបានយកមកអនុវត្តនៅក្នុងរឿងក្តីទល់នឹងប្រទេសអ៊ុយក្រែន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៩ កក្កដា ២០១១ កថាខណ្ឌ៧.៣ (រដ្ឋមានបន្ទុក នៃការផ្តល់ភស្តុតាង*

*ដោយសារលទ្ធភាព ទទួលបានព័ត៌មានមិនស្មើគ្នា)។*

**រដ្ឋត្រូវតែបញ្ជាក់អះអាងថា គ្មានអំពើទារុណកម្ម និងកំណត់ហេតុត្រូវតែបានធ្វើឡើង ដោយស្ម័គ្រចិត្តៈ** រដ្ឋទាំងឡាយត្រូវតែមាន លទ្ធភាពផលិតឯកសារស៊ីសង្វាក់គ្នាដើម្បីបង្ហាញឲ្យឃើញថា ជនជាប់ចោទមិនត្រូវបានគេធ្វើទារុណកម្មឡើយ និងបង្ហាញថា កំណត់ហេតុទាំងឡាយ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត។

*រឿងក្តី IDIEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣០ មីនា ២០០៩ កថាខណ្ឌ៩.៣ ដែលបានយកមកអនុវត្តក្នុងរឿងក្តី BUTOVENKO ទល់នឹងប្រទេសអ៊ុយក្រែន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៩ កក្កដា ២០១១ កថាខណ្ឌ៧.៤។*

**ឧបាស្រ័យសមស្រប សម្រាប់ចម្លើយសារភាពដែលទទួលបានតាមរយៈអំពើទារុណកម្មៈ** បើសិន បុគ្គលត្រូវបានកាត់ឲ្យជាប់ទោស ដោយផ្អែកតែលើចម្លើយសារភាពដែលទទួលបាន តាមរយៈអំពើទារុណកម្ម ឬទម្រង់ណាមួយ នៃការបង្ខិតបង្ខំការជំនុំជម្រះក្តីឡើងវិញ ស្របតាមការធានា ដែលមានចែងនៅក្នុងកតិកាសញ្ញា ICCPR គឺជាឧបាស្រ័យសមស្របមួយដូចគ្នានឹងការដោះលែងដែរ។

*រឿងក្តី DUNAEV ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣០ មីនា ២០០៩ កថាខណ្ឌ៧.៣៩។*

**មាត្រាស្រដៀងគ្នានៅក្នុង*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*ៈ** មាត្រា១៤(១) ១៤(៣)(ង) ១៤(៣)(ឆ) និង៧។ មាត្រា១៤(១) ចែងអំពីសិទ្ធិក្នុងការទទួលបានសវនាការ ដោយយុត្តិធម៌ និងជាសាធារណៈ ។ មាត្រា១៤ (៣) (ឃ) ធានាចំពោះសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់គាត់ និងការពារខ្លួនគាត់ ដោយខ្លួនឯង ឬតាមរយៈជំនួយផ្នែកច្បាប់។ មាត្រា១៤(៣)(ង) ការពារសិទ្ធិរបស់ជនជាប់ចោទ ដើម្បីដេញដោល ឬឲ្យគេដេញដោលសាក្សីប្រឆាំងនឹងគាត់តាមលក្ខខណ្ឌដូចគ្នានឹងសាក្សី ដែលប្រឆាំងនឹងគាត់ដែរ ហើយ មាត្រា១៤ (៣) (ឆ) ការពារសិទ្ធិរបស់ជនជាប់ចោទពីការបង្ខិតបង្ខំផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬឆ្លើយសារភាពពីទោសកំហុស រីឯមាត្រា ៧ ហាមប្រាមអំពើទារុណកម្ម ឬប្រព្រឹត្តិកម្មឃោរឃៅ អមនុស្សធម៌ ឬដែលបន្ទាបបន្ថោក ឬការដាក់ទោសទណ្ឌ។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**កំណត់ហេតុសួរចម្លើយជនជាប់ចោទ ដែលទទួលបានក្នុងពេលឃុំឃាំង តាមរយៈប្រព្រឹត្តកម្មមិនត្រឹមត្រូវ៖** កំណត់ហេតុដូច្នេះ មិនត្រូវប្រើប្រាស់ជាភស្តុតាងសំខាន់នៅក្នុងសវនាការឡើយ។

*រឿងក្តី ÖZEN ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១២ មេសា ២០០៧ កថាខណ្ឌ១០២-១០៥។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៦(១) និងមាត្រា ៦ (៣) (ឃ) ។ មាត្រា ៦ (១) ចែងអំពីសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ រីឯមាត្រា ៦ (៣) (ឃ) ធានាសិទ្ធិរបស់ជនជាប់ចោទក្នុងកោះហៅសាក្សីដោះបន្ទុកមកសួរដេញដោល ក្នុងល័ក្ខខណ្ឌដូចគ្នាក៏ត្រូវគេកោះហៅសាក្សីដាក់បន្ទុកមកផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនផងដែរ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានមូលដ្ឋាន មកពីក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍អំពីរបៀបដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំងគឺតុលាការកំពូល។*

**ចៅក្រមអាចពឹងផ្អែក លើឯកសារនីតិវិធីព្រហ្មទណ្ឌផ្សេងទៀតសម្រាប់សេចក្តីសម្រេចរបស់ខ្លួន៖** ប្រសិនបើឯកសារទាំងនោះត្រូវបានដាក់ ដើម្បីពិភាក្សាតទល់គ្នារវាងភាគីនានា។

*លេខ 73-90224 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៤៨០ តុលាការកំពូលបារាំង ១៩ ធ្នូ ១៩៧៣។*

**ឧទាហរណ៍ នៃភស្តុតាងដែលអាចទទួលយកបាន៖** ជារួមមានខ្សែអាត់ ភស្តុតាងដែលទទួលបានដោយខុសច្បាប់ ឬក៏ដោយភាពមិនស្មោះត្រង់ ចម្លើយសារភាព ការឆ្លើយឆ្លងរវាងមេធាវី និងកូនក្តីរបស់ខ្លួន ដែលទំនងជាបញ្ជាក់ពីការចូលរួម របស់មេធាវីនៅក្នុងបទល្មើស។

*JCP 1961. II. 12157 តុលាការកំពូលបារាំង ១៦ មីនា ១៩៦១ (ខ្សែអាត់សម្លេង/វីឌីអូ)។ លេខ 91-86067 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៦៦ តុលាការកំពូលបារាំង ១១ កុម្ភៈ ១៩៩២ (ភស្តុតាងបាន ដោយអំពើខុសច្បាប់ ឬមិនស្មោះត្រង់)។ លេខ97-83196 តុលាការកំពូលបារាំង ២៨ មករា ១៩៩៨ (ចម្លើយសារភាព) ។ លេខ91-86843 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១១២ តុលាការកំពូលបារាំង ១២ មីនា ១៩៩២ (ការឆ្លើយឆ្លងរបស់មេធាវី)។*

**ករណីដែលមេធាវី មិនអាចលើកអំណះអំណាងអំពីការសម្ងាត់ពាក់ព័ន្ធនឹងសំណុំឯកសារ៖** បើសិនជាឯកសារទាំងនោះ អាចនាំឲ្យមានការដាក់បន្ទុកលើខ្លួនឯង។

*លេខ 98-80007 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២០៦ តុលាការកំពូលបារាំង ៥ តុលា ១៩៩៩។*

**ការពិនិត្យភស្តុតាងដោយសាលាឧទ្ធរណ៍៖**អាចពិនិត្យភស្តុតាង ដែលបានដេញដោល និងមិនបានយកចិត្តទុកដាក់ ដោយយុត្តាធិការសាលាដំបូង។

*លេខ97-84260 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២០ តុលាការកំពូលបារាំង ១៦ កុម្ភៈ ១៩៩៩។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** មាត្រា ៤២៧ ៤២៨ និង ៤៣២។ មាត្រាទាំងនេះទាក់ទងនឹងការបង្ហាញភស្តុតាងនៅពេលសវនាការ រួមទាំងការវាយតម្លៃនៃប្រភេទភស្តុតាងនីមួយៗក្នុងអំឡុងពេលសវនាការ។

# មាត្រា ៣២២៖ វិធានទាក់ទងនឹងភាគីដែលមានវត្តមាននៅក្នុងសវនាការ

*ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ។*

*កាលណាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយសហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់ ក្រឡាបញ្ជីពិនិត្យមើលអត្តសញ្ញាណនៃអ្នកតំណាង និងសុពលភាពនៃការប្រគល់សិទ្ធិ។ ចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏ត្រូវធ្វើដូច្នេះដែរ។ ក្រឡាបញ្ជីត្រូវសុំយោបល់ប្រធានសវនាការ ក្នុងករណីចាំបាច់។*

*ភាគីនីមួយៗអង្គុយនៅតាមកន្លែងដែលទុកឱ្យខ្លួននៅក្នុងបន្ទប់សវនាការ។*

*ជនជាប់ចោទមិនត្រូវទាក់ទងនឹងគ្នាទេ។*

*អ្នកជំនាញ និងសាក្សីថយខ្លួនទៅក្នុងបន្ទប់រង់ចាំដែលទុកបម្រុងឱ្យខ្លួន ហើយដែលពីក្នុងបន្ទប់រង់ចាំនោះ ខ្លួនមិនអាចមើលឃើញ ឬឮអ្វីដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់សវនាការទេ។*

*នៅក្នុងពេលសវនាការ និងនៅក្នុងបន្ទប់រង់ចាំសាក្សី មិនត្រូវទាក់ទងនឹងគ្នាទេ។*

## *ការអនុវត្តនៅអ.វ.ត.ក*

**សាក្សីមិនអាចអង្គុយ នៅក្នុងបន្ទប់សវនាការ ឬបន្ទប់ សម្រាប់សាធារណជនបានទេ៖** ជនដែលមានឈ្មោះ ក្នុងបញ្ជីឈ្មោះសាក្សី មិនអនុញ្ញាតឱ្យអង្គុយក្នុងបន្ទប់ សម្រាប់សាធារណជនដើម្បីតាមដានមើលនូវ កិច្ចដំណើរការនីតិវិធីនោះទេ ព្រោះថា ទង្វើបែបនេះផ្ទុយទៅនឹងវិធានផ្ទៃក្នុងស្តីពីសាក្សី។ សាក្សីក្នុងបន្ទប់សវនាការ ឬបន្ទប់សម្រាប់សាធារណជន មានកាតព្វកិច្ចត្រូវតែចាកចេញមុនពេលដែលជនទាំងនោះ ត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៥ អ.វ.ត.ក អ.ជ.ស.ដ ៧ មេសា ២០០៩ ទំព័រ១ បន្ទាត់ទី២៤ ដល់ទំព័រ២ បន្ទាត់ទី៩។*

**ជនជាប់ចោទមានសិទ្ធិ ក្នុងការបោះបង់នូវសិទ្ធិរបស់ខ្លួន ក្នុងការបង្ហាញវត្តមាន នៅពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី៖** ជនជាប់ចោទមិនអាចត្រូវបានបង្ខំអោយស្ថិត នៅតែក្នុងតុលាការទេ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានេះគឺអាស្រ័យ លើមេធាវីការពារ របស់គាត់ក្នុងការផ្តល់ដំបូន្មាន ដល់គាត់ទាក់ទងនឹងផលវិបាក

នានា រួមទាំងបញ្ហាថា គាត់មិនអាចនឹងតទល់បានប្រកបដោយប្រសិទ្ធភាព ទៅនឹងភស្តុតាងប្រឆាំងនឹងគាត់ឡើយ។

*រឿងក្តីអៀង សារី៖ ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះ"ការកត់សំគាល់របស់ អៀង សារី" ១៤ តុលា ២០១១ (E130) អ.វ.ត.ក អ.ជ.ស.ជ ២៨ តុលា ២០១១ កថាខណ្ឌ២-៣។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៨៨។ វិធាននេះតម្រូវឱ្យភាគីនានាត្រូវបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ទោះជាយ៉ាងណាក្តី វិធាន៨៨(២) ចែងជាក់លាក់ថា សាក្សី និងអ្នកជំនាញត្រូវស្ថិតក្នុងបន្ទប់ដាច់ដោយឡែកមួយ ដែលជនទាំងនេះមិនត្រូវបានអនុញ្ញាតឱ្យមើលឃើញ ឬស្តាប់ឮកិច្ចដំណើរការនីតិវិធីឡើយ ហើយជនទាំងនេះក៏មិនត្រូវបានអនុញ្ញាតឱ្យប្រាស្រ័យទាក់ទងគ្នាដែរ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍ អំពីរបៀបដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំងគឺតុលាការកំពូល។*

**អវត្តមានជនជាប់ចោទ៖** អវត្តមានរបស់ជននេះមិនបង្កឲ្យមានមោឃភាពនោះទេ។

*លេខ 68-93194 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៥២ តុលាការកំពូលបារាំង ៦ ឧសភា ១៩៦៩។*

**សាក្សីដែលត្រូវផ្តល់ចម្លើយពីរដង៖** សាក្សីប្រភេទនេះអាចមានវត្តមានក្នុងបន្ទប់សវនាការ ក្រោយពីបានផ្តល់ចម្លើយលើកទីមួយរួច។

*លេខ 77-91896 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៣៩៧ តុលាការកំពូលបារាំង ១៤ ធ្នូ ១៩៧៧។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** មាត្រា៣៣១-១ មាត្រា៣៣១-២ មាត្រា៣៣៤ និង មាត្រា៤០៦។ មាត្រាទាំងនេះបង្កើតបានជាវិធានស្តីពីវត្តមានរបស់ភាគីនៅក្នុងពេលជំនុំជម្រះនៅចំពោះមុខតុលាការបទឧក្រិដ្ឋ (មាត្រា ៣៣១ និងមាត្រា ៣៣៤) និងតុលាការបទមជ្ឈិម (មាត្រា៤០៦)។

# មាត្រា ៣២៥៖ ការសួរចម្លើយជនជាប់ចោទ

*ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពីអំពើ ដែលគេចោទប្រកាន់លើខ្លួន និងធ្វើការសួរចម្លើយជនជាប់ចោទនោះ។ ប្រធានសវនាការសួរគ្រប់សំណួរ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស្វែងរកឱ្យឃើញការពិត។ ប្រធានសវនាការមានករណីយកិច្ចសួរចម្លើយជនជាប់ចោទនោះទាំងខាងផ្នែកដាក់បន្ទុក និងទាំងខាងផ្នែកដោះបន្ទុក។*

*ក្រោយពីប្រធានសវនាការសួរចម្លើយរួច ហើយព្រះរាជអាជ្ញា មេធាវី និងភាគីអាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរដល់ជនជាប់ចោទ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗទៀត ត្រូវសួរតាមរយៈប្រធានសវនាការ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេច ដោយឥស្សរចិត្តថាតើសំណួរនេះត្រូវតែសួរឬទេ។*

## *ការអនុវត្តនៅអ.វ.ត.ក*

**សិទ្ធិក្នុងការតាំងសំណួរ៖** ចៅក្រមនៃអង្គជំនុំជម្រះមានកាតព្វកិច្ចសួរ ជនជាប់ចោទនូវរាល់សំណួរដែលទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធី ដោយពុំគិតថា តើសំណួរទាំងនោះទំនងជាដើម្បីបង្ហាញឬច្រាលចោលពិរុទ្ធភាព របស់ជនជាប់ចោទនោះឡើយ។

*រឿងក្តីឧុចៈ សាលក្រមអ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ៩១។*

**លំដាប់លំដោយ នៃការបង្ហាញពីអង្គហេតុ ការផ្តល់សក្ខីកម្ម និងការតាំងសំណួរ៖** ការជំនុំជម្រះត្រូវធ្វើតាមលំដាប់លំដោយនៃអង្គហេតុ ដែលបានកំណត់ ក្នុងដីកាដំណោះស្រាយ។ ភាគីនានានឹងត្រូវបានជូនដំណឹង អំពីកាលបរិច្ឆេទកំណត់ថ្ងៃ ជំនុំជម្រះប្រហែលជារយៈពីរសប្តាហ៍ជាមុន។ ទោះបីជាអង្គហេតុណា ក៏ដោយអង្គជំនុំជម្រះនឹងស្តាប់ចម្លើយ ជនជាប់ចោទមុនគេបង្អស់ បន្ទាប់មកនឹងផ្តល់វេទិកា ជូនដល់ភាគីនានា ដើម្បីចោទសួរជនជាប់ចោទ។ ក្រោយមកទៀត អង្គជំនុំជម្រះនឹងធ្វើការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញដែលមានជាប់ទាក់ទងនឹងអង្គហេតុ ដ៏ជាក់លាក់មកផ្តល់ចម្លើយ។

*រឿងក្តីឧុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី២ អ.វ.ត.ក អ.ជ.ស.ជ ៦ មេសា ២០០៩ ទំព័រ២ បន្ទាត់ទី៩-១៧។*

**ការសួរដេញដោលតទល់គ្នាទៅនឹងចម្លើយ ជាលាយលក្ខណ៍អក្សររបស់សាក្សី៖** ជនជាប់ចោទ

គួរត្រូវបានសួរដេញដោល តទល់ទៅនឹងចម្លើយ ជាលាយលក្ខណ៍អក្សររបស់សាក្សី ក្រោយពេល សាក្សីបានផ្តល់នូវចម្លើយ លើកលែងតែសាក្សីទាំងនេះ អាចត្រូវបានបញ្ជូនមកតុលាការ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៤ អ.វ.ត.ក អ.ជ.ស.ជ ៦ មេសា ២០០៩ ទំព័រ២ បន្ទាត់ទី១៩-២១។*

**ភាគីនានាត្រូវបានណែនាំ មិនឱ្យសួរសំណួរនូវច្រំដែលៈ** សំណួរដែលបានចោទសួរ ទៅជនជាប់ចោទរួចហើយ មិនត្រូវសួរច្រំដែលឡើងវិញនោះទេ លុះត្រាតែមានការចាំបាច់ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ នូវចម្លើយតបរបស់ជនចាប់ចោទ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៦ អ.វ.ត.ក អ.ជ.ស.ជ ៨ មេសា ២០០៩ ពីទំព័រ២១ បន្ទាត់២៤ ដល់ទំព័រ២២ បន្ទាត់២។*

**មិនអាចកម្រិតឲ្យផ្តល់ចម្លើយ ត្រឹមតែមែន/មិនមែនទេៈ** មេធាវីការពារក្តីមិនត្រូវតម្រង់ចម្លើយ បង្ខំជនចាប់ចោទឲ្យឆ្លើយត្រឹមតែចម្លើយ "មែន" ឬ "មិនមែន" នោះទេ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៦ អ.វ.ត.ក អ.ជ.ស.ជ ៨ មេសា ២០០៩ ពីទំព័រ២ បន្ទាត់២៩ ដល់ទំព័រ៣ បន្ទាត់៤។*

**សំណួរត្រូវតែជាសំណួរ ដែលគេមិនទាន់បានសួរ និងសំណួរជាក់លាក់ៈ** សំណួរមុនៗដែលត្រូវបានសួរដោយអង្គជំនុំជម្រះ និងភាគីដែលពាក់ព័ន្ធនានារួចហើយ មិនគួរសួរឡើងវិញនោះទេ លុះត្រាតែ សំណួរច្រំដែលទាំងនោះ មានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ដើម្បីទាញយកនូវចម្លើយជាក់លាក់បន្ថែមទៀត។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៦ អ.វ.ត.ក អ.ជ.ស.ជ ៨ មេសា ២០០៩ ទំព័រ១៦ បន្ទាត់១២-១៥។*

**ជនជាប់ចោទមិនចាំបាច់ ឆ្លើយតបទៅនឹងសំណួរមិនពាក់ព័ន្ធឡើយៈ** ជនជាប់ចោទអាចរក្សាសិទ្ធិក្នុងការមិនឆ្លើយតបនឹងសំណួរមិនពាក់ព័ន្ធ ឬសំណួរទាំងឡាយណា ដែលពាក់ព័ន្ធនឹងភស្តុតាង ដែលមិនត្រូវបានទទួលស្គាល់។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី២២ អ.វ.ត.ក អ.ជ.ស.ជ ២៧ ឧសភា ២០០៩ ទំព័រ៥១បន្ទាត់២-៤។*

**អនុញ្ញាតឱ្យសួរសំណួរបិទៈ** បើទោះជាសំណួរបិទដូចជា "តើវាពិតទេដែលនិយាយថា" "តើវាត្រឹមត្រូវទេ ដែលនិយាយថា" "តើអ្នកយល់ស្របជាមួយខ្ញុំទេដែលថា" គឺជាសំណួរដែលមិនសូវប្រើប្រាស់ក្នុងប្រព័ន្ធច្បាប់ខំមិនឡក្តី ក៏អង្គជំនុំជម្រះ អនុញ្ញាតឱ្យសួរសំណួរទាំងនោះដែរ ដោយសារតែនៅពេលសួរសំណួរវែង នៅពេលនោះចម្លើយក៏វែងដូចគ្នា។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១៣ អ.វ.ត.ក អ.ជ.ស.ជ ២៨ មេសា ២០០៩ ទំព័រ៥៧បន្ទាត់១៨ ដល់ទំព័រ៥៨ បន្ទាត់១៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៨៩ស្ទួន និងវិធាន៩០។ វិធាន៨៩ស្ទួនគឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា៣២៥ លើកលែងចំណុចដែលវិធាននេះដាក់បន្ទុកដល់ក្រឡាបញ្ជីជំនួសប្រធានសវនាការក្នុងការអានបទចោទប្រឆាំងនឹងជនជាប់ចោទ ហើយវិធាននេះ ក៏អនុញ្ញាតឱ្យព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ ដែលអាចឱ្យមេធាវីឆ្លើយតបមុនពេលជនជាប់ចោទត្រូវបានចោទសួរ។ វិធាន៩០នៃវិធានផ្ទៃក្នុងគឺដូចគ្នាខ្លាំងទៅនឹងមាត្រា៣២៥ លើកលែងតែចំណុចមួយដែលចែងយ៉ាងច្បាស់ថា ប្រធានសវនាការត្រូវប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់ជននេះមុនពេលសួរចម្លើយ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ការពឹងផ្អែកលើវិមតិសង្ស័យ អំពីពិរុទ្ធភាពរបស់បុគ្គល គឺមានវិសមិតភាព ជាមួយនឹងសច្ចធារណ៍និរទោស** ៖ បើតុលាការពឹងផ្អែកលើចម្លើយ ដែលទាក់ទងទៅនឹងវិមតិសង្ស័យ នៃពិរុទ្ធភាពរបស់បុគ្គល ដើម្បីធ្វើការវាយតម្លៃអំពីពិរុទ្ធភាព ក្នុងករណីក្រោយៗទៀតនោះ សិទ្ធិសច្ចធារណ៍និរទោស ត្រូវបានគេរំលោភបំពាន ទោះបីក្រោយការសម្រេចឱ្យរួចខ្លួនស្ថាពរក៏ដោយ។

> *រឿងក្តី SEKANINA ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៥ សីហា ១៩៩៣ កថាខណ្ឌ ៣០។*

**មន្ត្រីសាធារណៈ ត្រូវគោរពសច្ចធារណ៍និរទោស៖** មន្ត្រីទាំងនេះមិនត្រូវធ្វើសេចក្តីប្រកាស ដែលជំរុញឱ្យសាធារណជនជឿថា ជនណាម្នាក់មានពិរុទ្ធភាពមុនពេលពិរុទ្ធភាពរបស់ជនជាប់ចោទ ត្រូវបានញគេរកឃើញឲ្យបានត្រឹមត្រូវ ដោយតុលាការឡើយ ជាពិសេស គឺនៅពេលដែលជននោះមិនទាន់ត្រូវបានចោទពីបទល្មើសណាមួយ។

> *រឿងក្តី BUTKEVICIUS ទល់នឹងប្រទេសលីទុយនីយ៉ា តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មីនា ២០០៣ កថាខណ្ឌ៥៣ (សច្ចធារណ៍និរទោសដោយមន្ត្រីសាធារណៈ) និងរឿងក្តី ALLENT DE RIBEMONT ទល់ទៅនឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១០ កុម្ភៈ ១៩៩៥ កថាខណ្ឌ៤១ (ការប្រកាសពិរុទ្ធភាព ដោយនគរបាលមុនត្រូវបានចោទ ពីបទល្មើសព្រហ្មទណ្ឌ) និងរឿងក្តី LAVENTS ទល់នឹងប្រទេសឡាតវីយ៉ា តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៨ វិច្ឆិកា ២០០២ កថាខណ្ឌ ១២៥ (ពិរុទ្ធភាពត្រូវតែរកឃើញឲ្យបានត្រឹមត្រូវដោយតុលាការ)។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មាត្រា៦(២)។ មាត្រានេះផ្តល់នូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងសិទ្ធិសម្រាប់ជន ដែលត្រូវបានចោទពីបទព្រហ្មទណ្ឌ ដែលនឹងត្រូវបានសន្មតថាគ្មានទោស រហូតដល់ពេលរកឃើញពិរុទ្ធភាពអនុលោមតាមច្បាប់។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍អំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ការប្រកាសពិរុទ្ធភាព របស់ជនជាប់ចោទមុនដំណាក់កាលនីតិវិធី៖** ប្រធានសវនាការមិនត្រូវប្រកាសអំពីអ្វីដែលទាក់ទងទៅនឹងករណីដែលថា ជនជាប់ចោទមានពិរុទ្ធភាពមុនពេលជននោះ ត្រូវបានគេវិនិច្ឆ័យនោះទេ។

*ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ២៧៦ តុលាការកំពូលបារាំង ១៤ មិថុនា ១៩៥៨។*

**ការអានសាលក្រម ផ្តន្ទាទោសមុនៗ/សាលក្រមផ្តន្ទាទោសផ្សេងទៀត៖** ការអានសាលក្រមផ្តន្ទាទោសរបស់សហចារីនៃជនជាប់ចោទ ឬសាលក្រមផ្តន្ទាទោសមុនៗរបស់ជនជាប់ចោទ មិនត្រូវបានហាមឃាត់នោះទេ។

*លេខ 91-82115 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៤៤២ តុលាការកំពូលបារាំង ២០ វិច្ឆិកា ១៩៩១ (សហចារី) និងលេខ91-85775 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ២០៩ តុលាការកំពូលបារាំង ២៥ ឧសភា ១៩៩២ (សាលក្រមផ្តន្ទាទោសមុនៗលើជនជាប់ចោទ)។*

**ការមិនសួរសំណួរជនជាប់ចោទ គឺជាមូលហេតុបង្កឱ្យមានមោឃភាព៖** លើកលែងតែរកឃើញថា ជនជាប់ចោទមិនអាចការពារខ្លួនឯងបាន នៅក្នុងមធ្យោបាយណាមួយ ក្រោយពេលសួរដេញដោល ដោយយោងតាមរបាយការណ៍។

*លេខ 67-91505 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២០៨ តុលាការកំពូលបារាំង ២៦ មិថុនា ១៩៦៨។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** មាត្រា ៣២៧ មាត្រា ៣២៨ និងមាត្រា ៤៤២។ មាត្រាទាំងនេះអនុញ្ញាតឱ្យមានការសួរចម្លើយជនជាប់ចោទ ក្នុងកំឡុងពេលជំនុំជម្រះ រួមទាំងផ្តល់លទ្ធភាពឲ្យភាគីនីមួយៗសួរសំណួរជនជាប់ចោទតាមរយៈប្រធានផងដែរ (មាត្រា៤៤២)។

# មាត្រា ៣២៦៖ ការស្តាប់ចម្លើយរបស់ភាគី

*ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រធានសវនាការ អាចស្តាប់នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី។*

*ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងទៀតត្រូវសួរតាមរយៈប្រធានសវនាការ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្ត ថាតើសំណួរនេះត្រូវតែសួរឬទេ។*

## ការអនុវត្តនៅអ.វ.ត.ក

**អង្គជំនុំជម្រះ សាលាដំបូងត្រូវព្យាយាមឲ្យអស់ពីលទ្ធភាព ដើម្បីកោះហៅសាក្សីនីមួយៗតែម្តងគត់ ប៉ុន្តែ ក៏អាចសម្រេចស្តាប់នូវចម្លើយសាក្សីម្តងទៀតបាន ប្រសិនបើ មានភាពពាក់ព័ន្ធទៅនឹងអង្គហេតុលើសពីមួយ៖** ចំពោះសាក្សី ដែលទាក់ទងទៅនឹងអង្គហេតុលើសពីមួយ អង្គជំនុំជម្រះនឹងសម្រេច ទៅតាមករណីនីមួយៗដោយផ្អែកលើមូលដ្ឋាន ថាតើសាក្សីទាំងនោះត្រូវផ្តល់ចម្លើយតែម្តងគត់ លើគ្រប់អង្គហេតុ ឬត្រូវកោះហៅឱ្យមកផ្តល់ចម្លើយម្តងទៀត នៅពេលក្រោយ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី២ អ.វ.ត.ក អ.ជ.ស.ជ ៦ មេសា ២០០៩ ទំព័រ២ បន្ទាត់២២ ដល់ទំព័រ៣ បន្ទាត់៥។*

**ការកំណត់កាលបរិច្ឆេទ ក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនៅពេលជំនុំជម្រះ៖** អង្គជំនុំជម្រះនឹងស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណា ដែលបានដឹងឮ អំពីអង្គហេតុជាក់លាក់ក្នុងពេល ដែលអង្គជំនុំជម្រះ ស្តាប់អង្គហេតុទាំងនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ផ្សេងទៀត នឹងត្រូវបានស្តាប់ចម្លើយក្នុងពេលតែមួយ ជាមួយគ្នារហូតទាល់តែចប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី២ អ.វ.ត.ក អ.ជ.ស.ជ ៦ មេសា ២០០៩ ទំព័រ៣ បន្ទាត់១១-១៧។*

**អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទ ស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីសាក្សី និងអ្នកជំនាញឲ្យបានពីរសប្តាហ៍មុនថ្ងៃសវនាការ លើកលែងតែជនទាំងនោះរស់ នៅក្រៅប្រទេស៖** ប្រសិនបើដើម

បណ្ដឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញរស់នៅក្រៅប្រទេស អង្គជំនុំជម្រះនឹងព្យាយាមឲ្យអស់ពីលទ្ធភាព ដើម្បីកំណត់នូវកាលបរិច្ឆេទយ៉ាងហោចណាស់ឱ្យបានបួនសប្តាហ៍ មុនថ្ងៃសវនាការ។ វាមានប្រយោជន៍ ក្នុងការកំណត់អំពីកាលបរិច្ឆេទស្តាប់ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ដែលរស់នៅក្រៅប្រទេស ប្រសិនបើអង្គជំនុំជម្រះ សាលាដំបូងទទួលបានដំណឹងយ៉ាងឆាប់ តាមដែលអាចធ្វើទៅបានពីកាលបរិច្ឆេទដែលជនទាំងនោះទំនេរ ឬក៏អត់។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៤ អ.វ.ត.ក អ.ជ.ស.ដ ៦ មេសា ២០០៩ ទំព័រ៣បន្ទាត់១៩ ដល់ទំព័រ៤បន្ទាត់១។*

**ដើម្បីធានាថា នីតិវិធីបានប្រព្រឹត្តទៅដោយត្រឹមត្រូវ ភាគីនានាមិនត្រូវចោទ នូវសំណួរច្រំដែលៗ ឬសំណួរដែលមិនពាក់ព័ន្ធ ទៅជនជាប់ចោទ សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីឡើយ៖** ប្រសិនបើ អ្នកតំណាងភាគីផ្លាស់ប្តូរវេនគ្នាសួរសំណួរទៅជនណាម្នាក់ ពួកគេត្រូវស្តាប់ព័ត៌មាន ពីអ្នកតំណាងភាគីមុនៗ ដើម្បីជៀសវាងការសួរសំណួរ ច្រំដែលឡើងវិញ។ សំណួរ ដែលមិនពាក់ព័ន្ធទៅនឹងអង្គហេតុ មិនត្រូវចោទសួរនោះទេ។ ចុងក្រោយ ភាគីត្រូវតែត្រៀមសំណួរជាមុន ដើម្បីចំណេញពេលវេលា (ឧទាហរណ៍ មិនត្រូវនិយាយ ដោយប្រើរយៈពេលពី៥ ទៅ១០នាទី ដើម្បីសួរសំណួរតែមួយនោះឡើយ)។ ការធ្វើបែបនេះគឺដើម្បីធានាថានីតិវិធីបានប្រព្រឹត្តទៅដោយត្រឹមត្រូវ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៧ អ.វ.ត.ក អ.ជ.ស.ដ ៩ មេសា ២០០៩ ទំព័រ៤០ បន្ទាត់១១ ដល់ទំព័រ៤១ បន្ទាត់១។*

**សំណួរត្រូវតែសួរឲ្យចំៗ និងខ្លី៖** ការធ្វើបែបនេះ ដើម្បីអាចឱ្យសាក្សីយល់ច្បាស់ អំពីសំណួរ និងអាចផ្តល់នូវចម្លើយបានត្រឹមត្រូវ។ មេធាវីក៏ត្រូវដឹងថា ចម្លើយខ្លះអាចទទួលបានត្រឹមតែការចងចាំក្នុងកម្រិតមួយតែប៉ុណ្ណោះ ដោយសារអង្គហេតុពាក់ព័ន្ធបានកើតឡើង ជាង៣០ឆ្នាំមកហើយ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី៧ អ.វ.ត.ក អ.ជ.ស.ដ ៩ មេសា ២០០៩ ទំព័រ៤១ បន្ទាត់៣-១០។*

**សាក្សី ឬអ្នកជំនាញមិនត្រូវបានគេសួរសំណួរឲ្យផ្តល់ចម្លើយ ដែលមិនមែនជាជំនាញ ឬលើសពីជំនាញរបស់ខ្លួនឡើយ៖** សំណួរបែបនោះនឹងមិនត្រូវបានអនុញ្ញាតឲ្យសួរឡើយ ហើយសាក្សី ឬ អ្នកជំនាញក៏នឹងមិនចាំបាច់ឆ្លើយតបដែរ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី២៣ អ.វ.ត.ក អ.ជ.ស.ដ ២៨ ឧសភា ២០០៩ ទំព័រ៤២បន្ទាត់៤-៥ និងបន្ទាត់១៧-១៩ និងទំព័រ៤៥បន្ទាត់៤-៧ និងបន្ទាត់១៤-២០។*

**អង្គជំនុំជម្រះ និង ភាគីនានាមិនជាប់កាតព្វកិច្ចក្នុងការចង្អុលបង្ហាញ ដែលផ្តល់ដល់ភាគី អំពីវិសាលភាព នៃសក្ខីកម្ម ដែលខ្លួនមានបំណង**

**ស្វែងរកពីអ្នកជំនាញទេ៖** អង្គជំនុំជម្រះសាលាដំបូង និងភាគីអាចសួរសំណួរណាមួយ ដែលអង្គជំនុំជម្រះ សាលាដំបូងយល់ឃើញថាពាក់ព័ន្ធ។ នៅពេលផ្តល់ចម្លើយប្រភេទនេះ អ្នកជំនាញជាប់កាតព្វកិច្ច លើសេចក្តីប្រកាស ឬរបាយការណ៍ ជាលាយលក្ខណ៍អក្សរពីមុនរបស់ខ្លួនប៉ុណ្ណោះនោះទេ។

*រឿងក្តីឌុច៖ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១៧ អ.វ.ត.ក អ.ជ.ស.ដ ១៩ ឧសភា ២០០៩ ទំព័រ៣១ បន្ទាត់២២ ដល់ទំព័រ៣២ បន្ទាត់២។*

**អង្គជំនុំជម្រះ អាចស្វែងរកមតិអ្នកជំនាញលើបញ្ហាណាមួយ ដែលចាត់ទុកថាជាការចាំបាច់សម្រាប់កិច្ចដំណើរការនីតិវិធី៖** កាលណាអង្គជំនុំជម្រះយល់ថា សក្ខីកម្មរបស់អ្នកជំនាញការពិសេសមួយ ដែលមិនអំណោយផលដល់កិច្ចការរដ្ឋបាល របស់តុលាការ ខ្លួនអាចបដិសេធសំណើ ដែលបុគ្គលនោះត្រូវបានកោះហៅ។

*រឿងក្តីនួនជា អៀង សារី និងខៀវ សំផន៖ សេចក្តីសម្រេច លើការចាត់តាំងអ្នកជំនាញ អ.វ.ត.ក អ.ជ.ស.ដ ៩ កក្កដា ២០១២ កថខណ្ឌ ១៤។*

**ជនជាប់ចោទ មានសិទ្ធិមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវមានវត្តមាន ដោយផ្ទាល់ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី៖** ជននោះអាចជ្រើសរើសដើម្បីចូលរួម ក្នុងកិច្ចដំណើរការនីតិវិធីពីចម្ងាយដោយមូលហេតុថា ជននោះមានតំណាងផ្នែកច្បាប់គ្រប់គ្រាន់។

*រឿងក្តី អៀង សារី៖ សម្បទាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ដ ២៦ វិច្ឆិកា ២០១២ កថាខណ្ឌ១៩។ រឿងក្តី អៀង សារី៖ សេចក្តីសម្រេចលើសំណើ របស់មេធាវីការពារ អៀង សារី នូវឯកសារជាខ្សែអាត់សំឡេង និង/ឬវីដេអូ នៅពេលអៀង សារីស្ថិតនៅក្នុងបន្ទប់ឃុំខ្លួន ខាងក្រោមសាលសវនាការ អ.វ.ត.ក អ.ជ.ស.ដ ១៦ មករា ២០១៣ កថាខណ្ឌ១៣-១៥។ រឿងក្តី នួន ជា៖ សេចក្តីសម្រេចលើកទីពីរ ស្តីពីសម្បទារបស់នួន ជាក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ដ ២ មេសា ២០១៣ កថាខណ្ឌ១៦។*

**ភាគីនានា ដែលបានចូលរួមនៅក្នុងដំណើរការនៃការស៊ើបអង្កេត អាចត្រូវបានគេចាត់ទុកថាជាសាក្សីជំនាញ៖** កាលណាផលប្រយោជន៍យុត្តិធម៌តម្រូវ អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការកោះហៅសាក្សីជំនាញ ដែលជាភាគីមួយដែលពីមុន បានចូលរួមនៅក្នុងដំណើរការស៊ើបអង្កេត៖ ទោះបីជាយ៉ាងណាក៏ដោយ ទម្ងន់ណាមួយត្រូវដាក់មកលើសក្ខីកម្ម របស់សាក្សីត្រូវតែពិចារណា ចំពោះការចូលរួមរបស់គេនៅក្នុងការស៊ើបអង្កេត។

*រឿងក្តីនួន ជា និងខៀវ សំផន៖ សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញ TCE-៣៣ អ.វ.ត.ក អ.ជ.ស.ដ ២៦ មេសា ២០១៣ កថាខណ្ឌ១៤។*

**សេចក្តីថ្លែងការណ៍ ស្តីពីផលប៉ះពាល់របស់ជនរងគ្រោះអាចបង្កើតបាន ជាផ្នែកមួយនៃសេចក្តីថ្លែងការណ៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រោះថា ជនជាប់ចោទត្រូវបានផ្តល់សិទ្ធិ ដើម្បីឆ្លើយតប៖** ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិ ក្នុងការធ្វើសេចក្តីថ្លែងការណ៍ ដែលរៀបរាប់អំពីបទនៃការឈឺចាប់ទាំងអស់របស់គេ។ ទោះបីជាយ៉ាងក៏ដោយ សេចក្តីថ្លែងការណ៍នោះ មិនត្រូវដាក់បញ្ចូលនូវការចោទប្រកាន់ថ្មីៗ ប្រឆាំងនឹងជនជាប់ចោទឡើយ។ លើសពីនេះទៀត ជនជាប់ចោទត្រូវទទួលបានជានិច្ច នូវសិទ្ធិតទល់ទៅនឹងសេចក្តីថ្លែងការណ៍ទាំងនេះ ជាពិសេសនៅពេលដែល សេចក្តីថ្លែងការណ៍ទាំងនេះទាក់ទងទៅនឹងភស្តុតាងដោះបន្ទុក។ ការតទល់ទាំងនោះត្រូវធ្វើឡើង ដោយអវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជៀសវាងនូវការឈឺចាប់បន្ថែមកើតមានឡើង។

*រឿងក្តីនួន ជា និងខៀវ សំផន៖ សេចក្តីសម្រេចលើសំណើសុំ កោះហៅឡើងវិញដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៨៧និងសុំឱ្យពិនិត្យឡើងវិញ លើបែបបទពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ ស្តីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើសុំ និងការឆ្លើយតបពាក់ព័ន្ធ អ.ជ.ស.ដ ២ ឧសភា ២០១៣ កថាខណ្ឌ១៩-២២។*

**ជនជាប់ចោទមានសិទ្ធិ ជាមូលដ្ឋាននៅស្ងៀមមិននិយាយស្តី៖** ចៅក្រមត្រូវប្រាប់សិទ្ធិនេះដល់ជនជាប់ចោទ នៅពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធី។

*រឿងក្តីនួន ជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.ជ.ស.ដ ៧ សីហា ២០១៤ កថាខណ្ឌ២៧-២៩។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៩១។ វិធាននេះគឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា៣២៦ លើកលែងតែថា វិធាន៩១ នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យចៅក្រមចោទសួរអ្វីក៏បានដោយមិនកំណត់ និងបានចែងថាសាក្សីត្រូវបន្តមានវត្តមាននៅកន្លែង ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់ ក្រោយពេលសួរសំណួររហូតទាល់តែអង្គជំនុំជម្រះសម្រេចថា វត្តមានរបស់ជននោះគឺមិនចាំបាច់ទៀតទេ។

## *ការអនុវត្តមាត្រាប្រហាក់ប្រហែលគ្នាក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប***

*ប្រទេសកម្ពុជាគឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួនគឺគណៈកម្មាធិការសិទ្ធិមនុស្ស អ.ប.ស។*

**ការរំលោភបំពាន៖ កិច្ចដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរ ដែលបដិសេធសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសវនាការ ដោយផ្ទាល់មាត់ចំពោះមុខ/ដោយមានមេធាវីតំណាងផង ហើយដែលអាចបង្ហាញនូវភស្តុតាង និងពិនិត្យសាក្សី៖** ការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌កើតឡើង នៅពេលដែលជនជាប់ចោទ ត្រូវបានកាត់សេចក្តី និងផ្តន្ទាទោស តាមរយៈនៃកិច្ចដំណើរការនីតិវិធី ជាលាយលក្ខណ៍អក្សរ ហើយការរំលោភបំពាននេះ គឺជាការបដិសេធនូវសិទ្ធិទទួលបានសវនាការ ដោយផ្ទាល់មាត់ ដែលជនជាប់ចោទអាចមានវត្តមានចំពោះមុខ ឬត្រូវតំណាងដោយមេធាវី និងមានឱកាសក្នុងការបង្ហាញភស្តុតាង និងពិនិត្យដេញដោលសាក្សី។

*រឿងក្តី RODRIGUEZ OREJUELA ទល់នឹងប្រទេសកូឡុំប៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ កក្កដា ២០០២ កថាខណ្ឌ៧.៣។*

**ការរំលោភបំពាន៖ ទម្ងន់ដែលផ្តល់លើសាក្សីរបស់រដ្ឋ ដែលជនជាប់ចោទមិនបានសួរតទល់ និងដែលផ្តល់លើការបដិសេធ ដោយគ្មានយុត្តិកម្មលើសំណើសុំរបស់ជនជាប់ចោទ ដែលបានស្នើសុំកោះហៅអ្នកជំនាញ និងត្រូវកោះហៅសាក្សីបន្ថែម៖** សមភាពរវាងមេធាវីការពារក្តី និងស្ថាប័នអយ្យការ ក្នុងការបង្កើតភស្តុតាង ត្រូវបានរំលោភបំពាន ហើយយុត្តិនិសេធក៏បានកើតឡើង នៅពេលតុលាការបានដាក់ "ទម្ងន់យ៉ាងច្រើនលើសលប់" ទៅលើភស្តុតាងដែលទទួលបានពីសាក្សីរបស់រដ្ឋ ដែលគ្មានសេចក្តីពន្យល់ពីការរកមិនឃើញសាក្សីនេះ សម្រាប់ចូលរួមសវនាការ។ ក្នុងករណីនេះ វាជាការបដិសេធឱកាសរបស់ជនជាប់ចោទនៅក្នុងការសួរតទល់គ្នា និងក្នុងករណីតុលាការខកខាន មិនបានផ្តល់មូលហេតុ ចំពោះការប្រានចោលសំណើ របស់ជនជាប់ចោទ ដែលស្នើសុំឲ្យកោះហៅអ្នកជំនាញ និងសាក្សីបន្ថែម។

*រឿងក្តី DUG IN ទល់នឹងសហព័ន្ធរុស្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៥ កក្កដា ២០០៤ កថាខណ្ឌ៩.៣។*

**ការរំលោភបំពាន៖ ការបដិសេធសិទ្ធិរបស់ជនជាប់ចោទក្នុងការបង្ហាញសាក្សីពាក់ព័ន្ធ៖** ទោះបី សិទ្ធិក្នុងការបង្ហាញអំពីភស្តុតាង ជំនួសជនណាម្នាក់មិនមានន័យថា ជនជាប់ចោទមានសិទ្ធិ ដោយគ្មានព្រំដែនកម្រិត ក្នុងការពិនិត្យសាក្សី ដោយខ្លួនផ្ទាល់ក៏ដោយ ក៏ការបដិសេធសិទ្ធិរបស់ជនជាប់ចោទ ក្នុងការបង្ហាញសាក្សីពាក់ព័ន្ធ គឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទ។ ជនជាប់ចោទត្រូវមានសិទ្ធិដូចគ្នាទៅនឹងស្ថាប័នអយ្យការ ក្នុងការបង្កើតភស្តុតាងចាប់

បង្ខំឱ្យសាក្សីមានវត្តមាន និងការសួរតតាំងជាមួយនឹងសាក្សីដាក់បន្ទុក។

*រឿងក្តី IDIEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣១ មីនា ២០០៩ កថាខណ្ឌ៩.៦ និងរឿងក្តី KHUSEYNOVA និង BUTAEVA ទល់នឹងប្រទេសតាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២០ តុលា ២០០៨ កថាខណ្ឌ៨.៥ (សិទ្ធិក្នុងការបង្ហាញសាក្សីពាក់ព័ន្ធ)។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា១៤(១) មាត្រា១៤(៣)(ង) និងមាត្រា១៤(៣)(ឆ)។ មាត្រា១៤(១) ចែងរំលឹកថា ជនជាប់ចោទមានសិទ្ធិទទួលបានសវនាការដោយ "យុត្តិធម៌"។ មាត្រា១៤(៣)(ង) បានការពារសិទ្ធិរបស់ជនជាប់ចោទ ក្នុងការពិនិត្យសាក្សីក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងសាក្សីដាក់បន្ទុក ខណៈមាត្រា១៤(៣)(ឆ) បានការពារសិទ្ធិជនជាប់ចោទមិនឱ្យគេបង្ខំខ្លួនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬបង្ខំខ្លួនឱ្យសារភាពអំពីពិរុទ្ធភាព។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ជនដែលបានផ្តល់ចម្លើយ ឲ្យនគរបាលដែលចម្លើយនេះបានដាក់នៅចំពោះមុខតុលាការ៖** ជនទាំងនេះមានដូចជាជនរងគ្រោះ នៃអំពើល្មើស ដែលត្រូវបានចាត់ទុកថា ជាសាក្សី ទោះបីពួកគេមិនបានផ្តល់នូវសក្ខីកម្មក្នុងតុលាការក៏ដោយ។

*រឿងក្តី DELTA ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៩ ធ្នូ ១៩៩០ កថាខណ្ឌ ៣៤។*

**សាក្សីដែលមិនមានវត្តមាន នៅអំឡុងពេលជំនុំជម្រះ ដែលបានផ្តល់នូវសក្ខីកម្ម ប្រឆាំងនឹងជនជាប់ចោទ៖** ក្នុងករណីចម្លើយ របស់អ្នកដាក់ពាក្យសុំមិនមែនជាកត្តាចូលរួម នៃការវិនិច្ឆ័យទោសទេ អវត្តមានរបស់សាក្សី ដែលបានផ្តល់សក្ខីកម្មដាក់បន្ទុក នៅខាងក្រៅតុលាការ ដូចជារបាយការណ៍ ជាលាយលក្ខណ៍អក្សរជាអាទិ៍ មិនបង្កើតបានជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះទេ។

*រឿងក្តី KAMASINSKI ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៩ ធ្នូ ១៩៨៩ កថាខណ្ឌ៨៩-៩១។*

**ចម្លើយដែលត្រូវបានទទួលយក សម្រាប់ការកំណត់អំពីនិរទោស ឬពិរុទ្ធភាពរបស់ជនជាប់ចោទ៖** រួមទាំងរបាយការណ៍ របស់សហជនជាប់ចោទ លើកលែងតែមេធាវីការពារក្តី មិនមានឱកាសសួរសហជនជាប់ចោទទាំងនេះ នៅក្នុងកំឡុងពេលនៃកិច្ចដំណើរការនីតិវិធី ព្រមទាំងចម្លើយរបស់សាក្សីដែលទទួលបាន នាដំណាក់កាលមុនអង្គសេចក្តី ដែលសិទ្ធិរបស់មេធាវីការពារក្នុងការតតាំង និងចោទសួរសាក្សីត្រូវបានគោរព។

*រឿងក្តី CRAXI ទល់នឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ៥ ធ្នូ ២០០២ កថាខណ្ឌ ៨៨-៨៩ (ចម្លើយរបស់សហជនជាប់ចោទ) និងរឿងក្តី ASCH ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មេសា ១៩៩១ កថាខណ្ឌ២៧ (ចម្លើយរបស់សាក្សី នៅក្នុងដំណាក់កាលមុនអង្គសេចក្តី)។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មាត្រា៦(១) និង(៣)។ មាត្រាទាំងនេះបានផ្តល់ឱ្យមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងសិទ្ធិរបស់ជនគ្រប់រូប ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ និងសមភាពរបស់ភាគីនីមួយៗក្នុងការទទួលបានឱកាស និងលក្ខខណ្ឌដូចគ្នា។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានមូលដ្ឋានចេញពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍អំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ការចោទសួរសាក្សីដោយមេធាវី៖** មេធាវីមិនត្រូវសួរសង្កត់លើរបាយការណ៍ ដែលទំនងអាចជះឥទ្ធិពលដល់សាក្សី ឬមួលបង្កាច់សក្ខីកម្មរបស់សាក្សីនោះទេ។

*លេខ 85-91259 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៩២ តុលាការកំពូលបារាំង ៥ មីនា ១៩៨៦។*

**ការចោទសួរជនរងគ្រោះ ពីសំណាក់ជនជាប់ចោទ និងដោយមេធាវីរបស់ខ្លួន៖** ការចោទសួរបែបនេះត្រូវបានអនុញ្ញាតក្នុងអំឡុងពេលសវនាការ។

*លេខ 00-81594 តុលាការកំពូលបារាំង ២៥ តុលា ២០០០។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** មាត្រា៣១១ និងមាត្រា៣១២។ មាត្រាទាំងនេះបើកឲ្យមានការស្តាប់ភាគីនានា ក្នុងអំឡុងពេលជំនុំជម្រះ រួមទាំងការផ្តល់លទ្ធភាពឲ្យភាគីចោទសួរជនជាប់ចោទតាមរយៈចៅក្រមប្រធានផងដែរ។

# មាត្រា ៣៣០៖ ជំនួយ និងសម្បថរបស់អ្នកបកប្រែ

*ក្នុងករណីចាំបាច់ ប្រធានសវនាការអាចស្នើសុំអ្នកបកប្រែ។ អ្នកបកប្រែនេះត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងជួយដល់តុលាការ និងបកប្រែចម្លើយឱ្យបានស្មោះត្រង់។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើស ក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូភាគី ឬសាក្សីទេ។*

*បទប្បញ្ញត្តិនៃមាត្រា១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) នៃក្រមនេះត្រូវយកមកអនុវត្តផងដែរ។*

## ការអនុវត្តនៅអ.វ.ត.ក

អង្គជំនុំជម្រះសាលាដំបូងបានបដិសេធ ក្នុងការចាត់ទុកឯកសារជាភាសាខ្មែរថា ជាឯកសារមានអានុភាពតាមផ្លូវច្បាប់ ពីព្រោះថា ឯកសារនេះបាន បកប្រែមកពីសំណៅ នៃភាសាអង់គ្លេស៖ ភាសាដើមត្រូវបានចាត់ទុកថា ជាឯកសារមានអានុភាពតាមផ្លូវច្បាប់ អង្គជំនុំជម្រះនឹងស្នើសុំអ្នកបកប្រែវិជ្ជាជីវៈ ឲ្យបម្រើការប្រៀបធៀបឯកសារដើម ដែលមានអានុភាពតាមផ្លូវច្បាប់ជាមួយនឹងឯកសារបកប្រែទៅជាភាសាខ្មែរ។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី២២ អ.វ.ត.ក អ.ជ.ស.ដ ២៧ ឧសភា ២០០៩ ទំព័រ៧៨ បន្ទាត់១៦-២០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៣០នៃវិធានផ្ទៃក្នុង។ វិធាន ៣០ ស្រដៀងគ្នាទៅនឹងមាត្រា៣៣០ ប៉ុន្តែបានពង្រីកបន្ថែមឲ្យព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ សាក្សី និងភាគីផ្សេងទៀត ក្រៅពីចៅក្រមមានសិទ្ធិស្នើសុំអ្នកបកប្រែភាសាផ្ទាល់មាត់/អ្នកបកប្រែឯកសារ។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

***គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប***

*ប្រទេសកម្ពុជាគឺជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រា*

*ស្រដៀងគ្នាទាំងឡាយ នៅក្នុងកតិកាសញ្ញាICCPRត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួនគឺគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប។*

**ប្រសិនបើជនជាប់ចោទ និងសាក្សីរបស់ខ្លួនអាចយល់ដឹងសមស្រប និងអាចសម្តែងមតិជាភាសាផ្លូវការរបស់តុលាការដោយខ្លួនឯងបាន វាពុំមានការរំលោភសិទ្ធិនោះទេ បើទោះជាពុំបានផ្តល់អ្នកបកប្រែភាសាផ្ទាល់មាត់ក៏ដោយ៖** ករណីនេះដូចគ្នា បើទោះជាភាសាផ្លូវការរបស់តុលាការពុំមែន ជាភាសាកំណើតរបស់ខ្លួន ដែលជាភាសាពួកគេប្រើប្រាស់ជាធម្មតា ឬដែលជាភាសាពួកគេពេញចិត្តក៏ដោយ។

*រឿងក្តី CADORET និងLE BIHAN ទល់នឹងប្រទេសបារាំង គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១១ មេសា ១៩៩១ កថាខណ្ឌ៥.៦ និង៥.៧។ រឿងក្តី GUESDON ទល់ទៅនឹងប្រទេសបារាំង គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៥ កក្កដា ១៩៩០ កថាខណ្ឌ១០.២ -១០.៣។ រឿងក្តី BARZHIG ទល់នឹងប្រទេសបារាំង គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១១ មេសា ១៩៩១ កថាខណ្ឌ៤.៥ដល់៦.៤។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា១៤(៣)(ច) ដែលស្រដៀងគ្នាទៅនឹងមាត្រា ៣៣០ លើកលែងតែមាត្រានេះចែងយ៉ាងច្បាស់ថា សិទ្ធិនេះអាចអនុវត្តទៅបានដោយជនជាប់ចោទដោយមិនអស់កម្រៃក្នុងករណីដែលជនជាប់ចោទពុំអាចយល់ ឬនិយាយភាសាដែលបានប្រើប្រាស់នៅក្នុងតុលាការ។ ស្រដៀងគ្នានេះដែរ មាត្រា ៣៣០ អនុញ្ញាតឲ្យអ្នកបកប្រែភាសាផ្ទាល់មាត់ម្នាក់មានវត្តមាននៅក្នុងបន្ទប់សវនាការ។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**សោហ៊ុយអ្នកកប្រែភាសាផ្ទាល់មាត់៖** ទណ្ឌិតមិនត្រូវចេញសោហ៊ុយ សម្រាប់អ្នកបកប្រែភាសាផ្ទាល់មាត់ទេ។

*រឿងក្តី LUEDICKE BELKACEM និងKOÇ ទល់នឹងប្រទេសអាល្លឺម៉ង់ តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៨ វិច្ឆិកា ១៩៧៨ កថាខណ្ឌ៤២។*

**ការចាត់តាំង និងការគ្រប់គ្រងអ្នកបកប្រែភាសាផ្ទាល់មាត់៖** ចៅក្រមត្រូវចាត់តាំងអ្នកបកប្រែភាសាផ្ទាល់មាត់ នឹងអាចមានវិសាលភាព ទៅលើការគ្រប់គ្រងភាពត្រឹមត្រូវ នៃការបកប្រែភាសាផ្ទាល់មាត់ត្រឹមតែកម្រិតណាមួយ បើសិនជា ខ្លួនត្រូវបានជូនដំណឹងអំពីភាពចាំបាច់នេះ។

*រឿងក្តី KAMASINSKI ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៩ ធ្នូ ១៩៨៩ កថាខណ្ឌ៧៤។*

**កម្រិតនៃជំនួយក្នុងការបកប្រែភាសាផ្ទាល់មាត់៖** កម្រិតនៃជំនួយ នៅក្នុងការបកប្រែភាសាផ្ទាល់មាត់ ដែលបានផ្តល់ជូនជនជាប់ចោទ គួរផ្តល់លទ្ធភាពឲ្យពួកគេបានដឹងអំពីរឿងក្តី និងអាចការពារខ្លួនឯងបានតាមរយៈការបង្ហាញនូវហេតុការណ៍ ដែលកើតឡើងចំពោះខ្លួន។

*រឿងក្តី LAGERBLOM ទល់នឹងប្រទេសស៊ុយអែត តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៤ មករា ២០០៣ កថាខណ្ឌ៦១។*

**ប្រធានសវនាការត្រូវធានាថា ជំនួយនេះមានលក្ខណៈគ្រប់គ្រាន់៖** ការរំលោភបានកើតឡើង នៅពេលដែលចៅក្រមបានអនុញ្ញាត ឲ្យបង/ប្អូនប្រុសរបស់ជនជាប់ចោទធ្វើ ជាអ្នកបកប្រែភាសាផ្ទាល់មាត់ក្រៅផ្លូវការក្រោយពីចៅក្រមបានដឹងថា មេធាវីការពារកំពុងជួបការលំបាក ក្នុងការប្រាស្រ័យទាក់ទងជាមួយជនជាប់ចោទ។

*រឿងក្តី CUSCA NI ទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៤ កញ្ញា ២០០២ កថាខណ្ឌ៣៨-៣៩។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖* មាត្រា៦(៣)។ មាត្រានេះចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងលទ្ធភាពក្នុងការទទួលបានជំនួយពីអ្នកបកប្រែភាសាផ្ទាល់មាត់ដោយពុំគិតថ្លៃ ប្រសិនបើជនជាប់ចោទមិនអាចយល់ ឬនិយាយភាសាដែលត្រូវបានប្រើប្រាស់នៅក្នុងតុលាការ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានចេញពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍អំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំងពោលគឺតុលាការកំពូល។*

**អានុភាពនៃការចាត់តាំង អ្នកបកប្រែភាសាផ្ទាល់មាត់នៅពេលបើកកិច្ចពិភាក្សាដេញដោល ពុំមែននៅក្នុងពេលចាត់តាំងគណៈវិនិច្ឆ័យនោះទេ៖** ពុំមានមោឃភាពកើតចេញពីករណីនេះឡើយ។

*ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១ តុលាការកំពូលបារាំង ៤ មករា ១៩១៧។*

**សុពលភាពនៃសម្បថ របស់អ្នកបកប្រែភាសាផ្ទាល់មាត់៖** សម្បថ នៅពេលបើកកិច្ចពិភាក្សាដេញដោលមានសុពលភាពរហូតដល់ពេលបញ្ចប់រឿងក្តី។

*លេខ 86-96736 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ៣៦៤ តុលាការកំពូលបារាំង ២២ តុលា ១៩៨៧។*

**នៅពេលជនជាប់ចោទ ឬសាក្សីលើសពីម្នាក់ពុំនិយាយភាសារបស់តុលាការ៖** ចម្លើយរបស់ពួកគេត្រូវតែបក

ប្រែទៅជាភាសា ដែលពួកគេនិយាយ និងយល់ និង ទៅជាភាសារប្រើប្រាស់របស់តុលាការ។

*លេខ 89-86557 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ២៥៣ តុលាការកំពូលបារាំង ២០ មិថុនា ១៩៩០។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៣៤៤។ មាត្រាទាំងនេះចែងអំពីការចាត់តាំងអ្នកបកប្រែភាសាផ្ទាល់មាត់មួយរូប ដើម្បីជួយដល់ភាគីនៅក្នុងពេលជំនុំជម្រះ នៅចំពោះមុខតុលាការព្រហ្មទណ្ឌ។

# មាត្រា ៣៣២៖ ការបង្ហាញវត្ថុតាង

*ប្រធានសវនាការអាចបង្គាប់ឱ្យជនណាម្នាក់បង្ហាញវត្ថុតាងបាន។*

## ការអនុវត្តនៅអ.វ.ត.ក

**សំណើសុំឲ្យបង្ហាញភស្តុតាង នៅក្នុងតុលាការ៖** អង្គជំនុំជម្រះ អាចកោះហៅភាគីឲ្យដាក់សំណើសុំឲ្យបង្ហាញភស្តុតាងនៅក្នុងតុលាការបាន។

*រឿងក្តីឌុចៈ ភាពអាចទទួលយកបាននៃភស្តុតាងបន្ថែម អ.វ.ត.ក អ.ជ.ស.ជ ២ តុលា ២០០៩ ទំព័រ១។*

**អត្ថបទដកស្រង់ចេញ ពីឯកសារនៅក្នុងសំណុំរឿងអាចត្រូវបានស្នើសុំ ឲ្យដាក់បញ្ចូលនៅក្នុងភស្តុតាងបាន៖** អង្គជំនុំជម្រះបានច្រានចោលការជំទាស់របស់ក្រុមមេធាវីការពារក្តី ដែលបានលើកឡើងថា សំណើរបស់ស្ថាប័នអយ្យការសុំដាក់អត្ថបទដកស្រង់ចេញ ពីក្នុងសំណុំរឿងពុំមានភាពសមស្របទេ ដោយសារវាពុំមែនជាឯកសារមួយ ដែលមាននៅក្នុងកំណត់ហេតុ នៃរឿងក្តី។

*រឿងក្តីឌុចៈ ប្រតិចារឹកសវនាការ ថ្ងៃជំនុំជម្រះទី១២ អ.វ.ត.ក អ.ជ.ស.ជ ២៧ មេសា ២០០៩ ទំព័រ១ បន្ទាត់២៣ ទំព័រ១១ បន្ទាត់១។*

**អង្គជំនុំជម្រះសាលដំបូងមានសិទ្ធិក្នុងការចាត់ថ្នាក់ឡើងវិញនូវឯកសារណា ដែលត្រូវបានគេចាត់ទុកជាឯកសារការសម្ងាត់ ក្នុងអំឡុងពេលដំណើរការនៃការស៊ើបអង្កេត ឬជាសាធារណៈនៅពេលបិទដំណើរការជំនុំជម្រះក្តី៖** កាលណាអង្គជំនុំជម្រះ ឬក៏ប្រធានអង្គជំនុំជម្រះសម្រេចថា ឯកសារទាំងនេះលែងមានហេតុផល ជាឯកសារ សម្ងាត់ទៀតហើយនោះ ហើយដើម្បីផលប្រយោជន៍សាធារណៈ ឯកសារទាំងនេះត្រូវប្រែក្លាយទៅជាឯកសារសាធារណៈ បន្ទាប់មកឯកសារទាំងនោះ អាចត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈ សម្រាប់គោលបំណងនោះ។

*រឿងក្តីនួន ជា និងខៀវ សំផន៖ សាលក្រមសំណុំរឿង ០០២/០១ អ.វ.ត.ត. អ.ជ.ស.ជ ៧ សីហា ២០១៤ កថាខណ្ឌ ៣៩។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៨៧(៨)។ វិធាននេះស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ៣៣២។

# មាត្រា ៣៣៩៖ កិច្ចស៊ើបសួរបន្ថែមដែលបង្គាប់ដោយតុលាការ

*ប្រសិនបើយល់ឃើញថា កិច្ចស៊ើបសួរថ្មីជាការចាំបាច់ តុលាការអាចបង្គាប់តាមសាលក្រមឱ្យធ្វើការស៊ើបសួរបន្ថែម។*

*អ្នកដែលមានសមត្ថកិច្ចធ្វើការស៊ើបសួរបន្ថែមនេះគឺ៖*

*- ប្រធានសវនាការ*

*- ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ កាលណាតុលាការសម្រេចជាក្រុមសមូហភាព*

*- ចៅក្រមដទៃទៀតនៃតុលាការជាន់ដំបូង*

*ចៅក្រមដែលបង្គាប់ធ្វើការស៊ើបសួរបន្ថែម ត្រូវចាត់តាំងចៅក្រមឱ្យទទួលភារកិច្ចនេះ។ នៅក្នុងលក្ខខណ្ឌដូចគ្នានឹងចៅក្រមស៊ើបសួរ ចៅក្រមនេះអាច៖*

*- ចុះទៅលើគ្រប់វិសាលភាពនៃដែនសមត្ថកិច្ចតុលាការឬលើគ្រប់វិសាលភាពនៃដែនដីជាតិ*

*- ស្តាប់ចម្លើយសាក្សី*

*- ធ្វើការឆែកឆេរ*

*- ចាប់យកវត្ថុតាង*

*- បង្គាប់ឱ្យធ្វើកោសលវិច័យ។*

*ដើម្បីអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រមអាចចេញដីកាចាត់ឱ្យសួរជំនួសបានដែរ។*

## ការអនុវត្តនៅអ.វ.ត.ក

**សំណើសុំឲ្យតែងតាំងអ្នកជំនាញបន្ថែម៖** បណ្តឹងឧទ្ធរណ៍ របស់ក្រុមមេធាវីការពារក្តីប្រឆាំងនឹងការបដិសេធសំណើសុំ ឲ្យចាត់តាំងអ្នកជំនាញបន្ថែម ពុំអាចទទួលយកបានទេ ក្នុងករណីដែលអ្នកជំនាញ ដែលត្រូវបានចាត់តាំងដំបូងពុំទាន់បានដាក់របាយការណ៍ របស់ខ្លួនជូនតុលាការនៅឡើយ។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសំណើសុំឲ្យចាត់តាំង អ្នកជំនាញបន្ថែម អ.វ.ត.ក អ.ជ.ស.ជ ១៤ធ្នូ ២០០៩ ទំព័រ២១-២២។*

**ការធ្វើឲ្យមានតុល្យភាពស្តីពីយុត្តិធម៌ និងការបង្កើនល្បឿនឲ្យបានឆាប់រហ័ស នៃដំណើរការជំនុំជម្រះ៖** នៅពេលពិចារណាថាតើត្រូវចេញដីកាសម្រេច ឱ្យមានការស៊ើបអង្កេតបន្ថែម

កាលណាអាយុ ឬសមត្ថភាពរបស់ជនជាប់ចោទ មានបញ្ហាចោទឡើង អ្នកជំនាញផ្នែកវេជ្ជសា ស្ត្រ អាចត្រូវបានតែងតាំងឡើង ដើម្បីពិនិត្យមើលសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ៖ កាលណាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ត្រូវបានតែងតាំង ជាគោលការណ៍នៅក្នុងការសម្រេច ថាតើជនជាប់ចោទអាចអនុវត្តនូវសិទ្ធិរបស់ខ្លួនបានដោយប្រសិទ្ធិភាព ក្នុងសំណុំរឿងប្រឆាំងនឹងគាត់ឬទេ។ សិទ្ធិទាំងនោះជារួមមាន (១) ប្ដឹងផ្ដល់ (២) យល់ដឹងពីប្រភេទនៃបទចោទ (៣) យល់ដឹងពីកិច្ចដំណើរការនីតិវិធីនេះ (៤) យល់ដឹងពីព័ត៌មានលម្អិត នៃភស្តុតាង (៥) ទទួលការណែនាំពីមេធាវី (៦) យល់ដឹងអំពីផលវិបាក នៃកិច្ចដំណើរការនីតិវិធី និង(៧) ផ្ដល់សក្ខីកម្ម។

*សវនាការ៖ អ.វ.ត.ក អ.ជ.ស.ដ ១៧ វិច្ឆិកា ២០១១ កថាខណ្ឌ១០។ រឿងក្តីនួន ជា៖ សេចក្តីសម្រេចលើកទីពីរ ស្តីពីសម្បទារបស់នួន ជា ក្នុងការចូលរួមសវនាការ អ.វ.ត.ក អ.ជ.ស.ដ ២ មេសា ២០១៣ កថាខណ្ឌ១៣។*

ទៀត អង្គជំនុំជម្រះ ក៏អាចពិចារណាឱ្យមានតុល្យភាពអំពីតម្រូវការ ដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវ នៃកិច្ចដំណើរការនីតិវិធី និងការបង្កើនល្បឿនឲ្យបានឆាប់រហ័សនៃដំណើរការជំនុំជម្រះក្តី។

*រឿងក្តីនួន ជា និងខៀវ សំផន៖ សេចក្តីសម្រេចលើសំណើ របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំការដាក់ភស្តុតាងថ្មី នៅចំពោះមុខអង្គជំនុំជម្រះ និងការឆ្លើយតបរបស់ខៀវ សំផន ដែលអ្នកជំនាញ អ.ជ.ស.ដ ១៤ មិថុនា ២០១៣ កថាខណ្ឌ៣។ រឿងក្តីនួន ជា៖ សេចក្តីសម្រេចលើសំណើរបស់នួន ជា សុំឱ្យទទួលយកឯកសារថ្មីឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក Rob LEMKIN អ.ជ.ស.ដ ២៤ កក្កដា ២០១៣ កថាខណ្ឌ១៩។*

*រឿងក្តីនួន ជា៖ សេចក្តីសម្រេចស្តីពីសម្បទាក្នុងការចូលរួមសវនាការ និងលើសំណើរបស់មេធាវីការពារក្តី ក្នុងការស្នើសុំអ្នកជំនាញវេជ្ជសាស្ត្របន្ថែម៖ អ.វ.ត.ក អ.ជ.ស.ដ ១៩ វិច្ឆិកា ២០១១ កថាខណ្ឌ ១៤។ រឿងក្តីអៀង ធីរិទ្ធ៖ សេចក្តីសម្រេចស្តីពីសម្បទា នៅក្នុងការចូលរួម*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៩៣(២)។ វិធាននេះស្រដៀងគ្នាមែនទែនទៅនឹងមាត្រា៣៣០ លើកលែងតែករណីដែលថា មាត្រា ៣៣៩ បានចែងលម្អិតជាងនេះអំពីប្រភេទនៃចៅក្រមដែលមានសិទ្ធិធ្វើការស៊ើបអង្កេត។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍ អំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំងគឺតុលាការកំពូល។*

**ការអនុវត្តសិទ្ធិបំពេញកិច្ចស៊ើបសួរបន្ថែម៖** ការអនុវត្តសិទ្ធិនេះគឺជាឆន្ទានុសិទ្ធិ របស់ប្រធានតុលាការព្រហ្ម ទណ្ឌ។

*លេខ 66-93479 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៦០ តុលាការកំពូលបារាំង ១៥ ឧសភា ១៩៦៨។*

**ការធ្វើកោសល្យវេជ្ជសាស្ត្រ លើជនជាប់ចោទពុំមែនជាព័ត៌មានបន្ថែមនោះទេ៖** វាពុំមែនជាព័ត៌មានបន្ថែមនោះទេ បើទោះជាវាត្រូវបានធ្វើឡើង ដើម្បីផ្ទៀងផ្ទាត់ ចំពោះភាពសមស្រប របស់ជនជាប់ចោទជាមួយនឹងការឃុំខ្លួន ឬដើម្បីចាត់ចែងលើការសួរចម្លើយ និងការបង្ហាញខ្លួននៅចំពោះមុខតុលាការ។

*លេខ 65-92650 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៤៥ តុលាការកំពូលបារាំង ១៥ កុម្ភៈ ១៩៦៦ (ភាពសមស្រប ជាមួយនឹងការឃុំខ្លួន)។ ព្រឹត្តិបត្ររដ្ឋប្បវេណីលេខ២៣៩៤ សការដ្ឋប្បវេណី ទី២ ១០ មេសា ១៩៦២ (ការសួរចម្លើយ និងការបង្ហាញខ្លួន)។*

**ការស្តាប់ចម្លើយបន្ថែមពីសាក្សី៖** ប្រធានសវនាការនៃតុលាការព្រហ្មទណ្ឌ អាចស្តាប់សាក្សីថ្មី និងបុគ្គលទាំងឡាយណា ដែលខ្លួនបានស្តាប់រួចហើយ នៅពេលធ្វើកំណត់ហេតុ ជាលាយលក្ខណ៍អក្សរនៃការស៊ើបអង្កេត។

*DP 1899. 1. 462 តុលាការកំពូលបារាំង ៣១ មករា ១៨៩៥។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំង៖** *ក្រមនីតិវិធីព្រហ្មទណ្ឌ* បារាំងពុំមានមាត្រាស្រដៀងគ្នាណាមួយទៅនឹងមាត្រា៣៤៦នោះទេ។ ទោះបីជាយ៉ាងនេះក្តី មាត្រា៣១៥ និងមាត្រា៤៥៨បានចែងអំពីសេចក្តីប្រកាសរបស់ភាគីឯកជនមែន។

# មាត្រា ៣៤២៖ សមត្ថកិច្ចរបស់តុលាការក្នុងរឿងអញ្ញត្រកម្ម

*តុលាការដែលទទួលបណ្តឹងអាជ្ញាមានសមត្ថកិច្ច ដើម្បីសម្រេចអំពីគ្រប់អញ្ញត្រកម្មទាំងអស់ដែលលើកឡើងដោយគូភាគី លើកលែងតែច្បាប់បានបញ្ញត្តផ្សេងពីនេះ។*

*តុលាការមានសមត្ថកិច្ច ជាអាទិ៍ ដើម្បីសម្រេចពីអញ្ញត្រកម្មស្តីពីមោឃភាពនៃនីតិវិធីដែលគេដាក់ជូនខ្លួនពិនិត្យ លើកលែងតែកាលណាតុលាការទទួលជំនុំជម្រះ តាមដីកាបញ្ជូនពីចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ។*

## ការអនុវត្តនៅអ.វ.ត.ក

អញ្ញត្រកម្មចំពោះយុត្តាធិការ នៃតុលាការអាចទទួលយកបាន ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីមុនអង្គសេចក្តី ទោះបីជានៅក្រោយពេលចេញដីកាដំណោះស្រាយ ហើយក៏ដោយ៖ ដោយសារតែបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងយុត្តាធិការ ដែលត្រូវបានគេកំណត់យ៉ាងជាក់លាក់ថា ជាមូលដ្ឋានមានកម្រិតមួយនៃបណ្តឹងឧទ្ធរណ៍ ត្រូវបានអនុញ្ញាតឲ្យធ្វើឡើង នៅក្នុងអំឡុងពេល នៃកិច្ចដំណើរការនីតិវិធី មុនអង្គសេចក្តី ហេតុដូច្នេះ ជនជាប់ចោទត្រូវបានគេអនុញ្ញាតឲ្យលើកឡើង នូវអញ្ញត្រកម្ម ចំពោះយុត្តាធិការលើកម្មវត្ថុ របស់តុលាការ បើទោះជានៅក្រោយពេល ចេញដីកាដំណោះស្រាយក៏ដោយ។ ក៏ប៉ុន្តែ ជនជាប់ចោទត្រូវលើកឡើងឲ្យបាន មុនពេលចាប់ផ្តើមការជំនុំជម្រះ។ ការពិចារណាលើបញ្ហានេះ នាដំណាក់កាលមុនអង្គសេចក្តី គាំទ្រចំពោះកិច្ចដំណើរការនីតិវិធីយ៉ាងមានប្រសិទ្ធភាព។

*រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយអ.វ.ត.ក អ.ជ.ស.ដ ១១ មេសា ២០១១ កថាខណ្ឌ៥៦។ សូមមើលផងដែរនូវរឿងក្តីអៀង សារី៖ សេចក្តីសម្រេច ស្តីពីការបដិសេធបឋម តាមវិធាន ៨៩ លើសំណើរបស់អៀងសារី អ.វ.ត.ក អ.ជ.ស.ដ ៣ វិច្ឆិកា ២០១១ កថាខណ្ឌ ១-១០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៨០(៤) វិធាន៨៩ និងវិធាន៩១ នៃវិធានផ្ទៃក្នុង។ វិធាន៨០(៤) នៃវិធានផ្ទៃក្នុងចែងថា អញ្ញត្រកម្មដែលភាគីអាចលើកឡើងពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃវត្ថុតាងឬ ឯកសារដែលភាគីស្នើសុំផ្តល់ជូន ឬដាក់បញ្ចូលនៅក្នុងរឿងក្តីអាចធ្វើឡើងជាលាយលក្ខណ៍អក្សរបាន នៅក្នុងរយៈពេលដែលត្រូវបានកំណត់ក្នុងច្បាប់នៅក្រោយសវនាការបឋម។ វិធាន៨៩ នៃវិធានផ្ទៃក្នុងចែងអំពីប្រភេទអញ្ញត្រកម្មដែលអាចត្រូវបានលើកឡើង នៅក្រោយដីកាដំណោះស្រាយចូលជាស្ថាពរ និងចែងអំពីរយៈពេលដែលអង្គជំនុំជម្រះចេញសាល

ដីកា ដែលមានសំអាងហេតុពាក់ព័ន្ធនឹងអញ្ញត្រកម្មទាំងនេះ។ វិធាន៩១នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យព្រះរាជអាជ្ញា ភាគី និងមេធាវីរបស់ខ្លួនជំទាស់ទៅនឹងការបន្តស្តាប់សក្ខីកម្មសាក្សី ប្រសិនបើភាគីយល់ឃើញថា សក្ខីកម្មបែបនេះពុំនាំទៅដល់ការស្វែងរកការពិត។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍ អំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំងពោលគឺតុលាការកំពូល។*

**អញ្ញត្រកម្មដែល ត្រូវបានលើកឡើងដោយចៅក្រមតាមគំនិតផ្តួចផ្តើមរបស់ខ្លួន៖** ការលើកឡើងទាំងនេះត្រូវតែផ្តោតលើសមត្ថកិច្ចរបស់តុលាការតែប៉ុណ្ណោះ។

*លេខ 90-81383 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៩៤ តុលាការ កំពូលបារាំង ២៥ កុម្ភៈ ១៩៩១។*

**អញ្ញត្រកម្មចំពោះបញ្ហាមោឃភាព៖** អញ្ញត្រកម្មទាំងនេះត្រូវតែបង្ហាញ នៅមុនពេលដេញដោលលើអង្គសេចក្តី។

*លេខ 09-80516 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៤ តុលាការកំពូលបារាំង ១៦ កុម្ភៈ ២០១០។*

*លេខ06-87787 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៨ តុលាការកំពូលបារាំង ២៣ មករា ២០០៨។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌ*** បារាំង៖ មាត្រា២៨៣។ មាត្រានេះចែងអំពីវិធានការពិសេស ឬវិធានការណាមួយផ្សេងទៀត ដែលប្រធានអាចធ្វើឡើងដើម្បីនាំទៅដល់ការស្វែងរកការពិត រួមទាំងការស៊ើបអង្កេតបន្ថែម ដែលប្រធានយល់ឃើញថាមានប្រយោជន៍។

# មាត្រា ៣៥០៖ ការប្រកាសពីពិរុទ្ធភាព

*តុលាការពិនិត្យមើលថា:*

*- អំពើនោះជាបទឧក្រិដ្ឋបទមជ្ឈិមឬបទលហុ*

*- ជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់លើខ្លួនឬទេ។*

*ប្រសិនបើពិនិត្យឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ។*

*ប្រសិនបើតុលាការយល់ឃើញថា អំពីនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ។*

## ការអនុវត្តនៅអ.វ.ត.ក

**អង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់ ថាតើអង្គហេតុកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចត្រូវបានកំណត់តាមផ្លូវច្បាប់ថា ជាឧក្រិដ្ឋកម្ម ពាក់ព័ន្ធដែរឬអត់៖** អង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់ថា តើអង្គហេតុ ក្នុងដីកាដំណោះស្រាយអាចត្រូវបានកំណត់ តាមផ្លូវច្បាប់ថា ជាឧក្រិដ្ឋកម្មដែរឬអត់ ដោយអនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយការកំណត់បែបនេះ ពុំមានអានុភាពលើយុត្តាធិការនៃ អ.វ.ត.ក ក្នុងការបញ្ជូនជនជាប់ចោទ ទៅជំនុំជម្រះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនេះទេ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៨០ ដែលដកស្រង់រឿងក្តីអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយអ.វ.ត.ក អ.ប.ជ ១១ មេសា ២០១១ កថាខណ្ឌ២៩៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៩៨(៣) ៩៨(៥) និងវិធាន៩៨(៦)។ វិធានទាំងនេះស្រដៀងគ្នាមែនទែនទៅនឹងមាត្រា៣៥០។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារ ដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជា ជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុ-សញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**គោលការណ៍សច្ចធារណ៍នៃនិរទោស គឺជាគោលការណ៍មូលដ្ឋាន៖** គោលការណ៍នេះ ជាធាតុផ្សំមួយនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

*រឿងក្តី DEWER ទល់នឹងប្រទេសបែលហ្សិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៧ កុម្ភៈ ១៩៨០ កថាខណ្ឌ៤៦។*

**បន្ទុកនៃការបង្ហាញភស្តុតាង គឺជាបន្ទុករបស់ស្ថា-ប័នអយ្យការ៖** វិមតិសង្ស័យគួរបានជាប្រយោជន៍ដល់ជនជាប់ចោទ។

*រឿងក្តី BARBERÀ, MESSEGUÉ និងJABARDO ទល់ទៅនឹងប្រទេសអេស្ប៉ាញ តុលាការសិទ្ធិមនុស្សអឺរ៉ុប ៦ ធ្នូ ១៩៨៨ កថាខណ្ឌ៧៧។*

**មន្ត្រីសាធារណៈ ត្រូវគោរពគោលការណ៍សច្ចធារណ៍និរទោស៖** មន្ត្រីទាំងនេះមិនត្រូវធ្វើសេចក្តីថ្លែងការណ៍ណាដែលជំរុញឲ្យសាធារណជនជឿថា បុគ្គលម្នាក់មានពិរុទ្ធភាពនៅមុនពេល ដែលពិរុទ្ធភាពរបស់ជនជាប់ចោទពុំទាន់ ត្រូវបានបង្ហាញឲ្យឃើញត្រឹមត្រូវពីតុលាការនៅឡើយនោះទេ ជាពិសេសនៅពេលបុគ្គលម្នាក់ពុំទាន់ត្រូវបានចោទប្រកាន់ អំពីឧក្រិដ្ឋកម្មណាមួយនៅឡើយនោះ។

*រឿងក្តី BUTKEVIČIUS ទល់ទៅនឹងប្រទេសលីទុយនីយ៉ា តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ មីនា ២០០៣ កថាខណ្ឌ៥៣ (គោលការណ៍សច្ចធារណ៍និរទោស ដោយមន្ត្រីសាធារណៈ)។ រឿងក្តីALLENET DE RIBEMONT ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១០ កុម្ភៈ ១៩៩៥ កថាខណ្ឌ៤១ (សេចក្តីប្រកាសអំពីពិរុទ្ធភាព ដោយនគរបាល មុនពេលត្រូវបានចោទប្រកាន់ អំពីឧក្រិដ្ឋកម្ម)។ រឿងក្តី LAVENTS ទល់នឹងប្រទេសឡាតវីយ៉ា តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៨ វិច្ឆិកា ២០០២ កថាខណ្ឌ១២៥ (ពិរុទ្ធភាពត្រូវតែបង្ហាញឲ្យត្រឹមត្រូវដោយតុលាការ)។*

**ការរំលោភសិទ្ធិ ទទួលបានសច្ចធារណ៍និរទោសរបស់ជន ដែលត្រូវបានតុលាការសម្រេច ឲ្យរួចផុតពីបទចោទ៖** ពេលដែលតុលាការបង្គាប់ជននេះឲ្យចេញថ្លៃ នៃកិច្ចដំណើរការនីតិវិធី រួមទាំងឲ្យចេញសំណងរបស់រដ្ឋអាជ្ញាផង។

*រឿងក្តី MINELLI ទល់នឹងប្រទេសស្វីស តុលាការការសិទ្ធិមនុស្សអឺរ៉ុប ២៥ មីនា ១៩៨៣ កថាខណ្ឌ៣៦-៣៧។*

**ការផ្អែកលើវិមតិសង្ស័យ នៃពិរុទ្ធភាពរបស់បុគ្គល មានវិសមិតភាពទៅនឹងគោលការណ៍ សច្ចធារណ៍និរទោស៖** សិទ្ធិនៃសច្ចធារណ៍និរទោស ត្រូវបានរំលោភ នៅពេលដែលតុលាការ ផ្អែកលើសេចក្តីថ្លែងការណ៍ ដែលពាក់ព័ន្ធនឹងវិមតិសង្ស័យ នៃពិរុទ្ធភាពរបស់បុគ្គល ដើម្បីធ្វើការវាយតម្លៃដោយខ្លួនឯង អំពីពិរុទ្ធភាពនៅក្នុងរឿងក្តីក្រោយៗ ទោះបីជានៅក្រោយការសម្រេចឲ្យរួចផុត ពីបទចោទជាស្ថាពរហើយក៏ដោយ។

*រឿងក្តី SEKANINA ទល់នឹងប្រទេសអូទ្រីស តុលាការការសិទ្ធិមនុស្សអឺរ៉ុប ២៥ សីហា ១៩៩៣ កថាខណ្ឌ៣០។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៦។ មាត្រានេះចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌រួមទាំងសិទ្ធិរបស់ជន ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌក្នុងការទទួលបានសច្ចធារណ៍និរទោស រហូតដល់ពេលរកឃើញពិរុទ្ធភាពដោយអនុលោមតាមច្បាប់។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍ អំពីរបៀប ដែលមាត្រាស្រដៀងគ្នានៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់បំផុតនៃប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ការកំណត់កាលបរិច្ឆេទ ចេញសាលក្រមប្រកាសអំពីពិរុទ្ធភាព និងអំពីទោសប្រសិនបើមាន៖** អ្នកវិនិច្ឆ័យ និងតុលាការត្រូវធ្វើសេចក្តីសម្រេច នៅពេលដំណាលគ្នា។

*លេខ 08-85224 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៦ តុលាការកំពូលបារាំង ១១ កុម្ភៈ ២០០៩។ លេខ60-12917 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៧៩ តុលាការកំពូលបារាំង ១៨ តុលា ១៩-៦២។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា៣៦២ ៣៦៣ ៤៦៤ ៥៣៩ និងមាត្រា៥៤០។ មាត្រាទាំងនេះចែងអំពីសេចក្តីប្រកាសអំពីពិរុទ្ធភាព និងផលវិបាកដែលកើតចេញពីសេចក្តីប្រកាសទាំងនេះ។ (មាត្រា៣៦២ និងមាត្រា៣៦៣ នៅចំពោះមុខតុលាការព្រហ្មទណ្ឌមាត្រា៤៦៤ នៅចំពោះមុខតុលាការបទមជ្ឈិម និងមាត្រា៥៣៩ នៅចំពោះមុខតុលាការបទលហុ)។

# មាត្រា ៣៥៥៖ ការសម្រេចអំពីប្រយោជន៍ផ្នែករដ្ឋប្បវេណី

*នៅក្នុងសាលក្រមតែមួយ ជាមួយរឿងព្រហ្មទណ្ឌតុលាការសម្រេច អំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ តុលាការវិនិច្ឆ័យអំពីភាពអាចទទួលបាននៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសម្រេចអំពីពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ កាលណាតុលាការមិនទាន់អាចសម្រេចបាន លើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីទេ តុលាការអាចបង្គង់ទៅសវនាការលើកក្រោយ និងអាចសម្រេចឱ្យប្រាក់បណ្តោះអាសន្ន។*

*បុគ្គលដែលត្រូវផ្តន្ទាទោស ក្នុងបទល្មើសតែមួយជាមួយគ្នានោះត្រូវទទួលខុសត្រូវ ក្នុងការសងការខូចខាតដោយសាមគ្គីភាព។*

## ការអនុវត្តនៅអ.វ.ត.ក

**ព្យសនកម្មពុំចាំបាច់ដោយផ្ទាល់ទេ៖** ព្យសនកម្មដើម្បីជាគោលបំណង នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែ ជាលក្ខណៈបុគ្គល ក៏ប៉ុន្តែ វាពុំចាំបាច់កើតឡើង ដោយផ្ទាល់ទេ។

> *រឿងក្តីនួន ជា អៀងសារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីអ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៨៣។ រឿងក្តីឌុចសាលដីកា អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ៤១៨។ រឿងក្តីនួន ជា ខៀវ សំផន៖ សាលក្រមសំណុំរឿង០០២/០១ អ.វ.ត.ក អ.ជ.ស.ជ ៧ សីហា ២០១៤ កថខណ្ឌ១១៤៩-១១៥០។*

**ភាពជាជនរងគ្រោះ ខាងផ្លូវចិត្តត្រូវតែពិចរណាទៅតាមបរិបទ៖** ដើម្បីវាយតម្លៃព្យសនកម្មខាងផ្លូវចិត្ត សម្រាប់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី វាមានសារសំខាន់ ដែលត្រូវពិចារណាលើភាពរងគ្រោះ ទៅតាមបរិបទសង្គម និងវប្បធម៌នៅពេល ដែលឧក្រិដ្ឋកម្ម ដូចបានចោទប្រកាន់បានកើតឡើង។

> *រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៨៣ និងកថាខណ្ឌ ៨៦។*

**ព្យសនកម្ម ខាងផ្លូវចិត្តត្រូវបានសន្មតថា ជាអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើ អ្នកដាក់ពាក្យសុំមកពីក្រុមដែលជាគោលដៅ៖** នៅក្នុងករណី ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដូចជាអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលដែល

អ្នកដាក់ពាក្យសុំនោះ គឺជាជនរងគ្រោះដោយប្រយោល (ឧទាហរណ៍ សាក្សី ឬបុគ្គល ដែលបានដឹងអំពីឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់) ព្យសនកម្ម ខាងផ្លូវចិត្តត្រូវបានសន្មតថា បានកើតឡើងជាលក្ខណៈបុគ្គល ប្រសិនបើ អ្នកដាក់ពាក្យសុំនោះ ទំនងពុំមែនជាសមាជិកនៅក្នុងក្រុម ដែលជាគោលដៅ ឬសហគមន៍តែមួយ ដែលជាជនរងគ្រោះដោយផ្ទាល់នោះទេ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៩៣។*

**ព្យសនកម្មខាងផ្លូវចិត្ត៖** ព្យសនកម្មអាចរួមបញ្ចូលទាំងវិបល្លាសខាងស្មារតី ឬជំងឺផ្លូវចិត្តដូចជាជំងឺបាក់ស្បាត។

*រឿងក្តីឌុច៖ សាលក្រម អ.វ.ត.ក អ.ជ.ស.ជ ២៦ កក្កដា ២០១០ កថាខណ្ឌ៦៤១។ រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ ៨៣។*

**ភស្តុតាងនៃអត្តសញ្ញាណ មានលក្ខណៈអាចបត់បែន៖** វិធីសាស្រ្តបត់បែន ដែលត្រូវបានអនុវត្តចំពោះលក្ខខណ្ឌតម្រូវ ដែលអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនោះ បានបង្ហាញច្បាស់ អំពីអត្តសញ្ញាណរបស់ខ្លួន ឧទាហរណ៍ សេចក្តីប្រកាសពីប្រធានភូមិ ឬមេឃុំដែលចាស់ទុំ អាចទទួលយកបានជាភស្តុតាងនៃអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៩៥។*

**ហានិភ័យដែលបានទទួលរង ដោយដើមបណ្តឹងរដ្ឋប្បវេណីអាចរួមបញ្ចូលទាំងការរងទុក្ខវេទនារាងកាយ ក៏ដូចជារបួសផ្លូវចិត្ត៖** ការខាតបង់សេដ្ឋកិច្ច ការបាត់បង់សេចក្តីថ្លៃថ្នូរ និងទុក្ខព្រួយ ដែលកើតឡើង ពីការបាត់បង់សមាជិកគ្រួសារ ឬ ទំនាក់ទំនងជិតស្និទ្ធ ក៏អាចត្រូវបានចាត់ទុកជាហានិភ័យ ចំពោះដើមបណ្តឹងរដ្ឋបណ្តឹងរដ្ឋប្បវេណីផងដែរ។

*រឿងក្តីនួន ជា ខៀវ សំផន៖ សាលក្រម សំណុំរឿង ០០២/០១ អ.វ.ត.ក អ.ជ.ស.ជ ៧ សីហា ២០១៤ កថខណ្ឌ ១១៥០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន២៣ វិធាន២៣ស្ទួន និងវិធាន១០០។ វិធាន២៣ និងវិធាន២៣ស្ទួន នៃវិធានផ្ទៃក្នុងចែងអំពីលក្ខខណ្ឌលម្អិត ចំពោះការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី។ វិធាន១០០នៃវិធានផ្ទៃក្នុងស្រដៀងគ្នាទៅនឹងមាត្រា៣៥៥ លើកលែងតែករណី ដែលវិធាននេះចែងថា អង្គជំនុំជម្រះមិនត្រូវចេញសាលក្រមលើបណ្តឹងរដ្ឋប្បវេណីផ្ទុយនឹងសាលក្រមលើបណ្តឹងអាជ្ញា នៅក្នុងរឿងក្តីតែមួយនោះទេ។ វិធាន នេះផ្តល់ឆន្ទានុសិទ្ធិទូលាយដល់អង្គជំនុំជម្រះ ដើម្បីពន្យារការចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងទាមទារ របស់ដើមបណ្តឹងរដ្ឋប្បវេណីបានក្នុងករណីសមស្រប។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ការពិចារណារបស់ចៅក្រម នៅពេលសម្រេចលើបណ្តឹងរដ្ឋប្បវេណីនៅពេល ដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាព៖** ត្រូវតែអនុវត្តតាមគោលការណ៍នៃច្បាប់រដ្ឋប្បវេណីពាក់ព័ន្ធ។ ត្រូវសម្រេចក្នុងវិសាលភាព នៃសេចក្តីសន្និដ្ឋានដែលត្រូវបានដាក់ជូនចៅក្រម។

> *លេខ 75-91154 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៦៤ តុលាការកំពូលបារាំង ១៧ ឧសភា ១៩៧៦ (គោលការណ៍ នៃច្បាប់រដ្ឋប្បវេណីដែលពាក់ព័ន្ធ)។ លេខ 03-80039 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ១៧៣ តុលាការកំពូលបារាំង ៣០ កញ្ញា ២០០៣ (វិសាលភាពនៃសេចក្តីសន្និដ្ឋាន ដែលត្រូវបានធ្វើឡើង)។*

**ទំហំនៃសំណង សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី៖** ចៅក្រមមានអធិបតេយ្យ នៅក្នុងការវាយតម្លៃ និងសម្រេចអំពីទំហំនៃសំណង។

> *លេខ 65-93378 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៧៧ តុលាការកំពូលបារាំង ២៨ មិថុនា ១៩៦៦។*

**ការសម្រេចលើបណ្តឹងរដ្ឋប្បវេណី ក្រោយពីសម្រេចលើបណ្តឹងអាជ្ញា៖** តុលាការអាចធ្វើដូច្នេះបាន បើសិន ខ្លួនបានបម្រុងទុកអំណាច របស់ខ្លួនបែបនេះ នៅក្នុងសេចក្តីសម្រេច។

> *លេខ 92-82543 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ៨៧ តុលាការ កំពូលបារាំង ២៤ កុម្ភៈ ១៩៩៣។*

**តុលាការអាចផ្ទេររឿងក្តី ក្នុងករណី ដែលខ្លួនមិនអាចសម្រេចលើសំណើសុំសំណង នៅក្នុងពេលនោះបាន៖** សិទ្ធិផ្ទេររឿងក្តីនេះ ត្រូវបានធ្វើឡើង នៅក្នុងកាលបរិច្ឆេទមួយជាក់លាក់ ហើយតុលាការត្រូវកំណត់រយៈពេលមួយ ដែលរឿងក្តីនេះនឹងត្រូវបានកោះហៅឡើងវិញ។

*លេខ 77-90185 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៣៣ តុលាការកំពូលបារាំង ៧ វិច្ឆិកា ១៩៧៧។*

**ជនរងគ្រោះ ដែលបានទទួលសំណងសម្រាប់ការខូចខាត នៅក្នុងដំណាក់កាលសាលាដំបូង៖** ជនរងគ្រោះប្រភេទនេះ ពុំមានសិទ្ធិទៅចូលអន្តរាគមន៍ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ នៅចំពោះមុខតុលាការដែលទទួលរឿងក្ដីដែលបានផ្ទេរ។

*លេខ 87-90447 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៥៦ តុលាការកំពូលបារាំង ១៣ មេសា ១៩៨៨។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៣៧១ (តុលាការបទឧក្រិដ្ឋ) មាត្រា៤៦៤ (តុលាការបទមជ្ឈិម) និងមាត្រា៥៣៩ (តុលាការបទលហុ)។ មាត្រាទាំងនេះចែងអំពីនីតិវិធី សម្រាប់ចេញសាលក្រមលើសំណងរដ្ឋប្បវេណី។

# បណ្ដឹងឧទ្ធរណ៍

ផ្នែកនេះមានរួមបញ្ចូលសេចក្ដីពន្យល់បន្ថែមលើមាត្រានានា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា (ក្រម):

- មាត្រា ៣៧៥ បុគ្គលដែលអាចធ្វើបណ្ដឹងឧទ្ធរណ៍
- មាត្រា ៣៩៩ អានុភាពនៃបណ្ដឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ
- មាត្រា ៤០១ ការកំណត់ប្រភេទគតិយុត្តនៃអង្គហេតុជាថ្មីដោយសាលាឧទ្ធរណ៍
- មាត្រា ៤២៩ ការពន្យាររយៈពេលនៃការសរសេរសារណា
- មាត្រា ៤៣៦ សេចក្ដីសម្រេចលើបញ្ហាគតិយុត្ត
- មាត្រា ៤៥៣ ការសំអាងហេតុចំពោះសាលដីកា

# មាត្រា ៣៧៥៖ បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍

*អាចប្តឹងឧទ្ធរណ៍បានៈ*
*- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍*
*- ទណ្ឌិត*
*- ដើមបណ្តឹងរដ្ឋប្បវេណីចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី*
*- អ្នកទទួលខុសត្រូវរដ្ឋប្បវេណីចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី*

## *ការអនុវត្តនៅអ.វ.ត.ក*

សិទ្ធិរបស់ ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការធ្វើបណ្តឹងឧទ្ធរណ៍កម្រិតត្រឹម ផលប្រយោជន៍របស់ខ្លួននៅក្នុងបណ្តឹងរដ្ឋប្បវេណី តែប៉ុណ្ណោះ៖ ដើមបណ្តឹងរដ្ឋប្បវេណី ពុំមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ ឬអន្តរាគមន៍ ចំពោះការដាក់ទោសជនជាប់ចោទឡើយ។

*រឿងក្តីឌុចៈ ដំហររបស់ដើមបណ្តឹង រដ្ឋប្បវេណីស្តីពីការដាក់ទោស អ.វ.ត.ក អ.ជ.ស.ជ ៩ តុលា ២០០៩កថាខណ្ឌ២៨ កថាខណ្ឌ២៩ និងកថាខណ្ឌ៤០។*

ដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមាននៅក្នុងសាលក្រមស្ថាពរ របស់អង្គជំនុំជម្រះសាលាដំបូង៖ នៅក្នុងស្ថានភាពបែបនេះ សេចក្តីសម្រេចលើពាក្យសុំត្រូវបានគេពិចារណា ជាផ្នែកមួយនៃសាលក្រមស្ថាពរ។

*រឿងក្តីឌុចៈ ការសម្រេចលើឋានៈ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម អ.វ.ត.ក អ.ជ.ត.ក ៣០ កញ្ញា ២០១០ កថាខណ្ឌ៤-៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន១០៥ នៃវិធានផ្ទៃក្នុង។ វិធាននេះស្រដៀងគ្នាទៅនឹងមាត្រា៣៧៥ តែបានចែងលម្អិតទូលំទូលាយជាងនេះ អំពីនីតិវិធីក្នុងការប្តឹងឧទ្ធរណ៍។ វិធាន១០៥ ក៏កំរឹតផងដែរអំពីលទ្ធភាពរបសដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីប្តឹងឧទ្ធរណ៍ទាមទារសំណង ហើយប្រសិនបើ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានហាមប្រាមយ៉ាងប្រាកដពី ការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចក្តី។

# *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជាគឺជា ភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួនគឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**ទណ្ឌិតមានសិទ្ធិទទួលបាននូវសាលក្រម ជាលាយលក្ខណ៍អក្សរស្តីពីការសម្រេចឲ្យជាប់ពិរុទ្ធភាពដោយពុំមានការពន្យារពេលយូរ ដោយពុំសមហេតុផល៖** សម្រេចឲ្យជាប់ពិរុទ្ធភាពឡើយ។ វាជាការទទួលខុសត្រូវរបស់មន្រ្តីតុលាការ ក្នុងការផ្តល់សាលក្រមជាលាយលក្ខណ៍អក្សរ ពីព្រោះថា បើគ្មានសាលក្រមនេះទេ ជនជាប់ចោទមិនអាចអនុវត្តសិទ្ធិនូវស្នើសុំឲ្យសើរើបានឡើយ។ ការពន្យារពេលចំនួន៤៥ ថ្ងៃ នៅក្នុងការចេញសាលក្រម ជាលាយលក្ខណ៍អក្សរ គឺជាការពន្យារពេលពុំសមហេតុផល។

*រឿងក្តី PRATT និង MORGAN ទល់នឹងប្រទេសចាម៉ៃកា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៦ មេសា ១៩៨៩ កថាខណ្ឌ១៣.៤-១៣.៥។*

**ការខកខាន ក្នុងការជូនដំណឹងដល់ទណ្ឌិតអំពីសេចក្តីសម្រេច នៅក្នុងដំណាក់កាលសាលាដំបូង គឺជាការរំលោភមួយ៖** ការខកខានបែបនេះ គឺជាការបដិសេធយ៉ាងមានប្រសិទ្ធភាពលើសិទ្ធិរបស់បុគ្គល ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ទៅសាលាក្តីជាន់ខ្ពស់ ដើម្បីប្រឆាំងនឹងការសម្រេចឲ្យជាប់ពិរុទ្ធភាព។

*រឿងក្តី J.O. ទល់នឹងប្រទេសបារាំង គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ មីនា ២០១១ កថាខណ្ឌ៩.៧។*

**នៅពេលសម្រេចឲ្យជាប់ពិរុទ្ធភាពរួចហើយ បុគ្គលនេះមានសិទ្ធិទទួលបាន "ការវាយតម្លៃពេញលេញលើភស្តុតាង និងកិច្ចដំណើរការនៃការជំនុំជម្រះ"** នៅក្នុងដំណាក់កាលសាលាឧទ្ធរណ៍៖ នេះគឺរួមទាំងសិទ្ធិទទួលបានសវនាការ។ ការសើរើតាមផ្លូវតុលាការលើអង្គច្បាប់ពុំមានភាពគ្រប់គ្រាន់ឡើយ។

*រឿងក្តី DOMUKOVSKY និងជនផ្សេងទៀត ទល់នឹងប្រទេសហ្សកហ្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៦ មេសា ១៩៩៨ កថាខណ្ឌ១៨.១១។*

**ដើម្បីផ្តល់អានុភាពលើសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចឲ្យជាប់ពិរុទ្ធភាព របស់ជនជាប់ចោទនៅក្នុងបណ្តឹងព្រហ្មទណ្ឌ ទោសត្រូវឲ្យជនជាប់ចោទបានដឹង ដោយពុំមានការពន្យារពេល ពុំសមហេតុផល៖** គ្រប់ដំណាក់កាល នៃកិច្ចដំណើរការនីតិវិធីទាំងអស់គួរធ្វើឡើង ដោយពុំមានការពន្យារពេលដោយពុំសមហេតុផលឡើយ ទាំងនៅក្នុងដំណាក់កាលសាលាដំបូង និងនៅក្នុងដំណាក់កាលសាលាឧទ្ធរណ៍។

*រឿងក្តី PRATT និង MORGAN ទល់នឹងប្រទេសចាម៉ៃកា គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៦ មេសា ១៩៨៩ កថាខណ្ឌ១៣.៣។*

**កត្តាហានិភ័យ ដែលអាចប៉ះពាល់ដល់សិទ្ធិ របស់ជនជាប់ចោទក្នុងការទទួលបាន ការសើរើទោសឡើងវិញ៖** រួមទាំងកង្វះ នៃភាពមិនលម្អៀង នៅក្នុងតុលាការការពន្យារពេល ដោយពុំសមហេតុផល នៅក្នុងកិច្ចដំណើរការនីតិវិធីសាលាឧទ្ធរណ៍ និងការរំលោភសិទ្ធិទទួលបានការការពារក្តី។

*រឿងក្តី SOBHRAJ ទល់នឹងប្រទេសណេប៉ាល់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ កក្កដា ២០១០ កថាខណ្ឌ៧.៥។*

**សិទ្ធិទទួលបាននូវការសើរើ អំពីការសម្រេចឲ្យជាប់ពិរុទ្ធភាព ទាមទារលក្ខខណ្ឌថាសាលាដំបូង និងសាលាឧទ្ធរណ៍ចេញសាលក្រម/សាលដីកា ដោយមានសំអាងហេតុត្រឹមត្រូវ៖** នៅក្នុងករណី ដែលតុលាការពុំបានផ្តល់សំអាងហេតុ ចាំបាច់អំពីហេតុផល ដែលបណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធចោល នៅពេលនោះ ទណ្ឌិតត្រូវបានរារាំងមិនឲ្យអនុវត្តសិទ្ធិសើរើរឿងក្តី។

*រឿងក្តី ABOUSHANIF ទល់នឹងប្រទេសណ័រវេស៍ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៧ កក្កដា ២០០៨ កថាខណ្ឌ៧.២។*

**តុលាការដែលសើរើរឿងក្តី ត្រូវមានលទ្ធភាពពិនិត្យភាពគ្រប់គ្រាន់ នៃភស្តុតាង ដែលត្រូវបានបង្ហាញនៅក្នុងពេលជំនុំជម្រះ៖** ការសើរើរឿងក្តីនេះមិនត្រូវកំណត់ត្រឹមតែការផ្ទៀងផ្ទាត់ ថាតើភស្តុតាង ដែលត្រូវបានបង្ហាញ នៅក្នុងពេលជំនុំជម្រះ "ស្របឬពុំស្របច្បាប់" ប៉ុណ្ណោះទេ ប៉ុន្តែការសើរើនេះ គួរវាយតម្លៃលើភាពគ្រប់គ្រាន់នៃភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុផងដែរ។

*រឿងក្តី UCLES ទល់នឹងប្រទេសអេស្ប៉ាញ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២២ កក្កដា ២០០៩ កថាខណ្ឌ១១.៣។ រឿងក្តី KATSORA និងជនផ្សេងទៀត ទល់នឹងប្រទេសបេឡារូស គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៥ តុលា ២០១០ កថាខណ្ឌ៧.៣ និងរឿងក្តី GAYOSO MARTINEZ ទល់នឹងប្រទេសអេស្ប៉ាញ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១៩ តុលា ២០០៩ កថាខណ្ឌ៩.៣។*

**ការរំលោភបំពាន៖ ការធ្វើបត្យាប័ន ដោយរំលោភលើដីកាផ្អាកកិច្ចដំណើរការនីតិវិធី៖ ជនជាប់ចោទពុំមានលទ្ធភាពធ្វើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេច ប៉ះពាល់ដល់ផលប្រយោជន៍នេះ៖** នៅក្នុងករណីដែលជនជាប់ចោទត្រូវបានធ្វើបត្យាប័ន ទៅសហរដ្ឋអាមេរិក បើទោះជា មានដីកាផ្អាកកិច្ចដំណើរការនីតិវិធី ពីតុលាការរដ្ឋបាលក៏ដោយ នៅពេលនោះការរំលោភបានកើតឡើងហើយ។ ដូចគ្នានេះដែរ នៅពេលជនជាប់ចោទ ពុំមានលទ្ធភាពប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចប៉ះពាល់ដល់ផលប្រយោជន៍ របស់តុលាការតំបន់នោះក៏ជាការរំលោភមួយដែរ។

*រឿងក្តី WEISS ទល់នឹងប្រទេសអូទ្រីស គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣ មេសា ២០០៣ កថាខណ្ឌ ៩.៦។*

**សិទ្ធិទទួលបាននូវពេលវេលា និងឯកសារសមស្របសម្រាប់ការត្រៀមការពារខ្លួនអនុវត្ត នៅក្នុងអំឡុងពេល នៃកិច្ចដំណើរការនីតិវិធី លើបណ្តឹងឧទ្ធរណ៍៖** ទណ្ឌិតត្រូវមានលទ្ធភាព ពិនិត្យប្រតិចារឹក នៃការជំនុំជម្រះសាលក្រមរបស់សាលាដំបូង ដែលមាន

សំអាងហេតុត្រឹមត្រូវ និងឯកសារផ្សេងទៀតដែលមានសារសំខាន់សម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍។

*រឿងក្តី MENNEN ទល់នឹងប្រទេសហូឡង់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៧ កក្កដា ២០១០ កថាខណ្ឌ៨.២-៨.៤។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា២(៣) មាត្រា១៤(១)(គ) និងមាត្រា១៤(៥) ស្រដៀងគ្នាទៅនឹងមាត្រា៣៧៥ ដែលមាត្រានេះផ្តល់សិទ្ធិឲ្យទណ្ឌិតមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ទៅសាលាក្តីជាន់ខ្ពស់អនុលោមតាមច្បាប់។ លើសពីនេះមាត្រា២(៣) ការពារសិទ្ធិបុគ្គលក្នុងការទទួលបានសំណងដែលមានប្រសិទ្ធភាព និងអាចអនុវត្តបាន។ មាត្រា១៤(១) ការពារសិទ្ធិបុគ្គលក្នុងការទទួលបានសមភាព នៅចំពោះមុខតុលាការ និងសាលាក្តី និងមាត្រា១៤(៣)(គ) ការពារសិទ្ធិបុគ្គលក្នុងការទទួលបានការជំនុំជម្រះ ដោយពុំមានការពន្យារពេលដោយពុំសមហេតុផល។

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**រដ្ឋអនុញ្ញាតឲ្យមានស្វយ័តភាព នៅក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍ ប៉ុន្តែត្រូវផ្តល់យុត្តិកម្មតាមផ្លូវច្បាប់ ចំពោះការរិតត្បិតលើសិទ្ធិប្តឹងឧទ្ធរណ៍៖** ទោះបីជា រដ្ឋទទួលបានសេរីភាពដ៏ទូលំទូលាយ នៅក្នុងការរៀបចំនីតិវិធីបណ្តឹងឧទ្ធរណ៍ក៏ដោយ (ឧទាហរណ៍ មិនថាតើសាលាឧទ្ធរណ៍នឹងពិនិត្យតែបញ្ហាអង្គច្បាប់ ឬក៏ថាតើជនជាប់ចោទ ត្រូវស្នើសុំការអនុញ្ញាត ធ្វើបណ្តឹងឧទ្ធរណ៍បនោះទេ) ក៏ការរិតត្បិតណាមួយ លើសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ត្រូវផ្តល់យុត្តិកម្ម ទៅតាមគោលបំណងច្បាប់ដែរ។

*រឿងក្តី KROMBACH ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៣ កុម្ភៈ ២០០១ កថាខណ្ឌ៩៦។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា២នៃពិធីសារទី៧។ មាត្រានេះចែងអំពីសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ នៅក្នុងបញ្ហាព្រហ្មទណ្ឌ រួមទាំងការលើកលែងចំពោះអញ្ញត្រកម្មពាក់ព័ន្ធនឹងបទល្មើសតូចតាច និងដូចមានចែងនៅក្នុងច្បាប់។

*តុលាការកំពូលបារាំង*

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**អានុភាព នៃបណ្តឹងសាទុក្ខ របស់ជនជាប់ចោទប្រឆាំង លើផ្នែកព្រហ្មទណ្ឌមិនមែន លើផ្នែករដ្ឋប្បវេណីក្នុងសេចក្តីសម្រេច៖** ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យ ដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចមួយ ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ស៊ីវិលរបស់ខ្លួនទេ។

*លេខ 02-80003 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១០ តុលាការកំពូលបារាំង ២៣ មករា ២០០២។*

**បណ្តឹងសាទុក្ខ ប្រឆាំងទៅនឹងសេចក្តីសម្រេចលើកលែងការចោទប្រកាន់៖** បណ្តឹងនេះ ត្រូវបានបើកចំហរចំពោះតែអគ្គរដ្ឋអាជ្ញាប៉ុណ្ណោះ។ កាលណាអគ្គរដ្ឋអាជ្ញា មិនដាក់នូវបណ្តឹងសាទុក្ខបែបនេះទេ បណ្តឹងសាទុក្ខនោះត្រូវបានបើកចំហរ ចំពោះភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលមានការទាក់ទង តែនឹងការទាមទារផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ។

*លេខ 02-84335 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៤៥ តុលាការកំពូលបារាំង ២៦ មិថុនា ២០០២ (បើកចំហរចំពោះតែអគ្គរដ្ឋអាជ្ញាប៉ុណ្ណោះ) ។ DA.លេខ 108-68-90940 តុលាការកំពូលបារាំង ២៦ មករា ១៩៤២ (បណ្តឹងទាមទារផ្នែករដ្ឋប្បវេណី)។*

**ការដាក់បណ្តឹងសាទុក្ខ ដោយអគ្គរដ្ឋអាជ្ញា៖** អាចត្រូវបានដាក់ដោយអគ្គរដ្ឋអាជ្ញាផ្ទាល់ ឬតាមរយៈអ្នកទទួលសិទ្ធិណាម្នាក់ ក្នុងចំណោមអ្នកទទួលសិទ្ធិរបស់អគ្គរដ្ឋអាជ្ញា។

*លេខ 03-87030 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២២៣ តុលាការកំពូលបារាំង ២៦ វិច្ឆិកា ២០០៣។*

**បញ្ជីឈ្មោះបុគ្គល ដែលត្រូវបានអនុញ្ញាតឲ្យដាក់នូវបណ្តឹងសាទុក្ខ៖** បញ្ជីឈ្មោះនេះ គឺជាបញ្ជីឈ្មោះមួយ ដែលមានការកំណត់ព្រំដែន។

*លេខ 83-94291 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១២ តុលាការកំពូលបារាំង ១០ មករា ១៩៨៤។*

**នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចទទួលយកបណ្តឹង ដោយផ្អែកលើមូលដ្ឋានតែមួយគត់ថា បណ្តឹងនេះ មានការទាក់ទងទៅនឹងបទល្មើសមជ្ឈិមមួយចំនួន៖** អង្គជំនុំជម្រះអាចនឹងពិនិត្យគ្រប់បណ្តឹងទាំងអស់ ជាមួយគ្នាតែម្តង ហើយធ្វើការសង្ខេប ពីប្រាក់ពិន័យនៅក្នុងគោលបំណង ដើម្បីសម្រេចថាតើភាគីមានសិទ្ធិ ក្នុងការប្តឹងសាទុក្ខដែរ ឬមួយក៏គ្មានទេ។

*D. 1949 លេខ៤២១ តុលាការកំពូលបារាំង ៥ ឧសភា ១៩៤៩។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៣៨០.២ ៤៧៩ និង៥៤៦។ មាត្រាទាំងនេះចែងអំពីបុគ្គល ដែលមានសិទ្ធិប្ដឹងសាទុក្ខលើសេចក្ដីសម្រេច ដែលបានចេញដោយសាលាឧក្រិដ្ឋ (Assize Court) (មាត្រា៣៨០.២) ដោយសាលាលហុ (Correctional Court) (មាត្រា៣៨០.២) និងតុលាការនគរបាល ឬតុលាការថ្នាក់ខណ្ឌ/ស្រុក (Police or Neighborhood Court) (មាត្រា៣៨០.២) ។

# មាត្រា ៣៩៩៖ អានុភាពនៃបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ

*សាលាឧទ្ធរណ៍ កាលណាបានទទួលបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ មិនអាចដាក់ទម្ងន់ទោសជននោះទេ។ តុលាការអាចកែប្រែសាលក្រមបាននៅក្នុងន័យ ដែលអនុគ្រោះដល់ជននេះតែប៉ុណ្ណោះ។ សាលាឧទ្ធរណ៍មិនអាចបន្ថែមទោសបន្ថែមពីលើមូលទោសបានទេ។*

*សាលាឧទ្ធរណ៍អាចជំនួសឈ្មោះបទល្មើស ដែលកំណត់ដោយតុលាការជាន់ដំបូង ដោយឈ្មោះបទល្មើសមួយទៀតបាន ប៉ុន្តែមិនអាចដាក់ទម្ងន់ទោសលើជនជាប់ចោទនេះទេ។*

*ប្រសិនបើ តុលាការជាន់ដំបូងភ្លេចប្រកាសទោសបន្ថែមណាមួយ ដែលដាច់ខាតត្រូវតែប្រកាស នោះសាលាឧទ្ធរណ៍បដិសេធសាលក្រម ហើយសម្រេចអំពីទោសជាថ្មីម្តងទៀត។*

*កាលណាបានទទួលបណ្តឹងតែពីជនជាប់ចោទ ប៉ុណ្ណោះសាលាឧទ្ធរណ៍មិនអាចបន្ថែមចំនួនទឹកប្រាក់សម្រាប់ជួសជុលការខូចខាតឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ។*

## ការអនុវត្តនៅអ.វ.ត.ក

**អលទ្ធភាពក្នុងការរកទឡ្ហីករណ៍ បន្ថែមសម្រាប់ការឃុំខ្លួននៅក្នុងបណ្តឹងសាទុក្ខទេ៖** តុលាការឧទ្ធរណ៍មិនអាចប្រើឱកាស សម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដែលដាក់ដោយជនត្រូវចោទ ដើម្បីរកទឡ្ហីករណ៍បន្ថែមសម្រាប់ការឃុំខ្លួនដូច្នោះទេ ខណៈដែលបណ្តឹងសាទុក្ខត្រូវគេបានកម្រិតត្រឹមតែទឡ្ហីករណ៍ សម្រាប់ការឃុំខ្លួនដែលត្រូវសំអាងលើសេចក្តីសម្រេច របស់តុលាការដំបូងប៉ុណ្ណោះ។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខភ្នាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៥២។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន១១០.៣ និង១១០.៤។ វិធានទាំងនេះគឺស្រដៀងគ្នាទៅនឹងមាត្រា៣៩៩ លើកលែងតែនៅក្នុងវិធាន១១០.៣បានចែងផងដែរថា អង្គជំនុំជម្រះមិនត្រូវបង្កើនសំណងខូចខាតដល់ជនត្រូវចោទឡើយ ប៉ុន្តែវិធាន១១០.៤ បានចែងថាអង្គជំនុំជម្រះអាចសម្រេចពីអនុទោសចាំបាច់ដែលអង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេច ដោយមិនបានចែងថា ត្រូវប្រកាសបដិសេធសាលក្រមឲ្យបានដូចដែលបានចែងនៅក្នុងមាត្រា៣៩៩នោះទេ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ការរំលោភបំពាន៖ ការបន្ថែមទម្ងន់ទោស ក្នុងបណ្ដឹងសាទុក្ខ៖** សេចក្ដីសម្រេច របស់សាលាព្រហ្មទណ្ឌលើបណ្ដឹងសាទុក្ខ ដែលបានដាក់ជំនួសទោសជាប់ពន្ធនាគារមួយជីវិត ដោយទោសជាប់ពន្ធនាគារ៣០ឆ្នាំ និងការបង្កើនការដាក់ទោស ជារួមមានការខាតបង់សិទ្ធិ និងករណីយកិច្ចរបស់ពលរដ្ឋ និងគ្រួសារចំនួន១០ឆ្នាំត្រូវបានគេពិចារណា ថាជាការបន្ថែមទម្ងន់ទោស និងជាការខុសច្បាប់។

*លេខ 02-85064 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៧៨ តុលាការកំពូលបារាំង ២៦ មីនា ២០០៣។*

**ការរំលោភបំពាន៖ ការពន្យារពេលទាំងមូលនៃទោសក្នុងបណ្ដឹងសាទុក្ខក្នុងករណីបទល្មើសមជ្ឈិម៖** លើសពីនេះទៀត នៅក្នុងបណ្ដឹងសាទុក្ខស្ដីពីការព្យួរទោស គឺជាការបន្ថែមនូវទម្ងន់ទោស កាលណារយៈពេលទាំងមូលនៃទោសត្រូវបានគេពន្យារ ដោយប្រៀបធៀបទៅនឹងសេចក្ដីសម្រេចនៅសាលាដំបូង។

*លេខ 01-82335 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៤២ តុលាការកំពូលបារាំង ២១ វិច្ឆិកា ២០០១។ លេខ 68-90940 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ១៩៣ តុលាការកំពូលបារាំង ១៣ មិថុនា ១៩៦៨។*

**សាលាឧទ្ធរណ៍មិនបន្ថែមស្ថានទម្ងន់ លើជនជាប់ចោទទេ កាលណាខ្លួនបានប្ដូរពីការព្យួរទោសឲ្យទៅជាការព្យួរទោសសាកល្បង៖** ការកែតម្រូវបែបនេះគឺគ្រាន់តែពាក់ព័ន្ធទៅ និងការអនុវត្តទោសប៉ុណ្ណោះ មិនមែនពី រយៈពេលនៃទោសនោះទេ។

*លេខ 01-84625 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៧៨ តុលាការកំពូលបារាំង ៤ មេសា ២០០២។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៣៨០.៣ ៣៨០.៦ និង៥១៥។ មាត្រាទាំងនេះចែងអំពីអានុភាពនៃបណ្ដឹងឧទ្ធរណ៍របស់ពីជនជាប់ចោទប៉ុណ្ណោះ ដោយរួមទាំងអលទ្ធភាពរបស់តុលាការក្នុងការទទួលបណ្ដឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ ដើម្បីធ្វើការប្រកាសពីទោសមួយដែលធ្ងន់ជាងទោស មួយទៀតដែលបានប្រកាសនៅសាលាដំបូង។

# មាត្រា ៤០១៖ ការកំណត់ប្រភេទគតិយុត្តនៃអង្គហេតុជាថ្មី ដោយសាលាឧទ្ធរណ៍

*សាលាឧទ្ធរណ៍អាចកែប្រែប្រភេទគតិយុត្ត នៃអង្គហេតុដែលសាលាដំបូងបានកំណត់តែមិនត្រូវបន្ថែមធាតុថ្មីណាមួយ ដែលមិនបានដាក់ជូនតុលាការជាន់ដំបូងសម្រេចនោះទេ។*

## *ការអនុវត្តនៅអ.វ.ត.ក*

អាចដាក់សំអាងហេតុជំនួស ក៏ប៉ុន្តែ ចំពោះតែបញ្ហាដែលត្រូវបានគេប្ដឹងសាទុក្ខ និងកាលណាមានការរកឃើញអង្គហេតុ ដែលផ្ដល់លទ្ធភាពឲ្យធ្វើការកែតម្រូវបានតែប៉ុណ្ណោះ៖ សាលាក៏ឧទ្ធរណ៍អាចដាក់សំអាងហេតុ របស់ខ្លួនជំនួសឲ្យសំអាងហេតុ ដែលមានកំហុសក្នុងសេចក្ដីសម្រេចរបស់តុលាការជាន់ទាប ប៉ុន្តែអាចធ្វើបែបនេះបាន តែនៅពេលដែល បញ្ហានោះត្រូវបានប្ដឹងសាទុក្ខ និងដែលអាចមានការរកឃើញអង្គហេតុ ដែលផ្ដល់លទ្ធភាពឲ្យធ្វើការកែតម្រូវនេះតែប៉ុណ្ណោះ។

*រឿងក្ដីខៀវ សំផន៖ បណ្ដឹងសាទុក្ខភ្លាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៥២។*

**អលទ្ធភាព ក្នុងការរកទឡ្ហីករណ៍បន្ថែម សម្រាប់ការឃុំខ្លួន នៅក្នុងបណ្ដឹងសាទុក្ខទេ៖** សាលាឧទ្ធរណ៍គឺមិនអាចប្រើឱកាស សម្រាប់បណ្ដឹងសាទុក្ខប្រឆាំង ទៅនឹងដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន ដែលដាក់ដោយជនត្រូវចោទ ដើម្បីរកទឡ្ហីករណ៍បន្ថែម សម្រាប់ការឃុំខ្លួនដូច្នោះទេ ខណៈ ដែលបណ្ដឹងសាទុក្ខត្រូវបានគេកម្រិតត្រឹមតែទឡ្ហីករណ៍ សម្រាប់ការឃុំខ្លួនដែលត្រូវសំអាងទៅលើសេចក្ដីសម្រេច របស់តុលាការជាន់ដំបូងប៉ុណ្ណោះ។

*រឿងក្ដីខៀវ សំផន៖ បណ្ដឹងសាទុក្ខភ្លាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៥២។*

**បទដ្ឋានសម្រាប់ធ្វើការពិនិត្យឡើងវិញភាពសមស្រប៖** តុលាការត្រូវអនុវត្តនូវបទដ្ឋាន ស្ដីពីភាពសមហេតុសមផល ក្នុងការពិនិត្យឡើងវិញនូវបញ្ហាអង្គច្បាប់ ដែលតុលាការជំនុំជម្រះបានអនុវត្តមិនមែនពិនិត្យ លើបញ្ហាអង្គហេតុនោះថា ជាការត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះទេ។ សេចក្ដីគោរពដ៏ធំធេងត្រូវបានប្រគល់ ជូនទៅតុលាការជំនុំជម្រះ ដែលជាការរកឃើញនូវការពិតរបស់ខ្លួនមិនគួរត្រូវបានរំខាន សូម្បីតែតិចតួចក៏ដោយ។ ជាទូទៅ សាលាឧទ្ធរណ៍អាចដាក់ការរកឃើញ របស់ខ្លួនមកជំនួសបាន តែក្នុងករណី ដែលគ្មានការវិនិច្ឆ័យលើអង្គហេតុដ៏សមហេតុផល ដែលបានទទួលយកនូវភស្តុ-

តាងដែលពាក់ព័ន្ធ ឬតែក្នុងករណីដែលការរកឃើញនោះ មានកំហុសទាំងស្រុងប៉ុណ្ណោះ។

*រឿងក្ដីឧបចះ សាលដីកា លើបណ្ដឹងសាទុក្ខ អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ១៧។*

**ការដាក់ពិរុទ្ធភាព ពីឧក្រិដ្ឋកម្មច្រើនជំនួសពិរុទ្ធភាពពីឧក្រិដ្ឋកម្មទោល៖** អង្គជំនុំជម្រះតុលាការកំពូលបានដាក់ជំនួស នូវការសម្រេចទោសពីឧក្រិដ្ឋកម្មទោល របស់អង្គជំនុំជម្រះសាលាដំបូងដោយការសម្រេចទោស ពីឧក្រិដ្ឋកម្មខុសៗគ្នាចំនួនប្រាំមួយ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានសម្រេចថា អង្គជំនុំជម្រះ សាលាដំបូងមានកំហុស ក្នុងការស្រូបបញ្ចូលឧក្រិដ្ឋកម្មបន្ថែមចំនួនប្រាំ ទៅក្នុងឧក្រិដ្ឋកម្មមូលដ្ឋាន ខណៈ ដែលឧក្រិដ្ឋកម្មនីមួយៗ ក្នុងចំណោមឧក្រិដ្ឋកម្មបន្ថែមទាំងប្រាំនោះ គឺមានធាតុផ្សំសំខាន់មួយផ្សេងទៀត ដែលខុសពីឧក្រិដ្ឋកម្មមូលដ្ឋាន និងខណៈដែលមានការចាំបាច់ត្រូវធ្វើការដោះស្រាយ ដាច់ដោយឡែកពីការខូចខាត ចំពោះផលប្រយោជន៍ សង្គមខុសៗគ្នាតាមរយៈការសម្រេចទោស ដាច់ដោយឡែកពីគ្នា។

*រឿងក្ដីឧបចះ សាលដីកា លើបណ្ដឹងសាទុក្ខ អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ៣៣១ និង៣៣៥-៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន១១០.២។ វិធាននេះគឺស្រដៀងគ្នាទៅនឹងមាត្រា៤០១។

# មាត្រា ៤២៩៖ ការពន្យាររយៈពេលនៃការសរសេរសារណា

*កាលណារយៈពេល២០ (ម្ភៃ) ថ្ងៃនេះមិនគ្រប់គ្រាន់ទេភាគីអាចសុំទៅ ដល់ប្រធានសភាព្រហ្ម-ទណ្ឌឱ្យពន្យារពេល។ ការពន្យារពេលនេះមិនអាចលើសពី១០ (ដប់) ថ្ងៃទេ។*

## ការអនុវត្តនៅ អ.វ.ត.ក

សំណើសុំពន្យារពេលដាក់ឯកសារ នៅក្រោយកាលបរិច្ឆេទកំណត់៖ តាមធម្មតាសំណើបែបនេះមិនត្រូវបានអនុញ្ញាតទេ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ សំណើសុំពន្យារពេល អ.វ.ត.ក អ.ជ.ស.ជ ៩ មិថុនា២០១១ ទំព័រ២។*

ការសុំពន្យារពេល ដើម្បីដាក់ឯកសារ និងបញ្ជីភស្តុតាងចំនួន១៥ថ្ងៃ ត្រូវបានអនុញ្ញាត កាលណាមានសំណើសុំជាបន្ទាន់ និងមិនបង្កឲ្យមានការខូចប្រយោជន៍របស់ភាគី៖ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាត ឲ្យមានការពន្យារពេលបែបនេះខណៈ ដែលមេធាវីការពារក្តីបានដាក់សំណើសុំពន្យារពេល ជាបន្ទាន់ដែលពេលវេលាសំខាន់ៗ មួយចំនួនដែលកំណត់ អំពីការដាក់ឯកសារស្ថិតនៅក្នុងកាលបរិច្ឆេទ មុនការពន្យារពេល និងដែលមិនបង្កឲ្យមានការខូចដល់ប្រយោជន៍របស់ភាគី។

*រឿងក្តីអៀង សារី៖ សំណើសុំពន្យារពេល អ.វ.ត.ក អ.ជ.ស.ជ ២៧ កក្កដា ២០១១ ទំព័រ២។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៣៩។ វិធាន៣៩នៃវិធានផ្ទៃក្នុងគឺស្រដៀងគ្នាទៅនឹងមាត្រា៤២៩ លើកលែងតែវិធាននេះបានអនុញ្ញាតឲ្យចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះធ្វើការពន្យារពេលវេលាកំណត់ដែលខ្លួនបានសម្រេច និងអនុញ្ញាតឲ្យពន្យារពេលវេលាកំណត់ ទៅតាមឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។

# មាត្រា ៤៣៦៖ សេចក្ដីសម្រេចលើបញ្ហាគតិយុត្ត

*តុលាការកំពូលត្រូវសម្រេចលើបញ្ហាច្បាប់ ដែលលើកឡើងដោយអ្នកប្ដឹងសាទុក្ខ និងដែលមានរៀបរាប់នៅក្នុងសារណា។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**បទដ្ឋានសម្រាប់អង្គជំនុំជម្រះ តុលាការកំពូលធ្វើការពិនិត្យសាជាថ្មី៖** ក្នុងឋានៈជាតុលាការសាលាឧទ្ធរណ៍ចុងក្រោយ អង្គជំនុំជម្រះរបស់តុលាការកំពូល ធ្វើការពិនិត្យលើសេចក្ដីសម្រេចរបស់តុលាការជាន់ទាប នៅលើមូលដ្ឋាននៃបណ្ដឹងសាទុក្ខ និងដោយស្របទៅនឹងសេចក្ដីណែនាំ សម្រាប់ធ្វើបណ្ដឹងសាទុក្ខ។

*រឿងក្ដីខៀវ សំផន៖ បណ្ដឹងសាទុក្ខភ្លាមៗ លើសំណើសុំឲ្យដោះលែង អ.វ.ត.ក អ.ជ.ត.ក ៦ មិថុនា ២០១១ កថាខណ្ឌ៤២។*

**គុណភាព នៃសេចក្ដីថ្លែងសំអាង៖** សេចក្ដីថ្លែងសំអាង ជាលាយលក្ខណ៍អក្សរអាចនឹងមិនទទួលយកបានទេ ផ្អែកតាមមូលដ្ឋាននីតិវិធី ដោយមកពីភាពមិនទាក់ទងគ្នា ឬមកពីការគ្មានភាពជាក់លាក់។ បញ្ហា ដែលត្រូវធ្វើការសម្រេចនោះ គឺ ថាតើដើមបណ្ដឹងសាទុក្ខ បានថ្លែងសំអាងលើរឿងក្ដីរបស់ខ្លួន ទៅតាមរបៀបមួយ ដែលអាចធ្វើឲ្យភាគីបដិបក្ខ យល់បានអំពីករណីដែលខ្លួនចង់បាននោះដែរឬទេ និងដែលអាចធ្វើឲ្យអង្គជំនុំជម្រះធ្វើការកំណត់ និងសម្រេចលើបញ្ហា នៅក្នុងទំនាស់នោះបានដែរឬទេ។ ការណ៍នេះ គឺអាស្រ័យទៅលើកាលៈទេសៈ ជាពិសេស លើចរិតនៃការតវ៉ាសុំឲ្យធ្វើការវិនិច្ឆ័យសម្រេចសេចក្ដី។

*រឿងក្ដីឌុចៈ សាលដីកា លើបណ្ដឹងសាទុក្ខ អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ៤២។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន១១០.១។ វិធាននេះគឺស្រដៀងគ្នាទៅនឹងមាត្រា៤៣៦។

# *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្ដីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**រដ្ឋមានព្រំដែនយ៉ាងទូលាយ ក្នុងការពិចារណា ដើម្បីធ្វើការកំណត់ ថាតើខ្លួនត្រូវអនុវត្តយ៉ាងដូចម្ដេចក្នុងការពិនិត្យឡើងវិញពីបញ្ហាគតិយុត្ត នៅក្នុងយុត្តាធិការរបស់ខ្លួន៖** រាល់ការកម្រិតត្រូវតែស្របច្បាប់ និងមិនត្រូវរំលោភលើសិទ្ធិក្នុងការពិនិត្យអង្គហេតុ និងអង្គច្បាប់ឡើងវិញ ឬមួយក៏ពិនិត្យតែលើអង្គច្បាប់ប៉ុណ្ណោះទេ។

*រឿងក្ដី KROMBACH ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៣ កុម្ភៈ ២០០១ កថាខណ្ឌ៩៦។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មាត្រា២នៃឯកសារពិធីការទី៧។ មាត្រានេះចែងអំពីសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍លើបញ្ហាព្រហ្មទណ្ឌ រួមទាំងទឡ្ហីករណ៍ផ្សេងៗ ដែលគេអាចអនុវត្តបានតាមច្បាប់។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**បណ្ដឹងទៅតុលាការកំពូល មានសុពលភាពទៅបានលុះត្រាតែបណ្ដឹងនោះ ត្រូវបានដាក់ប្រឆាំងនឹងការរំលោភខ្លាំងទៅលើច្បាប់ប៉ុណ្ណោះ៖** អានុភាពនេះមិនគិតពីភាគី ដែលដាក់បណ្ដឹងទេ។

*លេខ 81-93489 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៦៩ តុលាការកំពូលបារាំង ២៩ វិច្ឆិកា ១៩៨២។*

**ត្រូវតែដាក់ពាក្យបណ្ដឹង ប្រឆាំងនឹងសាលដីកា ដែលបានចេញដោយតុលាការជាន់ខ្ពស់៖** បើមិនដូច្នោះទេបណ្ដឹងទៅតុលាការកំពូល គឺមិនអាចទទួលយកបានឡើយ។

*លេខ 05-84275 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៤០ តុលាការកំពូលបារាំង ២៨ កញ្ញា ២០០៥។*

**មានតែភាគីនៅក្នុងសាលដីកា នៃតុលាការជាន់ខ្ពស់ប៉ុណ្ណោះដែលមានសិទ្ធិដាក់បណ្ដឹង៖** ភាគីទាំងនោះអាចដាក់បណ្ដឹងទៅតុលាការកំពូល ឬធ្វើអន្តរាគមន៍នៅចំពោះមុខតុលាការកំពូល។

*លេខ 68-93573 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៨១ តុលាការកំពូលបារាំង ៤ វិច្ឆិកា ១៩៦៩។*

**ពេលវេលា ដែលភាគីដើមបណ្ដឹងរដ្ឋប្បវេណីដាក់បណ្ដឹងទៅតុលាការកំពូល៖** គឺដើម្បីប្រឆាំងនឹងការបដិសេធដោយលម្មៀង ចំពោះប្រយោជន៍រដ្ឋប្បវេណីរបស់ខ្លួន។

*លេខ 78-93482 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៦៨ តុលាការកំពូលបារាំង ២ មិថុនា ១៩-៨០។ ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ៤៧ តុលាការកំពូលបារាំង ៩ កុម្ភៈ ១៩២៦។*

**បណ្ដឹងទៅតុលាការកំពូល ដោយរដ្ឋអាជ្ញា៖** រដ្ឋអាជ្ញាអាចដាក់បណ្ដឹង ទៅតុលាការកំពូលបាន ដើម្បីប្រឆាំងនឹងសេចក្ដីសម្រេច ធ្វើមោឃភាពណាមួយ ដែលនឹងរកទៅឃើញថា មិនស្របច្បាប់។ បណ្ដឹងរបស់ពួកគេដែលត្រូវតែទទួលយក គឺមានតែបណ្ដឹងប្រឆាំងទៅនឹងសេចក្ដីសម្រេច ដែលធ្វើឲ្យខូចផលប្រយោជន៍សាធារណៈប៉ុណ្ណោះ។

*លេខ 62-92075 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៦៨ តុលាការកំពូលបារាំង ២០ តុលា ១៩-៦៤ (អាចដាក់ប្រឆាំងទៅនឹងសេចក្ដីសម្រេចធ្វើមោឃភាពណាមួយក៏ដោយ)។ ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ២៥៤ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ២០ មិថុនា ១៩៤៦ (សេចក្ដីសម្រេចដោយលម្មៀង ចំពោះផលប្រយោជន៍សាធារណៈ)។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៥៦៧ និង៥៩១។ មាត្រាទាំងនេះចែងអំពីការដាក់បណ្ដឹងទៅតុលាការកំពូលរួមទាំងការចែងថា តុលាការកំពូលអាចត្រូវបានលើកឡើងពីការរំលោភច្បាប់តែប៉ុណ្ណោះ។

# មាត្រា ៤៥៣៖ ការសំអាងហេតុចំពោះសាលដីកា

*សាលដីកាត្រូវតែមានសំអាងហេតុ។ សាលដីកានេះត្រូវប្រកាសនៅពេលសវនាការជាសាធារណៈ។*

## ការអនុវត្តនៅ អ.វ.ត.ក

**ការចេញសេចក្តីសម្រេច និងសំអាងហេតុផ្សេងពីគ្នាអាចមិនមែនជាការរំលោភទេ៖** បញ្ហាថាតើការចេញសេចក្តីសម្រេច ជាមុនរបស់អង្គជំនុំជម្រះ ហើយសំអាងហេតុ តាមក្រោយបង្កើតបានជាការរំលោភ លើដំណើរការនីតិវិធីឬយ៉ាងណានោះ ត្រូវបានគេយល់ឃើញថា លុះត្រាណាតែ ទាំងសេចក្តីសម្រេច និងទាំងសំអាងហេតុត្រូវបានគេចេញ នៅក្រោយរយៈពេល ដែលត្រូវអនុញ្ញាត ដោយអនុលោមតាមវិធានផ្ទៃក្នុងតែប៉ុណ្ណោះ ទើបបង្កើតបានជាការរំលោភលើដំណើរការនីតិវិធី។ បើទាំងសេចក្តីសម្រេច និងសំអាងហេតុត្រូវបានចេញ នៅក្នុងរយៈពេល ដែលបានអនុញ្ញាត បញ្ហាស្តីពីភាពផ្សេងពីគ្នានោះ គឺមិនអាចលើកមកតវ៉ាបានទេ។

*រឿងក្តីនួន ជា និងអៀង ធីរិទ្ធ៖ បណ្តឹងសាទុក្ខភ្លាមៗលើសំណើសុំឲ្យដោះលែង ជាបន្ទាន់ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ៣១។*

**សិទ្ធិទទួលបានការសម្រេចសេចក្តី ដែលមានសំអាងហេតុ នេះគឺជាសិទ្ធិជាមូលដ្ឋាន៖** វិសាលភាពនៃកាតព្វកិច្ច នៅក្នុងការផ្តល់នូវហេតុផលផ្សេងៗគ្នា គឺអាស្រ័យទៅតាមប្រភេទ នៃការសម្រេចសេចក្តី ហើយត្រូវតែសម្រេចទៅតាមស្ថានភាពនៃរឿងក្តី។

*រឿងក្តីខៀវ សំផន៖ បណ្តឹងសាទុក្ខលើសំណើជាបន្ទាន់សុំឱ្យមានការដោះលែងភ្លាមៗ អ.វ.ត.ក អ.ជ.ត.ក ២២ សីហា ២០១៣ កថាខណ្ឌ៣០។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន១០១ និង១១១។ វិធាន១០១អនុវត្តចំពោះអង្គជំនុំជម្រះសាលាដំបូង (ប៉ុន្តែ អនុវត្តចំពោះអង្គជំនុំជម្រះតុលាការកំពូលតាមរយៈវិធាន១១១នៃវិធានផ្ទៃក្នុង) គឺស្រដៀងគ្នាទៅនឹងមាត្រា ៤៥៣ លើកលែងតែវាបានបញ្ជាក់យ៉ាងច្បាស់លាស់ថា សំអាងហេតុត្រូវតែមានរួមទាំងសំអាង ហេតុខាងអង្គហេតុ និងទាំងខាងអង្គច្បាប់។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ចរិតជាសាធារណៈ នៃសវនាការគឺជាសិទ្ធិជាសារវ័ន្ត ក្នុងការទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌៖** ទោះបីជាយ៉ាងណាក៏ដោយ គោលការណ៍នេះមិនមានលក្ខណៈដាច់ខាតទេ ហើយសវនាការអាចត្រូវបានធ្វើឡើងជាសម្ងាត់ ក្នុងគោលបំណងដើម្បីការពារជីវិតឯកជន ឬផលប្រយោជន៍នៃយុត្តិធម៌។

*រឿងក្តី DIENNET ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ កញ្ញា ១៩៩៥ កថាខណ្ឌ៣៣។*

**ការប្រកាសជាសាធារណៈ មិនត្រូវបានគេបកស្រាយឲ្យបានសុក្រឹត្យ តាមអង្គហេតុឡើយ៖** វាមិនចាំបាច់មានន័យថា សាលក្រមត្រូវតែអានឲ្យឮនោះឡើយ។ រដ្ឋជាច្រើនងាកមកប្រើការចុះបញ្ជីនៅកន្លែង ដែលសាធារណជនអាចចូលមើល សេចក្តីសម្រេចបាន។ រដ្ឋនីមួយៗមានព្រំដែន នៃការពិចារណា ដើម្បីអនុវត្តនូវគោលការណ៍ទាំងនេះ នៅក្នុងប្រព័ន្ធរបស់ខ្លួន។ ដូច្នេះ ការអនុវត្តបែបនេះមិនបំពាននឹងអនុសញ្ញាទេ។

*រឿងក្តី SUTTER ទល់នឹងប្រទេសស្វីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២២ កុម្ភៈ ១៩៨៤ កថាខណ្ឌ៣២-៣៤ (មិនត្រូវបានបកស្រាយទៅតាមន័យ របស់ពាក្យព្រំដែន នៃមូលវិចារណ៍)។ រឿងក្តី MOSER ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២១ កញ្ញា ២០០៦ កថាខណ្ឌ១០៣-១០៤ (ឧទាហរណ៍ ដែលមានសេចក្តីសម្រេចរំលោភលើការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយពុំបានប្រកាស ជាសាធារណៈ ឬមួយសាធារណជន មិនអាចចូលមើលបានគ្រប់គ្រាន់)។*

**បើសិន ការសម្រេចទោសត្រូវបានសម្រេច ដោយគណៈវិនិច្ឆ័យដែលមិនមែនជាអ្នកច្បាប់ ការពិតដែលថាសាលក្រមគ្មានសំអាងហេតុមិនមែនជាការរំលោភលើអនុសញ្ញាទេ៖** ទោះបីជា យ៉ាងណាក៏ដោយ ក៏សាលក្រមត្រូវតែអាចឲ្យគេយល់បាន។ កាលណាសវនាការត្រូវបានដំណើរការ ទៅដោយចៅក្រមវិជ្ជាជីវៈ សំអាងហេតុត្រូវតែមានភាពច្បាស់លាស់គ្រប់គ្រាន់។

*រឿងក្តី TAXQUET ទល់នឹងប្រទេសបែលហ្ស៊ិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៦ វិច្ឆិកា ២០១០ កថាខណ្ឌ៨៩-៩១។*

មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖* មាត្រា៦.១និង៤៥។ មាត្រា៦ចែងអំពីសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តី ដោយយុត្តិធម៌ និងមាត្រា៤៥ចែងអំពីសំអាងហេតុសម្រាប់សាលក្រម និងសេចក្តីសម្រេចដោយមានធ្វើការប្រកាសអំពីការអនុវត្តផ្សេងៗ ដែលអាចឬមិនអាចទទួលយកបានដោយរួមទាំងលទ្ធភាព ដែលចៅក្រមអាចសរសេរអំពីមតិផ្សេងគ្នា កាលណាសាលក្រមមិនមានបង្ហាញអំពីមតិជាឯកច្ឆន្ទរបស់ចៅក្រម។

# កិច្ចដំណើរការនីតិវិធីពិសេស

ផ្នែកនេះមានចំណារបន្ថែមលើមាត្រាមួយចំនួន ដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ក្រម) ដូចតទៅ៖

- មាត្រា ៥០៣ ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន
- មាត្រា ៥០៨ ការបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំ
- មាត្រា ៥៥៦ មូលហេតុនៃការប្ដឹងជំទាស់ចិត្តទៅក្រមអាសនៈ
- មាត្រា ៥៥៧ ពាក្យប្ដឹងដិតចិត្តទៅក្រមអាសនៈ
- មាត្រា ៥៥៨ អ្នកទទួលពាក្យប្ដឹងដិតចិត្តទៅក្រមអាសនៈ
- មាត្រា ៥៦១ ការពិនិត្យពាក្យប្ដឹងដិតចិត្តទៅក្រមអាសនៈ
- មាត្រា ៥៦២ សេចក្ដីសម្រេចលើពាក្យប្ដឹងដិតចិត្តទៅក្រមអាសនៈ
- មាត្រា ៥៦៣ កិច្ចដែលត្រូវបានបំពេញមុនពេលជូនដំណឹងអំពីពាក្យប្ដឹង

# មាត្រា ៥០៣៖ ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

*ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានគិតបញ្ចូលទាំងស្រុង ទៅក្នុងថិរវេលានៃទោសដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោស ដែលត្រូវទទួលរងបន្ទាប់ពីការស្រូប ទោសបញ្ចូលគ្នា។*

## ការអនុវត្តនៅ អ.វ.ត.ក

**អង្គជំនុំជម្រះ តុលាការកំពូលបដិសេធចោលសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបន្ថយទោសចំនួន៥ឆ្នាំ សម្រាប់ការឃុំខ្លួនដោយខុសច្បាប់៖** អង្គជំនុំជម្រះ សាលាដំបូងបានបន្ថយទោសឌុច ដែលបានជាប់ឃុំដោយខុសច្បាប់ចំនួន៥ឆ្នាំ និងសម្រាប់ទូទាត់កិច្ចសហការរបស់គាត់ ក្នុងពេលឃុំខ្លួនបណ្ដោះអាសន្ន។ អង្គជំនុំជម្រះ នៃតុលាការកំពូលបានបដិសេធ ដោយបញ្ជាក់ថា ដោយសារឧក្រិដ្ឋកម្មមានភាពធ្ងន់ធ្ងរខ្លាំងស្ពានសម្រាលទោស នៃការឃុំខ្លួនដោយខុសច្បាប់មិនត្រូវមានអានុភាព ទៅលើការសម្រេចទោសរបស់ឌុចទេ។ ដូច្នេះ អង្គជំនុំជម្រះ តុលាការកំពូលមិនបានផ្ដល់ការបន្ធូរបន្ថយទោសដល់ឌុច ជាថ្នូរទៅនឹងកិច្ចសហការរបស់គាត់ ក្នុងពេលឃុំខ្លួនបណ្ដោះអាសន្នទេ។

*រឿងក្ដីឌុច៖ សាលដីកា លើបណ្ដឹងសាទុក្ខ អ.វ.ត.ក អ.ជ.ត.ក ៣ កុម្ភៈ ២០១២ កថាខណ្ឌ៣៣-៣៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៦៣.១(ខ) ៩៩.១ និង៩៩.២។ វិធាន៦៣.១(ខ) នៃវិធានផ្ទៃក្នុងចែងថាដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន ដែលបានសម្រេចខណៈ ដែលជនត្រូវចោទកំពុងរៀបចំការការពារក្ដី ចំពោះការសម្រេចឃុំខ្លួនភ្លាមត្រូវបានកាត់បន្ថយថិរវេលា ចេញពីដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន។ វិធាន៩៩.១នៃវិធានផ្ទៃក្នុងគឺស្រដៀងគ្នាទៅនឹងមាត្រា៥០៣ លើកលែងតែវិធាននេះ អនុវត្តចំពោះតែករណី ដែលបានសម្រេចឲ្យរួចផុតពីបទចោទ ឬនៅពេលដែលទោសដែលបានដាក់តិចជាង ឬស្មើទៅនឹងរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលបានជាប់រួចមកហើយប៉ុណ្ណោះ។ នៅក្នុងករណីទាំងនេះវិធាន៩៩.១ នៃវិធានផ្ទៃក្នុងចែងថា គេត្រូវដោះលែងជនជាប់ចោទភ្លាម។ វិធាន៩៩.២ នៃវិធានផ្ទៃក្នុងគឺស្រដៀងគ្នាទៅនឹងមាត្រា៥០៣ ដោយវិធាននេះយោងទៅដល់សេចក្ដីសម្រេចស្ដីពី "ការឃុំខ្លួនបន្ត" ដែលបានបង្កប់ន័យថា ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នណាក៏ដោយ ត្រូវតែយកមកពិចារណានៅក្នុងសេចក្ដីសម្រេចផ្ដន្ទាទោស។

## ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត

*តុលាការសិទ្ធិមនុស្សអឺរ៉ុប*

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**តុលាការអាចបដិសេធ មិនធ្វើការកាត់បន្ថយរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នចេញពីទោស ដែលសម្រេចជាស្ថាពរទេះ** កាលណាការដកហូតសេរីភាពដែលបានតវ៉ានោះ មានលក្ខណៈស្របច្បាប់ និងអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។

*រឿងក្តី MONNELL និងMORRISទល់នឹងចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២ មីនា ១៩៨៧ កថាខណ្ឌ៥០។*

**មាត្រាស្រដៀងគ្នានៅក្នុង*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន*៖** មិនមានមាត្រាណាមួយនៅក្នុងអនុសញ្ញាអឺរ៉ុប ស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលសមមូលទៅនឹងមាត្រា៥០៣ទេ។ នៅក្នុងប្រព័ន្ធអឺរ៉ុបមូលដ្ឋានច្បាប់បឋម សម្រាប់ធ្វើការកាត់បន្ថយរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នចេញពីទោស ដែលសម្រេចចុងក្រោយគឺមាត្រា៣៣។ អនុសាសន៍២០០៦(១៣) នៃក្រុមប្រឹក្សាអឺរ៉ុបស្តីពីការប្រើប្រាស់នូវការបញ្ជូនត្រឡប់ទៅឲ្យឃុំខ្លួនវិញលក្ខខណ្ឌផ្សេងៗដែលកើតមាន និងបទប្បញ្ញត្តិស្តីពីការរក្សាការពារប្រឆាំងនឹងការបំពានផ្សេងៗ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**បទប្បញ្ញត្តិនេះគឺមិនពាក់ព័ន្ធទៅ និងករណីដែលជនសង្ស័យត្រូវបានឃុំខ្លួន នៅក្រៅប្រទេសបារាំងនោះឡើយ៖** បទប្បញ្ញត្តិនេះ មិនរាប់បញ្ចូលការសម្រេចទោស ដែលត្រូវបានប្រកាស ដោយអាជ្ញាធរតុលាការបរទេសឡើយ។

*លេខ 94-85994 តុលាការកំពូលបារាំង ២៤ តុលា ១៩៩៥។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មាត្រា៧១៦.៤។ មាត្រានេះចែងអំពីការកាត់បន្ថយរយៈពេលនៃការឃុំខ្លួនមុនសវនាការលើអង្គសេចក្តីចេញពីការប្រកាសទោសចុងក្រោយ។

# មាត្រា ៥០៨៖ ការបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំ

*គ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ឬមណ្ឌលឃុំឃាំង ត្រូវតែបង្ហាញខ្លួនជនជាប់ឃុំ ដល់ចៅក្រម តាមការស្នើសុំ ព្រមទាំងដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលបំពេញភារកិច្ចតាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ។*

## ការអនុវត្តក្នុង អ.វ.ត.ក

**ការពិភាក្សាទៅលើការឃុំខ្លួន ដែលបានកំណត់កាលវិភាគរួចហើយ គឺមិនមានលក្ខណៈចាប់បង្ខំទេកាលណាអង្គជំនុំជម្រះ សាលាដំបូងបានទទួលសំណុំរឿង៖** ទោះបីជា វិធានរបស់អង្គជំនុំជម្រះដែលអាចអនុវត្តបាន នៅដំណាក់កាលនៃការស៊ើបសួរ តម្រូវឲ្យជនត្រូវចោទ ដែលកំពុងត្រូវបានឃុំខ្លួន បណ្តោះអាសន្នត្រូវឲ្យនាំមកនៅចំពោះមុខ ចៅក្រមស៊ើបសួររៀងរាល់៤ខែម្តង ដើម្បីធ្វើការពិភាក្សាអំពីលក្ខខណ្ឌ នៃការឃុំខ្លួន និងអំពីប្រព្រឹត្តកម្មក៏ដោយ ក៏ការពិភាក្សាពីការឃុំខ្លួន ដែលបានកំណត់ កាលវិភាគរួចហើយ នេះមិនមានលក្ខណៈចាប់បង្ខំទេ កាលណាអង្គជំនុំជម្រះ សាលាដំបូងបានទទួលនូវសំណុំរឿង ពីព្រោះថា ចុងចោទអាចលើកឡើង នូវកង្វល់ផ្សេងៗ អំពីលក្ខខណ្ឌនៃការឃុំខ្លួនតាមរយៈសារណា ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ដើម្បីដាក់ជូនទៅអង្គជំនុំជម្រះបាន។ ដូច្នេះ ការពិភាក្សាពីការឃុំខ្លួន ដែលបានកំណត់កាលវិភាគ រួចហើយ នេះមិនមានលក្ខណៈចាំបាច់ សម្រាប់ធានារក្សាសិទ្ធិរបស់ចុងចោទក្នុងការ ដែលត្រូវឲ្យគេឃុំខ្លួនក្នុងលក្ខខណ្ឌមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរនោះទេ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ សំណើសុំឲ្យសាកសួរពីការបន្តការឃុំខ្លួន អ.វ.ត.ក អ.ជ.ស.ដ ១១ ឧសភា ២០១១ កថាខណ្ឌ៤-៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៦៣.៨។ វិធាននេះគឺស្រដៀងគ្នាទៅនឹងមាត្រា៥០៨លើកលែងតែវាមានចែងអំពីពេលវេលា កំណត់យ៉ាងហោចណាស់រៀងរាល់៤ខែម្តង ដើម្បីផ្តល់ឱកាសដល់ជនត្រូវចោទធ្វើការពិភាក្សាអំពីប្រព្រឹត្តកម្ម និងលក្ខខណ្ឌនានាក្នុងអំឡុងពេលនៃការឃុំខ្លួនបណ្តោះអាសន្ន។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្ដីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រី ដែលត្រូវធ្វើការវាយតម្លៃ លើភាពស្របច្បាប់នៃការឃុំខ្លួន៖** មន្ត្រីត្រូវស្ដាប់ចម្លើយជនជាប់ឃុំ ដោយផ្ទាល់។ បើសិនការឃុំខ្លួនមិនមានយុត្តិកម្មទេ មន្ត្រីនោះត្រូវមានអំណាចបង្គាប់ឲ្យធ្វើការដោះលែងបុគ្គលនោះ។

*រឿងក្ដី MAMEDOVA ទល់នឹងប្រទេសរុស្ស៊ី តុលាការសិទ្ធិមនុស្សអឺរ៉ុប ១ មិថុនា ២០០៦ កថាខណ្ឌ៨០-៨១ (មន្ត្រីត្រូវស្ដាប់ជនជាប់ចោទដោយផ្ទាល់)។ រឿងក្ដី NICOLOVA ទល់នឹងប្រទេសប៊ុលហ្គារី តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៥មីនា១៩៩៩ កថាខណ្ឌ៤៩-៥០ (តួនាទី និងគុណសម្បត្តិរបស់មន្ត្រី មន្ត្រីមានអំណាចបង្គាប់ឲ្យធ្វើការដោះលែង)។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៥.១ និង៥.៣។ មាត្រាទាំងនេះចែងអំពីសិទ្ធិក្នុងការមានសេរីភាព និងសន្តិសុខរបស់បុគ្គលរួមទាំងសិទ្ធិក្នុងការត្រូវចាប់ខ្លួនឬឃុំខ្លួនដោយស្របច្បាប់ ហើយនិងសិទ្ធិក្នុងការត្រូវនាំខ្លួនជាប្រញាប់ ទៅចំពោះមុខតុលាការផង។

# មាត្រា ៥៥៦៖ មូលហេតុនៃការប្តឹងជំទាស់ចៅក្រមអាសនៈ

*បណ្តឹងជំទាស់អាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមខាងអាសនៈប៉ុណ្ណោះ ចៅក្រមទាំងឡាយអាចត្រូវប្តឹងជំទាស់ដោយមូលហេតុដូចខាងក្រោមនេះ៖*

*- កាលណាចៅក្រមឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី*

*- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣របស់ភាគីណាមួយ*

*- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ*

*- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ*

*- កាលណាចៅក្រមបានធ្វើជាសាក្សីឬអ្នកជំនាញក្នុងរឿងក្តី*

*- កាលណាចៅក្រមជាឬធ្លាប់ជាអ្នកតំណាងឬជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តីឬ*

*- កាលណាចៅក្រមបានចូលរួម ក្នុងការសម្រេចសេចក្តីក្នុងនាមជាមជ្ឈត្តករ ចំពោះរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅសាលាដំបូង ដែលបានប្តឹងឧបាស្រ័យឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី។*

## *ការអនុវត្តនៅអ.វ.ត.ក*

**ទាំងភាពលម្អៀងពិតប្រាកដ និងទាំងភវនីយភាពទំនងនៃភាពលម្អៀង គឺជាមូលដ្ឋាន ដែលអាចទទួលយកបាន សម្រាប់ការប្តឹងជំទាស់៖** សម្រាប់គោលបំណង នៃការប្តឹងជំទាស់លក្ខខណ្ឌតម្រូវស្តីពីភាពអនាគតិ របស់តុលាការត្រូវបានគេរំលោភមិនត្រឹមតែដោយសារអត្ថិភាព នៃភាពលម្អៀងពិតប្រាកដតែប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងដោយសារតែភវនីយភាព នៃភាពលម្អៀងផងដែរ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ ការប្តឹងជំទាស់ចៅក្រមយូរ ឧត្តរា អ.វ.ត.ក អ.ជ.ស.ជ ៩ ឧសភា ២០១១ កថាខណ្ឌ១១។ រឿងក្តីអៀង ធីរិទ្ធ៖ ការប្តឹងជំទាស់ ចៅក្រមសោម សិរិវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ១០។ រឿងក្តីនួន ជា និងអៀង សារី៖ បណ្តឹងជំទាស់លោកស្រីចៅក្រម SILVIA CARTWRI GHT អ.វ.ត.ក អ.ជ.ស.ជ ២ ធ្នូ២០១១ កថាខណ្ឌ ១៣។ រឿងក្តីនួន ជា អៀង សារី និងខៀវ សំ*

*ផនះ បណ្ដឹងជំទាស់ជិតចិត្ត លើលោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ដ ៩ មីនា ២០១២ កថាខណ្ឌ១១។ រឿងក្ដីអៀង សារី៖ បណ្ដឹងជំទាស់ជិតចិត្ត លោកស្រីចៅក្រម Silvia CARTWRIGHT អ.វ.ត.ក អ.ជ.ស.ដ ៤ មិថុនា ២០១២ កថាខណ្ឌ ១២។*

**វិធីផ្សេងៗ ស្តែងចេញឲ្យ ឃើញភាពលម្អៀង៖ ដោយការបង្ហាញថា៖** ក) ចៅក្រមណាម្នាក់ជាភាគីមួយនៃរឿងក្ដី មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុពីលទ្ធផលនៃរឿងក្ដី ឬប្រសិនបើការសម្រេច របស់ចៅក្រមរូបនោះនឹងនាំឲ្យកើតចេញ នូវបុព្វហេតុអ្វីមួយផ្សេងទៀត ដែលចៅក្រមរូបនោះមានការពាក់ព័ន្ធ ឬខ) កាលៈទេសៈទាំងនោះ ធ្វើឲ្យអ្នកសង្កេតការណ៍ មិនលម្អៀងម្នាក់ ដែលបានទទួលនូវព័ត៌មានគ្រប់គ្រាន់យល់ឃើញ ដោយសមហេតុផលថាមានភាពលម្អៀង។

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ ការប្ដឹងជិតចិត្តចៅក្រមយូរ ឧត្តរា អ.វ.ត.ក អ.ជ.ស.ដ ៩ ឧសភា ២០១១ កថាខណ្ឌ១១។ រឿងក្ដីអៀង ធីរិទ្ធ៖ ការប្ដឹងជិតចិត្តចៅក្រមសោម សិរីវឌ្ឍ អ.វ.ត.ក អ.ជ .ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ១០។ រឿងក្ដីនួន ជា និងអៀង សារី៖ បណ្ដឹងជិតចិត្តលោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ដ ២ ធ្នូ២០១១ កថាខណ្ឌ១៣។ រឿងក្ដីនួន ជា អៀង សារី និងខៀវ សំផនះ បណ្ដឹងជិតចិត្ត លោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ដ ៩ មីនា ២០១២ កថាខណ្ឌ១២។ រឿងក្ដីអៀង សារី៖ បណ្ដឹងជិតចិត្ត លោកស្រីចៅក្រម Silvia CARTWRIGHT អ.វ.ត.ក អ.ជ.ស.ដ ៤ មិថុនា ២០១២ កថាខណ្ឌ១៣។*

**និយមន័យ នៃអ្នកសង្កេតការណ៍មិនលម្អៀង ដែលការយល់ឃើញ ដ៏សមហេតុផលរបស់គាត់ទៅលើភាពលម្អៀង របស់ចៅក្រមណាម្នាក់ ដោយបានអះអាង លើបណ្ដឹងជិតចិត្តចៅក្រមនោះថាពិត៖** ត្រូវតែជាបុគ្គល ដែលបានទទួលនូវព័ត៌មានគ្រប់កាលៈទេសៈ ពាក់ព័ន្ធទាំងអស់ ដោយរួមបញ្ចូលទាំងប្រវត្តិ នៃសេចក្ដីថ្លៃថ្នូរ និងភាពអនាគតិ ដែលបង្កើតបាន ជាផ្នែកមួយនៃទទ្បីករណ៍ និងជាបុគ្គល ដែលបានយល់ឃើញផងដែរថា ភាពអនាគតិ គឺជាភារកិច្ចមួយ ក្នុងចំណោមភារកិច្ច ដែលចៅក្រមត្រូវតែប្រកាន់ឲ្យបានខ្ជាប់ខ្ជួន។

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ ការប្ដឹងជិតចិត្តចៅក្រមយូរ ឧត្តរា អ.វ.ត.ក អ.ជ.ស.ដ ៩ ឧសភា ២០១១ កថាខណ្ឌ១១-១២។ រឿងក្ដីអៀង ធីរិទ្ធ៖ ការប្ដឹងជិតចិត្តចៅក្រម សោម សិរីវឌ្ឍ អ.វ.ត.ក អ.ជ.ត .ក ៣ មិថុនា ២០១១ កថាខណ្ឌ១០។ រឿងក្ដីនួន ជា និងអៀង សារី៖ បណ្ដឹងជិតចិត្ត*

*លោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ២ ធ្នូ២០១១ កថាខណ្ឌ ១៤។ រឿងក្តីនួន ជា អៀង សារី និងខៀវ សំផន ៖ បណ្តឹងជំទាស់ចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ៩ មីនា ២០១២ កថាខណ្ឌ១២។ រឿងក្តីអៀង សារីៈ បណ្តឹងជំទាស់ ចំពោះលោកស្រីចៅក្រម Silvia CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ៤ មិថុនា ២០១២ កថាខណ្ឌ ១៣។*

**ជាទូទៅមតិរបស់តតិយជន គឺមិនគ្រប់គ្រាន់ទេៈ** នៅពេលធ្វើការវាយតម្លៃ ទៅលើអង្គសេចក្តីនៃបណ្តឹងជំទាស់ ចំពោះចៅក្រមជាទូទៅមតិរបស់តតិយជនតែមួយមុខ គឺមិនគ្រប់គ្រាន់ទេក្នុងការដែលនាំឲ្យគេយល់ ដោយសមហេតុផលអំពីភាពលម្អៀងនោះ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធៈ ការប្តឹងជំទាស់ចៅក្រមយូរ ឧត្តរ អ.វ.ត.ក អ.ជ.ស.ជ ៩ ឧសភា ២០១១ កថាខណ្ឌ១៥។*

**ភាគីដែលមានបំណង ប្តឹងជំទាស់ចៅក្រមពីភាពលម្អៀងត្រូវតែបង្ហាញ ពីអសមត្ថភាពរបស់ចៅក្រមរូបនោះ ក្នុងការសម្រេចឲ្យបានត្រឹមត្រូវលើបញ្ហាជាក់លាក់នានា ឬលើភាគី នៅចំពោះមុខខ្លួនៈ** ភាពលម្អៀង ដែលមាននៅក្នុងសំណុំរឿងពីមុនមិនតម្រូវឲ្យ មានការប្តឹងជំទាស់ ជាស្វ័យប្រវត្តិនោះឡើយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធៈ ការប្តឹងជំទាស់ចៅក្រមយូរ ឧត្តរ អ.វ.ត.ក អ.ជ.ស.ជ ៩ ឧសភា ២០១១ កថាខណ្ឌ១២-១៣។ រឿងក្តីខៀវ សំផន និងអៀង សារីៈ សេចក្តីសម្រេច លើបណ្តឹងស្នើសុំឲ្យចាត់ការភ្លាមៗ ដោយអនុលោមទៅតាមវិធាន ៣៥ អ.វ.ត.ក អ.ជ.ស.ជ ២២ វិច្ឆិកា ២០១២ កថាខណ្ឌ ៩-១៤។ រឿងក្តីនួន ជាៈ សេចក្តីសម្រេច លើបណ្តឹងសាទុក្ខភ្លាមរបស់នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណើសុំឱ្យចាត់ការភ្លាមៗ ដោយអនុលោមតាមវិធាន ៣៥ អ.វ.ត.ក អ.ជ.ត.ក ២២ មីនា ២០១៣ កថាខណ្ឌ ២០-២៤។*

**សេចក្តីសម្រេចពីមុន ដែលមានភាពលម្អៀង ដែលធ្វើឡើងដោយចៅក្រម ច្រើនរូបមិនអាចគាំទ្រលើបណ្តឹងជំទាស់ លើចៅក្រមម្នាក់ ក្នុងចំណោមចៅក្រមទាំងនោះបានឡើយៈ** នេះគឺករណីដែលចៅក្រមរងការចោទប្រកាន់ គឺចៅក្រមជាសមាជិកតែម្នាក់គត់ ក្នុងចំណោមចៅក្រម ជាសមាជិកច្រើនរូបក្នុងក្រុមចៅក្រម ដែលបានចេញនូវសេចក្តីសម្រេច ដែលមានភាពលម្អៀង ហើយជាយោបល់ របស់ឯកត្តជនជាសមាជិកនៃក្រុមចៅក្រមនោះ មិនត្រូវបានលាតត្រដាងឡើយ។

*រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធៈ ការប្តឹងជំទាស់ចៅក្រមយូរ ឧត្តរ អ.វ.ត.ក អ.ជ.ស.ជ ៩ ឧសភា ២០១១ កថាខណ្ឌ១៦។ រឿងក្តីអៀង ធីរិទ្ធៈ ការប្តឹងជំទាស់*

*ចៅក្រមសោម សិរីវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ១១-១២។*

**នៅពេល ដែលមានការចោទប្រកាន់ អំពីភាពលម្អៀងរបស់តុលាការ នៅក្នុងបណ្តឹងជំទាស់ដិតចិត្ត សំអាងមិនគ្រប់គ្រាន់ ក្នុងការលើកឡើងពីហេតុផល តាមផ្លូវច្បាប់របស់ចៅក្រម នៅក្នុងសេចក្តីសម្រេចពីមុនមួយ ដែលមិនពាក់ព័ន្ធគ្នាគឺមានលក្ខណៈធ្វើឡើងតាមតែទំនើងចិត្ត ឬមិនគួរឲ្យជឿបាន៖ការណ៍នេះតែឯង គឺមិនបានបង្ហាញ ឬមិនត្រូវបានគេយល់ឃើញ យ៉ាងសមហេតុផលថា មានភាពលម្អៀងប្រឆាំងនឹងជនជាប់ចោទនោះឡើយ។**

*រឿងក្តីអៀង ធីរិទ្ធ៖ ការប្តឹងដិតចិត្តចៅក្រមសោម សិរីវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ១៣។*

**ការប្រាស្រ័យទាក់ទងតែភាគីម្ខាង មិនបង្កើតបានជាមូលដ្ឋានបឋមផ្អែកតាមអង្គហេតុ ដែលបង្កើតឲ្យមានភាពលំអៀងនោះទេ៖** កាលណាចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិករដ្ឋបាលតុលាការប្រាស្រ័យទាក់ទងគ្នាអំពីបញ្ហារដ្ឋបាលការពិតតែ គឺថាទំនាក់ទំនង ដែលបានកើតឡើងនេះ គឺមិនមែនជាមូលដ្ឋានផ្ទាល់ ដែលបង្កើតឲ្យមានភាពលំអៀងនោះទេ។

*រឿងក្តីនួន ជា និងអៀង សារី៖ បណ្តឹងដិតចិត្តលោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ២ ធ្នូ២០១១ កថាខណ្ឌ ១៦។ រឿងក្តី អៀង សារី៖ បណ្តឹងដិតចិត្តលោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ៤ មិថុនា ២០១២ កថាខណ្ឌ ១៥។ រឿងក្តីនួន ជា និងអៀង សារី៖ បណ្តឹងដិតចិត្តលោកស្រីចៅក្រ Silvia CARTWR IGHT អ.វ.ត.ក អ.ជ.ត.ក ១៧ មេសា ២០១២ កថាខណ្ឌ ២៣។*

**សេចក្តីថ្លែងការណ៍ ដែលធ្វើឡើងដោយមន្ត្រីសាធារណៈ ដល់ប្រព័ន្ធផ្សព្វផ្សាយអាចបំពានគោលការណ៍សន្មត់ ជាមុនថាគ្មានទោស ប៉ុន្តែក៏មិនបានបង្ហាញឲ្យឃើញ ដោយផ្ទាល់នូវឥទ្ធិពលមិនសមស្របរបស់ចៅក្រម នៅក្នុងការណ៏នេះឡើយ៖** កាលណាមន្ត្រីសាធារណៈត្រូវគេមើលឃើញ ជាសាធារណៈថា ធ្វើការអះអាងពីភាពមានទោសពៃរ៍ របស់ជនជាប់ចោទ ការដាក់ទណ្ឌកម្ម ខាងព្រហ្មទណ្ឌមួយនឹងអនុវត្តទៅបានកាលណា ជននោះជ្រៀតជ្រែក ឬប៉ុនប៉ងដោយដឹងជាមុន និងមានចេតនា ក្នុងការជ្រៀតជ្រែក ក្នុងរដ្ឋបាលយុត្តិធម៌របស់តុលាការឡើយ។

*រឿងក្តីនួន ជា អៀង សារី និងខៀវ សំផន៖ សេចក្តីសម្រេច លើការស្នើសុំឱ្យមានចំណាត់ការជាបន្ទាន់ តាមវិធាន៣៥ អ.វ.ត.ក អ.ជ.ស.ជ ១១ ឧសភា ២០១២ កថាខណ្ឌ១៩-២២។ រឿងក្តីនួន ជា អៀង សារី និងខៀវ សំផន៖*

*សេចក្តីសម្រេច លើការស្នើសុំឲ្យមានចំណាត់ការជាបន្ទាន់ ដោអនុលោមតាមវិធាន ៣៥ ប្រឆាំងនឹងនឹងរដ្ឋមន្ត្រីក្រសួងការបរទេសហោណាំហុង (ឯកសារ E219) អ.វ.ត.ក អ.ជ.ត.ក ២២ វិច្ឆិកា ២០១២ កថាខណ្ឌ៨-១០។ រឿងក្តីនួន ជា៖ សេចក្តីសម្រេចលើពាក្យសុំរបស់នួន ជា ឲ្យមានចំណាត់ការជាបន្ទាន់ ដោយអនុលោមតាមវិធាន៣៥ អ.ជ.ត.ក ១៤ កញ្ញា ២០១២ កថាខណ្ឌ ៣៣-៣៨។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៣៤.២ និង៣៥ នៃវិធានផ្ទៃក្នុង។ វិធាននេះគឺស្រដៀងគ្នាទៅនឹងមាត្រា៥៥៦ ប៉ុន្តែបានចែងអំពីមូលដ្ឋាន សម្រាប់ប្តឹងជំទាស់បានយ៉ាងទូលំទូលាយជាងមាត្រា៥៥៦។ នៅក្នុងវិធាន ៣៤.២ នៃវិធានផ្ទៃក្នុង ចៅក្រមអាចត្រូវបានប្តឹងជំទាស់លើករណីណាមួយក៏ដោយដែលចៅក្រមរូបនោះមានឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួនឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលម្អៀង។ វិធាន៣៥ នៃវិធានផ្ទៃក្នុងអនុវត្ត ចំពោះបុគ្គលណា ដែលជ្រៀតជ្រែកដោយដឹងជាមុន និងដោយចេតនានោះ ក្នុងរដ្ឋបាលយុត្តិធម៌ ព្រមទាំងរួមបញ្ចូលទាំងចៅក្រម ប៉ុន្តែ មិនត្រូវបានរឹតត្បិតចំពោះពួកគេ។

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជាគឺជា ភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួនគឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**អត្ថន័យនៃភាពអនាគតិរបស់តុលាការ៖** គោលការណ៍នេះ ដែលជាផ្នែកដ៏សំខាន់ នៃសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តី ដោយយុត្តិធម៌ មានន័យថា ចៅក្រមមិនត្រូវមានបុរេវិនិច្ឆ័យ ចំពោះបញ្ហា ដែលបានដាក់នៅចំពោះមុខខ្លួន និងមិនត្រូវចាត់ការតាមរបៀប ដែលលើកស្ទួយផលប្រយោជន៍ របស់ភាគីមួយក្នុងចំណោមភាគី នានានោះទេ។

*រឿងក្តី KARTTUNEN ទល់នឹងប្រទេសហ្វាំឡង់ គណៈកម្មាធិការ សិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ១៩៩២ កថាខណ្ឌ៧.២។*

**ការចូលរួម ក្នុងបណ្តឹងសាទុក្ខ នៅតុលាការកំពូល ពីសំណាក់ចៅក្រម ដែលពីមុនបានចូលរួមនៅក្នុងក្រុមប្រឹក្សាចៅក្រមក្នុងរឿងក្តី ទាក់ទងនឹងជនជាប់ចោទ ដដែលមិនចាំបាច់លើកពីបញ្ហា នៃភាពអនាគតិទេ៖** វាពុំមានបញ្ហាបែបដូច្នោះទេ បើកម្មវត្ថុនៃករណីខាងក្រោយនេះ មិនបង្កើតបានជាផ្នែកមួយនៃបណ្តឹងសាទុក្ខនៅតុលាការកំពូល។

*រឿងក្តីBARKINទល់នឹងសហព័ន្ធរុស្ស៊ី គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប ៣ មេសា ២០០៨ កថាខណ្ឌ១៣.៣។*

**ការរំលោភបំពាន៖ ការវាយតម្លៃភស្តុតាង ដែលឃើញច្បាស់ថាមានលក្ខណៈតាមទំនើងចិត្ត ឬមានលក្ខណៈដូចគ្នា ទៅនឹងការបដិសេធយុត្តិធម៌៖** ជាទូទៅទោះបីជា វាអាស្រ័យលើរដ្ឋ ដែលត្រូវធ្វើការវាយតម្លៃទៅលើអង្គហេតុ និងភស្តុតាង ក្នុងករណីជាក់លាក់ក៏ដោយ ក៏ការវាយតម្លៃនោះនឹងត្រូវបានរំលោភ លើលក្ខខណ្ឌតម្រូវស្តីពីភាពអនាគតិរបស់តុលាការដែរ បើគេអាចធ្វើការបង្ហាញបានថា ការវាយតម្លៃនោះ មានលក្ខណៈតាមទំនើងចិត្ត ឬមានលក្ខណៈដូចគ្នាទៅនឹងការបដិសេធយុត្តិធម៌។

*រឿងក្តី SHARIFOVA SAFAROV និង BURKHONOVទល់នឹងប្រទេស តាជីគីស្ថាន គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ១ មេសា ២០០៨ កថាខណ្ឌ៦.៥។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា១៤.១។មាត្រានេះធានាឲ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ ចំពោះមុខចុងចោទ នៅចំពោះមុខអង្គជំនុំជម្រះដែលមានភាពអនាគតិប៉ុន្តែមិនបានចែងអំពីកត្តាជាក់លាក់ស្តីពីមូលដ្ឋាន ដែលភាពអនាគតិអាចត្រូវបានតវ៉ាឬអំពី ថាតើគេត្រូវតែធ្វើតាមនីតិវិធីញអ្វីនោះទេ។

## ***ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត***

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការ-ពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**ជាតុផ្សំចំនួន២ នៅក្នុងលក្ខខណ្ឌតម្រូវ ស្តីពីភាពអនាគតិរបស់តុលាការៈ** គឺជាតុផ្សំជាអត្តនោម័ត និងជាសត្យានុម័ត។

*រឿងក្តី PIERSACK ទល់នឹងប្រទេសបែលហ្សិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ១ តុលា ១៩៨២ កថាខណ្ឌ៣០។*

**ជាតុផ្សំអត្តនោម័តៈ ភាពអនាគតិនៃបុគ្គលមានន័យថា គ្មានចៅក្រមណាម្នាក់ ត្រូវប្រកាន់យកនូវបុរេវិនិច្ឆ័យជាបុគ្គល ឬការចូលចិត្តខ្លាំងលើអ្វីមួយ ក្នុងសំណុំរឿងទេៈ** ដូច្នេះ ចៅក្រមមិនអាចមានទំនាក់ទំនងអ្វីជាមួយនឹងភាគីណាមួយ ក្នុងចំណោមភាគីទាំងអស់ ឬជាមួយនឹងមូលហេតុ ដែលចូលចិត្ត ឬមិនចូលចិត្តភាគីណាមួយ ក្នុងចំណោមពួកគេទាំងនោះឡើយ គឺចៅក្រមត្រូវតែមានចិត្តជាអនាគតិ។ ទោះបីជា យ៉ាងណាក៏ដោយភាពអនាគតិ របស់ចៅក្រមគឺជាការសន្មត រហូតទាល់តែមានសក្ខីកម្មផ្ទុយយកមកបញ្ជាក់។

*រឿងក្តី DAKTARAS ទល់នឹងប្រទេសលីត្វាណា តុលាការសិទ្ធិមនុស្សអឺរ៉ុប ១០ តុលា ២០០០ កថាខណ្ឌ៣០ (និយមន័យនៃភាពអនាគតិជាបុគ្គល)។ រឿងក្តីLE COMPTE VAN LEUVEN ទល់ទៅនឹងប្រទេសបែលហ្សិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៣ មិថុនា ១៩៨១ កថាខណ្ឌ ៥៨ (ភាពអនាគតិ របស់ចៅក្រមគឺជាការសន្មត)។*

**ជាតុផ្សំសត្យានុមតិៈ ទោះបីជា មានឬគ្មានការធានាដែលបានស្នើឡើង ដោយចៅក្រមនោះទេ ជាតុផ្សំសត្យានុមតិ គឺមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបំបាត់ការសង្ស័យណាមួយ ដែលត្រូវតាមច្បាប់ ដែលទាក់ទងទៅនឹងភាពអនាគតិ របស់ចៅក្រមរូបនោះ** ៖ ជាផលវិបាកការពាក់ព័ន្ធ របស់ចៅក្រមតែមួយដដែល ក្នុងដំណាក់កាលផ្សេងៗគ្នា នៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺបានលើកឡើងនូវបញ្ហាមួយដែលពាក់ព័ន្ធទៅនឹងភាពអនាគតិ របស់ចៅក្រមរូបនោះ។ ចៅក្រមរូបណាក៏ដោយ ដែលគេមានមូលហេតុត្រូវតាមច្បាប់ ចំពោះការភ័យខ្លាចថា ចៅក្រមនោះខ្វះភាពអនាគតិ ចៅក្រមរូបនោះត្រូវតែដកខ្លួនចេញ។

*រឿងក្តី HAUSCHILDT ទល់នឹងប្រទេសដាណឺម៉ាក តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៤ ឧសភា ១៩៨៩ កថាខណ្ឌ៤៨-៤៩ (និយមន័យនៃជាតុផ្សំជាសត្យានុម័ត ការចូលរួមចំណែកនៅដំណាក់កាលផ្សេងៗគ្នា)។ រឿងក្តី DECUBBER ទល់នឹងប្រទេសបែលហ្សិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ តុលា ១៩៨៤ កថាខណ្ឌ ២៦ (ចៅក្រមត្រូវតែដកខ្លួនចេញ បើមានមូលហេតុត្រូវតាមច្បាប់ ក្នុងការភ័យខ្លាចថាមិនមានភាពអនាគតិ)។*

**ជនស៊ីវិលក៏អាចមានការភ័យខ្លាច យ៉ាងត្រឹមត្រូវពីភាពអនាគតិ បើមានមន្ត្រីយោធា នៅក្នុងអង្គចៅក្រមនៃតុលាការថ្នាក់ទីពីរៈ** ការណីនេះ សូម្បីតែមានចៅក្រមអាសនៈជាស៊ីវិល នៅក្នុងចំណោមនៃអង្គចៅក្រមក៏ដោយ។ ក្រុមប្រឹក្សាចៅក្រមក៏ អាចត្រូវបានគេជះឥទ្ធិពលដោយជាតុផ្សំ ដែលមិនទាក់ទងទៅនឹងអង្គហេតុ នៃរឿងក្តីនោះដែលនាំឲ្យរំលោភសិទ្ធិ ក្នុងការទទួលបាននូវការជំនុំជម្រះក្តី ដោយយុត្តិធម៌។

*រឿងក្តី BASKAYA និង OKÇUOĞLU ទល់នឹងប្រទេសទួគី តុលាការសិទ្ធិមនុស្ស អឺរ៉ុប ៨ កក្កដា ១៩៩៩ កថាខណ្ឌ៧៩។*

**សេចក្តីថ្លែង ដែលធ្វើឡើងដោយចៅក្រម ទៅកាន់សារព័ត៌មាន អាចរំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌របស់ភាគីអ្នកដាក់ពាក្យសុំ ប្រសិនបើ បង្ហាញឲ្យឃើញពីការខ្វះខាត នៃភាពដែលមិនលម្អៀង៖** ការកត់សំគាល់ដែលធ្វើឡើង ដោយចៅក្រមទៅកាន់សារព័ត៌មាន បញ្ជាក់ឲ្យឃើញថា ចៅក្រមរូបនោះបានបង្កើតឡើងរួចទៅហើយ នូវទស្សនៈអវិជ្ជមាន ចំពោះភាគីអ្នកដាក់ពាក្យសុំ ហើយអាចត្រូវបានបង្ហាញឲ្យឃើញថា រំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ភាគីអ្នកដាក់ពាក្យសុំនោះ។ ការធ្វើតេស្តខាងសត្យានុម័ត ដើម្បីរកឲ្យឃើញការលំអៀង ឬការប្រាកដឡើងពិតប្រាកដ ដូច្នេះ អាចត្រូវបានបំពេញបន្ថែម ដោយការធ្វើតេស្តខាងអត្តនោម័តនៅក្នុងនោះ ភាពជឿជាក់ផ្ទាល់ខ្លួនរបស់ចៅក្រមត្រូវបានគេវាយតម្លៃ។

*រឿងក្តី OLUJIC ទល់នឹងប្រទេសក្រូអាត ៥ ឧសភា ២០០៩ កថាខណ្ឌ៥៨-៦០។ (ដោយកត់សម្គាល់ថា ចៅក្រមត្រូវតែអនុវត្តធន្ទានុសិទ្ធិជាអតិបរមា ក្នុងរឿងក្តីទាំងឡាយណា ដែលខ្លួនចាត់ការ ក្នុងគោលបំណងដើម្បីលើកកំពស់នូវភាពមិនលំអៀង ដែលជាលក្ខ័ណ្ឌតម្រូវដោយការិយាល័យ)។ រឿងក្តីLAVENTS ទល់នឹងប្រទេស Latvia តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៨ វិច្ឆិកា ២០០២ កថាខណ្ឌ១១៨-១២០។ (ការធ្វើតេស្តខាងសត្យានុម័ត របស់ចៅក្រមអាចនឹងត្រូវបានគេអនុវត្ត នៅក្នុងករណីមួយចំនួនជាក់លាក់)។ រឿងក្តី KYPRIOANOU ទល់នឹងប្រទេសCyprus តុលាការសិទ្ធិមនុស្សអឺរ៉ុប ១៥ ធ្នូ ២០០៥ កថាខណ្ឌ១១៩។ (ដោយកត់សម្គាល់លើការវិភាគ នៃភាពជឿជាក់ផ្ទាល់ខ្លួនរបស់ចៅក្រម នៅពេលដែលធ្វើការវាយតម្លៃ អំពីភាពលំអៀង)។*

**មាត្រាស្រដៀងគ្នានៅក្នុងអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖** មាត្រា៦ និង២១។ មាត្រា៦ចែងអំពីលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌រួមទាំងសិទ្ធិរបស់បុគ្គល ដែលត្រូវបានជំនុំជម្រះនៅចំពោះមុខតុលាការមួយដែលឯករាជ និងមិនលម្អៀងដែលបានបង្កើតឡើងដោយច្បាប់។ មាត្រា២១ ចែងអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការិយាល័យតុលាការ (គឺត្រូវមានចរិតប្រកបដោយសីលធម៌ និងគុណវុឌ្ឍិខ្ពស់)។

# មាត្រា ៥៥៧៖ ពាក្យប្តឹងជំទាស់ចៅក្រមអាសនៈ

*ភាគីដែលចង់ប្តឹងជំទាស់ចៅក្រមអាសនៈណាមួយត្រូវតែជូនពាក្យប្តឹង តាំងពីពេលខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជំទាស់បើពុំដូច្នេះទេមិនអាចទទួលបានឡើយ។*

*ក្នុងករណីណាក៏ដោយពាក្យប្តឹងជំទាស់ចៅក្រមមិនអាចធ្វើបានឡើយ នៅក្រោយពេលបិទការពិភាក្សាដេញដោល។*

## *ការអនុវត្តនៅ អ.វ.ត.ក*

**វិធានសម្រាប់ដាក់ពាក្យ ប្តឹងជំទាស់ចៅក្រមត្រូវតែបានបកស្រាយ តាមគោលការណ៍បូករួម (ត្រួត)៖** ពាក្យបណ្តឹងជំទាស់ចៅក្រមត្រូវតែដាក់ នៅក្នុងរយៈពេលកំណត់សមស្រប ដូចមានបញ្ជាក់នៅក្នុងវិធាន។

*រឿងក្តីអៀង ធីរិទ្ធ៖ ការប្តឹងជំទាស់ចៅក្រម សោម សិរីវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ៤ (ការបកស្រាយតាមគោលការណ៍ត្រួត)។ រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ ការប្តឹងជំទាស់ចៅក្រមនិល ណុន SILVIA CARTWRIGHT យ៉ា សុខន JEAN-MARC LAVERGNE និងជូ មណី អ.វ.ត.ក អ.ជ.ស.ជ ២៣ មីនា ២០១១ កថាខណ្ឌ៧ (ការដាក់ពាក្យ នៅក្នុងរយៈពេលកំណត់)។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៣៤.៤។ វិធាននេះគឺស្រដៀងគ្នាមែនទែនទៅនឹងមាត្រា៥៥៧ លើកលែងតែវាមានលក្ខណៈជាក់លាក់ជាងទាក់ទងទៅនឹងស្ថានភាព និងបុគ្គលដែលបណ្តឹងជំទាស់អាចត្រូវបានដាក់ប្រឆាំង។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការសិទ្ធិមនុស្សអឺរ៉ុប***

*អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចែងអំពីនីតិវិធីព្រហ្មទណ្ឌស្តីពីកិច្ចការពារដែលស្រដៀងគ្នាខ្លាំងទៅនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាជាភាគី។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងអនុសញ្ញាអឺរ៉ុបត្រូវបានបកស្រាយ និងអនុវត្តដោយតុលាការរបស់ខ្លួន គឺតុលាការសិទ្ធិមនុស្សអឺរ៉ុប។*

**កាលណាមានការសង្ស័យ អំពីភាពអនាគតិរបស់ចៅក្រម ហើយចៅក្រមរូបនោះមិនដកខ្លួនថយ ជនជាប់ចោទអាចដាក់ពាក្យប្តឹងជំទាស់ ចំពោះចៅក្រមរូបនោះ៖** ប៉ុន្តែ ជនជាប់ចោទអាចលះបង់សិទ្ធិ ក្នុងការដាក់ពាក្យបណ្តឹងជំទាស់បាន ការលះបង់សិទ្ធិបែបនេះ ត្រូវតែបានធ្វើឡើងតាមរបៀបមួយ ដែលគ្មានលក្ខខណ្ឌ។

*រឿងក្តី DE CUBBER ទល់នឹងប្រទេសបែលហ្ស៊ិក តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៦ តុលា ១៩៨៤ កថាខណ្ឌ២៦ (ចៅក្រមត្រូវតែដកខ្លួនចេញ បើសិនមានមូលហេតុត្រូវតាមច្បាប់ក្នុងការភ័យខ្លាចថា គ្មានភាពអនាគតិ)។ រឿងក្តី PFEIFER និង PLANKL ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៥ កុម្ភៈ ១៩៩២ កថាខណ្ឌ៣៧ (ការលះបង់សិទ្ធិត្រូវតែបានធ្វើឡើង តាមរបៀបមួយ ដែលគ្មានលក្ខខណ្ឌ)។ រឿងក្តី OBERSCHLICK ទល់នឹងប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុប ២៣ ឧសភា ១៩៩១ កថាខណ្ឌ៥១ (ការលះបង់សិទ្ធិ ត្រូវតែបានធ្វើឡើងតាមរបៀបមួយ ដែលគ្មានលក្ខខណ្ឌ)។*

មាត្រាស្រដៀងគ្នានៅក្នុង***អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖*** មាត្រា៦.១។ មាត្រានេះចែងអំពីសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ ទោះបីជាការបកស្រាយមាត្រា៦.១ ធ្វើឡើងដោយករណីយុត្តិសាស្ត្រ នៃតុលាការសិទ្ធិមនុស្សអឺរ៉ុបក៏ដោយ ក៏បានផ្តល់សិទ្ធិដល់ជនជាប់ចោទក្នុងការតវ៉ានឹងសមាសភាពរបស់អង្គតុលាការ ដែលត្រូវធ្វើការវិនិច្ឆ័យសេចក្តីលើបញ្ហានានាទាក់ទងនឹងវិធី ដែលជនជាប់ចោទអាចធ្វើបាននៅក្នុងវិសាលភាព នៃបទប្បញ្ញត្តិនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗដែរ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ទម្រង់នៃការដាក់ពាក្យ សុំប្តឹងជំទាស់៖** ពាក្យសុំដែលបុគ្គលកំពុងឋិត នៅក្រោមការត្រួតពិនិត្យ អះអាងថា មានការសង្ស័យជាខ្លាំង អំពីភាពអនាគតិរបស់ចៅក្រមអាសនៈ នៅក្នុងអង្គតុលាការ ដែលនាំឲ្យមានការដាក់ពាក្យប្តឹងជំទាស់។

*លេខ 76-92090 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៣៤៣ តុលាការកំពូលបារាំង ២៤ វិច្ឆិកា ១៩៧៦។*

មាត្រាស្រដៀងគ្នានៅក្នុង***ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖*** មាត្រា៦៦៩ និង៦៧០។ មាត្រាទាំងនេះចែងអំពីការតវ៉ាចំពោះភាពអនាគតិរបស់ចៅក្រម រួមទាំងការអនុញ្ញាតឲ្យដាក់ពាក្យសុំប្តឹងជំទាស់ចៅក្រមផង។

# មាត្រា ៥៥៨៖ អ្នកទទួលពាក្យប្តឹងជំទាស់ចៅក្រមអាសនៈ

*ភាគីត្រូវជូនពាក្យប្តឹងទៅ:*

*- ប្រធានសាលាឧទ្ធរណ៍កាលណាពាក្យប្តឹងជំទាស់នោះទាក់ទងដល់ប្រធាន ឬចៅក្រមតុលាការជាន់ដំបូង*

*- ប្រធានតុលាការកំពូលកាលណាពាក្យប្តឹងជំទាស់នោះទាក់ទង ដល់ចៅក្រមនៃតុលាការកំពូល ដល់ប្រធានសាលាឧទ្ធរណ៍ ឬចៅក្រមណាមួយនៃសាលាឧទ្ធរណ៍*

*ពាក្យប្តឹងត្រូវតែចង្អុលឱ្យច្បាស់លាស់អំពីមូលហេតុនៃការប្តឹងជំទាស់ ហើយត្រូវមានភស្តុតាងបញ្ជាក់ច្បាស់លាស់ បើពុំដូច្នោះទេពាក្យប្តឹងពុំអាចទទួលយកបានឡើយ*

## ការអនុវត្តនៅអ.វ.ត.ក

ដើម្បីដាក់ពាក្យប្តឹងជំទាស់ ម្ចាស់បណ្តឹងត្រូវតែមានបណ្តឹងសាទុក្ខ ដែលកំពុងរង់ចាំសេចក្តីសម្រេចនៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល៖ នៅពេលដាក់បណ្តឹងជំទាស់ ចំពោះចៅក្រម នៃអង្គជំនុំជម្រះតុលាការកំពូល ដោយមានមូលដ្ឋាននៅលើភាពលម្អៀង របស់តុលាការ ម្ចាស់បណ្តឹង ត្រូវតែមានបណ្តឹងសាទុក្ខ ដែលកំពុងរង់ចាំសេចក្តីសម្រេច នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល ដែលគេអាចនិយាយបានថា ផលប្រយោជន៍ផ្លូវច្បាប់ត្រូវបានប៉ះពាល់ ប្រសិនបើ អង្គជំនុំជម្រះពុំបានពិចារណាលើបណ្តឹងនោះ។

*រឿងក្តីអៀង ធីរិទ្ធ៖ ការប្តឹងជំទាស់ចៅក្រមសោម សិរិវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ៤។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖ វិធាន៣៤.៣។ វិធាននេះគឺស្រដៀងគ្នាទៅនឹងមាត្រា៥៥៨។**

# មាត្រា ៥៦១៖ ការពិនិត្យពាក្យប្តឹងជំទាស់ចៅក្រមអាសនៈ

*ពាក្យប្តឹងត្រូវបានពិនិត្យដោយមិនចាំបាច់ស្តាប់ភាគីឬចៅក្រមពាក់ព័ន្ធទេ*

*ប្រសិនបើ ការប្តឹងជំទាស់ត្រូវបានទទួលយកនោះត្រូវធ្វើការចាត់តាំងចៅក្រមថ្មីជំនួសចៅក្រមពាក់ព័ន្ធ*

*នៅក្នុងករណីផ្ទុយពីនេះ អ្នកប្តឹងជំទាស់អាចត្រូវទទួលពិន័យមិនលើសពី២០០.០០០ (ពីរសែន) រៀលដោយមិនទាន់គិតដល់សំណងជំងឺចិត្ត ដែលអាចត្រូវផ្តល់ឱ្យចៅក្រមដែលត្រូវគេប្តឹងជំទាស់នោះទេ*

## *ការអនុវត្តនៅអ.វ.ត.ក*

តុលាការអាចសម្រេច លើពាក្យប្តឹងជំទាស់ចំពោះចៅក្រមបាន ដោយពុំមានសវនាការជាសាធារណៈ៖ ច្បាប់អនុញ្ញាតបែបនេះ ពីព្រោះថា ផលប្រយោជន៍ នៃការបង្ហាញតម្លាភាពអាចត្រូវការពារ យ៉ាងពេញលេញ ដោយការដាក់ឯកសារពាក់ព័ន្ធទាំងនេះ ដើម្បីឲ្យសាធារណជនអាចទទួលបាន។

> *រឿងក្តីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ ការប្តឹងជំទាស់ចៅក្រមយូរ ឧត្តារ អ.វ.ត.ក អ.ជ.ស.ជ ៩ឧសភា ២០១១ កថាខណ្ឌ៩។ រឿងក្តីអៀង ធីរិទ្ធ៖ ការប្តឹងជំទាស់ចៅក្រមសោម សិរីវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ៧-៨។*

កាលណាវិធាន មិនបានចែងច្បាស់លាស់ផ្សេងពីនេះ សវនាការជាសាធារណៈ លើបណ្តឹងជំទាស់ ចៅក្រមអាសនៈ ដោយសារគ្មានភាពឯក-រាជ្យពុំត្រូវបានតម្រូវឲ្យធ្វើទេ៖ ដូច្នេះ បណ្តឹងនោះអាចត្រូវបានសម្រេច ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។

> *រឿងក្តីអៀង ធីរិទ្ធ៖ ការប្តឹងជំទាស់ចៅក្រមសោម សិរិវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ៨។ រឿងក្តីនួន ជា៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ដោយនួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីភាពត្រឹមត្រូវនៃដំណើរការស៊ើបអង្កេត របស់តុលាការ អ.វ.ត.ក អ.ជ.ត.ក ២៧ មេសា ២០១២ កថាខណ្ឌ ២៦។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៣៤ និង១០៩.១។ វិធាន៣៤នៃវិធានផ្ទៃក្នុងបានលើកឡើងពីខ្លឹមសារ និងនីតិវិធីសម្រាប់ការដកខ្លួននិងបណ្តឹងជំទាស់ ចំពោះចៅក្រមប៉ុន្តែមិនដូចជាមាត្រា៥៦១ទេគឺមិនបានចែង

ឲ្យបានច្បាស់លាស់អំពីថាតើគេតម្រូវឲ្យធ្វើសវនាការ ដោយផ្ទាល់មាត់ នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងជំទាស់ចិត្ត ទេ។ វិធាន៣៤.៧ នៃវិធានផ្ទៃក្នុងចែងថាបណ្តឹងជំទាស់ចិត្ត ចំពោះចៅក្រម ត្រូវយកមកពិចារណាដោយអង្គជំនុំជម្រះ ហើយ វិធាន៣៤.៨ ក្នុងករណីចាំបាច់គេអនុញ្ញាតឲ្យធ្វើការពិភាក្សាសម្រេច លើបណ្តឹងជំទាស់ចិត្តតាមមធ្យោបាយពីចម្ងាយ។ យ៉ាងណាក៏ដោយក៏មិនមានកន្លែងណា នៅក្នុងវិធាន៣៤នៃវិធានផ្ទៃក្នុងនិយាយអំពីថាតើម្ចាស់បណ្តឹងត្រូវមានសិទ្ធិថ្លែង ដោយផ្ទាល់មាត់នៅចំពោះមុខវត្តមានរបស់ចៅក្រមដែរឬអត់នោះឡើយ។

## ***ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត***

***គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប***

*ប្រទេសកម្ពុជាគឺជា ភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែល បញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញអំពី របៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិកាសញ្ញា ICCPR ត្រូវបានបកស្រាយ និងអនុវត្តដោយ ស្ថាប័នអនុវត្តរបស់ខ្លួនគឺគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប។*

**កាលណាទណ្ឌិតប្តឹងសាទុក្ខ ប្រឆាំងនឹងពិរុទ្ធភាព (ទោស) ដោយផ្អែកលើមូលដ្ឋាន ដែលថា ចៅក្រមមួយរូប ក្នុងចំណោមអង្គចៅក្រមទាំងអស់ ដែលគួរតែត្រូវបានប្តឹងជំទាស់ចិត្តទណ្ឌិតរូបនោះ មានសិទ្ធិចូលរួមធ្វើសវនាការជាសាធារណៈ៖** ការណ៍នេះគឺមកពី នីតិវិធីនេះអាចជួយធ្វើឲ្យអង្គតុលាការ ដែលត្រូវពិនិត្យបណ្តឹងសាទុក្ខ ធ្វើការពិនិត្យសាជាថ្មីលើគ្រប់ភស្តុតាងទាំងអស់ ដែលត្រូវបានលើកហេតុផលនៅពេលសវនាការ និងធ្វើការកំណត់ថាតើកំហុសនីតិវិធីបានប៉ះពាល់ ដល់លទ្ធផលនៃសវនាការដែរឬទេ។

*រឿងក្តី KARTTUNEN ទល់នឹងប្រទេសហ្វាំងឡង់ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ២៣ តុលា ១៩៩២ កថាខណ្ឌ៧.៣។*

មាត្រាស្រដៀងគ្នានៅក្នុង***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*** មាត្រា១៤.១។ មាត្រានេះធានាឲ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ ចំពោះចុងចោទ នៅចំពោះមុខអង្គជំនុំជម្រះមួយដែលមានភាពអនាគតិ។ យ៉ាងណាក៏ដោយ ក៏មាត្រានេះមិនបានចែងអំពីកត្តាជាក់លាក់ស្តីពីមូលដ្ឋាន ដែលភាពអនាគតិអាចត្រូវបានតវ៉ាឬអំពី ថាតើគេត្រូវតែធ្វើតាមនីតិវិធីអ្វីនោះទេ។

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេ បកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ប្រធានទីមួយ នៃតុលាការកំពូលធ្វើការសម្រេចតាមឆន្ទានុសិទ្ធិ លើចំនួនប្រាក់ពិន័យ ដែលម្ចាស់បណ្ដឹងត្រូវបង់នៅក្នុងករណី ដែលការតវ៉ាត្រូវបានបដិសេធ** ៖ ប្រាក់ពិន័យត្រូវបង់ គឺនៅចន្លោះពី៧៥€ ទៅ ៧៥០€។ យ៉ាងណាក៏ដោយការណ៍ ដែលចៅក្រមអាចធ្វើការកំណត់ អំពីចំនួនប្រាក់ពិន័យដើម្បីធានាឲ្យមានការគោរពគោលការណ៍ ស្ដីពីនីត្យានុកូលភាព និងការធ្វើបុគ្គលកម្មនៃទោស។

*លេខ 11-82861 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៩៧ តុលាការកំពូលបារាំង ៦ កក្កដា ២០១១។*

មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖ មាត្រា៦៧៣។ មាត្រានេះចែងអំពីការពិនិត្យលើពាក្យសុំប្ដឹងដិតចិត្ត។

# មាត្រា ៥៦២៖ សេចក្ដីសម្រេចលើពាក្យប្ដឹងជំទាស់ចៅក្រមអាសនៈ

*អាជ្ញាធរមានចែងនៅមាត្រា ៥៥៨ (អ្នកទទួលពាក្យប្ដឹងជំទាស់ចៅក្រមអាសនៈ) នៃក្រមនេះសម្រេចតាមដីកាមួយដែលមិនអាចប្ដឹងតវ៉ាបាន។ ដីកានេះត្រូវជូនដំណឹងដោយក្រឡាបញ្ជីដល់ចៅក្រមពាក់ព័ន្ធ និងដល់អ្នកប្ដឹងសុំជំទាស់។*

## ការអនុវត្តនៅ អ.វ.ត.ក

សេចក្ដីសម្រេចលម្អៀងពីមុន ដែលធ្វើឡើងដោយចៅក្រមច្រើនរូបមិនអាចគាំទ្រ ដល់ពាក្យប្ដឹងជំទាស់ចំពោះចៅក្រមមួយរូប ក្នុងចំណោមចៅក្រមច្រើនរូបទាំងនោះបានឡើយ៖ ការណ៍នេះ មាននៅក្នុងករណីដែលចៅក្រម ដែលត្រូវគេប្ដឹងជំទាស់គឺគ្រាន់តែ ជាសមាជិកចៅក្រមមួយរូប ក្នុងចំណោមក្រុមចៅក្រម ជាច្រើនរូបដែលបានចេញ សេចក្ដីសម្រេចលម្អៀងនោះ ហើយមតិរបស់សមាជិកជាបុគ្គល នៃក្រុមមិនត្រូវបានបង្ហាញឡើយ។

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ ការប្ដឹងជំទាស់ចៅក្រមយូរ ឧត្តរា អ.វ.ត.ក អ.ជ.ស.ជ ៩ ឧសភា ២០១១ កថាខណ្ឌ១៦។ រឿងក្ដីអៀង ធីរិទ្ធ៖ ការប្ដឹងជំទាស់ចៅក្រម សោម សិរីវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ១១-១២។*

នៅពេលធ្វើការវិនិច្ឆ័យ ទៅលើពាក្យប្ដឹងជំទាស់ចំពោះចៅក្រមអាសនៈ ចំណុចចាប់ផ្ដើមសម្រាប់ការសម្រេចណាមួយក៏ដោយ គឺជាសច្ចធារណ៍នៃភាពអនាគតិ៖ ការណ៍នេះ មានមូលដ្ឋាននៅលើសម្បថចូលកាន់តំណែង របស់ចៅក្រម និងលក្ខណៈសម្បត្តិនៅ ក្នុងការតែងតាំងរបស់គាត់។ សច្ចធារណ៍នេះ ដាក់ឲ្យមានព្រំដែនកំណត់មួយលើម្ចាស់បណ្ដឹង ដែលមានបន្ទុកត្រូវបង្ហាញផ្ទុយពីសច្ចធារណ៍នោះ។

*រឿងក្ដីអៀង ធីរិទ្ធ៖ ការប្ដឹងជំទាស់ចៅក្រម សោម សិរីវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ១០។ រឿងក្ដីនួន ជា និង អៀង សារី៖ បណ្ដឹងជំទាស់លោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ២ ធ្នូ២០១១ កថាខណ្ឌ១៤។ រឿងក្ដីនួន ជា អៀង សារី និងខៀវ សំផន៖ បណ្ដឹងជំទាស់លោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ៩ មីនា ២០១២ កថាខណ្ឌ១២។ រឿងក្ដីអៀង សារី៖ បណ្ដឹងជំទាស់ លោកស្រីចៅក្រម Silvia CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ៤ មិថុនា ២០១២ កថាខណ្ឌ១៣។*

នៅពេលធ្វើការចោទប្រកាន់ អំពីភាពលម្អៀងនៅក្នុងបណ្ដឹងជំទាស់ ចំពោះចៅក្រមភាពមិនគ្រប់គ្រាន់ក្នុងការអះអាងថា ការផ្ដល់សំអាង

**ហេតុតាមផ្លូវច្បាប់ របស់ចៅក្រមរូបនោះក្នុងសេចក្តីសម្រេចពីមុន ដែលមិនជាប់ទាក់ទងនោះ ដែលធ្វើតាមតែអំពើចិត្ត និងមិនអាចធ្វើឲ្យជឿបាន៖** ការណ៍នេះតែឯងនឹងមិនបង្ហាញ ឬត្រូវបានគេមើលឃើញ យ៉ាងសមហេតុផល ដែលបង្ហាញ អំពីសេចក្តីលម្អៀង ប្រឆាំងនឹងជនជាប់ចោទនោះឡើយ។

*រឿងក្តីអៀង ធីរិទ្ធ៖ ការប្តឹងជំទាស់ចៅក្រមសោម សិរីវឌ្ឍ អ.វ.ត.ក អ.ជ.ត.ក ៣ មិថុនា ២០១១ កថាខណ្ឌ១៣។*

**ការប្រាស្រ័យទាក់ទងតែភាគីម្ខាង មិនបង្កើតបានជាមូលដ្ឋានបឋមផ្អែកតាមអង្គហេតុ ដែលបង្កើតឲ្យមានភាពលំអៀងនោះទេ៖** កាលណាចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិករដ្ឋបាលតុលាការប្រាស្រ័យទាក់ទងគ្នា អំពីបញ្ហារដ្ឋបាល ការពិតតែគឺថាទំនាក់ទំនង ដែលបានកើតឡើងនេះ គឺមិនមែនជាមូលដ្ឋានផ្ទាល់ ដែលបង្កើតឲ្យមានភាពលំអៀងនោះទេ។

*រឿងក្តីនួន ជា អៀង សារី និងខៀវ សំផន៖ បណ្តឹងជំទាស់ លោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ២ ធ្នូ ២០១១ កថាខណ្ឌ១៦។ រឿងក្តី អៀង សារី៖ បណ្តឹងជំទាស់ លោកស្រីចៅក្រម SILVIA CARTWRIGHT អ.វ.ត.ក អ.ជ.ស.ជ ៤ មិថុនា ២០១២ កថាខណ្ឌ១៥។*

**នៅពេលធ្វើការវិនិច្ឆ័យ ទៅលើពាក្យប្តឹងជំទាស់ចំពោះចៅក្រមអាសនៈនោះ មូលដ្ឋាននីមួយៗ សម្រាប់ការប្តឹងជំទាស់នេះ ត្រូវតែពិចារណាថា ទាក់ទងទៅនឹងអង្គហេតុ បានចោទប្រកាន់៖** ហេតុផលនានា មិនពាក់ព័ន្ធត្រូវតែបានផ្តល់ឲ្យដោយអាជ្ញាធរ ដែលពិចារណាអំពីពាក្យសុំប្តឹងជំទាស់៖

*រឿងក្តីនួន ជា៖ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ក្លាមៗ ដោយនួន ជា ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីភាពត្រឹមត្រូវនៃដំណើរការស៊ើបអង្កេតរបស់តុលាការ អ.វ.ត.ក អ.ជ.ត.ក ២៧ មេសា ២០១២ កថាខណ្ឌ២៧-២៨។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៣៤។ វិធាននេះចែងអំពីខ្លឹមសារ និងនីតិវិធីស្តីពីការដកខ្លួន និងបណ្តឹងជំទាស់ ចំពោះចៅក្រមនានានៅអ.វ.ត.ក។

# មាត្រា ៥៦៣៖ កិច្ចដែលត្រូវបានបំពេញមុនពេលជូនដំណឹងអំពីពាក្យប្ដឹង

*កិច្ចដែលបានបំពេញដោយចៅក្រម ដែលត្រូវគេប្ដឹងជំទាស់ចិត្តមុនការជូនដំណឹងអំពីពាក្យប្ដឹងជំទាស់ចិត្តនោះមិនអាចត្រូវសើរើបានឡើយ។*

## ការអនុវត្តនៅអ.ច.ត.ក

សេចក្ដីសម្រេចពីមុនៗ ទាំងអស់ត្រូវចាត់ទុកថាមានសុពលភាព៖ សេចក្ដីសម្រេចណាមួយក៏ដោយដែលត្រូវបានចេញ មុនពេលមានការសម្រេចទៅលើពាក្យប្ដឹងជំទាស់ចិត្ត គឺត្រូវចាត់ទុកថា មានសុពលភាព។

*រឿងក្ដីនួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ៖ ការប្ដឹងជំទាស់ចិត្តចៅក្រមយូរ ឧត្ដម អ.វ.ត.ក អ.ជ.ស.ជ ៩ ឧសភា ២០១១ កថាខណ្ឌ៣។*

សេចក្ដីសម្រេច គឺមានសុពលភាព សូម្បីតែនៅពេលមានការផ្អាកបណ្ដឹងជំទាស់ចិត្តក៏ដោយ៖ វិធានដែលចែងថា សេចក្ដីសម្រេច ដែលបានចេញនៅមុនពេលមានការសម្រេច ទៅលើពាក្យប្ដឹងជំទាស់ចិត្តគឺត្រូវចាត់ទុកថា មានសុពលភាពនោះ អាចអនុវត្តទៅបាន សូម្បីតែកាលណាពាក្យប្ដឹងជំទាស់ចិត្តនោះ កំពុងត្រូវបានផ្អាក នៅពេលដែល គេចេញសេចក្ដីសម្រេចក៏ដោយ។

*រឿងក្ដីនួន ជា៖ ការប្ដឹងជំទាស់ចិត្តចៅក្រម ន័យ ថុល អ.វ.ត.ក អ.ប.ជ ៤ កុម្ភៈ ២០០៨ កថាខណ្ឌ៥។*

**វិធានស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុងអ.វ.ត.ក៖** វិធាន៣៤.៩។ វិធាននេះគឺខុសគ្នាពីមាត្រា៥៦៣នៅក្នុងសេចក្ដីដែលថាតាមវិធាន៣៤.៩ នៃវិធានផ្ទៃក្នុងកិច្ចដែលបានបំពេញដោយចៅក្រម ដែលត្រូវគេប្ដឹងជំទាស់ចិត្តនៅតែមានសុពលភាពឲ្យតែកិច្ចទាំងនោះមានមុនសេចក្ដីសម្រេចលើពាក្យបណ្ដឹងជំទាស់ចិត្ត ចំពោះចៅក្រមរូបនោះ។

## *ការអនុវត្តមាត្រាស្រដៀងគ្នានៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងទៀត*

***តុលាការកំពូលបារាំង***

*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានមូលដ្ឋានមកពីក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀប ដែលមាត្រាស្រដៀងគ្នា នៅក្នុងក្រមរបស់ប្រទេសបារាំងត្រូវបានគេបកស្រាយ និងអនុវត្តនៅក្នុងតុលាការជាន់ខ្ពស់ប្រទេសបារាំងពោលគឺតុលាការកំពូល។*

**ការជូនដំណឹង អំពីការតវ៉ាប្រឆាំងនឹងចៅក្រមនឹងមិនធ្វើឲ្យមានមោឃភាព ដល់កិច្ចទាំងអស់ដែលចៅក្រមរូបនោះបានបំពេញឡើយ៖** មានតែការបង្ហាញអំពីការរំលោភលើលក្ខខណ្ឌតម្រូវ ស្តីពីភាពអនាគតិប៉ុណ្ណោះដែលអាចនឹងនាំឲ្យមាន ជាលទ្ធផលដូច្នេះបាន។

*លេខ 02-82676/07-82110 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ២០ កុម្ភៈ ២០០៨។*

**មាត្រាស្រដៀងគ្នានៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង*៖** មិនមានមាត្រាណានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បារាំងដែលសមមូលទៅនឹងមាត្រា៥៦៣ទេ។ យ៉ាងណាក៏ដោយភាពស្រដៀងគ្នាអាចត្រូវបានពិចារណាក្នុងមាត្រា៦៧៤ ដែលចែងអំពីការដាក់ពាក្យសុំប្តឹងដិតចិត្តដោយរួមទាំងកិច្ច ដែលបានបំពេញនៅមុនពេលមានការជូនដំណឹង។

# តារាងរឿងក្ដី

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### *ការិយាល័យសហចៅក្រមស៊ើបសួរ*

*រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធិ ដីកាស្ដីពីការទទួលស្គាល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី (កែប) (ដីកា ស្ដីពីការទទួលស្គាល់អ្នកសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណាពីលំនៅដ្ឋានបច្ចុប្បន្ន នៅខេត្តកែប) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យសហចៅក្រមស៊ើបសួរ សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D392 ២៥ សីហា ២០១០។*

*រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធិ៖ ដីកាដំណោះស្រាយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យសហចៅក្រមស៊ើបសួរ សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D427 ១៥ សីហា ២០១០។*

*រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធិ និងឌុច៖ ដីកាដំណោះស្រាយ (ដីកាស្ដីពីការស្នើសុំក្នុងការបញ្ជាក់បំភ្លឺ ដីកាទាក់ទងនឹងការស្នើសុំការបញ្ជាក់បំភ្លឺលើបទចោទនានា) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យសហចៅក្រមស៊ើបសួរ សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D198/1 ២០ វិច្ឆិកា ២០០៩។*

*រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធិ៖ ដីកាស្ដីពីការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងភស្តុតាងដោះបន្ទុក៖ (ដីកាស្ដីពីការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ ក្នុងការស្វែងរកភស្តុតាងដោះបន្ទុកក្នុង SMD) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យសហចៅក្រមស៊ើបសួរ សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D164/2 ១៩ មិថុនា ២០០៩។*

## ***អង្គបុរេជំនុំជម្រះ***

***រឿងក្តី ឌុចៈ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*** *(សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់កាំងហ្គេច អ៊ាវហៅ "ឌុច") អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេ ជំនុំជម្រះ (អ.ប.ជ ០២) សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D99/3/42 ៥ ធ្នូ ២០០៨។*

***រឿងក្តី ឌុចៈ សំណើរបស់អៀងសារីសុំដាក់សារណា ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម*** *(សាធារណៈ - សេចក្តីសម្រេចលើសំណើរបស់លោកអៀង សារីសុំដាក់អំណះអំណាង ស្តីពីការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿង ទៅជំនុំជម្រះលើករណីរបស់កាំងហ្គេក អ៊ាវហៅ "ឌុច") អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ, ០២) សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D99/3/19 ៦ តុលា ២០០៨។*

***រឿងក្តី ឌុចៈ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន*** *(សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទកាំងហ្គេកអ៊ាវហៅ "ឌុច") អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០១) សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/-ក.ស.ច.ស ឯកសារលេខ C5/45 ៣ ធ្នូ ២០០៧។*

***រឿងក្តី ឌុចៈ សំណើសុំឆ្លើយតបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*** *(សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសារណារបស់អ្នក ដែលមិនមែនជាភាគីនៃរឿងក្តី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០១) សំណុំរឿងលេខ០០២/១៤-០៨-២០០៦-អ.វ.ត.ក អ.ប.ជ ឯកសារលេខ C10 ២៦ តុលា ២០០៧។*

***រឿងក្តី អៀង សារី និងឌុចៈ ញត្តិស្នើសុំដកអ្នកដែលមិនមែនជាភាគីនៃរឿងក្តី*** *(សាធារណៈ - សេចក្តីសម្រេចលើពាក្យសុំរបស់លោកអៀង សារីសុំដកអ្នក ដែលមិនមែនជាភាគីនៃរឿងក្តី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០២) សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D99/3/23, ១៤ តុលា ២០០៨។*

***រឿងក្តី អៀង សារីៈ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យតែងតាំងអ្នកជំនាញ ផ្នែកប្រជាសាស្ត្របន្ថែម*** *(សាធារណៈ - [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារីប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើ របស់ខ្លួនសុំការតែងតាំងអ្នកជំនាញ ផ្នែកប្រជាសាស្ត្របន្ថែម*

*ដើម្បីពិនិត្យឡើងវិញនូវខ្លឹមសារ នៃរបាយការណ៍អ្នកជំនាញដាក់ជូន ដោយលោកស្រីEWA TABEAU និងលោកធីឃាម) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៥៥) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D140/9/5 ២៨ មិថុនា ២០១០។*

***រឿងក្តី អៀង សារីៈ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យតែងតាំងអ្នកជំនាញបន្ថែម*** *(សាធារណៈ - [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទអៀង សារីប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំឲ្យតែងតាំងអ្នកជំនាញបន្ថែម) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ២៨) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D140/4/5 ១២ ធ្នូ ២០០៩។*

***រឿងក្តី អៀង សារីៈ ការទទួលយកបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងភស្តុតាង ដែលទទួលបានតាមរយៈអំពើទារុណកម្ម*** *(សាធារណៈ - សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោកអៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្ទតរបស់ក.ស.ច.ស លើសំណើរបស់លោកអៀង សារីទាក់ទងនឹងការទទួលស្គាល់របស់ក.ស.ច.សនូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈអំពើទារុណកម្ម) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៣១) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D130/7/3/5 ១០ ឧសភា ២០១០។*

***រឿងក្តី អៀង សារីៈ បណ្តឹងឧទ្ធរណ៍លើសំណើសុំតារាងវិភាគភស្តុតាង*** *(សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារីប្រឆាំងនឹងដីកាបដិសេធរបស់ក.ស.ច.ស ទៅនឹងសំណើលើកទីបីសុំឲ្យផ្តល់ជូនមេធាវីការពារក្តីនូវតារាងវិភាគពីភស្តុតាង ជាមួយនឹងដីកាដំណោះស្រាយ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៦៥) សំណុំរឿងលេខ០០២/ ១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ A372/2/7៨ មិថុនា ២០១០។*

***រឿងក្តី អៀង សារីៈ ការទទួលយកសេចក្តីសង្ខេតរបស់ដើមបណ្តឹងរដ្ឋប្បវេណី*** *(សេចក្តីសម្រេចទទួលយកសេចក្តីសង្កេតជាទូទៅ របស់ដើមបណ្តឹងរដ្ឋប្បវេណី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៣) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ ក.ស.ច.ស ឯកសារលេខ C22/I/41 ២៤ មិថុនា ២០០៨។*

***រឿងក្តី អៀង សារីៈ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំលើកអំណះអំណាងនៅចំពោះមុខតុលាការ*** *(សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលបានសម្រេចផ្ទាល់មាត់នៅថ្ងៃទី០១ កក្កដា ២០០៨ អំពីសំណើសុំលើកអំណះអំណាង នៅចំពោះមុខតុលាការដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី)*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៣) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C22/I/54 ០៣ កក្កដា ២០០៨។*

***រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នក្នុងដីកាដំណោះស្រាយ*** *(សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារីប្រឆាំងនឹងការសម្រេចបន្តថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នក្នុងដីកាដំណោះស្រាយ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១៥២) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D427/5/10 ២១ មករា ២០១១។*

***រឿងក្តី អៀងសារី៖ បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ*** *(សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារីប្រឆាំងនឹងដីកាដំណោះស្រាយ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៧៥) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D427/1/30 ១១ មេសា ២០១១។*

***រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យស្វែងរកភស្តុតាងដោះបន្ទុក*** *(សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំឲ្យស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ២៥) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D164/3/6 ១២ វិច្ឆិកា ២០០៩។*

***រឿងក្តី អៀងសារី៖ ការពន្យារពេលដើម្បីជំទាស់នឹងយុត្តាធិការ*** *(សាធារណៈ - សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់សហមេធាវីការពារក្តីសុំពន្យារពេលសមស្រប ដើម្បីដាក់សេចក្តីជំទាស់ទៅនឹងបញ្ហាយុត្តាធិការ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៣) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C22/I/13 ៣ មីនា ២០០៨។*

***រឿងក្តី អៀង សារី៖ ព័ត៌មានអំពីលោកDAVID BOYLE*** *(សាធារណៈ - សាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍របស់លោកអៀង សារី ប្រឆាំងនឹងលិខិតដែលពាក់ព័ន្ធនឹងសំណើរសុំព័ត៌មានអំពីមន្ត្រីច្បាប់លោក DAVID BOYLE) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៨) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ A162/III/6 ២៨ សីហា ២០០៨។*

***រឿងក្តី អៀង សារី៖ សំណើសុំពន្យារពេលសវនាការលើបញ្ហាយុត្តាធិការ*** *(សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលបានសម្រេចផ្ទាល់មាត់នៅថ្ងៃទី៣០ មិថុនា ២០០៨ អំពីសំណើសុំពន្យារ ពេលសវនាការ*

*លើបញ្ហាយុត្តាធិការរបស់សហមេធាវីការពារក្ដី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៣) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ ក.ស.ច.ស ឯកសារលេខ C22/I/49 ០២ កក្កដា ២០០៨ ។*

***រឿងក្ដី អៀង សារី៖ បណ្ដឹងឧទ្ធរណ៍លើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់ទួន ជា*** *(សាធារណៈ - សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបសួរលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់ទួន ជា) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ២០) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D158/5/3/15 ២៥ សីហា ២០០៩។*

***រឿងក្ដី អៀង សារី៖ បណ្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្ទំស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន*** *(សេចក្ដីសម្រេចលើបញ្ហាបន្ទាន់បន្ទំ ដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើង នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់អៀង សារីចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៣) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C22/I/46 ១ កក្កដា ២០០៨។*

***រឿងក្ដី អៀង សារី៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន*** *(សាធារណៈ - សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទអៀង សារី បណ្ដោះអាសន្ន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអង្គបុរេជំនុំជម្រះ (អ.ប.ជ ០៣) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C22/I/74 ១៧ តុលា ២០០៨។*

***រឿងក្ដី អៀង សារី៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្ដថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន*** *(សាធារណៈ -[កោសលុប] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោកអៀង សារីប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបសួរអំពីការបន្ដថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១៧) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/-ក.ស.ច.ស ឯកសារលេខ C22/5/39 ២៦ មិថុនា ២០០៩។*

***រឿងក្ដី អៀង សារី៖ បណ្ដឹងឧទ្ធរណ៍អំពីអ្នកជំនាញផ្នែកចិត្តសាស្ត្រ*** *(សាធារណៈ - សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោកអៀង សារីទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១០) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ A189/I/8 ២១ តុលា ២០០៨។*

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារពេលឃុំខ្លួនបណ្តោះអាសន្នលើកទីពីរ* (*សាធារណៈ - [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារីប្រឆាំងនឹងដីកាសម្រេចលើកាបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំ-ជម្រះ (អ.ប.ជ ៣២) សំណុំរឿងក្តីលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C22/9/14 ៣០ មេសា ២០១០។*

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីបី* (*សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារីប្រឆាំងនឹងការបដិសេធតាមការសន្មត របស់សហចៅក្រមស៊ើបសួរទៅលើសំណើសុំលើកទីបីរបស់អៀងសារីសុំឱ្យបំពេញកិច្ចស៊ើបសួរ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ២៩) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/-ក. ស.ច.ស ឯកសារលេខ D171/4/5 ២២ ធ្នូ ២០០៩។*

*រឿងក្តី អៀង សារី៖ បណ្តឹងឧទ្ធរណ៍លើសិទ្ធិទាក់ទងនឹងការបកប្រែ* (*សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោកអៀង សារីប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១២) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ A190/II/9 ២០ កុម្ភៈ ២០០៩។*

*រឿងក្តី អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសហកម្មឧក្រិដ្ឋកម្មរួម* (*សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបសួរ ចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៣៥ ) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខD97/14/15 ២០ ឧសភា ២០១០។*

*រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍លើចម្លើយ ដែលអាចបានមកដោយសារអំពើទារុណកម្ម* (*សាធារណៈ - សាលដីកាលើភាពអាចទទួលយកបាន នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបសួរបដិសេធសំណើសុំលើកទីបីរបស់ អៀង សារី សុំឲ្យបំពេញកិច្ចស៊ើបសួរ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ២៦) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D130/9/21 ១៨ ធ្នូ ២០០៩។*

*រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរអំពីទ្រព្យសម្បត្តិរបស់ជនត្រូវចោទ* (*សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី*

*ប្រឆាំងនឹងដីកាសម្រេចលើសំណើ របស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំឲ្យបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៥៧) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D193/5/5 ៤ សីហា ២០១០។*

***រឿងក្ដី អៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍លើសំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ*** *(សាធារណៈ - សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបសួរ សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៤១) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D263/2/6 ២៥ មិថុនា ២០១០។*

***រឿងក្ដី អៀង ធីរិទ្ធ៖ សេចក្ដីជូនដំណឹងអំពីកំហុសនៅក្នុងការបកប្រែ*** *(សាធារណៈ - សេចក្ដីសម្រេចលើសេចក្ដីជូនដំណឹងរបស់មេធាវីការពារក្ដីអំពីកំហុសនៅក្នុងការបកប្រែ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១៤) សំណុំរឿងលេខ០០២/២០-១០-២០១០-អ.វ.ត.ក អ.ប.ជ ១៧ ធ្នូ ២០១០។*

***រឿងក្ដី អៀង ធីរិទ្ធ៖ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់នួនជា*** *(សាធារណៈ - សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបសួរលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់នួនជា) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១៩) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ ក.ស.ច.ស ឯកសារលេខ D158/5/4/14 ២៥ សីហា ២០០៩។*

***រឿងក្ដី អៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារពេលសវនាការស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន*** *(សាធារណៈ - សេចក្ដីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ ( អ.ប.ជ ០២) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C20/I/13 ១ មេសា ២០០៨។*

***រឿងក្ដី អៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន*** *(សាធារណៈ - សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទអៀងធីរិទ្ធ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០២) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C20/I/27 ៩ កក្កដា ២០០៨។*

***រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារពេលឃុំខ្លួនបណ្តោះអាសន្នលើកទីពីរ*** *(សាធារណៈ - [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៣៣) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C20/9/15 ៣០ មេសា ២០១០។*

***រឿងក្តី អៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍លើការផ្អាកកិច្ចដំណើរការនីតិវិធី*** *(សាធារណៈ - សាលដីកាលើបណ្តឹងបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៤២) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D264/2/6 ១០សីហា ២០១០។*

***រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យធ្វើមោឃភាព*** *(សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ខៀវ សំផនប្រឆាំងនឹងដីកាសម្រេចលើសំណើសុំឲ្យធ្វើមោឃភាព ដោយមូលហេតុរំលោភនីតិវិធី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៣០) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D197/5/8 ៤ ឧសភា ២០១០។*

***រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍លើចម្លើយ ដែលអាចបានមកដោយសារអំពើទារុណកម្ម*** *(សាធារណៈ សាលដីកាលើភាពអាចទទួលយកបាន នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា របស់សហចៅក្រមស៊ើបសួរសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារអំពើទារុណកម្ម) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ២៧) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D130/10/12 ២៧ មករា ២០១០។*

***រឿងក្តី ខៀវ សំផន៖ សំណើសុំឯកសារគាំទ្រដីកាដំណោះស្រាយ*** *(សាធារណៈ - សេចក្តីសម្រេចលើសំណើសុំឲ្យបកប្រែគ្រប់ឯកសារទាំងអស់ប ដែលបានប្រើប្រាស់ ដើម្បីគាំទ្រដីកាដំណោះស្រាយ) អង្គ-ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១៦) សំណុំរឿងលេខ០០២/១៨-១១-២០១០-អ.វ.ត.ក ឯកសារលេខ២ អ.ប.ជ ១៥ ធ្នូ ២០១០។*

***រឿងក្តី ខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍លើការទទួលយកកស្តុតាងដោះបន្ទុក*** *(សាធារណៈ - សេចក្តីសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍ ដែលដាក់ដោយខៀវ សំផន និងសេចក្តីបង្គាប់ដល់សហព្រះរាជ-*

*អាជ្ញា) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ២៤) សំណុំរឿងលេខ ០០២/១០-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D164/4/7 ២២ កញ្ញា ២០០៩។*

***រឿងក្ដី ខៀវ សំផន៖ ការពន្យារពេលលើបណ្ដឹងឧទ្ធរណ៍អំពីដីកាឃុំខ្លួនបណ្ដោះអាសន្ន*** *(សេចក្ដីសម្រេចលើសំណើសុំពន្យារពេលសវនាការ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៤) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C26/I/25 ២៣ មេសា ២០០៨។*

***រឿងក្ដី ខៀវ សំផន៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន និងការបដិសេធសំណើ*** *(សាធារណៈ - [កោសលុប] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទខៀវសំផនប្រឆាំងនឹងដីកាបដិសេធ លើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន) អង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១៤ និង១៥) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C26/5/26 ៣ កក្កដា ២០០៩។*

***រឿងក្ដី ខៀវ សំផន៖ សំណើសុំឲ្យបើកសវនាការសាធារណៈ*** *(សាធារណៈ - ដីកាសម្រេចស្ដីពីការស្នើសុំឲ្យបើកសវនាការសាធារណៈរបស់មេធាវី ចំពោះបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងស្ដីពីការស្នើសុំរបស់សហព្រះរាជអាជ្ញា ដែលសុំឱ្យមានការលុបចេញកថាខណ្ឌមួយចំនួនដែលមាននៅក្នុងបណ្ដឹងឧទ្ធរណ៍ របស់មេធាវីការពារក្ដី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៤) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C26/I/13 ៣ មីនា ២០០៨។*

***រឿងក្ដី ខៀវ សំផន៖ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នលើកទីពីរ*** *(សាធារណៈ - [កោសលុប] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ខៀវ សំផនប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៣៦) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ ក.ស.ច.ស ឯកសារលេខ C26/9/12 ៣០ មេសា ២០១០។*

***រឿងក្ដី ខៀវ សំផន៖ ការដកបណ្ដឹងឧទ្ធរណ៍*** *(សាធារណៈ - សេចក្ដីសម្រេចពាក់ព័ន្ធនឹងសេចក្ដីជូនដំណឹងអំពីការដកបណ្ដឹងឧទ្ធរណ៍) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៤) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C26/I/31 ១៥ តុលា ២០០៨។*

*រឿងក្តី នួន ជា និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយនួន ជា និងអៀង ធីរិទ្ធប្រឆាំងនឹងដីកាដំណោះស្រាយ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១៤៥ និង១៤៦) សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D427/2/15 ១៥ កុម្ភៈ ២០១១។*

*រឿងក្តី នួន ជា និងអៀង សារី៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីកោះហៅសាក្សី (សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយនួន ជា និងអៀង សារី លើសំណើរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីកោះហៅសាក្សី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៣៨) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D314/2/7 ១៥ មិថុនា ២០១០។*

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យតែងតាំងអ្នកជំនាញផ្នែកប្រជាសាស្ត្របន្ថែម (សាធារណៈ - [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោកនួន ជាប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបសួរសម្រេចបដិសេធលើសំណើសុំយោបល់ពីអ្នកជំនាញជាលើកទីពីរ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៦៦) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D365/2/9 ១ កក្កដា ២០១០។*

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍លើដីកាបដិសេធពាក្យសុំមោឃភាព (សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោកនួនជាប្រឆាំង ចំពោះដីកាបដិសេធពាក្យសុំមោឃភាព) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៦) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D55/I/8 ២៦ សីហា ២០០៨។*

*រឿងក្តី នួន ជា៖ ការចូលរួមសវនាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរឿងឃុំខ្លួនបណ្តោះអាសន្ន (សាលដីកាអំពីការចូលរួម របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០១) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C11/53 ២០ មីនា ២០០៨។*

*រឿងក្តី នួន ជា៖ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យធ្វើការពិចារណាឡើងវិញ (សាធារណៈ - សេចក្តីសម្រេចលើសំណើរួម របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញ) អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ០៦) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D55/I/13 ២៥ កុម្ភៈ ២០០៩។*

*រឿងក្តី នួនជា៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីដប់មួយ* (*សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបសួរលើសំណើលើកទីដប់មួយរបស់ជនត្រូវចោទសុំឲ្យបំពេញកិច្ចស៊ើបសួរ*) *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ* (*អ.ប.ជ ២១*) *សំណុំរឿងលេខ០០២/១៩ -០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D158/5/1/15 ១៨ សីហា ២០០៩។*

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍លើការចាត់តាំងអ្នកជំនាញ* (*សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោកនួន ជា ចំពោះការចាត់តាំងអ្នកជំនាញ*) *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ* (*អ.ប.ជ ០៧*) *សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D54/V/6 ២២ តុលា ២០០៨។*

*រឿងក្តី នួន ជា៖ បណ្តឹងជិតចិត្តចំពោះចៅក្រមន័យថុល* (*សាធារណៈសេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទនួន ជា ចំពោះលោកចៅក្រមន័យ ថុល ក្នុងពេលរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន*) *អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ* (*អ.ប.ជ ០១*) *សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ C11/29 ៤ កុម្ភៈ ២០០៨។*

*រឿងក្តី នួន ជា៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន* (*សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន បណ្តោះអាសន្នជនត្រូវចោទនួនជា*) *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ* (*អ.ប.ជ ០១*) *សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/-ក.ស.ច.ស ឯកសារលេខ* C11/54 *២០ មីនា២០០៨។*

*រឿងក្តី នួន ជា អៀង សារី និងខៀវ សំផន៖ បណ្តឹងឧទ្ធរណ៍លើភស្តុតាងបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្ម* (*សាធារណៈ - សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបសួរ ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង*) *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ* (*អ.ប.ជ ៦៧*) *សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D365/2/17 ២៧កញ្ញា២០១០។*

*រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំដាក់ឯកសារភស្តុតាងបន្ថែម* (*សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹង*

*ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីការសុំដាក់ឯកសារភស្ដុតាងបន្ថែម ទៅក្នុងសំណុំរឿង ដែលគាំទ្រការបញ្ជាក់ពីការដឹងឮ របស់ជនត្រូវចោទអំពីឧក្រិដ្ឋកម្ម) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៦៧) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D365/2/10 ១៥ មិថុនា ២០១០។*

***រឿង ក្ដីនួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ ការពិចារណាឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*** *(សាធារណៈ - សាលដីកាសម្រេចអំពីការពិចារណាសារជាថ្មីឡើងវិញ អំពីការទទួលយកពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៤៧ និង៥៣) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D364/1/6 ១ កក្កដា ២០១១។*

***រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*** *(សាធារណៈ - [កោសលុប] សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបសួរលេខ D250/3/3 ១៣ មករា ២០១០ និងដីកាសម្រេចលេខ D250/3/2 ១៣ មករា ២០១០ លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៤៧ និង៤៨) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ ក.ស.ច.ស ឯកសារលេខ D411/3/6 ២៤ មិថុនា ២០១១។*

***រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*** *(សាធារណៈ - សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបសួរលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៧៦ ១១២ ១១៣ ១១៤ ១១៥ ១៤២ ១៥៧ ១៦៤ ១៦៥ ១៧២) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D411/3/6 ២៤ មិថុនា ២០១១។*

***រឿងក្ដី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្ដឹងឧទ្ធរណ៍លើសំណើស្ដីពីការរក្សាការសម្ងាត់សមភាព និងភាពយុត្តិធម៌*** *(សាធារណៈ - សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបសួរទៅនឹងសំណើស្ដីពីការរក្សាការសម្ងាត់សមភាព និងភាពយុត្តិធម៌) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ១៤៧) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ A410 /2/6 ២៩ មិថុនា ២០១១។*

***រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ សំណើសុំបង្ហាញឯកសារ អ.ប.ជ-០៨ទាំងអស់*** (សាធារណៈ - [កោសលុប] សេចក្តីសម្រេចលើសំណើរបស់អៀង សារីសុំឲ្យបង្ហាញឯកសារ អ.ប.ជ-០៨ ទាំងអស់ដល់ផ្នែកគាំពារការការពារក្តី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ-០៨) សំណុំរឿងលេខ០០២/១៤-១២-២០០៩-អ.វ.ត.ក អ.ប.ជ ឯកសារលេខ 31 ១៩ កក្កដា ២០១១។

***រឿងក្តី នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និងឌុចៈ បណ្តឹងឧទ្ធរណ៍លើសំណើសុំសម្ភាសន៍បុគ្គលដែលបាត់ខ្លួនដោយបង្ខំ និងរៀបការដោយបង្ខំ*** (សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំសម្ភាសន៍បុគ្គល ដូចរាយនាមនៅក្នុងសំណើសុំឲ្យ បំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបការដោយបង្ខំ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ៥២) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D310/1/3 ២១ កក្កដា ២០១០។

***រឿងក្តី នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ៖ បណ្តឹងឧទ្ធរណ៍លើសំណើសុំឲ្យស្វែងរកភស្តុតាងដោះបន្ទុក*** (សាធារណៈ - សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំឲ្យស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ (អ.ប.ជ ២៤ សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D164/4/13 ១៨ វិច្ឆិកា ២០០៩។

## *អង្គជំនុំជម្រះសាលាដំបូង (សេចក្តីសម្រេច)*

***រឿងក្តី ឌុចៈ ភាពអាចទទួលយកបាននៃភស្តុតាងបន្ថែម*** (សេចក្តីសម្រេចលើសំណើរបស់គាគីនានាសុំដាក់សម្ភារៈមួយចំនួន នៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធានផ្ទៃក្នុង៨៧(២)) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ឯកសារលេខ E176 ២៨ តុលា ២០០៩។

***រឿងក្តី ឌុចៈ ភាពអាចទទួលយកភស្តុតាង*** (សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈ ដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ឯកសារលេខ E43/4 ២៦ ឧសភា ២០០៩។

***រឿងក្តី ឌុចៈ សំណើសុំពន្យារពេលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី** (សេចក្តីសម្រេចលើសំណើសុំពន្យារពេលក្នុងការដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ឯកសារលេខ E2/92/2 ១០ មីនា ២០០៩។*

***រឿងក្តី ឌុចៈ ការធ្វើសេចក្តីសន្និដ្ឋានលើការផ្តន្ទាទោស របស់ដើមបណ្តឹងរដ្ឋប្បវេណី** (សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹង រដ្ឋប្បវេណីសុំឲ្យចេញសេចក្តីសម្រេច អំពីសិទ្ធិរបស់សហមេធាវីតំណាងដើម បណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទអ្នកជំនាញ និងសាក្សី ដែលបានកោះហៅឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ឯកសារលេខ E72/3 ៩ តុលា ២០០៩។*

***រឿងក្តី ឌុចៈ ដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលមរណភាព** (សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ឯកសារលេខ E2/5/3 ១៣ មីនា ២០០៩។*

***រឿងក្តី ឌុចៈ សាលក្រម** (សាលក្រម) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ឯកសារលេខ E188 ២៦ កក្កដា ២០១០។*

***រឿងក្តី ឌុចៈ សំណើសុំឲ្យដោះលែង** (សេចក្តីសម្រេចលើសំណើសុំឲ្យដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ឯកសារលេខ E39/5 ១៥ មិថុនា ២០០៩។*

